# សមន្តប្បាសាទិកា

## អដ្ឋកថា វិនយបិដក

## ចុល្លវគ្គ

## ភាគ ៩-១០-១១

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

### ចុល្លវគ្គ

## ភាគ ៩-១០-១១

ឈ្មោះសៀវភៅ សមន្តបាសាទិកា អដ្ឋកថាបិដក ចុល្លវគ្គ

# ភាគ ៩_១០_១១

ប្រែដោយ ភិក្ខុ អគ្គធីរោ គង់ សុមិត្ត

ផ្ទៀងផ្ទាត់ដោយ ភិក្ខុ_សាមណេរវត្តនិគ្រោធវ័ន

| | |
|---|---|
| ភិក្ខុ គូ សុភាព | ភិក្ខុ តុន ប៊ុនសាយ |
| ភិក្ខុ ភួង សុវណ្ណ | ភិក្ខុ សឹម ស៊ីសាមុត |
| ភិក្ខុ ឈឹម ហ៊ាន | សាមណេរ នៅ ហៃឡុន |
| ភិក្ខុ ឈូក សុមន | សាមណេរ សឿន សាន |

កាលបរិច្ឆេទ ព.ស. ២៥៥៣

ស្ថានទីធ្វើ ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន

"គល់ទទឹង" ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល

ISBN 9789996306020



ភិក្ខុ អគ្គធីរោ គង់_សុមិត្ត

# ជីវប្រវត្តិសង្ខេប

ភិក្ខុ គង់-សុមិត្ត អាយុ៣៩ឆ្នាំ គង់នៅវត្តនិគ្រោធវ័នគល់ទទឹង ។

ញោមប្រុសឈ្មោះ គង់-តិក( ស្លាប់ ) ញោមស្រីឈ្មោះ ហុក-តាង

កើតថ្ងៃព្រហស្បតិ៍៩កើត ខែមិគសិរ ឆ្នាំថោះ ព.ស.២៥១៩ ។ មានបងប្អូន ៧ នាក់ គឺប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ ។ ក្នុងកុមារបានចូលរៀនសាលារដ្ឋ ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡុយលឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងផា ខេត្តបាត់ដំបង ។ ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទា ជាភិក្ខុភាវៈ ។

ព.ស. ២៥៤០ មកគង់នៅវត្តនិគ្រោធវ័ន រៀនធម៌វិន័យ ។ ព.ស. ២៥៤១ ចេញទៅគង់នៅវត្តខេមវ័ន( ខេត្តកំពង់ចាម ) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌វិន័យ ។

ព.ស. ២៥៤៦ បួសជាសាមណេរវិញ ឧបជ្ឈាយ៍ព្រះនាម យឹទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុក គៀនស្វាយ ខេត្តកណ្តាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។

ព.ស. ២៥៤៧ បំពេញជាភិក្ខុភាវៈ បានជួយបង្រៀននិងខិតខំរៀបចំអដ្ឋកថា និងសៀវភៅធម៌វិន័យជាច្រើនទៀត រហូតមក ។

# ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ

ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ជិតក្រុងវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមានប្រមាណច្រើនចំនួន ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍បានចូលទៅលើកពាក្យចោទប្រកាន់ ចំពោះព្រះដ៏មានព្រះភាគ មានពាក្យជាដើមថា “ព្រះគោតមមិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមក ក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះ ឱ្យអង្គុយលើអាសនៈ( ក៏ព្រះអង្គមិនធ្វើ )” ព្រះដ៏មានព្រះភាគទ្រង់ញ៉ាំងព្រាហ្មណ៍នោះ ឱ្យជ្រះថ្លាហើយ និងប្រកាសខ្លួនជាឧបាសក ដល់ព្រះត្រ័យសរណគមន៍ស្មើដោយជីវិត រួចក៏អារាធនាឱ្យទ្រង់ចាំវស្សាជិតស្រុកវេរញ្ជានោះមួយអន្លើដោយភិក្ខុសង្ឃ ។

ក្នុងវស្សានោះ ស្រុកវេរញ្ជាកើតអំណត់អត់បាយ ព្រះដ៏មានព្រះភាគ និងព្រះភិក្ខុសង្ឃឆាន់បាយក្រៀមរបស់ពួកឈ្មួញសេះ ។ ព្រះមហាមោគ្គល្លានទូលសូមសម្តេចឫទ្ធិប្រែត្រឡប់ផែនដី ដើម្បី បានឱជារសដែលកើតឡើងអំពីស្រទាប់នៃផែនដី និងទូលសូមនាំភិក្ខុទៅបិណ្ឌបាត

ឯឧត្តរកុរុទ្វីប, តែព្រះដ៏មានព្រះភាគទ្រង់មិនអនុញ្ញាត ។ ចំណែកព្រះសារីបុត្រ ក៏ក្រាបទូលសួរអំពីសាសនារបស់ព្រះពុទ្ធទាំងឡាយ ដែលឋិតនៅមិនបានយូរ និងដែលឋិតនៅបានយូរ, ព្រះដ៏មានព្រះភាគក៏ទ្រង់សម្ដែងសាសនារបស់ព្រះពុទ្ធទាំង ៦ ព្រះអង្គមានព្រះពុទ្ធព្រះនាមវិបស្សីជាដើម ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ក្រោកចាកអាសនៈហើយ ធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា "សូមទ្រង់ព្រះមេត្តាប្រោស កាលនេះជាកាលគួរហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ៗ គួរបញ្ញត្តិសិក្ខាបទ គួរសម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ព្រោះកិច្ចដូច្នេះហើយ ជាហេតុនឹងឱ្យព្រហ្មចរិយធម៌ឋិតនៅអស់កាលអង្វែងទៅ" ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា "ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន តថាគតឯងសឹងដឹងកាលគួរក្នុងកិច្ចដែលនឹងបញ្ញត្តសិក្ខាបទជាដើមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ មិនទាន់ប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមណា ព្រះសាស្ដាក៏មិនទាន់បញ្ញត្តសិក្ខាបទ មិនទាន់សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយត្រឹមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទី

តាំងនៃអាសវៈ មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលណា ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយក្នុងកាលនោះ ដើម្បីនឹងការពារកាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងនោះប៉ុណ្ណោះ ម្នាលសារីបុត្ត សង្ឃនៅមិនទាន់មានភិក្ខុបួសចាស់វស្សាច្រើនគ្នាត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមនោះ ម្នាលសារីបុត្តម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្តីចម្រើនមានភិក្ខុបួសចាស់វស្សាច្រើនគ្នា ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នឹងមានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារកាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់បាននូវសេចក្តីចម្រើនមានគ្នាច្រើនត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះ ត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្តីចម្រើនមានគ្នាច្រើន ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារកាំងនូវធម៌ទាំងឡាយ

ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់ដល់នូវសេចក្តីចម្រើនដោយលាភសក្ការៈដ៏ប្រសើរត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នៅមិនទាន់មានប្រាកដចំពោះសង្ឃត្រឹមនោះ ម្នាលសារីបុត្ត លុះសង្ឃបានដល់នូវសេចក្តីចម្រើនដោយលាភសក្ការៈដ៏ប្រសើរក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងកាលនោះដែរ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារពាំងនូវធម៌ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត ពីព្រោះ( ឥឡូវ )ភិក្ខុសង្ឃនៅមិនទាន់មានពុត( ហ៊ានលបលួចធ្វើអាក្រក់ )នៅឡើយ មិនទាន់មានទោសមោះមៃនៅឡើយ កំពុងនៅមានធម៌បរិសុទ្ធ ឥតទាន់មានពណ៌ខ្មៅសៅហ្មង សុទ្ធសឹងតែផូរផង់ផូង់ចិត្តឋិតនៅក្នុងធម៌មានខ្លឹមនៅឡើយ ម្នាលសារីបុត្ត ក៏បណ្តាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុដែលមានមគ្គផលយ៉ាងទាបចុងគេបំផុតនោះ ក៏គង់បានសម្រេចត្រឹមថ្នាក់សោតៈ ជាបុគ្គលទៀងទាត់ លែងធ្លាក់ទៅក្នុងអបាយភូមិហើយ នឹងបានត្រាស់ដឹងមគ្គផលត ៗទៅទៀតជាប្រាកដ” ។

ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ ចប់

# ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ

## ឃោសកុមារកើតឡើង និងការសិក្សាត្រៃវេទ

រាប់អំពីកាលនៃការបរិនិព្វានរបស់ព្រះមានព្រះភាគ កន្លងទៅហើយបាន ៩៥៦ ព្រះវស្សា ។ ព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមថា មហានាម បានគ្រងរាជ្យសម្បត្តិ ប្រកបដោយទសពិធរាជធម៌ក្នុងលង្កាទ្វីប ។ បានឮថា ក្នុងសម័យនោះឯង មានព្រាហ្មណ៍ មាណពម្នាក់ កើតនៅក្នុងត្រកូលព្រាហ្មណ៍មួយ បិតាឈ្មោះ **កេសី** ជារាជបុរោហិត មាតាឈ្មោះ **កេសិនី** មានលំនៅស្ថិតនៅក្នុងទីជិតនៃពោធិមណ្ឌល (កន្លែងត្រាស់ដឹងរបស់ព្រះសម្ពុទ្ធ) ក្នុងមជ្ឈិមប្រទេសជម្ពូទ្វីប ។

ក៏ព្រោះក្នុងវេលាដែលមាណពនោះប្រសូតមក ពួកបរិវាររបស់ព្រាហ្មណ៍ មានទាសនិងកម្មករជាដើម បញ្ចេញសំឡេង សម្ដែងភាពត្រេកអររីករាយយ៉ាងគឹកកង ដូច្នោះ ទើបគេដាក់ឈ្មោះឱ្យកុមារនោះថា **ឃោសៈ** ។ ទីខ្លះក៏ពោលថា មាណពនោះ កើតនៅក្នុងឃោសគ្រាម ទើបដាក់ឈ្មោះឱ្យថា ឃោសៈ ។ ឃោសៈមាណពនោះ ជាអ្នកដឹងវិជ្ជានិងក្បួនសិល្បៈទាំងពួងយ៉ាងជំនាញ ចេះចប់ត្រៃវេទយ៉ាងប្រាកដក្នុងលទ្ធិ បានត្រាច់ទៅដើម្បីសាកសួរ និងដោះស្រាយបញ្ហាវិជ្ជាសិល្បៈ ក្នុងស្រុកនិគមជនបទ រាជធានីទាំងឡាយ ក្នុងជម្ពូទ្វីប ។

ដឹងថា មានសមណព្រាហ្មណ៍ ដែលជាបណ្ឌិតនៅក្នុងទីណា ៗ ក៏ចូលទៅធ្វើការសាកច្បាក្នុងទីនោះ ៗ បណ្ឌិតដទៃ (នោះ) ៗ មិនអាចឆ្លើយនូវបញ្ហាដែលមាណពនោះ សួរបានឡើយ តែមាណពនោះ អាចឆ្លើយនូវបញ្ហារបស់បណ្ឌិតទាំងនោះ ៗ ដែលសួរហើយបាន ។

## ឃោសមាណពជួបនឹងព្រះរេវតត្ថេរ

មាណពនោះ ត្រាច់ទៅពេញ ទូទាំងជម្ពូទ្វីបដោយអាការយ៉ាងនេះ រហូតមកដល់វត្តមួយ (ក៏បានស្នាក់នៅក្នុងបរិវេណវត្តនោះ) ។ ក៏ក្នុងវត្តនោះមានភិក្ខុនៅច្រើនរូប ព្រះរេវតៈ(ឬធម្មឃោសៈ) ជាសង្ឃត្ថេររបស់ភិក្ខុទាំងនោះ ជាព្រះមហាខីណាស្រពបានសម្រេចបដិសម្ភិទា អាចញុំាញ៉ីបរប្បវាទបាន ។ គ្រានោះ កាលវេលាអាធ្រាត្រ ព្រាហ្មណ៍មាណព បានបរិវត្តបាតញ្ជលី (ស្វាធ្យាយ) នូវមន្តឱ្យមានបទបរិបូណ៌ និងឱ្យជាបរិមណ្ឌល ព្រះថេរៈស្តាប់នូវសំឡេងព្រាហ្មណ៍ស្វាធ្យាយមន្ត ក៏ជ្រាបថា "ព្រាហ្មណ៍នេះជាអ្នកមានបញ្ញាច្រើន" (រួចទើប) គិតថា "បើយើងទូន្មានឱ្យមករាប់អានព្រះពុទ្ធសាសនាបាននឹងជាការល្អ" ទើបហៅព្រាហ្មណ៍នោះមក រួចសួរថា "ម្នាលព្រាហ្មណ៍ អ្នកណាហ្នឹ៎ស្រែកជាសំឡេងដូចលា" ។ ឃោសៈព្រាហ្មណ៍នោះសួរថា "នែបព្វជិតដ៏ចម្រើន លោកដឹងនូវសំឡេងរបស់ពួកលាឬ ?" ព្រះថេរៈតបថា "យើង

ដឹង" ។ ព្រាហ្មណ៍នោះ ទើបសួរព្រះថេរៈក្នុងគណ្ឋិដ្ឋាន (គឺមន្តដែលយល់បានលំបាក) ទាំងឡាយក្នុងគម្ពីរត្រៃវេទ ទាំងគម្ពីរឥតិហាសជាគម្ពីរ ទី៥ ដែលខ្លួនឯងសម្លឹងមិនឃើញន័យឡើយ ទាំងអាចារ្យរបស់ខ្លួន ក៏មិនឃើញមកហើយផង ដែលព្រះថេរៈនោះ ដោយប្រក្រតីក៏ជាអ្នកចេះចប់ត្រៃវេទហើយ មកដល់ឥឡូវនេះ ជាអ្នកបានសម្រេចនូវបដិសម្ភិទាទៀត ព្រោះហេតុនោះ សេចក្តីលំបាកក្នុងការឆ្លើយនូវបញ្ហាទាំងនោះ ទើបមិនមានដល់លោក ព្រោះដូច្នោះ ទើបព្រះថេរៈឆ្លើយនូវបញ្ហាទាំងនោះបានភ្លាម ។ ហើយពោលនឹងព្រាហ្មណ៍នោះថា "នែព្រាហ្មណ៍ដ៏ចំរើន អ្នកសាកសួរយើងមកច្រើនហើយ ឥឡូវនេះ យើងនឹងសាកសួរនូវបញ្ហាកម្មនឹងអ្នកមួយ អ្នកនឹងឆ្លើយបញ្ហារបស់យើងបានឬទេ ?" ព្រាហ្មណ៍តបថា "ខ្ញុំនឹងឆ្លើយមន្តនោះប្រគេនបាន លោកម្ចាស់ចូរសួរមកចុះ" ទើបព្រះថេរៈសួរនូវបញ្ហាក្នុងគម្ពីរអភិធម្ម ចិត្តយមកៈ[១]នេះថា "**យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ តស្ស ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ យស្ស វា បន ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ តស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ :** ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះនឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ នឹងមិនកើត

---

១. អភិ. យម. យមកវគ្គ. ៩១. ១/១ ។

ឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់"[១] ។

ព្រាហ្មណមាណពនោះ មិនអាចនឹងឆ្លើយបាន មិនថា លើ ឬក្រោម ទើបសួរថា "បពិត្រលោកម្ចាស់ដ៏ចំរើន មន្តនេះឈ្មោះមន្តអ្វី ?" ព្រះថេរៈតបថា "ម្នាលព្រាហ្មណ៍ មន្តនេះ ឈ្មោះថា ពុទ្ធមន្ត" ។ ព្រាហ្មណ៍សួរថា "លោកម្ចាស់ដ៏ចម្រើន ឱ្យមន្តនេះដល់ខ្ញុំព្រះករុណាបានដែរឬទេ ?" ព្រះថេរៈតបថា "ម្នាលព្រាហ្មណ៍ យើងឱ្យ (មន្តនេះ) ដល់អ្នកបាន លុះត្រាតែអ្នកបួសជាបព្វជិតដូចយើង" ។

## មាណពបួស ប្រាកដឈ្មោះ ព្រះពុទ្ធឃោសៈ

ឃោសៈព្រាហ្មណ៍ដែលបុព្វហេតុ (គឺកុសលក្នុងកាលមុន) ទាំងឡាយជាស់តឿនហើយ ទើបសូមបព្វជ្ជា ដើម្បីត្រូវការមន្ត ព្រះថេរៈទើឱ្យព្រាហ្មណ៍បព្វជ្ជាឧបសម្បទាហើយ ឱ្យរៀនព្រះត្រៃបិដកពុទ្ធវចនៈ ភិក្ខុនោះ ក៏យល់ដឹងអត្ថធម៌របស់ព្រះត្រៃបិដកថា "នេះជាឯកាយមគ្គ (ដំណើរផ្លូវដ៏ឯក ប្រសើរជាងលទ្ធិចាស់របស់ខ្លួន)" (តមក) ក៏បានជាអ្នកប្រាកដច្បាស់ក្នុងលោក ដូច

---

១. ពាក្យថា **រមែងកើតឡើង** គឺនៅក្នុងឧប្បាទខណៈ, ពាក្យថា **រមែងមិនរលត់** គឺមិនទាន់ដល់និរោធឬភង្គខណៈ ។ ចិត្តក្នុងទីនេះ សំដៅដល់បច្ឆិមចិត្ត គឺចុតិចិត្ត របស់ព្រះអរហន្ត ខណៈចិត្តរបស់ព្រះអរហន្តកំពុងប្រព្រឹត្តទៅ ឈ្មោះថា រមែងកើតឡើង រមែងមិនរលត់ កាលដល់ភង្គខណៈហើយ ចុតិចិត្តនោះ ក៏នឹងរលត់ និងមិនមានចិត្តដទៃកើតឡើងតទៅទៀត ។

ពន្លឺភ្លើង ដូចពន្លឺព្រះចន្ទ ដូចពន្លឺព្រះអាទិត្យ ដោយការដែលលោកបានព្យាករណ៍ ពោលឆ្លើយបញ្ហាព្រះធម៌ដ៏ជ្រាលជ្រៅដល់ជនទាំងឡាយ ដូចជាពុទ្ធព្យាករណ៍, ភិក្ខុឃោសៈ ទើបបានប្រាកដនាមថា "ព្រះពុទ្ធឃោសៈ" ព្រោះល្បីផ្សាយទៅក្នុងផ្ទៃផែនដីដូចព្រះពុទ្ធអង្គ ។

## ព្រះថេរៈបញ្ជូនឱ្យទៅប្រែគម្ពីរអដ្ឋកថា

ព្រះពុទ្ធឃោសៈនោះ ជាអ្នកនៅក្នុងវិហារនោះ បានតែងបករណ៍ឈ្មោះញាណោទ័យទុកក្នុងវិហារហើយ ផ្តើមតែងអដ្ឋកថា ព្រះអភិធម្មសង្គណី និងអដ្ឋកថាច្បាប់ឈ្មោះអដ្ឋសាលិនី ព្រះថេរៈឃើញដូច្នោះទើបប្រាប់ថា "ម្នាលអាវុសោពុទ្ធឃោសៈ ក្នុងជម្ពូទ្វីបនេះ មានតែគម្ពីរព្រះត្រៃបិដកបាលីប៉ុណ្ណោះ អដ្ឋកថារបស់ព្រះត្រៃបិដកនោះ និងថេរវាទ (គឺពាក្យដែលព្រះថេរៈក្នុងសម័យសង្គីតិ ពោលទុកជាច្បាប់) មិនមាន តែអដ្ឋកថាព្រះត្រៃបិដកដែលឡើងកាន់សង្គីតិទាំង៣លើក ជាពាក្យដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងទុក និងព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើមចងក្រងទុកហើយ ឯព្រះមហិន្ទត្ថេរត្រួតមើលកថាមគ្គ (សម្តែងផ្លូវនៃពាក្យដែលពោលទុក)ហើយ (រួបរួមមក) តែងទុកដោយភាសាសីហឡៈ កំពុងប្រព្រឹត្តទៅនៅក្នុងសីហឡទ្វីប ចូរលោកទៅកាន់សីហឡទ្វីបនោះ ត្រួតរមើលឱ្យសព្វអន្លើហើយ បកប្រែមកជាភាសាមគធ

បាន អដ្ឋកថានោះ នឹងនាំមកនូវប្រយោជន៍សុខដល់មនុស្សលោកទាំងពួង" ។

កាលព្រះថេរណែនាំយ៉ាងនោះ ព្រះពុទ្ធឃោសៈ ជាអ្នកមានបញ្ញាច្រើន ក៏កើតបីតិសោមនស្ស ក្រាបទូលលាព្រះឧបជ្ឈាយ៍ និងភិក្ខុសង្ឃ បានធ្វើដំណើរទៅកាន់កំពង់ទឹកដោយលំដាប់ឡើង ទូកទៅជួបព្រះពុទ្ធទត្តត្ថេរតាមផ្លូវដែលមកដល់កណ្តាលសមុទ្រ ក៏បាននិយាយប្រាស្រ័យគ្នា ហើយធ្វើដំណើរបន្តទៅដរាបដល់កំពុង ក្រុងលង្កា ក្នុងកាលនោះ ព្រះបាទមហានាម គ្រប់គ្រងរាជ្យក្នុងលង្កាទ្វីប ។

# តែងបករណ៍ ឈ្មោះវិសុទ្ធិមគ្គ

ព្រះពុទ្ធឃោសៈ និមន្តទៅជួបព្រះសង្ឃក្នុងវិហារ ក្រុងអនុរាធបុរី ហើយទើបទៅកាន់សំណាក់ព្រះសង្ឃបាលត្ថេរ ដែលគង់នៅក្នុងមហាបធានឃរៈ បានស្តាប់ ( ជ្រាបសេចក្តី ) អដ្ឋកថាភាសាសីហឡៈ និងថេរវាទទាំងពួងហើយជឿទុកចិត្តថា "នេះឯងជាព្រះពុទ្ធាធិប្បាយរបស់ព្រះធម្មសាមិត្រពិត" ទើបទៅកាន់ទីប្រជុំសង្ឃ ក្នុងវិហារនោះ ដើម្បីសូមគម្ពីរធ្វើអដ្ឋកថាព្រះត្រៃបិដក ក៏បានពោលសូមថា "សូមលោកម្ចាស់ទាំងឡាយ មេត្តាឱ្យសៀវភៅគម្ពីរទាំងឡាយដល់ខ្ញុំព្រះករុណាដើម្បីធ្វើអដ្ឋកថា" ។ ដើម្បីសាកល្បង សមត្ថភាពរបស់

លោក ទើបភិក្ខុសង្ឃឱ្យគាថា ២ បទ ហើយពោលថា "លោកចូរសម្តែងសមត្ថភាពក្នុងគាថា ២ បទនេះ យើងទាំងឡាយ បានឃើញសមត្ថភាពរបស់លោកហើយ នឹងប្រគល់ ច្បាប់គម្ពីរឱ្យទាំងអស់" ព្រះពុទ្ធឃោសមើលបាលីព្រះត្រៃបិដក និងអដ្ឋកថារបស់ព្រះត្រៃបិដកនោះហើយ ទើបព្រះថេរៈរួបរួមព្រះត្រៃបិដកព្រមទាំងអដ្ឋកថាដោយសង្ខេប តែងបករណ៍ ឈ្មោះ វិសុទ្ធិមគ្គឡើង ក្នុងមហាវិហារនេះឯង ។

គ្រានោះ ទេវតា[១]មានបំណង ដើម្បីនឹងប្រកាសថ្វីដៃរបស់លោកឱ្យប្រាកដ ក្នុងមហាជន ទើបបណ្តាលឱ្យសៀវភៅគម្ពីរច្បាប់ (ដែលលោកសរសេររួចហើយ) ឱ្យអន្តរធានបាត់ទៅ ទើបលោកសរសេរឡើងថ្មីមួយច្បាប់ទៀត ទេវតាក៏បណ្តាលឱ្យអន្តរធានបាត់ទៅទៀត ទើបលោកសរសេរឡើងថ្មីលើកទី ៣ ទៀត ក៏បាន ចប់សព្វគ្រប់ទៀត ក្នុងគ្រានោះ ព្រះពុទ្ធឃោសៈនិមន្តព្រះសង្ឃ ដែលជាអ្នកឆ្លាសក្នុងធម៌របស់ព្រះសម្ពុទ្ធឱ្យមកប្រជុំគ្នា ក្នុងទីជិតមហាពោធិព្រឹក្ស(ប្រទេសលង្កា) ប្រារព្ធនឹងអានបករណ៍វិសុទ្ធិមគ្គនោះ (ឱ្យសង្ឃស្តាប់) ស្រាប់តែទេវតាដែលបំបាំងសៀវភៅនោះ នាំសៀវភៅទាំងពីរចប់នោះ មកប្រគេនសងវិញព្រមក្នុងខណៈនោះ ទើបបានជាសៀវភៅវិសុទ្ធិមគ្គ

---

១. ខ្លះថា ព្រះសង្ឃ ។

បីចប់ឡើង ក៏បានប្រគល់សៀវភៅទាំងបីចប់ ទៅព្រះភិក្ខុសង្ឃ, ភិក្ខុសង្ឃឱ្យអានសៀវភៅទាំងបីចប់ ព្រមគ្នា ការខុសគ្នាំងគ្នាត់បីចប់នោះ ដោយគណ្ឋៈក្តី ដោយអក្ខរៈក្តី ដោយបទក្តី ដោយព្យញ្ជនៈក្តី ដោយអត្ថក្តី ដោយការសរសេរមុន ក្រោយក្តី ដោយវាទៈទាំងឡាយមានថេរវាទជាដើមក្តី ដោយព្រះបាលីទាំងឡាយក្តី មិនមានឡើយ បានឮថា កាលគម្ពីរវិសុទ្ធិមគ្គ ទាំង ៣ ដែលព្រះពុទ្ធឃោសៈធ្វើរួចស្រេចហើយយ៉ាងនោះ ទេវតាទាំងឡាយ បាននាំគ្នាធ្វើសាធុការ សម័យនោះភិក្ខុច្រើនពាន់ប្រជុំ គ្នានៅក្នុងវិហារ ឃើញការអស្ចារ្យនោះហើយ ក៏នាំគ្នាសរសើរឱ្យសាធុការ ប្រកាសប្រាប់គ្នាសុសសាយទៅថា "នេះព្រះពោធិសត្វ មេត្រីមកកើត ដោយឥតសង្ស័យ"[១] ។

## បកប្រែអដ្ឋកថាព្រះត្រៃបិដក មកជាភាសាមគធៈ

ចំណែកស្តេចផែនដី ទ្រង់បានស្តាប់ដំណឹងនោះ ក៏ស្តេចចេញពីព្រះនគរព្រមទាំងរាជបរិវារទៅកាន់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយ ទ្រង់នមស្ការព្រះពុទ្ធឃោសៈ និមន្តឱ្យទទួលនូវចង្ហាន់នៅក្នុងរាជវាំងជាប្រចាំរហូតដល់ការតែងគម្ពីរចប់ ព្រះថេរៈ ទទួលនិមន្តដោយតុណ្ហីភាព ។

ព្រះភិក្ខុសង្ឃឃើញសមត្ថភាពរបស់ព្រះថេរៈហើយ ទើបប្រគល់សៀវភៅ

---

១. នេះជាការឃើញអស្ចារ្យរបស់ភិក្ខុទាំងឡាយទេ មិនប្រាកដជាព្រះមេត្រីឡើយ ។

ព្រះត្រៃបិដកបាលី ព្រមទាំងសៀវភៅអដ្ឋកថាសីហឡៈឱ្យដល់ព្រះថេរៈ, ព្រះថេរៈទទួលសៀវភៅគម្ពីរទាំងអស់ទៅទុកក្នុងប្រាសាទ ឈ្មោះថា បធានឃរៈ ដែលតាំងនៅខាងត្បូងនៃមហាវិហារ ប្រែអដ្ឋកថាទាំងអស់ធ្វើជាអដ្ឋកថាព្រះត្រៃបិដកក្នុងភាសាមគធ ដែលជាមូលភាសា (គឺភាសាដើម) ។

ក៏អដ្ឋកថាសីហឡៈនោះ មាន ៣ ភាគ គឺ មហាអដ្ឋកថា ១ បច្ចរិយអដ្ឋកថា ១ កុរុន្ទីអដ្ឋកថា ១ ។

អដ្ឋកថាដែលឡើងកាន់មហាសង្គីតិ ព្រះមហិន្ទត្ថេរនាំមកតែងទុកក្នុងភាសាសីហឡៈ ឈ្មោះថា **មហាអដ្ឋកថា** ។

មានផ្ទះផែមួយខ្នង មានឈ្មោះហៅក្នុងភាសាសីហឡៈថា បច្ចរិយៈ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងផ្ទះផែនោះ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

មានវិហារមួយកន្លែង ឈ្មោះកុរុន្ទវិហារ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងវិហារនោះ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទដែលព្រះថេរៈជំនាន់មុនមានព្រះថេរិកាចារ្យ (អាចារ្យធំ) ជាដើមកាន់យកន័យព្រះបាលីតែងទុក ឈ្មោះថា **ថេរវាទ** ។

ព្រះពុទ្ធឃោសៈ ប្រែកុរុន្ទីអដ្ឋកថាភាសាសីហឡៈ ធ្វើអដ្ឋកថាព្រះវិន័យបិដក ឈ្មោះសមន្តប្បាសាទិកា ក្នុងភាសាមគធៈហើយ តពីនោះក្នុងសុត្តន្តបិដក បកប្រែមហាអដ្ឋកថាអំពីភាសាសីហឡៈ តាំងជាអដ្ឋកថាទីឃនិកាយ

ឈ្មោះសុមង្គលវិលាសិនី, ជាអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី, ជាអដ្ឋកថាសំយុត្តនិកាយ ឈ្មោះ សារត្ថបកាសិនី, និងជាអដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះមនោរថបូរណី, តពីនោះ ក្នុងអភិធម្មបិដក បកប្រែបច្ចរិយអដ្ឋកថាអំពីភាសាសីហឡ: តាំងជាអដ្ឋកថាបករណ៍ធម្មសង្គណី ឈ្មោះអដ្ឋសាលិនីក្នុងភាសាមគធ: ជាអដ្ឋកថាបករណ៍វិភង្គ ឈ្មោះសម្មោហវិនោទនី និងជាអដ្ឋកថា ៥ បករណ៍ ឈ្មោះបរមត្ថទីបនី ។

ព្រះពុទ្ធឃោសៈ ធ្វើអដ្ឋកថាសីហឡៈទាំងអស់ឱ្យជាអដ្ឋកថា ព្រះត្រៃបិដក ក្នុងភាសាមគធៈ ដែលជាមូលភាសាដូចពោលមកហើយដូច្នោះ អដ្ឋកថានោះឯង បាននាំមកនូវប្រយោជន៍សុខដល់ពពួកជន ក្នុងប្រទេសដទៃ ៗទាំងពួងយ៉ាងច្រើនសន្ធឹកសន្ធាប់ហើយ រស់នៅរហូតដល់អស់អាយុ ទើបទៅកាន់ទេវលោកនោះឯង ។

កាលដែលបានបកប្រែអដ្ឋកថាព្រះត្រៃបិដក ចប់សព្វគ្រប់ហើយ ផែនដីក៏កក្រើកញ័រ (ជាអស្ចារ្យ) អដ្ឋកថាព្រះត្រៃបិដក ដែលព្រះថេរៈ ធ្វើដូចពោលមកនេះ គឺបកប្រែចប់សព្វ គ្រប់ តែក្នុងរយៈកាល ១ ឆ្នាំប៉ុណ្ណោះ ។

លុះបកប្រែរួចហើយ ព្រះពុទ្ធឃោសៈ ប្រាថ្នាដើម្បីនឹងបាន មកថ្វាយបង្គំព្រះមហាពោធិព្រឹក្ស ទើបក្រាបថ្វាយបង្គំព្រះភិក្ខុសង្ឃ ត្រឡប់មកជម្ពូទ្វីបវិញ ។

ព្រះរាជាមហានាម ទ្រង់គ្រងផែនដីអស់ ១២ ឆ្នាំ ទ្រង់ធ្វើបុណ្យច្រើនយ៉ាង ដោយប្រការផ្សេង ៗហើយ ស្តេចក៏ទៅកាន់បរលោកតាមយថាកម្ម ។ ចំណែកព្រះពុទ្ធឃោសត្ថេរនោះ បានរចនាអដ្ឋកថានៃព្រះត្រៃបិដកទុក បានសាងប្រយោជន៍ដ៏សមគួរដល់សត្វលោកជាច្រើន តាំងនៅរហូតគ្រប់អាយុខ័យ ក៏បានទៅកាន់ឋានតាវត្តិង្សហើយ ដូច្នេះឯង ។

## សេចក្តីប្រាថ្នារបស់ព្រះពុទ្ធឃោសត្ថេរ

យំ សិទ្ធំ ឥមិនា បុញ្ញ          យំ ចញ្ញំ បសុតំ មយា
ឯតេន បុញ្ញកម្មេន          ទុតិយេ អត្តសម្ភវេ
តាវតឹសេ បមោទេន្តោ          សីលាចារគុណេ រតោ
អលគ្គោ បញ្ចកាមេសុ          បត្វា បឋមំ ផលំ
អន្តិមេ អត្តភាវម្ហិ          មេត្តេយ្យំ មុនិបុង្គវំ
លោកគ្គបុគ្គលំ នាថំ          សព្វសត្តហិតេ រតំ
ទិស្វាន តស្ស ធីរស្ស          សុត្វា សទ្ធម្មទេសនំ
អធិគន្ត្វា ផលំ អគ្គំ          សោភេយ្យំ ជិនសាសនន្តិ ។

បុណ្យណា ដែលសម្រេចហើយដោយការធ្វើនេះ និងបុណ្យដទៃណា ដែលខ្ញុំបានខ្វល់ខ្វាយទុក ដោយអំណាចនៃបុណ្យនោះ ក្នុងអត្តភាពទី២ សូមឱ្យខ្ញុំរីករាយក្នុងឋានតាវត្តិង្ស ត្រេកអរក្នុងគុណគឺសីលនិងអាចារៈ មិនជាប់ជំពាក់ក្នុងកាមគុណទាំង ៥ បានសម្រេចអរិយផលទី ១ (សោតាបត្តិផល) ក្នុងអត្តភាពចុងបំផុត សូមឱ្យខ្ញុំបានជួបព្រះអារ្យមេត្រី ព្រះមុនីដ៏ប្រសើរ ជាបុគ្គលចម្បងក្នុងលោក ជាព្រះលោកនាថ ទ្រង់ពេញព្រះទ័យក្នុងការជួយសត្វលោកទាំងពួង សូមឱ្យខ្ញុំបានស្តាប់ព្រះសទ្ធម្មរបស់ព្រះមុនីអង្គនោះ ដែលទ្រង់ជាអ្នកប្រាជ្ញា ហើយបានសម្រេចអរិយផលជាន់ខ្ពស់ (អរហត្តផល) ញ៉ាំងព្រះសាសនារបស់ព្រះជិនស្រីឱ្យល្អស្អាត ដោយប្រការដូច្នេះហោង ។

ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ ចប់

# ឧប្បត្តិកថា

សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យ ជាស្នាដៃរបស់ព្រះពុទ្ធឃោសាចារ្យ

ប្រទេសខ្មែរយើងនេះ មានគម្ពីរព្រះត្រៃបិដកចប់សព្វគ្រប់ ដែលក្រុមជំនុំ បានរៀបចំឡើងជាភាសាបាលីផង ភាសាខ្មែរផង ខ្ញុំមានចិត្តសោមនស្សរីករាយ ហើយក៏រៀបចំប្រែអដ្ឋកថាព្រះវិន័យនេះ ឱ្យមកជាភាសាខ្មែរផង ដើម្បីបានការយល់ដឹងក្នុងផ្នែកព្រះវិន័យរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទខ្មែរយើង ដែលកំពុង តែប្រឹងប្រែងសិក្សាព្រះវិន័យ ។

ខ្ញុំបានសរសេរពាក្យបញ្ចូលថែម, គឺ ពាក្យខ្លះយកអំពីបិដក តាមដែល អដ្ឋកថាចង្អុលប្រាប់ផង មិនប្រាប់ផង ដោយមានលេខយោងបញ្ជាក់, ពាក្យខ្លះ មិនមានក្នុងបាលីអដ្ឋកថាទេ ថែមដោយបំណងដើម្បីបញ្ជាក់សេចក្តីប៉ុណ្ណោះ, ម្យ៉ាងទៀត បានដាក់លេខឃ្នាបតាមបិដក ដើម្បីងាយដឹងថា នេះជាសេចក្តីពន្យល់ ក្នុងបិដកត្រង់លេខឃ្នាបនេះ ។ តែដោយសមត្ថភាពរបស់ខ្ញុំព្រមទាំងក្រុមប្រឹក្សា តិចតួច សៀវភៅនេះក៏នៅមានសេចក្តី និងអក្ខរៈ ខុសភ្លាំងភ្លាត់នៅឡើយ ដោយអចេតនា សូមមេត្តាជួយសម្រួលដោយអនុគ្រោះផងចុះ ។

បុណ្យដែលកើតអំពីការព្យាយាមសាងសៀវភៅនេះ សូមចែកដល់អ្នកសិក្សាទាំងឡាយផង ។ សូមអ្នកសិក្សាទាំងឡាយ ទទួលអនុមោទនាត្រេកអរនូវបុណ្យនេះ ដោយមហាកុសលសោមនស្សរីករាយ ដែលប្រកបដោយបញ្ញា ឱ្យបានគ្រប់ ៗគ្នា សូមអនុមោទនា !!! ។

សូមឱ្យកុលបុត្រខ្មែរ ខិតខំសិក្សាព្រះធម៌វិន័យ ឱ្យកើតបញ្ញាយល់ដឹង ហើយទ្រទ្រង់សិក្ខាឱ្យបានមាំមួន ឱ្យបានតាំងនៅក្នុងភាពជាអ្នកខ្មាសបាប សង្រួម ប្រយ័ត្នដើម្បីកម្ចាត់បង់នូវបាបចេញ លាងជម្រះមន្ទិលសៅហ្មងក្នុងចិត្ត បំពាក់ អលង្ការ គឺព្រះសទ្ធម្ម ធ្វើខ្លួនឱ្យមានគុណតម្លៃ ឱ្យប្រសើរ ឱ្យផុតពីទុក្ខកង្វល់ នាំខ្លួនឱ្យដល់ឋានសុខសាន្ត ។

ខ្ញុំសូមប្រាថ្នាឱ្យមានបញ្ញាទ្រទ្រង់ព្រះធម៌ព្រះវិន័យ សូមឱ្យបានផុតពីក្តី អន្តរាយទាំងពួង និងបានសម្រេចតាមគោលបំណងដ៏ល្អ ជាពិសេសឱ្យបានដល់ ទីបំផុតទុក្ខ គឺ ព្រះនិព្វាន ដោយឆាប់រហ័សហោង ។

# អក្សរសង្ខេប និងអក្សរពេញ

## បិដក

| អក្សរសង្ខេប | អក្សរពេញនៃបិដក | | | ភាគ |
|---|---|---|---|---|
| *វិន. បារា.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *បារាជិក* | *ភាគ ១* |
| *វិន. សង្ឃា.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *សង្ឃាទិសេស* | *ភាគ ២* |
| *វិន. និស្ស.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *និស្សគ្គិយ* | *ភាគ ៣* |
| *វិន. បាចិ.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *បាចិត្តិយ* | *ភាគ ៤* |
| *វិន. ភិក្ខុនី.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *ភិក្ខុនីវិភង្គ* | *ភាគ ៥* |
| *វិន. មហា.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *មហាវគ្គ* | *ភាគ ៦-៨* |
| *វិន. ចុល្ល.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *ចុល្លវគ្គ* | *ភាគ ៩-១១* |
| *វិន. បរិ.* | *វិន័យបិដក* | *ខុទ្ទកនិកាយ* | *បរិវារៈ* | *ភាគ ១២-១៣* |
| *ទីឃ. សីល.* | *សុត្តន្តបិដក* | *ទីឃនិកាយ* | *សីលក្ខន្ធវគ្គ* | *ភាគ ១៤-១៥* |
| *ទីឃ. មហា.* | *សុត្តន្តបិដក* | *ទីឃនិកាយ* | *មហាវគ្គ* | *ភាគ ១៦-១៧* |
| *ទីឃ. បាដិ.* | *សុត្តន្តបិដក* | *ទីឃនិកាយ* | *បាដិកវគ្គ* | *ភាគ ១៨-១៩* |
| *មជ្ឈិ. មូល.* | *សុត្តន្តបិដក* | *មជ្ឈិមនិកាយ* | *មូលបណ្ណាសក* | *ភាគ ២០-២២* |
| *មជ្ឈិ. មជ្ឈិ.* | *សុត្តន្តបិដក* | *មជ្ឈិមនិកាយ* | *មជ្ឈិមបណ្ណាសក* | *ភាគ ២៣-២៥* |
| *មជ្ឈិ. ឧប.* | *សុត្តន្តបិដក* | *មជ្ឈិមនិកាយ* | *ឧបរិបណ្ណាសក* | *ភាគ ២៦-២៨* |
| *សំយុ. សគា.* | *សុត្តន្តបិដក* | *សំយុត្តនិកាយ* | *សគាថវគ្គ* | *ភាគ ២៩-៣០* |
| *សំយុ. និទា.* | *សុត្តន្តបិដក* | *សំយុត្តនិកាយ* | *និទានវគ្គ* | *ភាគ ៣១-៣២* |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | | ភាគ |
|---|---|---|---|---|
| សំយុ. ខន្ធ. | សុត្តន្តបិដក | សំយុត្តនិកាយ | ខន្ធវារវគ្គ | ភាគ ៣៣-៣៤ |
| សំយុ. សឡា. | សុត្តន្តបិដក | សំយុត្តនិកាយ | សឡាយតនវគ្គ | ភាគ ៣៥-៣៦ |
| សំយុ. មហា. | សុត្តន្តបិដក | សំយុត្តនិកាយ | មហាវារវគ្គ | ភាគ ៣៧-៣៩ |
| អង្គុ. ឯក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកនិបាត | ភាគ ៤០ |
| អង្គុ. ទុក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទុកនិបាត | ភាគ ៤០ |
| អង្គុ. តិក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | តិកនិបាត | ភាគ ៤១ |
| អង្គុ. ចតុ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ចតុកនិបាត | ភាគ ៤២-៤៣ |
| អង្គុ. បញ្ច. | សុត្តន្តបិដក | អង្គុត្តរនិកាយ | បញ្ចកនិបាត | ភាគ ៤៤-៤៥ |
| អង្គុ. ឆក្ក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឆក្កនិបាត | ភាគ ៤៦ |
| អង្គុ. សត្ត. | សុត្តន្តបិដក | អង្គុត្តរនិកាយ | សត្តកនិបាត | ភាគ ៤៧ |
| អង្គុ. អដ្ឋ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | អដ្ឋកនិបាត | ភាគ ៤៨ |
| អង្គុ. នវ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | នវកនិបាត | ភាគ ៤៩ |
| អង្គុ. ទស. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទសកនិបាត | ភាគ ៥០-៥១ |
| អង្គុ. ឯកា. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកាទសកនិបាត | ភាគ ៥១ |
| ខុទ្ទ. បាឋ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ខុទ្ទកបាឋ | ភាគ ៥២ |
| ខុទ្ទ. ធម្ម. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ធម្មបទ | ភាគ ៥២ |
| ខុទ្ទ. ឧទា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឧទាន | ភាគ ៥២ |
| ខុទ្ទ. ឥតិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឥតិវុត្តក | ភាគ ៥៣ |
| ខុទ្ទ. សុត្ត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | សុត្តនិបាត | ភាគ ៥៤ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | | ភាគ |
|---|---|---|---|---|
| ខុទ្ទ. វិមា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | វិមានវត្ថុ | ភាគ ៥៥ |
| ខុទ្ទ. បេត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បេតវត្ថុ | ភាគ ៥៦ |
| ខុទ្ទ. ថេរ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរគាថា | ភាគ ៥៦. ៥៧. |
| ខុទ្ទ. ថេរី. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរីគាថា | ភាគ ៥៧ |
| ខុទ្ទ. ជាត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ជាតក | ភាគ ៥៨-៦៣ |
| ខុទ្ទ. មហា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | មហានិទ្ទេស | ភាគ ៦៤-៦៦. |
| ខុទ្ទ. ចូឡ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចូឡនិទ្ទេស | ភាគ ៦៧. ៦៨. |
| ខុទ្ទ. បដិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ | ភាគ ៦៩-៧១. |
| ខុទ្ទ. អប្ប. | សុត្តន្តបិដក | ខុទ្ទកនិកាយ | អបទាន | ភាគ ៧២-៧៦ |
| ខុទ្ទ. ពុទ្ធ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ពុទ្ធវង្ស | ភាគ ៧៦ |
| ខុទ្ទ. ចរិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចរិយាបិដក | ភាគ ៧៦ |
| អភិ. សង្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធម្មសង្គណី | ភាគ ៧៨. ៧៩. |
| អភិ. វិភ. | អភិធម្មបិដក | ខុទ្ទកនិកាយ | វិភង្គ | ភាគ ៨០-៨២. |
| អភិ. ធាតុ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធាតុកថា | ភាគ ៨៣. |
| អភិ. បុគ្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | បុគ្គលបញ្ញត្តិ | ភាគ ៨៣. |
| អភិ. កថា. | អភិធម្មបិដក | ខុទ្ទកនិកាយ | កថាវត្ថុ | ភាគ ៨៤-៩០ |
| អភិ. យម. | អភិធម្មបិដក | ខុទ្ទកនិកាយ | យមក | ភាគ ៩១-៩៣. |
| អភិ. បដ្ឋា. | អភិធម្មបិដក | ខុទ្ទកនិកាយ | មហាបដ្ឋាន | ភាគ ៩៤-១១០ |

# អដ្ឋកថា

| អក្សរសង្ខេប | | អក្សរពេញនៃអដ្ឋកថា | | |
|---|---|---|---|---|
| សមន្ត. | ពាហិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | ពាហិរនិទាន |
| សមន្ត. | វេរ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | វេរញ្ជកណ្ឌ |
| សមន្ត. | បារា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | បារាជិកកណ្ឌ |
| សមន្ត. | សង្ឃា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | សង្ឃាទិសេស |
| សមន្ត. | និស្ស. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | និស្សគ្គិយ |
| សមន្ត. | បាចិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | បាចិត្តិយ |
| សមន្ត. | មហា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | មហាវគ្គ |
| សមន្ត. | ចុល្ល. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | ចុល្លវគ្គ |
| សមន្ត. | បរិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | បរិវារៈ |
| សុមង្គ. | សីល. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | សីលក្ខន្ធវគ្គ |
| សុមង្គ. | មហា. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | មហាវគ្គ |
| សុមង្គ. | បាដិ. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | បាដិកវគ្គ |
| បបញ្ច. | មូល. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | មូលបណ្ណាសក |
| បបញ្ច. | មជ្ឈិ. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក |
| បបញ្ច. | ឧប. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | ឧបរិបណ្ណាសក |
| សារត្ថ. | សគា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | សគាថវគ្គ |
| សារត្ថ. | និទា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | និទានវគ្គ |
| សារត្ថ. | ខន្ធ. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | ខន្ធវារវគ្គ |

| **អក្សរសង្ខេប** | **អក្សរពេញនៃអដ្ឋកថា** | | |
|---|---|---|---|
| សារត្ថ. សឡា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | សឡាយតនវគ្គ |
| សារត្ថ. មហា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | មហាវារវគ្គ |
| មនោរ. ឯក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឯកនិបាត |
| មនោរ. ទុក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ទុកនិបាត |
| មនោរ. តិក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | តិកនិបាត |
| មនោរ. ចតុ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ចតុក្កនិបាត |
| មនោរ. បញ្ច. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | បញ្ចកនិបាត |
| មនោរ. ឆក្ក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឆក្កនិបាត |
| មនោរ. សត្ត. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | សត្តកនិបាត |
| មនោរ. អដ្ឋ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | អដ្ឋកនិបាត |
| មនោរ. នវ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | នវកនិបាត |
| មនោរ. ទស. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ទសកនិបាត |
| មនោរ. ឯកា. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឯកាទសកនិបាត |
| បរត្ថ. បាឋ. | បរមត្ថជោតិកាយ | អដ្ឋកថានៃខុទ្ទកនិកាយ | ខុទ្ទកបាឋ |
| អដ្ឋ. ធម្ម. | ធម្មបទដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ធម្មបទគាថា |
| បរត្ថ. ឧទា. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ឧទាន |
| បរត្ថ. ឥតិ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ឥតិវុត្តក |
| បរត្ថ. សុត្ត. | បរមត្ថជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | សុត្តនិបាត |
| បរត្ថ. វិមា. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | វិមានវត្ថុ |
| បរត្ថ. បេត. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | បេតវត្ថុ |

## អក្សរសង្ខេប អក្សរពេញនៃអដ្ឋកថា

| | | | |
|---|---|---|---|
| បរត្ថ. ថេរ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរគាថា |
| បរត្ថ. ថេរី. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរីគាថា |
| អដ្ឋ. ជាត. | ជាតកដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ជាតក |
| សទ្ធម្ម. មហា. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | មហានិទ្ទេស |
| សទ្ធម្ម. ចូឡ. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | ចូឡនិទ្ទេស |
| សទ្ធម្ម. បដិ. | សទ្ធម្មប្បកាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ |
| វិសុទ្ធ. អប្ប. | វិសុទ្ធជនវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | អប្បទាន |
| មធុរ. ពុទ្ធ. | មធុរត្ថវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ពុទ្ធវង្ស |
| បរម. ចរិ. | វិមលវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ចរិយា |
| អដ្ឋសា. សង្គ. | អដ្ឋសាលិនី | អដ្ឋកថានៃព្រះអភិធម្ម | ធម្មសង្គណី |
| សម្មោហ. វិភ. | សម្មោហវិនោទនី | អដ្ឋកថានៃព្រះអភិធម្ម | វិភង្គ |
| បរម. បញ្ចប. | បរមត្ថទីបនី | អដ្ឋកថានៃព្រះអភិធម្ម | បញ្ចបករណ៍ |
| វិសុ. សីល. | វិសុទ្ធិមគ្គ | សីលនិទ្ទេស | ភាគ ១ |
| វិសុ. សមាធិ. | វិសុទ្ធិមគ្គ | សមាធិនិទ្ទេស | ភាគ ២ |
| វិសុ. បញ្ញា. | វិសុទ្ធិមគ្គ | បញ្ញានិទ្ទេស | ភាគ ៣ |
| ថៃ. | អដ្ឋកថាថៃ | | |
| ភូមា. | ឆដ្ឋសង្គាយនាភូមា | | |

គប្បីជ្រាបលេខ ដែលនៅបន្ទាប់ពីអក្សរសង្ខេប ដូច្នេះ គឺ លេខខាងដើមជាលេខភាគនៃគម្ពីរ លេខកណ្តាលជាលេខឃ្នាប លេខខាងចុងជាលេខទំព័រ ។

ឧទាហរណ៍ ៤. ៤៧៦/៤៧៨ គឺ ភាគទី ៤ ឃ្លាបទី ៤៧៦ ទំព័រទី ៤៧៨ ។



# បញ្ជីមាតិកា

**មាតិកា** **ទំព័រ**

ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ ... ... ... ... ... ... ក
ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ ... ... ... ... ... ... ... ... ង
ឧប្បត្តិកថា ... ... ... ... ... ... ... ... ... ... ... ... ... ឋ
អក្សរសង្ខេប និងអក្សរពេញ ... ... ... ... ... ... ... ... ធ
បញ្ជីមាតិកា ... ... ... ... ... ... ... ... ... ... ... ... ... ម

## មាតិកាចុល្លវគ្គ

១១. កម្មក្ខន្ធកវណ្ណនា
តជ្ជនីយកម្ម ... ... ... ... ... ... ... ... ... ... ១
បព្វាជនីយកម្ម ... ... ... ... ... ... ... ... ... ៧
បដិសារណីយកម្ម ... ... ... ... ... ... ... ... ... ៩
ឧក្ខេបនីយកម្ម ... ... ... ... ... ... ... ... ... ១២

១២. បារិវាសិកក្ខន្ធកវណ្ណនា
បារិវាសិកវត្តកថា ... ... ... ... ... ... ... ... ១៥
បរិវាសកថា . ... ... ... ... ... ... ... ... ... ៣៨

បកតត្តរបស់គ្នានិងគ្នា … … … … … … … ៤០

យ

## បញ្ជីមាតិកាអដ្ឋកថាចុល្លវគ្គ

មាតិកា ទំព័រ

១៣. សមុច្ចយក្ខន្ធកវណ្ណនា
មានត្ត ៤ យ៉ាង … … … … … … … … … ៤២
អប្បដិច្ឆន្នមានត្ត … … … … … … … … … ៤៣
បរិវាសកថា … … … … … … … … … … ៤៨
អាការបិទបាំងអាបត្តិ … … … … … … … … ៤៩
វិធីឱ្យបរិវាស … … … … … … … … … … ៥៦
វិធីឱ្យមានត្ត … … … … … … … … … … ៦៥
សុទ្ធន្តបរិវាស … … … … … … … … … … ៦៨
ចូឡសុទ្ធន្តៈ … … … … … … … … … … ៦៩
សមោធានបរិវាស … … … … … … … … … ៧២
បក្ខមានត្ត … … … … … … … … … … … ៧៧
សមោធានមានត្ត … … … … … … … … … ៨៦
១៤. សមថក្ខន្ធកវណ្ណនា
សម្មុខាវិន័យ … … … … … … … … … … ៩៥
សតិវិន័យ … … … … … … … … … … … ៩៦
អមូឡ្ហវិន័យ … … … … … … … … … … ៩៨

យេភុយ្យសិកា ... ... ... ... ... ... ... ... ... ៩៨



**មាតិកា** **ទំព័រ**

តស្សបាបីយសិកាកម្ម ... ... ... ... ... ... ... ... ១០០
តិណវត្ថារកៈ ... ... ... ... ... ... ... ... ... ... ១០១
អធិករណ៍ ៤ ... ... ... ... ... ... ... ... ... ... ១០៤
អធិករណវិភាគ ... ... ... ... ... ... ... ... ... ១០៨
ឧព្វាហិកា ... ... ... ... ... ... ... ... ... ... ... ១១២
យេភុយ្យសិកា ... ... ... ... ... ... ... ... ... ១១៤
តស្សបាបិយសិកា ... ... ... ... ... ... ... ... ... ១១៧

១៥. ខុទ្ទកវត្ថុខន្ធកវណ្ណនា

ការងូតទឹក ... ... ... ... ... ... ... ... ... ... ... ១១៩
ការតែងខ្លួនជាដើម ... ... ... ... ... ... ... ... ១២១
ការរាំនិងច្រៀងជាដើម ... ... ... ... ... ... ... ១២៥
សរភញ្ញ . ... ... ... ... ... ... ... ... ... ... ១២៧
បាត្រ ... ... ... ... ... ... ... ... ... ... ... ... ១២៨
កាំបិតនិងម្ជុល ... ... ... ... ... ... ... ... ... ១៣៦
ឈើស្តឹង ... ... ... ... ... ... ... ... ... ... ... ១៣៧
តម្រង ... ... ... ... ... ... ... ... ... ... ... ... ១៤០

ចង្ក្រមទិងពេងភ្លើង … … … … … … … … ១៤១

ល បញ្ជីមាតិកាអដ្ឋកថាចុល្លវគ្គ

**មាតិកា** **ទំព័រ**

ការឆាន់. … … … … … … … … … … … ១៤៥
ការផ្គាប់បាត្រ … … … … … … … … … … ១៤៦
រឿងពោធិរាជកុមារ … … … … … … … … ១៤៧
គ្រឿងជូតជើង … … … … … … … … … ១៤៨
ផ្លិត … … … … … … … … … … … … ១៤៩
ឆត្រ … … … … … … … … … … … … ១៤៩
ទណ្ឌសម្មតិជាដើម … … … … … … … … ១៥០
ភិក្ខុដែលទំពារអៀង … … … … … … … … ១៥០
កាំបិតកាត់ក្រចក … … … … … … … … … ១៥១
សក់ និង ពុកមាត់ … … … … … … … … ១៥២
កាយពន្ធ … … … … … … … … … … … ១៥៤
ការស្លៀកដណ្ដប់ … … … … … … … … … ១៥៦
អម្រែកជាដើម … … … … … … … … … ១៦០
ការដុតភ្លើង … … … … … … … … … … ១៦១
ការឡើងដើមឈើ … … … … … … … … ១៦២
គម្ពីរលោកាយត: … … … … … … … … … ១៦៣

លោហភណ្ឌៈជាដើម ... ... ... ... ... ... ... ... ១៦៥



**មាតិកា** **ទំព័រ**

១៦. សេនាសនក្ខន្ធកវណ្ណនា

វិនិច្ឆ័យក្នុងសេនាសនក្ខន្ធកៈ ... ... ... ... ... ១៦៦

វិហារទាន ... ... ... ... ... ... ... ... ... ... ... ១៦៧

ខ្សែទាញជាដើម ... ... ... ... ... ... ... ... ... ១៧០

គ្រែនិងតាំង ... ... ... ... ... ... ... ... ... ... ១៧១

កម្រាលផែនដីនិងសំឡីជាដើម ... ... ... ... ... ១៧៣

ខ្នើយ ... ... ... ... ... ... ... ... ... ... ... ១៧៤

ពូក ... ... ... ... ... ... ... ... ... ... ... ... ១៧៥

បរិកម្មផែនដី ... ... ... ... ... ... ... ... ... ១៧៨

បន្ទប់ជាដើម ... ... ... ... ... ... ... ... ... ... ១៧៩

ភាជន៍ទឹក ទ្វារ ... ... ... ... ... ... ... ... ... ១៨១

រឿងអនាថបិណ្ឌិកៈ ... ... ... ... ... ... ... ... ១៨២

នវកម្ម ... ... ... ... ... ... ... ... ... ... ... ១៨៦

ការកាន់កាប់សេនាសនៈ ... ... ... ... ... ... ... ១៨៦

ទំនៀមក្នុងរោងឆាន់ ... ... ... ... ... ... ... ... ១៨៧

សេនាសនៈដែលសមគួរដល់ភិក្ខុអាពាធ . ... ... ១៨៩

ភិក្ខុដែលសេនាសនគាហាបកៈ … … … … … ១៩០

ស

បញ្ជីមាតិកាអដ្ឋកថាចុល្លវគ្គ

**មាតិកា** **ទំព័រ**

សេនាសនគាហវិនិច្ឆ័យ … … … … … … … ១៩២
ការកាន់សេនាសនៈក្នុងវេជ្ជកាល … … … … … ១៩៥
ការកាន់សេនាសនៈក្នុងកាលចាំវស្សា … … … … ១៩៧
ការកាន់សេនាសនៈរម្ងាប់ … … … … … … … ២១៩
ភិក្ខុដែលមានអាសនៈស្មើគ្នា … … … … … … ២២២
គិហិវិកតិ . … … … … … … … … … … ២២៣
គរុភណ្ឌ … … … … … … … … … … … ២២៤
បរិវត្តនន័យ … … … … … … … … … … ២២៧
នវកម្ម … … … … … … … … … … … … ២៤២
សិទ្ធិនៃនវកម្មិកៈ … … … … … … … … … ២៤៨
ការប្រើសេនាសនៈ . … … … … … … … … ២៥១
សង្ឃភត្ត . … … … … … … … … … … ២៥៣
ឧទ្ទេសភត្ត … … … … … … … … … … … ២៥៥
និមន្តនភត្ត … … … … … … … … … … … ២៧៤
សលាកភត្តកថា … … … … … … … … … ២៨១
បក្ខិកភត្តជាដើម . … … … … … … … … ២៩៤

អាគន្តុកភត្តជាដើម … … … … … … … … ២៩៦


**មាតិកា** **ទំព័រ**

ភត្ត ៣ ប្រភេទទៀត … … … … … … … … ៣០១
ភត្តដទៃ ៤ យ៉ាងក្នុងអដ្ឋកថា … … … … … ៣០៣
គិលានប្បច្ច័យដែលគួរចែក … … … … … … ៣០៥
តួនាទីរបស់អ្នកចែក … … … … … … … … ៣០៩
១៧. សង្ឃភេទក្ខន្ធកវណ្ណនា … … … … … … … … ៣១១
អង្គនៃទូតជាដើម … … … … … … … … … ៣១៩
សង្ឃរាជី … … … … … … … … … … … ៣២២
ភេទករវត្ថុ ១៨ ប្រការ.. … … … … … … … ៣២៥
១៨. វត្តក្ខន្ធកវណ្ណនា … … … … … … … … … ៣៣១
អាវាសិកវត្ត … … … … … … … … … … ៣៣៣
គមិកវត្ត … … … … … … … … … … … ៣៣៥
រឿងអនុមោទនា … … … … … … … … … ៣៣៧
ភត្តគ្គវត្ត … … … … … … … … … … … ៣៣៨
បិណ្ឌចារិកវត្ត … … … … … … … … … … ៣៤២
អារញ្ញកវត្ត … … … … … … … … … … ៣៤៣

សេនាសនវត្ត ... ... ... ... ... ... ... ... ... ... ៣៤៤




**មាតិកា** **ទំព័រ**


ជន្តាឃរវត្ត ... ... ... ... ... ... ... ... ... ... ៣៤៥

និទាននៃវច្ចកុដិវត្ត រឿងទឹកជម្រះ ... ... ... ... ៣៤៥

វច្ចកុដិវត្ត ... ... ... ... ... ... ... ... ... ... ... ៣៤៦

១៩. បាតិមោក្ខដ្ឋបនក្ខន្ធកវណ្ណនា ... ... ... ... ... ... ៣៤៨

ការឃាត់បាតិមោក្ខ ... ... ... ... ... ... ... ... ៣៥០

អង្គនៃការកាន់យកអធិករណ៍ ... ... ... ... ... ៣៥២

ធម៌ដែលអ្នកចោទគប្បីពិចារណាចំពោះខ្លួន ... ... ៣៥៥

ធម៌ដែលអ្នកចោទគប្បីតាំងមាំក្នុងខ្លួន ... ... ... ... ៣៥៧

ធម៌ដែលអ្នកចោទគប្បីពិចារណាក្នុងខ្លួន ... ... ... ៣៥៨

ធម៌របស់អ្នកត្រូវគេចោទ ... ... ... ... ... ... ... ៣៦០

២០. ភិក្ខុនីខន្ធកវណ្ណនា

គរុធម៌ ៨ ... ... ... ... ... ... ... ... ... ... ៣៦១

ឧបសម្បទានៃភិក្ខុនីជាដើម ... ... ... ... ... ... ៣៦៤

អវន្ទិយករណ៍ជាដើម ... ... ... ... ... ... ... ... ៣៦៦

ការតែងខ្លួនជាដើម ... ... ... ... ... ... ... ... ៣៦៩

ការដាក់បរិក្ខារ ... ... ... ... ... ... ... ... ... ៣៧២



**មាតិកា** **ទំព័រ**

អាមិសដែលគេថ្វាយចំពោះខ្លួន ... ... ... ... ... ៣៧៣
ឋានៈនៃរបស់ដែលទទួលប្រគេន ... ... ... ... ៣៧៤
ការអង្គុយ ... ... ... ... ... ... ... ... ... ... ៣៧៤
ការឧបសម្បទាដោយទូត ... ... ... ... ... ... ... ៣៧៦
ពេលរក្សារបស់ជាដើម ... ... ... ... ... ... ... ៣៧៦
លាសិក្ខាជាដើម ... ... ... ... ... ... ... ... ... ៣៧៧
ត្រេកអរការអភិវាទជាដើម ... ... ... ... ... ... ៣៧៨
២១. បញ្ចសតិកក្ខន្ធកវណ្ណនា ... ... ... ... ... ... ... ... ៣៨០
២២. សត្តសតិកក្ខន្ធកវណ្ណនា ... ... ... ... ... ... ... ... ៣៨៤
សិង្គិលោណកប្បៈ ... ... ... ... ... ... ... ... ... ៣៨៧
អាវាសកប្បៈ ... ... ... ... ... ... ... ... ... ... ៣៩០
អនុមតិកប្បៈ ... ... ... ... ... ... ... ... ... ... ៣៩១
អទសកនិសីទនកប្បៈ ... ... ... ... ... ... ... ... ៣៩២
គាថាសរូប ... ... ... ... ... ... ... ... ... ... ៣៩៣

បញ្ជីមាតិកានៃចុល្លវគ្គ ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## ចុល្លវគ្គ

## បឋមភាគ

## ៩

# ១១. កម្មក្ខន្ធកវណ្ណនា

## តជ្ជនីយកម្ម

វិនិច្ឆ័យក្នុងកម្មក្ខន្ធកៈទី១ នៃចុល្លវគ្គ គប្បីជ្រាបដូច្នេះ ៖

[១] បទថា បណ្ឌុកលោហិតកា : បណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ បានដល់ ជន ២ នាក់ ក្នុងពួកឆព្វគ្គិយ គឺ បណ្ឌុកៈ ១ លោហិតកៈ ១ សទ្ធិវិហារិកទាំងឡាយ របស់លោកទាំង ២ ក៏ប្រាកដឈ្មោះថា បណ្ឌុកៈ និងលោហិតកៈដូចគ្នា ។

[៣] បីបទថា ពលវា ពលវំ បដិមន្តេថ : ចូរលោកពាល់គ្នាប្រឹងជជេកឱ្យពេញទំហឹង មានសេចក្តីថា លោកទាំងឡាយ តតាំងវាទឱ្យល្អ ឱ្យខ្លាំងក្លា ។

បទថា អលមត្ថតរា ច : ទាំងជាអ្នកអង់អាច គឺ ជាអ្នកមានអំណាចជាង ។

[៤] ក្នុងអង្គ ៣ មាន អសម្មុខា កតំ : កម្មដែលសង្ឃធ្វើកំបាំងមុខ ជាដើម មានសេចក្តីថា កម្មដែលធ្វើ គឺ ចោទមិនចំពោះមុខសង្ឃ ធម្មវិន័យ និង បុគ្គល, មិនសាកសួរមុនធ្វើ, ធ្វើដោយមិនតាមពាក្យបដិញ្ញានៃបុគ្គលនោះឯង ។

[៥] បទថា អទេសនាគាមិនិយា : មិនមែនជាទេសនាគាមិនី បានដល់ ធ្វើដោយអាបត្តិបារាជិក ឬ អាបត្តិសង្ឃាទិសេស ។

[៦-១៥] បណ្តាតិកៈទាំងនេះ ៩ បទ ក្នុង៣ តិកៈដើម ទ្រង់ផ្សំម្តង មួយបទ ៗ នឹង ២ បទនេះ គឺ អធម្មេន កាតំ វគ្គេន កាតំ : កម្មដែលធ្វើមិនត្រូវតាមធម៌ កម្មដែលធ្វើដោយពួក ត្រាស់ជា ៩ តិកៈ ។

រួមទាំងអស់ទើបជា ១២ តិកៈ ដោយប្រការដូច្នេះ ។

[១៦-២៧] ១២ តិកៈនេះឯង ត្រាស់ទុកសូម្បីក្នុងសុក្កបក្ខ ដោយអំណាចនៃកម្មផ្ទុយគ្នា ។

[២៨] ពីរបទថា អននុលោមិកេហិ គិហិសំសគ្គេហិ : ប្រឡូកប្រឡំដោយគ្រហស្ថដោយការប្រឡូកប្រឡំមិនសមគួរ មានសេចក្តីថា ដោយការប្រឡូកប្រឡំនឹងគ្រហស្ថ មានភាពជាអ្នកមានសេចក្តីទុក្ខសោកជាមួយគេជាដើម ដែលមិនសមគួរដល់បព្វជិត ។

[៣៤] ពាក្យថា ន ឧបសម្បាទេតព្វំ : មិនត្រូវឱ្យឧបសម្បទាជាដើម មានសេចក្តីថា បើជាឧបជ្ឈាយ៍ហើយ មិនគប្បីឱ្យកុលបុត្រឧបសម្បទា, មិនគប្បីឱ្យនិស្ស័យដល់ភិក្ខុអាគន្តុកៈ, មិនគប្បីទទួលសាមណេរដទៃទុក ។

ពីរបទថា អញ្ញា វា តាទិសិកា : ឬអាបត្តិដទៃប្រហែលគ្នាបានដល់ អាបត្តិដ៏ទៃប្រហែលគ្នាក្តី ។

បទថា **ធាបិដ្ឋតរា : អាបត្តិធ្ងន់ជាង** បានដល់ អាបត្តិធ្ងន់ជាង អាបត្តិមុន ។

កម្មនោះ បានដល់ តជ្ជនីយកម្ម គឺអំពើគួរដល់ការគម្រាម ។

កម្មដែលពួកភិក្ខុណាធ្វើហើយ ពួកភិក្ខុនោះ ឈ្មោះថា អ្នកធ្វើកម្ម ។

ពាក្យថា ន សវចនីយំ កាតព្វំ **: មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ** មានសេចក្ដីថា ខ្លួនដែលភិក្ខុណា ចោទហើយយ៉ាងនេះថា "ខ្ញុំព្រះករុណានឹងចោទ លោកជាចុងចោទក្នុងក្ដីនេះ និងលោកកុំឈានចេញអំពីអាវាសនេះ សូម្បីតែមួយជំហាន រហូតអស់វេលាដែលអធិករណ៍នោះនៅមិនទាន់ស្ងប់រម្ងាប់" ភិក្ខុនោះ ដែលខ្លួនមិនគប្បីធ្វើជាអ្នកមានមាត់ពាក្យ ។

បទថា ន អនុវាទោ **: មិនត្រូវទទួលនាទី** មានសេចក្ដីថា មិនគប្បីទទួល តំណែងការងារក្នុងវត្ត ។

បទថា ន ឱកាសោ **: មិនត្រូវឱ្យធ្វើឱកាស** មានសេចក្ដីថា មិនគប្បីឱ្យភិក្ខុដទៃធ្វើឱកាស យ៉ាងនេះថា "លោកចូរធ្វើឱកាសដល់ខ្ញុំព្រះករុណា, ខ្ញុំព្រះករុណាប្រាថ្នានឹងនិយាយជាមួយលោក" ។

ពាក្យថា ន ចោទេតព្វោ **: មិនត្រូវចោទគេ** មានសេចក្ដីថា មិនគប្បីចោទភិក្ខុដទៃ ដោយវត្ថុ ឬអាបត្តិ, គឺ មិនគប្បីឱ្យភិក្ខុដទៃរលឹក

ដោយពាក្យថា "នេះជាទោសរបស់លោកឬ ?"

ពាក្យថា នំ សម្បយោជេតព្វំ : មិនត្រូវប្រកបភិក្ខុ មានសេចក្តីថា មិនគប្បីជួយគ្នា និងគ្នា ឱ្យធ្វើការឈ្លោះ ។

ពាក្យថា តិណ្ណំ ភិក្ខវេ ភិក្ខូនំ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ៣ ពួក ជាដើម[១] ព្រះមានព្រះភាគត្រាស់ទុកដើម្បីសម្តែងថា សង្ឃសមគួរដាក់តជ្ជនីយកម្មដោយអង្គ សូម្បីមួយ ៗ ។

ពិតមែន ភាពជាអ្នកបង្កហេតុ ព្រះមានព្រះភាគត្រាស់ទុកឱ្យជាអង្គពិសេស សម្រាប់ភិក្ខុដែលគួរគម្រាម, ភាពជាអ្នកមានអាបត្តិរឿយ ៗ ត្រាស់ទុកជាអង្គពិសេស សម្រាប់ភិក្ខុគួរធ្វើឱ្យថយយស, ភាពជាអ្នកទ្រុស្តត្រកូល ត្រាស់ទុកជាអង្គពិសេស សម្រាប់ភិក្ខុដែលគួរបណ្តេញ, តែសង្ឃគួរធ្វើកម្ម សូម្បីទាំងអស់ដោយអង្គយ៉ាងណាមួយក្នុងអង្គទាំង ៣ នេះ ។

បើមានពាក្យតវ៉ាថា បើដូច្នោះ, ពាក្យដែលព្រះមានព្រះភាគត្រាស់ទុកក្នុងចម្លេយ្យក្ខន្ធកៈថា "សង្ឃធ្វើនិយស្សកម្មដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្ម ។ល។ ធ្វើអព្ភានដល់អ្នកគួរឱ្យឧបសម្បទា[២], ម្នាលឧបាលិ

---

១. ក្នុង[៣១] ។ ២. ពាក្យថា "ធ្វើអព្ភានដល់អ្នកគួរឱ្យឧបសម្បទា" នេះ មិនមានក្នុងបិដកខ្មែរ ។

កម្មមិនជាធម៌ និងកម្មមិនជាវិន័យ រមែងមានយ៉ាងនេះឯង ក៏បើយ៉ាង នោះ សង្ឃរមែងជាអ្នកមានទោស” ដូច្នេះ រមែងជំទាស់នឹងពាក្យថា តិណ្ណំ ភិក្ខវេ ភិក្ខូនំ ជាដើមនេះ ។

ឆ្លើយថា ពាក្យនេះមិនជំទាស់គ្នាទេ ។

ព្រោះហេតុអ្វី ?

ព្រោះក្នុងសេចក្តីនៃពាក្យផ្សេងគ្នា ។

ពិតមែន កម្មសន្និដ្ឋានជាសេចក្តីនៃពាក្យនេះថា តជ្ជនីយ-កម្មារហស្ស ជាដើម ។ សភាពនៃអង្គជាសេចក្តីនៃពាក្យជាដើមថា តិណ្ណំ ភិក្ខវេ ភិក្ខូនំ ដូច្នេះ ។ ព្រោះហេតុនោះ សង្ឃប្រជុំគ្នា ធ្វើកម្មសន្និដ្ឋានថា “នឹងធ្វើកម្ម ឈ្មោះនេះ ដល់ភិក្ខុនេះ” ដូច្នេះ ក្នុងកាលណា, ក្នុងកាលនោះ ភិក្ខុនោះ ឈ្មោះថា គួរដល់កម្ម ព្រោះហេតុនោះ ដោយលក្ខណៈនេះ គប្បីយល់ថា ធ្វើនិយស្សកម្មជាដើម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្មជាដើម ជាកម្មខុសធម៌ និងជាកម្មខុសវិន័យ ។

ក៏ក្នុងអង្គទាំងឡាយ មានភាពជាអ្នកបង្កហេតុជាដើម អង្គណាមួយ មានដល់ភិក្ខុណា, សង្ឃប្រាថ្នានឹងធ្វើដល់ភិក្ខុនោះ គប្បីកំណត់កម្មយ៉ាងណាមួយ ដោយអង្គយ៉ាងណាមួយ ក្នុងអង្គ និងកម្មទាំងឡាយតាមដែលទ្រង់អនុញ្ញាតទុកហើយ គប្បីធ្វើភិក្ខុនោះឱ្យគួរដល់កម្ម ហើយ

ធ្វើកម្មចុះ ។ វិនិច្ឆ័យក្នុងពាក្យទាំង ២ នេះប៉ុណ្ណេះ កាលកាន់យកវិនិច្ឆ័យយ៉ាងនេះ ពាក្យក្រោយ និងពាក្យមុន រមែងសមគ្នា ។

ក្នុងបាលីនោះ កម្មវាចាក្នុងតជ្ជនីយកម្ម ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃភិក្ខុជាអ្នកធ្វើការបង្កហេតុដោយពិត, ទោះជាយ៉ាងនោះក៏ដោយ កាលទឹងធ្វើតជ្ជនីយកម្មដល់ភិក្ខុពាល មិនឆ្លាត មានអាបត្តិច្រើន សង្ឃគប្បីធ្វើកម្មវាចា ដោយអំណាចនៃភិក្ខុពាល មិនឆ្លាត ។ ពិតមែន កាលធ្វើយ៉ាងនោះ កម្មជាការធ្វើហើយ ដោយវត្ថុដែលមាន, និងមិនជាការធ្វើដោយវត្ថុនៃកម្មដទៃ ។

ព្រោះហេតុអ្វី ?

ព្រោះហេតុថា សូម្បីតជ្ជនីយកម្មនេះ ព្រះមានព្រះភាគទ្រង់អនុញ្ញាតឱ្យធ្វើដោយវត្ថុ ពោលគឺ ភាពជាបុគ្គលពាល ជាអ្នកមិនឆ្លាតដូច្នេះឯង ។ ក្នុងកម្មទាំងពួងមានន័យដូចគ្នា ។

ខ្ញុំព្រះករុណាទឹងពណ៌នា វត្ថុនៃការប្រព្រឹត្តដ៏ប្រពៃ ១៨ យ៉ាងក្នុងបារិវាសិកក្ខន្ធកៈ ។

[៣៥] ពីរបទថា លោមំ បាតេន្តិ : ទាំងសម្ពបរោម មានសេចក្តីថា ជាអ្នកឈប់ប្រទង់ប្រទាញគ្នាហើយ អធិប្បាយថា ប្រព្រឹត្តតាមភិក្ខុទាំងឡាយ ។

ពីរបទថា នេត្ថារំ វត្តន្តិ : ប្រព្រឹត្តគួរដល់កិរិយារលាស់ចេញ មានសេចក្ដីថា វត្តនេះ ជារបស់ភិក្ខុទាំងឡាយអ្នកចេញចាកកម្ម ព្រោះហេតុនោះ ឈ្មោះថា នេត្ថារំ វត្តរបស់អ្នកចេញ ។ អធិប្បាយថា ខ្លួនអាចចេញចាកនិស្សារណា ដោយវិធី ១៨ យ៉ាងណា, ក៏ប្រព្រឹត្តវិធី ១៨ យ៉ាងនោះ ដោយប្រពៃ ។

សួរថា ភិក្ខុដែលត្រូវនិស្សារណា បំពេញវត្តអស់កាលប៉ុន្មាន ?

ឆ្លើយថា ១០ ថ្ងៃ ឬ ២០ ថ្ងៃក៏បាន ។

ពិតមែន ក្នុងកម្មក្ខន្ធកៈនេះ វត្តជារបស់ដែលភិក្ខុគប្បីបំពេញដោយថ្ងៃប្រមាណប៉ុណ្ណេះ, ប៉ុណ្ណោះ ។

## បព្វាជនីយកម្ម

វិនិច្ឆ័យក្នុងរឿងព្រះសេយ្យសកៈ គប្បីជ្រាបដូច្នេះ ៖

[៤៤] ពាក្យថា អបិស្សុ ភិក្ខូ បកតត្តា : ឯភិក្ខុទាំងឡាយជាបកតត្ត មានសេចក្ដីថា ភិក្ខុទាំងឡាយ រមែងជាអ្នកខ្វល់ខ្វាយជានិច្ច ។

ពាក្យដ៏សេសដូចបានពោលហើយក្នុងតជ្ជនីយកម្មនុ៎ះឯង ។

[១០៨] រឿងអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ ខ្ញុំព្រះករុណាបានពណ៌នាហើយក្នុងសង្ឃាទិសេស ។ តែវិនិច្ឆ័យក្នុងពាក្យជាដើមថា

កាយិកេន ធរេន : លេងដោយកាយ ក្នុងរឿងអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុនេះ គប្បីជ្រាបដូច្នេះ ៖

ការលេងប្រព្រឹត្តទៅមកកាយ ឱ្យឈ្មោះថា ការគ្មានក្រែងរអែងប្រព្រឹត្តទៅតាមមកកាយ ។ សូម្បីក្នុង២ បទ ដ៏សេសក៏ន័យនេះឯង ។

[១០៩] ការប្រព្រឹត្តល្មើសក្នុងសិក្ខាបទដែលទ្រង់បញ្ញត្តិទុកដោយកាយទ្វារ ឱ្យ ឈ្មោះថា អនាចារប្រព្រឹត្តទៅមកកាយ ។ សូម្បីក្នុងពីរបទដ៏សេស ក៏ន័យនេះឯង ។

ការបៀតបៀន បានខាងការបំផ្លាញពន្រ្ទេច ដោយការមិនសិក្សានូវសិក្ខាបទដែលទ្រង់បញ្ញត្តិទុកក្នុងកាយទ្វារ ឱ្យឈ្មោះថា ការបៀតបៀនដោយមកកាយ ។ អធិប្បាយថា ជាការបំផ្លាញ គឺធ្វើឱ្យហិនហោច ។ ២ បទដ៏សេសក៏ន័យនេះឯង ។

ការស្លប្រេង និងត្រាំថ្នាំជាដើម ដោយអំណាចនៃវេជ្ជកម្ម ដែលធ្វើដល់ជនដែលទ្រង់ហាមជាដើម ឱ្យឈ្មោះថា មិច្ឆាជីវៈ ប្រព្រឹត្តទៅមកកាយ ការទទួលនិងប្រាប់ដំណឹងជាដើមរបស់ពួកគ្រហស្ថ ឱ្យឈ្មោះថា មិច្ឆាជីវៈ ប្រព្រឹត្តទៅមកវាចា ។ កិច្ចទាំង ២ នោះ ឈ្មោះថា មិច្ឆាជីវៈ ប្រព្រឹត្តទៅ ទាំងមកកាយទាំងមកវាចា ។ ពាក្យដ៏សេសមានន័យដូចពោលហើយ ក្នុងតជ្ជនីយកម្មនុ៎ះឯង ។

# បដិសារណីយកម្ម

ក៏ឯវិនិច្ឆ័យក្នុងរឿងសុធម្មភិក្ខុ គប្បីជ្រាបដូច្នេះ ៖

[១២៩] បទថា អនបលោកេត្វា បានដល់ ន អាបុច្ឆិត្វា មិនទាន់ប្រាប់ ។

[១៣២] បទថា ឯតទវោច : ក៏បាននិយាយពាក្យនេះ មានសេចក្ដីថា សុធម្មភិក្ខុសួរថា "ម្នាលគហបតី ខាទនីយភោជនីយៈនេះ អ្នកចាត់ចែងទុកដើម្បីព្រះថេរៈទាំងឡាយឬ ?" ដូច្នេះ ហើយឱ្យបើកទាំងអស់ឃើញហើយ ទើបបានពោលពាក្យនេះ ។

ពាក្យថា ឯកា ច ខោ ឥធ នត្ថិ យទិទំ តិលសង្គុឡិកា : ទាស់តែក្នុងទីនេះ គ្មាននំទ្រាបល្ងមួយមុខប៉ុណ្ណោះ មានសេចក្ដីថា នំនេះគេហៅថា នំទ្រាបល្ង, នំនោះមិនមាន ។ បានឮថា នំដ៏ប្លែកមួយប្រភេទ មានក្នុងខាងដើមវង្សត្រកូលរបស់គហបតីនោះ ។ ព្រោះហេតុនោះ ព្រះថេរៈប្រាថ្នានឹងជេរគហបតីនោះ ប៉ះពាល់ដោយជាតិ ទើបពោលយ៉ាងនោះ ។

ពាក្យថា យទេវ កិញ្ចិ : តែបន្តិចបន្តួចជាដើម សេចក្ដីថា កាលពុទ្ធវចនៈ មានច្រើនយ៉ាងនេះ (ហេតុអ្វីក៏)លោកម្ចាស់សុធម្ម លះបង់ពុទ្ធវចនៈជាច្រើនដែលជារតនៈចេញ ហើយពោលពាក្យតែបន្តិចបន្តួច

ថា "នាំទ្រាបលូវិញ" ដែលជាពាក្យគ្រោតគ្រាតនុ៎ះឯង ។

គហបតីសម្តែងសេចក្តីនេះ ដោយឧទាហរណ៍រឿងកូនមាន់ថា កូនមាន់នោះ មិនបានរងាវដូចជាក្អែក មិនបានរងាវដូចជាមាន់យ៉ាងណា, លោកម្ចាស់ មិនបានពោលពាក្យរបស់ភិក្ខុ មិនបានពោលពាក្យរបស់គ្រហស្ថ ក៏យ៉ាងនោះ ។

[១៥០] តិកៈទាំងឡាយ មានពាក្យថា **អសម្មុខា** កាតំ **: ធ្វើក្នុងទីកំបាំងមុខ** ជាដើម មានប្រការដូចពោលហើយនោះឯង ។ ភិក្ខុដែលប្រកបដោយអង្គ មិនដូចគ្នានឹងភិក្ខុមុន ៗ ។

[១៥១] បណ្តាអង្គទាំងនោះ មានពាក្យថា **គិហីនំ អលាភាយ : មិនឱ្យពួកគ្រហស្ថបានលាភ** ជាដើម សេចក្តីថា គ្រហស្ថទាំងឡាយនឹងមិនបានលាភដោយប្រការណា, កាលភិក្ខុខ្វល់ខ្វាយ គឺព្យាយាមដោយប្រការនោះ ឈ្មោះថា ព្យាយាមមិនឱ្យពួកគ្រហស្ថបានលាភ ។ ក្នុងអនត្ថៈជាដើមក៏ន័យនេះ ។

បណ្តាពាក្យទាំងនោះ សេចក្តីខូចប្រយោជន៍ ឈ្មោះថា អនត្ថៈ ។

បទថា **អនត្ថាយ : មិនបានប្រយោជន៍** បានដល់ ដើម្បីឱ្យខូចប្រយោជន៍ ។

ការនៅក្នុងទីនោះមិនបាន ឈ្មោះថា មិនឱ្យបានលំនៅ ។

[១៦២] ពាក្យថា គិហីនំ ពុទ្ធស្ស អវណ្ណំ : ពោលតិះដៀលព្រះពុទ្ធចំពោះមុខគ្រហស្ថ សេចក្តីថា ពោលតិះដៀលព្រះពុទ្ធក្នុងសំណាក់គ្រហស្ថ ។

ពាក្យថា ធម្មិកំ បដិស្សវំ ន សច្ចាបេតិ : ទទួលពាក្យប្តេជ្ញាប្រកបដោយធម៌ អំពីពួកគ្រហស្ថហើយ ត្រឡប់ជាមិនធ្វើឱ្យពិត តាមពាក្យប្តេជ្ញា មានសេចក្តីថា ការទទួល នឹងប្រាកដពិតបាន ដោយប្រការណា, លោកមិនធ្វើដោយប្រការនោះ; គឺ ទទួលការចាំវស្សាហើយមិនទៅ ឬមិនធ្វើកម្មបែបនោះយ៉ាងដទៃ ។

ពាក្យថា បញ្ចន្នំ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ (ភិក្ខុ)៥ពួកជាដើម ព្រះ មានព្រះភាគត្រាស់ដើម្បីសម្តែងប្រភេទដែលភិក្ខុគួរដល់កម្មសូម្បីដោយអង្គតែមួយ ។

ពាក្យដ៏សេសក្នុងរឿងនេះ មានសេចក្តីងាយយល់ទាំងអស់ និងមានន័យដូចពោលហើយក្នុងតជ្ជនីយកម្មទាំងនោះ ។

# ឧក្ខេបនីយកម្ម

វិនិច្ឆ័យក្នុងរឿងឆន្នភិក្ខុ គប្បីជ្រាបដូច្នេះ ៖

[១៧៥] ពាក្យថា អាវាសបរម្បរញ្ច ភិក្ខវេ សំសថ : ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រាប់គ្នាក្នុងអាវាសត ៗទៅ មានសេចក្ដីថា លោកទាំងឡាយ ចូរប្រាប់ក្នុងអាវាសទាំងពួង ។

[២០០] ក្នុងបទថា ភណ្ឌនការកោ : ភិក្ខុអ្នកបង្កហេតុ ជាដើម មានវិនិច្ឆ័យថា សង្ឃគប្បីលើកអាបត្តិដែលត្រូវ ព្រោះបច្ច័យមានការបង្កហេតុជាដើម ធ្វើកម្ម ព្រោះមិនឃើញអាបត្តិនោះឯង ។

តិកៈទាំងឡាយ មានសេចក្ដីដូចពោលហើយដូចគ្នា ។ តែការប្រព្រឹត្តដោយប្រពៃក្នុងរឿងព្រះឆន្នៈនេះ មានវត្ត ៤៣ ប្រការ ។

[២០៦] បណ្ដាវត្តទាំងនោះ ពាក្យថា ន អនុទ្ធំសេតព្វោ : មិនត្រូវចោទភិក្ខុជាបកតត្ត បានដល់ មិនគប្បីចោទភិក្ខុដទៃ ។

ពាក្យថា ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វំ : មិនត្រូវប្រកបពួកភិក្ខុ(ឱ្យ ឈ្លោះ)នឹងពួកភិក្ខុផងគ្នា បានដល់ មិនគប្បីញុះញង់ភិក្ខុ និងភិក្ខុដទៃឱ្យបែកគ្នា ។

[២២១] ពាក្យថា ន គិហិឆជោ : មិនទ្រទ្រង់ទង់ជ័យរបស់គ្រហស្ថ បានដល់ មិនគប្បីទ្រទ្រង់សំពត់ស សំពត់មិនបានកាត់ជាយនិងសំពត់មានលាយផ្កា ។

ពាក្យថា ន តិត្ថិយធជោ : មិនទ្រទ្រង់ទង់ជ័យរបស់តិរ្ថិយ បានដល់ មិនគប្បីទ្រទ្រង់សំពត់ស្បូវជាដើម ។

ពាក្យថា ន អាសាទេតព្វោ : មិនត្រូវរុករាន បានដល់ មិនគប្បីរុកកួនភិក្ខុដទៃ ។

ពីរបទថា អន្តោ វា ពហិ វា : ខាងក្នុងឬខាងក្រៅ បានដល់ អំពីខាងក្នុងក្ដី អំពីខាងក្រៅក្ដី នៃកុដិជាលំនៅ ។

បីបទ មានបទថា ន តិត្ថិយេ សេវតិ : មិនសេពគប់នឹងពួកតិរ្ថិយ ១ ភិក្ខូ សេវតិ : មិនសេពគប់នឹងពួកភិក្ខុ ១ ភិក្ខុសិក្ខាយ សិក្ខតិ : សិក្សាសិក្ខាបទរបស់ភិក្ខុ ១ មានសេចក្ដីងាយយល់ទាំងអស់នោះឯង ។

ខ្ញុំព្រះករុណានឹងពណ៌នាបទដែលសល់ទាំងអស់ ក្នុងបារិវាសិកក្ខន្ធកៈ ។

ពាក្យដ៏សេសមានន័យដូចពោលក្នុងតជ្ជនីយកម្មហើយ ។

[២២៥] ក៏ឧក្ខេបនីយកម្ម ព្រោះការមិនសម្ដែងអាបត្តិ ដូចគ្នានឹងឧក្ខេបនីយកម្ម ព្រោះការមិនឃើញអាបត្តិ ក្នុង[១៧៥]នេះឯង ។

[២៧៦] រឿងអរិដ្ឋភិក្ខុ បានពោលហើយក្នុងវណ្ណនានៃបាចិត្តិយកណ្ឌ ។

[៣០៦] វិនិច្ឆ័យក្នុងបទថា ភណ្ឌនការកោ ជាដើម គប្បីជ្រាបដូច្នេះ ៖

ភិក្ខុអាស្រ័យទិដ្ឋិណា ទើបធ្វើការបង្កហេតុជាដើម, គប្បីធ្វើកម្មព្រោះការមិនលះបង់ទិដ្ឋិនុ៎ះឯង ។

បទដ៏សេសមានន័យដូចពោលហើយក្នុងតជ្ជនីយកម្មនោះឯង ។

[៣០៩] សូម្បីការប្រព្រឹត្តដោយប្រពៃក្នុងឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិលាមកនេះក៏មានវត្ត ៤៣ ប្រការដូចគ្នា ដោយប្រការដូច្នេះ ។

## កម្មក្ខន្ធកវណ្ណនា ចប់

# ១២. បារិវាសិកក្ខន្ធកវណ្ណនា

## បារិវាសិកវត្តកថា

វិនិច្ឆ័យក្នុងបារិវាសិកក្ខន្ធកៈ នេះ គប្បីជ្រាបដូច្នេះ ៖

[៣២០] បទថា **បារិវាសិកា :** ភិក្ខុអ្នកនៅបរិវាស បានដល់ភិក្ខុដែលកំពុងប្រព្រឹត្តបរិវាស ។

ក្នុងពាក្យថា **បារិវាសិកា** នោះ បរិវាសមាន ៤ យ៉ាង គឺ អប្បដិច្ឆន្នបរិវាស ១ បដិច្ឆន្នបរិវាស ១ សុទ្ធន្តបរិវាស ១ សមោធានបរិវាស ១ ។

បណ្ដាបរិវាស ៤ យ៉ាងនោះ តិត្ថិយបរិវាស ដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងមហាខន្ធកៈយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលណាឯទៀត ធ្លាប់ជាតិត្ថិយដទៃហើយ ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទា ក្នុងធម្មវិន័យនេះ, សង្ឃត្រូវឱ្យបរិវាសដល់បុគ្គលនោះកំណត់ត្រឹម ៤ ខែ"[១] ដូច្នេះ ឈ្មោះអប្បដិច្ឆន្នបរិវាស ។ ពាក្យណាដែលគប្បីពោលក្នុងអប្បដិច្ឆន្នបរិវាសនោះ ពាក្យនោះ ខ្ញុំព្រះករុណាបានពោលទុកល្អហើយ ។ ប៉ុន្តែថា អប្បដិច្ឆន្នបរិវាសនេះ ព្រះមានព្រះភាគទ្រង់មិនប្រាថ្នាក្នុងបារិវាសិកក្ខន្ធកៈនេះ ។

---

១. វិន. មហា. មហាខន្ធកៈ. ៦. ១០០/២៣១ ។

បរិវាសបីយ៉ាងដ៏សេស សង្ឃគប្បីឱ្យដល់ភិក្ខុដែលត្រូវអាបត្តិសង្ឃាទិសេសហើយ និងបិទបាំងទុក ។ ពាក្យណាដែលគប្បីពោលក្នុងបរិវាស ៣ យ៉ាងនោះ ពាក្យនោះ ខ្ញុំព្រះករុណានឹងពណ៌នាក្នុងសមុច្ចយក្ខន្ធកៈ ។ ក៏ឯបរិវាស ៣ យ៉ាង នេះ ព្រះមានព្រះភាគទ្រង់ប្រាថ្នាក្នុងបារិវាសិកក្ខន្ធកៈនេះ ។ ព្រោះហេតុនោះ ភិក្ខុដែលនៅបរិវាសយ៉ាងណាមួយ ក្នុង៣ បរិវាសនេះ គប្បីជ្រាបថា បារិវាសិកភិក្ខុ ។

[៣២១] ពីរបទថា **បកតត្តានំ ភិក្ខូនំ : របស់ភិក្ខុជាបកតត្តទាំងឡាយ** បានដល់ ភិក្ខុបកតត្តដ៏សេស ដោយហោចទៅ សូម្បីភិក្ខុដែលគួរដល់មូលាយបដិកស្សនាជាដើម វៀរបារិវាសិកភិក្ខុដែលខ្វិជាងចេញ ។

ពីរបទថា **អភិវាទនំ បច្ចុដ្ឋានំ : អភិវាទនកម្ម បច្ចុដ្ឋានកម្ម** មានសេចក្ដីថា ភិក្ខុបកតត្តទាំងនោះ ធ្វើសេចក្ដីគោរពមានអភិវាទជាដើមយ៉ាងណា បារិវាសិកភិក្ខុទាំងឡាយ រមែងត្រេកអរ គឺ ព្រមទទួលសេចក្ដីគោរពយ៉ាងនោះ ។ អធិប្បាយថា មិនហាមឃាត់ ។

បណ្ដាបទទាំងនោះ បទថា **សាមីចិកម្មំ** នេះ ជាឈ្មោះរបស់អភិសមាចារិកវត្ត មានការបក់ផ្លិតឱ្យជាដើម ដល់ភិក្ខុដទៃ ដែលសមគួរ វៀរសេចក្ដីគោរពមានអភិវាទជាដើមចេញ ។

បទថា អាសនាភិហារំ : ការនាំអាសនៈមកឱ្យ បានដល់ ការចាត់ចែងអាសនៈប្រគេន គឺ ចាប់អាសនៈទៅប្រគេន គឺកម្រាលប្រគេន នុ៎ះឯង ។ សូម្បីក្នុងការចាត់ចែងទីដេកប្រគេន ក៏ន័យនេះឯង ។

បទថា បាទោទកំ : ទឹកសម្រាប់ជើង នោះ គឺ ទឹកសម្រាប់លាងជើង ។

បទថា បាទបីឋំ : តាំងសម្រាប់ជើង នោះ គឺ តាំងសម្រាប់ទ្រជើងដែលលាងហើយ ។

បទថា បាទកឋលិកំ : វត្ថុសម្រាប់ជូតជើង នោះ គឺ បន្ទះក្តារសម្រាប់ដាក់ជើងដែលមិនទាន់បានលាង ឬផែនក្តារសម្រាប់ជូតជើង ។

ពីរបទថា អាបត្តិ ទុក្កដស្ស មានសេចក្តីថា ជាអាបត្តិទុក្កដដល់ភិក្ខុដែលត្រេកអរ សូម្បីរបស់សទ្ធិវិហារិកជាដើម ។ ព្រោះហេតុនោះ បារិវាសិកភិក្ខុនោះ គប្បីប្រាប់និស្សិតទាំងឡាយ មានសទ្ធិវិហារិកជាដើមនោះថា “ខ្ញុំព្រះករុណាកំពុងធ្វើវិន័យកម្ម, ពួកលោកកុំធ្វើវត្តដល់ខ្ញុំព្រះករុណាឡើយ កុំពោលលាចូលស្រុកចំពោះខ្ញុំព្រះករុណាឡើយ” ។ បើពួកកុលបុត្របួសដោយសទ្ធាពោលថា “សូមលោកម្ចាស់ធ្វើវិនយកម្មរបស់លោកម្ចាស់ចុះ” ដូច្នេះ ហើយនៅតែប្រឹងធ្វើវត្ត ទាំងពោលលាចូលស្រុកផង ចាប់ពីវេលាដែលហាមហើយទៅ មិនត្រូវ

អាបត្តិ ។

ពីរបទថា **មិទុ យថាវុឌ្ឍំ : តាមលំដាប់ចាស់ខ្ចី** មានសេចក្តីថា ក្នុងបារិវាសិកភិក្ខុផងគ្នា ភិក្ខុណា ៗ ជាភិក្ខុចាស់ជាងគ្នានិងគ្នា តថាគត អនុញ្ញាតឱ្យភិក្ខុនោះ ៗ ត្រេកអរអភិវាទជាដើមរបស់ភិក្ខុដែលខ្ចីជាងបាន ។

ពីរបទថា **បញ្ច យថាវុឌ្ឍំ : ទាំង ៥ យ៉ាង តាមលំដាប់ភិក្ខុចាស់** មានសេចក្តីថា តថាគតអនុញ្ញាតចំណែក ៥ តាមលំដាប់ភិក្ខុចាស់ ព្រមដោយភិក្ខុទាំងឡាយ សូម្បីភិក្ខុបកតត្ត ព្រោះហេតុនោះ កាលកំពុងសូធ្យបាតិមោក្ខ បារិវាសិកភិក្ខុអង្គុយក្នុងហត្ថបាស រមែងគួរ ។

តែក្នុងមហាបច្ចរីពោលថា កុំអង្គុយក្នុងលំដាប់ គប្បីលះលំដាប់ចេញ តែកុំអង្គុយលះហត្ថបាស ។

កាលធ្វើបារិសុទ្ធិឧបោសថ គប្បីអង្គុយក្នុងទីរបស់សង្ឃនវកៈ និងអង្គុយក្នុងទីនោះឯង ធ្វើបារិសុទ្ធិឧបោសថក្នុងលំដាប់របស់ខ្លួន ។

តែក្នុងមហាបច្ចរីពោលថា គប្បីធ្វើបារិសុទ្ធិឧបោសថក្នុងលំដាប់ ។ សូម្បីកាលធ្វើបវារណា ក៏គប្បីអង្គុយក្នុងទីរបស់សង្ឃនវកៈ និងអង្គុយក្នុងទីនោះឯង បវារណាក្នុងលំដាប់របស់ខ្លួន ។ សូម្បីសំពត់វស្សិកសាដក ដែលសង្ឃវាយគោះហើយចែកគ្នា បារិវាសិកភិក្ខុ ទឹង

ទទួលក្នុងទីដែលដល់ខ្លួន ក៏គួរ ។

ភត្តដែលភិក្ខុលះបង់ឱ្យ ហៅថា ភត្តដែលភិក្ខុប្រគល់ឱ្យ ។ ក៏បើឧទ្ទេសភត្តជាដើម ២-៣ ដែលត្រូវដល់បារិវាសិកភិក្ខុសោត ។ តែលោកមានសេចក្តីប្រាថ្នាចំពោះបុគ្គលិកភត្តដទៃ, ឧទ្ទេសភត្តជាដើមទាំងនោះ លោកគប្បីទទួលតាមលំដាប់ ហើយប្រាប់លះបង់ចេញថា "លោកម្ចាស់ មេត្តាឱ្យខ្ញុំព្រះករុណាទទួលលើកក្រោយចុះ, ថ្ងៃនេះ សេចក្តីសង្ឃឹមចំពោះភត្ត(ឯទៀត)របស់ខ្ញុំព្រះករុណាមាន, ស្អែកនេះ ខ្ញុំព្រះករុណានឹងទទួលយក" ។ ដោយការលះបង់ចេញយ៉ាងនេះ លោករមែងបានទទួលភត្តទាំងនោះ ក្នុងថ្ងៃស្អែក ។

ក្នុងកុរុន្ទីពោលថា ក្នុងថ្ងៃស្អែក គប្បីឱ្យដល់បារិវាសិកភិក្ខុនោះមុនភិក្ខុទាំងពួង ។ តែបើលោកមិនទទួល ហើយមិនប្រគល់ឱ្យទេ, ក្នុងថ្ងៃស្អែក រមែងមិនបាន ។ ភត្តដែលភិក្ខុប្រគល់ឱ្យនេះឯង ព្រះមានព្រះភាគទ្រង់អនុញ្ញាតចំពោះបារិវាសិកភិក្ខុប៉ុណ្ណោះ ។

ព្រោះហេតុអ្វី ? ព្រោះថា យាគូ និងរបស់ទំពារជាដើម ក្នុងពេលអាហារ រមែងកើតដល់លោកដែលអង្គុយក្នុងទីសង្ឃនវកៈខ្លះ មិនដល់ខ្លះ; ព្រោះហេតុនោះ ភត្តដែលភិក្ខុប្រគល់ឱ្យនេះ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតដោយចំពោះ ដើម្បីធ្វើការសង្គ្រោះដល់បារិវាសិកភិក្ខុនោះថា "លោកកុំលំបាកដោយភិក្ខាចារឡើយ" ។

បទថា ភត្តំ **: ការទទួលភត្ត** បានដល់ ចតុសាលភត្តរបស់សង្ឃក្នុងវិហារ ដែលភិក្ខុមកហើយ គប្បីទទួលតាមលំដាប់ភិក្ខុចាស់, បារិវាសិកភិក្ខុ រមែងបានភត្តនោះ តាមលំដាប់ភិក្ខុចាស់ ។ តែមិនបានដើម្បីទៅឬឈរក្នុងជួរ ។ ព្រោះហេតុនោះ គប្បីថយឱ្យឆ្ងាយអំពីជួរហើយ ឈរក្នុងហត្ថបាស ឈោងដៃទទួល ដូចសត្វស្ទាំងបោះពួយឆាបយកដូច្នោះ ។ លោកមិនបានដើម្បីប្រើអារាមិកបុរស ឬសមណុទ្ទេសឱ្យនាំមក ។ បើគេនាំមកដោយខ្លួនឯង ការនាំមកនោះគួរ សូម្បីក្នុងមហាបេឡភត្តរបស់ព្រះរាជា ក៏ន័យនេះឯង ។

ក្នុងមហាបច្ចរីពោលថា តែក្នុងចតុសាលភត្ត បើបារិវាសិកភិក្ខុជាអ្នកប្រាថ្នានឹងធ្វើការប្រគល់ឱ្យ, កាលអាហារដែលគេលើកឡើងហើយដើម្បីខ្លួន គប្បីប្រាប់ថា "ថ្ងៃនេះ ភត្តរបស់យើង មាន, ស្អែកនេះយើងនឹងទទួល" ដូច្នេះ ក្នុងថ្ងៃស្អែក រមែងបានអាហារ ២ ចំណែក ។ សូម្បីឧទ្ទេសភត្តជាដើម គប្បីថយឆ្ងាយអំពីជួរសិន សឹមទទួល ។ និងពួកទាយកនិមន្តឱ្យអង្គុយក្នុងទីណា ហើយអង្គាស, គប្បីជាប្រធានរបស់ពួកសាមណេរ ជាសង្ឃនវកៈរបស់ពួកភិក្ខុអង្គុយក្នុងទីនោះ ។

ឥឡូវនេះ វិនិច្ឆ័យក្នុងការប្រព្រឹត្តដ៏ប្រពៃ ដែលព្រះមានព្រះភាគត្រាស់ទុកនេះ ។

[៣២២] បទថា ន ឧបសម្បាទេតព្វំ : មិនត្រូវឱ្យឧបសម្បទា មានសេចក្តីថា បើជាឧបជ្ឈាយ៍មិនគប្បីឱ្យឧបសម្បទា តែនឹងជាក់វត្ត ហើយឱ្យឧបសម្បទា គួរ ។

ជាអាចារ្យហើយ សូម្បីកម្មវាចាក៏មិនគួរសូធ្យ, កាលភិក្ខុដទៃមិនមាននឹងជាក់វត្តហើយសូធ្យ គួរ ។

បទថា ន និស្សយោ ទាតព្វោ : មិនត្រូវឱ្យនិស្ស័យ មានសេចក្តីថា មិនគប្បីឱ្យនិស្ស័យដល់ពួកភិក្ខុអាគន្តុកៈ សូម្បីភិក្ខុពួកណាបានកាន់និស្ស័យ តាមប្រក្រតីហើយ គប្បីប្រាប់ភិក្ខុទាំងនោះថា ខ្ញុំព្រះករុណាកំពុងធ្វើវិន័យកម្ម ។ ពួកលោកចូរកាន់និស្ស័យក្នុងសំណាក់ព្រះថេរៈ ឈ្មោះឯណោះ កុំធ្វើវត្តដល់ខ្ញុំព្រះករុណាឡើយ កុំពោលលាចូលស្រុកចំពោះខ្ញុំព្រះករុណាឡើយ ។ កាលបើប្រាប់យ៉ាងនោះហើយ ពួកនិស្សិតក៏នៅតែប្រឹងធ្វើ សូម្បីពួកលោកនៅតែប្រឹងធ្វើទៀត ចាប់តាំងពីកាលដែលបានហាមហើយនោះទៅ មិនត្រូវអាបត្តិដល់បារិវាសិកភិក្ខុនោះទៀតទេ ។

បទថា ន សាមណេរោ : មិន(ត្រូវឱ្យ)សាមណេរ(បម្រើខ្លួន) មានសេចក្តីថា មិនគប្បីទទួលសាមណេរដទៃ; សូម្បីពួកសាមណេរដែលខ្លួនជាឧបជ្ឈាយ៍ទទួលយកទុក ខ្លួនក៏គួរប្រាប់ថា ខ្ញុំព្រះករុណា

កំពុងធ្វើវិន័យកម្ម, ពួកលោកកុំធ្វើវត្តដល់ខ្ញុំព្រះករុណាឡើយ កុំពោលលាចូលស្រុកចំពោះខ្ញុំព្រះករុណាឡើយ ។ កាលបើប្រាប់យ៉ាងនោះហើយ លោកទាំងឡាយនៅតែប្រើងធ្វើ; សូម្បីកាលលោកទាំងឡាយ នៅតែធ្វើតទៀត ចាប់តាំងពីកាលដែលបានហាមហើយនោះទៅ មិនត្រូវអាបត្តិដល់បារិវាសិកភិក្ខុនោះ ។

ដែលឈ្មោះថា ការសម្មតិឱ្យជាអ្នកទូន្មានភិក្ខុនី ដែលជាតំណែងរបស់អ្នកជាធំ លោកហាម, ព្រោះដូច្នោះ បារិវាសិកភិក្ខុ គប្បីប្រាប់ដល់ភិក្ខុសង្ឃថា "លោកម្ចាស់ ខ្ញុំព្រះករុណាកំពុងធ្វើវិន័យកម្ម, លោកទាំងឡាយ ចូរដឹងភិក្ខុដែលគួរទូន្មានភិក្ខុនី ឬគប្បីប្រគល់ភារៈដល់ភិក្ខុដែលអាចក៏បាន និងគប្បីប្រាប់ភិក្ខុនីទាំងឡាយ ដែលនាំគ្នាមកថា នាងទាំងឡាយចូរទៅរកសង្ឃ ។ សង្ឃនឹងដឹងភិក្ខុដែលឱ្យឱវាទដល់នាងទាំងឡាយ ឬគប្បីប្រាប់ថា ខ្ញុំព្រះករុណាកំពុងធ្វើវិន័យកម្ម នាងទាំងឡាយចូរទៅរកភិក្ខុឈ្មោះឯណោះ ។ លោកនឹងឱ្យឱវាទដល់នាងទាំងឡាយ ។

បទថា សា អាបត្តិ **: អាបត្តិនោះ** មានសេចក្តីថា មិនគប្បីបញ្ចេញសុក្កៈ ទៀតក្នុងកាលបរិវាស ដើម្បីការបញ្ចេញសុក្កៈដែលសង្ឃឱ្យហើយ ។

ពីរបទថា អញ្ញា វា តាទិសិកា **: ឬអាបត្តិដទៃប្រហែលគ្នា**

បានដល់ គរុកាបត្តិមានកាយសំសគ្គៈជាដើម ។

ពីរបទថា **តតោ វា ធុបិដ្ឋតរា** : ដែលធ្ងន់ជាងអាបត្តិនោះ បានដល់ អាបត្តិបារាជិក, ក្នុងអាបត្តិ ៧ កង អាបត្តិទុព្ភាសិត ជាអាបត្តិអាក្រក់ អាបត្តិទុក្កដ ជាអាបត្តិអាក្រក់ជាង, អាបត្តិទុក្កដជាអាបត្តិអាក្រក់ អាបត្តិបាដិទេសនីយៈ ជាអាបត្តិអាក្រក់ជាង ។

គប្បីជ្រាបន័យក្នុងអាបត្តិបាចិត្តិយ ថុល្លច្ច័យ សង្ឃាទិសេស និងបារាជិកដោយឧបាយយ៉ាងនេះ ។

សូម្បីក្នុងវត្ថុទាំងឡាយនៃអាបត្តិទាំងនោះ គប្បីជ្រាបសេចក្តីផ្សេងគ្នាដោយន័យមុននោះឯងថា វត្ថុនៃទុព្ភាសិតអាក្រក់ វត្ថុនៃទុក្កដអាក្រក់ជាង តែក្នុងសិក្ខាបទដែលជាបណ្ណត្តិវជ្ជៈ ទាំងវត្ថុ ទាំងអាបត្តិអាក្រក់ ។ ចំណែកសិក្ខាបទដែលជាលោកវជ្ជៈអាក្រក់ជាងទាំង ២ យ៉ាង ។ កម្មវាចានៃបរិវាស លោកហៅថា កម្ម, មិនគប្បីជាប់ដោយពាក្យជាដើមថា កម្មនោះ មិនជាការធ្វើ ជាការធ្វើដោយអាក្រក់ ឬដោយពាក្យជាដើមថា កម្មប្រភេទនេះ ជាកសិកម្ម ជាគោរក្ខកម្មដែរឬ ?

បទថា **កម្មិកា** : ពួកភិក្ខុអ្នកធ្វើកម្ម មានសេចក្តីថា កម្មដែលភិក្ខុពួកណាធ្វើហើយ ភិក្ខុទាំងនោះ លោកហៅថា កម្មិកា ។ មិនគប្បីតិះដៀលភិក្ខុទាំងនោះ ដោយពាក្យថា ជាពាល មិនឆ្លាតជាដើម ។

ពាក្យថា ន សវចនីយំ កាតព្វំ : មិនត្រូវឱ្យជាអ្នកមានមាត់ពាក្យ មានសេចក្តីថា មិនគប្បីធ្វើឱ្យជាអ្នកមានមាត់ពាក្យ ដើម្បីប្រយោជន៍ដល់ការកង្វល់ ឬដើម្បីប្រយោជន៍ដល់ការកោះហៅខ្លួន ។

ពិតមែន កាលនឹងធ្វើដើម្បីប្រយោជន៍ដល់ការកង្វល់ រមែងធ្វើយ៉ាងនេះថា "ខ្ញុំព្រះករុណានឹងធ្វើលោកឱ្យរលឹកក្នុងក្តីនេះ, លោកកុំចេញចាកអាវាសនេះ សូម្បីត្រឹមតែមួយជំហានរហូតដល់វេលាដែលអធិករណ៍នោះ នៅមិនទាន់រម្ងាប់" ដូច្នេះ, កាលនឹងធ្វើដើម្បីប្រយោជន៍ដល់ការកង្វល់ដល់ខ្លួន រមែងធ្វើយ៉ាងនេះថា ខ្ញុំព្រះករុណានឹងធ្វើលោកឱ្យរលឹក, លោកចូរមក ទៅចំពោះមុខព្រះវិន័យធរជាមួយខ្ញុំព្រះករុណា មិនគួរធ្វើជាអ្នកមានពាក្យត្រូវពោលទាំង ២ យ៉ាងនោះ ។

បទថា ន អនុវាទោ : មិន( ត្រូវទទួល )តំណែងជាធំ មានសេចក្តីថា មិនគប្បីទទួលតំណែងជាធំក្នុងវត្ត, គឺ មិនគប្បីជាអ្នកសូធ្យបាតិមោក្ខ ឬអាភាធនាសម្តែងធម៌ ។ មិនគប្បីធ្វើការជាប់ដោយភាពជាធំសូម្បីដោយអំណាចសម្មតិណាមួយ ក្នុងសម្មតិ ១៣ ។

បទថា ន ឱកាសោ : មិន( ឱ្យធ្វើ )ឱកាស មានសេចក្តីថា មិនគប្បីធ្វើឱកាសដល់ភិក្ខុបកតត្តយ៉ាងនេះថា លោកចូរធ្វើឱកាសដល់ខ្ញុំព្រះករុណា, ខ្ញុំព្រះករុណាចង់និយាយចំពោះលោក, គឺមិនគប្បីចោទ

ដោយវត្ថុ ឬអាបត្តិ, មិនគប្បីឱ្យភិក្ខុដទៃចេញពាក្យឆ្លើយ ដោយពាក្យថា “នេះជាទោសរបស់លោកឬ ?”

បទថា ន ភិក្ខុ ភិក្ខូហិ សម្បយោជេតព្វំ : មិនត្រូវប្រកបពួកភិក្ខុ(ឱ្យឈ្លោះ)នឹងពួកភិក្ខុផងគ្នា មានសេចក្តីថា មិនគប្បីជួយគ្នានិងគ្នាឱ្យធ្វើការឈ្លោះ ។

[៣២៣] បទថា បុរតោ : ខាងមុខ មានសេចក្តីថា ជាសង្ឃថេរៈមិនគួរទៅខាងមុខ គឺគប្បីលះការទៅជិតគ្នាប្រមាណ ១២ ហត្ថ ទៅតែម្នាក់ឯង ។

សូម្បីក្នុងការអង្គុយ ក៏មានន័យដូចគ្នា ។

អាសនៈដែលចាត់ថា ចុងបង្អស់របស់សង្ឃនវកៈ ក្នុងពេលអាហារជាដើម ឈ្មោះថា អាសនៈចុងបង្អស់ ។ អាសនៈចុងបង្អស់នោះគួរឱ្យដល់បារិវាសិកភិក្ខុនោះ, លោកគប្បីអង្គុយលើអាសនៈនោះ ។

ទីចុងបង្អស់របស់ទីដេកទាំងឡាយ បានដល់ គ្រែតាំងដែលអាក្រក់ជាងគ្រែតាំងទាំងអស់ ឈ្មោះថា ទីដេកចុងបង្អស់ ។ ពិតមែនបារិវាសិកភិក្ខុនេះ មិនបានដើម្បីកាន់យកទីដេកក្នុងទីដែលដល់ខ្លួនតាមលំដាប់វស្សា ។ តែទីដេកដែលអាក្រក់ ដែលត្បាញដោយផ្តៅនិងសំបកឈើជាដើម មានអាចម៍សង្អើចប្រឡាក់លើទីដេក ដែលភិក្ខុទាំងពួងកាន់

យកហើយ គួរឱ្យដល់លោក ។

បទថា វិហារបរិយន្តេ : ជាទីបំផុតនៃលំនៅ មានសេចក្តីថា ក៏ទីដេកយ៉ាងណា ទីនៅក៏យ៉ាងនោះ, ម្យ៉ាងទៀត សូម្បីអាវាស ក៏មិនគួរដល់លោកក្នុងទីដែលដល់ខ្លួនតាមលំដាប់វស្សា ។ តែបណ្ណសាលាដែលមានផ្ទៃរនាប ច្រើនដោយធូលី ពេញទៅដោយអាចម៍ប្រចៀវ និងកណ្តុរ ដែលនៅសល់អំពីការកាន់យករបស់ភិក្ខុទាំងឡាយ គួរឱ្យដល់លោក ។ បើភិក្ខុបកតត្តទាំងអស់ជារុក្ខមូលិក ឬអព្ភោកាសិកមិនចូលទីប្រក់, អាវាសទាំងអស់ចាត់ថា ជាអាវាសដែលភិក្ខុទាំង នោះ លះបង់ចេញហើយ ។

បណ្តាអាវាសទាំងនោះ លោករមែងបានអាវាសដែលខ្លួនត្រូវការ ។

មួយទៀត ក្នុងថ្ងៃវស្សូបនាយិកា លោកអាចឈរក្នុងទីម្ខាងទទួលបច្ច័យតាមលំដាប់វស្សាបាន, តែមិនបានកាន់យកសេនាសនៈ ។ បារិវាសិកភិក្ខុដែលប្រាថ្នានឹងកាន់យកសេនាសនៈ ដែលមានសំពត់ចាំណាំវស្សាជានិច្ច គប្បីដាក់វត្តមុនហើយ ទើបកាន់យក ។

បទថា តេន ច សោ សាទិតព្វោ : ត្រូវត្រេកអរចំពោះឱកាសនោះ មានសេចក្តីថា ភិក្ខុទាំងឡាយ ឱ្យអាសនៈចុងបង្អស់ជាដើម យ៉ាងណាដល់លោក, អាសនៈចុងបង្អស់ជាដើមយ៉ាងនោះឯង ដែលលោក

គប្បីត្រេកអរ ។

បទថា បុរេសមណេន វា បច្ឆាសមណេន វា : ជាបុរេសមណៈ ជាបច្ឆាសមណៈ មានសេចក្តីថា លោកទទួលការនិមន្តក្នុងទីនៃញាតិ និងអ្នកបវារណាថា "សូមលោកកាន់យកភិក្ខុទាំងឡាយ មានប្រមាណប៉ុណ្ណោះហើយមក" ហើយបបួលយ៉ាងនេះថា "ត្រកូលឈ្មោះឯណោះ និមន្តភិក្ខុទាំងឡាយ, ពួកលោកចូរមក យើងទាំងឡាយចូលទៅក្នុងត្រកូលនោះ" ដូច្នេះ មិនគប្បីធ្វើភិក្ខុទាំងឡាយ ដែលជាបកតត្តឱ្យជាបុរេសមណៈ ឬបច្ឆាសមណៈទៅ ។

ប៉ុន្តែថា សមគួរនឹងពោលដោយបរិយាយ យ៉ាងនេះថា "បពិត្រលោកម្ចាស់ដ៏ចម្រើន មនុស្សទាំងឡាយក្នុងស្រុកឈ្មោះឯណោះ ប្រាថ្នានូវការនិមន្តមករបស់ភិក្ខុទាំងឡាយ, បើលោកម្ចាស់ទាំងឡាយ ធ្វើសេចក្តីសង្គ្រោះដល់មនុស្សទាំងនោះ ជាការប្រពៃណាស់" ។

បទថា ន អារញ្ញិកង្គំ : មិន(ត្រូវសមាទាន)អារញ្ញិកធុតង្គ មានសេចក្តីថា កាលធុញទ្រាន់ក្នុងការប្រាប់ដល់ភិក្ខុទាំងឡាយ ដែលមកហើយ ៗ មិនគួរសមាទានអារញ្ញិកធុតង្គ ។

អារញ្ញិកធុតង្គនោះ សូម្បីភិក្ខុណា សមាទានហើយតាមប្រក្រតី ភិក្ខុនោះ គប្បីបបួលភិក្ខុជាសម្លាញ់ទទួលអរុណក្នុងព្រៃ, តែមិនគួរទៅ

តាមទំនើងចិត្តខ្លួនឯង ។

មួយទៀត កាលនៀយណាយចំពោះការអង្គុយលើអាសនៈចុងបង្អស់ ក្នុងរោងភត្តជាដើម មិនគួរសមាទានសូម្បីនូវបិណ្ឌបាតិកធុតង្គ តែមិនហាមដល់ភិក្ខុដែលកាន់បិណ្ឌបាតតាមប្រក្រតី ។

បទថា ន ច តប្បច្ចយា : ព្រោះបច្ច័យនោះទេ មានសេចក្តីថា មិនគួរឱ្យនាំបិណ្ឌបាតចេញទៅ ព្រោះហេតុនេះថា យើងជាអ្នកមានអាហារដែលនាំទៅ ហើយអង្គុយឆាន់នៅក្នុងកុដិនោះឯង ទីងរាប់រាត្រីបាន គឺថា វត្តិច្ឆេទ គប្បីមានដល់យើង ដែលទៅឃើញភិក្ខុមកក្នុងស្រុក ហើយមិនប្រាប់ ។

បទថា មា មំ ជានឹសុ : ជនទាំងឡាយ កុំដឹងរឿងអញឡើយ មានសេចក្តីថា លោកមិនគួរឱ្យសាមណេរជាដើម ចំអិន( ភត្ត )ហើយ ឆាន់ក្នុងវត្ត ដោយអធ្យាស្រ័យនេះថា សូម្បីតែភិក្ខុមួយរូប ចូរកុំដឹងយើង, គឺ គប្បីចូលស្រុកដើម្បីបិណ្ឌបាតនុ៎ះឯង ។ តែបារិវាសិកភិក្ខុដែលអាពាធ ឬអ្នកខ្វល់ខ្វាយក្នុងនវកម្ម និងកិច្ចរបស់អាចារ្យឧបជ្ឈាយ៍ជាដើម គួរនៅក្នុងកុដិជាទីនៅ ។ បើភិក្ខុច្រើនរយរូបត្រាច់ទៅក្នុងស្រុក មិនអាចនឹងប្រាប់បាន, គួរទៅកាន់គាមកាវាស ហើយនៅក្នុងទីនៃភិក្ខុដែលជាសភាគគ្នា ។ សូម្បីជាអាគន្តុកៈមកកាន់វត្តណា ក៏គប្បីប្រាប់ដល់

ភិក្ខុទាំងឡាយក្នុងវត្តនោះ ។ បើឃើញភិក្ខុទាំងអស់នៅក្នុងទីមួយជាមួយគ្នា គប្បីឈរប្រាប់ក្នុងទីជាមួយគ្នាតែម្តង បើភិក្ខុទាំងឡាយ បែកស្ទែកគ្នានៅតាមគល់ឈើជាដើម, គប្បីទៅប្រាប់ក្នុងទីនោះ ៗ ។ កាលដឹងហើយមិនប្រាប់ ជារត្តិច្ឆេទផង ត្រូវអាបត្តិទុក្កដព្រោះវត្តភេទផង បើគន់មើលមិនជួបពួកខ្លះ ត្រឹមតែជារត្តិច្ឆេទ មិនត្រូវអាបត្តិទុក្កដ ព្រោះវត្តភេទទេ ។

[៣២៤] បទថា **អាគន្តុកស្ស : ដល់អាគន្តុកផងគ្នា** មានសេចក្តីថា គប្បីប្រាប់ដល់ភិក្ខុអាគន្តុកៈមួយរូប ឬច្រើនរូប សូម្បីដែលមកកាន់កុដិជាលំនៅរបស់ខ្លួន តាមន័យដែលពោលហើយនុ៎ះឯង ។

មួយទៀត សូម្បីរត្តិច្ឆេទនិងវត្តភេទ ក្នុងអាគន្តុកាពេចនាធិការនេះក៏គប្បីជ្រាបតាមន័យដែលពោលហើយដូចគ្នា ។

បើភិក្ខុអាគន្តុកៈសម្រាកមួយភ្លែត ឬមិនសម្រាក មិនទៅក្នុងវត្តយ៉ាងនោះ, គួរប្រាប់សូម្បីដល់ភិក្ខុអាគន្តុកៈទាំងនោះ, បើភិក្ខុអាគន្តុកៈចេញទៅ ក្នុងកាលដែលបារិវាសិកភិក្ខុនោះមិនដឹង តែបើថា បារិវាសិកភិក្ខុនេះដឹងក្នុងវេលាដែលចេញទៅហើយ, គប្បីទៅប្រាប់ ។ កាលមិនអាចនឹងទៅទាន់ ក៏ត្រឹមតែជារត្តិច្ឆេទ មិនជាទុក្កដព្រោះវត្តភេទ ។

ចំណែកភិក្ខុអាគន្តុកៈពួកណា មិនចូលកាន់ខាងក្នុងវត្ត ចូលឧបចារៈសីមាហើយចេញទៅ, និងបារិវាសិកភិក្ខុនេះ បានឮសំឡេងឆត្រ ឬសំឡេងក្អក ឬសំឡេងកណ្តាស់របស់ភិក្ខុអាគន្តុកៈទាំងនោះ ដឹងថា ជា

អាគន្តុកៈ គប្បីទៅប្រាប់ ។ សូម្បីដឹងក្នុងវេលាដែលពួកលោកទៅហើយ ក៏គួរតាមទៅប្រាប់ឱ្យបាន កាលមិនអាចនឹងទៅទាន់ទេ ក៏ត្រឹមតែជាវត្តិច្ឆេទ មិនត្រូវអាបត្តិទុក្កដព្រោះវត្តភេទ ។

ចំណែកភិក្ខុអាគន្តុកៈណា មកក្នុងពេលយប់ហើយ ចេញទៅក្នុងពេលយប់នោះឯង សូម្បីភិក្ខុអាគន្តុកៈនោះ រមែងធ្វើឱ្យជាវត្តិច្ឆេទដល់បាវិវាសិកភិក្ខុនោះ ។ តែព្រោះមិនដឹង ទើបមិនមានអាបត្តិទុក្កដព្រោះវត្តភេទ ។

ក្នុងកុរុន្ទីពោលថា បើមិនដឹងធ្វើអញ្ញានកម្ម, អញ្ញានកម្មនោះ មិនឈ្មោះថា ធ្វើទេ ព្រោះហេតុនោះ គួររាប់រាត្រីឱ្យលើសទុក ហើយសឹមធ្វើអញ្ញានកម្ម ។ នេះជាការបដិបត្តិដែលមិនខុស ។

ឃើញភិក្ខុទៅកាន់ទូកក្នុងទន្លេជាដើមក្តី ឈរឯត្រើយខាងណោះក្តី ទៅក្នុងអាកាសក្តី តាំងនៅក្នុងទីឆ្ងាយមានភ្នំ លើគោក និងព្រៃជាដើមក្តី, បើមានសេចក្តីកំណត់បានថា ជាភិក្ខុ គប្បីទៅប្រាប់ដោយទូកជាដើមក៏បាន គប្បីប្រញាប់តាមទៅប្រាប់ក៏បាន ។ កាលមិនប្រាប់ ជាវត្តិច្ឆេទផង ត្រូវអាបត្តិទុក្កដព្រោះវត្តភេទផង ។ បើថា សូម្បីព្យាយាមហើយ ក៏មិនអាចនឹងទៅទាន់ ឬឱ្យបានឮ ត្រឹមតែជាវត្តិច្ឆេទ មិនត្រូវអាបត្តិទុក្កដព្រោះវត្តភេទ ។

ចំណែកព្រះសង្ឃសេនាភយត្ថេរៈ ពោលអំពីអំណាចនៃវិស័យ

និងអវិស័យថា បានឮថា កាលមិនប្រាប់ក្នុងវិស័យ (ដែលនិងប្រាប់បាន) ជាវត្តិច្ឆេទផង ត្រូវអាបត្តិទុក្កដព្រោះវត្តភេទផង, តែក្នុងអវិស័យមិនមាន (វត្តិច្ឆេទ និងវត្តភេទ) ទាំង ២ យ៉ាង ។

ចំណែកព្រះករវិកតិស្សត្ថេរៈ ពោលថា សេចក្តីកំណត់ថា "អ្នកនេះជាសមណៈ" នោះជាប្រមាណ ។ បើសូម្បីមិនមែនវិស័យ, មិនមានទុក្កដ ព្រោះវត្តភេទប៉ុណ្ណោះ តែគង់ជាវត្តិច្ឆេទពិត ។

បទថា ឧបោសថេ : ក្នុងថ្ងៃឧបោសថ មានសេចក្តីថា ពិតមែនភិក្ខុអាគន្តុកៈទាំងឡាយ រមែងមកដោយតាំងចិត្តថា យើងនឹងទាន់ឧបោសថ សូម្បីទៅដោយឫទ្ធិគប្បីជ្រាបថា ជាថ្ងៃឧបោសថ រមែងចុះធ្វើឧបោសថកម្ម ។ ព្រោះហេតុនោះ ទើបគួរប្រាប់ក្នុងថ្ងៃឧបោសថ ដើម្បីជម្រះអាគន្តុកៈ ។ សូម្បីក្នុងបវារណា ក៏មានន័យដូចគ្នា ។

ភិក្ខុអាពាធនោះ បានដល់ ភិក្ខុដែលមិនអាចនឹងទៅ ។

សូម្បីវិនិច្ឆ័យក្នុងពាក្យថា ទូតេន : ប្រើបម្រើទៅ នេះ គប្បីជ្រាបថា មិនគួរបញ្ជូនអនុបសម្បន្នទៅ ។ គប្បីបញ្ជូនភិក្ខុឱ្យទៅប្រាប់ ។

[៣២៥] បទថា អភិក្ខុកោ អាវាសោ : អាវាសដែលមិនមានភិក្ខុ បានដល់ វត្តដែលទំណេរ, ភិក្ខុសូម្បីមួយរូប មិនមានក្នុងវត្តណាមិនគប្បីទៅដើម្បីត្រូវការនៅក្នុងវត្តនោះ ព្រោះរាត្រីដែលនៅក្នុងវត្តទទេ

នោះ ជារាត្រីដែលមិនល្មមឱ្យរាប់ ។ តែទីងនៅជាមួយភិក្ខុបកតត្ត សម គួរ ។ តែកាលអន្តរាយ ១០ យ៉ាងមាន សូម្បីថា រាត្រីទាំងឡាយនឹង មិនល្មមឱ្យរាប់ ក៏គួរចេញទៅ ដើម្បីផុតពីអន្តរាយពិត ។ ព្រោះហេតុ នោះ ទើបព្រះមានព្រះភាគត្រាស់ថា វៀរតែអន្តរាយ ដូច្នេះ ទើបមិនគួរ ធ្វើវិន័យកម្មដល់ភិក្ខុដែលជានានាសំវាស ។ សូម្បីព្រោះមិនប្រាប់ដល់ ភិក្ខុនានាសំវាសទាំងនោះ វត្តច្ឆេទ រមែងមិនមាន, ទីលំនៅនោះ រមែង ដូចគ្នានឹងអាវាសមិនមានភិក្ខុទុះឯង ព្រោះហេតុនោះ ទើបព្រះមានព្រះ ភាគត្រាស់ពាក្យនេះថា ក្នុងអាវាសណា ភិក្ខុទាំងឡាយជានានាសំវាស ?

ពាក្យដ៏សេស មានន័យដូចពោលហើយ ក្នុងឧបោសថក្ខន្ធកៈទុះ ឯង ។

[៣២៨] វិនិច្ឆ័យក្នុងបទថា **ឯកច្ចន្នេ អាវាសេ : ក្នុងអាវាស ដែលមានដំបូលតែមួយ** ជាដើម គប្បីជ្រាបដូច្នេះ ៖

សេនាសនៈ ដែលធ្វើទុកដើម្បីប្រយោជន៍ ដល់ការនៅ ឈ្មោះថា អាវាស ។

ស្ថានទីមានជាដើមយ៉ាងនេះ គឺ ចេតិយ រោងពោធិ រោងដាក់ អំបោស រោងដាក់ឈើ រោងទឹក វច្ចកុដិ ស៊ុមទ្វារ ឈ្មោះថា អនា វាស ។

ទាំង ២ ប្រភេទនៃអាវាសនិងអនាវាសនោះ ព្រះមានព្រះភាគ

ទ្រង់កាន់យកដោយបទទី ៣ ។

ក្នុងមហាបច្ចរី ពោលថា ភិក្ខុដែលត្រូវសង្ឃលើកវត្តហើយ មិនគួរនៅក្នុងឱកាសទាំងនេះ ណាមួយ ទីប្រក់តែមួយ កំណត់ដោយទីធ្លាក់ចុះនៃទឹកពីសំយ៉ាប (កុដិ) ។ តែបារិវាសិកភិក្ខុ មិនបានដើម្បីនៅខាងក្នុងអាវាសប៉ុណ្ណោះ ។

ចំណែកមហាអដ្ឋកថាពោលថា ការនៅនោះ ហាមដោយសំយ៉ាប (កុដិ) ដោយមិនប្លែកគ្នា ។

ក្នុងកុរុន្ទីពោលថា ការដែលបារិវាសិកភិក្ខុ និងភិក្ខុដែលត្រូវសង្ឃលើកវត្តនៅរួមនឹងភិក្ខុបកតត្ត ក្នុងទីប្រក់ដោយគ្រឿងប្រក់ ៥ យ៉ាងទាំងនោះ លោកហាមដោយសំយ៉ាប (កុដិ) ។

ព្រោះហេតុនោះ បារិវាសិកភិក្ខុ មិនគួរនៅក្នុងទីប្រក់តែមួយជាមួយគ្នា សូម្បីមានឧបចារៈផ្សេងគ្នា ។ ក៏បើថា ភិក្ខុជាបកតត្ត សូម្បីឧបសម្បទាក្នុងថ្ងៃនោះ ចូលទៅដេកមុនក្នុងឱកាសដែលប្រក់ជាមួយគ្នានេះ បារិវាសិកភិក្ខុ សូម្បីមានវស្សា ៦០ ចូលទៅពេលក្រោយដឹងក៏ដេកជារត្តិច្ឆេទផង ត្រូវអាបត្តិទុក្កដ ព្រោះវត្តភេទផង ។ កាលមិនដឹង ត្រឹមតែជារត្តិច្ឆេទ មិនត្រូវអាបត្តិទុក្កដ ព្រោះវត្តភេទ ។ តែបើកាលបារិវាសិកភិក្ខុនោះដេកមុន ភិក្ខុជាបកតត្តចូលទៅដេកខាងក្រោយ, ទិនបារិវាសិកភិក្ខុក៏បានដឹង, ជារត្តិច្ឆេទផង ត្រូវអាបត្តិទុក្កដ ព្រោះវត្តភេទផង ។ បើ

មិនដឹង, ត្រឹមតែជាវត្តច្ឆេទ មិនត្រូវអាបត្តិទុក្កដ ព្រោះវត្តភេទ ។

ពីរបទថា **វុដ្ឋាតព្វំ និមន្តេតព្វោ** : **ត្រូវក្រោក ត្រូវនិមន្ត** មានសេចក្ដីថា បារិវាសិកភិក្ខុ ឃើញភិក្ខុបកតត្ត សូម្បីឧបសម្បទាក្នុងថ្ងៃនោះ គប្បីក្រោកឡើងពិត, និងគ្រាក្រោកឡើងហើយ មិនគប្បីគេចចេញទៅដោយគិតថា យើងអង្គុយសប្បាយហើយ ភិក្ខុនេះធ្វើឱ្យយើងត្រូវក្រោក ។ ភិក្ខុបកតត្តនោះ ដែលលោកគប្បីនិមន្តយ៉ាងនេះថា លោកអាចារ្យ នេះអាសនៈ, និមន្តអង្គុយលើអាសនៈនេះ ។ ចំណែកនវកភិក្ខុបកតត្ត មិនគួរទៅកាន់សំណាក់ព្រះថេរៈដែលនៅបរិវាសដោយតាំងចិត្តថា យើងនឹងធ្វើព្រះមហាថេរៈឱ្យជាអ្នកអៀនអន់ចិត្ត ។

បទថា **ឯកាសនេ** : **លើអាសនៈមួយ** មានសេចក្ដីថា លើគ្រែ ឬតាំង ដែលជាទីអង្គុយនៃភិក្ខុដែលមានវស្សាប៉ុណ្ណោះ ។

បទថា **ន ឆមាយំ និសិន្នេ** : **អង្គុយលើផែនដី មិន...** មានសេចក្ដីថា កាលភិក្ខុជាបកតត្ត អង្គុយលើផែនដី ចំណែកបារិវាសិកភិក្ខុមិនគប្បីអង្គុយលើអាសនៈ ដោយហោចទៅសូម្បីជាកម្រាលស្មៅ ឬសូម្បីជាពុំនូកខ្សាច់ដែលខ្ពស់ជាង តែនឹងអង្គុយវៀរឧបចារៈទុក ១២ ហត្ថ គួរ ។

បទថា **ន ឯកចង្កមេ** : **ក្នុងទីចង្រ្កមមួយទេ** មានសេចក្ដីថា មិនគួរចង្រ្កម ក្នុងទីចង្រ្កមជាមួយនឹងភិក្ខុជាបកតត្ត ធ្វើហាក់ដូចជា

សម្លាញ់គ្នា ។

ពាក្យថា ឆមាយំ ចង្កមតិ : ចង្ក្រមលើផែនដី មានសេចក្តីថា កាលភិក្ខុបកតត្តចង្ក្រមនៅលើផែនដី ។

ម្យ៉ាងទៀត នេះឯងជាបាលី ។ និងគប្បីជ្រាបសេចក្តីក្នុងពាក្យនេះដូចតទៅ ៖

កាលភិក្ខុជាបកតត្តចង្ក្រមនៅលើផែនដី ដែលមិនបានរៀបរយល្អ មិនគប្បីចង្ក្រមក្នុងទីចង្ក្រមដែលរៀបរយ កៀរខ្សាច់ ប្រកបស្នូរដើមាំសូម្បីជាទីទាបជាង នឹងមិនបាច់ត្រូវពោលថ្វីក្នុងទីចង្ក្រម ដែលព្រមសម្រេចដោយការបូកឥដ្ឋ ទាំងព័ទ្ធដោយកំផែងកែវ ។ តែបើមានចង្ក្រមដែលព័ទ្ធដោយកំផែង ប្រកបដោយស៊ុមទ្វារ ឬថា មានទីចង្ក្រមដែលបិទបាំងល្អ ក្នុងចន្លោះភ្នំ ចន្លោះព្រៃ និងចន្លោះ គុម្ពឈើ ; នឹងចង្ក្រមក្នុងទីចង្ក្រមដូច្នោះ សមគួរ, និងវៀរឧបចារៈចង្ក្រមក្នុងទីចង្ក្រមសូម្បីមិនបានបិទបាំង ក៏គួរ ។

[៣២៩] វិនិច្ឆ័យក្នុងពាក្យថា វុឌ្ឍតរេន : ដែលចាស់ជាងខ្លួននេះ គប្បីជ្រាបដូច្នេះ ៖

ក្នុងកុរុន្ទីពោលថា បើកាលបារិវាសិកភិក្ខុដែលចាស់ជាងដេកមុនចំណែកបារិវាសិកភិក្ខុ (ភិក្ខុខ្ចីជាង)ដឹងហើយ ដេកខាងក្រោយ ភិក្ខុនោះ ជារត្តិច្ឆេទផង ត្រូវអាបត្តិទុក្កដ ព្រោះវត្តភេទដល់លោកផង តែ

សម្រាប់បារិវាសិកភិក្ខុដែលចាស់ជាង ត្រឹមតែជារត្តិច្ឆេទ មិនត្រូវអាបត្តិទុក្កដព្រោះវត្តភេទទេ ។ ភិក្ខុខ្ចីជាងមិនដឹង សូម្បីកាលដេក, មិនជាវត្តភេទដូចគ្នាទាំង ២ ផ្នែក, តែជារត្តិច្ឆេទ ។ បើកាលបារិវាសិកភិក្ខុដែលខ្ចីដេកមុន ភិក្ខុចាស់ជាងទើបដេក, និងភិក្ខុខ្ចីជាងដឹង, ភិក្ខុនោះ រមែងដាច់រាត្រីផង ត្រូវអាបត្តិទុក្កដព្រោះវត្តភេទផង ។ ចំណែកភិក្ខុចាស់ជាងត្រឹមតែជារត្តិច្ឆេទ មិនជាវត្តភេទ ។ បើភិក្ខុខ្ចីជាង មិនដឹង, មិនជាវត្តភេទដូចគ្នាទាំង ២ ផ្នែក តែគង់ជារត្តិច្ឆេទ បើទាំង ២ ផ្នែកដេកមិនមុនមិនក្រោយគ្នា, ភិក្ខុចាស់ជាងត្រឹមតែជារត្តិច្ឆេទ ។ ចំណែកភិក្ខុខ្ចីជាងជារត្តិច្ឆេទផង ជាវត្តភេទផង ។

បារិវាសិកភិក្ខុ ២ រូប មានវស្សាប៉ុនគ្នា មួយរូបដេកមុន មួយរូបដឹងប្រាកដ ដេកខាងក្រោយ, រាត្រីរបស់ភិក្ខុដែលដេកក្រោយ រមែងដាច់ និង ត្រូវអាបត្តិទុក្កដ ព្រោះវត្តភេទដល់លោកផង ។ សម្រាប់ភិក្ខុដេកមុន ត្រឹមតែជារត្តិច្ឆេទ មិន ជាវត្តភេទ ។ បើសូម្បីភិក្ខុដេក ពេលក្រោយក៏មិនដឹង មិនមានវត្តភេទជាមួយគ្នាទាំង ២ ផ្នែក, តែគង់ជារត្តិច្ឆេទ ។ បើសូម្បីទាំង ២ ចំណែកដេក មិនមុន មិនក្រោយគ្នា ។ ជារត្តិច្ឆេទប៉ុណ្ណោះ មិនជាវត្តភេទទាំង ២ ផ្នែក ។

ក៏បើបារិវាសិកភិក្ខុ ២ រូបគប្បីនៅជាមួយគ្នា ។ លោកគប្បីដឹងអជ្ឈាចាររបស់គ្នានិងគ្នា គប្បីជាអ្នកមិនគោរព ឬមានសេចក្តីក្តៅ

ក្រោយ ហើយត្រូវអាបត្តិដែលអាក្រក់ជាង ឬស្ទឹកចេញ ព្រោះហេតុនោះ ការដេករួមគ្នារបស់ពួកលោក ទើបព្រះមានព្រះភាគទ្រង់ហាមដោយប្រការទាំងពួង ដូច្នេះឯង ។

ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។

និងក្នុងបារិវាសិកវត្តាធិការនេះ ភិក្ខុដែលគួរដល់មូលាយបដិកស្សនាជាដើម គប្បីជ្រាបថា តាំងនៅក្នុងឋានរបស់ភិក្ខុជាបកតត្តរបស់បារិវាសិកភិក្ខុជាដើម ។

[៣៣០] វិនិច្ឆ័យក្នុងពាក្យថា ចារិវាសិកចតុត្ថោ ចេ ភិក្ខវេ បរិវាសំ ទទេយ្យ : ម្នាលភិក្ខុទាំងឡាយ បើគណៈសង្ឃមានបារិវាសិកភិក្ខុជាគម្រប់ ៤ ឱ្យបរិវាស នេះ គប្បីជ្រាបដូច្នេះ ៖

ការដែលសង្ឃធ្វើបារិវាសិកភិក្ខុឱ្យជាគម្រប់ ៤ ធ្វើកម្មមានឱ្យបរិវាសជាដើម ដល់គ្នានិងគ្នា យកជាការមិនបានដោយពិត ។ ក្នុងកម្មមានឱ្យបរិវាសជាដើម ទាំងនេះប៉ុណ្ណោះ ដែលបារិវាសិកភិក្ខុនេះ ជាគណបូរកៈមិនបាន, ក្នុងសង្ឃកម្មដ៏សេស ជាគណបូរកៈបាន និងកាលគណៈមិនគ្រប់ គប្បីឱ្យបារិវាសិកភិក្ខុដាក់វត្តហើយ ទើបធ្វើឱ្យជាគណបូរកៈដូច្នេះឯង ។

បារិវាសិកវត្តកថា ចប់

# បរិវាសកថា

[៣៣១] ក៏ព្រោះបានស្តាប់វត្តកថានេះ ព្រះឧបាលីថេរៈជាអ្នកទ្រទ្រង់វិន័យ នៅក្នុងទីពួនសម្ងំ ទើបបានកើតការរំពឹងយ៉ាងនេះថា វត្តសម្រាប់ភិក្ខុដែលនៅបរិវាស ព្រះមានព្រះភាគទ្រង់បញ្ញត្តិទុកច្រើន, ក្នុងវត្តនេះ ការដាច់រាត្រីរបស់បារិវាសិកភិក្ខុមានប៉ុន្មានហ្ន៎ ?

ទើបព្រះថេរៈចូលគាល់ព្រះមានព្រះភាគ ទូលសួរសេចក្តីនោះ ។ សូម្បីព្រះមានព្រះភាគក៏បានទ្រង់ព្យាករណ៍ដល់ព្រះថេរៈ ។

ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា អថ ខោ អាយស្មា ឧបាលិ ។ល។ បារិវាសិកស្ស ភិក្ខុនោ រត្តិច្ឆេទា : **គ្រានោះព្រះឧបាលិមានអាយុ ។ល។ ការដាច់រាត្រីរបស់បារិវាសិកភិក្ខុមានប៉ុន្មាន** ដូច្នេះ ។

ក្នុង៣ យ៉ាងនោះ ដែលឈ្មោះថា **ការនៅរួមគ្នា** បានដល់ ការនៅជាមួយគ្នា ដែលព្រះមានព្រះភាគត្រាស់ទុក ដោយន័យមានពាក្យជាដើមថា "បកតត្តេន ភិក្ខុនា សទ្ធឹ ឯកច្ឆន្នេ : **ក្នុងទីដែលមានដំបូលតែមួយ ជាមួយនឹងភិក្ខុជាបកតត្ត**" ក្នុង[៣២៨] ។

ដែលឈ្មោះថា នៅប្រាសចាក បានដល់ ការនៅរបស់ភិក្ខុតែមួយរូបប៉ុណ្ណោះ ។

ដែលឈ្មោះថា មិនប្រាប់ បានដល់ មិនប្រាប់ភិក្ខុអាគន្តុកៈ ជា

ដើម ។

វត្តច្ឆេទ រមែងមានដោយហេតុម្យ៉ាង ៗ ក្នុងហេតុ ៣ យ៉ាងនេះ ។

[៣៣២] ពាក្យថា ន សក្កោន្តិ : **មិនអាច** មានសេចក្ដីថា កាលមិនអាចទៅ ប្រាប់ដល់ភិក្ខុទាំងពួងក្នុងទីនោះ ៗ ព្រោះភាពនៃសង្ឃធំ ឈ្មោះថា មិនអាចនឹងញ៉ាំងបរិវាសឱ្យបរិសុទ្ធិបាន ។

ក្នុងពីរបទនេះ គឺ **បរិវាសំ និក្ខិបាមិ** ខ្ញុំព្រះករុណាសូមដាក់នូវបរិវាស ១, **វត្តំ និក្ខិបាមិ** ខ្ញុំព្រះករុណាសូមដាក់នូវវត្ត ១ ; សូម្បីដាក់ដោយបទមួយ ៗ ឈ្មោះថា ដាក់បរិវាស, ដាក់ដោយបទទាំង ២ ឈ្មោះថា ដាក់រៀបរយពិត ។ សូម្បីក្នុងការសមាទាន ក៏មានន័យដូចគ្នា ។ ភិក្ខុដែលសមាទានវត្ត នៅបរិវាសសម្រេចយ៉ាងនោះហើយ កាលនឹងកាន់មានត្ត មិនមានកិច្ចដែលនិងត្រូវសមាទានវត្តទៀត ។

ពិតមែន ភិក្ខុអង្គុយគង់ជាអ្នកសមាទានវត្តនុ៎ះឯង, ព្រោះហេតុនោះ សង្ឃគប្បីឱ្យមានត្ត ៦ រាត្រីដល់លោក, លុះលោកប្រព្រឹត្តមានត្តហើយគប្បីធ្វើអព្ភាន ។ លោកជាអ្នកមិនមានអាបត្តិ តាំងនៅក្នុងចំណែកនៃអ្នកបរិសុទ្ធយ៉ាងនោះហើយ នឹងបំពេញត្រៃសិក្ខា ធ្វើទីបំផុតនៃទុក្ខបាន ដោយប្រការដូច្នេះ ។

បរិវាសកថា ចប់

# បកតត្តរបស់គ្នានិងគ្នា

[៣៣៤] ពាក្យថា មូលាយ បដិកស្សនារហា ភិក្ខូ សាទិយន្តិ បកតត្តានំ : ពួកភិក្ខុដែលគួរដល់មូលាយបដិកស្សនា ត្រេកអរនឹង... របស់ភិក្ខុជាបកតត្តទាំងឡាយ មានសេចក្តីថា វៀរលែងតែភិក្ខុដែលគួរដល់មូលាយបដិកស្សនា ខ្ចីជាងចេញ បានដល់ ភិក្ខុទាំងឡាយដ៏សេស ដោយហោចទៅសូម្បីភិក្ខុដែលនៅបរិវាសជាដើម ។

ពិតមែន បណ្ដាភិក្ខុ ៥ ពួក គឺ ភិក្ខុដែលនៅបរិវាស ១ ភិក្ខុដែលគួរដល់មូលាយបដិកស្សនា ១ ភិក្ខុដែលគួរដល់មានត្ត ១ ភិក្ខុដែលប្រព្រឹត្តមានត្ត ១ ភិក្ខុដែលគួរដល់អព្ភាន ១ ទាំងនេះ វៀរភិក្ខុដែលខ្ចីជាងរបស់ខ្លួនចេញ ដ៏សេសទាំងអស់គង់ចាត់ជាភិក្ខុបកតត្ត ។

ព្រោះហេតុអ្វី ?

ព្រោះហេតុដែលការអភិវាទជាដើម ព្រះមានព្រះភាគទ្រង់អនុញ្ញាតតាមលំដាប់ គឺ តាមភិក្ខុចាស់ ៗ ព្រោះហេតុនោះ ទើបខ្ញុំព្រះករុណាពោលថា បានដល់ ភិក្ខុទាំងឡាយដ៏សេស ដោយហោចទៅ សូម្បីភិក្ខុដែលនៅបរិវាសជាដើម ។ ចំណែកលក្ខណៈនៃភិក្ខុដែលគួរដល់មូលាយបដិកស្សនាជាដើមទាំងនោះ នឹងមានជាក់ច្បាស់ខាងមុខ ។

ពាក្យដ៏សេសក្នុងអធិការ ពោលអំពីភិក្ខុ ដែលគួរដល់មូលាយបដិកស្សនា ត្រេកអរអភិវាទជាដើមរបស់ភិក្ខុបកតត្តនេះ គប្បីជ្រាបតាម

ន័យដែលពោលហើយ ក្នុងវត្តរបស់ភិក្ខុដែលគួរដល់មានត្តជាដើម សូម្បីដទៃក្រៅពីអធិការនេះ និងក្នុងវត្តរបស់បារិវាសិកភិក្ខុនុ៎ះឯង ។

[៣៤៣] វិនិច្ឆ័យសូម្បីក្នុងពាក្យថា មូលាយបដិកស្សនារហា-ចតុត្ថោ ចេ : បើគណៈសង្ឃមានមូលាយបដិកស្សនារហភិក្ខុជាគម្រប់ ៤ ជាដើមគប្បីជ្រាបដូច្នេះ ៖

សូម្បីភិក្ខុដែលគួរដល់មូលាយបដិកស្សនាទាំងនោះ រមែងជាគណបូរកៈ ក្នុងវិន័យកម្មទាំងនោះមិនបាន ដូចបារិវាសិកភិក្ខុដូច្នោះឯង ។ ក្នុងសង្ឃកម្មដ៏សេស ជាគណបូរកៈបាន ។

សេចក្ដីប្លែកគ្នាក្នុងវត្តរបស់មានត្តចារិកភិក្ខុ គឺ មានត្តចារិកភិក្ខុត្រូវប្រាប់រាល់ថ្ងៃ ។

[៣៦៥] ភិក្ខុ ៤ រូប ឬច្រើនជាងនោះ ឈ្មោះថា គណៈ ក្នុងពាក្យថា ឩនេ គណេ : ក្នុងពួកបកតត្តភិក្ខុមិនគ្រប់ចំនួន នេះ ក្នុងពួករត្តិច្ឆេទ ។ ព្រោះហេតុនោះ បើសូម្បីមានត្តចារិកភិក្ខុ នៅជាមួយភិក្ខុ ៣ រូប ជារត្តិច្ឆេទតែម្តង ។

[៣៦៦-៧] ក្នុងការដាក់និងសមាទានមានត្ត វិនិច្ឆ័យដូចដែលពោលហើយនុ៎ះឯង ។ ពាក្យដ៏សេសគ្រប់ ៗ កន្លែងងាយយល់ទាំងអស់ដោយប្រការដូច្នេះ ។

បារិវាសិកក្ខន្ធកវណ្ណនា ចប់

# ១៣. សមុច្ចយក្ខន្ធកវណ្ណនា

## មានត្ត ៤ យ៉ាង

វិនិច្ឆ័យក្នុងសមុច្ចយក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

[៣៧៨] ពាក្យថា ឆារត្តំ មានត្តំ : មានត្ត ៦ រាត្រី នេះ មានវិនិច្ឆ័យថា មានត្ត ៤ យ៉ាង គឺ អប្បដិច្ឆន្នមានត្ត ១ បដិច្ឆន្នមានត្ត ១ បក្ខមានត្ត ១ សមោធានមានត្ត ១ ។

ក្នុងមានត្ត ៤ យ៉ាងនោះ ដែលឈ្មោះអប្បដិច្ឆន្នមានត្ត បានដល់ មានត្តដែលសង្ឃឲ្យភិក្ខុដែលគួរដល់មានត្ត ដោយភាពជាអ្នកត្រូវអាបត្តិសុទ្ធប៉ុណ្ណោះ មិនត្រូវឲ្យបរិវាស ដើម្បីអាបត្តិដែលមិនបានបិទបាំងទុក ។

ដែលឈ្មោះបដិច្ឆន្នមានត្ត បានដល់ មានត្តដែលសង្ឃឲ្យដល់ភិក្ខុដែលនៅបរិវាសរួចហើយ ដើម្បីអាបត្តិដែលបិទបាំងទុក ។

ដែលឈ្មោះបក្ខមានត្ត បានដល់ មានត្តកន្លះខែដែលសង្ឃឲ្យដល់ភិក្ខុនី ដើម្បីអាបត្តិដែលបិទបាំងទុក ឬមិនបានបិទបាំងទុក ។

ដែលឈ្មោះសមោធានមានត្ត បានដល់ មានត្តដែលសង្ឃរួម គឺផ្សំគ្នាឲ្យ ។

# អប្បដិច្ឆន្នមានត្ត

បណ្តាមានត្ត ៤ យ៉ាងនោះ អប្បដិច្ឆន្នមានត្តនេះ គប្បីជ្រាបថា ជាអប្បដិច្ឆន្នមានត្ត តាមព្រះបាលីថា ឆារត្តំ មានត្តំ **:** មានត្ត ៦ រាត្រី ដើម្បីអាបត្តិដែលមិនបិទបាំងទុក ។ កាលនឹងឱ្យអប្បដិច្ឆន្នមានត្តនោះ បើភិក្ខុជាអ្នកត្រូវអាបត្តិតែមួយ គប្បីឱ្យតាមន័យដែលពោលហើយ ក្នុងអប្បដិច្ឆន្នមានត្តនោះចុះ ។

បើត្រូវអាបត្តិ ២ ឬ ៣ ឬក្រៃលែងជាងនោ; ពាក្យថា ឯកំ អាបត្តឹ **:** អាបត្តិ ១ ដែលលោកពោលហើយយ៉ាងណា ។ ពាក្យថា ទ្វេ អាបត្តិយោ; តិស្សោ អាបត្តិយោ ក៏គប្បីពោលដូច្នោះ ។ តែដែលក្រៃលែងជាងនោះ បើសូម្បីមានចំនួនមួយរយ ឬចំនួនមួយពាន់, គប្បីពោលថា សម្ពហុលា **:** ច្រើន ។

[៣៧៩] វិធីឱ្យសម្រាប់អាបត្តិទាំងនេះ ដែលសង្ឃគប្បីរួមអាបត្តិ សូម្បីមានវត្ថុផ្សេង ៗគ្នាឱ្យ ខ្ញុំព្រះករុណានឹងពោលក្នុងការឱ្យបរិវាស ។

កាលមានត្ត ដែលសង្ឃធ្វើកម្មវាចាដោយអំណាចនៃអាបត្តិឱ្យហើយយ៉ាងនោះ មានត្តចារិកភិក្ខុគប្បីសមាទានវត្ត តាមន័យដែលពោលហើយថា មានត្តំ សមាទិយាមិ, វត្តំ សមាទិយាមិ **:** ខ្ញុំព្រះករុណាសូមសមាទាននូវមានត្ត, ខ្ញុំព្រះករុណាសូមសមាទាននូវវត្ត, ដូច្នេះ ទុះ

ឯង ត្រង់សីមានៃរោងតែម្ដង ក្នុងទីបំផុតនៃកម្មវាចាថា **ឯវមេតំ ធារយាមិ : ខ្ញុំព្រះករុណាសូមចាំសេចក្ដីនេះទុក ដោយអាការស្ងៀម យ៉ាងនេះ ។**

កាលសមាទានហើយ គប្បីប្រាប់ដល់សង្ឃក្នុងសីមានៃរោងនោះតែម្ដង និងកាលប្រាប់ គប្បីប្រាប់យ៉ាងនេះថា "បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិមួយ ឈ្មោះសញ្ចេតនិកាសុក្កវិស្សដ្ឋិ មិនបានបិទបាំងទុក, ខ្ញុំព្រះករុណានោះ បានសូមហើយនូវមានត្ត ៦ រាត្រី អំពីសង្ឃ ដើម្បីអាបត្តិមួយ ឈ្មោះសញ្ចេតនិកាសុក្កវិស្សដ្ឋិ ដែលមិនបិទបាំងទុក; សង្ឃបានឱ្យហើយនូវមានត្ត ៦ រាត្រី ដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិមួយ ឈ្មោះសញ្ចេតនិកាសុក្កវិស្សដ្ឋិ ដែលមិនបានបិទបាំង; បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណានោះ កំពុងប្រព្រឹត្តនូវមានត្ត, បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាសូមប្រាប់វត្ត សូមសង្ឃចាំទុកថា ភិក្ខុនេះ បានប្រាប់វត្ត" ។ ក៏បើនឹងកាន់យកសេចក្ដីនេះ ប្រាប់ដោយវាចាយ៉ាងណាមួយ សមគួរដូចគ្នា ។ កាលប្រាប់ហើយ បើមានប្រាថ្នានឹងដាក់ គប្បីដាក់នៅកណ្ដាលសង្ឃ តាមន័យដែលពោលហើយនុ៎ះឯង ។ កាលភិក្ខុទាំងឡាយ ចេញចាកសីមានៃរោងចេញទៅ នឹងដាក់ក្នុងសំណាក់ភិក្ខុមួយរូប ក៏គួរ ។ ភិក្ខុដែលចេញចាកសីមានៃរោងទៅហើយ ទើប

ត្រឡប់បានសតិ គប្បីដាក់ក្នុងសំណាក់ភិក្ខុដែលទៅ ជាមួយគ្នា ។ បើភិក្ខុសូម្បីនោះ ក៏ជៀសចេញទៅ មិនទាន់បានប្រាប់ដល់ភិក្ខុដទៃ, ភិក្ខុណា ដែលនៅក្នុងវេន គប្បីប្រាប់ដល់ភិក្ខុនោះឱ្យដឹងហើយដាក់ចុះនិងកាលប្រាប់ គប្បីពោលថា វេទិយតីតិ មំ អាយស្មា ធារេតុ : សូមលោកមានអាយុចាំខ្ញុំព្រះករុណាទុកថា ប្រាប់ឱ្យដឹង ដូច្នេះ ក្នុងអវសាន ។

កាលទឹងប្រាប់ដល់ភិក្ខុ ២ រូប គប្បីពោលថា អាយស្មន្តា ធារេន្តុ ។ កាលទឹងប្រាប់ដល់ភិក្ខុ ៣ រូប គប្បីពោលថា អាយស្មន្តោ ធារេន្តុ ។ ចាប់ផ្ដើមតាំងពីវេលាដែលដាក់ហើយទៅ គង់តាំងនៅក្នុងឋានជាបកតត្ត ។

បើវត្តមានភិក្ខុតិច, ភិក្ខុជាសភាគគ្នា; មិនត្រូវដាក់វត្ត រាប់រាត្រីក្នុងខាងក្នុងវត្តនុ៎ះឯង ។ បើមិនអាចធ្វើឱ្យបរិសុទ្ធិ ។ គប្បីដាក់វត្តតាមន័យដែលពោលហើយនុ៎ះឯង ព្រមដោយភិក្ខុ ៤ រូប ឬ ៥ រូប ចៀសចេញពីមកធំអង្គុយក្នុងទីកំបាំងដោយគុម្ពឈើ ឬដោយរបង ឱ្យហួស ២ លេណ្ឌុបាទ អំពីរបងនៃវត្តដែលលោមព័ទ្ធ អំពីទីគួរដល់របងនៃវត្តដែលអត់របង ក្នុងវេលាជិតភ្លឺ ។ គប្បីសមាទានវត្ត ហើយប្រាប់វត្តតាមន័យដែលពោលហើយនុ៎ះចុះ ក្នុងពេលមុនអរុណរះ ។

បើភិក្ខុជទៃមកទីនោះ ដោយកិច្ចជាចាំបាច់យ៉ាងណាមួយ ; បើមានត្តចារិកភិក្ខុនោះ ឃើញភិក្ខុនោះ ឬបានឮសំឡេងរបស់លោក, គួរប្រាប់ កាលមិនប្រាប់ ជារត្តិច្ឆេទ និងជាវត្តភេទ ។

បើភិក្ខុនោះកន្លងឧបចារៈចូលទៅ ១២ ហត្ថហើយចេញទៅ តែកាលមានត្តចារិកភិក្ខុមិនទាន់ដឹង, មានតែរត្តិច្ឆេទប៉ុណ្ណោះ ចំណែកវត្តភេទមិនមាន ។

ក៏ចាប់តាំងពីកាលដែលបានប្រាប់ហើយទៅ មានភិក្ខុទាំងឡាយវៀរភិក្ខុទុកមួយរូប ដ៏សេសទឹងចេញទៅ ក្នុងកាលមានកិច្ចចាំបាច់ក៏គួរ គ្រាអរុណរះហើយ គប្បីដាក់វត្តក្នុងសំណាក់ភិក្ខុនោះ ។ បើភិក្ខុសូម្បីនោះ ចេញទៅមុនអរុណរះ ដោយកិច្ចអ្វីមួយ មានត្តចារិកភិក្ខុឃើញភិក្ខុណាមុន ទឹងជាភិក្ខុជទៃដែលចេញចាកវត្តទៅក៏ដោយ ជាអាគន្តុកៈក៏ដោយ គប្បីប្រាប់ហើយដាក់វត្ត ក្នុងសំណាក់ភិក្ខុនោះ ។

ក៏មានត្តចារិកភិក្ខុនេះ ប្រាប់ដល់គណៈនិងចាំកំណត់សេចក្ដីដែលមានភិក្ខុច្រើនរូប, ដោយហេតុនោះ ទោសព្រោះប្រព្រឹត្តក្នុងគណៈមិនគ្រប់ ឬទោសព្រោះនៅប្រាសចាក ទើបមិនមានដល់លោក ។

ព្រះមហាសុមត្ថេរៈពោលថា បើមិនឃើញភិក្ខុណាទេ, គប្បីទៅកាន់វត្ត ហើយដាក់ក្នុងសំណាក់ភិក្ខុមួយរូប ក្នុងបណ្ដាភិក្ខុដែលទៅជាមួយខ្លួន ។

ចំណែកព្រះមហាបទុមថេរៈពោលថា ឃើញភិក្ខុណាមុន, គប្បីប្រាប់ហើយដាក់ក្នុងសំណាក់ភិក្ខុនោះ, នេះជាបរិហាររបស់ភិក្ខុដែលដាក់វត្តហើយ ។

[៣៨០] ភិក្ខុនោះគ្រាប្រព្រឹត្តមានត្ត ៦ រាត្រីមិនដាច់យ៉ាងនោះហើយ គប្បីសូមអព្ភានក្នុងទីដែលមានភិក្ខុសង្ឃជាគណៈ ២០ រូប ។ និងភិក្ខុទាំងឡាយដែលនឹងត្រូវធ្វើអព្ភាន គប្បីធ្វើភិក្ខុនោះ ឱ្យជាភិក្ខុដែលគួរដល់អព្ភានជាមុន ។

ពិតមែន ភិក្ខុនេះឈ្មោះថា តាំងនៅក្នុងឋានជាបកតត្តភិក្ខុ ព្រោះលោកដាក់វត្តហើយ ។ នឹងធ្វើអព្ភានដល់បកតត្តភិក្ខុ រមែងមិនគួរ ។ ព្រោះដូច្នោះ គប្បីឱ្យភិក្ខុនោះ សមាទានវត្ត ។ ភិក្ខុនោះ រមែងជាភិក្ខុដែលគួរដល់អព្ភាន ក្នុងកាលសមាទានវត្តហើយ ។ សូម្បីភិក្ខុនោះគប្បីសមាទានវត្តហើយប្រាប់ ហើយសូមអព្ភាន ។ កិច្ចដែលនឹងត្រូវសមាទានវត្តទៀត រមែងមិនមានដល់ភិក្ខុដែលមិនបានដាក់វត្ត ។

ពិតមែន ភិក្ខុដែលមិនបានដាក់វត្តនោះ ជាភិក្ខុដែលគួរដល់អព្ភានដោយកន្លង ៦ រាត្រីប៉ុណ្ណោះ, ព្រោះហេតុនោះ ភិក្ខុនោះ ដែលសង្ឃគប្បីធ្វើអព្ភាន ។

[៣៨១] អព្ភានវិធីក្នុងអប្បដិច្ឆន្នាបត្តិនោះ ព្រះមានព្រះភាគត្រាស់ទុកក្នុងព្រះបាលីថា ឯវញ្ច បន ភិក្ខវេ អព្ភេតព្វោ : ម្នាលភិក្ខុ

ទាំងឡាយ សង្ឃត្រូវធ្វើអព្ភានកម្មយ៉ាងនេះ ដូច្នេះឯង តែអព្ភានវិធីនេះ ព្រះអង្គត្រាស់ដោយអំណាចអាបត្តិតែមួយ ៗ ក៏បើជាអាបត្តិ ២-៣ ឬច្រើន មានវត្ថុតែមួយ ឬ មានវត្ថុផ្សេងគ្នា, គប្បីធ្វើកម្មវាចាដោយអំណាចអាបត្តិទាំងនោះ អប្បដិច្ឆន្នមានត្ត សង្ឃគប្បីឱ្យដោយប្រការយ៉ាងនេះ ។

## បរិវាសកថា

[៣៨៣] ក៏បដិច្ឆន្នមានត្ត ជារបស់ដែលសង្ឃគួរឱ្យដល់ភិក្ខុដែលនៅបរិវាស ដើម្បីអាបត្តិដែលបិទបាំងទុក រួចហើយ ព្រោះហេតុនោះ ខ្ញុំព្រះករុណានឹងពោលបរិវាសកថាមុន ហើយនឹងពោលបដិច្ឆន្នមានត្តនោះ ។

បរិវាសនិងមានត្ត ព្រះមានព្រះភាគត្រាស់ដោយអាការជាអនេកក្នុងព្រះបាលី ដោយន័យជាដើមថា "ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឱ្យឯកាហប្បរិវាស (បរិវាស១ថ្ងៃ) ដល់ឧទាយីភិក្ខុ ចំពោះអាបត្តិ១ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបានបិទបាំងទុក ១ ថ្ងៃចុះ" ។

វិនិច្ឆ័យដែលលោកបានពោលទុក ក្នុងអនាគតស្ថានរបស់បរិវាសនិងមានត្តនោះ ៗ ដល់សេចក្តីពិស្តារពេកណាស់ ដូចក្នុងបាលីទាំងជាវិនិច្ឆ័យដែលអ្នកណា ៗ មិនអាចកំណត់បានដោយងាយទេ, ព្រោះហេតុនោះ ខ្ញុំព្រះករុណានឹងប្រមូលបរិវាស និងមានត្តនោះ សម្តែងក្នុងអធិការ

នេះតែម្តង ។

ក៏ដែលឈ្មោះថា បរិវាសនេះ ដែលប្រាថ្នាក្នុងព្រះបាលីនេះ មាន ៣ យ៉ាង គឺ បដិច្ឆន្នបរិវាស ១ សុទ្ធន្តបរិវាស ១ សមោធានបរិវាស ១ ។ ក្នុង៣ យ៉ាង នោះ បដិច្ឆន្នបរិវាស គួរឱ្យដើម្បីអាបត្តិតាមដែលបិទបាំងទុកជាមុន ។

ពិតមែន អាបត្តិរបស់ភិក្ខុះ បិទបាំងមួយថ្ងៃ ដូចអាបត្តិរបស់ព្រះឧទាយីថេរៈនេះ, អាបត្តិរបស់ភិក្ខុះបិទបាំង ២ ថ្ងៃជាដើម ដូចអាបត្តិរបស់ព្រះឧទាយីថេរៈនុ៎ះឯង ដែលមកហើយខាងដើម, អាបត្តិរបស់ភិក្ខុះ មានតែមួយដូចអាបត្តិនេះ, អាបត្តិរបស់ភិក្ខុះមាន ២-៣ ឬច្រើនជាងនោះ ដូចដែលមកហើយខាងដើម ។ ព្រោះហេតុនោះ កាលសង្ឃឱ្យបដិច្ឆន្នបរិវាស គួរជ្រាបសេចក្តីនៃអាបត្តិដែលបិទបាំងជាដំបូង ។

## អាការបិទបាំងអាបត្តិ

ក៏ដែលឈ្មោះថា អាបត្តិនេះ រមែងឈ្មោះថា បិទបាំងដោយអាការ ១០ យ៉ាង ។

ក្នុងការបិទបាំងអាបត្តិនោះ ដូច្នេះ ៖

ជាអាបត្តិ១, សម្គាល់ថា ជាអាបត្តិ១, ជាបកតត្ត១, សម្គាល់ថា ជាបកតត្ត១, មិនមានអន្តរាយ១, សម្គាល់ថា មិនមានអន្តរាយ១, អាច១, សម្គាល់ថា អាច១, ប្រាថ្នានឹងបិទបាំង១, ក៏បិទបាំងទុក១ ។

ក្នុងពាក្យទាំងនេះ ពាក្យថា **ជាអាបត្តិ១, សម្គាល់ថា ជាអាបត្តិ១,** មានអធិប្បាយថា ភិក្ខុត្រូវអាបត្តិណា សម្គាល់ថា ជាអាបត្តិនោះពិត ៗ និងសូម្បីភិក្ខុនោះ ក៏មានការសម្គាល់ក្នុងអាបត្តិនោះថា ជាអាបត្តិដូចគ្នា ៗ កាលភិក្ខុដឹងយ៉ាងនេះ ក៏បិទបាំងទុក ជាការបិទបាំង, តែបើភិក្ខុនេះ សម្គាល់ក្នុងអាបត្តិនោះថា ជាអនាបត្តិ មិនជាការបិទបាំង ។

ចំណែកអនាបត្តិ ដែលភិក្ខុបិទបាំង ដោយសម្គាល់ថា ជាអាបត្តិក្តី សម្គាល់ថា ជាអនាបត្តិក្តី មិនជាការបិទបាំងឡើយ ។

ភិក្ខុបិទបាំងលហុកាបត្តិ ដោយសម្គាល់ថា ជាគរុកាបត្តិក្តី បិទបាំងគរុកាបត្តិ ដោយសម្គាល់ថា ជាលហុកាបត្តិក្តី; មួយទៀត លោកនៅក្នុងពួកអលជ្ជី អាបត្តិ មិនជាការបិទបាំង ។

ភិក្ខុសម្គាល់គរុកាបត្តិថា ជាលហុកាបត្តិ និងសម្តែង, អាបត្តិនោះមិនជាការសម្តែង, មិនជាការបិទបាំង ។

ស្គាល់គរុកាបត្តិថា ជាគរុកាបត្តិ ហើយបិទបាំងទុក ជាការបិទបាំង ។ មិនស្គាល់ថា ជាអាបត្តិធ្ងន់ អាបត្តិស្រាល គិតថា "យើងបិទបាំងអាបត្តិ" ហើយបិទបាំងទុក ជាការបិទបាំងពិត ។

ភិក្ខុមិនត្រូវសង្ឃធ្វើឧក្ខេបនីយកម្ម ៣ យ៉ាង ឈ្មោះថា ភិក្ខុបកតត្ត ។

បើលោកជាអ្នកមានការសម្គាល់ថា "ខ្ញុំជាភិក្ខុបកតត្ត" ហើយបិទ

បាំងទុក ជាការបិទបាំងទុកពិត, បើលោកសម្គាល់ថា "ខ្លួនមិនមែនជាភិក្ខុបកតត្ត" ដោយ យល់ថា "សង្ឃធ្វើកម្មដល់យើង" ទិងបិទបាំងទុក មិនជាការបិទបាំងទេ ។

អាបត្តិសូម្បីដែលភិក្ខុមិនមែនភិក្ខុបកតត្ត ដែលមានសេចក្តីសម្គាល់ខ្លួនថា "ជាភិក្ខុបកតត្ត" ឬសម្គាល់ខ្លួនថា "មិនមែនភិក្ខុបកតត្ត" បិទបាំងហើយ មិនឈ្មោះថា បិទបាំងពិត ។

ពិតមែន ពាក្យនេះ សូម្បីព្រះមានព្រះភាគក៏បានត្រាស់ទុក ដូច្នេះថា ៖

"ឧបសម្បន្នមិនមែនភិក្ខុនី ត្រូវគរុកាបត្តិជាអវសេសាបត្តិ, ហើយបិទបាំងទុក អាស្រ័យសេចក្តីមិនអើពើ, តែមិនត្រូវទោស ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ" ។[១]

ពិតមែន បញ្ហានេះ លោកពោលដោយភិក្ខុដែលត្រូវសង្ឃលើកវត្ត ។

ពាក្យថា អនន្តរាយិកោ : ជាអ្នកមិនមានអន្តរាយ មានសេចក្តីថា ក្នុងអន្តរាយ ១០ យ៉ាង អន្តរាយសូម្បីមួយ មិនមានដល់ភិក្ខុណា,

១. វិន. បរិ. សេទមោចនគាថា. ១៣. ៤២១/៤១៥ ។

បើភិក្ខុនោះ ជាអ្នកមានការសម្គាល់ថា មិនមានអន្តរាយទេ ហើយបិទបាំងទុក, អាបត្តិនោះ ជាការបិទបាំង ។

បើសូម្បីលោកជាអ្នកមានការសម្គាល់ថា មានអន្តរាយ ព្រោះអមនុស្ស និងសត្វកាច ក្នុងវេលាយប់ ព្រោះជាអ្នកមានជាតិនៃអ្នកខ្លាចទើបបិទបាំងទុក អាបត្តិនោះ មិនជាការបិទបាំងទេ ។

ក៏កាលភិក្ខុណា នៅក្នុងវិហារជិតភ្នំ គរុកាបត្តិរបស់ភិក្ខុនោះ ត្រូវឆ្លងញកភ្នំ ឬព្រៃ ឬទន្លេទៅប្រាប់ ។ ភ័យមានសត្វកាច និងអមនុស្សជាដើម មានក្នុងចន្លោះមក, ពស់ទាំងឡាយ រមែងដេកក្នុងមក ទន្លេក៏ជោរជន់ពេញដោយទឹកជំនន់, និងកាលអន្តរាយនោះ មានប្រាកដពិត ៗ លោកមានការសម្គាល់ថា មានអន្តរាយ ទើបបិទបាំងទុក, អាបត្តិនោះ មិនជាការបិទបាំងទេ ។

មួយទៀត កាលភិក្ខុមានអន្តរាយ បិទបាំងទុកដោយសម្គាល់ថា មិនមានអន្តរាយ អាបត្តិនោះ ក៏មិនជាការបិទបាំងដូចគ្នា ។

ពាក្យថា បហុ : អាច មានសេចក្តីថា ភិក្ខុណា អាចទៅកាន់សំណាក់ភិក្ខុ និងដើម្បីប្រាប់បាន, បើលោកជាអ្នកមានការសម្គាល់ថា ខ្លួនអាច ហើយបិទបាំងទុក, អាបត្តិនោះ ជាការបិទបាំងពិត ។ បើមាត់របស់លោកមានបូសតូច ៗ, ឬខ្យល់សៀតចង្កា, ឬឈឺធ្មេញ, ឬបាន

ភិក្ខាតិច ; ដោយហេតុត្រឹមតែប៉ុណ្ណោះ នឹងចាត់ថា មិនអាចប្រាប់ មិនអាចទៅ មិនបានទេ ។ ក៏ប៉ុន្តែថា លោកមានការសម្គាល់ថា យើងមិនអាច ភិក្ខុនេះ ជាអ្នកអាច តែឈ្មោះថា អ្នកមានការសម្គាល់ថា ខ្លួនមិនអាច ។ អាបត្តិសូម្បីដែលភិក្ខុនេះ បិទបាំងទុក ចាត់ថា មិនបានបិទបាំង ។

មួយទៀត អាបត្តិដែលភិក្ខុមិនអាច គឺ មិនអាចនឹងប្រាប់ ឬនឹងទៅ ទោះជាមានការសម្គាល់ថា ខ្លួនអាចក៏ដោយ មានការសម្គាល់ថា ខ្លួនមិនអាចក៏ដោយ បិទបាំងទុក មិនជាការបិទបាំងទេ ។

ពាក្យថា ជាអ្នកប្រាថ្នានឹងបិទបាំង ក៏បិទបាំងទុក នេះងាយយល់ទាំងអស់ ។

តែបើភិក្ខុដាក់ធុរៈថា យើងនឹងបិទបាំង ក្នុងបុរេភត្ត ឬ បច្ឆាភត្ត ឬ ក្នុងយាមទាំងឡាយ មានបឋមយាមជាដើម មានចិត្តចុះកាន់លជ្ជីធម៌ បានប្រាប់មុនពេលអរុណរះទុំះឯង; ភិក្ខុនេះ ឈ្មោះថា អ្នកប្រាថ្នានឹងបិទបាំង តែមិនបានបិទបាំង ។

តែកាលភិក្ខុណា នៅក្នុងស្ថានមិនមានភិក្ខុ ត្រូវអាបត្តិហើយ រងចាំការមកនៃភិក្ខុដែលជាសភាគគ្នា ឬទៅកាន់សំណាក់របស់ភិក្ខុ ដែលជាសភាគគ្នាកន្លងទៅកន្លះខែក្តី មួយខែក្តី; ភិក្ខុនេះ ឈ្មោះថា បិទបាំងទុក

ទាំងដែលមិនប្រាថ្នានឹងបិទ, សូម្បីអាបត្តិនេះ ក៏មិនឈ្មោះថា បិទបាំង ។

ចំណែកភិក្ខុណាគ្រាន់តែត្រូវហើយភ្លាម ប្រញាប់ជៀសទៅកាន់សំណាក់ភិក្ខុដែលជាសភាគគ្នា ធ្វើឱ្យជាក់ច្បាស់ហើយ ដូចបុរសជាន់ភ្លើងដូច្នោះ ; ភិក្ខុនេះ ឈ្មោះថា អ្នកមិនប្រាថ្នានឹងបិទបាំង ទាំងមិនបិទបាំង ។

តែបើសូម្បីឃើញភិក្ខុដែលជាសភាគគ្នាហើយ ក៏មិនប្រាប់ព្រោះអៀនខ្មាសថា "អ្នកនេះ ជាឧបជ្ឈាយ៍របស់យើង ឬថា ភិក្ខុនេះ ជាអាចារ្យរបស់យើង" ។ អាបត្តិជាការបិទបាំងពិត ។

ពិតមែន ភាពជាឧបជ្ឈាយ៍ជាដើម មិនជាប្រមាណក្នុងការប្រាប់អាបត្តិនេះ, ការដែលភិក្ខុមិនមែនជាអ្នកមានវេរា និងជាសភាគគ្នាប៉ុណ្ណោះជាប្រមាណព្រោះហេតុនោះ គួរប្រាប់ក្នុងសំណាក់ភិក្ខុដែលមិនមែនជាអ្នកមានពៀរវេរា និងជាសភាគគ្នា ។

ចំណែកភិក្ខុណា ជាវិសភាគគ្នា ជាអ្នកប្រាថ្នានឹងស្តាប់ហើយផ្ចាញ់ផ្ចាល, មិនគួរប្រាប់ក្នុងសំណាក់ភិក្ខុបែបនោះ សូម្បីជាឧបជ្ឈាយ៍ ។

បណ្តាកាលទាំងនោះ ភិក្ខុជាអ្នកត្រូវអាបត្តិក្នុងបុរេភត្តក្តី បច្ឆាភត្តក្តី ពេលថ្ងៃក្តី ពេលយប់ក្តី គួរប្រាប់តាំងពីមុនអរុណរះ ។ កាលអរុណរះហើយ អាបត្តិនោះ ជាការបិទបាំងពិត ។ ទាំងត្រូវទុក្កដ ព្រោះ

ការបិទបាំងជាបច្ច័យ ។ នឹងធ្វើឱ្យជាក់ច្បាស់ក្នុងសំណាក់ភិក្ខុ ដែលត្រូវសង្ឃាទិសេស ប្រភេទតែមួយដូចគ្នា មិនគួរ ។

បើនឹងធ្វើឱ្យជាក់ច្បាស់ អាបត្តិជាការបើកបង្ហាញ, តែភិក្ខុមិនផុតអាបត្តិទុក្កដ; ព្រោះហេតុនោះ គួរបើកបង្ហាញក្នុងសំណាក់ភិក្ខុដែលបរិសុទ្ធិ ។

ក្នុងកុរុន្ទីពោលថា កាលនឹងបើកបង្ហាញ ចូរពោលថា "ខ្ញុំព្រះករុណាធ្វើឱ្យជាក់ច្បាស់នូវអាបត្តិមួយក្នុងសំណាក់របស់លោក", ឬថា "ខ្ញុំព្រះករុណាប្រាប់អាបត្តិមួយក្នុងសំណាក់របស់លោក", ឬថា "ខ្ញុំព្រះករុណាផ្ចៀងអាបត្តិមួយ ក្នុងសំណាក់របស់លោក", ឬថា "លោកចូរជ្រាបនូវខ្ញុំព្រះករុណាជាអ្នកត្រូវអាបត្តិមួយ", ក៏បាន ។ អាបត្តិមិនជាការបិទបាំង ដោយអាការទាំងពួង ។ តែបើភិក្ខុពោលដោយន័យជាដើមថា "ខ្ញុំព្រះករុណាធ្វើឱ្យជាក់ច្បាស់នូវលហុកាបត្តិ" ដូច្នេះ អាបត្តិនោះ ជាការបិទបាំងទុកពិត ។

អាបត្តិជាការប្រាប់ ដោយអាការទាំង ៣ យ៉ាង គឺ ប្រាប់ចំពោះវត្ថុ, ប្រាប់ចំពោះអាបត្តិ, ប្រាប់ទាំង ២ ។ កាលសង្ឃនឹងឱ្យបដិច្ឆន្នបរិវាស គប្បីកំណត់ហេតុ ១០ នេះ គប្បីជ្រាបភាពនៃអាបត្តិ ជាការបិទបាំងមុន ដោយប្រការដូច្នេះ ។

# វិធីឱ្យបរិវាស

[៣៨៤] លំដាប់នោះ គប្បីកំណត់ថ្ងៃដែលបិទបាំង និងអាបត្តិ, បើបិទបាំងមួយថ្ងៃប៉ុណ្ណោះ ; គប្បីឱ្យសូមយ៉ាងនេះថា ៖

អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋិ ឯកាហប្បដិច្ឆន្នំ : បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ហើយគប្បីសូមឲ្យកម្មវាចាឱ្យបរិវាស តាមន័យដែលពោលហើយក្នុងបាលីនេះនុ៎ះឯង ។

[៣៩២] បើបិទបាំងទុក ២ ថ្ងៃ ៣ ថ្ងៃជាដើម គប្បីឱ្យសូមយ៉ាង នេះថា ៖

ទ្វីហប្បដិច្ឆន្នំ, តីហប្បដិច្ឆន្នំ, ចតូហប្បដិច្ឆន្នំ, បញ្ចាហប្បដិច្ឆន្នំ, ឆាហប្បដិច្ឆន្នំ, សត្តាហប្បដិច្ឆន្នំ, អដ្ឋាហប្បដិច្ឆន្នំ, នវាហប្បដិច្ឆន្នំ, ទសាហប្បដិច្ឆន្នំ, ឯកាទសាហប្បដិច្ឆន្នំ, ទ្វាទសាហប្បដិច្ឆន្នំ, តេរសាហប្បដិច្ឆន្នំ, ចុទ្ទសាហប្បដិច្ឆន្នំ ។

គប្បីតែងពាក្យប្រកបតាមចំនួនថ្ងៃ ត្រឹមតែ ១៤ ថ្ងៃ ដោយប្រការដូច្នេះ ។

[៤១៥] សម្រាប់អាបត្តិដែលបិទបាំងទុក ១៥ ថ្ងៃ គប្បីតែង

*ពាក្យសួធ្យប្រេកបថា* បក្ខបដិច្ចន្តុំ ។ តាំងពី ១៥ ថ្ងៃទៅដរាបដល់ថ្ងៃទី ២៩ គប្បីតែង*ពាក្យសួធ្យប្រេកបថា* អតិរេកបក្ខប្បដិច្ចន្តុំ តាំងពី ២៩ ថ្ងៃឡើងទៅ គប្បីតែង*ពាក្យសួធ្យប្រេកបថា* មាសប្បដិច្ចន្តុំ, អតិរេកមាសប្បដិច្ចន្តុំ, ទ្វិមាសប្បដិច្ចន្តុំ, អតិរេកទ្វិមាសប្បដិច្ចន្តុំ, តេមាសប្បដិច្ចន្តុំ, អតិរេកតេមាសប្បដិច្ចន្តុំ, ចតុមាសប្បដិច្ចន្តុំ, អតិរេកចតុមាសប្បដិច្ចន្តុំ, បញ្ចមាសប្បដិច្ចន្តុំ, អតិរេក-បញ្ចមាសប្បដិច្ចន្តុំ ។ ឆមាស, អតិរេកឆមាស, សត្តមាស, អតិរេកសត្តមាស, អដ្ឋមាស, អតិរេកអដ្ឋមាស ។ នវមាស, អតិរេកនវមាស, ទសមាស, អតិរេកទសមាស, ឯកាទសមាស, អតិរេកឯកាទសមាសប្បដិច្ចន្តុំ ។

*កាលពេញមួយឆ្នាំ* គប្បីតែង*ពាក្យសម្រាប់សួធ្យប្រេកបថា* ឯកសំវច្ឆរប្បដិច្ចន្តុំ ។

*ខាងមុខអំពីនោះ* គប្បីតែង*ពាក្យសម្រាប់សួធ្យប្រេកបយ៉ាងនេះថា* អតិរេកឯកសំវច្ឆរ, ទ្វិសំវច្ឆរ, អតិរេកទ្វិសំវច្ឆរ, តិសំវច្ឆរ, អតិរេកតិសំវច្ឆរ, ចតុសំវច្ឆរ, អតិរេកចតុសំវច្ឆរ, បញ្ចសំវច្ឆរ, អតិរេកបញ្ចសំវច្ឆរបដិច្ចន្តុំ, *ដូច្នេះ ដរាបដល់ថា* សដ្ឋីសំវច្ឆរ,

អតិរេកសង្ឃាទិសេសាវត្ថុបតិច្ឆន្នំ ឬស្ដម្បីច្រើនជាងនោះ ។

[៤៤៣] បើជាអាបត្តិ ២-៣ ឬច្រើនជាងនោះ គប្បីពោលថា ទ្វេ អាបត្តិយោ, តិស្សោ អាបត្តិយោ, ដូចដែលបានពោលទុកក្នុងទីនេះថា ឯកំ អាបត្តឹ ដូច្នោះ ។ តែដែលច្រើនជាងនោះ ទោះជាចំនួនមួយរយ ឬមួយពាន់ក៏ដោយ សមគួរពោលថា សម្ពហុលា ។

សូម្បីក្នុងអាបត្តិដែលមានវត្ថុផ្សេងគ្នា គប្បីតែងពាក្យសូធ្យប្រកបដោយអំណាចនៃចំនួនយ៉ាងនេះថា ៖

អហំ ភន្តេ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ ឯកំ សុក្កវិស្សដ្ឋឹ ឯកំ កាយសំសគ្គំ ឯកំ ទុដ្ឋុល្លំ វាចំ ឯកំ អត្តកាមបារិចរិយំ ឯកំ សញ្ចរិត្តំ ឯកាហប្បដិច្ឆន្នាយោ : បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិសង្ឃាទិសេសជាច្រើន ឈ្មោះ សុក្កវិស្សដ្ឋិ ១ កាយសំសគ្គៈ ១ ទុដ្ឋុល្លវាចា ១ អត្តកាមបារិចរិយៈ ១ សញ្ចរិតៈ ១ បិទបាំង ១ ថ្ងៃ ។

ឬដោយអំណាចនៃការបញ្ជាក់វត្ថុយ៉ាងនេះថា ៖

អហំ ភន្តេ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ នានាវត្ថុកាយោ ឯកាហប្បដិច្ឆន្នាយោ : បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំ

ព្រះករុណា ត្រូវហើយនូវអាបត្តិសង្ឃាទិសេសជាច្រើន មានវត្ថុផ្សេងគ្នា បិទបាំង ១ ថ្ងៃ ។

ឬដោយអំណាចនៃការបញ្ជាក់ឈ្មោះយ៉ាងនេះថា ៖

អហំ ភន្តេ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ ឯកាហប្បដិច្ឆន្នាយោ : បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិសង្ឃាទិសេសជាច្រើន បិទបាំង ១ ថ្ងៃ ។

ក្នុងវត្ថុនិងឈ្មោះនោះ ឈ្មោះមាន ២ យ៉ាង គឺ ឈ្មោះដែលទូទៅរបស់អាបត្តិដែលមានជាតិស្មើគ្នា ១ ឈ្មោះដែលទូទៅរបស់អាបត្តិទាំងពួង ១ ។

បណ្តាឈ្មោះទាំង ២ យ៉ាងនោះ ពាក្យថា សង្ឃាទិសេសោ ជាឈ្មោះដែលទូទៅរបស់អាបត្តិដែលមានជាតិស្មើគ្នា ។

ពាក្យថា អាបត្តិ ជាឈ្មោះដែលទូទៅរបស់អាបត្តិទាំងពួង ។

ព្រោះដូច្នោះ គួរនឹងតែងពាក្យសូធ្យ ប្រកបដោយអំណាចសូម្បីនៃឈ្មោះ ដែលទូទៅរបស់អាបត្តិទាំងពួងយ៉ាងនេះ សម្ពហុលា អាបត្តិយោ អាបជ្ជឹ ឯកាហប្បដិច្ឆន្នាយោ : ត្រូវហើយនូវអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ ។

ពិតមែន វិនយកម្មមានបរិវាសជាដើម សូម្បីទាំងពួងនេះ សមគួរនឹង

តែងពាក្យសួធ្យប្រកបដោយអំណាចនៃវត្ថុ ដោយអំណាចនៃគោត្រ ដោយអំណាចនៃឈ្មោះ និងដោយអំណាចនៃអាបត្តិ ។

ក្នុងវត្ថុនិងគោត្រជាដើមនោះ ពាក្យថា សុក្កវិស្សដ្ឋិ ជាវត្ថុផង ជាគោត្រផង ។

ពាក្យថា សញ្ចេតនិកា សុក្កវិស្សដ្ឋិ ជាឈ្មោះផង ជាអាបត្តិផង ។

ពាក្យថា កាយសំសគ្គោ ជាវត្ថុផង ជាគោត្រផង ។

ពាក្យថា សង្ឃាទិសេសោ ជាឈ្មោះផង ជាអាបត្តិផង ។

ក្នុងវត្ថុជាដើមនោះ វត្ថុនិងគោត្រ ជាការកាន់យកហើយ ដោយពាក្យថា សុក្កវិស្សដ្ឋិ និង កាយសំសគ្គោ ជាដើមខ្លះ ដោយពាក្យថា នានាវត្ថុកាយោ ខ្លះ ។

ឈ្មោះ និងអាបត្តិ ជាការកាន់យកហើយ ដោយពាក្យថា សង្ឃាទិសេសោ ខ្លះ ដោយពាក្យថា អាបត្តិយោ ខ្លះ ។

និងក្នុងបាលីនេះ ទាំងឈ្មោះ ទាំងវត្ថុនិងគោត្រ ជាការកាន់យកហើយពិត ដោយពាក្យថា ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ ។

ដូចក្នុងបាលីនេះ លោកពោលថា អយំ ឧទាយិ ភិក្ខុ យ៉ាង

ណា, ភិក្ខុណា ៗ ជាអ្នកត្រូវ, គប្បីកាន់យកឈ្មោះរបស់ភិក្ខុនោះ ៗ ធ្វើកម្មវាចាថា អយំ ឥត្ថន្នាមោ ភិក្ខុ ដូច្នោះ ។

ក្នុងវេលាចប់កម្មវាចា ភិក្ខុនោះ គប្បីសមាទានវត្តក្នុងសីមានៃរោងតែម្តង តាមន័យដែលពោលហើយនុ៎ះឯងថា បរិវាសំ សមាទិយាមិ វត្តំ សមាទិយាមិ : ខ្ញុំព្រះករុណាសូមសមាទាននូវបរិវាស សូមសមាទាននូវវត្ត កាលសមាទានហើយ គប្បីប្រាប់នៅកណ្តាលសង្ឃ ក្នុងសីមានៃរោងនោះឯង ក៏ឯកាលនឹងប្រាប់ គប្បីប្រាប់យ៉ាងនេះថា ៖

អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ ឯកាហប្បដិច្ឆន្នំ, សោហំ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា ឯកាហប្បដិច្ឆន្នាយ ឯកាហប្បរិវាសំ យាចឹ ។ តស្ស មេ សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា ឯកាហប្បដិច្ឆន្នាយ ឯកាហប្បរិវាសំ អទាសិ ។ សោហំ បរិវសាមិ, វេទិយាមហំ ភន្តេ, វេទិយតីតិ មំ សង្ឃោ ធារេតុ : បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណា ត្រូវហើយនូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ បិទបាំង ១ ថ្ងៃ, ខ្ញុំព្រះករុណានោះសូមហើយនូវឯកាហប្បរិវាសអំពីសង្ឃ ដើម្បីអាបត្តិ ១ ឈ្មោះ

សញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបិទបាំងទុក ១ ថ្ងៃ, សង្ឃបានឱ្យហើយនូវឯកាហប្បរិវាស ដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ បិទបាំង ១ ថ្ងៃ, (ឥឡូវនេះ) ខ្ញុំព្រះករុណានោះ ប្រព្រឹត្តបរិវាស, បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណា សូមប្រាប់វត្ត សូមព្រះសង្ឃចាំទុកនូវខ្ញុំថា ភិក្ខុនេះ បានប្រាប់វត្ត ។

ក៏ជាការសមគួរពិតដែលនឹងកាន់យកសេចក្តីនេះ ប្រាប់ដោយភាសាយ៉ាងណាមួយ ។ កាលប្រាប់ហើយ បើប្រាថ្នានឹងដាក់ គប្បីដាក់ក្នុងកណ្តាលជំនុំសង្ឃ តាមន័យដែលពោលហើយនុ៎ះចុះ ។ កាលភិក្ខុទាំងឡាយ ចេញពីពេងទៅហើយ នឹងដាក់ក្នុងសំណាក់ភិក្ខុសូម្បីមួយរូបក៏គួរ ។

លោកចេញពីពេងទៅហើយ ទើបត្រឡប់បានសតិ គប្បីដាក់ក្នុងសំណាក់ភិក្ខុដែលទៅជាមួយគ្នា បើភិក្ខុសូម្បីនោះ ក៏ជៀសចេញទៅ ខ្ពនមិនទាន់បានប្រាប់វត្តដល់ភិក្ខុដទៃណា ដែលនៅក្នុងពេង, គប្បីប្រាប់ដល់ភិក្ខុនោះហើយដាក់វត្ត និងកាលប្រាប់ គប្បីពោលក្នុងទីបំផុតថា វេទិយតីតិ មំ អាយស្មា ធារេតុ កាលប្រាប់ដល់ភិក្ខុ ២ រូប គប្បីពោលថា អាយស្មន្តា ធារេន្តុ កាលប្រាប់ដល់ភិក្ខុ ៣ រូប ឬច្រើនជាងគប្បីពោលថា អាយស្មន្តោ ធារេន្តុ ឬថា សង្ឃោ ធារេតុ ៖ ចាប់ផ្តើម

ពីវេលាដែលដាក់ហើយទៅ លោករមែងតាំងនៅក្នុងឋានៈជាបកតត្ត ។

ប្រសិនបើវត្តមានភិក្ខុតិច; ភិក្ខុទាំងឡាយជាសភាគគ្នា ក៏មាន មិនត្រូវដាក់វត្តគប្បីធ្វើការកំណត់រាប់រាត្រី ក្នុងវត្តនោះឯង ។

ប្រសិនបើមិនអាចឱ្យបរិសុទ្ធិបាន ។ គប្បីដាក់វត្តតាមន័យដែលពោលហើយនុ៎ះឯង ក្នុងវេលាជិតភ្លឺព្រមដោយភិក្ខុមួយរូបកន្លងឧបចារៈសីមាចេញទៅ គេចចេញអំពីមកធំ អង្គុយក្នុងទីកំបាំងតាមន័យដែលពោលហើយ ក្នុងវណ្ណនានៃមានត្តនោះឯង សមាទានវត្តតាមន័យដែលពោលហើយ ប្រាប់បរិវាសដល់ភិក្ខុនោះ ក្នុងពេលមុនអរុណរះតែម្តងកាលប្រាប់ បើភិក្ខុនោះខ្ចីជាង គប្បីពោលថា អាវុសោ បើជាភិក្ខុចាស់ជាង គប្បីពោលថា ភន្តេ ។

បើភិក្ខុដទៃមកកាន់ទីនោះ ដោយកិច្ចចាំបាច់យ៉ាងណាមួយឯបារិវាសិកភិក្ខុនេះ ក៏ឃើញលោក ឬបានឮសំឡេងរបស់លោកគួរប្រាប់, កាលមិនប្រាប់ ជារត្តិច្ឆេទ និងជាវត្តភេទ បើលោកកន្លងឧបចារៈសីមាចូលទៅ ១២ ហត្ថហើយចេញទៅ តែកាលបារិវាសិកភិក្ខុមិនទាន់ដឹងមានតែរត្តិច្ឆេទ ចំណែកវត្តភេទមិនមាន កាលអរុណរះហើយគប្បីដាក់វត្ត ។

ព្រះមហាសុមត្ថេរៈពោលថា បើភិក្ខុដែលទៅជាមួយគ្នានោះ

ជៀសចេញទៅ ដោយកិច្ចចាំបាច់យ៉ាងណាមួយ, ខ្លួនជួបភិក្ខុដទៃរូបណា មុនភិក្ខុទាំងអស់គប្បីប្រាប់ដល់ភិក្ខុនោះឯង ហើយដាក់វត្ត, បើមិនជួបអ្នកណា គប្បីទៅកាន់វត្តហើយដាក់វត្តក្នុងសំណាក់ភិក្ខុដែលទៅជាមួយខ្លួន ។

ចំណែកព្រះមហាបទុមត្ថេរៈ ពោលថា ជួបភិក្ខុណាមុន, គប្បីប្រាប់ដល់ភិក្ខុនោះ ហើយដាក់ នេះជាបរិហារសម្រាប់ភិក្ខុដែលដាក់វត្តហើយ ។

អាបត្តិដែលបានបិទបាំងទុក អស់ថ្ងៃប៉ុន្មាន ដើម្បីត្រូវការនឹងបន្ទោបង់សេចក្តីវង្វៀស គប្បីនៅបរិវាសអស់ថ្ងៃប៉ុណ្ណោះ ឬច្រើនជាងនោះហើយ ចូលទៅរកសង្ឃសូមមានវត្តហើយ គប្បីសូមមានត្ត ដោយប្រការដូច្នេះ ។

ពិតមែន ភិក្ខុនេះចាត់ជាអ្នកគួរដល់មានត្ត បន្ទាប់ពីកាលលោកសមាទានវត្តហើយប៉ុណ្ណោះ ព្រោះលោកជាអ្នកដាក់វត្ត នៅបរិវាស ។ តែកិច្ចដែលនឹងត្រូវសមាទានវត្តទៀត រមែងមិនមានដល់ភិក្ខុដែលមិនបានដាក់វត្ត, ពិតមែន លោកជាអ្នកគួរដល់មានត្ត ដោយកន្លងថ្ងៃដែលបិទបាំងទុកពិត, ព្រោះហេតុនោះ សង្ឃគួរឱ្យមានត្ត ដល់លោកតែម្តង ។

# វិធីឱ្យមានត្ត

[៤៥៣] នេះឈ្មោះថា បដិច្ឆន្នមានត្ត ។ កាលនឹងឱ្យបដិច្ឆន្នមានត្តនោះ បើមានអាបត្តិមួយ, គប្បីឱ្យតាមន័យដែលពោលទុកក្នុងបាលីនុ៎ះចុះ បើមាន ២ ឬ ៣ គប្បីកំណត់អាបត្តិ និងថ្ងៃ ហើយតែងពាក្យសូធ្យ ប្រកបតាមន័យដែលពោលទុកក្នុងបរិវាសនុ៎ះថា សោហំ បរិវុត្ថបរិវាសោ សង្ឃំ ទ្វិន្នំ[1] តិស្សន្នំ[2] អាបត្តីនំ ឯកាហប្បដិច្ឆន្នំ ឆារត្តំ មានត្តំ យាចាមិ : (ឥឡូវនេះ) ខ្ញុំព្រះករុណានោះ បានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ, មកសូមមានត្ត ៦ រាត្រី ចំពោះអាបត្តិ ២ ចំពោះអាបត្តិ ៣ បិទបាំងមួយថ្ងៃ ។

សូម្បីប្រមូលអាបត្តិដែលមិនបិទបាំង និងអាបត្តិដែលបិទបាំងទុកឱ្យ ក៏គួរ ។

យ៉ាងណា ? ភិក្ខុនៅបរិវាស ដើម្បីអាបត្តិដែលបិទបាំងសម្រេចហើយ គប្បីសូមមានត្ត ដើម្បីអាបត្តិដែលបិទបាំង និងអាបត្តិដែលមិនបានបិទបាំង រួមគ្នាថា អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ ឯកាហប្បដិច្ឆន្នំ សោហំ សង្ឃំ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា ឯកាហប្បដិច្ឆន្នាយ ឯកាហបរិវាសំ

១. សម្រាប់អាបត្តិ ២ ។ ២. សម្រាប់អាបត្តិ ៣ ។

យាចឹ; តស្ស មេ សង្ឃោ ឯកិស្សា អាបត្តិយា សញ្ចេតនិកាយ សុក្កវិស្សដ្ឋិយា ឯកាហប្ប ដិច្ឆន្នាយ ឯកាហបរិវាសំ អទាសិ, សោហំ បរិវុត្ថបរិវាសោ; អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ អប្បដិច្ឆន្នំ, សោហំ ភន្តេ សង្ឃំ តាសំ អាបត្តីនំ សញ្ចេតនិកានំ សុក្កវិស្សដ្ឋីនំ បដិច្ឆន្នាយ ច អប្បដិច្ឆន្នាយ ច ឆារត្តំមានត្តំ យាចាមិ ។

បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ បិទបាំងទុក ១ ថ្ងៃ, ខ្ញុំព្រះករុណានោះ បានមកសូមនូវឯកាហប្បរិវាសអំពីសង្ឃ ចំពោះអាបត្តិ ១ ឈ្មោះ សញ្ចេតនិកសុក្កវិស្សដ្ឋិ បិទបាំង ១ ថ្ងៃ, សង្ឃក៏បានឱ្យហើយនូវ ឯកាហប្បរិវាស ដល់ខ្ញុំព្រះករុណានោះ ចំពោះអាបត្តិ ១ ឈ្មោះ សញ្ចេតនិកសុក្កវិស្សដ្ឋិ ដែលបិទបាំងទុក ១ ថ្ងៃហើយ, (ឥឡូវនេះ) ខ្ញុំព្រះករុណានោះ បានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ ។ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិ ១ ឈ្មោះ សញ្ចេតនិកសុក្កវិស្សដ្ឋិ មិនបានបិទបាំងទេ, បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណានោះ សូមនូវមានត្ត ៦ រាត្រីនឹងសង្ឃ ពោះអាបត្តិឈ្មោះ សញ្ចេតនិកសុក្កវិស្សដ្ឋិទាំងឡាយនោះ ដែលបានបិទបាំងផង ដែលមិនបានបិទបាំងផង ។

លំដាប់នោះ សង្ឃគប្បីតែងកម្មវាចាឱ្យសមគួរដល់ពាក្យសូមនោះ ឱ្យមានត្តដល់មានត្តរហភិក្ខុនោះ ។

បើអាបត្តិដែលបិទបាំងទុក ២ ដែលមិនបានបិទបាំងតែមួយ ; គប្បីពោលថា បដិច្ឆន្នានញ្ច អប្បដិច្ឆន្នាយ ច ។

បើអាបត្តិដែលបិទបាំងទុកតែមួយ ដែលមិនបានបិទបាំង ២ គប្បីពោលថា បដិច្ឆន្នាយ ច អប្បដិច្ឆន្នានញ្ច ។

បើអាបត្តិដែលបិទបាំងទុកក៏មាន ២ ដែលមិនបានបិទបាំងទុក ក៏មាន ២ គប្បីពោលថា បដិច្ឆន្នានញ្ច អប្បដិច្ឆន្នានញ្ច ។

សង្ឃគប្បីតែងកម្មវាចាដ៏សមគួរ ឱ្យមានត្តក្នុងអាបត្តិដែលបិទបាំង និងមិនបានបិទបាំងទាំងពួង ។ និងគប្បីតែងកម្មវាចាដ៏សមគួរដល់មានត្តនោះ និងធ្វើអព្ភានដល់ភិក្ខុដែលប្រព្រឹត្តមានត្តហើយ ។

តែអព្ភានក្នុងបាលីនេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃអាបត្តិតែមួយ ។

មានត្តណា ដែលសង្ឃតែងឱ្យក្នុងទីបំផុតនៃបរិវាស ដើម្បីអាបត្តិដែលបិទបាំងទុកនិងបដិច្ឆន្នមានត្ត ព្រះមានព្រះភាគត្រាស់ ក្នុងបាលីនេះដោយកម្មវាចាសម្រាប់ជាគំរូមួយប៉ុណ្ណោះ គឺដោយអំណាចអាបត្តិតែមួយ ។

ខ្ញុំព្រះករុណានឹងពោលបក្ខមានត្ត និងសមោធានមានត្ត ក្នុងទីបំផុតនៃបរិវាសកថាដ៏សេស ។

# សុទ្ធន្តបរិវាស

[៤៦៦] បរិវាសដ៏សេស ២ យ៉ាង គឺ សុទ្ធន្តបរិវាស ១ សមោធានបរិវាស ១ ។

ក្នុងបរិវាស ២ យ៉ាងនោះ ដែលឈ្មោះសុទ្ធន្តបរិវាស បានដល់បរិវាសដែលទ្រង់អនុញ្ញាតក្នុងរឿងនេះថា តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុសម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបន្នោ ហោតិ ។ សោ[1] អាបត្តិបរិយន្តំ ន ជានាតិ រត្តិបរិយន្តំ ន ជានាតិ : សម័យនោះឯង មានភិក្ខុមួយរូប ត្រូវអាបត្តិសង្ឃាទិសេសជាច្រើន ភិក្ខុនោះមិនដឹងកំណត់អាបត្តិ ទាំងមិនដឹងកំណត់រាត្រី ។ ដូច្នេះ ក្នុងទីបំផុតនៃការប្រព្រឹត្តមានត្តដែលមិនជាធម៌ខាងដើម ។

សុទ្ធន្តបរិវាសនោះ មាន ២ យ៉ាង គឺ ចូឡសុទ្ធន្តៈ ១ មហាសុទ្ធន្តៈ ១ ក៏សុទ្ធន្តបរិវាសនេះទាំង ២ យ៉ាង សង្ឃគប្បីឱ្យដល់ភិក្ខុដែលមិនដឹងនិងរលឹកមិនបាន ទីកំណត់រាត្រីទាំងអស់ ឬរាត្រីខ្លះ និងអ្នកមានសេចក្តីសង្ស័យក្នុងការកំណត់រាត្រីនោះ ។ តែភិក្ខុនឹងដឹងចំនួនទីបំផុតនៃអាបត្តិថា យើងត្រូវអាបត្តិប៉ុណ្ណេះ ឬ មិនដឹងក៏ដោយ នោះមិនជាហេតុ មិនជាប្រមាណ ។

---

១. ភូមា. មិនមាន ពាក្យថា សោ នេះ ។

# ចូឡសុទ្ធន្តៈ

ក្នុងសុទ្ធន្តបរិវាស ២ យ៉ាងនោះ ភិក្ខុណា សូម្បីព្រះវិន័យធរសួរថា លោករលឹកដឹងថា លោកជាអ្នកបរិសុទ្ធិ រហូតដល់អស់មួយថ្ងៃ ឬបក្ខ ឬខែ ឬឆ្នាំ ឯណោះ និងឯណោះឬ ? ដូច្នេះ តាមលំដាប់ តាំងពីឧបសម្បទាមក ឬបព្វជ្ជាសលំដាប់តាំងពីថ្ងៃដែលប្រាប់ទៅក្តី ទើបឆ្លើយថា "ជ្រាបបាន លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាជាអ្នកបរិសុទ្ធិរហូតដល់អស់កាលត្រឹមតែប៉ុណ្ណេះ" ។

សុទ្ធន្តបរិវាសដែលសង្ឃឱ្យដល់ភិក្ខុនោះ ហៅថា ចូឡសុទ្ធន្តៈ ។ ភិក្ខុអ្នកទទួលចូឡសុទ្ធន្តបរិវាសនោះ នៅបរិវាស គប្បីបែងចែកកាលដែលខ្លួនរលឹកដឹងថា "ខ្លួនជាអ្នកបរិសុទ្ធិហើយ" គប្បីនៅបរិវាសរហូតដល់អស់១ខែ ឬ ២ ខែដ៏សេស ។

បើកំណត់បានថា "យើងជាអ្នកមិនបរិសុទ្ធិត្រឹមតែមួយខែ" បានទទួលបរិវាសហើយ, កំពុងនៅបរិវាសរលឹកខែដទៃបានទៀត គប្បីនៅបរិវាសរហូតដល់អស់ខែនោះដោយពិត, មិនមានកិច្ចដែលនឹងត្រូវឱ្យបរិវាសទៀត ។

បើកំណត់បានថា យើងជាអ្នកមិនបរិសុទ្ធិ ២ ខែ បានទទួលបរិវាសហើយ, តែកំពុងនៅបរិវាស ធ្វើសេចក្តីកំណត់ក្នុងចិត្តថា យើង

មិនបរិសុទ្ធិត្រឹមតែមួយខែប៉ុណ្ណោះ គប្បីនៅបរិវាសមួយខែប៉ុណ្ណោះ ។ មិនមានកិច្ចដែលនឹងត្រូវឱ្យបរិវាសទៀត ។ ពិតមែន ធម្មតាសុទ្ធន្តបរិវាសនេះ កើនឡើងក៏បាន ថយចុះក៏បាន ។ នេះជាលក្ខណៈរបស់សុទ្ធន្តបរិវាសនោះ ។

ចំណែកក្នុងការចេញចាកអាបត្តិដទៃ មានលក្ខណៈដូច្នេះ ៖

ភិក្ខុណាធ្វើវិន័យកម្មថា បិទបាំងទុកសម្រាប់អាបត្តិដែលមិនបានបិទបាំង, អាបត្តិរបស់ភិក្ខុនោះ រមែងចេញ ។ ចំណែកភិក្ខុណា ធ្វើវិន័យកម្មថា មិនបានបិទបាំងសម្រាប់អាបត្តិដែលបិទបាំង, អាបត្តិរបស់ភិក្ខុនោះ មិនចេញ ។ ភិក្ខុណាធ្វើវិន័យកម្មថា បិទបាំងទុកយូរ សម្រាប់អាបត្តិដែលបិទបាំងទុកមិនយូរ, អាបត្តិរបស់ភិក្ខុសូម្បីនោះ រមែងចេញ ។ ភិក្ខុណាធ្វើវិន័យកម្មថា បិទបាំងទុកមិនយូរ សម្រាប់អាបត្តិដែលបិទបាំងទុកយូរ ។ អាបត្តិរបស់ភិក្ខុសូម្បីនោះ មិនចេញ ។ ភិក្ខុណា ត្រូវអាបត្តិមួយធ្វើវិន័យកម្មថាច្រើន អាបត្តិរបស់ភិក្ខុសូម្បីនោះ រមែងចេញព្រោះវៀរអាបត្តិមួយចេញហើយ ច្រើនក៏មិនមាន ។ ចំណែកភិក្ខុណាត្រូវអាបត្តិច្រើន តែធ្វើវិន័យកម្មថា យើងត្រូវអាបត្តិតែមួយ, អាបត្តិរបស់ភិក្ខុសូម្បីនោះ មិនចេញ ។

# មហាសុទ្ធន្តៈ

ចំណែកភិក្ខុណា សូម្បីព្រះវិន័យធរសួរដោយន័យអនុលោមនិងបដិលោមដូចពោលហើយ មិនដឹង រលឹកមិនបាននូវទីបំផុតនៃរាត្រីឬជាអ្នកមានសេចក្ដីសង្ស័យ សុទ្ធន្តបរិវាសដែលសង្ឃឱ្យដល់ភិក្ខុនោះ ហៅថា មហាសុទ្ធន្តៈ ។ ភិក្ខុទទួលបរិវាសនោះហើយ គប្បីនៅបរិវាសរាប់រាត្រីតាំងពីថ្ងៃដែលទទួលដរាបដល់ថ្ងៃឧបសម្បទា ។

មហាសុទ្ធន្តៈនេះ មិនកើនឡើងទេ មានតែថយចុះ ព្រោះដូច្នោះ បើកំពុងនៅបរិវាស ធ្វើការតាំងចិត្តកំណត់រាត្រីទុកថា កាលយើងត្រូវអាបត្តិ ជាវេលា ១ ខែ ឬ១ឆ្នាំ; គប្បីនៅបរិវាស ១ខែ ឬ១ឆ្នាំ, ចំណែកលក្ខណៈការសូម និងការឱ្យបរិវាសក្នុងមហាសុទ្ធន្តបរិវាសនេះ គប្បីជ្រាបតាមន័យដែលមកក្នុងបាលី ( ទំព័រ៤៥ )ខាងដើមនុ៎ះឯង ។

ការសមាទានវត្ត ក្នុងទីបំផុតនៃកម្មវាចា មានវត្តនិងអព្ភាន មានន័យដូចពោលហើយនុ៎ះឯង ។ នេះឈ្មោះថា សុទ្ធន្តបរិវាស ។

# សមោធានបរិវាស

[៤៨៩] ដែលឈ្មោះសមោធានបរិវាស មាន ៣ យ៉ាង គឺ ឱធានសមោធាន ១ អគ្ឃសមោធាន ១ មិស្សកសមោធាន ១ ។

## ១. ឱធានសមោធាន

បណ្ដាសមោធានបរិវាស ៣ យ៉ាងនោះ ដែលឈ្មោះថា ឱធានសមោធាន លោកហៅបរិវាសដែលសង្ឃគប្បីរលាស់ចោល គឺ លប់ថ្ងៃដែលបាននៅបរិវាសហើយចេញ ប្រមូលអាបត្តិដែលត្រូវខាងក្រោយចុះក្នុងកំណត់ថ្ងៃពីដើមនៃអាបត្តិដើម ឱ្យដល់ភិក្ខុដែលត្រូវអាបត្តិក្នុងចន្លោះហើយបិទបាំងទុក ។

ឱធានសមោធានបរិវាសនោះ មានមកហើយខាងក្រោយ ក្នុងព្រះបាលីទុំះឯង ដោយពិស្ដារ តាំងពីពាក្យនេះថា "ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឱ្យបញ្ញាហបរិវាស (បរិវាស៥ថ្ងៃ)ដល់ឧទាយីភិក្ខុចំពោះអាបត្តិ១ ឈ្មោះថា សញ្ចេតនិកាសុក្កវិស្សដ្ឋិដែលបិទបាំងទុក ៥ ថ្ងៃចុះ" ។

ក៏វិនិច្ឆ័យក្នុងឱធានសមោធាននេះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុណា ទទួលបរិវាស ដើម្បីអាបត្តិដែលបិទបាំងហើយ កំពុងនៅបរិវាស ឬជាមានត្តារហៈ ឬកំពុងប្រព្រឹត្តមានត្ត ឬជាអព្ភានារហៈ

ត្រូវអាបត្តិដទៃហើយបិទបាំងទុក ស្មើនឹងរាត្រីរបស់អាបត្តិដើម ឬ តិចជាងក្តី សង្ឃគប្បីលប់ថ្ងៃដែលនៅបរិវាសហើយ និងថ្ងៃដែលប្រព្រឹត្តមានត្តហើយទាំងអស់នោះគឺ ធ្វើឱ្យជាថ្ងៃដែលមិនបានការ ប្រមូលអាបត្តិដែលត្រូវខាងក្រោយចុះក្នុងអាបត្តិដើម ឱ្យបរិវាសដល់ភិក្ខុនោះ ដោយមូលាយបដិកស្សនៈ ។

ភិក្ខុនោះ គប្បីនៅបរិវាស ១ បក្ខម្តងទៀត, បើអាបត្តិដើមបិទបាំងទុក ១ បក្ខ អន្តរាបត្តិបិទបាំងទុកតិចជាងបក្ខ ។ សូម្បីបើអន្តរាបត្តិបិទបាំងទុក ១ បក្ខគប្បីនៅបរិវាស ១ បក្ខដូចគ្នា, ដោយឧបាយនេះគប្បីជ្រាបវិនិច្ឆ័យដរាបដល់អាបត្តិដើមដែលបិទបាំងទុក ៦០ ឆ្នាំ ។ ពិតមែន ភិក្ខុដែលនៅបរិវាសគ្រប់ ៦០ ឆ្នាំ សូម្បីជាមានត្តរហៈ ហើយបិទបាំងអន្តរាបត្តិទុក ១ ថ្ងៃ រមែងជាអ្នកគួរនៅបរិវាស ៦០ ឆ្នាំទៀត ។ កាលភិក្ខុទាំងឡាយពោលថា ក៏បើថា អន្តរាបត្តិបិទបាំងទុកច្រើនជាងអាបត្តិដើម គប្បីធ្វើយ៉ាងណាក្នុងអាបត្តិនោះ ?

ព្រះមហាសុមត្ថេរៈពោលថា បុគ្គលនេះ ជាអតេកិច្ឆៈ, ធម្មតាបុគ្គលដែលជាអតេកិច្ឆៈ ក៏គួរឱ្យធ្វើឱ្យជាក់ច្បាស់ហើយលែងចោល ។

ចំណែកព្រះមហាបទុមត្ថេរៈឆ្លើយថា ព្រោះហេតុអ្វី បុគ្គលនេះទើបឈ្មោះថា ជាអតេកិច្ឆៈ ? ធម្មតាថា សមុច្ចយក្ខន្ធកៈនេះ រមែងដូចជាកាលដែលព្រះពុទ្ធទាំងឡាយទ្រង់នៅមានព្រះជន្ម ។

ដែលឈ្មោះថា អាបត្តិ ទីងបិទបាំងទុកក៏ដោយ មិនបានបិទបាំងទុកក៏ដោយ បិទបាំងទុកប៉ុនគ្នាក៏ដោយ តិចជាងក៏ដោយ សូម្បីបិទបាំងទុកច្រើនជាង ក៏ដោយ ; ការដែលព្រះវិន័យធរជាអ្នកអាចប្រកបកម្មវាចាទាំងឯង ជាប្រមាណក្នុងការកែខែអាបត្តិនេះ ព្រោះហេតុនោះ អន្តរាបត្តិណាបិទបាំងទុកច្រើនជាង, គប្បីធ្វើអន្តរាបត្តិនោះ ឱ្យជាអាបត្តិដើម ប្រមូលអាបត្តិក្រៅនេះចូលក្នុងអាបត្តិដើមនោះ ឱ្យបរិវាស ។

នេះឈ្មោះថា ឱធានសមោធាន ។

## ២. អគ្ឃសមោធាន

ដែលឈ្មោះអគ្ឃសមោធាន គឺ បណ្តាអាបត្តិទាំងឡាយច្រើនអាបត្តិពួកណា ទោះជាមួយក្តី ពីរក្តី បីក្តី ច្រើនក្តី ដែលបិទបាំងទុកយូរជាងអាបត្តិទាំងពួង, សង្ឃប្រមូលដោយតម្លៃនៃអាបត្តិទាំងនោះ ឱ្យបរិវាសដើម្បីអាបត្តិដ៏សេស ដែលបិទបាំងទុកតិចជាង ដោយអំណាចការកំណត់រាត្រីនៃអាបត្តិទាំងនោះ នេះហៅថា អគ្ឃសមោធាន ។

អគ្ឃសមោធាននោះ បានមកខាងដើមហើយក្នុងបាលី ដោយន័យជាដើមថា ក៏សម័យនោះ ភិក្ខុណាមួយ ត្រូវអាបត្តិសង្ឃាទិសេសច្រើន, អាបត្តិមួយបិទបាំងទុក ១ ថ្ងៃ អាបត្តិមួយបិទបាំងទុក ២ ថ្ងៃ ។

សួរថា ក៏អាបត្តិរបស់ភិក្ខុណាមានមួយៗបិទបាំងទុក ១០ ថ្ងៃ

សុម្បីមួយរយទៀត ក៏បិទបាំងទុក ១០ ថ្ងៃ យ៉ាងនេះ ១០ ដង, ទើបជាអាបត្តិមួយពាន់ បិទបាំងទុក១០០ ថ្ងៃ, ភិក្ខុនោះត្រូវធ្វើយ៉ាងណា ?

គប្បីប្រមូលអាបត្តិទាំងអស់នៅបរិវាស ១០ ថ្ងៃ ។ សុម្បីទាំងមួយរយថ្ងៃ រមែងជាថ្ងៃដែលភិក្ខុត្រូវនៅបរិវាសពិត ៗ ដោយ១០ ថ្ងៃត្រឹមតែមួយដងប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

ពិតមែន សុម្បីពាក្យនេះ ព្រះមានព្រះភាគក៏បានត្រាស់ទុកហើយថា "បរិវាសិកភិក្ខុបិទបាំងអាបត្តិអស់មួយរយរាត្រី ត្រូវជាមួយពាន់អាបត្តិ ហើយចូលបរិវាសនៅ ១០ រាត្រី រួច(ចាកអាបត្តិនោះ)បាន"[១], បញ្ហានេះ លោកអ្នកឆ្លាតទាំងឡាយ គិតគ្នាហើយ ។

នេះឈ្មោះថា អគ្ឃសមោធាន ។

## ៣. មិស្សកសមោធាន

ដែលមានឈ្មោះមិស្សកសមោធាន បានដល់ បរិវាសដែលសង្ឃរួមអាបត្តិផ្សេង ៗ វត្ថុចូលជាមួយគ្នាឱ្យ ។

ក្នុងមិស្សកសមោធាននោះ មានន័យដូច្នេះ ៖

គប្បីឱ្យភិក្ខុនោះសូម ៣ ដង ថា អហំ ភន្តេ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ ឯកំ សុក្កវិស្សដ្ឋិំ ឯកំ

១. វិន. បរិ. ទុតិយគាថាសង្គណិក. ១៣. ៣៥៨/៣៨៨ ។

កាយសំសគ្គំ ឯកំ ទុដ្ឋុល្លវាចំ ឯកំ អត្តកាមំ ឯកំ សញ្ចរិតំ ឯកំ កុដិការំ ឯកំ វិហារការំ ឯកំ ទុដ្ឋទោសំ ឯកំ អញ្ញភាគិយំ ឯកំ សង្ឃភេទកំ ឯកំ ភេទានុវត្តកំ ឯកំ ទុព្វចំ ឯកំ កុលទូសកំ, សោហំ ភន្តេ សង្ឃំ តាសំ អាបត្តីនំ សមោធានបរិវាសំ យាចាមិ : *បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិសង្ឃាទិសេសជាច្រើន ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ ១ កាយសំសគ្គៈ ១ ទុដ្ឋុល្លវាចា ១ អត្តកាមៈ ១ សញ្ចរិតៈ ១ កុដិការៈ ១ វិហារការៈ ១ ទុដ្ឋទោសៈ ១ អញ្ញភាគិយៈ ១ សង្ឃភេទកៈ ១ ភេទានុវត្តកៈ ១ ទុព្វចៈ ១ កុលទូសកៈ ១ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណានោះ សូមនូវសមោធានបរិវាសអំពីសង្ឃ ដើម្បីអាបត្តិទាំងឡាយនោះ ។*

*ដូច្នេះ ហើយគប្បីឱ្យបរិវាសដោយកម្មវាចាសមគួរដល់ពាក្យសូមនោះ ។*

*ក៏ក្នុងមិស្សកសមោធាននេះ សមគួរនឹងតែងកម្មវាចាប្រកបដោយអំណាចវត្ថុខ្លះ ដោយអំណាចគោត្រខ្លះ ដោយអំណាចឈ្មោះខ្លះ ដោយអំណាចអាបត្តិខ្លះ តាមន័យដែលពោលហើយ ក្នុងកាលខាងដើមនុ៎ះឯង យ៉ាងនេះថា* សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិ នានាវត្ថុកាយោ

: ដូច្នេះក៏បាន ថា សច្ឆាធិសេសា អាបត្តិយោ អាបជ្ជិ ដូច្នេះក៏បាន ។

នេះឈ្មោះថា មិស្សកសមោធាន ។

ចំណែកកថា សម្តែងរឿងមានជាដើម គឺ វត្ថុដែលជាក់ និងមិនបានជាក់ ក្នុងទីបំផុតនៃកម្មវាចាឱ្យបរិវាសទាំងពួង គប្បីជ្រាបតាមន័យមុនទុំះចុះ ។

បរិវាសកថា ចប់ ។

## បក្ខមានត្ត

ឥឡូវនេះ ដល់ឱកាសនៃពាក្យដែលខ្ញុំព្រះករុណាបានពោលទុកថា ខ្ញុំព្រះករុណានឹងពោលបក្ខមានត្ត និងសមោធានមានត្ត ក្នុងទីបំផុតនៃបរិវាសកថាដ៏សេស ព្រោះដូច្នោះ មានត្ត ២ យ៉ាងនោះ ខ្ញុំព្រះករុណានឹងពោលមានត្តដែលសង្ឃគប្បីឱ្យដល់ភិក្ខុនី ឈ្មោះថា បក្ខមានត្ត ។

ក៏បក្ខមានត្តនោះ សង្ឃគប្បីឱ្យកន្លះខែប៉ុណ្ណោះ ទាំងអាបត្តិដែលបិទ ទាំងអាបត្តិដែលមិនបានបិទ ។ ពិតមែន ពាក្យនេះ ព្រះមានព្រះភាគបានត្រាស់ទុកថា "គរុធម្មំ អជ្ឈាបន្នាយ ភិក្ខុនិយា ឧភតោសង្ឃេ បក្ខមានត្តំ ចរិតព្វំ : ភិក្ខុនីត្រូវគរុកាបត្តិហើយ គប្បីប្រព្រឹត្តបក្ខមានត្ត

ក្នុងសំណាក់សង្ឃទាំង ២ ពួក”[១] ។

ក៏បក្ខមានត្តនោះ ដែលភិក្ខុនីទាំងឡាយ គប្បីជម្រះសីមារបស់ខ្លួនឱ្យហ្មត់ចត់ហើយឱ្យក្នុងវិហារសីមា ឬកាលមិនអាចជម្រះវិហារសីមាឱ្យហ្មត់ចត់គប្បីឱ្យប្រជុំគណៈចតុវគ្គ ដោយកំណត់យ៉ាងទាបបំផុតហើយឱ្យក្នុងខណ្ឌសីមាក៏បាន ។

បើមានអាបត្តិតែមួយ, គប្បីតែងកម្មវាចាប្រកបដោយអំណាចអាបត្តិតែមួយ, បើមានអាបត្តិ ២ ឬ ៣ ឬច្រើន មានវត្ថុមួយ ឬ វត្ថុផ្សេង ៗគ្នា, គប្បីកាន់យកវត្ថុ គោត្រ នាម និងអាបត្តិដែលខ្លួនប្រាថ្នាតែងកម្មវាចាប្រកបដោយអំណាចនៃអាបត្តិទាំងនោះ ៗ ។

ឧទាហរណ៍ដែលល្មមជាគំរូ ដោយអំណាចអាបត្តិតែមួយ ក្នុងបក្ខមានត្ត នោះ ដូច្នេះ ៖

ភិក្ខុនីដែលត្រូវអាបត្តិហើយនោះ គប្បីចូលទៅរកភិក្ខុនីសង្ឃ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ថ្វាយបង្គំបាទារបស់ភិក្ខុនីទាំងឡាយ ដែលចាស់ជាង អង្គុយច្រហោងផ្គងអញ្ជលីពោលយ៉ាងនេះថា អហំ អយ្យេ ឯកំ **អាបត្តឹ អាបជ្ជឹ គាមន្តរំ, សាហំ អយ្យេ សង្ឃំ ឯកិស្សា អាបត្តិយា គាមន្តរាយ បក្ខមានត្តំ យាចាមិ** : បពិត្រលោកម្ចាស់

១. វិន. ចុល្ល. ភិក្ខុនីខន្ធកៈ. ១១. ១៨០/២៦៧ ។

ដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិ ១ ឈ្មោះគាមន្តរៈ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណានោះ សូមនូវបក្ខមានត្តអំពីសង្ឃ ដើម្បីអាបត្តិ ១ ឈ្មោះគាមន្តរនោះ ។

កាលឱ្យសូម ៣ ដងយ៉ាងនោះហើយ ភិក្ខុនីអ្នកឆ្លាតវាងវៃ គប្បីប្រកាសឱ្យសង្ឃជ្រាបថា បពិត្រលោកម្ចាស់សូមសង្ឃស្តាប់ខ្ញុំព្រះករុណា ភិក្ខុនីឈ្មោះនេះ រូបនេះ ត្រូវអាបត្តិ ១ ឈ្មោះគាមន្តរា, នាងសូមបក្ខមានត្តអំពីសង្ឃដើម្បីអាបត្តិ ១ ឈ្មោះគាមន្តរា បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ, សង្ឃគប្បីឱ្យបក្ខមានត្ត ដើម្បីអាបត្តិ១ ឈ្មោះគាមន្តរាដល់ភិក្ខុនីឈ្មោះនេះ ។ នេះជាពាក្យផ្តៀងសង្ឃឱ្យដឹង ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំព្រះករុណា ភិក្ខុនីឈ្មោះនេះ ត្រូវអាបត្តិ ១ ឈ្មោះគាមន្តរា, នាងសូមបក្ខមានត្តចំពោះសង្ឃ ដើម្បីអាបត្តិ១ ឈ្មោះគាមន្តរា សង្ឃឱ្យបក្ខមានត្ត ដើម្បីអាបត្តិ ១ ឈ្មោះគាមន្តរា ដល់ភិក្ខុនីឈ្មោះនេះ គាប់ចិត្តដល់លោកម្ចាស់ណា លោកម្ចាស់នោះគប្បីនៅស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់ណា លោកម្ចាស់នោះ គប្បីនិយាយឡើង ខ្ញុំព្រះករុណាពោលសេចក្តីនេះ ជាគម្រប់ពីរដងផង ។ល ។ ជាគម្រប់បីដងផង ។ បពិត្រលោកម្ចាស់ សូមសង្ឃស្តាប់ខ្ញុំព្រះករុណា ។ល ។ បក្ខមានត្ត ដើម្បីអាបត្តិ ១ ឈ្មោះគាមន្តរា សង្ឃឱ្យហើយដល់ភិក្ខុនីឈ្មោះនេះ គាប់ចិត្តដល់សង្ឃ; ព្រោះហេតុនោះ ទើបសង្ឃស្ងៀម ខ្ញុំព្រះ

ករុណាចាំទុកនូវសេចក្ដីនេះ យ៉ាងនេះ ។

ក្នុងទីបំផុតនៃកម្មវាចា ភិក្ខុនីជាមានត្តចារិកានោះ គប្បីសមាទានវត្ត ហើយ គប្បីប្រាប់ដល់សង្ឃ តាមន័យដែលពោលហើយ ក្នុងភិក្ខុមានត្តកថានុ៎ះចុះ បើប្រាថ្នានឹងដាក់វត្ត គប្បីដាក់ក្នុងកណ្ដាលជំនុំសង្ឃនោះក៏បាន កាលភិក្ខុនីទាំងឡាយ ជៀសចេញទៅហើយ គប្បីដាក់ក្នុងសំណាក់ភិក្ខុនីមួយរូប ឬក្នុងសំណាក់ភិក្ខុនីជាសម្លាញ់ តាមន័យដែលពោលហើយក៏បាន ។

មួយទៀត គប្បីប្រាប់ដាក់ក្នុងសំណាក់ភិក្ខុនីដទៃ ជាអាគន្តុកៈ ចាប់តាំងពីវេលាដែលដាក់វត្តទៅ តាំងនៅក្នុងឋានភិក្ខុនីជាបកតត្ត ។ តែកាលសមាទានថ្មីនឹងទទួលអរុណ មិនបានដើម្បីនៅក្នុងសំណាក់ភិក្ខុនីទាំងឡាយ ដោយពិត ។

ពិតមែន ព្រះមានព្រះភាគបានត្រាស់ទុកថា ភិក្ខុនីត្រូវគរុកាបត្តិ ហើយគប្បីប្រព្រឹត្តបក្ខមានត្ត ក្នុងសំណាក់សង្ឃទាំង ២ ពួក ។ ព្រោះដូច្នោះ អាចារ្យនិងឧបជ្ឈាយ៍របស់ភិក្ខុនីជាមានត្តចារិកានោះ គប្បីទៅកាន់វត្តហើយប្រាប់ព្រះមហាថេរៈ ឬភិក្ខុធម្មកថិក ១ រូប ដែលតាំងនៅក្នុងចំណែកនៃអ្នកសង្គ្រោះថា មានវិន័យកម្មដែលគប្បីធ្វើដល់ភិក្ខុនី ១ រូប, លោកម្ចាស់មេត្តាបញ្ជូន ភិក្ខុ ៤ រូបទៅក្នុងស្ថានទីធ្វើវិន័យកម្មនោះរបស់យើងទាំងឡាយចុះ ព្រះមហាថេរៈ ឬភិក្ខុជាធម្មកថិក នឹងមិនធ្វើការ

សង្គ្រោះ មិនបាន, ត្រូវប្រាប់ថា យើងនឹងបញ្ជូនទៅឱ្យ ។

ក្នុងកុរុន្ទីពន្យល់ថា បកតត្តភិក្ខុនី ៤ រូប គប្បីនាំនាងភិក្ខុនីដែលប្រព្រឹត្តមានត្តចេញទៅ មុនអរុណឱ្យលើស ២ លេណ្ឌុបាទអំពីឧបចារៈស្រុកចេញទៅ គេចចេញចាកមកធំ អន្លុយក្នុងទីដែលបិទបាំងដោយគុម្ពឈើនិងរបងជាដើម ។ គប្បីឱ្យលើស ២ លេណ្ឌុបាទសូម្បីអំពីឧបចារៈនៃវត្តចេញទៅ ។ ចំណែកភិក្ខុជាបកតត្ត ៤ រូប គប្បីទៅក្នុងទីនោះ ។ ក៏ឯកាលទៅហើយ មិនគប្បីអន្លុយក្នុងទីមួយជាមួយនឹងភិក្ខុនីទាំងឡាយ គប្បីជៀសទៅអង្គុយ ក្នុងទីមិនឆ្ងាយពេក ។

ចំណែកក្នុងមហាបច្ចរីជាដើមពន្យល់ថា សូម្បីភិក្ខុនីទាំងឡាយ ក៏គួរបបួលឧបាសិកា ១ នាក់ ឬ ២ នាក់ ដែលជាអ្នកឆ្លាតទៅផង ដើម្បីប្រយោជន៍ដល់ការរក្សាខ្លួន ចំណែកភិក្ខុទាំងឡាយ គប្បីបបួលឧបាសក ១ នាក់ ឬ ២ អ្នកទៅផង ដើម្បីប្រយោជន៍ដល់ការរក្សាខ្លួន ។

តែក្នុងកុរុន្ទីពន្យល់ថា ទីឯលះឧបចារៈនៃសំណាក់ភិក្ខុនី និងវត្តរបស់ភិក្ខុ ក៏គួរ, មិនពោលថា “ទីឯលះឧបចារៈនៃស្រុក ក៏គួរ” ទេ ។ កាលភិក្ខុទាំងឡាយ និងភិក្ខុនីទាំងឡាយ អង្គុយហើយយ៉ាងនោះ ភិក្ខុនីនោះ គប្បីសមាទានវត្តថា **មានត្តំ សមាទិយាមិ វត្តំ សមាទិយាមិ :** ខ្ញុំព្រះករុណាសូមសមាទាននូវមានត្ត សមាទាននូវវត្ត ហើយគប្បីប្រាប់ដល់ភិក្ខុសង្ឃមុន យ៉ាងនេះថា

អហំ អយ្យេ ឯកំ អាបត្តឹ អាបជ្ជឹ គាមន្តរំ, សាហំ សង្ឃំ ឯកិស្សា អាបត្តិយា គាមន្តរាយ បក្ខមានត្តំ យាចឹ ។ តស្សា មេ សង្ឃោ ឯកិស្សា អាបត្តិយា គាមន្តរាយ បក្ខមានត្តំ អទាសិ ។ សាហំ បក្ខមានត្តំ ចរាមិ ។ វេទិយាមហំ អយ្យេ, វេទិយតីតិ មំ សង្ឃោ ធារេតុ ។

*បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិ ១ ឈ្មោះគាមន្តរ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណានោះ សូមនូវបក្ខមានត្តអំពីសង្ឃ ដើម្បីអាបត្តិ ១ ឈ្មោះគាមន្តរៈនោះ ។ សង្ឃបានឱ្យហើយនូវបក្ខមានត្ត ដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិ ១ ឈ្មោះគាមន្តរនោះ, (ឥឡូវនេះ) ខ្ញុំព្រះករុណានោះ កំពុងប្រព្រឹត្តនូវបក្ខមានត្ត, បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណា សូមប្រាប់វត្ត សូមព្រះសង្ឃចាំទុកនូវខ្ញុំព្រះករុណាថា ភិក្ខុនីនេះបានប្រាប់វត្ត ។*

*ខាងក្រោយ គប្បីទៅប្រាប់ក្នុងសំណាក់ភិក្ខុសង្ឃយ៉ាងនេះថា*

អហំ អយ្យា ឯកំ អាបត្តឹ អាបជ្ជឹ គាមន្តរំ ។បេ ។ វេទិយាមហំ អយ្យា, វេទិយតីតិ មំ សង្ឃោ ធារេតុ : *បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិ ១ ឈ្មោះគាមន្តរៈ ។ល ។ បពិត្រព្រះ*

សង្ឃដ៏ចម្រើន ខ្ញុំព្រះករុណា សូមប្រាប់វត្ត សូមព្រះសង្ឃចាំទុកនូវខ្ញុំព្រះករុណាថា ភិក្ខុនីនេះបានប្រាប់វត្ត ។

សូម្បីក្នុងបក្ខមានត្តនេះ ភិក្ខុនីនឹងប្រាប់ដោយភាសា យ៉ាងណាមួយក៏គួរ ។ គប្បីអង្គុយប្រាប់ក្នុងសំណាក់នៃភិក្ខុនីសង្ឃប៉ុណ្ណោះ ។ ចាប់ផ្តើមតាំងពីកាលដែលប្រាប់ហើយទៅ ទើបគួរទៅកាន់សំណាក់នៃភិក្ខុទាំងឡាយ, បើទីនោះជាទីប្រកបដោយសេចក្តីរង្កៀស, ភិក្ខុនីទាំងឡាយចង់នៅក្នុងស្ថាននៃភិក្ខុទាំងឡាយ ក្នុងទីប៉ុណ្ណោះ; ភិក្ខុទាំងឡាយគប្បីរងចាំ ។

បើភិក្ខុ ឬភិក្ខុនីរូបដទៃ មកកាន់ទីនោះ, កាលឃើញត្រូវប្រាប់, បើមិនប្រាប់ ជារត្តិច្ឆេទ, និងត្រូវអាបត្តិទុក្កដ ព្រោះវត្តភេទ ។ បើកាលភិក្ខុនីជាមានត្តចារិកា មិនដឹងភិក្ខុ ឬភិក្ខុនីដទៃកន្លងឧបចារៈចូលមកយ៉ាងនោះហើយ ចេញទៅ ត្រឹមតែជារត្តិច្ឆេទ មិនត្រូវអាបត្តិទុក្កដ ព្រោះវត្តភេទ ។

បើភិក្ខុនីទាំងឡាយ ជាអ្នកចង់ប្រញាប់ទៅមុន ដើម្បីធ្វើវត្តដល់ឧបជ្ឈាយ៍ជាដើម គប្បីឃាត់ភិក្ខុនីទុក ១ រូប ដើម្បីការពាររត្តិវិប្បវាសាបត្តិ គណឱហាយនាបត្តិ និងគាមន្តរាបត្តិ ទើបទៅ ។ កាលអរុណរះឡើងហើយ ភិក្ខុនីនោះ គប្បីដាក់វត្តក្នុងសំណាក់ភិក្ខុនីនោះ ។

ភិក្ខុនីនោះ គប្បីប្រព្រឹត្តមានត្តគ្រប់ ១៥ រាត្រីមិនដាច់ដោយឧបាយនេះ ។ ចំណែកភិក្ខុនី ដែលមិនបានដាក់វត្ត គប្បីប្រព្រឹត្តដោយប្រពៃតាមន័យដែលពោលហើយ ក្នុងបារិវាសិកក្ខន្ធកៈនោះចុះ ។

ចំណែកសេចក្តីដែលប្លែកគ្នា មានដូចតទៅនេះ ៖

ក្នុងពាក្យថា **គប្បីប្រាប់ដល់អាគន្តុកៈ** នេះ មានវិនិច្ឆ័យថា ក្នុងបុរេភត្តឬបច្ឆាភត្ត ភិក្ខុឬភិក្ខុនីទាំងឡាយ មានប្រមាណប៉ុន្មាន មកកាន់ស្រុកនោះ ។ គួរប្រាប់ទាំងអស់ ។ កាលមិនប្រាប់ ជារត្តិច្ឆេទផង ត្រូវអាបត្តិទុក្កដ ព្រោះវត្តភេទផង, សូម្បីបើភិក្ខុរូបខ្លះ កន្លងតាមឧបចារៈនោះចូលមកក្នុងរាត្រី ហើយចេញទៅ ជារត្តិច្ឆេទប៉ុណ្ណោះ, រមែងផុតពីវត្តភេទ ព្រោះសេចក្តីមិនដឹងជាបច្ច័យ ។

ចំណែកក្នុងកុរុន្ទីជាដើមពោលថា វត្តដែលភិក្ខុនីមិនបានដាក់ បណ្ឌិតគប្បីពោលតាមន័យដែលពោលហើយ ក្នុងវត្តរបស់ភិក្ខុទាំងឡាយ ។ ពាក្យនោះប្រាកដថា សមគួរក្រៃលែង ព្រោះវត្តទាំងឡាយ មានបរិវាសវត្តជាដើម លោកកំណត់ដោយឧបចារៈសីមា ។ គប្បីប្រាប់ក្នុងថ្ងៃឧបោសថ ។ គប្បីប្រាប់ក្នុងថ្ងៃបវារណា ។ ត្រូវប្រាប់រាល់ថ្ងៃ ដល់ភិក្ខុ ៤ រូប និងភិក្ខុនី ៤ រូប បើភិក្ខាចារក្នុងស្រុកនោះ ទូទៅដល់ភិក្ខុទាំងឡាយផង ។ ភិក្ខុទាំង ៤ រូបនោះ គប្បីទៅក្នុងស្រុកនោះតែម្តង ។

បើមិនទូទៅដល់ភិក្ខុទាំងឡាយ សូម្បីទៅក្នុងទីដទៃហើយ ទើបមកក្នុងស្រុកនោះ ត្រូវសម្ដែងខ្លួនទៅ ។ ឬគប្បីធ្វើទីសង្កេតទុក ខាងក្រៅស្រុកថា "លោកទាំងជួបពួកយើងក្នុងទីឈ្មោះឯណោះ" ។ ភិក្ខុនីនោះគប្បីទៅកាន់ទីកំណាត់ទុកហើយប្រាប់, មិនជួបក្នុងទីកំណាត់ទុក ត្រូវទៅវត្តហើយប្រាប់, ត្រូវប្រាប់ភិក្ខុគ្រប់រូបក្នុងវត្ត បើមិនអាចប្រាប់គ្រប់រូបបាន, ត្រូវនៅក្រៅឧបចារៈសីមា ហើយពឹងពាក់ភិក្ខុនីទាំងឡាយទៅជំនួស ។ គប្បីប្រាប់ដល់ភិក្ខុ ៤ រូបដែលភិក្ខុនីទាំងនោះនាំមក ។ បើវត្តនៅឆ្ងាយទាំងគួរវង្វៀស, គប្បីបបួលឧបាសកនិងឧបាសិកាទាំងឡាយទៅផង ។

ក៏បើភិក្ខុនីនេះ នៅតាមទំនើងចិត្តខ្លួនឯង, រមែងត្រូវអាបត្តិ ព្រោះរត្តិវិប្បវាស; ព្រោះហេតុនោះ សង្ឃគប្បីសម្មតិនាងភិក្ខុនីជាបកតត្ត ១ រូប ឱ្យដល់ភិក្ខុនីនោះ ដើម្បីប្រយោជន៍ ដល់ការនៅក្នុងទីប្រកែតែមួយជាមួយគ្នា ។ ភិក្ខុនីប្រព្រឹត្តមានត្តមិនដាច់យ៉ាងនោះហើយ គប្បីធ្វើអព្ភានតាមន័យដែលពោល ហើយក្នុងភិក្ខុសង្ឃ ដែលមាន ២០ រូបជាគណៈទុះចុះ ។

ក្នុងកុរុន្ទីពោលថា បើកំពុងប្រព្រឹត្តមានត្ត ត្រូវអន្តរាបត្តិ សង្ឃគប្បីនាំចូលរកអាបត្តិដើមហើយ ឱ្យមានត្ត ដើម្បីអាបត្តិនោះ ។ នេះឈ្មោះថា បក្ខមានត្ត ។

# សមោធានមានត្ត

[៥០៨] ចំណែកសមោធានមានត្ត មាន ៣ យ៉ាង គឺ ឱធានសមោធាន ១ អគ្ឃសមោធាន ១ មិស្សកសមោធាន ១ ។

ក្នុងបណ្តា ៣ យ៉ាងនោះ ដែលឈ្មោះថា ឱធានសមោធាន បានដល់ មានត្ត ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកខាងដើម សម្រាប់ព្រះឧទាយីថេរៈ ដែលកំពុងនៅបរិវាសដើម្បីអាបត្តិដែលបិទបាំងទុក ៥ ថ្ងៃ ត្រូវអន្តរាបត្តិក្នុងបរិវាស និងក្នុងឋានៈដែលជាអ្នកគួរដល់មានត្ត ត្រូវសង្ឃទាញមកដាក់ក្នុងអាបត្តិដើម ដោយបាលីថា "តេនហិ ភិក្ខវេ សង្ឃោ ឧទាយិស្ស ភិក្ខុនោ តិស្សន្នំ អាបត្តីនំ ឆារត្តំ មានត្តំ ទេតុ : ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឱ្យមានត្ត ៦ រាត្រី ដល់ឧទាយីភិក្ខុ ចំពោះអាបត្តិ ៣ ចុះ"[១] ដូច្នេះ ។

ពិតមែន មានត្តប្រភេទនេះ សង្ឃលប់ថ្ងៃដែលនៅបរិវាសហើយចេញ ដោយមូលាយបដិកស្សនៈដដែលដូចគ្នា ប្រមូលឱ្យព្រមនឹងអាបត្តិដើមទាំងឡាយ ព្រោះដូច្នោះ ទើបហៅថា ឱធានសមោធាន ។

ចំណែកក្នុងកុរុន្ទីពោលថា មានត្តដែលសង្ឃគប្បីឱ្យដល់ភិក្ខុដែល

១. វិន. ចុល្ល. សមុច្ចយក្ខន្ធកៈ. ៩. ៤២៦/៣២១ ។

នៅសមោធានបរិវាសហើយ ឈ្មោះថា សមោធានមានត្ត សូម្បីពាក្យនោះ ក៏ត្រូវដោយបរិយាយនោះ ។

ចំណែកអគ្ឃសមោធាន និងមិស្សកសមោធាន លោកហៅចំពោះមានត្ត ដែលសង្ឃគប្បីឱ្យក្នុងទីបំផុតនៃអគ្ឃសមោធានបរិវាស និងមិស្សកសមោធានបរិវាស ។

អគ្ឃសមោធាននិងមិស្សកសមោធាននោះ គប្បីប្រកបឱ្យតាមទំនងកម្មវាចានៃបរិវាស ។

ពាក្យណាដែលខ្ញុំព្រះករុណាបានពោលទុកថា បរិវាសនិងមានត្ត ព្រះមានព្រះភាគត្រាស់ទុកក្នុងបាលី ដោយអាការច្រើនយ៉ាងតាមន័យមានពាក្យថា "ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរឱ្យឯកាហបរិវាស (បរិវាស១ ថ្ងៃ) ដល់ឧទាយីភិក្ខុ ចំពោះអាបត្តិ ១ ឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ ដែលបិទបាំងទុក ១ ថ្ងៃចុះ"[១] ដូច្នេះជាដើម, វិនិច្ឆ័យយ៉ាងនេះ ដែលលោកពោលទុកក្នុងអនាគតស្ថាននៃបរិវាស និងមានត្តនោះ រមែងដល់សេចក្តីពិស្តារពេក ដូចក្នុងបាលី, ទាំងជាវិនិច្ឆ័យដែលអ្នកណា ៗ មិនអាចកំណត់បានដោយងាយ, ព្រោះហេតុនោះ ខ្ញុំព្រះករុណានឹងប្រមូលបរិវាស និងមានត្តនោះ សម្តែងក្នុងអធិការនេះតែ

---

១. វិន. ចុល្ល. សមុច្ចយក្ខន្ធកៈ. ៩. ៣៨៣/២៥៧ ។

ម្តង ដូច្នេះ ពាក្យនេះ ជាការដែលខ្ញុំព្រះករុណាឱ្យសម្រេចព្រមដោយអធិប្បាយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ ព្រះបាលីណា ដែលព្រះមានព្រះភាគត្រាស់ជំបូងដោយអំណាចអាបត្តិតែមួយដែលមិនបានបិទបាំង, ព្រះបាលីនោះ មានសេចក្តីងាយទាំងអស់ ។

[៣៩២] ខាងមុខអំពីនោះ ព្រះមានព្រះភាគត្រាស់បរិវាសទុកក្នុងព្រះបាលី ដោយអំណាចនៃអាបត្តិដែលបិទបាំងទុក ២ ថ្ងៃ ៣ ថ្ងៃ ៤ ថ្ងៃ ៥ ថ្ងៃប៉ុណ្ណោះ ហើយទ្រង់សម្តែងអន្តរាបត្តិ ចាប់ផ្តើមតាំងពីបរិវាសដើម្បីអាបត្តិដែលបិទបាំងទុក ៥ ថ្ងៃ ។

ក៏ព្រះឧទាយីត្រូវអាបត្តិនោះហើយ រមែងចាត់ជាអ្នកគួរដល់មូលាយបដិកស្សនៈ; ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់អនុញ្ញាតមូលាយបដិកស្សនៈក្នុងអាបត្តិដែលបិទបាំងទុក ៥ ថ្ងៃទាំងនោះ ដល់ព្រះឧទាយីនោះ ។

តែបើលោកដាក់វត្តហើយត្រូវទៀត រមែងជាអ្នកមិនសមគួរដល់មូលាយបដិកស្សនៈ ។

ព្រោះហេតុអ្វី ?

ព្រោះលោកមិនបានត្រូវក្នុងពេលកំពុងនៅបរិវាស លោកតាំងនៅក្នុងឋានៈជាភិក្ខុបកតត្តហើយត្រូវ លោកគប្បីញែកការប្រព្រឹត្តមានត្តដើម្បី

អាបត្តិនោះ ។ បើលោកអ្នកដាក់វត្តត្រូវអាបត្តិហើយ បិទបាំងទុកសោត ត្រូវនៅបរិវាសផង ។

កាលមូលាយបដិកស្សនៈ ដែលព្រះមានព្រះភាគត្រាស់ទុក ដែលសង្ឃធ្វើហើយ, ថ្ងៃទាំងឡាយដែលលោកនៅបរិវាសហើយ រមែងជាការលុបចោលពិត ។

ព្រះមានព្រះភាគ ទ្រង់សម្តែងអន្តរាបត្តិ ក្នុងបរិវាសហើយ ទ្រង់សម្តែងអន្តរាបត្តិដល់ភិក្ខុដែលគួរដល់មានត្តទៀត ហើយ ទើបត្រាស់មូលាយបដិកស្សនៈ ដោយប្រការដូច្នេះ ។

ពិតមែន កាលមូលាយបដិកស្សនៈនោះ ដែលសង្ឃធ្វើហើយ, ថ្ងៃទាំងឡាយដែលនៅបរិវាសហើយ រមែងជាការលុបចោលពិត ។ លំដាប់នោះ ទើបទ្រង់សម្តែងសមោធានមានត្ត ដើម្បីអាបត្តិទាំង ៣ នោះនៃភិក្ខុដែលនៅបរិវាសរួចហើយ ។ លំដាប់នោះ ទ្រង់បានសម្តែងអន្តរាបត្តិរបស់ភិក្ខុដែលជាមានត្តចារិកៈ ហើយត្រាស់មូលាយបដិកស្សនៈ ។

ក៏កាលមូលាយបដិកស្សនៈនោះ ដែលសង្ឃធ្វើហើយ; ថ្ងៃដែលប្រព្រឹត្តមានត្តហើយក្តី ថ្ងៃដែលនៅបរិវាសហើយក្តី រមែងជាការលុបចោលពិត ។ លំដាប់នោះ ទ្រង់សម្តែងអន្តរាបត្តិនៃភិក្ខុដែលគួរដល់អព្ភាន ហើយត្រាស់មូលាយបដិកស្សនៈ ។

សូម្បីកាលមូលាយបដិកស្សនៈនោះ ដែលសង្ឃធ្វើហើយ, ថ្ងៃ

ដែលនៅបរិវាស និងប្រព្រឹត្តមានត្តហើយ ទាំងអស់នោះ រមែងជាការលុបចោលពិត ។ បន្ទាប់អំពីនោះ ទ្រង់ប្រកបអន្តរាបត្តិទាំងពួងសម្តែងអព្ភានកម្ម ។

កម្មវាចា ៥ ប្រភេទ ។ ដោយអំណាចនៃអាបត្តិ ដែលបិទបាំងទុក មួយថ្ងៃជាដើម កម្មវាចា ៤ ប្រភេទ ដោយអំណាចនៃអន្តរាបត្តិទាំងឡាយ រួមជាកម្មវាចា ៩ ប្រភេទ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយក្នុងបដិច្ឆន្នវារៈ ដោយប្រការដូច្នេះ ។

[៤២១] បន្ទាប់តអំពីនោះ ទ្រង់សម្តែងសមោធានបរិវាស និងសមោធានមានត្ត ដោយអំណាចនៃអន្តរាបត្តិដែលបិទបាំងទុក ៥ ថ្ងៃចាប់តាំងពីខាងក្នុងនៃបរិវាសដើម្បីអាបត្តិដែលបិទបាំងទុក ១ បក្ខ ។

ក៏ក្នុងអធិការពោលអំពីសមោធានបរិវាស និងសមោធានមានត្តនេះ កាលសង្ឃធ្វើមូលាយបដិកស្សនៈ ដើម្បីអាបត្តិដែលត្រូវ សូម្បីក្នុងវេលាដែលជាមានត្តចារិកៈ និងជាមានត្តរហៈ ថ្ងៃ ដែលប្រព្រឹត្តមានត្តហើយក្តី ថ្ងៃដែលនៅបរិវាសរួចហើយក្តី ជាការលុបចោលទាំងអស់តែម្តង ។

ព្រោះហេតុអ្វី ?

ព្រោះហេតុដែលបិទបាំងអន្តរាបត្តិទុក ។ ដោយហេតុនោះឯងព្រះមានព្រះភាគ ទើបត្រាស់ពាក្យថា "មូលាយ បដិកស្សិត្វា បុរិមាយ អាបត្តិយា សមោធានបរិវាសំ ទត្វា ឆារត្តំ មានត្តំ ទេតុ : ចូរទាញមក

ដាក់ក្នុងមូលាបត្តិ ហើយឱ្យសមោធានបរិវាស ចំពោះអាបត្តិខាងដើម ហើយសឹមឱ្យមានត្ត ៦ រាត្រីទៅចុះ"[១] ។

[៤៣៩] បន្ទាប់អំពីនោះ ទ្រង់ប្រកបអន្តរាបត្តិទាំងពួង សម្តែងអព្ភានកម្ម ឱ្យចប់រឿងនៃអាបត្តិ ឈ្មោះសញ្ចេតនិកាសុក្កវិស្សដ្ឋិ ។

[៤៤០] លំដាប់នោះ ទ្រង់សម្តែងន័យ ២ យ៉ាង គឺ ឯកាបត្តិមូលកន័យ ១ អាបត្តិវឌ្ឍនកន័យ ១ ហើយទ្រង់សម្តែងអគ្ឃសមោធានបរិវាស ។

[៤៤៩-៤៥៥] តអំពីនោះ ទ្រង់សម្តែងរឿងអាបត្តិ ដែលភិក្ខុក្លែងមិនប្រាប់ហើយ ទ្រង់តាំងបាលីដោយន័យមានពាក្យថា ឥធ បន ភិក្ខវេ ជាដើម ដើម្បីសម្តែងកម្ម ដែលគប្បីធ្វើសម្រាប់អាបត្តិ ដែលភិក្ខុមិនបានប្រាប់ ដោយការមិនបានក្លែង មិនដឹង រលឹកមិនបាន និងជាអ្នកមានសេចក្តីសង្ស័យ ក្នុងកាលលជ្ជីធម៌ ឬការដឹង ការរលឹកបាន និងជាអ្នកមិនមានសេចក្តីសង្ស័យ កើតឡើងខ្លះ ក្នុងកាលខាងក្រោយ ។

លំដាប់នោះ ទ្រង់សម្តែងបាលីដូចនោះ ដើម្បីសម្តែងអាបត្តិទាំងឡាយ ដែលបិទបាំងទុក ដោយការមិនដឹង រលឹកមិនបាន និងភាពជាអ្នកមានសេចក្តីសង្ស័យ មិនជាការបិទបាំង ។

---

១. វិន. ចុល្ល. សមុច្ចយក្ខន្ធកៈ. ៩. ៤២៩/៣២៤ ។

[៤៥៦-៤៦៥] លំដាប់នោះ ទ្រង់សម្តែងរឿងសូមបរិវាស១ខែ ដើម្បីអាបត្តិ ២ បិទបាំងទុក ២ ខែ ហើយទ្រង់តាំងបាលីដោយន័យមុននុ៎ះឯង ដើម្បីសម្តែងកម្មដែលគប្បីធ្វើ សម្រាប់ខែក្រៅនេះ ដែលមិនបានប្រាប់ ដោយមិនបានក្លែង មិនដឹង រលឹកមិនបាន និងភាពជាអ្នកមានសេចក្តីសង្ស័យ ក្នុងកាលលជ្ជីធម៌ជាដើម កើតឡើងខាងក្រោយ និងដើម្បីសម្តែងនូវខែដែលបិទបាំងទុក ដោយការមិនដឹង រលឹកមិនបាន និងភាពជាអ្នកមានសេចក្តីសង្ស័យ មិនជាការបិទបាំង ។

[៤៦៦-៤៧០] លំដាប់នោះ ទ្រង់សម្តែងសុទ្ធន្តបរិវាស ដោយន័យមានពាក្យថា អាបត្តិបរិយន្តំ ន ជានាតិ រត្តិបរិយន្តំ ន ជានាតិ : មិនដឹងកំណត់អាបត្តិ មិនដឹងកំណត់រាត្រី ជាដើម ។

[៤៧១] តអំពីនោះ ទ្រង់តាំងបាលីដើម្បីធ្វើបារិវាសិកភិក្ខុ ឱ្យជាគំរូសម្តែងការបដិបត្តិក្នុងពាក្យថា "សឹកហើយឧបសម្បទាថ្មី" ជាដើម ។

[៤៨៨-៥០៧] បណ្តាបទទាំងនោះ ក្នុងបទថា អន្តរា សម្ពហុលា អាបត្តិយោ អាបជ្ជតិ បរិមាណា អប្បដិច្ឆន្នាយោ : ត្រូវអាបត្តិសង្ឃាទិសេស ច្រើនក្នុងចន្លោះ កំណត់រាប់បាន មិនបានបិទបាំងទុក ជាដើម មានសេចក្តីថា កំណត់រាប់បានដោយអំណាចការកំណត់អាបត្តិនិងមិនបានបិទបាំងទុក ។

[៥០៩] ពីរបទថា បច្ឆិមស្មឹ អាបត្តិក្ខន្ធេ : កងអាបត្តិ ខាងក្រោយប៉ុន្មានថ្ងៃ គឺ កងអាបត្តិនោះ គង់ជាអាបត្តិដូចគ្នាតែមួយដូចគ្នា, តែព្រោះបិទបាំងទុក ក្នុងកាលជាខាងក្រោយ លោកទើបពោលថា "ចំពោះកងអាបត្តិ ខាងក្រោយប៉ុន្មានថ្ងៃ" ។

[៥១០] សូម្បីក្នុងពាក្យថា បុរិមស្មឹ : ពីមុន នេះ ក៏មានន័យដូចគ្នា ។

[៥៥៤] ពាក្យថា វវត្ថិតា សម្ភិន្នា : ជាអាបត្តិដែលកំណត់បាន ជាអាបត្តិដែលច្រឡូកច្រឡំគ្នា នេះ ជាពាក្យហៅអាបត្តិទាំងឡាយដែលជាសភាគគ្នា និងដែលជាវិសភាគគ្នាទុំះឯង ។

[៥៥៥] ខាងមុខអំពីនោះ ត្រាស់ពាក្យថា ទ្វេ ភិក្ខូ : មានភិក្ខុពីររូប ជាដើម ដើម្បីសម្តែងការបដិបត្តិក្នុងភិក្ខុដែលបិទបាំងទុក ។

បណ្តាបទទាំងនោះ បទថា មិស្សកំ បានដល់ សង្ឃាទិសេស ដែលលាយដោយលហុកាបត្តិ មានថុល្លច្ច័យជាដើម ។

បទថា សុទ្ធកំ បានដល់ សង្ឃាទិសេស វៀរកងលហុកាបត្តិចេញទាំងនោះ ។

[៥៧៨] តអំពីនោះទៀត ត្រាស់ពាក្យថា ឥធ បន ភិក្ខវេ ភិក្ខុ សម្ពហុលា សង្ឃាទិសេសា : ម្នាលភិក្ខុទាំងឡាយ ភិក្ខុធម្មវិន័យ

នេះ ត្រូវអាបត្តិសង្ឃាទិសេស ជាច្រើន ជាដើម ដើម្បីសម្តែងអាបត្តិទាំងនោះ ដែលមិនស្រេបគ្នានិងស្រេបគ្នា ។

បទណា ៗ ដែលឈ្មោះថា មិនច្បាស់លាស់ ដោយព្យញ្ជនៈ ឬដោយអធិប្បាយ រមែងមិនមានក្នុងពាក្យនោះ ... ។

ព្រោះដូច្នោះ ពាក្យនោះ និងពាក្យទាំងពួងដែលមិនបានពោលទុកពីមុននេះ គប្បីជ្រាបតាមផ្លូវនៃព្រះបាលីនុ៎ះឯង ដោយប្រការដូច្នេះ ។

## សមុច្ចយក្ខន្ធកវណ្ណនា ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## ចុល្លវគ្គ

## បឋមភាគ ៩

## ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## ចុល្លវគ្គ

## ទុតិយភាគ ១០

# ១៤. សមថក្ខន្ធកវណ្ណនា

## សម្មុខាវិន័យ

[១] វិនិច្ឆ័យក្នុងសមថក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

[២] ព្រះមានព្រះភាគ ទ្រង់ដាក់បទមាតិកា ៦ មានពាក្យថា អធម្មវាទី បុគ្គលោ : អ្នកពោលមិនត្រូវតាមធម៌ ជាដើម ។

[៣] ត្រាស់សេចក្ដីពិស្ដារ ដោយន័យមានពាក្យថា អធម្មវាទីបុគ្គលោ ធម្មវាទី បុគ្គលំ សញ្ញាបេតិ : បុគ្គលជាអធម្មវាទីញុំាងបុគ្គលដែលជាធម្មវាទីឱ្យកត់សំគាល់ ជាដើម ។

បណ្ដាបទទាំងនោះ បទថា សញ្ញាបេតិ បានដល់ ពោលពាក្យដែលសមនឹងហេតុ បន្ទំឱ្យយល់ព្រម ។

បទថា និជ្ឈាបេតិ : ឱ្យពិចារណា គឺ ធម្មវាទីបុគ្គលនោះ នឹងសម្លឹងមើល គឺ ក្រឡេកមើលសេចក្ដីនោះ ដោយប្រការណា, រមែងធ្វើដោយប្រការនោះ ។

ពីរបទថា បេក្ខេតិ អនុបេក្ខេតិ : ឱ្យពិនិត្យ ឱ្យពិនិត្យរឿយ ៗ គឺ ធម្មវាទីបុគ្គលនោះ នឹងសម្លឹងមើល នឹងសម្លឹងមើលរឿយ ៗ នូវសេចក្ដីនោះ ដោយប្រការណា, រមែងធ្វើដោយប្រការនោះ ។

ពីរបទថា ទស្សេតិ អនុទស្សេតិ : ឱ្យឃើញ ឱ្យឃើញរឿយ ៗ

ជាពាក្យបរិយាយនៃពីរបទថា បេក្ខេតិ អនុបេក្ខេតិ នោះឯង ។

ពីរបទថា អធម្មេន វូបសមតិ : រម្ងាប់ដោយមិនត្រឹមត្រូវតាមធម៌ មានសេចក្តីថា ព្រោះហេតុដែលអធម្មវាទីបុគ្គលនោះ ញ៉ាំងធម្មវាទីបុគ្គលនោះ ឱ្យវង្វេងហើយ សម្តែងអធម៌ទុំះឯង ដោយន័យមានជាដើមថា "នេះជាធម៌", ព្រោះហេតុនោះ អធិករណ៍ ទើបឈ្មោះថា រម្ងាប់ដោយអធម៌ ។

[៤] ពីរបទថា ធម្មេន វូបសមតិ : រម្ងាប់ដោយធម៌ មានសេចក្តីថា ព្រោះហេតុដែលធម្មវាទីបុគ្គល មិនញ៉ាំងអធម្មវាទីបុគ្គលឱ្យវង្វេង សម្តែងធម៌ទុំះឯង ដោយន័យមានពាក្យថា នេះជាធម៌ជាដើម ។ ព្រោះហេតុនោះ អធិករណ៍ ទើបឈ្មោះថា រម្ងាប់ដោយធម៌ ។

## សតិវិន័យ

[១៥] ក្នុងពាក្យថា បញ្ចិមានិ ភិក្ខវេ ធម្មិកានិ សតិវិនយស្ស ទានានិ : ម្នាលភិក្ខុទាំងឡាយការឱ្យសតិវិន័យ ដែលប្រកបដោយធម៌នេះ មាន ៥ យ៉ាង នេះ ការឱ្យមាន ៥ យ៉ាងនេះ គឺ ឱ្យដល់ភិក្ខុដែលបរិសុទ្ធិមិនមានអាបត្តិ១ ឱ្យដល់ភិក្ខុត្រូវគេចោទ១ ឱ្យដល់ភិក្ខុដែលសូម១ សង្ឃឱ្យខ្លួនឯង១ សង្ឃព្រមព្រៀងគ្នាតាមធម៌ឱ្យ១ ។

ក្នុងពាក្យថា **បញ្ចិមានិ ភិក្ខវេ** ជាដើមនេះ មានអធិប្បាយដូច្នេះថា ការឱ្យសតិវិន័យ ៥ នេះ ភិក្ខុរមែងបានដោយអំណាចអង្គមួយ ៗ ក៏ទេ, ព្រោះដូច្នោះ ពាក្យនោះ ទើបត្រឹមតែជាទេសនាប៉ុណ្ណោះ ។ តែការឱ្យសតិវិន័យប្រកបដោយអង្គ ៥ ទើបប្រកបដោយធម៌ ។

ក៏ឯបណ្តាបទទាំងនោះ គប្បីជ្រាបដូច្នេះ ៖

បទថា **អនុវទន្តិ** បានដល់ **ចោទេន្តិ** : ចោទ ។ បទដ៏សេសងាយយល់ទាំងអស់ ។

មួយទៀត សតិវិន័យនេះ គប្បីឱ្យដល់ព្រះខីណាស្រពប៉ុណ្ណោះ, មិនគប្បីឱ្យដល់ភិក្ខុដទៃ ដោយហោចទៅសូម្បីជាព្រះអនាគាមី ។

ក៏សតិវិន័យនោះឯង គប្បីឱ្យដល់ព្រះខីណាស្រពដែលត្រូវភិក្ខុដទៃចោទប៉ុណ្ណោះ មិនគប្បីឱ្យដល់ព្រះខីណាស្រព ដែលមិនត្រូវចោទ ។

ក៏កាលសតិវិន័យនោះ ដែលសង្ឃឱ្យហើយ ពាក្យរបស់អ្នកចោទរមែងមិនឡើង ។ សូម្បីអ្នកចោទ រមែងជាអ្នកដែលភិក្ខុទាំងឡាយគប្បីរុករានថា "ភិក្ខុនេះ ជាព្រះខីណាស្រព បានសតិវិន័យហើយ, អ្នកណា នឹងជឿតាមពាក្យរបស់លោក" ។

## អមូឡ្ហវិន័យ

[១៦] បទថា ភាសិតបរិក្កន្តំ : បានពោលនិងព្យាយាម បានដល់ ពោលដោយវាចា ព្យាយាមដោយកាយនោះតែម្តង អធិប្បាយថា ប្រព្រឹត្តល្មើស ធ្វើទាំងបំពាន ។

ក្នុងពាក្យថា សរតាយស្មា ឯវរូបឹ អាបត្តឹ អាបជ្ជិតា : លោកដ៏មានអាយុចូររលឹកមើលចុះ លោកជាអ្នកត្រូវអាបត្តិមានសភាពយ៉ាងនេះ នេះ មានសេចក្តីដូច្នេះថា "អ្នកមានអាយុ ចូររលឹកដល់អាបត្តិបែបនេះ, អ្នកមានអាយុ ត្រូវនូវអាបត្តិបែបនេះ" ។ បាលីថា អាបជ្ជិត្វា ក៏មាន ។ សេចក្តីនៃបាលីនោះថា "អ្នកមានអាយុត្រូវមុនហើយ ខាងក្រោយចូររលឹកដល់អាបត្តិនោះ" ។

## យេភុយ្យសិកា

[២៧] ក្នុងពាក្យថា យេភុយ្យសិកាយ វូបសមេតុំ : រម្ងាប់ដោយយេភុយ្យសិកា នេះ ធម្មវាទីបុគ្គលនៃកិរិយាណា ជាអ្នកច្រើនជាងកិរិយានោះ ឈ្មោះថា យេភុយ្យសិកា ។

វិនិច្ឆ័យក្នុងការចាប់ស្លាកដែលមិនជាធម៌ គប្បីជ្រាបដូច្នេះ ៖

[២៨] បទថា ឱរមត្តកំ : បន្តិចបន្តួច គឺ អធិករណ៍ជារឿង

តូច គឺ មានប្រមាណតិច ត្រឹមតែជាការបន្តហេតុប៉ុណ្ណោះ ។

បទថា **ន ច គតិគតំ : មិនទៅតាមគតិ ១** គឺ អធិករណ៍មិនរាលដាលទៅដល់ ២-៣ អាវាស ឬមិនបានវិនិច្ឆ័យដល់ ២-៣ គ្រាក្នុងអាវាសនោះ ៗ ប៉ុណ្ណោះ ។

បទថា **ន ច សរិតសារិតំ : មិនទាន់បានរំលឹកខ្លួនឯងនិងរំលឹកអ្នកដទៃ ១** គឺ អធិករណ៍នោះ មិនជារឿង ដែលភិក្ខុទាំងនោះរលឹកបានខ្លួនឯង ឬភិក្ខុពួកដទៃជាស់តឿនឱ្យរលឹក បានដល់ ២-៣ដង ។

បទថា **ជានាតិ : ដឹង** គឺ កាលចាប់ស្លាកដឹងថា "អធម្មវាទីបុគ្គលច្រើនជាង" ។

បទថា **អប្បេវនាម : ធ្វើដូចម្តេចហ្ន៎** គឺ អធ្យាស្រ័យរបស់ភិក្ខុនោះ រមែងរិះគិតដូច្នេះថា "កាលស្លាកដែលយើងឱ្យភិក្ខុទាំងឡាយ ចាប់ដោយឧបាយនេះ ឈ្មោះថា សូម្បីយ៉ាងណា អធម្មវាទីបុគ្គលគប្បីជាអ្នកច្រើនជាង" សូម្បីក្នុង ២ បទទៀត ក៏មានន័យដូចគ្នា ។

ពីរបទថា **អធម្មេន គណ្ហន្តិ : ចាប់ស្លាកដោយមិនតាមធម៌** គឺ ពួកអធម្មវាទី ចាប់ស្លាកមួយរូប ៗ ២ ស្លាក ដោយគិតថា "ពួកយើងនឹងជាអ្នកច្រើនជាងដោយការចាប់ស្លាកយ៉ាងនេះ" ។

ពីរបទថា **វគ្គា គណ្ហន្តិ : ចាប់ស្លាកជាពួក ៗ** គឺ ពួកអធម្មវាទីសម្គាល់ថា "ធម្មវាទី ២ រូប ចាប់ស្លាកធម្មវាទី ១ ដោយការចាប់

ស្អាតយ៉ាងនេះ ពួកធម្មវាទី នឹងជាអ្នកមិនច្រើនជាង” ។

ពីរបទថា ន ច យថាទិដ្ឋិយា គណ្ហន្តិ : មិនចាប់ស្លាកតាមសមគួរដល់ទិដ្ឋិ ១ គឺ ចាប់ស្លាកផ្ទែកអធម្មវាទី ដោយគិតថា “យើងជាពួកធម្មវាទី នឹងជាផ្នែកមានកម្លាំង” ។ ក្នុងការចាប់ស្លាកហើយយ៉ាងនោះ បើធម្មវាទីជាចំណែកច្រើនជាង ពួកលោកពោលយ៉ាងណា គប្បីរម្ងាប់អធិករណ៍យ៉ាងនោះ ; អធិករណ៍ ជាការរម្ងាប់ដោយយេភុយ្យសិកា ដោយប្រការដូច្នេះ នេះជាសេចក្ដីសង្ខេបក្នុងសមថក្ខន្ធកៈនេះ, ចំណែកសេចក្ដីពិស្ដារ នឹងមកខាងមុខខ្លះ[១] ។

## តស្សបាបិយសិកាកម្ម

[៣១] ពាក្យថា អសុចិ : មិនស្អាត នោះ គឺ អ្នកប្រកបដោយកាយកម្មនិងវចីកម្មដែលមិនស្អាត ។

ពាក្យថា អលជ្ជិ : មិនមានសេចក្ដីខ្មាស នោះ គឺ អ្នកប្រកបដោយលក្ខណៈនៃបុគ្គលអលជ្ជី មានចេតនាក្លែងធ្វើឱ្យត្រូវ(អាបត្តិ)ជាដើម ។

ពាក្យថា សានុវាទោ : ប្រកបដោយពាក្យតិះដៀល នោះ គឺ អ្នកប្រព្រឹត្តទៅព្រមដោយការចោទ ។

១. គឺ មាននៅក្នុងទំព័រ ១១១ ខាងមុខទៀត ។

ហេតុ ៣ យ៉ាងដោយអំណាចអង្គ ៣ ទាំងនេះ ការធ្វើ ២ យ៉ាងនេះ គឺ ការដែលសង្ឃធ្វើ ១ ការដែលសង្ឃព្រមព្រៀងធ្វើដោយធម៌ ១ រួមជាការធ្វើនៃតស្សបាបិយសិកាកម្ម ៥ ដោយប្រការដូច្នេះ ។ ពាក្យដ៏សេសក្នុងតស្សបាបិយសិកាកម្មនេះ មានន័យដូច ពោលហើយក្នុងតជ្ជនីយកម្មជាដើមនុ៎ះឯង ។

ចំណែកសេចក្តីនៃពាក្យក្នុងបទថា តស្ស ធាបិយសិកាកម្មំ នេះ គប្បីជ្រាបដូច្នេះ ។ ពិតមែន កម្មនេះ លោកហៅ តស្សបាបិយសិកាកម្ម ព្រោះភាពជាកម្ម ដែលសង្ឃគប្បីធ្វើដល់បុគ្គលអាក្រក់ដោយភាពជាអ្នកមានបាបច្រើន ។

## តិណវត្ថារកៈ

[៤១] ពីរបទថា កក្ខឡតាយ វាឡតាយ : ដើម្បីសេចក្តីរឹងរូស ដើម្បីកំណាច មានសេចក្តីថា អធិករណ៍នោះ គប្បីប្រព្រឹត្តទៅដើម្បីសេចក្តីអាក្រក់ និងដើម្បីសេចក្តីកាចសាហាវ ។

បទថា ភេទាយ : ដើម្បីទម្លាយ មានសេចក្តីថា ដើម្បីសេចក្តីបែកនៃសង្ឃ ។

[៤៣] ពាក្យថា សព្វេហេវ ឯកជ្ឈំ : ភិក្ខុទាំងអស់ ក្នុងទីជា

មួយគ្នា មានសេចក្តីថា មិនគប្បីនាំឆន្ទៈរបស់អ្នកណា ៗមក សូម្បីភិក្ខុដែលអាពាធក៏គប្បីនាំ មកប្រជុំដោយភាពជាពួកតែមួយជាមួយគ្នា ក្នុងទីប្រជុំនោះតែម្តង ។

ក្នុងពាក្យថា **តិណវត្ថារកេន វូបសមេយ្យ : រម្ងាប់ដោយតិណវត្ថារកសមថៈ** នេះ កម្មនេះ លោកហៅថា តិណវត្ថារកៈ ក៏ព្រោះជាកម្មគ្របទុកដោយស្មៅ ។

ដូចឧទាហរណ៍ថា គូថ ឬមូត្រដែលបុគ្គលកាលព្យាយាម រមែងបៀតបៀនដោយភាពជារបស់មានក្លិនស្អុយ, តែកាលគូថ ឬ មូត្រនោះដែលបុគ្គលគ្របហើយដោយស្មៅ បិទជិតជាប់ល្អហើយ ក្លិននោះ រមែងបៀតបៀនមិនបានយ៉ាងណា; អធិករណ៍ណា សូម្បីភាពជាមូលធំមូលតូច (នៃអធិករណ៍) ដែលសង្ឃរម្ងាប់ហើយ ប្រព្រឹត្តទៅដើម្បីសេចក្តីអាក្រក់ ដើម្បីសេចក្តីកាចសាហាវ ដើម្បីសេចក្តីបែកគ្នា, អធិករណ៍នោះ រម្ងាប់ដោយកម្មនេះហើយ រមែងជាការរម្ងាប់ដោយល្អ ដូចគូថដែលបិទបាំងទុកដោយគ្រឿងគ្រប គឺស្មៅ សេចក្តីនេះ ក៏ដូច្នោះឯង ព្រោះហេតុនោះ កម្មនេះលោកទើបហៅថា តិណវត្ថារកៈ ព្រោះជាកម្មគ្របទុកដោយស្មៅ ។

អាបត្តិដែលជាទោសធ្ងន់នោះ បានដល់ បារាជិក និង សង្ឃាទិសេស ។

បទថា **គិហិប្បដិសំយុត្តំ : អាបត្តិដែលជាគហិបដិសំយុត្ត** គឺវៀរអាបត្តិដែលត្រូវ ព្រោះជេរគ្រហស្ថដោយពាក្យអាក្រក់ និងទទួល

ហើយ មិនធ្វើតាមធម៌ ។

[៤៧] ពាក្យថា **ឯវញ្ច បន ភិក្ខវេ តេ ភិក្ខូ តាហិ អាបត្តីហិ វុដ្ឋិតា ហោន្តិ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថាបានចេញចាកអាបត្តិទាំងឡាយនោះ** មានសេចក្តីថា កាលតិណវត្ថារកកម្មវាចាដែលភិក្ខុ ទាំង ២ ផ្នែក ធ្វើហើយយ៉ាងនោះ ក្នុងខណៈចប់កម្មវាចា ភិក្ខុមានប្រមាណប៉ុនណា ដែលប្រជុំក្នុងទីនោះ ដោយហោចទៅភិក្ខុដេកលក់ក្តី ចូលសមាបត្តិក្តី អ្នកបញ្ជូនចិត្តទៅក្នុងទីដទៃក្តី ភិក្ខុទាំងអស់នោះត្រូវហើយនូវអាបត្តិទាំងឡាយ ដ៏សេសពួកណា ក្រៅអំពីអាបត្តិដែលជាទោសធ្ងន់ និងអាបត្តិដែលជាប់ដោយគ្រហស្ថ ចាប់តាំងពីមណ្ឌលនៃឧបសម្បទា រមែងជាអ្នកចេញហើយអំពីអាបត្តិទាំងនោះទាំងអស់ ។

បទថា **ឋបេត្វា ទិដ្ឋាវិកម្មំ : តែការធ្វើឱ្យច្បាស់នូវទិដ្ឋិ** មានសេចក្តីថា ចំណែកភិក្ខុពួកណា ធ្វើឱ្យជាក់ច្បាស់នូវទិដ្ឋិដល់គ្នានិងគ្នាថា សេចក្តីនោះមិនពេញចិត្តខ្ញុំព្រះករុណា ឬថា ភិក្ខុពួកណាសូម្បីត្រូវអាបត្តិជាមួយនឹងភិក្ខុទាំងនោះ តែមិនមកក្នុងទីប្រជុំនោះ ឬថា ភិក្ខុពួកណាមកហើយប្រគល់ឆន្ទៈហើយអង្គុយ ក្នុងទីទាំងឡាយមានបរិវេណជាដើម, ភិក្ខុពួកនោះ រមែងជាអ្នកមិនចេញចាកអាបត្តិទាំងនោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "វៀរលែងតែការធ្វើឱ្យជាក់ច្បាស់នូវទិដ្ឋិ វៀរលែងតែមិនបាននៅក្នុងទីនោះ" ។

# អធិករណ៍ ៤

[៤៨] ពីរបទថា ភិក្ខុនីនំ អនុបខ្ជ : ចូលជៀតជ្រែកទៅរកពួកភិក្ខុនី បានដល់ ការទៅហើយកន់ខាងក្នុងនៃពួកភិក្ខុនី ។ សេចក្ដីនៃពាក្យរបស់អធិករណ៍ទាំងឡាយ មានវិវាទាធិករណ៍ជាដើម បានពោលហើយក្នុងអដ្ឋកថានៃទុដ្ឋទោសសិក្ខាបទ[១] ។

[៤៩] ពីរបទថា វិបច្ចតាយ វោហារោ : ការពោលដើម្បីសេចក្ដីទុក្ខដល់ចិត្ត បានដល់ វោហារ ដើម្បីទុក្ខដល់ចិត្ត, សេចក្ដីថា ពាក្យគ្រោតគ្រាត ។

[៥០] ច្រើនបទថា យោ តត្ថ អនុវាទោ : បណ្ដាអធិករណ៍ទាំង៤នោះ ការចោទណា គឺការចោទណា ក្នុងកាលភិក្ខុទាំងនោះចោទ ។

បទថា អនុវទនា : ការតិះដៀល នេះ ជាពាក្យសម្ដែងអាការសេចក្ដីថា កិរិយាដែលចោទ ។

ពីរបទថា អនុល្លបនា អនុភណនា : ការពោលរឿយ ៗ ការនិយាយរឿយ ៗ ត្រឹមតែថា ជាវេវចនៈ របស់កិរិយាដែលចោទប៉ុណ្ណោះ ។

---

១. សមន្ត. សង្ឃា. ៣. ២៤៨/១៧៧ ។

បទថា អនុសម្បវង្កតា : ការបង្អោនចិត្តទៅ មានសេចក្តីថា ភាពជាអ្នកបណ្តោយតាម គឺភាពជាអ្នកស្រេបតាមរួមផ្សំ ក្នុងការចោទនោះឯង ដោយកាយចិត្ត និងវាចារឿយ ៗ ។

បទថា អព្ភុស្សហនតា : ការប្រឹងប្រែងឡើង បានដល់ កិរិយាចោទធ្វើ សេចក្តីឧស្សាហ៍ថា ហេតុអ្វី ទើបយើងមិនចោទយ៉ាងនោះហ្ន៎ ?

បទថា អនុពលប្បទានំ : ការបន្ថែមកម្លាំង គឺ សម្តែងហេតុនៃពាក្យខាង ដើម បន្ថែមកម្លាំងដោយពាក្យខាងក្រោយ ។

[៥២] ក្នុងពីរបទថា កិច្ចយតា ករណីយតា : កិច្ចរបស់សង្ឃ កម្មដែលសង្ឃត្រូវធ្វើបាន នេះ មានវិគ្រោះថា កម្មដែលគប្បីធ្វើនុ៎ះឯង ឈ្មោះថា កិច្ចយំ ភាពនៃកម្មដែលគប្បីធ្វើឈ្មោះថា កិច្ចយតា, ភាពនៃកិច្ចដែល គប្បីធ្វើឈ្មោះថា ករណីយតា ។

ពាក្យទាំង ២ នោះ ជាឈ្មោះនៃសង្ឃកម្មនុ៎ះឯង

ចំណែកពាក្យថា អបលោកនកម្មំ ជាដើម ព្រះមានព្រះភាគត្រាស់ដើម្បីសម្តែងប្រភេទនៃសង្ឃកម្មនោះឯង ។

បណ្តាសង្ឃកម្មទាំងនោះ កម្មដែលត្រូវញុំាងសង្ឃទាំងអស់ដែលឋិតនៅក្នុងសីមាឱ្យម៉ត់ចត់ នាំឆន្ទៈរបស់ភិក្ខុដែលគួរដល់ឆន្ទៈមក

សូធ្យប្រកាស ៣ ដង ធ្វើតាមអនុមតិរបស់សង្ឃដែលព្រមព្រៀងគ្នា ឈ្មោះថា អបលោកនកម្ម ។

កម្មដែលត្រូវធ្វើដោយញត្តិតែម្យ៉ាង តាមអនុមតិរបស់សង្ឃ ដែលព្រមព្រៀងគ្នា តាមន័យដែលពោលហើយនុ៎ះឯង ឈ្មោះថា ញត្តិកម្ម ។

កម្មដែលត្រូវធ្វើដោយអនុសាវនា មានញត្តិជាគម្រប់ ២ យ៉ាងនេះ គឺ ញត្តិ ១ អនុសាវនា ១ តាមអនុមតិរបស់សង្ឃដែលព្រមព្រៀងគ្នាតាមន័យដែលពោលហើយនោះឯង ឈ្មោះថា ញត្តិទុតិយកម្ម ។

កម្មដែលត្រូវធ្វើដោយអនុសាវនា ៣ មានញត្តិជាគម្រប់ ៤ យ៉ាងនេះ គឺ ញត្តិ ១ អនុសាវនា ៣ តាមអនុមតិរបស់សង្ឃដែលព្រមព្រៀងគ្នាតាមន័យដែលពោលហើយនោះឯង ឈ្មោះថា ញត្តិចតុត្ថកម្ម ។ បណ្តាកម្មទាំងនោះ អបលោកនកម្ម គប្បីធ្វើត្រឹមតែអបលោកន៍ ។ មិនត្រូវធ្វើដោយអំណាចញត្តិកម្មជាដើម ។ សូម្បីញត្តិកម្ម គប្បីធ្វើតាំងញត្តិតែម្យ៉ាង, មិនត្រូវធ្វើដោយអំណាចអបលោកនកម្មជាដើម ។ ចំណែកញត្តិទុតិយកម្ម ដែលត្រូវអបលោកនៈធ្វើក៏មាន មិនត្រូវអបលោកនៈក៏មាន ។ ក្នុង២ យ៉ាងនោះ កម្មធ្ងន់ ៦ យ៉ាងនេះ គឺ សន្មតសីមា ដកសីមា ឱ្យសំពត់កឋិន ដោះកឋិន សម្តែងទីដីសាងកុដិ

សម្តេងទីដីសាងវិហារ មិនគួរ ធ្វើអបលោកនៈ ; គប្បីសូធ្យញត្តិទុតិយកម្មវាចាធ្វើប៉ុណ្ណោះ ។ កម្មស្រាលបែបនេះ គឺ សន្ទុត ១៣ ដ៏សេសនិងសន្ទុតក្នុងការកាន់សេនាសនៈ និងឱ្យមត៌កចីវរជាដើម សូម្បីធ្វើអបលោកនៈ ក៏គួរ ។ តែមិនគប្បីធ្វើដោយអំណាចញត្តិកម្ម និងញត្តិចតុត្ថកម្មឡើយ ។ ញត្តិចតុត្ថកម្ម ត្រូវសូធ្យញត្តិនិងកម្មវាចា ៣ ធ្វើប៉ុណ្ណោះ មិនគប្បីធ្វើដោយអំណាចអបលោកនកម្មជាដើម ដូច្នេះឯង ។ សេចក្តីសង្ខេបក្នុងសមថក្ខន្ធកៈនេះប៉ុណ្ណោះ ។

ចំណែកវិនិច្ឆ័យនៃកម្មទាំងនោះ បានមកហើយដោយពិស្តារ ក្នុងកម្មវគ្គចុងគម្ពីរបរិវារ ដោយន័យមានពាក្យថា "ឥមានិ ចត្តារិ កម្មានិ កតីហាការេហិ វិបជ្ជន្តិ : កម្មទាំង ៤ នេះ តែងវិបត្តិព្រោះអាការប៉ុន្មាន"[១] ជាដើម ។ ក៏ក្នុងន័យនោះ បទណា មិនទាន់ច្បាស់លាស់ ខ្ញុំព្រះករុណានឹងពណ៌នាបទនោះ ក្នុងកម្មវគ្គនុ៎ះឯង ។

ពិតមែន កាលបើមានហេតុដូច្នេះ ការពណ៌នាក្នុងអដ្ឋានៈនឹងមិនមាន ។ មួយទៀត សេចក្តីវិនិច្ឆ័យនឹងជាការដឹងច្បាស់បានដោយងាយព្រោះភាវៃនៃកម្មនោះ ៗ គឺលោកបានជ្រាបមកហើយ តាំងពីដើម ។

---

១. វិន. បរិ. បញ្ចវគ្គ. ១៣. ៤២៣/៤២០ ។

# អធិករណវិភាគ

[៥៣] ពាក្យថា វិវាទាធិករណស្ស កឹ មូលំ : អ្វីជាមូលនៃវិវាទាធិករណ៍ ដូច្នេះជាដើម គប្បីជ្រាបដោយអំណាចនៃបាលីនុ៎ះឯង ។

[៦៦] ក្នុងពាក្យថា វិវាទាធិករណំ សិយា កុសលំ : វិវាទាធិករណ៍ ជាកុសល ជាដើម គប្បីជ្រាបសេចក្តីដោយន័យមានជាដើមយ៉ាងនេះថា ភិក្ខុទាំងឡាយ រមែងវិវាទគ្នាដោយចិត្តុប្បាទណា, ចិត្តុប្បាទនោះ ឈ្មោះថា វិវាទ និងឈ្មោះថា អធិករណ៍ ព្រោះភាពជាហេតុដែលនឹងត្រូវរម្ងាប់ដោយសមថៈទាំងឡាយ គប្បីជ្រាបសេចក្តីដោយអំណាចនៃពាក្យ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងបាលីនេះថា "អាបត្តាធិករណ៍ ជាអកុសលក៏មាន ជាអព្យាកតក៏មាន អាបត្តាធិករណ៍ ជាកុសលគ្មានទេ"[១] ។

ពិតមែន កុសលចិត្តជាអង្គក្នុងអាបត្តាធិករណ៍ មានជីកផែនដីជាដើមយ៉ាងណា កាលកុសលចិត្តនោះ ដែលជាអង្គនៃអាបត្តាធិករណ៍នោះ ដែលកាន់យកដោយភាពជាអាបត្តិមានមែន អ្នកណា ៗមិនអាចពោលបានថា "អាបត្តាធិករណ៍ ដែលជាកុសល មិនមាន" ។

---

១. វិន. ចុល្ល. សមថក្ខន្ធកៈ. ១០. ៧៤/៧៤ ។

ព្រោះហេតុនោះ ពាក្យថា អាបត្តធិករណ៍ដែលជាកុសលមិនមាននេះឈ្មោះថា ដែលព្រះមានព្រះភាគត្រាស់សំដៅយកចិត្តដែលល្មមជាអង្គមិនបាន ។ ប៉ុន្តែថា ព្រះអង្គត្រាស់សំដៅយកសេចក្តីនៃវិកប្ប ដូច្នេះ ៖

អាបត្តធិករណ៍ណា ជាលោកវជ្ជៈ អាបត្តធិករណ៍នោះ ជាអកុសលដោយចំណែកតែមួយប៉ុណ្ណោះ, សេចក្តីកំណត់ថា កុសលគប្បីមាន ដូច្នេះ រមែងមិនមានក្នុងលោកវជ្ជៈនោះ ។

ចំណែកអាបត្តធិករណ៍ណា ជាបណ្ណត្តិវជ្ជៈ, អាបត្តធិករណ៍នោះ រមែងជាអកុសលចំពោះភិក្ខុដែលក្លែងប្រព្រឹត្តកន្លងថា "យើងនឹងប្រព្រឹត្តកន្លងអាបត្តិនេះ", តែអាបត្តធិករណ៍នោះ រមែងជាអព្យាកត ព្រោះការត្រូវដោយអំណាចនៃសហសេយ្យជាដើម របស់ភិក្ខុដែលមិនក្លែង មិនដឹងអ្វីឡើយ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់សំដៅយកសេចក្តីនៃវិកប្បនេះ ដោយអំណាចនៃការក្លែង និងមិនក្លែង ក្នុងបណ្ណត្តិវជ្ជៈនោះ ទើបត្រាស់ពាក្យថា អាបត្តធិករណ៍ដែលជាអកុសលក៏មាន, ដែលជាអព្យាកតក៏មាន, អាបត្តធិករណ៍ជាកុសលមិនមាន ។

ក៏បើថា អ្នកណា ៗ គប្បីពោលថា "ភិក្ខុមានចិត្តជាកុសល រមែងត្រូវអាបត្តធិករណ៍ណា, អាបត្តធិករណ៍នេះ លោកពោលថា អាបត្តធិករណ៍ជាកុសល" ។ កុសលចិត្តគប្បីចូលគ្នាបាន សូម្បីដល់

ឯឡូកលោមសមុដ្ឋាន និងបទសោធម្មទេសនាសមុដ្ឋានជាដើម ដែលជាអចិត្តកៈ ។ តែកុសលចិត្តសូម្បីមានទៅក្នុងកិរិយា ដែលត្រូវនោះក៏មិនចាត់ជាអង្គនៃអាបត្តិ ។

ចំណែកកាយវាចា ដែលកម្រើកញ័រ ប្រព្រឹត្តទៅដោយអំណាចកាយវិញ្ញត្តិ និងវចីវិញ្ញត្តិ យ៉ាងណាមួយនុ៎ះឯង រមែងជាអង្គនៃអាបត្តិ ។ ក៏ប៉ុន្តែថា អង្គនោះចាត់ជាអព្យាកត ព្រោះអង្គនោះ ជាចំណែកដែលរាប់បញ្ចូលក្នុងរូបខន្ធ ។

[៧៥] ក៏ក្នុងពាក្យថា យំ ជាឧទ្ទេ : ភិក្ខុកាលបើដឹងហើយណា ជាដើម មានសេចក្ដីដូច្នេះ ៖

ចិត្តណា រមែងជាអង្គនៃអាបត្តិ ។ ដឹងនូវវត្ថុដោយចិត្តនោះ និងដឹងដឹងព្រមដោយអាការ គឺ ប្រព្រឹត្តកន្លងថា "យើងកំពុងប្រព្រឹត្តកន្លងនូវវត្ថុនេះ" និងក្លែង គឺ តាំងចិត្ត ដោយអំណាចវិតិក្កមចេតនាញាំញីដោយអំណាចនៃសេចក្ដីព្យាយាមល្មើសបំពាន គឺ បញ្ជូនចិត្តដែលប្រាសចាកសេចក្ដីរង្កៀសទៅ រមែងប្រព្រឹត្តកន្លងទៅ គឺ រមែងត្រូវអាបត្តាធិករណ៍ណា ។ វិតិក្កមៈណារបស់ភិក្ខុនោះ អ្នកប្រព្រឹត្តកន្លងដោយប្រការយ៉ាងនោះ, វិតិក្កមៈនេះ លោកពោលថា "អាបត្តាធិករណ៍ជាអកុសល" ។

សេចក្តីសូម្បីក្នុងអព្យាកតវារៈ គប្បីជ្រាបដូច្នេះ ៖

ចិត្តណា រមែងជាអង្គនៃអាបត្តិ, កាលមិនដឹង គឺថា មិនដឹងព្រម មួយអន្លើដោយការប្រព្រឹត្តកន្លង មិនតាំងចិត្ត ដោយការមិនមានវីតិក្កមចេតនា ដែលជាអង្គ នៃអាបត្តិ មិនល្មើសបំពាន គឺ មិនបានបញ្ជូនចិត្តដែលប្រាសចាក សេចក្តីវង្វេងស ដោយការក្លែង ញាំញី ប្រព្រឹត្តកន្លង គឺ រមែងត្រូវអាបត្តាធិករណ៍ណា វីតិក្កមៈណារបស់ភិក្ខុនោះ អ្នកប្រព្រឹត្តកន្លងដោយប្រការយ៉ាងនោះ វីតិក្កមៈនេះ លោកពោលថា "អាបត្តាធិករណ៍ជាអព្យាកត" ។

[៨១] ក្នុងពាក្យថា អយំ វិវាទោ នោ អធិករណំ : ការប្រកួតប្រកាន់ណា ក្នុងអធិករណ៍ ជាដើម គប្បីជ្រាបសេចក្តីយ៉ាងនេះថា វិវាទនេះ មិនចាត់ជាអធិករណ៍ ព្រោះមិនមែនភាវជាកិច្ចដែលនឹងត្រូវរម្ងាប់ដោយសមថៈទាំងឡាយ ។

[៨៩] ក្នុងពាក្យថា យាវតិកា ភិក្ខូ កម្មប្បត្តា : ភិក្ខុមានចំនួនប៉ុន្មានរូប ដែលគួរដល់កម្ម នេះ គប្បីជ្រាបថា ក្នុងកម្មដែលធ្វើដោយសង្ឃចតុវគ្គ ភិក្ខុ ៤ រូប ជាអ្នកល្មមធ្វើកម្មឱ្យសម្រេច, ក្នុងកម្មដែលគប្បីធ្វើដោយសង្ឃបញ្ចវគ្គ ភិក្ខុ ៥ រូបជាអ្នកល្មមធ្វើកម្មឱ្យសម្រេច, ក្នុងកម្មដែលគប្បីធ្វើដោយសង្ឃទសវគ្គ ភិក្ខុ ១០រូប ជាអ្នកល្មមធ្វើកម្មឱ្យសម្រេច, ក្នុងកម្មដែលគប្បីធ្វើដោយសង្ឃវីសតិវគ្គ ភិក្ខុ

២០ រូប ជាអ្នកល្មមធ្វើកម្មឱ្យសម្រេច ។

[៩០] បទថា **សុបរិគ្គហិតំ :** សេចក្តីកំណត់ឱ្យស្រួលបួល មានសេចក្តីថា អធិករណ៍នោះ ដែលភិក្ខុទាំងឡាយ ជាម្ចាស់អាវាស គប្បីធ្វើឱ្យជាការដែលខ្ពនការពារយ៉ាងល្អិតល្អន់ហើយ ទើបទទួល ។

ក៏ឯគ្រាទទួលហើយ គប្បីពោលថា "ថ្ងៃនេះ ពួកយើងនឹងបោកចីវរ, ថ្ងៃនេះ ពួកយើងនឹងដុតបាត្រ, ថ្ងៃនេះ មានកង្វល់យ៉ាងណាមួយ" ដូច្នេះហើយបណ្តោយឱ្យកន្លងទៅ ២-៣ ថ្ងៃ ដើម្បីប្រយោជន៍ដល់ការគ្របសង្កត់មានះ ។

## ឧព្វាហិកា

[៩១] ពាក្យថា **អនន្តានិ ចេវ ភស្សានិ ជាយន្តិ : ក៏មានពាក្យទ្រហឹងអឺងកងមិនមានទីបំផុត** សេចក្តីថា ពាក្យទាំងឡាយ មិនមានបរិមាណកើតឡើងខាងនេះ និងខាងនេះ ។

បាឋៈថា **ភាសានិ** ក៏មានសេចក្តីដូចគ្នានេះ ។

ពីរបទថា **ឧព្វាហិកាយ សម្មន្និតព្វោ : សង្ឃគប្បីសន្មតដោយឧព្វាហិកាកម្មវាចា** មានសេចក្តីថា ភិក្ខុដែលប្រកបដោយអង្គ ១០ រូប ដែលសង្ឃគប្បីអបលោកន៍ ឬសន្មតដោយញត្តិទុតិយកម្មវាចា ដែល

ពោលហើយខាងមុខ ។ ក៏ដែលភិក្ខុទាំងឡាយ បានទទួលសន្មតហើយ យ៉ាងនោះ គប្បីអង្គុយផ្សេងដទៃហើយវិនិច្ឆ័យអធិករណ៍នោះ ឬគប្បី ប្រកាសដល់បរិស័ទនោះឯងថា "ភិក្ខុពួកដទៃកុំគប្បីពោលពាក្យណា ៗ" ហើយវិនិច្ឆ័យអធិករណ៍នោះ ក៏បាន ។

[៩៤] បទថា តត្រស្ស : មាន ... នោះ មានសេចក្តីថា ភិក្ខុ ជាធម្មកថិក គប្បីមានក្នុងបរិស័ទនោះ ។

ពីរបទថា នេវ សុត្តំ អាគតំ : មិនចាំសូត្រ គឺ ចាំមាតិកាមិន បាន ។

ពីរបទថា នោ សុត្តវិភង្គោ : មិនចាំសុត្តវិភង្គ គឺ មិនជំនាញ ក្នុងវិន័យ ។

ពាក្យថា ព្យញ្ជនឆាយាយ អត្ថំ បដិពាហតិ : ប្រកាន់យកតែ ព្យញ្ជនៈជាប្រមាណ មានសេចក្តីថា ព្រះធម្មកថិកនោះ កាន់យកត្រឹមតែ ព្យញ្ជនៈប៉ុណ្ណោះ ជំទាស់នឹងសេចក្តី គឺ ឃើញពួកភិក្ខុ ដែលជាវិន័យ ធរទាំងឡាយ ពិន័យដោយអាបត្តិ ព្រោះទទួលមាសប្រាក់ និងស្រែសួន ជាដើម ទើបពោលថា "ហេតុដូចម្តេចលោកទាំងឡាយ ទើបពិន័យភិក្ខុ ទាំងនេះ ដោយអាបត្តិ ?" កិរិយាត្រឹមតែរៀរប៉ុណ្ណោះ ដែលព្រះមានព្រះ ភាគត្រាស់ ហើយក្នុងសូត្រយ៉ាងនេះថា "ភិក្ខុទាំងឡាយ ជាអ្នករៀរ

ស្រឡះបាកកិរិយាទទួលកាន់យកនូវមាស និងប្រាក់” ដូច្នេះ មិនមែនឬ ? អាបត្តិក្នុងសូត្រនេះ មិនមាន ។ ព្រះធម្មកថិកមួយរូប កាលព្រះវិន័យធរប្រាប់ដល់ភិក្ខុទាំងឡាយ អ្នកស្លៀកសំពត់រយីករយាក ព្រោះព្រះសូត្រដែលមកហើយ ទើបពោលថា “ហេតុដូចម្ដេច ទើបលោកទាំងឡាយលើកអាបត្តិដល់ភិក្ខុទាំងនេះ ? ក្នុងសូត្រនេះ ព្រះមានព្រះភាគ ត្រាស់ត្រឹមតែការធ្វើសេចក្ដីសិក្សាយ៉ាងនេះថា គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងស្លៀកឱ្យជាបរិមណ្ឌល” ដូច្នេះប៉ុណ្ណោះ មិនមែនឬ ? អាបត្តិក្នុងសូត្រនេះ មិនមាន ។

## យេភុយ្យសិកា

[៩៦] វិនិច្ឆ័យក្នុងពាក្យថា **យថា ពហុតរា ភិក្ខូ : បើភិក្ខុទាំងឡាយ មានចំនួនច្រើនជាង ពោលយ៉ាងណា នេះ គប្បីជ្រាប** ដូច្នេះ ៖

ភិក្ខុដែលជាធម្មវាទីលើស សូម្បីត្រឹមតែមួយរូប ក៏ចាត់ជាចំណែកច្រើនជាងបាន ។

ក៏នឹងត្រូវពោលថ្វីដល់ទៅ ២-៣ រូប ។

[៩៧] បទថា **សញ្ញត្តិយា : បញ្ញាក់** មានសេចក្ដីថា តថាគតអនុញ្ញាតការចាប់ស្លាក ៣ វិធីដើម្បីត្រូវការឱ្យភិក្ខុទាំងនោះយល់ព្រម ។

វិនិច្ឆ័យក្នុងពាក្យថា **គូឡ្ហកំ : បិទមុខ** ជាដើម គប្បីជ្រាប ដូច្នេះ ៖

ក្នុងបរិស័ទដែលច្រើន សូម្បីដោយពួកអលជ្ជី គប្បីធ្វើការចាប់ស្លាកដែលជា **គូឡ្ហក : បិទបាំង** ។ ក្នុងបរិស័ទដែលច្រើនសូម្បីដោយពួកលជ្ជី គប្បីធ្វើការចាប់ស្លាកដែលជា **វិវដក : បើកចំហ** ។ ក្នុងបរិស័ទដែលច្រើន សូម្បីដោយភិក្ខុពាល គប្បីធ្វើការចាប់ស្លាកដែលជា **សកណ្ណជប្បក : ខ្សឹបប្រាប់ត្រង់ត្រចៀក** ។

ពីរបទថា **វណ្ណាវណ្ណាយោ កត្វា : ធ្វើឱ្យមានពណ៌ផ្សេងគ្នា** មានសេចក្ដីថា ស្លាករបស់ខាងធម្មវាទី និងខាងអធម្មវាទី ត្រូវប្រាប់សម្គាល់គឺ គ្រឿងសម្គាល់ ហើយធ្វើឱ្យមានចំណែកផ្សេងពីគ្នា ។ ខាងក្រោយគប្បីយកស្លាកទាំងអស់នោះ ដាក់ក្នុងផ្នត់ចីវរហើយ ឱ្យចាប់តាមន័យដែលពោលហើយនុ៎ះឯង ។

ពាក្យថា **ទុគ្គហោតិ បច្ចុក្កឌ្ឍិតព្វំ : ការចាប់នេះមិនល្អទេ ហើយសើរើជាថ្មីទៀត** មានសេចក្ដីថា គប្បីប្រាប់ថា “ស្លាកចាប់មិនល្អ” ហើយឱ្យចាប់ថ្មី ត្រឹមតែលើកទី ៣ ។

ពាក្យថា **សុគហោតិ សាវេតព្វំ : ត្រូវប្រកាសថា ការចាប់នេះល្អហើយ** មានសេចក្ដីថា កាលភិក្ខុដែលជាធម្មវាទីច្រើនជាង សូម្បីតែ

មួយរូប គប្បីប្រកាសថា "ស្លាកចាប់ល្អហើយ" ក៏ភិក្ខុពួកធម្មវាទីទាំងនោះ រមែងពោលយ៉ាងណា, អធិករណ៍នោះ គប្បីឱ្យរម្ងាប់យ៉ាងនោះដូច្នេះឯង ។

បើថា ភិក្ខុពួកអធម្មវាទីនៅតែច្រើនជាង សូម្បីដល់ ៣ ដង គប្បីពោលថា "ថ្ងៃនេះវេលាមិនសមគួរ ស្អែកនេះយើងទាំងឡាយនឹងដឹងគ្នា" ហើយចេញស្វែងរកពួកធម្មវាទី ដើម្បីប្រយោជន៍ដល់ការទម្លាយពួកអលជ្ជីចេញ គប្បីធ្វើការចាប់ស្លាក ក្នុងថ្ងៃស្អែកនេះជាការចាប់ស្លាកបែបបិទបាំង ។

ក៏គប្បីជ្រាបវិន័យ ក្នុងការចាប់ស្លាកបែបខ្សឹបប្រាប់ត្រង់ត្រចៀក ។

ក្នុងពាក្យថា **គហិតេ វត្តព្វោ : លុះចាប់ស្លាកទៅហើយ សលាកគ្គាហាបកភិក្ខុ ត្រូវប្រាប់** មានសេចក្ដីថា បើព្រះសង្ឃថេរៈ នឹងចាប់ស្លាកអធម្មវាទីសោត, គប្បីប្រាប់ឱ្យលោកជ្រាបយ៉ាងនេះថា "លោកម្ចាស់ដ៏ចម្រើន លោកជាភិក្ខុចាស់ ចម្រើនវ័យហើយ ការចាប់ស្លាកនោះមិនគួរដល់លោកម្ចាស់, នេះជាស្លាកអធម្មវាទី" គប្បីសម្ដែងស្លាកក្រៅនេះដល់លោក, បើលោកចាប់ធម្មវាទីស្លាកនោះ, គប្បីឱ្យ ។ បើថាលោកនៅមិនទាន់ជ្រាប, លំដាប់នោះ គប្បីប្រាប់លោកថា "កុំប្រាប់ដល់អ្នកណា ៗ" ពាក្យដ៏សេស មានន័យដូចពោលហើយនុ៎ះឯង ។

បទថា **វិវដកំ : បើកចំហ** នោះ គឺ បើកបង្ហាញសេចក្ដីនុ៎ះឯង ។

# តស្សបាបិយសិកា

[១០៣] វិនិច្ឆ័យក្នុងពាក្យថា ធារាជិកាសាមន្តំ វា : ឬអាបត្តិជើបារាជិក នេះ គប្បីជ្រាបដូច្នេះ ៖

ក្នុងមេថុនធម្ម អាបត្តិទុក្កដ ឈ្មោះថា អាបត្តិជើបារាជិក ។ ក្នុងអទិន្នាទានជាដើមដ៏សេស អាបត្តិថុល្លច្ច័យ ឈ្មោះថា អាបត្តិជើបារាជិក ។

បទថា និវេឋេន្តំ : ដែលប្រកែក មានសេចក្តីថា អ្នកបំបិតដោយពាក្យថា ខ្ញុំព្រះករុណារលឹកមិនបាន ដូច្នេះ ។

បទថា អតិវេឋេតិ : ចោទប្រកាន់ មានសេចក្តីថា លោកគាបសង្កត់ ដោយពាក្យថា ឥង្ឃាយស្មា : នឹករកឃើញ ជាដើម ។

ពាក្យថា សរាមិ ខោ អហំ អាវុសោ : លោកមានអាយុ ខ្ញុំនឹកឃើញត្រឹមតែ មានសេចក្តីថា ភិក្ខុនោះ ប្តេជ្ញាយ៉ាងនោះ ដើម្បីត្រូវការបិទបាំងអាបត្តិបារាជិក ។ កាលត្រូវលោកគាបសង្កត់ខ្លាំងឡើងទៀតទើបឱ្យប្តេជ្ញាថា "ខ្ញុំព្រះករុណារលឹកបាន" ហើយពោលពាក្យថា "ពាក្យនោះ ខ្ញុំព្រះករុណានិយាយលេងទេ" ដូច្នេះ ជាដើម ព្រោះខ្លាចថា "ភិក្ខុទាំងនេះនឹងញាំងយើងឱ្យវិនាសក្នុងកាល ឥឡូវនេះ សង្ឃគប្បីធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុនោះ" ។

បើថា លោកជាអ្នកមានសីល, លោកញ៉ាំងវត្តឱ្យពេញហើយ នឹងបានសេចក្ដីរម្ងាប់ ។

បើថា លោកជាអ្នកមិនមានសីល, លោកជាអ្នកដែលសង្ឃឱ្យវិនាសយ៉ាងនោះតែម្ដង ។

ពាក្យដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ ដូច្នេះឯង ។

**សមថក្ខន្ធកវណ្ណនា ចប់ ៕**

# ១៥. ខុទ្ទកវត្ថុខន្ធកវណ្ណនា

## ការងូតទឹក

វិនិច្ឆ័យក្នុងខុទ្ទកវត្ថុខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

[១១១] បទថា មល្លមុដ្ឋិកា : អ្នកប្រដាល់ បានដល់ អ្នកដាល់គ្នា ដោយកណ្ដាប់ដៃ ។

បទថា គាមបូដ វា : ឬពួកមនុស្សអ្នកនៅក្នុងក្រុង បានដល់ អ្នកក្រុងដែលប្រកបរឿយ ៗ នូវការប្រដាប់សម្បុរកាយ, បាឋៈថា គាមបោតកា ក៏មានសេចក្ដីដូចគ្នា ។

[១១២] បទថា ថម្ភេ : ទឹងសសរ បានដល់ សសរដែលគេបោះទុកត្រង់កំពង់ជាទីងូតទឹក ។

[១១៣] បទថា កុឌ្ឌេ : ជញ្ជាំង បានដល់ បណ្ដាជញ្ជាំងឥដ្ឋ ជញ្ជាំងថ្ម និងជញ្ជាំងឈើ ជញ្ជាំងប្រភេទណាមួយ ។

[១១៤] ឈើដែលគេចាំងធ្វើជាផែនក្ដារ ហើយឆូតឱ្យស្នាមគំនូសដូចជាក្រឡាចត្រង្គ ហើយបោះទុកត្រង់កំពង់ជាទីងូតទឹក ហៅថា ទីមិនគួរ, មនុស្សទាំងឡាយយកដៃឈើនោះដាក់គ្រឿងលំអិតដុសខ្លួន ។

[១១៥] បទថា គន្ធព្វហត្ថកេន : ដោយឈើដែលធ្វើជាដៃគន្ធព្វ មានសេចក្ដីថា ភិក្ខុឆព្វគ្គិយ រមែងងូតដោយដៃដែលធ្វើដោយឈើ ដែលគេតម្កល់ទុកក្បែរកំពង់សម្រាប់ងូតទឹក, បានឮថា មនុស្ស

ទាំងឡាយយកគ្រឿង លំអិតទៅដាក់គរទឹងដៃឈើនោះ ហើយត្រដុស កាយដោយឈើនោះ ។

[១១៦] បទថា **កុរុវិន្ទកសុត្តិយា : លំអិតថ្មឈ្មោះកុរុវិន្ទកៈ** លោកហៅដុំមូល ៗ គេយកលំអិតថ្ម ឈ្មោះកុរុវិន្ទកៈ (សិលាមានពណ៌ដូចដំឡូងក្រហម) មកលាយប្រឡាក់ទឹងល័ក្ខ ហើយសូនឲ្យធ្វើជាដុំ ហើយស្រែះដោយអំបោះ ហើយកន់របស់នោះខាងចុងខាងដើម ហើយ ត្រដុសកាយ ក្នុងវេលាងូតទឹក ។

[១១៧] ពាក្យថា **វិគ្គយ្ហ បរិកម្មំ ការាបេន្តិ : ញាំងគ្នានឹងគ្នាឱ្យធ្វើបរិកម្មទៅវិញទៅមក** មានសេចក្តីថា ឆព្វគ្គិយភិក្ខុ យកខ្នងនឹងខ្នងត្រដុសគ្នានិងគ្នាទៅវិញទៅមក ។

[១១៨] ឈើដែលគេឆ្លាក់ជាក្បាច់ធ្មេញមង្ករ ហើយធ្វើឱ្យមានទ្រង់ទ្រាយដូចជើងកន្ទោរ ឈ្មោះថា មល្លកៈ, ឈើដូចជើង កន្ទោរដែលឆ្លាក់ជាក្បាច់ធ្មេញនេះ សូម្បីភិក្ខុអាពាធ ក៏មិនគួរ ។

[១១៩] ឈើដូចជើងកន្ទោរដែលមិនបានឆ្លាក់ជាក្បាច់ធ្មេញមង្ករ ឈ្មោះថា អកតមល្លកៈ, ឈើដូចជើងកន្ទោរដែលមិនបានឆ្លាក់ជាក្បាច់ធ្មេញមង្ករនេះ មិនគួរដល់ភិក្ខុដែលមិនអាពាធ ។ ចំណែកផែនឥដ្ឋ ឬ ផែនក្បឿងគួរ ។

[១២០] បទថា ឧក្កាសិកំ : ខ្នាញ់សំពត់ បានដល់

ជួនសំពត់ ។ ព្រោះហេតុនោះ ភិក្ខុកាលងូតទឹកនឹងដុសខ្លួនដោយជួនសំពត់សម្រាប់ងូត ក៏គួរ ។

[១២១] ការបរិកម្មដោយដៃ ហៅថា **បុថុបាណិកំ : ការដុសខ្លួនដោយដៃ** ។ ព្រោះហេតុនោះ ភិក្ខុទាំងពួងនឹងធ្វើបរិកម្មខ្លួនដោយដៃ គួរ ។

## ការតែងខ្លួនជាដើម

[១២២] ពាក្យថា **វល្លិកា** នេះ ជាឈ្មោះនៃគ្រឿងប្រដាប់ត្រចៀកជាដើមថា កែវមុក្តារ និងក្រវិលដែលពាក់នៅនឹងត្រចៀក ។ មិនមែនក្រវិលតែម៉្យាងប៉ុណ្ណោះទេ ដែលមិនគួរ, សូម្បីគ្រឿងប្រដាប់ត្រចៀកយ៉ាងណាមួយ ដោយហោចទៅ សូម្បីស្លឹកត្នោត ក៏មិនគួរដែរ ។ ខ្សែពាក់លម្អប្រភេទណាមួយ ឈ្មោះថា **សង្វារ** ។ គ្រឿងប្រដាប់សម្រាប់តែងត្រង់ក ប្រភេទណាមួយ ឈ្មោះថា **ខ្សែក** ។ គ្រឿងប្រដាប់ចង្កេះប្រភេទណាមួយ ដោយហោចទៅសូម្បីត្រឹមតែជាខ្សែអំបោះ ឈ្មោះថា **ខ្សែចង្កេះ** ។ **វល័យ** ឈ្មោះថា **កង** ។ **សុវណ្ណពាហុ** (គ្រឿងប្រដាប់ដើមដៃ) ជាដើម ប្រាកដច្បាស់ហើយ, គ្រឿងប្រដាប់មិនថាប្រភេទណាមួយទេ មិនគួរ (ទាំងអស់) ។

[១២៣] វិនិច្ឆ័យក្នុងពាក្យថា **ឱមាសិកំ វា ឱវត្តុលំ វា :**

កំណត់ត្រឹមពីរខែ ឬកំណត់ត្រឹមពីរធ្នាប់ នេះ គប្បីជ្រាបដូច្នេះ ៖

បើថា ខាងក្នុង២ ខែ សក់វែងដល់ ២ ធ្នាប់ ត្រូវកោរចេញខាងក្នុង២ ខែប៉ុណ្ណោះ, នឹងទុកឱ្យវែងលើស ២ ធ្នាប់ ទៅ មិនគួរ ។

សូម្បីថា មិនវែង, នឹងទុកឱ្យលើសពី ២ ខែទៅសូម្បីមួយថ្ងៃ ក៏មិនបានដូចគ្នា នេះជាកំណត់យ៉ាងខ្ពស់ ដែលព្រះមានព្រះភាគត្រាស់ដោយបទទាំង ២ ដោយប្រការដូច្នេះ ។ តែតិចជាងកំណត់នោះ ដែលឈ្មោះថា សេចក្តីមិនសមគួរ មិនមាន ។

[១២៤] ពីរបទថា កោច្ឆេន ឱសណ្ឋេន្តិ : សិតដោយស្និតមានសេចក្តីថា ភិក្ខុឆព្វគ្គិយប្រើប្រាស់ស្និតសិតសក់ធ្វើឱ្យរៀបរយ ។

បទថា ផណកេន : ដោយក្រាស មានសេចក្តីថា ភិក្ខុឆព្វគ្គិយប្រើប្រាស់ក្រាសយ៉ាងណាមួយមានក្រាសភ្លុកជាដើម សិតសក់ឱ្យរៀបរយ ។

បទថា ហត្ថផណកេន : ដោយក្រាសគឺដៃ មានសេចក្តីថា ភិក្ខុឆព្វគ្គិយ កាលនឹងប្រើដៃទុំះឯង ជំនួសក្រាស ទើបសិតសក់ដោយម្រាមដៃទាំងឡាយ ។

បទថា សិត្ថតេលកេន : ដោយក្រមួន និងប្រេង មានសេចក្តីថា ភិក្ខុឆព្វគ្គិយ សិតសក់ដោយរបស់ស្អិតយ៉ាងណាមួយ មានក្រមួន

ឃ្មុំនិងជ័រជាដើម ។

បទថា ឧទកតេលកេន : **ដោយប្រេងដែលលាយដោយទឹក** មានសេចក្តីថា ភិក្ខុឆព្វគ្គិយ សិតសក់ដោយប្រេងលាយទឹក, ដើម្បីប្រយោជន៍ដល់ការប្រដាប់ ពិន័យទុក្កដគ្រប់កន្លែង, តែគប្បីជ្រលក់ដៃឱ្យសើមហើយជូតសីសៈ ដើម្បីញុំាំងសក់ដែលមានចុងង ឱ្យរាបទៅតាមលំដាប់, នឹងយកដៃដែលសើមជូត សូម្បីនូវសីសៈដែលក្តៅខ្លាំងដោយកំដៅ និងប្រឡាក់ធូលី ក៏គួរ ។

[១២៥] វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ អាទាសេ វា ឧទកបត្តេ វា : **ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវមើលមុខនិមិត្តក្នុងកញ្ចក់ ឬក្នុងភាជន៍ទឹកទេ** គប្បីជ្រាបដូច្នេះ ៖

ស្រមោលមុខ រមែងប្រាកដក្នុងវត្ថុពួកណា វត្ថុពួកនោះទាំងអស់ សូម្បីមានបន្ទះសំរិទ្ធិជាដើម រមែងដល់ការរាប់ថា កញ្ចក់ដូចគ្នា, សូម្បីវត្ថុទាំងឡាយមានទឹកបាយជាដើម រមែងដល់ការរាប់ថា ភាជនៈទឹកដូចគ្នា ព្រោះដូច្នោះ ភិក្ខុដែលឆ្លុះមើល (ស្រមោលមុខ) ក្នុងទីណាមួយ ត្រូវអាបត្តិទុក្កដ ។

[១២៦] បទថា អាពាធបច្ចយា : **បើមានអាពាធជាហេតុ** មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុមើលស្រមោលមុខដើម្បីដឹងថា "ដំបៅ

លើផ្ទៃមុខរបស់អាត្មាអញមានស្បែកពេញឬនៅ"ប៉ុណ្ណោះ ។

(ក្នុងបុរាណអដ្ឋកថា)ពោលថា សមគួរមើលស្រមោលមុខដើម្បីពិចារណាអាយុសង្ខារយ៉ាងនេះថា "អាត្មាអញចាស់ឬនៅមិនទាន់ចាស់ហ្ន៎ ?" ដូច្នេះក៏បាន ។

[១២៧] ពីរបទថា **មុខំ អាលិម្បេន្តិ : ផាត់មុខ** មានសេចក្ដីថា ភិក្ខុឆព្វគ្គិយ រមែងផាត់ដោយគ្រឿងផាត់មុខ សម្រាប់ធ្វើឱ្យមុខមានសម្បុរផូរផង់ ។

បទថា **ឧម្មទ្ទេន្តិ : ជុស** មានសេចក្ដីថា ជុសខាត់មុខ ដោយគ្រឿងជុសខាត់ផ្សេង ៗ ។

បទថា **ចុណ្ណេន្តិ : ប្រស់** មានសេចក្ដីថា រមែងប្រស់ ដោយលំអិតសម្រាប់ប្រស់មុខ ។

ច្រើនបទថា **មនោសិលកាយ មុខំ លញ្ឆេន្តិ : ចុចមុខដោយមនោសិលា** មានសេចក្ដីថា រមែងធ្វើនូវស្នាមអុជ ៗ មានចុចជាប្រជ្រុយជាដើម ដោយថ្មមនោសិលា ។ ការចុចទាំងនោះ រមែងមិនគួរសូម្បីដោយវត្ថុមានហរតាល(វត្ថុមានពណ៌លឿង)ជាដើមពិត ។ ការលាបខ្លួនជាដើម ជាក់ច្បាស់ហើយ ។ ជាអាបត្តិទុក្កដក្នុងទីទាំងពួង ។

# ការរាំនិងច្រៀងជាដើម

[១២៩] វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ នច្ចំ វា គីតំ វា វាទិតំ វា ទស្សនាយ គន្តព្វំ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទៅមើលរាំ ស្តាប់ច្រៀង ឬភ្លេងប្រគំទេ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុដែលទៅ ដើម្បីមើលការរាំយ៉ាងណាមួយ ដោយហោចទៅសូម្បីការរាំនៃសត្វក្ងោក ក៏ត្រូវអាបត្តិទុក្កដ ។ ភិក្ខុរាំសូម្បីដោយខ្លួនឯងក្តី ប្រើឱ្យអ្នកដទៃរាំក្តី ក៏ត្រូវអាបត្តិទុក្កដដូចគ្នា ។

[១៣០] សូម្បីចម្រៀងយ៉ាងណាមួយ ជាចម្រៀងរបស់អ្នករបាំក៏ដោយ ជាចម្រៀងដែលល្អ (គឺ ជាប់ដោយអនិច្ចធម៌ជាដើម )ក៏ដោយ ដោយហោចទៅសូម្បីច្រៀងដោយធ្មេញ ក៏មិនគួរ ។

ភិក្ខុគិតថា "យើងនឹងច្រៀង" ហើយស្រែកសំឡេងទទេ ក្នុងចំណែកខាងដើមភ្លេងច្រៀង សូម្បីការស្រែកសំឡេងទទេនោះ ក៏មិនគួរ ។ ភិក្ខុច្រៀងខ្លួនឯងក្តី ប្រើឱ្យអ្នកដទៃច្រៀងក្តី ក៏ត្រូវអាបត្តិទុក្កដដូចគ្នា ។ សូម្បីការប្រគំ យ៉ាងណាមួយ ក៏មិនគួរ ។ តែកាលធុញទ្រាន់ ឬបិតនៅក្នុងទីគួររង្កៀស ទើបផ្ទាត់ម្រាមដៃ ឬទះដៃ ក្នុងហេតុទាំងនោះ មិនជាអាបត្តិ, មិនជាអាបត្តិដល់ភិក្ខុដែលនៅខាងក្នុងវត្ត ឃើញការលេងគ្រប់យ៉ាងមានការរាំជាដើម ។

កាលភិក្ខុចេញចាកវត្តទៅកាន់វត្ត (ដទៃ) ដោយតាំងចិត្តថា "យើងនឹងមើល" ដូច្នេះ ជាអាបត្តិពិត ។ ភិក្ខុអង្គុយនៅលើអាសនៈសាលាហើយឃើញ, មិនជាអាបត្តិ ។ ភិក្ខុក្រោកដើរទៅដោយគិតថា "យើងនឹងមើល" ជាអាបត្តិ, សូម្បីឋិតនៅលើមកថ្នល់ហើយងាក-កមើល ជាអាបត្តិដូចគ្នា ។

បទថា សរកុត្តី : សូច្បរលាក់រលែក បានដល់ ធ្វើសំឡេង ។

ពីរបទថា ភគ្គោ ហោតិ : រមែងខូច មានសេចក្ដីថា មិនអាចនឹងញាំងសមាធិដែលខូចមិនទាន់បាន ឱ្យកើតឡើងទេ, មិនអាចនឹងចូលសមាធិដែលខូចបានហើយទេ ។

ពាក្យថា បច្ឆិមា ជនតា : ពួកជនខាងក្រោយ ជាដើម មានសេចក្ដីថា ពួកជនជំនាន់ក្រោយ រមែងយកតម្រាប់តាមថា "អាចារ្យក្ដីឧបជ្ឈាយ៍ក្ដី របស់ពួកយើងច្រៀងហើយយ៉ាងនេះ" រមែងច្រៀងយ៉ាងនោះដែរ ។

វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ អាយតកេន : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិន ... ដោយសំឡេងច្រៀងដ៏វែង ៗទេ នេះ គប្បីជ្រាបដូច្នេះ ៖

កិរិយាច្រៀងដែលទំលាយនូវវត្ត (គឺ វិធីប្តូរសំឡេង) នោះ ៗ ធ្វើអក្ខរទាំងឡាយឱ្យខូច ឈ្មោះថា សំឡេងច្រៀងដ៏វែង ។ ចំណែកក្នុងធម៌ វត្តសម្រាប់សុត្តន្តៈក៏មាន វត្តសម្រាប់ជាតកក៏មាន វត្តសម្រាប់គាថាក៏មាន, ការញ៉ាំងវត្តនោះឱ្យខូច ធ្វើសំឡេងឱ្យវែងហួសពេក មិនគួរ ។ គប្បីសម្តែងបទនិងព្យញ្ជនៈទាំងឡាយឱ្យរៀបរយដោយវត្ត (គឺ ការប្តូរសំឡេង)ដែលមូល មានជ្រុង ៤ ។

## សរភញ្ញ

[១៣១] បទថា សរភញ្ញំ : សូធ្យសារភ័ញ្ញបាន គឺ ការសូធ្យដោយសំឡេង ។ បានឮថា ក្នុងសរភ័ញ្ញមានវត្ត ៣២ មានតរង្គវត្ត (ទំនងដូចទឹករលក) ទោហកវត្ត (ទំនងដូចរីតទឹកដោះគោ) គលិតវត្ត (ទំនងដូចធ្មេញរណា) ជាដើម ។ ក្នុងវត្តទាំងនោះ ភិក្ខុរមែងបានដើម្បីប្រើវត្តដែលខ្លួនត្រូវការ ។

ការដែលមិនញ៉ាំងបទនិងព្យញ្ជនៈទាំងឡាយឱ្យខូច គឺ មិនធ្វើឱ្យខុសភ្លាត់ដោយន័យមានជ្រុង ៤ ដ៏សមរម្យ ដែលសមគួរដល់សមណៈនុ៎ះឯង ជាលក្ខណៈនៃវត្តទាំងពួង ។

[១៣២] ពីរបទថា ពាហិរលោមី ឧណ្ណី : សំពត់ដែលធ្វើដោយរោមសត្វ មានរោមចេញមកខាងក្រៅ មានសេចក្តីថា ភិក្ខុ

ឆព្វគ្គិយដណ្តប់សំពត់ឧណ្ណបាវារ ធ្វើរោមឱ្យចេញមកខាងក្រៅ ។ ជាអាបត្តិទុក្កដដល់ភិក្ខុដែលទ្រទ្រង់យ៉ាងនោះ ។ នឹងដណ្តប់ធ្វើរោមទុកខាងក្នុងគួរ ។

[១៣៥] សមណកប្បកថា បានពោលទុកហើយក្នុងអដ្ឋកថានៃភូតគាមសិក្ខាបទ ។

[១៣៨] ច្រើនបទថា ន ហិ ភិក្ខវេ អត្តនោ អង្គជាតំ : **ភិក្ខុមិនត្រូវកាត់អង្គជាតរបស់ខ្លួនទេ** មានសេចក្តីថា ភិក្ខុដែលកាត់អង្គជាតប៉ុណ្ណោះ ត្រូវអាបត្តិថុល្លច្ច័យ ។ ប៉ុន្តែភិក្ខុកាត់អវយវៈដទៃណាមួយ មានត្រចៀកច្រមុះ និងម្រាមជាដើម ឬញ៉ាំងទុក្ខបែបនោះឱ្យកើតឡើងក៏ដោយ ជាទុក្កដ ។ តែមិនជាអាបត្តិដល់ភិក្ខុដែលបឺតលោហិត ឬកាត់អវយវៈ ព្រោះត្រូវពស់ចឹកឬជន្លូវមាស់ពេលជាដើមក៏ដោយ ព្រោះបច្ច័យ គឺ អាពាធយ៉ាងដទៃក៏ដោយ ។

## បាត្រ

[១៣៩] បីបទថា ចន្ទនគណ្ឋិ ឧប្បន្នា ហោតិ : **បាត្រពកឈើចន្ទន៍** មានសេចក្តីថា បាត្រដែលសម្រេចដោយខ្លឹមចន្ទន៍ជារបស់កើតឡើងហើយ ។

បានឮថា រាជគហសេដ្ឋីនោះឱ្យលាតសំណាញ់ទាំងខាងលើទឹក

និងទាំងខាងក្រោម ហើយលេងក្នុងទន្លេគង្គា ។ ពកឈើចន្ទន៍ដែលក្រសែនៃទន្លេនោះ ផាត់អណ្តែតមកជាប់នឹងសំណាញ់ បុរសទាំងឡាយរបស់សេដ្ឋីនោះ បាននាំពកឈើចន្ទន៍នោះមកឱ្យ ។ ពកឈើចន្ទន៍នោះជារបស់កើតឡើង ដោយប្រការដូច្នេះ ។

[១៤៣] ឥទ្ធិបាដិហារ្យ គឺ ការសម្តែង ព្រះមានព្រះភាគទ្រង់ហាមហើយក្នុងបទថា ឥទ្ធិប្បាដិហារិយំ នេះ ។

ចំណែកឫទ្ធិដែលសម្រេចដោយអំណាចអធិដ្ឋាន គប្បីជ្រាបថា "ទ្រង់មិនបានហាម" ។

[១៤៤] វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ សោវណ្ណមយោ បត្តោ ធារេតព្វោ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើប្រាស់បាត្រធ្វើដោយមាស ជាដើមគប្បីជ្រាបដូច្នេះ ៖

ក៏បើថា គ្រហស្ថទាំងឡាយដាក់បាយក្នុងភាជនៈ មានចានមាសជាដើម បង្អោនចូលទៅប្រគេនក្នុងរោងភត្ត, មិនគួរ សូម្បីដើម្បីនឹងពាល់ត្រូវ ។

មួយទៀត ភាជនៈទាំងឡាយ មានចានជាដើម ដែលធ្វើដោយកែវផលិក ធ្វើដោយកញ្ចក់ និងធ្វើដោយសំរឹទ្ធិជាដើម ត្រឹមតែប្រើប្រាស់ជារបស់បុគ្គលប៉ុណ្ណោះ មិនគួរ ប្រើប្រាស់ជារបស់សង្ឃ ឬជាគិហិវិកតិ (គឺ ជារបស់គ្រហស្ថ) គួរ ។

បាត្រសូម្បីជាវិការនៃស្ពាន់ ក៏មិនគួរ ចំណែកភាជនៈ គួរ ។ ពាក្យទាំងពួងដែលពោលដូច្នេះនេះ លោកពោលទុកក្នុងកុរុន្ទី ។

ចំណែកបាត្រដែលធ្វើដោយកែវ មានកែវឥន្ទនិលជាដើម ព្រះមានព្រះភាគត្រាស់ក្នុងបទថា **មណិមយោ : ធ្វើដោយកែវមណីនេះ** ។

សូម្បីបាត្រសម្រេចហើយដោយវដ្តលោហ លោករួមចូលក្នុងបទថា **កំសមយោ : ធ្វើដោយសំរិទ្ធ** នេះ ។

[១៤៦] ពាក្យថា **លិខិតុំ : ឱ្យក្រឡឹង** នេះ ព្រះមានព្រះភាគត្រាស់ ដើម្បីប្រយោជន៍ដល់ការធ្វើឱ្យស្តើង ។

[១៤៧] ជើងបាត្រជាប្រក្រតីនោះ បានដល់ ជើងបាត្រដែលឆ្លាក់ជាធ្មេញមង្ករនោះឯង ។

[១៥១] បទថា **អាវដ្តិត្វា : រមៀលបែក** បានដល់ ប៉ះខ្ទប់គ្នានិងគ្នា ។

វិនិច្ឆ័យក្នុងពាក្យថា **បត្តាធារកំ : គ្រឿងរងតម្កល់បាត្រ** នេះ គប្បីជ្រាបដូច្នេះ ៖

ក្នុងកុរុន្ទីពោលថា លើជើងបាត្រដែលជាប់នឹងផ្ទៃដី ដែលធ្វើដោយភ្លុក វល្លិ និងផ្តៅជាដើម គួរដាក់បាត្រត្រួតលើគ្នាបាន ៣, លើ

ជើងបាត្រដែលធ្វើដោយឈើ គួរដាក់បាត្រត្រួតគ្នាបាន ២ ។
ចំណែកក្នុងមហាអដ្ឋកថាពោលថា លើជើងបាត្រដែលជាប់នឹងផ្ទៃដី មិនជាឱកាសនៃបាត្រ ៣ នឹងដាក់តែ ២ ក៏គួរ ។ សូម្បីជើងបាត្រឈើនិងជើងបាត្រកំណាត់ឈើ ដែលរៀបចំល្អហើយ ក៏មានន័យដូចគ្នា ។
ក៏ឯជើងបាត្រឈើដែលស្រួចដៀងចុងគ្រឿងក្រឡឹង និងជើងបាត្រកំណាត់ឈើដែលចងដោយឈើ ៣ កំណាត់ មិនជាឱកាសនៃបាត្រសូម្បីតែមួយ ។ សូម្បីដាក់លើជើងនោះហើយ ក៏ត្រូវអង្គុយយកដៃកាន់ទុកយ៉ាងនោះ ។ ចំណែកលើផែនដីគប្បីផ្កាប់ទុកតែបាត្រមួយប៉ុណ្ណោះ ។
[១៥២] បទថា មិឍន្តេ[1] : ទីបំផុតនៃផែនក្តាតាំង បានដល់ត្រង់ទីបំផុតនៃរបៀងនិងផែនក្តារតាំងជាដើម ។ ក៏បើថា បាត្ររមៀលទៅហើយ នឹងទើនៅលើទីបំផុតក្តាររបៀងនុ៎ះឯង ; នឹងដាក់លើក្តាររបៀងដែលធំបែបនោះ ក៏គួរ ។
[១៥៣] បទថា បរិភណ្ឌន្តេ : ក្នុងទីបំផុតនៃថ្នាក់ គឺ ក្នុងទីបំផុតនៃថ្នាក់ដែលគេធ្វើទុកខាងក្រៅ ។

១. ភូមា. មិឡ្ហន្តេ ។

វិនិច្ឆ័យសូម្បីក្នុងការរបៀនដែលចង្អៀតនេះ ក៏គប្បីជ្រាបតាមន័យដែលពោលហើយក្នុងការរបៀននុ៎ះឯង ។

[១៥៤] បទថា ចោឡកំ : កំណាត់សំពត់ បានដល់ សំពត់ដែលគេក្រាល ហើយដាក់បាត្រ ។ ក៏កាលសំពត់នោះមិនមាន គួរដាក់លើកន្ទេលផែង ឬលើកន្ទេលទន់ ឬលើផ្ទៃដីគេបូកបង្ហាប់ដោយដីស្អិត ឬលើផែនដី (មានសភាពហាប់ដូចដីស្អិត) បែបនោះ ដែលមិនប្រទូស្ត ដល់បាត្រ ឬលើខ្សាច់ក៏បាន ។

ប៉ុន្តែភិក្ខុដាក់លើអាចម៍ដី និងធូលីជាដើម ឬ លើផ្ទៃដីរវឹង ត្រូវទុក្កដ ។

ពេងសម្រាប់រក្សាបាត្រនោះ ទឹងបូកដោយឥដ្ឋ ឬធ្វើដោយឈើក៏គួរ ។

ភាជន៍ដីមានមាត់ធំសម្រាប់ទុកវត្ថុ ទ្រង់ទ្រាយស្រដៀងថ្លាងទឹកមានមាត់ធំ ហៅថា ភាជន៍សម្រាប់ទុកបាត្រ ។

[១៥៥] ពីរបទថា យោ លគ្គេយ្យ : ភិក្ខុណាព្យួរ មានសេចក្ដីថា ជាអាបត្តិទុក្កដដល់ភិក្ខុដែលព្យួរបាត្រក្នុងទីណាមួយ ។ សូម្បីចងព្យួរទុកត្រង់ស្នួរចីវរ ក៏មិនគួរ ។

[១៥៦-៩] គ្រែ និងតាំង ជារបស់ដែលគេធ្វើទុក ដើម្បីដាក់វត្ថុ

ប៉ុណ្ណោះ ឬដើម្បីអង្គុយ-ដេក ក៏ដោយ, ជាអាបត្តិទុក្កដដល់ភិក្ខុដែលដាក់បាត្រលើគ្រែ ឬតាំងយ៉ាងណាមួយ តែនឹងចងជាមួយទ្រព្យដទៃទុកដាក់គួរ ។ ឬនឹងចងត្រង់មេគ្រែព្យួរទុកក៏គួរ ។ នឹង ចងហើយដាក់ខាងលើគ្រែនិងតាំង មិនគួរដូចគ្នា ។

ក៏បើថា គ្រែក្តី តាំងក្តី ជារបស់ដែលគេលើកឡើងពាក់ជារន្ទា លើស្នួរចីវរជាដើម, នឹងដាក់លើគ្រែឬតាំងនោះ ក៏គួរ ។ នឹងយកខ្សែយោគពាក់លើស្មាហើយដាក់លើភ្លៅ ក៏គួរ ។ បើបាត្រដែលប្រដាប់លើស្មាសូម្បីពេញដោយបាយ ក៏មិនគួរដាក់លើឆត្រ ។ តែនឹងដាក់បាត្រប្រភេទណាមួយ ឬលើឆត្រដែលចងជា មួយភណ្ឌៈ ឬលើឆត្រដែលចងជាភាន គួរ ។

[១៦០] វិនិច្ឆ័យក្នុងពាក្យថា **បត្តហត្ថេន : មានបាត្រនៅដៃ** គប្បីជ្រាបដូច្នេះ ៖

បាត្ររបស់ភិក្ខុណានៅក្នុងដៃ ភិក្ខុនោះឯង ឈ្មោះថា អ្នកមានបាត្រក្នុងដៃតែម្យ៉ាង ក៏ទេ, មួយទៀត ភិក្ខុដែលមានបាត្រនៅក្នុងដៃ រមែងមិនបានដើម្បីប្រានទ្វារតែម្យ៉ាងប៉ុណ្ណោះ ក៏មិនបាន ។

តែការពិត កាលបាត្រនៅក្នុងដៃឬលើខ្នងជើង ឬត្រង់អវយវៈនៃសរីរៈណាមួយ រមែងមិនបានដើម្បីនឹងប្រានទ្វារ មិនបានដើម្បីនឹងជកនូវគន្លឹះចេញ មិនបានដើម្បីនឹងយកកូនសោចាក់មេសោ ដោយដៃឬដោយខ្នង

ជើង ឬដោយសីសៈ ឬដោយអវយវៈនៃសរីរៈណាមួយ ។ តែស្ពាយបាត្រលើស្មាហើយ រមែងបានដើម្បីបើកគន្លឹះទ្វារតាមសប្បាយពិត ។

[១៦១] សំបកឃ្លោក ហៅថា តុម្ពកដាហំ ទឹងវក្សាសំបកឃ្លោកនោះទុក មិនគួរ ។ ក៏បើបានមកហើយក៏ទឹងប្រើប្រាស់ជារបស់ទ្វីគួរ សូម្បីក្នុងអម្បែងផ្ទាំង ក៏មានន័យដូចគ្នា ។

[១៦២] អម្បែងផ្ទាំង ហៅថា ឃដិកដាហ ។

[១៦៣] ពាក្យថា អត្តមេ្ន : ដល់អញតើ នេះ ជាពាក្យសម្តែងសេចក្តីរន្ធត់ចិត្ត ។

វិនិច្ឆ័យក្នុងបទថា សព្វបំសុកូលិកេន : ជាអ្នកប្រព្រឹត្តយកវត្ថុបង្សុកូលគ្រប់មុខ នេះ គប្បីជ្រាបដូច្នេះ ៖

ចីវរ គ្រែ និងតាំង ជារបស់បង្សុកូល រមែងគួរ ។ ចំណែករបស់ដែលគប្បីបរិភោគ ដែលគេឱ្យហើយទុំះឯង គប្បីកាន់យក ។

[១៦៤] បទថា ចលកានិ : ដាក់កាកអាមិស បានដល់ អាមិសដែលទឹងចោលចេញ មិនបរិភោគ ។

បទថា អដ្ឋិកានិ : ឆ្អឹង បានដល់ ឆ្អឹងត្រី ឬឆ្អឹងសត្វ ។

បទថា ឧច្ចិដ្ឋោទកំ : ទឹកជាដែល បានដល់ ទឹកខ្ពុរមាត់ ។ កាលភិក្ខុប្រើ បាត្រជញ្ជូនវត្ថុអ្វីមួយចោល ក្នុងអាមិសដែលជារបស់

សល់ជាដើមនោះ ត្រូវអាបត្តិទុក្កដ ភិក្ខុ រមែងមិនបាន ដើម្បីធ្វើបាត្រឱ្យជាកន្ទោរលាងដៃ នឹងដាក់សូម្បីនូវទឹកលាងដៃលាងជើងចុះក្នុងបាត្រហើយនាំទៅចាក់ ក៏មិនគួរ ។ នឹងចាប់បាត្រដែលស្អាត ដែលមិនប្រលាក់នូវកាកសំណល់ ដោយដៃដែលប្រលាក់នូវកាកសំណល់ ក៏មិនគួរ ។ តែនឹងយកដៃឆ្វេងចាក់ទឹកចុះ ក្នុងបាត្រដែលស្អាតនេះហើយ បឺតយកទឹកមួយមាត់ ហើយទើបចាប់ដោយដៃដែលប្រលាក់ គួរ ។ ពិតមែន សូម្បីដោយហេតុត្រឹមតែប៉ុណ្ណេះបាត្រនោះ រមែងជាបាត្រប្រលាក់ផង ។

មួយទៀត លាងដៃដែលប្រលាក់ដោយទឹកខាងក្រៅហើយ ទើបចាប់ (បាត្រ) គួរ ។

កាលកំពុងឆាន់សាច់ត្រីនិងផលាផលជាដើម ក្នុងរបស់ទាំងនោះវត្ថុណាជាឆ្អឹង ឬជារបស់សល់ ជាអ្នកប្រាថ្នានឹងចោល, នឹងយកវត្ថុនោះដាក់ចុះក្នុងបាត្រ រមែងមិនបាន ។ ចំណែកវត្ថុណា ចង់នឹងឆាន់តទៅទៀត យកវត្ថុនោះដាក់ចូលក្នុងបាត្រក៏បាន ។ ដាក់សាច់ដែលមានឆ្អឹងនិងត្រីដែលមានឆ្អឹងជាដើម ក្នុងបាត្រនោះ និងយកដៃបេះចេញឆាន់ ក៏គួរ ។ តែវត្ថុណាមួយដែលយកចេញពីក្នុងមាត់មក ហើយនៅចង់ឆាន់ទៀត យកវត្ថុនោះដាក់ចូលក្នុងបាត្រ មិនបាន ។

ចំណិតខ្ទឹមនិងចំណិតដូងជាដើម ខាំហើយ នឹងដាក់ទៀត ក៏បាន ។

# កាំបិតនិងម្នូល

[១៦៥] បទថា ឆមតកំ : កំណាត់រុំ បានដល់ កំណាត់សំពត់សម្រាប់រុំកាំបិត ។

[១៦៦] បទថា ឆណ្ឌសត្ថកំ : កាំបិតមានដង បានដល់ កាំបិតដែលបញ្ចូលដងយ៉ាងណាមួយ ជាកាំបិតបត់ ឬកាំបិតដទៃក៏បាន ។

[១៦៨] ពីរបទថា កណ្ណកិតាយោ ហោន្តិ : មានច្រែះចាប់ គឺ ជារបស់ដែលច្រែះចាប់ ។

ពីរបទថា កិណ្ណេន បូរេតុំ : ឱ្យដាក់លំអិតពេញ មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យដាក់លំអិតពេញ(ក្នុងបំពង់ម្ជុល) ។

បទថា សត្តុយា : ដែលលាយដោយល្មៀត មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យដាក់ពេញដោយលំអិតម្សៅដែលលាយដោយល្មៀត ។

សុម្ពីលំអិតនៃសិលា ហៅថា លំអិតថ្ម ។ សេចក្ដីថា តថាគតអនុញ្ញាតឱ្យដាក់ពេញដោយលំអិតសិលានោះ ។

ពីរបទថា មធុសិត្ថកេន សារេតុំ : ឱ្យលាបដោយក្រមួនឃ្មុំ មានសេចក្ដីថា តថាគតអនុញ្ញាលាប(ម្ជុល) ដោយក្រមួនឃ្មុំ ។

ពីរបទថា សរិតកម្បិ បរិភិជ្ជតិ : ដែលលាបហើយ ក៏បែករាត់រាយទៅ មានសេចក្ដីថា ក្រមួនឃ្មុំដែលលាបនោះបែកខ្ចាយ ។

បទថា សរិតសិព្វានិកំ : សំពត់សម្រាប់រុំ បានដល់ សំពត់ខ្ចប់ក្រមួនឃ្មុំ ។

ក្នុងកុរុន្ទីពោលថា ចំណែកកំណាត់សំពត់សម្រាប់រុំស្រោមកាំបិត ក៏អនុលោមតាមកំណាត់សំពត់សម្រាប់រុំក្រមួនឃ្មុំ ។

## ឈើស្ទឹង

[១៦៩] ឈើស្ទឹងនោះ បានដល់ មេស្ទឹងផង កន្ទេលផ្ដៅឬកន្ទេលផែងណាមួយ ដែលគប្បីក្រាលលើមេស្ទឹងនោះផង ។

ខ្សែចងឈើស្ទឹងនោះ បានដល់ ខ្សែសម្រាប់ចងចីវរលើឈើស្ទឹងកាលដេរចីវរ ២ ជាន់ ។

ពីរបទថា គាឋិនំ នប្បហោតិ : ឈើស្ទឹងមិនល្មមគ្នានឹងចីវរ មានសេចក្ដីថា ឈើស្ទឹងដែលធ្វើតាមខ្នាតរបស់ភិក្ខុដែលខ្ពស់ ចីវររបស់ភិក្ខុដែលទាប កាលលាត សន្ធឹងលើឈើស្ទឹងនោះ រមែងមិនល្មម គឺរលុងនៅខាងក្នុងប៉ុណ្ណោះ, អធិប្បាយថា មិនដល់គែមឈើស្ទឹង ។

បទថា ទណ្ឌកឋិនំ : ដងឈើស្ទឹង មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យចងឈើស្ទឹងដទៃ តាមខ្នាតរបស់ភិក្ខុដែលទាបក្រៅនេះ ត្រង់កណ្ដាលនៃមេស្ទឹងវែងនោះ ។

បទថា វិទលកំ : ការបត់ទ្រនាប់ផ្ដៅ បានដល់ ការបត់ជា

យដោយជុំវិញនៃកន្ទេលផ្តៅធ្វើឱ្យជា ២ជាន់ ល្មមខ្នាតនឹងកន្ទោងស្តឹង ។

បទថា សលាកំ : ស្លាក បានដល់ ចំរៀកឈើសម្រាប់ស៊ក ចូលក្នុងចន្លោះនៃចីវរ ២ ជាន់ ។

បទថា វិនន្ធនរជ្ជុំ : ខ្សែរឹតបណ្តឹង បានដល់ ខ្សែដែលចង មេស្តឹងតូចនឹងមេស្តឹងធំ ត្រង់ឈើស្តឹងនោះ ។

បទថា វិនន្ធនសុត្តកំ : អំបោះរឹតចីវរភ្ជាប់ បានដល់ អំបោះ ដែលសង្កត់ចីវរជាប់ នឹងមេស្តឹងតូច ។

បីបទថា វិនន្ធិត្វា ចីវរំ សិព្វេតុំ : ដើម្បីចងចីវរហើយដេរ មានសេចក្តីថា តថាគតអនុញ្ញាតឱ្យសង្កត់ចីវរត្រង់មេស្តឹងនោះ ដោយអំបោះនោះហើយដេរ ។

ពីរបទថា វិសមា ហោន្តិ : មិនស្មើគ្នា មានសេចក្តីថា ដោយមិនស្មើកន្លែងខ្លះតូច កន្លែងខ្លះធំ ។

បទថា កឡិម្ពកំ : ខ្នាតសម្រាប់វាស់ បានដល់ វត្ថុមានស្លឹកត្នោតជាដើមយ៉ាងណាមួយសម្រាប់ធ្វើការកំណត់ប្រមាណ ។

បទថា មោឃសុត្តកំ : ខ្សែបន្ទាត់ បានដល់ ការធ្វើគ្រឿងសម្គាល់ដោយបន្ទាត់ល្មៀត ដូចការធ្វើគ្រឿងសម្គាល់លើឈើ ដោយសរសៃបន្ទាត់ខ្មៅរបស់ពួកជាងឈើទាំងឡាយ ។

[១៧៣] ពីរបទថា អច្ចលិយា បដិគ្គណ្ហន្តិ : កាន់ដោយម្រាមដៃ មានសេចក្ដីថា ភិក្ខុទាំងឡាយ(ដេរចីវរ) ចាប់ដោយម្រាមដៃត្រង់មុខម្ជុល ។

បទថា បដិគ្គហំ : ស្នាប់កាន់ បានដល់ ស្នាប់ម្រាមដៃ ។

ភាជនៈមានថាសនិងប្រអប់ជាដើម យ៉ាងណាមួយ ឈ្មោះថា ភាជនៈសម្រាប់ប្រឆេះនិងកំប៉ុង ។

[១៧៦] បទថា ឧច្ចវត្ថុកំ : ឱ្យធ្វើទីឱ្យខ្ពស់ឡើង មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យភិក្ខុចាក់ដីធ្វើផ្ទៃដីឱ្យខ្ពស់ ។

[១៧៧] ច្រើនបទថា ឱគុម្ពេត្វា ឧល្លិត្តាវលិត្តំ កាតុំ : ឱ្យគាបដំបូល ហើយបូកទាំងក្នុងទាំងក្រៅ មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យភិក្ខុគាបដំបូល ហើយធ្វើដែរណែនឱ្យញឹក បូកដោយដីស្អិតទាំងខាងក្នុងនិងខាងក្រៅ ។

បទថា គោឃំសិកាយ : ដោយឈើស្នូល មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យភិក្ខុដាក់ឫស្សីឬឈើខាងក្នុងហើយមូរមេស្ដឹងជាមួយនឹងឈើនោះ ។

បទថា ពន្ធនរជ្ជុំ : ខ្សែសម្រាប់ចង បានដល់ ខ្សែសម្រាប់រុំមេស្ដឹងដែលមូរហើយយ៉ាងនោះ ។

# តម្រងទឹក

[១៨២] សំពត់ត្រងដែលចងជាប់នឹងឈើ ៣ កំណាត់ ឈ្មោះថា តម្រង សម្រាប់ត្រង ។

[១៨៤] ពាក្យថា យោ ន ទទេយ្យ : ភិក្ខុណាមិនឱ្យ មានសេចក្ដីថា ភិក្ខុណា មិនឱ្យសំពត់តម្រងដល់ភិក្ខុ ដែលមិនមានសំពត់តម្រងនុ៎ះឯង, ជាអាបត្តិដល់ភិក្ខុនោះពិត ។

ចំណែកភិក្ខុណា កាលសំពត់តម្រងក្នុងដៃរបស់ខ្លួនសូម្បីមានហើយ នៅតែមកខ្ចី បើមិនចង់ឱ្យក៏កុំគប្បីឱ្យភិក្ខុនោះ ។

[១៨៦] បទថា ទណ្ឌបរិស្សាវនំ[១] : សំពត់តម្រងមានជើង មានសេចក្ដីថា គប្បីចងសំពត់ នឹងឈើដែលធ្វើដូចមេជណ្ដើរ ខណ្ឌកណ្ដាល ដែលចងជាប់លើជើង ៤ ហើយចាក់ទឹកចុះត្រង់កណ្ដាលឈើ ដូចតម្រងទឹកក្បួនរបស់ពួកជាងជ្រលក់ ។ ទឹកនោះពេញទាំង ២ បន្ទប់ហើយ រមែងហូរចេញ ។ ភិក្ខុទាំងឡាយ ក្រាលសំពត់តម្រងណា ចុះក្នុងទឹកហើយ យកឆ្នាំងដងទឹក សំពត់ត្រងនោះ ឈ្មោះថា ឱត្ថរិកំ : សំពត់តម្រងត្រាំ ។

១. ថៃ. ទណ្ឌកបរិស្សាវនំ ។

ពិតមែន ភិក្ខុទាំងឡាយចងសំពត់ជាប់នឹងឈើ ៤ ដែលបោះបង្គោល ៤ ដើម ចុះក្នុងទឹកហើយ ចងសំពត់តម្រងនោះ ជាប់នឹងបង្គោលនោះ ឱ្យជាយសំពត់ជុំវិញទាំងអស់ផុតពីទឹកត្រង់ កណ្ដាលស្រុតចុះ ហើយយកឆ្នាំងដងទឹក ។

[១៨៧] ផ្ទះដែលធ្វើដោយចីវរ ហៅថា មកសកុដិក : មុងការពារមូស ។

## ទីចង្ក្រមនិងរោងភ្លើង

[១៨៨] បទថា អភិសន្នកាយា : មានកាយចម្រើនទៅដោយរោគ គឺអ្នកមានកាយពេញទៅដោយវត្ថុដែលជាទោសមានស្លេស្មជាដើម ។

[១៨៩] សសរសម្រាប់ដាក់ស្នៀត ខ្ទាតប៉ុននឹងសន្ទះទ្វារល្មមល្អ ហៅថា អគ្គឡវដ្ដិ : សសររបស់សន្ទះទ្វារ ។

សសរសម្រាប់ដាក់ត្រដោកនោះ ជាសសរដែលគេចោះទុក ៣-៤ រន្ធ ហើយដាក់ត្រដោក ។

ក្រវិលសម្រាប់ដាក់បណ្ដូល ដែលគេចោះសន្លឹកទ្វារហើយ សង្កត់ជាប់ត្រង់សន្ទះទ្វារនោះ ឈ្មោះថា ឆ្នាក់ពេជ្រ ។ គេចោះប្រហោងត្រង់កណ្ដាលនោះ ហើយស៊កទុក ឈ្មោះថា សូចិកា : រន្ទុកទ្វារ ។ វត្ថុ

ដែលគេភ្ជាប់ទុកខាងលើ ឈ្មោះថា **យដិកា** : គន្លឹះទ្វារ ។

ពីរបទថា **មណ្ឌលិកំ កាតុំ** : ឱ្យធ្វើដីឱ្យទាបជុំវិញ មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យធ្វើផែនដីឱ្យទាបវិញ ។

បំពង់ផ្សែងនោះ បានដល់ ប្រហោងសម្រាប់ផ្សែងភ្លើងចេញ ។

[១៩៥] បទថា **វាសេតុំ** : អប់ដោយគ្រឿងក្រអូប មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យអប់ដោយគ្រឿងក្រអូបទាំងឡាយ ។

[១៩៦] **ឧទកនិធាន** : សៀនទឹក នោះ បានដល់ កន្លែងដែលសម្រាប់តម្កល់ទឹកទុក ។ ភិក្ខុគប្បីប្រើឆ្នាំងតម្កល់ទឹកទុកក្នុងកន្លែងនោះ ហើយយកផ្ដិលដងទឹកប្រើប្រាស់ ។

[១៩៨] **កោដ្ឋកោ** : ស៊ុំ[១] បានដល់ ស៊ុំទ្វារ ។

[២០៣] វិនិច្ឆ័យក្នុងពាក្យថា **តិស្សោ បដិច្ឆាទិយោ** : ទីបិទបាំង ៣ យ៉ាង នេះ គប្បីជ្រាបដូច្នេះ ៖

គ្រឿងបិទបាំង គឺ រោងភ្លើង១ គ្រឿងបិទបាំង គឺ ទឹក១ គួរដល់ភិក្ខុដែលធ្វើបរិកម្មប៉ុណ្ណោះ ។ មិនគួរក្នុងសាមីចិកម្មទាំងឡាយដ៏សេសមានការអភិវាទជាដើម ។ គ្រឿងបិទបាំង គឺសំពត់ គួរក្នុងកម្មទាំងពួង ។

---

១. បិដកខ្មែរត្រង់នេះថា បន្ទប់; តែក្នុងទំព័រ៣០៤ កោដ្ឋកំ ប្រែថា ខ្លោងទ្វារ ដែរ ។

[២០៨] ពាក្យថា **មិនទាន់មានទឹក** នោះ បានដល់ មិនមានទឹកសម្រាប់ផ្ទុត ។

[២០៩] បទថា តុលំ : **ឈើថ្លឹង** បានដល់ ជញ្ជីងសម្រាប់យោងទឹកឡើង ដូចជញ្ជីងរបស់ពួកអ្នកផ្សារ ។

បទថា ករកដកោ : **ព្រ័ត្រវែង** បានដល់ យន្តដែលទឹមគោ ឬប្រើដៃចាប់ទាញដោយខ្សែដែលវែង ។

បទថា ចក្កវដ្ដកំ : **កង់វិល** បានដល់ រ៉តដែលមានដុំចងជាប់នឹងកាំ ។

ដែលឈ្មោះថា ចម្មខណ្ឌំ : **បំពង់ស្បែក** បានដល់ ភាជនៈដែលធ្វើដោយស្បែក គប្បីចងជាប់នឹងឈើថ្លឹង ឬរហាត់ ។

[២០៩] ពីរបទថា ឆាកដា ហោតិ : **តាំងនៅក្នុងទីវាល** មានសេចក្ដីថា អណ្ដូងទឹកជ្រាំ មិនបានលោមព័ទ្ធ ។

[២១០] បទថា ឧទកបុញ្ឆនិ : **វត្ថុសម្រាប់ជូតទឹក** មានសេចក្ដីថា គ្រឿងជូតទឹកធ្វើដោយភ្លុកក្ដី ធ្វើដោយស្នែងក្ដី ធ្វើដោយឈើក្ដី រមែងគួរ ។ កាលគ្រឿងជូតទឹកនោះមិនមាននឹងប្រើសំពត់ផ្ចិតទឹកក៏គួរ ។

[២១១] បទថា **ឧទកមាតិកំ** : ប្រឡាយទឹក បានដល់ ប្រឡាយសម្រាប់ទឹកហូរ ។

[២១២] ដែលឈ្មោះថា **និល្លេខជន្តាឃរំ** : រោងភ្លើងជហ្វាជង្ក្តារ គឺ រោងភ្លើងដែលជាប់ជង្ក្តារដោយជុំវិញ ។

ពាក្យថា **រោងភ្លើងមិនមានជហ្វាជង្ក្តារ** នោះ ជាឈ្មោះនៃរោងភ្លើងដែលមានដំបូលធ្វើជាកំពូល ជាប់ជង្ក្តារត្រង់មណ្ឌលជហ្វាលើវនុកទាំងឡាយ ។

[២១៣] ពីរបទថា **ចាតុម្មាសំ និសីទនេន វិប្បវសិតព្វំ** : នៅប្រាសចាកនិសីទនៈអស់ ៤ ខែ មានសេចក្តីថា ភិក្ខុមិនគប្បីនៅប្រាសចាកសំពត់និសីទនៈរហូតដល់អស់ ៤ ខែ ។

[២១៤] បទថា **បុប្ផាភិកិណ្ណេសុ** : ដែលរោយរាយដោយផ្កា មានសេចក្តីថា ភិក្ខុមិនគប្បីដេកលើទីដេកដែលគេប្រដាប់ដោយផ្កាឈើ ។

[២១៦] បទថា **ឆមតកំ** : កម្រាលស្នាច់ មានសេចក្តីថា កម្រាលអង្គុយ ស្រដៀងសន្ថតដែលគេធ្វើ គឺត្បាញដោយរោមចៀម គប្បីប្រើប្រាស់ដោយបរិហារ ទុកដូចកំណាត់ស្បែក ។

## ការឆាន់

[២១៧] ឈ្មោះថា អាសិត្តកូបធានេ : ក្នុងភាជន៍ពិសេស សម្រាប់រងឆាន់ នោះ ជាពាក្យហៅ តុ ឬថាស ដែលធ្វើដោយទង់ដែង ឬដោយប្រាក់ ។ មួយទៀត ភាជន៍ពិសេសនោះ សូម្បីធ្វើដោយឈើ ក៏មិនគួរ ព្រោះជារបស់ដែលទ្រង់ហាមហើយ ។

[២១៨] ជើងទ្រធ្វើដោយកំណាត់ឈើ ហៅថា មឡោរិក : ភាជន៍សម្រាប់រង ។ សូម្បីទម្រដែលធ្វើដោយស្លឹក ជាលទិងកព្រៃង ក៏រាប់បញ្ចូលក្នុងភាជន៍សម្រាប់រងនេះដែរ ។

ពិតមែន វត្ថុមានសសរឈើជាដើមនោះ ចាប់ផ្ដើមតាំងពីដល់ការរួមចុះថា ជាគ្រឿងទ្រ មានប្រហោងបោះទុកខាងក្នុងក្ដី បោះទុកដោយជុំវិញក្ដី គួរដូចគ្នា ។

[២១៩] វិនិច្ឆ័យក្នុងពាក្យថា ឯកភាជនេ : ក្នុងភាជន៍ជាមួយគ្នា នេះ គប្បីជ្រាបដូច្នេះ ៖

បើថា ភិក្ខុមួយរូបកាន់យកផ្លែឈើ ឬនំអំពីភាជន៍ជៀសទៅ, កាលភិក្ខុនោះ ជៀសចេញទៅហើយ ការដែលភិក្ខុក្រៅនេះ ឆាន់ផ្លែឈើ ឬនំដ៏សេស រមែងគួរ ។ សូម្បីភិក្ខុក្រៅអំពីនេះ នឹងកាន់យកក្នុងខណៈនោះទៀត ក៏គួរ ។

# ការផ្គាប់បាត្រ

[២២៣] វិនិច្ឆ័យក្នុងពាក្យថា អដ្ឋហង្គេហិ : អង្គ ៨ ប្រការនេះគប្បីជ្រាបដូច្នេះ ៖

ការដែលសង្ឃផ្គាប់បាត្រខាងក្នុងសីមា ឬទៅខាងក្រៅសីមាហើយផ្គាប់បាត្រក្នុងទីទាំងឡាយមានទន្លេជាដើម ដល់ឧបាសកដែលប្រកបសូម្បីដោយអង្គមួយ ៗ រមែងគួរពិត ។

ក៏បើកាលបាត្រ ដែលសង្ឃផ្គាប់ហើយយ៉ាងនោះ ទេយ្យធម៌ណា ៗ ក្នុងផ្ទះរបស់ឧបាសកនោះ ភិក្ខុទាំងឡាយមិនគប្បីទទួល ។ គប្បីបញ្ជូនដំណឹងទៅក្នុងវត្ត ដទៃទៀតថា "លោកទាំងឡាយកុំទទួលភិក្ខាក្នុងផ្ទះរបស់ឧបាសកឯណោះឡើយ" ។

[២២៧] ក៏ក្នុងការដែលនឹងផ្ងារបាត្រ ត្រូវឱ្យឧបាសកនោះ សូមខមាទោស ៣ ដង ឱ្យឧបាសកនោះលះហត្ថបាសហើយ គប្បីផ្ងារបាត្រដោយញត្តិទុតិយកម្ម ។

# រឿងពោធិរាជកុមារ

[២៣២] ពីរបទថា បុរក្ខិត្វា : ឱ្យស្ដេចយាងទៅខាងមុខ បានដល់ ចាត់ទុកដោយភាពជាកំពូល ។

បទថា សំហរតុ : សូមទ្រង់សារចេញ មានសេចក្ដីថា សំពត់ទាំងឡាយ លោកចូរមូរទុក ។

បទថា ចេឡបដិកំ : កម្រាល បានដល់ កម្រាល គឺ សំពត់ ។

បានឮថា ពោធិរាជកុមារនោះ ក្រាលហើយដោយបំណងថា "បើយើងនឹងបានបុត្រ, ព្រះមានព្រះភាគទ្រង់នឹងជាន់ផ្ទាំងសំពត់របស់យើង" ។

ពិតមែន ពោធិរាជកុមារនោះ មិនសមគួរបានបុត្រ ; ព្រោះហេតុនោះ ទើបព្រះមានព្រះភាគមិនជាន់ ។ បើថា ព្រះអង្គទ្រង់ជាន់, ខាងក្រោយ កាលកុមារមិនបានបុត្រ នឹងប្រកាន់ទិដ្ឋិថា "ព្រះមានព្រះភាគនេះមិនមែនព្រះសព្វញ្ញូ" ។ នេះជាហេតុក្នុងការដែលព្រះមានព្រះភាគទ្រង់មិនជាន់មុន ។

[២៣៣] ចំណែកភិក្ខុទាំងឡាយណា មិនដឹង គប្បីជាន់, ភិក្ខុទាំងនោះ គប្បីជាអ្នកត្រូវពួកគ្រហស្ថមើលងាយ, ព្រោះហេតុនោះ ទើប

ព្រះមានព្រះភាគទ្រង់បញ្ញត្តិសិក្ខាបទ ដើម្បីដោះភិក្ខុទាំងឡាយ អំពីសេចក្ដីមើលងាយ ។ នេះជាហេតុក្នុងការបញ្ញត្តិសិក្ខាបទ ។

[២៣៤] ពាក្យថា **មង្គលត្ថាយ យាចិយមានេន : កាលបើគេអង្វរដើម្បីប្រយោជន៍ជាមង្គល** មានសេចក្ដីថា ស្ត្រីណាមួយជាអ្នកមានគភ៌សម្រាលហើយ ឬជាអ្នកមានគភ៌ចាស់ ( មានទម្ងន់ ), ភិក្ខុដែលគេអង្វរ ដើម្បីត្រូវការមង្គល ក្នុងឋានៈបែបនោះ សមគួរជាន់ ។

## គ្រឿងជូតជើង

[២៣៥] កម្រាល ជារបស់ដែលគេក្រាលទុកជិតទីលាងជើង ដើម្បីប្រយោជន៍ដល់ការជាន់ ដោយជើងដែលលាងហើយ ឈ្មោះថា **កម្រាលសម្រាប់ភិក្ខុដែលមានជើងស្អាតបាត**, ភិក្ខុគួរជាន់កម្រាលនោះ ។

[២៣៦-៧] វត្ថុដែលមានរចនាស្រដៀងពកផ្លៃឈូក ដែលគេធ្វើឱ្យកន្ទួលតាំងឡើង ដើម្បីជូតជើងឈ្មោះថា គ្រឿងជូតជើង, គ្រឿងជូតជើងនោះ នឹងជារបស់មូល ឬដោយប្រភេទផ្សេង ៗ មាន ៤ ជ្រុងជាដើម ជារបស់ដែលទ្រង់ហាមហើយ ព្រោះជារបស់ប្រកបការច្រើននោះឯង; មិនគួរទទួល មិនគួរប្រើប្រាស់ទេ ។

សិលា ហៅថា ក្រួស សូម្បីថ្មពពុះទឹក ( ផ្កាថ្ម ) ក៏គួរ ។

## ផ្លិត

[២៣៨-៩] ផ្លិតវិជនី ហៅថា វិធូបនំ : ផ្លិត ៤ ជ្រុង ។ ចំណែកផ្លិតមូលដូចស្លឹកត្នោត ជារបស់ដែលធ្វើអំពីស្លឹកត្នោត ឬធ្វើអំពីបន្ទះឫស្សី និងបន្ទះភ្លុក ឬធ្វើដោយរោមកន្ទុយក្ងោក ឬធ្វើដោយចម្រៀកតិទាំងឡាយ គួរគ្រប់យ៉ាង ។

[២៤០] ផ្លិតសម្រាប់បក់មូសនោះ សូម្បីមានដងធ្វើដោយភ្លុក ឬស្នែង ក៏គួរ ។ សូម្បីផ្លិតដែលធ្វើពីពួរនៃដើមកេតនិងស្លឹកកណ្ដាលជាដើម ក៏សង្គ្រោះចូលក្នុងផ្លិតដែលធ្វើដោយសំបកឈើ ។

## ឆត្រ

[២៤៣] វិនិច្ឆ័យក្នុងពាក្យថា គិលានស្ស ឆត្តំ : អនុញ្ញាតឆត្រដល់ភិក្ខុមានជម្ងឺ នេះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុណា មានសេចក្ដីក្ដៅក្នុងកាយ ឬមានការពិបាកចិត្ត ឬមានភ្នែកស្រវាំង ឬអាពាធប្រភេទដទៃយ៉ាងណាមួយ ដែលវៀរឆត្រចេញ រមែងកើតឡើង, ភិក្ខុនោះ គួរបាំងឆត្រក្នុងស្រុក ឬក្នុងព្រៃបាន ។ មួយទៀត កាលភ្លៀងធ្លាក់ បាំងឆត្រដើម្បីរក្សាចីវរ និងក្នុងទីគួរខ្លាចសត្វកាចនិងចោរ បាំងឆត្រដើម្បីការពារខ្លួន ក៏គួរ ។ ចំណែកឆត្រស្លឹកឈើមួយសន្លឹក រមែងគួរក្នុងទីទាំងពួងតែម្ដង ។

## ទណ្ឌសម្មតិជាដើម

[២៤៥] បទថា អសិស្ស កាត់បទថា អសិ អស្ស ប្រែថា ជារបស់ គឺ ជារបស់ចោរនោះ ។

បទថា វិជោតលតិ : ភ្លឺស្វាច បានដល់ ពន្លឺភ្លឺរន្ទាល ។

[២៤៦] វិនិច្ឆ័យក្នុងពាក្យថា ទណ្ឌសម្មតី : សន្មតឱ្យឈើច្រត់ នេះ គប្បីជ្រាបដូច្នេះ ៖

ឈើច្រត់ប្រកបដោយប្រមាណ គឺ ប្រវែង ៤ ហត្ថប៉ុណ្ណោះ ដែលសង្ឃគប្បីសន្មតឱ្យ ។ ឈើច្រត់ដែលខ្លី ឬវែងជាង ៤ ហត្ថនោះ សូម្បីវៀរចាកការសន្មត ក៏គួរដល់ភិក្ខុទាំងពួង ។

[២៤៩] ចំណែកសង្រែក មិនគួរដល់ភិក្ខុដែលមិនអាពាធ ។ សង្ឃគប្បីសន្មតឱ្យចំពោះភិក្ខុដែលអាពាធប៉ុណ្ណោះ ។

## ភិក្ខុដែលទំពាអៀង

[២៥៤] វិនិច្ឆ័យក្នុងពាក្យថា រោមជ្ជកស្ស : ដល់ភិក្ខុអ្នកទំពាអៀងជាប្រក្រតី នេះ គប្បីជ្រាបដូច្នេះ ៖

វៀរលែងតែភិក្ខុដែលទំពារអៀងចេញ ជាអាបត្តិដល់ភិក្ខុទាំងឡាយដ៏សេស អ្នកញុំាងអាហារដែលកើបឬក្អួតចេញមក ឱ្យឃាំងនៅក្នុង

មាត់ហើយលេបចូលវិញ ។ តែបើថា អាហារដែលភើចេញមកនោះ មិនទាន់ឃាំងនៅក្នុងមាត់ ក៏ហូរចូលទៅក្នុងបំពង់-កវិញ គួរ ។

[២៥៥] ពាក្យថា យំ ធិយ្យមានំ[១] : គ្រាប់បាយណាដែលគេកំពុងឱ្យហើយធ្លាក់ចុះ នេះ ខ្ញុំព្រះករុណាបានពណ៌នាទុកហើយ ក្នុងភោជនវគ្គ ។

## កាំបិតកាត់ក្រចក

[២៥៦] ពីរបទថា កុប្បំ គរិស្សាមិ : ហើយទីងស្រែកឥឡូវនេះ មានសេចក្តីថា យើងនឹងធ្វើនូវសំឡេង ។

[២៥៧] មិនមានអាបត្តិ ព្រោះកាត់ក្រចកដោយក្រចកជាដើម ។ តែព្រះមានព្រះភាគ ទ្រង់អនុញ្ញាតកាំបិតឬកន្ត្រៃកាត់ក្រចក ក៏ដើម្បីរក្សាខន្ធ ។

[២៥៨] បទថា វីសតិមដ្ឋំ : ក្រចកទាំង ២០ មានសេចក្តីថា ភិក្ខុឆព្វគ្គិយឱ្យតាក់តែងក្រចកទាំង ២០ ឱ្យរលោងដោយការកោស ។

បទថា មលមត្តំ : ត្រឹមល្មមប៉ុណ្ណោះ មានសេចក្តីថា តថាគតអនុញ្ញាតឱ្យឆ្កឹះតែអាចម៍ក្រចកចេញ ។

---

១. ថៃ. ទីយមានំ ។

# សក់ និង ពុកមាត់

[២៥៩] បទថា ខុរសិបាដិកំ បានដល់ ខុរកោសកំ : ស្រោមកាំបិតកោរ ។

[២៦០] ពីរបទថា មស្សុំ កប្បាបេន្តិ : ឱ្យគេកាត់ពុកមាត់ មានសេចក្ដីថា ភិក្ខុឆព្វគ្គិយឱ្យកាត់ពុកមាត់ដោយកន្ត្រៃ ។

ពីរបទថា មស្សុំ វឌ្ឍាបេន្តិ : ទុកពុកមាត់ បានដល់ តាក់តែងពុកមាត់ឱ្យវែង ពុកចង្កាត្រង់ចង្កាដែលទុកវែងដូចពុកចង្ការបស់ពពែ ហៅថា ពុកមាត់ដូចកញ្ចុំរោមគោ ។

បទថា ចតុរស្សកំ : ជា ៤ ជ្រុង បានដល់ តាក់តែងពុកមាត់ជា៤ជ្រុង ។

បទថា បរិមុខំ : ត្រង់ទ្រូង បានដល់ ធ្វើការប្រមូលផ្ដុំនៃរោមត្រង់ទ្រូង ។

បទថា អឌ្ឍុរុកំ : ត្រង់ពោះ បានដល់ ទុករោមត្រង់ពោះ ។

ពីរបទថា អាបត្តិ ទុក្កដស្ស : ត្រូវអាបត្តិទុក្កដ មានសេចក្ដីថា ជាអាបត្តិទុក្កដ ក្នុងទីទាំងពួងមានកាត់ពុកមាត់ជាដើម ។

[២៦១] ច្រើនបទថា អាពាធប្បច្ចយា សម្ពាធេ លោមំ សំហរាបេតុំ : មានអាពាធជាហេតុ ឱ្យគេដករោមក្នុងទីចង្អៀតបាន

មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យនាំរោមក្នុងទីបង្អៀតចេញ ព្រោះបច្ច័យ គឺ អាពាធមានឫសធំ និងតូចជាដើម ។

[២៦៣] ច្រើនបទថា អាពាធប្បច្ចយា កត្តរិកាយ កេសេ ឆេទាបេតុំ : មានអាពាធជាហេតុ ឱ្យគេកាត់សក់ដោយកន្ត្រៃបាន មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យកាត់សក់ដោយកន្ត្រៃ ព្រោះបច្ច័យ គឺ អាពាធដោយអំណាចនៃរោគត្រង់សីសៈ គឺឫសធំនិងតូច ។

[២៦៥] មិនមានអាបត្តិ ព្រោះដករោមច្រមុះដោយវត្ថុមានក្រួសជាដើម ចំណែកសណ្ឌាស ព្រះមានព្រះភាគទ្រង់អនុញ្ញាត ដើម្បីរក្សាខ្លួន ។

[២៦៦] វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ បលិតំ គាហាបេតព្វំ : ម្នាលភិក្ខុទាំងឡាយភិក្ខុមិនត្រូវឱ្យគេដកសក់ស្កូវទេ នេះ គប្បីជ្រាបដូច្នេះ ៖

រោមណាដុះឡើងត្រង់ចិញ្ចើម ឬត្រង់ថ្ងាស ឬត្រង់ពុកចង្កា ជារបស់គួរខ្ពើមដូច្នោះក៏ដោយ ទាំងស្កូវក៏ដោយ មិនស្កូវក៏ដោយ សមគួរដកចេញ ។

[២៦៩] បទថា កាំសបត្តរិកា : ពួកអ្នកឈ្នួញសំរិទ្ធ បានដល់ ឈ្នួញគ្រឿងសំរិទ្ធិ ។

[២៧០] បទថា ពន្ធនមត្តំ : នឹងកិច្ចសព្វបើគ្រាន់តែចង បានដល់ ត្រឹមតែចងនូវស្រោមនៃកាំបិត និងឈើប្រត់ជាដើម ។

# កាយពន្ធ

[២៧៣] វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ អកាយពន្ធនេន គាមោ បវិសិតព្វោ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានកាយពន្ធ មិនត្រូវចូលទៅកាន់ស្រុកទេ នេះ គប្បីជ្រាបដូច្នេះ ៖

កាយពន្ធ ដែលភិក្ខុមិនបានចងហើយចេញទៅ ខ្លួនរលឹកបានក្នុងទីណា គប្បីចងក្នុងទីនោះ, គិតថា "នឹងចងត្រង់អាសនៈសាលា" ដូច្នេះ នឹងទៅក៏គួរ ។ រលឹកបានហើយមិនគួរត្រាច់បិណ្ឌបាត រហូតដល់អស់វេលាដែលនៅមិនបានចង ។

[២៧៤] កាយពន្ធមានខ្សែច្រើន ឈ្មោះថា កលាពុកំ : ចម្រៀកច្រើន ។

កាយពន្ធស្រដៀងក្បាលពស់ទឹក ឈ្មោះថា ទេឌ្ឌុភកំ : ពស់ទឹក ។

កាយពន្ធ ដែលត្បាញធ្វើឱ្យមានសណ្ឋានមូល ដូចសម្ភោរ ឈ្មោះថា មុរជ្ជំ : ស្គរសម្ភោរ ។

កាយពន្ធ ដែលមានទ្រង់ទ្រាយ ដូចសង្វារ ឈ្មោះថា មទ្ទវីណំ : ខ្សែពិណ ។

ពិតមែន កាយពន្ធដូច្នេះ សូម្បីតែមួយប្រភេទ ក៏មិនគួរ ចាំបាច់ពោលទៅថ្វីដល់ច្រើនប្រភេទ ។

វិនិច្ឆ័យក្នុងពាក្យថា **បង្គិកំ សូករន្តកំ : កាយពន្ធធ្វើជាផ្ទាំង, កាយពន្ធដូចពោះវៀនជ្រូក,** នេះ គប្បីជ្រាបដូច្នេះ ៖

ផ្ទាំងកាយពន្ធដែលត្បាញតាមប្រក្រតី ឬក្រងជាឆ្អឹងត្រី រមែងគួរ ។

កាយពន្ធដ៏សេស មានប្រភេទកាយពន្ធដូចក្អែកដំរីជាដើម មិនគួរ ។

ដែលឈ្មោះថា កាយពន្ធចង្កេះពោះវៀនជ្រូក ជារបស់មានទ្រង់ទ្រាយដូចពោះវៀនជ្រូកនិងស្រោមកូនសោ ។ ចំណែកកាយពន្ធខ្សែមួយសរសៃ និងកាយពន្ធមូល អនុលោមតាមកាយពន្ធពោះវៀនជ្រូក ។

ពាក្យថា **"អនុជានាមិ ភិក្ខវេ មុរជំ មទ្ទវីណំ** : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតជាយ កាយពន្ធមានសណ្ឋាន ដូចខ្សែរឹតសំភោរ និងជាយកាយពន្ធ មានសណ្ឋានដូចសង្វារ" នេះ ទ្រង់អនុញ្ញាតត្រង់ជាយទាំង ២ ។ ក៏ក្នុងជាយមូល និងជាយដូចខ្សែសង្វារនេះ ជាយដូចខ្សែសង្វារលើសពី ៤ សរសៃ មិនគួរ ។

ការបត់ចូលហើយដេរត្រង់រឹមមាត់ ឈ្មោះថា **សោភកំ : ដេរលើន** ។

ការដេរដោយសណ្ឋានដូចវង់ចិញ្ចៀន ឈ្មោះថា គណាកំ[១] : ដេរជាចង្អោម ៗ ពិតមែន ជាយវត្ថុពួនចង្អេះដែលដេរយ៉ាងនោះ រមែងជារបស់ណែន ៗ

រួមចូលមកខាងក្នុងក្រវិល ហៅថា បវនន្តោ : ចុងអន្ទាក់ ៗ

## ការស្លៀកដណ្តប់

[២៧៩] ភិក្ខុស្លៀកធ្វើជាយឱ្យស្លុយចុះ មានសណ្ឋានដូចប្រមោយដំរី តាំងពីផ្ចិត ដូចការស្លៀករបស់ស្ត្រីចោឡប្រទេស ឈ្មោះថា ហត្ថិសោណ្ឌកំ : ស្លៀកដូចប្រមោយដំរី ៗ

ភិក្ខុស្លៀកឱ្យស្លុយចុងជាយម្ខាង ស្លុយដើមជាយម្ខាង ឈ្មោះថា មច្ឆវាឡកំ : ស្លៀកដូចកន្ទុយត្រី ៗ

ស្លៀកបញ្ចេញជាយជា ៤ ជ្រុង យ៉ាងនេះ គឺ ខាងលើ ២ជ្រុង ខាងក្រោម ២ជ្រុង ឈ្មោះថា ចតុក្កណ្ណកំ : ស្លៀកឱ្យមានជ្រុង ៤ ៗ

ការស្លៀកនូវសំពត់ស្លុយចុះទៅ ដោយអាការដូចធាងត្នោត ឈ្មោះថា តាលវណ្តកំ : ស្លៀកដូចធាងត្នោត ៗ

---
១. ឱ. ម. គុណកំ ៗ

ភិក្ខុស្លៀកសាជកវែងបត់ឱ្យជាផ្នត់ ៗច្រើនត្រង់ជាយក្តី ស្លៀកឱ្យឃើញស្រទាប់អន្ទាញ់ ៗច្រើន ត្រង់ខាងឆ្វេងនិងខាងស្តាំក្តី ឈ្មោះថា សតវលិកំ : ស្លៀកអន្ទាញ់ឱ្យមានផ្នត់ច្រើន ។ តែបើថា ស្លៀកឱ្យប្រាកដត្រឹមតែមួយផ្នត់ ឬ ពីរផ្នត់ តាំងពីជង្គង់ឡើងទៅ រមែងគួរ ។

[២៨១] ពីរបទថា សំវេល្លិយំ និវាសេន្តិ : ស្លៀកចងក្បិន មានសេចក្តីថា ភិក្ខុឆព្វគ្គិយស្លៀកចងក្បិន ដូចអ្នកប្រដាល់និងកម្មករជាដើម ។ ការស្លៀកចងក្បិននោះ រមែងមិនគួរដល់ភិក្ខុអាពាធ និងភិក្ខុធ្វើដំណើរ ។

ភិក្ខុទាំងឡាយដែលកំពុងធ្វើដំណើរ លើកជាយម្ខាង ឬ ពីរខាងឡើងសៀតលើស្បង់ ឬស្លៀកសំពត់កាសាវៈមួយផ្ទាំង យ៉ាងនោះ ទុកខាងក្នុងហើយ ស្លៀកមួយផ្ទាំងទៀត សង្កត់ខាងក្រៅ សូម្បីយ៉ាងណា ការស្លៀកដណ្តប់បែបនោះ មិនគួរទាំងអស់ ។

ចំណែកភិក្ខុដែលអាពាធ បញ្ចេញនូវជាយសំពត់កាសាវៈខាងក្នុង ហើយស្លៀកមួយផ្ទាំងទៀត សង្កត់ខាងក្រៅ ក៏បាន ។

ភិក្ខុដែលមិនអាពាធ កាលនឹងស្លៀកសំពត់ ២ ផ្ទាំង គប្បីស្លៀកត្រួតចូលគ្នាជា ២ ជាន់ ។ ដោយប្រការយ៉ាងនេះ គប្បីវៀរការស្លៀកទាំងពួង ដែលព្រះមានព្រះភាគ ទ្រង់ហាមក្នុងខុទ្ទកវត្ថុក្ខន្ធកៈនេះ ដែល

ព្រះអដ្ឋកថាចារ្យហាមក្នុងសេក្ខិយវណ្ណនា បិទបាំងឱ្យបានមណ្ឌល ៣ ប្រាសចាកវិការ ស្លៀកឱ្យរៀបរយ ។ កាលភិក្ខុធ្វើវិការប្លែកយ៉ាងណាមួយ មិនផុតពីទុក្កដ ។

ការដែលមិនដណ្ដប់ ដូចការដណ្ដប់របស់គ្រហស្ថដែលទ្រង់ហាមទុកយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដណ្ដប់ដូចពួកគ្រហស្ថទេ" ដូច្នេះ ដណ្ដប់ចាប់មុំទាំង ២ ឱ្យស្មើគ្នា ឈ្មោះថា ដណ្ដប់រៀបរយ ។ ការដណ្ដប់រៀបរយនោះ ដែលភិក្ខុគប្បីដណ្ដប់ ។

ក្នុងការដណ្ដប់ដូចគ្រហស្ថ និងការដណ្ដប់រៀបរយនោះ ការដណ្ដប់យ៉ាងណាមួយ ដែលដណ្ដប់ហើយដោយប្រការដទៃ អំពីលក្ខណៈដែលរៀបរយ មានជាដើមយ៉ាងនេះ គឺ ដណ្ដប់សំពត់ស ដណ្ដប់ដូចបរិព្វាជក ដូចអ្នកដែលប្រើសំពត់ផ្ទាំងតែមួយ ដណ្ដប់ដូចអ្នកលេង ដណ្ដប់ដូចអ្នកនៅក្នុងវាំង ដណ្ដប់ឃ្លុំទាំងខ្លួន ដូចគហបតីជាធំ ដណ្ដប់ដូចអ្នកស្រែចូលខ្ទម ដណ្ដប់ដូចព្រាហ្មណ៍ ដណ្ដប់ដូចភិក្ខុអ្នករៀបជួរ ការដណ្ដប់នេះទាំងអស់ ឈ្មោះថា ដណ្ដប់ដូចគ្រហស្ថ ។ ព្រោះហេតុនោះ និគ្រន្ថទាំងឡាយប្រើសំពត់ស ដណ្ដប់ពាក់កណ្ដាលកាយ រមែងដណ្ដប់យ៉ាងណា, មួយទៀត បរិព្វាជកពួកខ្លះ បើកទ្រូងពាក់សំពត់ដណ្ដប់ទុកលើចង្កួយស្មាទាំង ២ យ៉ាងណា, មួយទៀត មនុស្សទាំងឡាយដែលប្រើ

សំពត់តែមួយផ្ទាំង យកជាយសំពត់ម្ខាង ដណ្តប់ខ្នង ពាក់មុំទាំង ២ លើចង្កេះទាំង ២ យ៉ាងណា, មួយទៀត ពួកអ្នកលេងសុរាជាដើម យកសំពត់រុំក ព្យួរជាយទាំង ២ ចុះទៅលើទ្រូងខ្លះ ក្រវាត់ទុកលើខ្នងខ្លះ យ៉ាងណា, មួយទៀត ស្រ្តីក្នុងវាំងជាដើម ដណ្តប់គ្របក្បាល បើកតែប្រឡោះភ្នែកទុក យ៉ាងណា, មួយទៀត គហបតីអ្នកជាធំទាំងឡាយ ស្លៀកសំពត់វែងរុំខ្លួនទាំងអស់ ដោយជាយ ម្ខាងនៃជាយសំពត់នោះឯង យ៉ាងណា, មួយទៀត ពួកអ្នកស្រែ កាលនឹងចូលកាន់ខុមស្រែ ដណ្តប់សំពត់គ្រវាត់ចូលទៅក្នុងក្លៀកហើយរុំខ្លួន ដោយជាយម្ខាងនៃសំពត់នោះឯង យ៉ាងណា, មួយទៀត ពួកព្រាហ្មណ៍ស៊កសំពត់ទៅតាមក្លៀកទាំង ២ ហើយ វាត់ទុកលើទីនចង្កេះទាំង ២ យ៉ាងណា, មួយទៀត ភិក្ខុអ្នករៀបជួរ បើកដើមដៃឆ្វេងដែលដណ្តប់ដោយសំពត់ដណ្តប់ឆៀងស្មា លើកចីវរឡើងពាក់លើចង្កេះ យ៉ាងណា; ភិក្ខុមិនគប្បីដណ្តប់ដូច្នោះឡើយ គប្បីវៀរទោសនៃការដណ្តប់ទាំងអស់នោះ និងទោសនៃការដណ្តប់បែបទាំងឡាយនោះដទៃចេញ ដណ្តប់ឱ្យជាបរិមណ្ឌលប្រាសចាកអំពីវិការ ។

កាលភិក្ខុមិនដណ្តប់យ៉ាងនោះ ធ្វើវិការយ៉ាងណាមួយ ដោយមិនអើពើ ក្នុងវត្តក៏ដោយ ក្នុងចន្លោះស្រុកក៏ដោយ រមែងត្រូវអាបត្តិទុក្កដ ។

# អម្រែកជាដើម

[២៨២] បទថា មុណ្ឌវដ្ដី : អ្នកនាំគ្រឿងបរិក្ខារ មានអធិប្បាយថា ដូចអ្នកកែរបស់សម្រាប់ប្រើប្រាស់ របស់ព្រះរាជាជាស្ដេចទៅក្នុងទីណា ៗ ។

បទថា អន្តរាកាជំ : សែង បានដល់ ភារៈដែលគប្បីពាក់ទុកនៅកណ្ដាលឈើស្នែង ហើយសែងទៅ ២ នាក់ ។

[២៨៣] បទថា អចក្ខុស្សំ : នាំឱ្យថយកម្លាំងភ្នែក សេចក្ដីថា មិនជាប្រយោជន៍ដល់ភ្នែកទាំងឡាយ គឺថា ញ៉ាំងសេចក្ដីវិនាសឱ្យកើតឡើងដល់ភិក្ខុ ។

បទថា ន ឆាទេតិ : ឆាន់មិនឆ្ងាញ់ បានដល់ មិនពេញចិត្ត ។

[២៨៤] បទថា អដ្ឋង្គុលបរមំ : យ៉ាងវែងត្រឹម ៨ ធ្នាប់ បានដល់ ឈើស្ទន់វែង មានប្រវែងត្រឹម ៨ ធ្នាប់ ដោយធ្នាប់របស់មនុស្សទាំងឡាយ ។

[២៨៥] បទថា អតិមដ្ឋាហកំ : ខ្លីពេក បានដល់ ឈើស្ទន់ដែលតូចពេក ។

# ការដុតភ្លើង

[២៨៦] ពីរបទថា ទាយំ អាឡេបេន្តិ : ដុតព្រៃ មានសេចក្តីថា ភិក្ខុឆព្វគ្គិយដុតភ្លើងត្រង់ព្រៃស្មៅជាដើម ។

[២៨៧] បទថា បដគ្គឹ : ភ្លើងតទល់ មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុដុតភ្លើងទទួល ។

បទថា បរិត្តំ : សេចក្តីការពារ មានសេចក្តីថា តថាគតអនុញ្ញាតឱ្យការពារបាន, ដោយការធ្វើឱ្យប្រាសចាកវត្ថុខៀវ ឬដោយការជីកប្រឡាយ ។ តែក្នុងរឿងការពារនេះ កាលមានអនុបសម្បន្ន ភិក្ខុដុតភ្លើងខ្លួនឯង រមែងមិនបាន ។

កាលមិនមានអនុបសម្បន្ន ភិក្ខុនឹងដុតភ្លើងខ្លួនឯងក្តី ជម្រះផែនដីនាំស្មៅចេញក្តី ជីកប្រឡាយក្តី កាប់មែកឈើស្រស់ ពន្លត់ ភ្លើងក្តី រមែងបាន ។

ភ្លើងឆេះដល់សេនាសនៈហើយក្តី មិនទាន់ដល់ក្តី ភិក្ខុរមែងបានដើម្បីញ៉ាំងភ្លើងឱ្យរលត់ដោយឧបាយយ៉ាងនោះឯង ។

តែកាលនឹងឱ្យភ្លើងរលត់ដោយទឹក រមែងបានដើម្បីពន្លត់ដោយទឹកដែលគួរប៉ុណ្ណោះ ក្រៅពីនោះមិនបាន ។

# ការឡើងដើមឈើ

[២៨៩] ពាក្យថា សតិ ករណីយេ **: កាលបើមានកិច្ចគួរធ្វើ** មានសេចក្ដីថា កាលមាន កិច្ចដែលនឹងត្រូវកាន់យកអុសស្ងួតជាដើម ។

បទថា បោរិសិយំ **: បានត្រឹមមួយជួរបុរស** សេចក្ដីថា អនុញ្ញាតឲ្យភិក្ខុឡើងដើមឈើប្រមាណមួយជំហរបុរស ។

ពាក្យថា អាបទាសុ **: បើមានអន្តរាយ** មានសេចក្ដីថា ភិក្ខុឃើញអន្តរាយ មានសត្វសាហាវជាដើម ឬជាអ្នកវង្វេងមក ឬជាអ្នកប្រាថ្នារកមើល ទិស ឬឃើញភ្លើងឆេះព្រៃភាលមក ឬឃើញទឹកជំនន់ហូរមក ព្រោះអន្តរាយបែបនេះ នឹងឡើងដើមឈើសូម្បីខ្ពស់ហួសប្រមាណក៏គួរ ។

# គម្ពីរលោកាយតៈ

[២៩០] បទថា កល្យាណវាក្ករណោ : មានសំឡេងល្អ បាន ដល់ ជាអ្នកមានសំឡេងពីរោះ ។

ពីរបទថា ឆន្ទសោ អារោបេម : សូមលើកតាមឆន្ទៈ មានសេចក្តីថា ខ្ញុំព្រះអង្គ នឹងលើកព្រះពុទ្ធវចនៈឡើងកាន់មកនៃការពោលដោយភាសាសំស្រ្កិត ដូចវេទ[១] ។

វោហាររបស់អ្នកមគធ មានសេចក្តីដូចដែលព្រះសម្មាសម្ពុទ្ធត្រាស់ហើយ ឈ្មោះថា ភាសាខ្លួន ក្នុងពាក្យថា សកាយ និរុត្តិយា : តាមសកភាសា ( គឺមគធភាសា ) នេះ ។

គម្ពីរតិរ្ឆិយ ដែលប្រកបដោយហេតុឥតប្រយោជន៍ មានជាដើមយ៉ាងនេះថា វត្ថុទាំងពួងជាសំណល់ ព្រោះហេតុនេះ វត្ថុទាំងពួងមិនជាសំណល់ ព្រោះហេតុនេះ ក្អែកស[២] ព្រោះហេតុនេះ, សត្វក្តុកខ្មៅ[៣] ព្រោះ

១. គឺ តែងជាកាព្យឃ្លោងជាសាកលដូចគម្ពីរវេទរបស់ព្រាហ្មណ៍ ។

២_៣. វិនយាលង្ការដីកាថា ក្អែកស ព្រោះឆ្អឹងស, កុកខ្មៅ ព្រោះជើងខ្មៅ, បាចិត្តិយទិថា កុកក្រហម ព្រោះឈាមក្រហម ។
ហេតុនេះ ដូច្នេះ ឈ្មោះគម្ពីរលោកយតៈ (ដែលជាប់ដោយលោក) ។

[២៩៥] ពីរបទថា អន្តរា អហោសិ : ក៏ដាច់ពាក់កណ្តាល មានសេចក្តីថា ធម្មកថា បានជារឿងដាច់វគ្គ គឺ បានត្រូវសំឡេងនោះលុបចេញ ។

[២៩៨] បទថា អាពាធប្បច្ចយា : បើមានអាពាធជាហេតុ មានសេចក្តីថា ខ្ញុំមជាថ្នាំដើម្បីរម្ងាប់អាពាធណា អាពាធនោះ ជាហេតុ ។

[២៩៩] វិនិច្ឆ័យក្នុងពាក្យថា បស្សាវបាទុកំ : ទ្រនាប់ជើងសម្រាប់បន្ទោបង់បស្សាវៈ នេះ គប្បីជ្រាប ដូច្នេះ ៖

ទ្រនាប់ជាន់ដែលធ្វើដោយឥដ្ឋក្តី ដោយថ្មក្តី ដោយឈើក្តី គួរ ។

សូម្បីក្នុងវច្ចបាទុកា : ទ្រនាប់ជើងសម្រាប់បន្ទោបង់វច្ចៈ ក៏មានន័យដូចគ្នា ។

[៣០៤] បទថា បរិវេណំ : ទីលាន បានដល់ ទីខាងក្នុងនៃរបងលោមព័ទ្ធរបស់វច្ចកុដិ ។

[៣០៥] ពាក្យថា យថាធម្មោ ការេតព្វោ : វិន័យធរគប្បីឱ្យ

ភិក្ខុនោះធ្វើតាមធម៌ មានសេចក្តីថា ក្នុងវត្ថុនៃទុក្កដ គប្បីពិន័យទុក្កដ ក្នុងវត្ថុនៃបាចិត្តិយ គប្បីពិន័យបាចិត្តិយ ។

## លោហភណ្ឌៈជាដើម

[៣០៦] លោហភ័ណ្ឌដែលគេធ្វើទុក ដើម្បីប្រហារ ហៅថា បហរណិ : គ្រឿងប្រហារ ។

សេចក្តីថា ពាក្យថា គ្រឿងប្រហារនោះ ជាឈ្មោះរបស់វត្ថុដែលរាប់ថា អាវុធប្រភេទណាមួយ, តថាគតអនុញ្ញាតគ្រឿងលោហៈទាំងពួងវៀរលែងតែលោហៈដែលជាគ្រឿងប្រហារ ។

ក្នុងពាក្យថា កតកញ្ច កុម្ភការិកញ្ច : គ្រឿងជូតជើងដែលគេធ្វើជាពកឱ្យស្រួច ៗឡើងមានអាការដូចពកគ្រាប់ផ្លែឈូក និងកុដិធ្វើដោយដីសុទ្ធ នេះ មានវិនិច្ឆ័យថា ៖

គ្រឿងជូតជើងនោះ បានពោលទុកហើយ[១] ។

កុដិធ្វើដោយដីសុទ្ធ ដូចកុដិរបស់ព្រះធនិយៈ ហៅថា កុម្ភការិកា ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

ខុទ្ទកវត្ថុខន្ធកវណ្ណនា ចប់

១. ក្នុងទំព័រ ១៤៨ ។

# ១៦. សេនាសនក្ខន្ធកវណ្ណនា

## វិនិច្ឆ័យក្នុងសេនាសនក្ខន្ធកៈ

វិនិច្ឆ័យក្នុងសេនាសនក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

[៣០៩] ពាក្យថា សេនាសនៈជារបស់ដែលទ្រង់មិនទាន់បានបញ្ញត្តិ បានដល់ ជារបស់មិនទាន់បានអនុញ្ញាត ។

[៣១០] ទីលំនៅដ៏សេស ផុតពីផ្ទះប្រក់ជុំបូលតែមួយ ជាដើមទៅ ឈ្មោះថា វិហារ ។

អឌ្ឍយោគ គឺ ផ្ទះប្រក់ជុំបូលតែមួយនោះ បានដល់ ផ្ទះដែលកោងដូចស្លាបគ្រុឌ ។

ប្រាសាទនោះ បានដល់ ប្រាសាទវែង ។

ហម្មិយៈ គឺ ផ្ទះត្រងិលនោះ បានដល់ ប្រាសាទទុំះឯង តែមានផ្ទះកំពូលតាំងនៅលើផ្ទៃអាកាស ។

គុហា គឺ ល្អាង នោះ បានដល់ ល្អាងឥដ្ឋ ល្អាងថ្ម ល្អាងឈើ ល្អាងដី ។

[៣១២] ពាក្យថា ដើម្បីសង្ឃទាំង ៤ ទិសដែលមកហើយ និងមិនទាន់មក គឺ ដើម្បីសង្ឃដែលនៅក្នុងទិសទាំង៤ ទាំងដែលមកហើយ

ទាំងដែលមិនទាន់បានមក ។

# វិហារទាន

[៣១៣] វិនិច្ឆ័យក្នុងអនុមោទនាគាថា គប្បីជ្រាបដូច្នេះ ៖

ពីរបទថា សីតំ ឧណ្ហំ : រងា ក្តៅ ព្រះមានព្រះភាគត្រាស់ដោយអំណាចវជ្ជវផ្ទុយគ្នា ។

ខ្យល់លាយតំណក់ទឹក លោកហៅថា ខ្យល់ក្នុងសិសិរវដូវ ក្នុងពាក្យនេះថា សិសិរេ ចាបិ វុដ្ឋិយោ : ត្រជាក់ទាំងឡាយផង គ្រប់ភ្លៀងទាំងឡាយផង ។

ភ្លៀងនោះ គឺ ភ្លៀងដែលកើតពីពពកដោយត្រង់ទុំះឯង ។ បទទាំងអស់នេះ គប្បីប្រកបទឹងបទនេះថា បដិហន្តិ : រមែងការពារ ។

បទថា បដិហញ្ញតិ : រមែងបាត់ទៅវិញ បានដល់ ខ្យល់និងកំដៅថ្ងៃដែលវិហារ រមែងការពារ ។

បទថា លេណត្ថំ : ដើម្បីជាទីជ្រកកោន គឺដើម្បីនៅពួនសម្ងំ ។

បទថា សុខត្ថំ : ដើម្បីនៅជាសុខ គឺ ដើម្បីការនៅសប្បាយព្រោះមិនមានអន្តរាយ មានត្រជាក់ជាដើម ។

ពីរបទថា ឈាយិតុញ្ច វិបស្សិតុំ : ដើម្បីចម្រើនវិបស្សនាផង គប្បីប្រកបនឹងបទនេះថា សុខត្ថញ្ច ។

ពិតមែន លោកពោលពាក្យអធិប្បាយដូច្នេះ ៖

ការថ្វាយវិហារ ដើម្បីសេចក្តីសុខ ការថ្វាយវិហារដើម្បីសេចក្តីសុខ ដូចម្តេច ? សេចក្តីសុខណា មានដើម្បីសម្លឹងពិនិត្យ និងដើម្បីឃើញច្បាស់, ការថ្វាយវិហារដើម្បីសេចក្តីសុខនោះ ។

មួយទៀត ពីរបទថា ឈាយិតុញ្ច វិបស្សិតុំ នេះ គប្បីប្រកបនឹងបទក្រោយថា ថ្វាយវិហារដើម្បីសម្លឹងពិនិត្យ និងដើម្បីឃើញច្បាស់ ។

ការថ្វាយវិហារដល់សង្ឃ របស់ទាយកអ្នកថ្វាយដោយតាំងចិត្តថា "ភិក្ខុទាំងឡាយនឹងសម្លឹងពិនិត្យ នឹងឃើញច្បាស់ ក្នុងកុដិនេះ លោកអ្នកឈ្លាសទាំងឡាយ សរសើរថា (ជាទាន)ដ៏ប្រសើរ" ។ ពិតមែន ព្រះមានព្រះភាគបានត្រាស់ពាក្យនេះថា "បុគ្គលណាឱ្យទីនៅអាស្រ័យ បុគ្គលនោះ ឈ្មោះថា ឱ្យវត្ថុគ្រប់យ៉ាង"[១] ។

ពិតមែន ការថ្វាយវិហារ លោកអ្នកប្រាជ្ញទាំងឡាយសរសើរថា "ដ៏ប្រសើរ" ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់គាថាព័ន្ធថា "តស្មា ហិ បណ្ឌិតោ បោសោ : ព្រោះហេតុនោះឯង បុរស

១. សំយុ. សគា. កិន្ទទសូត្រ. ២៩. ១៤០/៨០ ។

(ស្ត្រី )ជាបណ្ឌិត” ។

ពាក្យថា វាសយេត្ត ពហុស្សុតេ : ហើយគួរនិមន្តលោកដែលជាពហុស្សូត មានសេចក្តីថា គប្បីនិមន្តភិក្ខុទាំងឡាយ ដែលជាពហុស្សូតដោយការសិក្សា និងជាពហូស្សូតដោយសេចក្តីត្រាស់ដឹង ឱ្យនៅក្នុងវិហារនេះ ។

ច្រើនបទថា តេសំ អន្នញ្ច : លោកទាំងឡាយ (ដែលមានចិត្តត្រង់ ហើយប្រគេន) បាយ ជាដើម មានសេចក្តីថា បាយ ទឹក សំពត់ និងសេនាសនៈ មានគ្រែតាំងជាដើមយ៉ាងណា សមគួរដល់ភិក្ខុទាំងនោះ, គប្បីប្រគេនបច្ច័យទាំងពួងនោះ ភិក្ខុទាំងនោះ អ្នកស្មោះត្រង់ គឺ មានចិត្តមិនកោងកាច ។

បទថា ទទេយ្យ : ហើយប្រគេន គឺ គប្បីប្រគល់ ។

ក៏គប្បីប្រគល់បច្ច័យនោះ ដោយចិត្តជ្រះថ្លា មិនញ៉ាំងសេចក្តីជ្រះថ្លានៃចិត្តឱ្យបាត់បង់ទៅ ។ ពិតមែន ទាយកនោះ នឹងដឹងទូទៅដល់ធម៌ណា ក្នុងព្រះសាសនានេះហើយ ជាអ្នកមិនមានអាសវៈ បរិព្វាន ភិក្ខុជាពហូស្សូតទាំងនោះ រមែងសម្តែងធម៌នោះ ដែលជាគ្រឿងបន្ទោបង់ទុក្ខ

ទាំងពួង ដល់ទាយកអ្នកមានចិត្តថ្លាផូវ ផង់យ៉ាងនេះ ដូច្នេះឯង ។

# ខ្សែទាញជាដើម

[៣១៤] វិនិច្ឆ័យក្នុងពាក្យថា អាវិញ្ឆនច្ឆិទ្ទំ អាវិញ្ឆនរជ្ជុំ : ក្របទ្វារដំណាប់ក្រោមនិងដំណាប់លើ នេះ មានសេចក្តីថា ដែលឈ្មោះថា ខ្សែ សូម្បីបើជារបស់ដែលធ្វើដោយកន្ទុយខ្លា គួរពិត ។ ខ្សែយ៉ាងណាមួយមិនគួរ ក៏ទេ ។

[៣១៥] សោ ៣ ប្រភេទនោះ បានដល់ កូនសោ ៣ យ៉ាង ។

វិនិច្ឆ័យក្នុងពាក្យថា យន្តកំ សូចិកំ : គ្រឿងយន្ត និងគន្លឹះនេះថា ភិក្ខុគួរធ្វើកូនសោយន្តដែលខ្លួនស្គាល់ និងកូនសោសម្រាប់ចាក់សោយន្តនោះ ។

[៣១៦] ដែលឈ្មោះថា វេទិកាវាតបាន់ : បង្អួចមានវេទី បានដល់ បង្អួចស្តូចខាងលើ ស្រដៀងវេទីនៃចេតិយ ដែលឈ្មោះថា ជាលវាតបាន់ បង្អួចក្រឡាសំណាញ់ បានដល់ បង្អួច ដែលបិទដោយសំណាញ់ ។

ដែលឈ្មោះថា សលាកវាតបាន់ : បង្អួចមានឈើចំរឹង បាន

ដល់ បង្អួចចម្រឹង ។

ក្នុងពាក្យថា ចក្កលិកំ : នៅំងបង្អួច នេះ មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យចងសំពត់តូច ៗ ដូចសំពត់ជូតជើង ។

ពាក្យថា វាតបានភិសិកំ : នៅំងពូកបង្អួច មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យធ្វើកន្ទេល បានខ្ទាតប៉ុនបង្អួចចងទុក ។

## គ្រែនិងតាំង

[៣១៨] បទថា មិឌ្ឍី : បន្ទះក្តារសម្រាប់ដេក បានដល់ ក្តារតាំង ។

បទថា វិធលមញ្ចកំ បានដល់ វេត្តមញ្ចំ : គ្រែផ្តៅ គឺ គ្រែដែលត្បាញអំពីផ្តៅ ឬគ្រែដែលត្បាញ ដោយបន្ទះឫស្សី ។

[៣២៣] តាំង ៤ ជ្រុង ហៅថា អាសន្ទិកោ : អាសន្ទិកៈ ។

ពិតមែន តាំងវែងតែមួយផ្នែកប៉ុណ្ណោះ មានជើង ៨ ធ្នាប់ ទើបគួរ, ចំណែកតាំង ៤ ជ្រុង គប្បីជ្រាបថា សូម្បីលើសប្រមាណក៏គួរ ព្រោះព្រះបាលីថា "អនុជានាមិ ភិក្ខវេ ឧច្ចកម្បិ អាសន្ទិកំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតតាំង ៤ ជ្រុង សូម្បីមានជើងខ្ពស់" ។

សត្តង្គោ នាម : ដែលឈ្មោះថា គ្រែមានអង្គ ៧ បានដល់ គ្រែដែលធ្វើបង្អែកភ្នាក់ដៃ ៣ ខាង ។ សត្តង្គៈនេះ សូម្បីលើស ប្រមាណក៏គួរ ។

ភទ្ទបីឋំ : តាំងចាក់ផ្ដៅ គឺ តាំងដែលធ្វើសម្រេចដោយផ្ដៅសុទ្ធ ។

បីឋិកា : តាំងសំពត់ គឺ ចំពោះតាំងដែលចងលាតសន្ធឹង ដោយសំពត់ចាស់ ។

ឯឡកបាទបីឋំ នាម : ដែលឈ្មោះថា តាំងមានជើងដូចជើង ពពែ តាំងដែលជាប់ជើងលើឈើទ្រ ធ្វើស្រដៀងតុដាក់បាយបរិភោគ ។

អាមលកវដ្តកបីឋំ នាម : ដែលឈ្មោះថា តាំងដូចផ្លែកន្ទួត ព្រៃ តាំងមានជើងច្រើន ប្រកបទុកដោយអាការដូចផ្លែកន្ទួតព្រៃ ។

តាំងដែលមកក្នុងព្រះបាលីប៉ុណ្ណេះ ចំណែកតាំងឈើគួរទាំងអស់ វិនិច្ឆ័យក្នុងអធិការពោលអំពីតាំងនេះ ប៉ុណ្ណេះ ។ តាំងដែលធ្វើដោយ ស្បូវ ឬដោយស្មៅយ៉ាប្លង ឬដោយស្មៅ ដំណេកទន្សាយ ហៅថា កៅអី ។

[៣២៦] ក្នុងពាក្យថា អដ្ឋង្គុលបរមំ មញ្ចបដិបាទកំ : ទ្រនាប់គ្រែយ៉ាងខ្ពស់ ត្រឹម ៨ ធ្នាប់ នេះ ពាក្យថា ៨ ធ្នាប់ គឺ ខ្នាត

ធ្លាប់របស់ពួកមនុស្សទុំះឯង ។

## កម្រាលផែនដីនិងសំឡីជាដើម

[៣២៧] ដែលឈ្មោះថា **ចិមិលិកា** : សំពត់ទ្រនាប់ គឺកម្រាលដើម្បីត្រូវការរក្សាពណ៌នៃផែនដីដែលធ្វើបរិកម្ម ។

សំឡីនៃដើមឈើនោះ បានដល់ សំឡីនៃដើមឈើពួកណាមួយ មានដើមរកាជាដើម ។

សំឡីនៃវល្លិនោះ បានដល់ សំឡីនៃវល្លិពួកណាមួយ មានវល្លិទឹកដោះជាដើម ។

សំឡីនៃស្មៅនោះ បានដល់ សំឡីនៃតិណជាតិពួកណាមួយ មានសំឡី ស្មៅ( ស្បូវ )ជាដើម ដោយហោចទៅ សូម្បីសំឡីនៃអំពៅ និងបបុសជាដើម ។ ភូតគាមទាំងពួង ជាការដែលព្រះមានព្រះភាគ ទ្រង់រួមចូលដោយដើមឈើ វល្លិ និងស្មៅ ទាំង ៣ ប្រភេទនេះ ។ ពិតមែនដែលឈ្មោះថា ភូតគាមដទៃ ដែលផុតពីរុក្ខជាតិ វល្លិជាតិ និងតិណជាតិទៅ រមែងមិនមាន ។ ព្រោះដូច្នោះ សំឡីនៃភូតគាមប្រភេទណាមួយ រមែងគួរក្នុងការធ្វើខ្នើយ ។

តែគ្រាមកដល់ពួកសំឡីនោះ សូម្បីគ្រប់ប្រភេទ លោកពោលថា

ជាសំឡីដែលមិនគួរ ។ និងគួរក្នុងការធ្វើខ្នើយ ចំពោះសំឡីនោះ តែម្យ៉ាងក៏ទេ, សូម្បីរោមនៃសត្វគ្រប់ប្រភេទ មានហង្ស និងក្ងោកជាដើម សត្វជើង ៤ គ្រប់ប្រភេទ មានសីហៈជាដើម ក៏គួរ ។

តែផ្កាឈើប្រភេទណាមួយ មានផ្កាប្រយង្គនិងផ្កាពិកុលជាដើម មិនគួរ ។ ចំពោះស្លឹកតមាល[១]សុទ្ធ ៗ តែម្តង មិនគួរ, តែលាយ គួរ សូម្បីសំឡីគឺរោមសត្វជាដើម ៥ យ៉ាង ដែលទ្រង់អនុញ្ញាត សម្រាប់ពូក ក៏គួរក្នុងការធ្វើខ្នើយ ។

## ខ្នើយ

[៣២៨] ក្នុងកុរុន្ទីពោលថា បទថា អឌ្ឍកាយិកានិ[២] : **ខ្នើយពាក់កណ្តាលកាយ** មានសេចក្តីថា ជនទាំងឡាយ រមែងសណ្តូកត្រឹមពាក់កណ្តាលកាយ តាំងពីចង្កេះដល់ ក្បាលលើខ្នើយពួកណា ខ្នើយទាំងនោះ ឈ្មោះថា មានប្រមាណពាក់កណ្តាលកាយ ។ ខ្នើយដែលចាត់ថា ប្រមាណត្រឹមក្បាល គឺ ផ្នែកទទឹង កាលវាស់ក្នុងចន្លោះមុំទាំង ២ វៀរមុំមួយចេញក្នុងបណ្តាមុំ ៣ បាន ១ ចំអាម នឹង ៤ ធ្នាប់ ត្រង់កណ្តាលបាន ១ ហត្ថក្តាប់ ។ ចំណែកផ្នែកបណ្តោយ ប្រវែង១ហត្ថ ១ចំអាម ឬ ២ ហត្ថ ។

១. អភិធានប្បទីបិកា : ឈើនេះស្លឹកវាពណ៌ក្រហមក្រមៅ ច្រើនដុះនៅតាមមាត់សមុទ្រ ។ ២. ភូមា. អន្ទកាយិកានិ ។

នេះជាកំណត់យ៉ាងខ្ពស់នៃខ្នើយដែលមានខ្នាតប៉ុនក្បាល ។ ធំលើសពី កំណត់នេះឡើងទៅមិនគួរ ។ តូចចុះមកគួរ ។

ខ្នើយ ២ ប្រភេទ គឺ ខ្នើយកើយក្បាល និងខ្នើយកល់ជើង គួរដល់ភិក្ខុដែលមិនអាពាធពិត ។ ភិក្ខុដែលអាពាធនឹងដាក់ខ្នើយច្រើនហើយក្រាលកម្រាលខាងលើសិនសឹមសឹង ក៏គួរ ។

មួយទៀត ព្រះបុស្សទេវត្ថេរះពោលថា សំឡីដែលជាកប្បិយ ៥ យ៉ាង សំឡីពួកណាដែលទ្រង់អនុញ្ញាតសម្រាប់ពូកទាំងឡាយ, ខ្នើយដែលធ្វើដោយសំឡីពួកនោះ សូម្បីធំ ក៏គួរ ។

ចំណែកព្រះឧបតិស្សត្ថេរះជាព្រះវិន័យធរពោលថា ប្រមាណទុំះឯង គួរដល់ភិក្ខុដែលញាត់សំឡីជាកប្បិយ ឬសំឡីជាអកប្បិយដោយគិតថា "នឹងធ្វើខ្នើយ" ។

## ពូក

[៣២៩] ពូក ៥ យ៉ាងនោះ បានដល់ ពូកដែលញាត់ដោយរបស់ ៥ យ៉ាង មានរោមសត្វជាដើម ។

ពិតមែន ព្រះមានព្រះភាគត្រាស់ចំនួននៃពូកទាំងនេះ តាមចំនួននៃ

សំឡី ។

បណ្ដាសំឡីទាំងនោះ រោមចៀមតែម៉្យាងប៉ុណ្ណោះ មិនបានទ្រង់កាន់យកដោយឧណ្ណស័ព្ទ, ប៉ុន្ដែថា វៀររោមមនុស្សចេញហើយ រោមបក្សីនិងសត្វជើង ៤ ដែលជាជាតិមានសាច់ ជាកប្បិយនិងអកប្បិយប្រភេទណាមួយ, រោមទាំងអស់នោះ ទ្រង់កាន់យកក្នុងអធិការពោលអំពីពូកនេះ ដោយឧណ្ណស័ព្ទទាំងនោះ ។

ព្រោះដូច្នោះ បណ្ដាចីវរ ៦ ប្រភេទ និងអនុលោមចីវរ ៦ ប្រភេទ ភិក្ខុធ្វើស្រោមពូកប្រភេទណាមួយហើយ ញាត់រោមសត្វគ្រប់យ៉ាងនោះធ្វើជាពូក ក៏គួរ ។

មួយទៀត សូម្បីពូកដែលភិក្ខុមិនបានញាត់រោមចៀម ដាក់តែសំពត់កម្ពល ៤ ជាន់ឬ ៥ ជាន់ រមែងដល់សេចក្ដីរាប់ថា ពូករោមសត្វដូចគ្នា ។

បណ្ដាពូកទាំងឡាយ មានចោឡភិសិជាដើម ពូកដែលគេរួបរួមប្រមូលសំណល់សំពត់ថ្មី ឬសំណល់សំពត់ចាស់យ៉ាងណាមួយប្រកចូល ឬញាត់ចូលខាងក្នុងឈ្មោះថា ចោឡភិសិ ។ ពូកដែលញាត់សំបកឈើប្រភេទណាមួយ ឈ្មោះថា វាកភិសិ ។ ពូកដែលញាត់ស្មៅប្រភេទណាមួយ ឈ្មោះថា តិណភិសិ ។ ពូកដែលញាត់ស្លឹកឈើប្រភេទណាមួយ ក្រៅអំពីស្លឹកតមាលសុទ្ធ គប្បីជ្រាបថា បណ្ណភិសិ ។

ចំណែកស្លឹកតមាល ដែលលាយជាមួយនឹងស្លឹកឈើដទៃ ទើបគួរ ។ ស្លឹកតមាលសុទ្ធមិនគួរ ។ សម្រាប់ពូក មិនមានកំណត់ប្រមាណ ។ គប្បីប៉ាន់ប្រមាណតាមសេចក្ដីពេញចិត្តរបស់ខ្លួន កំណត់មើលល្មមសមគួរដល់ពូកទាំងនេះ គឺ ពូកគ្រែ ពូកតាំង ពូកក្រាលផែនដី ពូកទីចង្ក្រម ពូកសម្រាប់ជូតជើង ។

ចំណែកក្នុងកុរុន្ទីពន្យល់ថា សំឡី ៥ យ៉ាង មានរោមសត្វជាដើម ដែលគួរក្នុងពូក រមែងគួរសូម្បីក្នុងពូកស្បែក ។ ដោយពាក្យដែលពោលក្នុងអដ្ឋកថាកុរុន្ទីនោះ ជាការសម្រេចសន្និដ្ឋានថា ភិក្ខុប្រើប្រាស់ពូកស្បែក រមែងគួរ ។

[៣៣១] ពាក្យថា **យកពូកសម្រាប់គ្រែទៅក្រាលលើតាំង** បានដល់ ក្រាលចុះលើតាំង ។ សូម្បីអត្ថថា នាំទៅដើម្បីប្រយោជន៍ដល់ការក្រាល ដូច្នេះក៏សមគួរ ។

ពីរបទថា ឧល្លោកំ អកត្វា **:** ពូកភិក្ខុមិនបានទ្រាប់ពីក្រោម មានសេចក្ដីថា មិនក្រាលសំពត់ទ្រាប់ខាងក្រោម ។

ពីរបទថា ដោសិតុំ **:** ប្រសព្រំ មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យយកទឹកជ្រលក់ឬល្មៀតលាបខាងលើ ។

បទថា ភិត្តិកម្មំ **:** គូសដោយគំនូសផ្សេង ៗ មានសេចក្ដីថា តថាគតអនុញ្ញាតឱ្យធ្វើស្នាមជាមក ៗ លើស្រោមពូក ។

បទថា ហត្ថភិត្តី : ផ្ទិតទីងម្រាម មានសេចក្ដីថា តថាគត អនុញ្ញាតឱ្យចុចស្នាមសំគាល់ដោយម្រាមទាំង ៥ ។

## បរិកម្មផែនដី

[៣៣៣] បទថា ឥក្កាសំ : ជ័រ បានដល់ ជ័រឈើឬជ័រផ្សំ ។

បទថា បិដ្ឋមទ្ទំ បានដល់ បិដ្ឋខលី : បាយម៉ាន ។

[៣៣៤] បទថា កុណ្ឌកមត្តិកំ : ដីលាយកណ្ឌក បានដល់ ដីស្អិតលាយអង្កាម ។

បទថា សាសបកុដ្ដំ បានដល់ សាសបបិដ្ឋំ : ម្សៅគ្រាប់ស្ពៃ ។

បទថា សិត្ថតេលកំ : ប្រេងលាយក្រមួន បានដល់ ក្រមួនឃ្មុំរាវ ។

ពីរបទថា អច្ចុស្សន្នំ ហោតិ : ដំណក់ថ្នាំលាប ក៏ជោរឡើង មានសេចក្ដីថា ជាដំណក់ ៗ ជាប់នៅ ។

បទថា បច្ចុទ្ធរិតុំ បានដល់ បុញ្ឆិតុំ : ជូត ។

បទថា លណ្ឌមត្តិកំ[១] : ដីស្អិតនៃជន្លេន បានដល់ ដីស្អិតជាអាចម៍កើតឡើងដោយជន្លេន ។

បទថា កសាវំ : ទឹកចត់ បានដល់ ទឹកចត់នៃកន្ទួតព្រៃនិងសម៉ ។

[៣៣៦] វិនិច្ឆ័យក្នុងពាក្យថា ន ភិក្ខវេ បដិភាណចិត្តំ

---
១. ថៃ. លណ្ឌមត្តិកំ; ភូមា. គណ្ឌមត្តិកំ ។

ការាបេតព្វំ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យគេគូរគំនូរ នេះ គប្បីជ្រាបដូច្នេះ ៖

រូបស្រ្តី និងបុរសតែម្យ៉ាងប៉ុណ្ណោះ ដែលភិក្ខុមិនគួរឲ្យធ្វើក៏ទេ រូបសត្វតិរច្ឆាន ដោយហោចទៅសូម្បីរូបជន្លេន ភិក្ខុមិនគួរធ្វើដោយខ្លួនឯង ឬបង្គាប់គេថា "អ្នកចូរធ្វើ" រមែងមិនបានសូម្បីបង្គាប់ថា "ម្នាលឧបាសក អ្នកចូរធ្វើរូបមនុស្សរក្សាទ្វារ" ។ តែរមែងឲ្យអ្នកដទៃគូររឿងទាំងឡាយ ដែលគួរជ្រះថ្លា មានបករណ៍ជាតក និងអសុទិសទានជាដើម ឬដែលបដិសំយុត្តដោយសេចក្តីនឿយណាយ, ទាំងព្រមឲ្យធ្វើខ្លួនឯងនូវមាលាកម្មជាដើម ។

[៣៣៨] បទថា អាឡកមណ្ឌា : មនុស្សកុះករ មានសេចក្តីថា ជាលានតែមួយ ចង្អៀតគ្នាដោយមនុស្ស ។

## បន្ទប់ជាដើម

វិនិច្ឆ័យក្នុងបទថា តយោ គព្ភា : បន្ទប់ ៣ យ៉ាង នេះ គប្បីជ្រាបដូច្នេះ ៖

សិវិកាគព្ភំ : បន្ទប់ដូចគ្រែស្នែង នោះ បានដល់ បន្ទប់ ៤ ជ្រុង ។

នាឡិកាគព្ភំ : បន្ទប់ដូចនាឡិ នោះ បានដល់ បន្ទប់វែងជាងទទឹង ២ ឬ ៣ ដង ។

ហម្មិយគព្ភំ : បន្ទប់មានដំបូលខ្ពស់ នោះ បានដល់ បន្ទប់ផ្ទះកំពូលព្ឋដ៏អាកាស ឬបន្ទប់មានដំបូលត្រងិល ។

[៣៤០] បទថា កុលង្កបាទកំ : ទ្រនាប់ជើងជញ្ជាំង មានសេចក្តីថា តថាគតអនុញ្ញាតឱ្យធ្វើទ្រនាប់ជើងជញ្ជាំង ដែលរំកិលប្តូរទីមិនបាន ដែលបោះឈើដំចម្រឹងក្នុងឈើនោះ ទ្រលើផែនដីដើម្បីកល់ជើងជញ្ជាំងចាស់ ។

បទថា បរិត្តាណកិដិកំ : ធ្វើប្រដឹសការពារភ្លៀង មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភ្ជាប់បាំងសាច ដើម្បីការពារភ្លៀង ។

បទថា ឧទ្ធាសុធំ : ហើយលាបដីស្អិត បានដល់ ដីស្អិតដែលលាយជាមួយអាចម៍គោ និងផេះ ។

[៣៤៤] បទថា អាលិន្ទោ : យ៉មុខ ហៅថា រានហាល ។

ដែលឈ្មោះថា បឃន : ជើងជញ្ជាំង គប្បីជ្រាបដូច្នេះ ៖ ជនទាំងឡាយ កាលចេញ និងចូល រមែងប៉ះខ្ទប់ប្រទេសណា ដោយ

ជើងទាំងឡាយ, ពាក្យថា បឃនៈ នេះ ជាឈ្មោះរបស់ប្រទេសនោះ ដែលនាំជញ្ជាំងចេញ ២ ខាង ធ្វើទុកត្រង់ទ្វារ កុដិ (បានដល់របាំង) បឃនៈ នោះ ហៅថា បឃានៈខ្ទះ ។

របៀងជុំវិញបន្ទប់កណ្ដាល ហៅថា បក្កុទ្ទៈ ធរណីបាំងសាចជុំវិញ, បាលីថា បក្កុដ្ឋំ ក៏មាន ។

ឱសារកើ : ហោណាំង នោះ បានដល់ យ៉មុខមានដំបូល ដែលជាប់របារ ហើយដកកំណាត់ឈើចេញពីរបារនោះទៅ ធ្វើទុកត្រង់កុដិដែលមិនមានរបៀង ។

បាំងសាចដែលជាប់កងមូលសម្រាប់រូត ឈ្មោះថា រនាំងព្រួល ។

## ភាជន៍ទឹក_ទ្វារ

[៣៨៦] បទថា ធានីយភាជនំ : ភាជន៍សម្រាប់ដាក់ទឹកឆាន់ នោះ បានដល់ ភាជនៈសម្រាប់ដងទឹកឱ្យអ្នកផឹក ។ ប្រោយ និងផ្តិល អនុលោមតាមស័ទ្ធដងទឹក ។

[៣៨៩] បទថា អបេសី : ទ្វារគោបបន្ទា នោះ បានដល់ គ្រឿងការពារទ្វារ ដែលដាក់ចម្រឹងចូលក្នុងឈើវែងហើយចងបន្ទា ។

បទថា បលិឃំ : ទ្វារជើងគុល នោះ បានដល់ គ្រឿងការពារ

ទ្វារដែលជាប់កន្លងដូចត្រង់ទ្វារស្រុក ។

## រឿងអនាថបិណ្ឌិកៈ

[៣៥៦] រថទាំងឡាយទឹមដោយមេសេះអស្សតរទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា រថទឹមមេសេះអស្សតរ ។

បទថា អាមុត្តមណិកុណ្ឌលា : ដែលប្រដាប់ដោយកុណ្ឌលជាវិការនៃកែវមណី បានដល់ អ្នកប្រដាប់ក្រវិលកែវមណី ។

[៣៥៩] បទថា បរិនិព្វុតោ : អ្នកមានទុក្ខរំលត់ហើយ មានសេចក្តីថា ព្រោះមិនមានឧបធិ គឺ កិលេស និងឧបធិ គឺ ខន្ធ លោកទើបពោលថា "អ្នកត្រជាក់ស្និទ្ធ មិនមានឧបធិ" ។

បាទគាថាថា សព្វា អាសត្តិយោ ឆេត្វា : កាត់បង់សេចក្តីប្រាថ្នាក្នុងភពទាំងពួង មានសេចក្តីថា កាត់សេចក្តីប្រាថ្នាក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ឬក្នុងភពទាំងពួង

បាទគាថាថា វិនេយ្យ ហទយេ ទរំ : ហើយនាំបង់នូវសេចក្តីក្រវល់ក្រវាយក្នុងព្រះទ័យចេញ បានដល់ កម្ចាត់សេចក្តីខ្វល់ខ្វាយ គឺកិលេសក្នុងចិត្តចេញ ។

[៣៦២] ទ្រព្យសម្រាប់ប្រើប្រាស់អស់ទៅ ហៅថា វេយ្យាយិកំ

វត្ថុសម្រាប់ចាយវាយ ។

[៣៦៦] បទថា **អាធេយ្យវាចោ : មានវាចាគួរឱ្យអ្នកផងកាន់យក** មានសេចក្ដីថា ពាក្យរបស់អនាថបិណ្ឌិកគហបតីនោះ ដែលជនជាច្រើនគួរជឿបាន ; អធិប្បាយថា មនុស្សទាំងឡាយជាច្រើន រមែងសម្គាល់ពាក្យរបស់គហបតីនោះថា "ដែលខ្លួនគួរស្ដាប់" ។

ពីរបទថា **អារាមេ អកាំសុ :** មានសេចក្ដីថា ជនពួកណាមានទ្រព្យ ជនទាំងនោះបានសាងដោយទ្រព្យរបស់ខ្លួន ជនពួកណាមានទ្រព្យតិច និងមិនមានទ្រព្យ គហបតីបានឱ្យទ្រព្យដល់ជនទាំងនោះ ។

គហបតីនោះ ឱ្យទ្រព្យ១សែនកហាបណៈ និងវត្ថុមានតម្លៃមួយសែន ធ្វើការសាងវិហារទុកក្នុងរវាងមកមួយយោជន៍ ក្នុងមកចម្ងាយ ៤៥ យោជន៍ហើយ បានទៅក្រុងសាវត្ថី ដោយប្រការដូច្នេះ ។

ពីរបទថា **កោដិសន្ថរំ សន្ថរាបេសិ : ឱ្យតម្រៀបដោយកោដិនៃកហាបណៈ** មានសេចក្ដីថា បានតំរៀបកហាបណៈឱ្យផ្ទឹបគ្នា ក្នុងទីកន្លែងកំណត់ យកប្រមាណនៃគ្រឿងលោមព័ទ្ធរបស់ដើមឈើ ឬស្រះ ដែលមានក្នុងវត្ថុជេតវ័ននោះក្រាលហើយ ទ្រព្យមួយរណ្ដៅ ដែលមាន ១៨ កោដិ របស់គហបតីនោះ ក៏ដល់នូវការអស់ទៅ ដោយប្រការដូច្នេះ ។

ពីរបទថា **កុមារស្ស ឯតទហោសិ : កុមារមានសេចក្ដីត្រិះរិះ**

ដូច្នេះថា មានសេចក្តីថា សេចក្តីរំពឹងនេះ បានមានដល់រាជកុមារ ព្រោះឃើញអាការដែលថ្លាផូរផង់នៃមុខរបស់គហបតី សូម្បីត្រូវលះបង់ទ្រព្យច្រើន យ៉ាងនោះ ។

ពីរបទថា កោដ្ឋកំ មាបេសិ : បានសាងខ្លោងទ្វារ មានសេចក្តីថា រាជកុមារឱ្យសាងប្រាសាទមានស៊ុមទ្វារ ៧ ជាន់ ។

ពាក្យថា អថ ខោ អនាថបិណ្ឌិកោ គហបតិ ជេតវនេ វិហារេ ការាបេសិ ។បេ ។ មណ្ឌបេ ការាបេសិ : លំដាប់នោះ អនាថបិណ្ឌិកគហបតី ឱ្យគេធ្វើវិហារ ។ល ។ ឱ្យគេធ្វើមណ្ឌបក្នុងវត្តជេតវន ។ មានសេចក្តីថា អនាថបិណ្ឌិកគហបតីសាងវិហារជាដើមទាំងនេះ លើផ្ទៃដីប្រមាណ ៨ ករីស[1] ដោយទ្រព្យ ១៨ កោដិ ដទៃទៀត ។

ពិតមែន គហបតីឈ្មោះ បុនព្វសុមិត្ត បានទិញដី ប្រមាណមួយយោជន៍ ដោយក្រាលឥដ្ឋមាស (ពេញផ្ទៃដី) សាងវិហារថ្វាយព្រះមានព្រះភាគទ្រង់ព្រះនាមថា វិបស្សី ។

សិរិវឌ្ឍគហបតី បានទិញដីប្រមាណ ៣គាវុត[2] ដោយក្រាលឈើសសរមាស សាងវិហារថ្វាយព្រះមានព្រះភាគ ទ្រង់ព្រះនាមថា សិខី ។

---

១. ១ករីស = ១២៥ ហត្ថ. ឬ ១ សេន ១១ ព្យាម ១ ហត្ថ ។ ២. ១ គាវុត =

១០០ សេន ។

សោត្ថិជគហបតី បានទិញដី ប្រមាណកន្លះយោជន៍ ក្រាលដោយផាលមាស សាងវិហារថ្វាយព្រះមានព្រះភាគ ទ្រង់ព្រះនាមថា វេស្សភូ ។

អច្ចុតគហបតី បានទិញដីប្រមាណមួយគាវុត ដោយតំរៀបជើងដំរីមាស សាងវិហារថ្វាយព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **កកុសន្ធៈ** ។

ឧគ្គគហបតី បានទិញដីប្រមាណកន្លះគាវុត ដោយតំរៀបឥដ្ឋមាស សាងវិហារថ្វាយព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **កោនាគមនៈ** ។

សុមង្គលគហបតី បានទិញដីប្រមាណ ២០ ឧសភៈ[១] ដោយតំរៀបអណ្តើកមាស សាងវិហារថ្វាយព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **កស្សបៈ** ។

សុទត្តគហបតី បានទិញដីប្រមាណ ៨ ករីស ដោយតំរៀបកហាបណៈ សាងវិហារថ្វាយព្រះមានព្រះភាគ របស់យើងទាំងឡាយ ដូច្នេះឯង ។

សម្បត្តិទាំងឡាយសាបសូន្យអស់ទៅដោយលំដាប់ ដោយប្រការដូច្នេះ ព្រោះហេតុនោះ សមគួរនឹងនឿយណាយក្នុងសម្បត្តិទាំងពួង សមគួរនឹងរួចផុតចេញទៅ ដូច្នេះឯង ។

---

១. ១ឧសភ = ២៥ ព្យាម ។

## នវកម្ម

[៣៦៩] បទថា ខណ្ឌំ : បាក់ បានដល់ ឱកាសដែលបាក់ ។

បទថា ផុល្លំ : បែក បានដល់ ឱកាសដែលបែក ។

បទថា បដិសង្ខរិស្សតិ : នឹងជួសជុល បានដល់ នឹងធ្វើឱ្យដូចដើមតាមប្រក្រតីវិញ ។

ក្នុងកុរុន្ទីពន្យល់ថា ក៏ភិក្ខុដែលបាននវកម្ម មិនគួរកាន់យកគ្រឿងដៃមានកាំបិតពូថៅ និងពន្លាកជាដើម ចុះដៃធ្វើខ្លួនឯង ។ គួរដឹងថា "ជាការធ្វើហើយ ឬមិនជាការធ្វើ" ។

## ការកាន់សេនាសនៈ

[៣៧០] ច្រើនបទថា បិដ្ឋិតោ បិដ្ឋិតោ គន្ត្វា : ទៅអំពីខាងក្រោយ ៗ មានសេចក្ដីថា បានឮថា ព្រះថេរៈរវល់តែទៅប្រណិបត្តិភិក្ខុឈឺ រវល់តែជួយខ្វល់ខ្វាយដល់ភិក្ខុដែលចាស់ជរា ទើបមកខាងក្រោយភិក្ខុទាំងពួង ។ នេះជាចរិតរបស់លោក ។ ដោយហេតុនោះ ព្រះធម្មសង្គាហកាចារ្យ ទើបពោលថា ទៅខាងក្រោយ ៗ ។

[៣៧១] បទថា អគ្គាសនំ : អាសនៈប្រសើរ បានដល់ ថេរាសនៈ ។

បទថា អគ្គោទកំ : ទឹកប្រសើរ បានដល់ ទឹកដែលបុគ្គលឱ្យដើម្បីជាទាន ឬ ទឹកជាគ្រឿងចម្រើន ។

បទថា អគ្គបិណ្ឌំ : ដុំបាយប្រសើរ បានដល់ បិណ្ឌបាតសម្រាប់ព្រះសង្ឃថេរៈ ។

[៣៧២] បទថា អន្តរា សត្ថីនំ ការិត្វា : ក្នុងចន្លោះភ្លៅទាំងពីរហើយដើរទៅ សេចក្តីថា ធ្វើត្រង់ចន្លោះនៃជើងបួន ។

[៣៨០] បទថា បតិដ្ឋាបេសិ : ប្រតិស្ឋាន បានដល់ ធ្វើការបរិច្ចាគទ្រព្យ ១៨ កោដិសាងទុក ។ អនាថបិណ្ឌិកគហបតី បរិច្ចាគទាំងអស់ ៥៤ កោដិ[១] ដោយប្រការដូច្នេះ ។

## ទំនៀមក្នុងរោងឆាន់

[៣៨២] បទថា វិប្បកតភោជនេ[២] : កំពុងឆាន់មិនទាន់លែងមានសេចក្តីថា ភិក្ខុកំពុងឆាន់នៅក្នុងទីណាមួយ ក្នុងចន្លោះស្រុកក្តី ក្នុងវិហារក្តី ក្នុងព្រៃក្តី កាលឆាន់មិនទាន់ស្រេចមិនគួរឱ្យក្រោក ។ ក្នុងចន្លោះស្រុក ភិក្ខុដែលមកខាងក្រោយ គប្បីទទួលភិក្ខាហើយទៅកាន់ទីនៃ

---

១. ទិញដី ១៨ កោដិ សាងវិហារជាដើម ១៨ កោដិ ធ្វើបុណ្យឆ្លង ១៨ កោដិ ។

២. ឱ.ម. វិប្បកតភោជនំ ។

ភិក្ខុដែលជាសភាគគ្នា ។ បើអ្នកស្រុក ឬ ភិក្ខុទាំងឡាយ និមន្តថា "សូមលោកម្ចាស់ចូលទៅ" គួរប្រាប់ថា "កាលយើងចូលទៅ ភិក្ខុទាំងឡាយនឹងត្រូវក្រោកឡើង" ។ លោកដែលគេពោលថា "ទីនេះនៅមានទីអង្គុយ" ទើបគួរចូលទៅ ។ បើអ្នកណា ៗ មិនពោលពាក្យតិចតួចគប្បីទៅត្រង់អាសនៈសាលាហើយ មកឈរក្នុងទីនៃភិក្ខុដែលជាសភាគគ្នា ; កាលភិក្ខុទាំងឡាយធ្វើឱកាសហើយ លោកដែលគេនិមន្តថា "និមន្តចូលមកចុះ" ដូច្នេះ គប្បីចូលទៅ ។ តែបើទីអាសនៈដែលនឹងត្រូវដល់លោកម្ចាស់មាន ភិក្ខុមិនបានឆាន់អង្គុយ នឹងឱ្យភិក្ខុនោះក្រោកឡើងគួរ ។ ភិក្ខុដែលអង្គុយឆាន់យាគូ និងរបស់ទំពារជាដើម យ៉ាងណាមួយហើយ សូម្បីមានដៃទទេក៏មិនគួរឱ្យក្រោក ដរាបទាល់តែភិក្ខុដទៃមកដល់ព្រោះថា លោករាប់ថា "ជាអ្នកនៅឆាន់" ដូចគ្នា ។

ពាក្យថា សចេ វុដ្ឋាបេតិ : តែបើ ( ភិក្ខុចាស់ ) បណ្ដេញ ( ភិក្ខុខ្ចី ) មានសេចក្ដីថា បើសូម្បីលោកក្លែង កន្លងអាបត្តិ ឱ្យក្រោកឡើងទាល់តែបាន ។

ពាក្យថា បរិវារិតោ ច ហោតិ : ត្រូវភិក្ខុខ្ចីឃាត់ មានសេចក្ដីថា លោកនឹងឱ្យភិក្ខុណាក្រោក, បើភិក្ខុនេះ ជាអ្នកហាមភោជនហើយ, លោកដែលភិក្ខុនោះគប្បីពោលថា "ចូរទៅរកទឹកមក" ។

ពិតមែន នេះឯងជាឋានមួយ ដែលភិក្ខុកម្លោះប្រើភិក្ខុចាស់ជាង

បាន ។ បើលោកមិនរកទឹកមកឱ្យ ។ លំដាប់នោះ ព្រះមានព្រះភាគ នឹងទ្រង់សម្តែងនាទីដែលភិក្ខុនីជាផគប្បីធ្វើ ទើបត្រាស់ពាក្យជាដើមថា "ត្រូវភិក្ខុនីលេបគ្រាប់បាយឱ្យស្រួល" ។

## សេនាសនៈដែលសមគួរដល់ភិក្ខុអាពាធ

[៣៨៤] វិនិច្ឆ័យក្នុងពាក្យថា គិលានស្ស បដិរូបំ សេយ្យំ : ទីដេកដ៏សមគួរដល់ភិក្ខុឈឺ នេះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុណាជាអ្នកអាពាធ ដោយរោគហឹតឬរោគឫសដូងប្រមុះ និងរោគធ្លាក់ឈាមជាដើម, ភាជនៈមានកន្ទោរនិងថ្នាំងឧច្ចារៈជាដើម ជារបស់ដែលភិក្ខុនោះគួរត្រៀមទុក ។

ម្យ៉ាងទៀត ភិក្ខុកើតរោគឃ្លង់ រមែងធ្វើសេនាសនៈឱ្យខូច, គួរឱ្យនៅខាងក្រោមប្រាសាទ មណ្ឌប និងសាលាជាដើម យ៉ាងណាមួយ ជាសេនាសនៈ ចំណែកមួយ ដល់ភិក្ខុបែបនោះ ។ កាលភិក្ខុអាពាធរូបណានៅ នឹងមិនធ្វើសេនាសនៈឱ្យវិនាស ។ សូម្បីទីដេកប្រណីត ក៏គួរឱ្យដល់ភិក្ខុរូបនោះពិត ។ ចំណែកភិក្ខុណា ធ្វើថ្នាំយ៉ាងណាមួយជាដើមថា ថ្នាំក្រហម ថ្នាំបញ្ចុះ និងថ្នាំទត្ថ (ហឹតតាមប្រមុះ) ភិក្ខុនោះ ទាំងអស់ចាត់ថា ភិក្ខុអាពាធដែរ ។ គប្បីកំណត់ឱ្យសេនាសនៈ ដែលសមគួរដល់

ភិក្ខុសូម្បីនោះ ។

[៣៨៥] បទថា លេសកប្បេន : កលមយាអាត្រក់ បានដល់ត្រឹមតែឈឺក្បាលជាដើម បន្តិចបន្តួច ។

## ភិក្ខុជាសេនាសនគាហាបកៈ

[៣៨៩] ពីរបទថា ភិក្ខូ គណេត្វា : លុះរាប់ចំនួនភិក្ខុរួចហើយ បានដល់ ដឹងចំនួនភិក្ខុទាំងឡាយក្នុងវិហារថា "មានភិក្ខុប៉ុណ្ណេះ" ។

ទីតាំងគ្រែ ហៅថា ទីដេក ។

បទថា សេយ្យគ្គេន : តាមកំណត់នៃដំណេក បានដល់ ចំនួនទីដេក ។ សេចក្តីថា ក្នុងថ្ងៃចូលវស្សា តថាគតអនុញ្ញាតឱ្យភិក្ខុមួយរូបប្រកាសវេលា ហើយឱ្យកាន់យកទីដាក់គ្រែមួយកន្លែង ។

ពីរបទថា សេយ្យគ្គេន គាហេន្តា : ភិក្ខុទាំងឡាយក៏ប្រគល់ឱ្យតាមកំណត់នៃដំណេក បានដល់ កាលឱ្យកាន់យកតាមចំនួនទីដេក ។

ពីរបទថា សេយ្យា ឧស្សាទិយឹសុ : ដំណេកក៏នៅសល់ច្រើន គឺ កាលឱ្យកាន់យកយ៉ាងនោះ តាំងទិងគ្រែនៅសល់ច្រើន ។ សូម្បីក្នុងចំនួនវិហារជាដើម ក៏មានន័យដូចគ្នា ។ វិហារនោះប្រាថ្នាយកបន្ទប់មានឧបចារៈ ។

បទថា អនុភាគំ : តាមចំណែកជាលំដាប់ទៅ មានសេចក្ដីថា តថាគតអនុញ្ញាត ដើម្បីឱ្យចំណែកសូម្បីដទៃទៀត, ពិតមែន កាលភិក្ខុមានតិច សមគួរឱ្យមួយអង្គ ២-៣ បរិវេណ ។

ពាក្យថា ន អកាមា ទាតព្វោ : មិនត្រូវការ មិនគប្បីឱ្យទេ មានសេចក្ដីថា អ្នកចែកមិនគប្បីឱ្យ ព្រោះមិនប្រាថ្នានឹងឱ្យ (ចំណែកបន្ថែមនោះ) ។

ក្នុងថ្ងៃចូលវស្សា នាកាលចំណែកបន្ថែម ដែលភិក្ខុទាំងឡាយកាន់យកហើយ ចំណែកបន្ថែមនោះមិនគួរឱ្យដល់ភិក្ខុដែលមកខាងក្រោយ ព្រោះខ្លួន (គឺ អ្នកកាន់យកហើយ) មិនពេញចិត្ត ។

តែបើចំណែកបន្ថែមដែលភិក្ខុណាមិនទាន់កាន់យកហើយ ភិក្ខុនោះ រមែងឱ្យចំណែកបន្ថែមនោះ ឬចំណែកដំបូង ដោយសេចក្ដីពេញចិត្តរបស់ខ្លួន ដូច្នេះគួរ ។

[៣៩០] ពីរបទថា និស្សីមេ ឋិតស្ស : ដល់ភិក្ខុដែលឋិតនៅក្នុងទីក្រៅសីមា បានដល់ អ្នកតាំងនៅខាងក្រៅឧបចារៈសីមា ។ តែថា សូម្បីភិក្ខុដែលតាំងនៅឆ្ងាយ តែនៅខាងក្នុងឧបចារៈសីមា រមែងបានពិត ។

[៣៩១] ពីរបទថា សេនាសនំ គហេត្វា : ទទួលយកសេនាសនៈហើយ បានដល់ កាន់ក្នុងថ្ងៃចូលវស្សា ។

ពីរបទថា សព្វកាលំ បដិពាហន្តិ : ឃាត់ទាំងទុកគ្រប់កាល

បានដល់ ហួងហែងសូម្បីក្នុងរដូវកាលដែលកន្លង ៤ ខែហើយ ។

# សេនាសនគាហវិនិច្ឆ័យ

[៣៩២] បណ្តាការកាន់សេនាសនៈ ៣ យ៉ាង ការកាន់ ២ យ៉ាងនេះ ជាការកាន់ជានិច្ច គឺ កាន់ក្នុងថ្ងៃចូលវស្សាដំបូង ១ កាន់ក្នុងថ្ងៃចូលវស្សាក្រោយ ១ ។

ការកាន់សេនាសនៈដែលជាអន្តរាមុត្តកៈ គឺ ផុតពីនោះ មានវិនិច្ឆ័យ ដូច្នេះ ៖

ក្នុងវិហារមួយ មានសេនាសនៈ ដែលមានលាភច្រើន ។ ម្ចាស់របស់សេនាសនៈ បម្រុងភិក្ខុអ្នកចាំវស្សា ដោយបច្ច័យទាំងពួងដោយអើពើ ប្រគេនសមណបរិក្ខារច្រើន ក្នុងវេលាបវារណា ហើយនឹងទៅ ។

ព្រះមហាថេរៈទាំងឡាយមកពីឆ្ងាយ ក្នុងថ្ងៃចូលវស្សាកាន់យកសេនាសនៈនោះនៅសប្បាយ កាលចាំវស្សាហើយ ទទួលលាភជៀសចេញទៅ ។

ពួកភិក្ខុដែលម្ចាស់វត្ត មិនថែរក្សាសេនាសនៈនោះ សូម្បីទ្រុឌទ្រោមទៅដោយគិតថា "ពួកយើងមិនបានលាភដែលកើតក្នុងសេនាសនៈនោះ, ព្រះមហាថេរៈជាអាគន្តុកៈ ថែរក្សាបានជានិច្ច, ពួកលោកទុំះឯងនឹងមកថែទាំសេនាសនៈនោះ" ។

ដើម្បីឱ្យថែទាំសេនាសនៈនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ដែលឈ្មោះថា អន្តរាមុត្តកៈ ត្រូវភិក្ខុប្រគល់ឱ្យតាំងអំពីថ្ងៃបវារណាក្នុងខែអស្សុជទៅ ដើម្បីនៅចាំវស្សាតទៅ (ដែលនឹងមកដល់ខាងមុខ)" ។ កាលភិក្ខុដែលសេនាសនគ្គាហាបកៈ នឹងឱ្យកាន់អន្តរាមុត្តកសេនាសនៈនោះ គប្បីប្រាប់ព្រះសង្ឃថេរៈថា "លោកម្ចាស់ដ៏ចម្រើន និមន្តកាន់យកសេនាសនៈ ជាអន្តរាមុត្តកៈចុះ" ។

បើលោកទទួល គប្បីឱ្យ, បើមិនទទួល, គប្បីឱ្យដល់ភិក្ខុដែលនឹងទទួល តាំងពីព្រះអនុថេរៈជាដើមទៅ ដោយហោចទៅសូម្បីសាមណេរ ដោយឧបាយនេះឯង ។ ចំណែកអ្នកទទួលនោះ គប្បីទំនុកបម្រុងសេនាសនៈនោះ ៨ ខែ បណ្ដាជំបូលជញ្ជាំងនិងផែនដី វត្ថុណាមួយទ្រុឌទ្រោម ឬបាក់បែកទៅ, គួរជួសជុលទាំងអស់ ។ សូម្បីនឹងឱ្យពេលថ្ងៃអស់ទៅ ដោយឧទ្ទេស និងបរិបុច្ឆាជាដើម ពេលយប់ទើបនៅក្នុងសេនាសនៈនោះក៏បាន ។ ពេលយប់នឹងនៅក្នុងបរិវេណ ពេលថ្ងៃឱ្យអស់ទៅ ដោយការនៅក្នុងសេនាសនៈនោះ ក៏បាន សូម្បីនឹងនៅក្នុងសេនាសនៈនោះឯង ទាំងពេលយប់ទាំងពេលថ្ងៃក៏បាន មិនគួរហួងហែងភិក្ខុដែលចាស់ជាងមកក្នុងរដូវកាល ។ តែកាលដល់ថ្ងៃចូលវស្សាហើយ ព្រះសង្ឃថេរៈពោលថា "លោកចូរឱ្យសេនាសនៈនេះដល់ខ្ញុំព្រះ

ករុណា” ; ដូច្នេះមិនបាន ។

ភិក្ខុជាសេនាសនគាហាបកៈ មិនគប្បីឱ្យ ត្រូវបញ្ជាក់ប្រាប់ថា “លោកម្ចាស់ដ៏ចម្រើន សេនាសនៈនេះ ភិក្ខុមួយរូបកាន់យកជាអន្តរាមុត្តកៈ បានទំនុកបម្រុងមក ៨ ខែហើយ” ។ សេនាសនៈនោះ ត្រូវឱ្យភិក្ខុដែលទំនុកបម្រុងមក ៨ ខែទុំះឯង កាន់យកបាន ។

ចំណែកក្នុងសេនាសនៈណា ពួកម្ចាស់របស់ប្រគេនបច្ច័យ មួយឆ្នាំ ២ ដង, សេនាសនៈនោះ មិនគួរឱ្យកាន់ជាអន្តរាមុត្តកៈ គ្រប់កាលដែលកន្លង ៦ ខែ ឬថា ក្នុងសេនាសនៈណា ពួកម្ចាស់របស់ប្រគេនបច្ច័យមួយឆ្នាំ ៣ ដង សេនាសនៈនោះ មិនគួរឱ្យកាន់ជាអន្តរាមុត្តកៈ គ្រប់កាលដែលកន្លង ៤ ខែ ឬ ក្នុងសេនាសនៈណា ពួកម្ចាស់របស់ប្រគេនបច្ច័យមួយឆ្នាំ ៤ ដង, សេនាសនៈនោះ មិនគួរឱ្យកាន់ជាអន្តរាមុត្តកៈគ្រប់កាលដែលកន្លង ៣ ខែ ។ ព្រោះថា សេនាសនៈនោះ នឹងបានទំនុកបម្រុងដោយបច្ច័យ ពិត ។

ចំណែកក្នុងសេនាសនៈណា ពួកម្ចាស់របស់ប្រគេនបច្ច័យ ច្រើនណាស់ត្រឹមតែមួយឆ្នាំម្តង, សេនាសនៈនោះ គួរឱ្យកាន់ជាអន្តរាមុត្តកៈបាន ។

កថាពោលអំពីការកាន់សេនាសនៈ ដែលមកក្នុងបាលី ដោយថ្ងៃចូលវស្សាខាងក្នុងវជ្ជវគ្គៀង ប៉ុណ្ណេះ ។

# ការកាន់សេនាសនៈ ក្នុងរដូវកាល

ដែលឈ្មោះថា ការកាន់សេនាសនៈនេះ រមែងមាន ២ យ៉ាង គឺ កាន់ក្នុងរដូវកាល ១ កាន់ក្នុងវស្សាវាស្សកាល ១ ។

ក្នុងបណ្តា ២ យ៉ាងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងរដូវកាលជាមុន

ពួកភិក្ខុអាគន្តុកៈខ្លះ មកក្នុងវេលាព្រឹក, ពួកខ្លះមកក្នុងវេលារសៀល, ពួកខ្លះមកក្នុងបឋមយាម, ពួកខ្លះមកក្នុងមជ្ឈិមយាម, ពួកខ្លះមកក្នុងបច្ឆិមយាមក៏មាន; ពួកណាមកក្នុងវេលាណា, ភិក្ខុជាសេនាសនគាហាបកៈ គប្បីឱ្យភិក្ខុទាំងឡាយ ក្រោកឡើងហើយ ឱ្យសេនាសនៈដល់ភិក្ខុទាំងនោះ ក្នុងវេលានោះតែម្តង, ដែលឈ្មោះថា សម័យដែលមិនមែនកាល រមែងមិនមាន ។

ចំណែកភិក្ខុជាអ្នកចាត់ចែងសេនាសនៈ ត្រូវជាអ្នកឆ្លាត គប្បីវៀរតាំងនិងគ្រែទុក ១ ឬ ២ កន្លែង ។ បើព្រះមហាថេរៈ ១ រូប ឬ ២ រូប មកក្នុងវេលាវិកាល ។ គប្បីប្រាប់លោកថា "លោកម្ចាស់ដ៏ចម្រើន ភិក្ខុសូម្បីទាំងអស់ កាល ខ្ញុំព្រះករុណាឱ្យក្រោកឡើងតាំងពីដើម នឹងត្រូវនាំគ្នាជញ្ជូនរបស់ចេញ, សូមលោកម្ចាស់នៅក្នុងលំនៅរបស់ខ្ញុំព្រះករុណាចុះ" ។ តែកាលព្រះមហាថេរៈនាំគ្នាមកច្រើនអង្គ គប្បីឱ្យភិក្ខុទាំងឡាយ ក្រោកចេញហើយឱ្យតាមលំដាប់ ។

បើបរិវេណគ្រប់គ្រាន់, គប្បីឱ្យដល់មួយអង្គមួយបរិវេណ; សូម្បីស្ថានទាំងពួងជាដើមថា រោងភ្លើង រោងវែង និងរោងមូល ក្នុងបរិវេណនោះ រមែងត្រូវបានដល់លោកផង ។ កាលបែកយ៉ាងនោះមិនគ្រប់អង្គ គួរឱ្យតាមចំនួនប្រាសាទ[១] ។ កាលប្រាសាទមិនគ្រប់គ្រាន់ គួរឱ្យតាមចំនួនបន្ទប់តូច ។ កាលចំនួនបន្ទប់តូចមិនគ្រប់គ្រាន់ គួរឱ្យតាមចំនួនទីដេក ។ កាលទីគ្រែមិនគ្រប់គ្រាន់ គួរឱ្យចំពោះទីល្មមតាំងមួយ តែមិនគួរឱ្យកាន់យកទីត្រឹមតែឱកាសល្មមភិក្ខុឈរបាននោះទេ ព្រោះទីប៉ុណ្ណោះ មិនចាត់ជាសេនាសនៈ ។ តែកាលទីតាំងមិនល្មម គប្បីឱ្យទីគ្រែ ឬ ទីតាំងមួយដល់ភិក្ខុ ៣ រូប ដោយពោលថា "លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ផ្លាស់ ប្ដូរគ្នាសម្រាកចុះ" ។

ក្នុងវជ្ជីត្រែជាក់ អ្នកណា ៗ មិនអាចនឹងនៅទីវាលរហូតដល់មួយយប់, ព្រះមហាថេរៈ គួរសម្រាក រហូតដល់អស់បឋមយាម ហើយចេញទៅប្រាប់ព្រះថេរៈទី ២ ថា "អ្នកដ៏មានអាយុ ចូរលោកទៅក្នុងទីនេះ" បើព្រះមហាថេរៈជាអ្នកផ្ងោកផ្ទុយដេកមិនដឹងវេលា, ព្រះថេរៈទី ២ គប្បីគ្រហែម គោះទ្វារប្រាប់ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ជាកាលគួរ

១. ទីនៅដែលធ្វើជាន់ ៗ ប្រាសាទក្នុងទីនេះគួរនឹងសំដៅថា មួយជាន់ ៗ ។

ស្វាងហើយ សេចក្ដីត្រជាក់តែងបៀតបៀន” ដូច្នេះ ។ លោកគួរចេញទៅឱ្យឱកាស នឹងមិនឱ្យមិនបាន ។

ចំណែកព្រះថេរៈទី ២ សម្រាករហូតដល់អស់មជ្ឈិមយាមហើយ ក៏គួរឱ្យដល់ភិក្ខុក្រៅនេះ តាមន័យមុនដូចគ្នា ។ ព្រះថេរៈទី ២ ជាអ្នកខ្ជិល ក៏គួរដាស់តាមន័យដែលពោលហើយ ដូចគ្នា ។ ទីគ្រែមួយកន្លែងគប្បីឱ្យដល់ភិក្ខុ ៣ រូបរហូតដល់អស់មួយយប់យ៉ាងនេះ ។

តែភិក្ខុពួកខ្លះក្នុងជម្ពូទ្វីបឃើញថា “សេនាសនៈ ឬទីគ្រែ ឬទីតាំងចំពោះកន្លែងខ្លះ រមែងជាទីសប្បាយសម្រាប់ភិក្ខុខ្លះ មិនជាទីសប្បាយសម្រាប់ភិក្ខុខ្លះ” ភិក្ខុទាំងឡាយជាអាគន្តុកៈ ឬ មិនមែនក៏ដោយ រមែងឱ្យកាន់សេនាសនៈរាល់ថ្ងៃ នេះឈ្មោះថា ការកាន់សេនាសនៈក្នុងរដូវកាល ។

## ការកាន់សេនាសនៈក្នុងកាលចាំវស្សា

ចំណែកក្នុងរដូវកាលចាំវស្សា រមែងមានអាគន្តុកវត្ត មានអាវាសិកវត្ត ។ អាគន្តុកៈនិងអាវាសិកៈនោះ ភិក្ខុអាគន្តុកៈប្រាថ្នា នឹងលះអាវាសរបស់ខ្លួន ទៅនៅទីដទៃ មិនគួរ ទៅក្នុងទីដទៃនោះ ក្នុងថ្ងៃចូលវស្សា ។ ព្រោះថា ទីលំនៅក្នុងទីនោះនឹងត្រូវចង្អៀតគ្នា, ឬភិក្ខាចារមិនគ្រប់គ្រាន់ ។ ដោយហេតុនោះ លោកនៅមិនសប្បាយ, ព្រោះដូច្នោះ គប្បីប៉ាន់ស្មានថា

"តាំងពីឥឡូវនេះទៅ ប្រមាណជាមួយខែទឹងចូលវស្សា" ហើយចូលទៅកាន់វិហារនោះ ។

កាលនៅក្នុងវិហារនោះ ប្រមាណមួយខែ បើមានសេចក្តីត្រូវការរៀនបាលីទឹងកំណត់ទុកថា "ការរៀនបាលីបរិបូណ៌ហើយ" បើប្រាថ្នាចំពោះកម្មដ្ឋានទឹងកំណត់បានថា "កម្មដ្ឋានជាទីសប្បាយ" បើមានសេចក្តីត្រូវការបច្ច័យ ទឹងកំណត់បច្ច័យលាភបាន ទឹងនៅជាសុខខាងក្នុងវស្សា ។

ក៏កាលទឹងចេញពីអាវាសរបស់ខ្លួនទៅក្នុងទីនោះ មិនគួរប៉ះទង្គិចគោចរគ្រាម, គឺ កុំស្តីបន្ទោសដល់អ្នកស្រុកក្នុងទីនោះថា "សលាកភត្តជាដើមក្តី យាគូនិងរបស់គួរទំពាក្តី សំពត់ចំណាំវស្សាក្តី ដែលអាស្រ័យពួកអ្នក រមែងមិនមាន នេះបរិក្ខាររបស់ចេតិយ នេះបរិក្ខាររបស់រោងឧបោសថ នេះរនុកនិងកូនសោ អ្នកចូរទទួលទីនៅរបស់អ្នក" ។ ដែលត្រឹមត្រូវ គួរចាត់ចែងសេនាសនៈរក្សាភណ្ឌៈឈើនិងភណ្ឌៈដី បំពេញគមិយវត្តឱ្យពេញ ហើយទើបទៅ ។

សូម្បីកាលទឹងទៅយ៉ាងនោះ គប្បីឱ្យភិក្ខុកម្លោះយួរនូវបាត្រ និងចីវរជាដើម ឱ្យជួយកន់បំពង់ប្រេង និងឈើច្រត់ជាដើម បាំងឆត្រកុំងាកខ្លួនទៅមកទ្វារស្រុកឡើយ, គួរទៅតាមខាងព្រៃដែលកំបាំង, កាលមកចូលព្រៃមិនមាន ក៏កុំសំរុកចូលគុម្ពឈើជាដើមទៅឡើយ ។

មួយទៀត គប្បីបំពេញគមិយវត្តកាត់វិតក្ក មានចិត្តផូរផង់ ទៅ

ដោយទំនៀមនៃការទៅប៉ុណ្ណោះ ។

តែបើមកមានមកទ្វារស្រុក, និងពួកអ្នកស្រុកឃើញខ្លួន និងបរិវារកំពុងទៅ នឹងចូលមករកដោយគិតថា "ថេរៈនោះ តាមមើលដូចជាព្រះថេរៈរបស់ពួកយើង" ហើយនឹងប្រាស្រ័យថា "លោកម្ចាស់ លោកជញ្ជូនបរិក្ខារទាំងអស់ទៅណា ?"

បើក្នុងពួកលោក ១ រូប ពោលយ៉ាងនេះថា "នេះជាវេលាជិតចូលវស្សាហើយ, ភិក្ខុទាំងឡាយ រមែងទៅក្នុងទីដែលខ្លួននឹងបានភិក្ខាចារជានិច្ច និងវត្ថុសម្រាប់បិទបាំងខាងក្នុងវស្សា" ។

បើអ្នកស្រុកទាំងនោះ បានស្ដាប់ពាក្យតបរបស់លោកហើយពោលថា "សូម្បីក្នុងស្រុកនេះជនរមែងបរិភោគ រមែងស្លៀក (ដូចគ្នា) ករុណា លោកម្ចាស់ កុំទៅក្នុងទីដទៃឡើយ" ដូច្នេះ ហើយឱ្យគេហៅមិត្តនិងអាមាត្យទាំងឡាយមកហើយ ជនទាំងអស់ប្រឹក្សាព្រមព្រៀងគ្នា តាំងនិច្ចភត្តនិងភត្តផ្សេង ៗ មានសលាកភត្តជាដើម ទាំងសំពត់ចំណាំវស្សាផង ទុកក្នុងសំណាក់ ហើយជួយគ្នាអង្វរថា "និមន្តចាំវស្សាក្នុងសំណាក់នេះឯង លោកម្ចាស់" ។ ភិក្ខុសមគួរត្រេកអរទាំងអស់, វត្ថុទាំងពួងមាននិច្ចភត្តជាដើមនោះ ជារបស់គួរនិងមិនមានទោសទេ ។

ចំណែកក្នុងកុរុន្ទីពន្យល់ថា កាលគេប្រាស្រ័យថា "លោកម្ចាស់ទៅណា ?" គប្បីប្រាប់ថា "ទីឯណោះ" ត្រូវគេសួរថា "ហេតុអ្វី ទើប

ទៅទីនោះ ?” គប្បីប្រាប់ហេតុ និងពាក្យទាំង ២ នេះឈ្មោះថា មិនមានទោស ព្រោះលោកជាអ្នកមានចិត្តបរិសុទ្ធិពិត ។ នេះឈ្មោះអាគន្តុកវត្ត ។

ចំណែកអាវាសិកវត្ត គប្បីជ្រាបដូច្នេះ ៖

ភិក្ខុទាំងឡាយជាម្ចាស់អាវាស គប្បីចាត់ចែងទីនៅជាមុននោះឯង គប្បីធ្វើការជួសជុលសេនាសនៈ ដែលទ្រុឌទ្រោមបាក់បែក និងការថែរក្សា ។ គប្បីចាត់ចែងស្ថានទាំងពួងនេះ គឺ ទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ វច្ចកុដិ និងទីបន្ទោបង់បស្សាវៈ ផ្ទះបំពេញសេចក្ដីព្យាយាម និងមកនៃទីលំនៅ ។

គប្បីធ្វើកិច្ចទាំងពួងសូម្បីនេះ គឺ លាបកំបោរសត្រង់ព្រះចេតិយ លាបប្រេងលើមុទ្ធវេទិកា និងជូតសំអាតគ្រែនិងតាំងដោយតាំងចិត្តថា “ភិក្ខុទាំងឡាយដែលប្រាថ្នានឹងចាំវស្សាមកហើយ កាលធ្វើកិច្ច មានឧទ្ទេសបរិបុច្ឆា និងប្រកបសេចក្ដីព្យាយាម ក្នុងកម្មដ្ឋានជាដើម នឹងនៅជាសុខ” ។

កាលម្ចាស់អាវាសធ្វើបរិកម្មសម្រេចហើយ ភិក្ខុនោះគប្បីសួរដល់សំពត់ចំណាំវស្សា ចាប់ផ្ដើមតាំងពីថ្ងៃ ៥ កើត ខែ អាសាឍ ។

គប្បីសួរក្នុងទីណា ?

គប្បីសួរក្នុងទីដែលខ្លួនបាននៅតាមប្រក្រតី តែមិនគួរនឹងសួរជនទាំងឡាយដែលមិនធ្លាប់ឱ្យ ។

ហេតុអ្វីទើបត្រូវសួរ ?

ពេលខ្លះជនទាំងឡាយក៏ប្រគេន, ពេលខ្លះពួកគេត្រូវទុព្ភិក្ខ ភ័យជាដើមបៀតបៀន រមែងមិនប្រគេន ; ក្នុងជនទាំងនោះ ពួកណា នឹងមិនប្រគេន, កាលមិនសួរពួកនោះហើយ ឱ្យគេកំណត់សំពត់ចំណាំវស្សាទៅអន្តរាយដល់លាភ និងមានដល់ពួកភិក្ខុដែលគេកំណត់ទុក ; ព្រោះហេតុនោះ គួរសួរមុនហើយ ទើបឱ្យគេកំណត់យកទៅ ។ កាលនឹងសួរ គប្បីពោលថា "វេលាកំណត់សំពត់ ចំណាំវស្សារបស់ពួកអ្នកជិតចូលមកហើយ" ។

បើគេពោលថា "លោកម្ចាស់ដ៏ចម្រើន រយៈពេលមួយឆ្នាំនេះ ពួកខ្ញុំព្រះករុណាត្រូវឆាតកភ័យ (ភ័យកើតអំពីការអត់ឃ្លាន) ជាដើមបៀតបៀន មិនអាចនិងប្រគេនបាន" ឬថា "ពួកខ្ញុំព្រះករុណានឹងប្រគេនតិចជាង ដែលធ្លាប់ប្រគេន" ឬថា "ឥឡូវនេះ ចំណែកបានល្អ, ខ្ញុំព្រះករុណានឹងប្រគេនឱ្យច្រើនជាងដែលធ្លាប់ប្រគេន" ដូច្នេះ ; ភិក្ខុគប្បីកំណត់ពាក្យនោះទុកហើយ ឱ្យភិក្ខុទាំងឡាយទទួលសំពត់ចាំវស្សា ក្នុងសេនាសនៈរបស់ជនទាំងនោះ តាមន័យដែលសមគួរដល់ពាក្យនោះ ។

បើគេពោលថា "សំពត់ចំណាំវស្សារបស់ពួកខ្ញុំព្រះករុណា ត្រូវបានលោកម្ចាស់អង្គណា, លោកម្ចាស់អង្គនោះ ចូរតាំងទឹកឆាន់ទុកចូរថែរក្សាមកជាទីលំនៅ ចូរបោសសំអាតលានចេតិយ និងលានពោធិព្រឹក្ស

ចូរស្រោចទឹកដើមពោធិព្រឹក្ស រហូតអស់ត្រៃមាស”, សំពត់ចំណាំវស្សារបស់គេ ត្រូវប្រគេនភិក្ខុណា, គប្បីប្រាប់ដល់ភិក្ខុនោះ ។ ចំណែកស្រុកណា ឆ្ងាយទៅនៅក្នុងរយៈ ១ យោជន៍ ឬ ២ យោជន៍ បើត្រកូលទាំងឡាយក្នុងស្រុកនោះ ប្រគល់ទ្រព្យជាដើម ទុកដើម្បីប្រគេនសំពត់ចំណាំវស្សាក្នុងទីនៅ ។ សូម្បីមិនសួរត្រកូលទាំងនោះ ក៏គួរឱ្យភិក្ខុដែលធ្វើវត្តនៅក្នុងសេនាសនៈរបស់ត្រកូលទាំងនោះ ទទួលសំពត់ចំណាំវស្សា ។

តែបើភិក្ខុដែលកាន់សំពត់បង្សុកូល នៅក្នុងសេនាសនៈរបស់ត្រកូលទាំងនោះ, គេទើងឃើញលោកមកហើយពោលថា “ខ្ញុំព្រះករុណាប្រគេនសំពត់ចំណាំវស្សាដល់លោកម្ចាស់” ។ ភិក្ខុនោះ គប្បីប្រាប់ដល់សង្ឃ ។

បើត្រកូលទាំងនោះ មិនប្រាថ្នាទឹងថ្វាយសង្ឃ ពោលថា “ពួកខ្ញុំព្រះករុណាប្រគេនចំពោះពួកលោកម្ចាស់” ។ ភិក្ខុដែលកាន់សំពត់បង្សុកូលនោះ គប្បីបង្គាប់ភិក្ខុដែលជាសភាគគ្នាថា “លោកចូរធ្វើវត្តហើយទទួលយកទៅ”, តែសំពត់ចំណាំវស្សានោះ មិនគួរដល់ភិក្ខុដែលកាន់សំពត់បង្សុកូល ។ គប្បីសួរជនទាំងឡាយ អ្នកប្រគេនដោយសទ្ធាទេយ្យដោយប្រការដូច្នេះ ។

ឯចីវរដែលកើតឡើងក្នុងសំណាក់នោះ គួរសួរគប្បិយការក ។ សួរយ៉ាងណា ?

គួរសួរថា “អ្នកមានអាយុ ភណ្ឌៈសម្រាប់បិទបាំង (គឺ សំពត់) របស់សង្ឃមានឬ ?”

បើគេពោលថា “មានលោកម្ចាស់ ខ្ញុំព្រះករុណានឹងប្រគេនសំពត់មួយរូប ៩ ហត្ថ សូមលោកម្ចាស់ទាំងឡាយឱ្យកំណត់សំពត់ចំណាំវស្សាចុះ” ដូច្នេះ ; គប្បីឱ្យភិក្ខុកាន់សេនាសនៈបាន ។ សូម្បីគេពោលថា “សំពត់មិនមាន តែវត្ថុមាន, សូមលោកម្ចាស់ឱ្យកំណត់ចុះ”, សូម្បីកាលមានវត្ថុ ក៏គួរឱ្យកាន់សេនាសនៈបានពិត, ព្រោះថា ព្រះមានព្រះភាគទ្រង់អនុញ្ញាតឱ្យភិក្ខុបរិភោគវត្ថុដែលជាកប្បិយទាំងពួង ដែលកើតអំពីវត្ថុដែលទាយកប្រគល់ទុកក្នុងដៃកប្បិយការក បន្ទាប់ថា “សូមលោកម្ចាស់ប្រើប្រាស់របស់ដែលគួរចុះ” ។

ចំណែកវត្ថុណា ទាយកប្រគេនចំពោះភិក្ខុ ក្នុងសំណាក់នេះដើម្បីប្រយោជន៍ដល់បិណ្ឌបាត ឬដើម្បីប្រយោជន៍ដល់គិលានប្បច្ច័យ, វត្ថុនោះ កាលភិក្ខុទាំងឡាយបង្អោនចូលក្នុងចីវរ គប្បីអបលោកនៈដើម្បីសេចក្ដីយល់ព្រមរបស់សង្ឃហើយ ទើបបង្អោន ។

វត្ថុដែលគេប្រគេនដើម្បីប្រយោជន៍ដល់សេនាសនៈ រមែងជាគរុភណ្ឌ ។

ចំណែកវត្ថុដែលគេប្រគេនទុកដើម្បីតម្លៃចីវរ ឬជាតម្លៃបច្ច័យ ៤

កាលនឹងបង្អោនចូលក្នុងចីវរ មិនមានកិច្ចដែលនឹងត្រូវធ្វើដោយអបលោកនកម្ម ។

ក៏ឯកាលនឹងធ្វើអបលោកនកម្ម គួរធ្វើឱ្យជាប់ដោយបុគ្គលប៉ុណ្ណោះ មិនគួរធ្វើឱ្យជាប់ដោយសង្ឃ មិនគួរធ្វើអបលោកនកម្ម សូម្បីជាប់ដោយមាសនិងប្រាក់ ឬជាប់ដោយអង្ករ ។ គួរធ្វើ តែជាប់ដោយអំណាចកប្បិយភណ្ឌៈ និងដោយអំណាចចីវរ និងអង្ករជាដើមប៉ុណ្ណោះ ។

ក៏ឯអបលោកនកម្មនោះ គប្បីធ្វើយ៉ាងនេះថា "ឥឡូវនេះភិក្ខាហាររកបានងាយ បិណ្ឌបាតបានងាយ, ភិក្ខុទាំងឡាយលំបាកដោយចីវរ, ភិក្ខុទាំងឡាយពេញចិត្ត នឹងបង្អោនចំណែកអង្ករប៉ុណ្ណោះធ្វើចីវរ ; គិលានបច្ច័យរកបានងាយ ។ មួយទៀត ភិក្ខុដែលអាពាធក៏មិនមាន, ភិក្ខុទាំងឡាយពេញចិត្ត នឹងបង្អោនចំណែកអង្ករប៉ុណ្ណោះធ្វើជាចីវរ" ។ កាលកំណត់ចីវរបច្ច័យយ៉ាងនេះហើយ គប្បីសន្មតភិក្ខុជាសេនាសនគាហាបកៈ ក្នុងកាលជាទីឱ្យកាន់សេនាសនៈបានប្រកាសហើយ សង្ឃប្រជុំគ្នាហើយ ។

ព្រះអដ្ឋកថាចារ្យពោលថា ក៏ឯកាលនឹងសន្មត មិនគួរសន្មតតែមួយរូប គប្បីសន្មត ២ រូប ។ ព្រោះថា កាលសន្មតយ៉ាងនោះ ភិក្ខុទីទី២នឹងឱ្យភិក្ខុចាស់កាន់សេនាសនៈ ភិក្ខុចាស់នឹងឱ្យភិក្ខុទី២កាន់ ដូច្នេះឯង ។

ចំណែកក្នុងសំណាក់ធំ ដូចមហាវិហារ គួរសន្មតទុក ៣-៤ រូប ។

តែក្នុងកុរុន្ទីពោលថា នឹងសន្មតទុក ៨ រូបខ្លះ ១៦ រូបខ្លះ ក៏គួរ ។ ការសន្មតភិក្ខុទាំងនោះ នឹងធ្វើដោយកម្មវាចាក៏បាន ដោយអបលោកនកម្មក៏បាន គួរទាំងអស់ ; ភិក្ខុដែលបានទទួលសន្មតហើយទាំងនោះ គប្បីកំណត់សេនាសនៈ ។

ក៏ព្រះចេតិយ រោងពោធិព្រឹក្ស រោងព្រះពុទ្ធរូប (ព្រះវិហារ) រានអំបោស រានរក្សាឈើ វច្ចកុដិ រោងឥដ្ឋ រោងជាងឈើ ស៊ុមទ្វារ រោងទឹក សាលាក្បែរមេក សាលាម៉ាត់ស្រះទាំងនេះ មិនមែនជាសេនាសនៈ ។

កុដិជាលំនៅ ផ្ទះប្រក់ដំបូលតែមួយ ប្រាសាទ ផ្ទះត្រង៉ោលល្អាងមណ្ឌបគល់ឈើ គុម្ពឫស្សី ទាំងនេះ ចាត់ជាសេនាសនៈ ។ ព្រោះដូច្នោះ គួរឱ្យកាន់សេនាសនៈទាំងនោះ ។ កាលនឹងឱ្យកាន់គប្បីឱ្យកាន់តាមន័យដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងបាលីនេះថា "តថាគតអនុញ្ញាតឱ្យ (ភិក្ខុជាសេនាសនគាហាបកៈ) រាប់ភិក្ខុមុន លុះរាប់ភិក្ខុរួចហើយ ឱ្យរាប់ដំណេក លុះរាប់ដំណេករួចហើយ សឹមប្រគល់ឱ្យតាមកំណត់នៃដំណេក"[១] ។

ចីវរប្បច្ច័យមាន ២ ប្រភេទ គឺ ជារបស់សង្ឃ ១ ជារបស់

១. វិន. ចុល្ល. សេនាសនក្ខន្ធក. ១០. ៣៨៩/៣២៩ ។

ទាយកថ្វាយដោយសទ្ធា ១ ។ ក្នុង២ ប្រភេទនោះ ភិក្ខុទាំងឡាយប្រាថ្នានឹងកាន់ប្រភេទណាមុន គប្បីឱ្យកាន់យកប្រភេទនោះ ហើយគប្បីឱ្យកាន់យកប្រភេទក្រៅនេះ តាំងពីដើមលំដាប់នៃប្រភេទសូម្បីនោះទៅ ។

ព្រះមហាសុមត្ថេរៈពោលថា “កាលបើភិក្ខុជាសេនាសនគាហាបកៈនឹងឱ្យភិក្ខុកាន់សេនាសនៈដោយចំនួនបរិវេណ” ព្រោះមានភិក្ខុតិចបរិវេណទីមួយមានលាភច្រើន, ភិក្ខុដែលនៅ បានត្រៃចីវរ ១០ ឬ ១២ សម្រាប់ ; គប្បីបែងចែកចីវរនោះ ទៅក្នុងអាវាសដទៃ ៗ ដែលមិនមានលាភ ឱ្យភិក្ខុទាំងឡាយ សូម្បីពួកដទៃកាន់យកក៏បាន ។

ចំណែកព្រះមហាបទុមត្ថេរៈពោលថា មិនគួរធ្វើយ៉ាងនោះ ដែលជនទាំងឡាយថ្វាយបច្ច័យ ក៏ដើម្បីប្រយោជន៍ដល់ការទំនុកបម្រុងអាវាសរបស់ខ្លួន ; ព្រោះដូច្នោះ ភិក្ខុពួកដទៃគប្បីចូលទៅក្នុងបរិវេណ ដែលមានលាភច្រើននោះ ។ តែបើព្រះមហាថេរៈនៅក្នុងបរិវេណដែលមានលាភច្រើននោះ ជំទាស់ថា “អ្នកមានអាយុ លោកចូរកុំឱ្យភិក្ខុទាំងឡាយកន់យកយ៉ាងនោះ, ចូរធ្វើតាមពាក្យដែលព្រះមានព្រះភាគទ្រង់អនុសាសន៍ទុក”; ពិតមែន ព្រះមានព្រះភាគបានត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឱ្យប្រគល់តាមកំណត់បរិវេណ”[១] ភិក្ខុជា

---

១ វិន. ចុល្ល. សេនាសនក្ខន្ធក. ១០. ៣៨៩/៣២៩ ។

សេនាសនគាហាបកៈ មិនគួរវៀរ ព្រោះពាក្យជំទាស់របស់ព្រះមហាថេរៈនោះ គប្បីពោលថា "លោកដ៏ចម្រើន ភិក្ខុមានច្រើន បច្ច័យមានតិច គួរធ្វើសេចក្ដីសង្គ្រោះ ញុំាងលោកឱ្យត្រេកអរហើយ គប្បីឱ្យភិក្ខុទាំងឡាយកាន់យកតែម្ដង" ។

ក៏ឯភិក្ខុដែលបានទទួលសន្មតហើយ កាលនឹងឱ្យកាន់យក គប្បីទៅរកព្រះមហាថេរៈហើយពោលយ៉ាងនេះថា "លោកម្ចាស់ដ៏ចម្រើន សេនាសនៈត្រូវបានដល់លោកម្ចាស់, សូមលោកម្ចាស់កាន់យកបច្ច័យចុះ" ។ លោកពោលថា "អ្នកមានអាយុ បច្ច័យរបស់ត្រកូលឯណោះ និងសេនាសនៈឯណោះ ត្រូវបានមកយើងឬ ?" គប្បីពោលថា "ករុណាត្រូវបានលោកម្ចាស់, សូមលោកម្ចាស់កាន់យកសេនាសនៈនោះ" ។ លោកពោលថា "អ្នកមានអាយុ យើងនឹងកាន់យក" ។ យ៉ាងនេះ សេនាសនៈជាការលោកកាន់យកហើយ ។

ព្រះមហាសុមត្ថេរៈពោលថា តែបើកាលភិក្ខុជាសេនាសនគាហាបកៈពោលថា "លោកម្ចាស់ដ៏ចម្រើន សេនាសនៈលោកម្ចាស់កាន់យកហើយឬ ?" ព្រះមហាថេរៈពោលថា "យើងកាន់យកហើយ" ឬកាលភិក្ខុជាសេនាសនគាហាបកៈពោលថា "លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់នឹងកាន់យកឬ ?" ព្រះមហាថេរៈឆ្លើយថា "យើងនឹងកាន់យក" ដូច្នេះ មិនឈ្មោះថា កាន់សេនាសនៈទេ ។

ចំណែកព្រះមហាបទុមត្ថេរៈពោលថា ពាក្យជាអតីត និងអនាគត ឬពាក្យជាបច្ចុប្បន្នក៏ដោយ ។ ការពិត ពាក្យសំដីត្រឹមតែធ្វើឱ្យមានសតិ ត្រឹមតែជាគ្រឿងធ្វើអាល័យប៉ុណ្ណោះ ជាប្រមាណក្នុងការកាន់សេនាសនៈនេះ ; ព្រោះហេតុនោះ ព្រះមហាថេរៈ ឈ្មោះថា កាន់យកសេនាសនៈហើយពិត ។

ចំណែកភិក្ខុដែលកាន់សំពត់បង្សុកូលណា កាន់សេនាសនៈហើយលះបង់បច្ច័យចេញ ។ សូម្បីបច្ច័យដែលភិក្ខុនោះ លះបង់ហើយនេះ មិនគប្បីបង្អោនទៅក្នុងអាវាសដទៃ ; គប្បីទុកដាក់ក្នុងអាវាសនោះឯង ។ នឹងឱ្យភិក្ខុដទៃដែលនៅក្នុងរោងភ្លើង ឬក្នុងសាលាវែង ឬក្រោមម្លប់ឈើក្នុងបរិវេណនោះឯងកាន់យកក៏គួរ ។

ភិក្ខុដែលកាន់សំពត់បង្សុកូលទទួលថា “នឹងនៅ ហើយនឹងថែទាំសេនាសនៈ” ។ ភិក្ខុក្រៅនេះទទួលថា “នឹងកាន់យកបច្ច័យ ហើយថែទាំសេនាសនៈ” ។ សេនាសនៈជាការបានទទួលថែទាំយ៉ាងល្អ ដោយហេតុ ២ ប្រការ ដោយប្រការដូច្នេះ ។

តែក្នុងមហាបច្ចរីពោលថា កាលភិក្ខុកាន់សំពត់បង្សុកូលទទួលសេនាសនៈ ដើម្បីនៅ សេនាសនគាហាបកភិក្ខុគប្បីពោលថា “ក្នុងសេនាសនៈនេះមានបច្ច័យ លោកម្ចាស់, បច្ច័យនោះគួរធ្វើយ៉ាងណា ?” ភិក្ខុដែលកាន់សំពត់បង្សុកូលនោះ គប្បីពោលថា “ខាងក្រោយ សូម

លោកម្ចាស់ឱ្យភិក្ខុដទៃកាន់យកចុះ” ។

បើលោកនៅតែមិននិយាយអ្វីសោះ, ទាយកទាំងឡាយ ប្រគេនសំពត់ ទុកដាក់ទៀបជើងរបស់លោកដែលចាំវស្សាហើយ ក្នុងសេនាសនៈនោះ, សំពត់នោះ គួរដល់លោក ។

បើទាយកពោលថា “ខ្ញុំព្រះករុណាប្រគេនសំពត់ចំណាំវស្សា” សំពត់នោះ រមែងបានភិក្ខុទាំងឡាយ ដែលចាំវស្សាក្នុងសេនាសនៈនោះ ។

ចំណែកទាយកពួកណា មិនមានសេនាសនៈ, ប្រគេនបច្ច័យតែម្យ៉ាង សមគួរឱ្យភិក្ខុដែលចាំវស្សាក្នុងសេនាសនៈ ដែលមិនមានសំពត់ចំណាំវស្សា ទទួលបច្ច័យរបស់ទាយកទាំងនោះ ។ ជនទាំងឡាយសាងសថូបហើយ ឱ្យភិក្ខុទទួលសំពត់ចំណាំវស្សា ។ ធម្មតាសថូបមិនមែនសេនាសនៈ, គប្បីប្រគល់ឱ្យភិក្ខុដែលចាំវស្សាត្រង់ដើមឈើ ឬមណ្ឌបដែលនៅជិតសថូបនោះទទួលទៅ ។

ភិក្ខុនោះ គប្បីប្រណិបត្តិចេតិយ ។ សូម្បីក្នុងដើមពោធិព្រឹក្ស រោងពោធិព្រឹក្ស រោងព្រះពុទ្ធរូប (ព្រះវិហារ) រោងឈើអំបោស រោងរក្សាឈើ វច្ចកុដិ ស៊ុមទ្វារ កុដិទឹក រោងទឹក និងរោងឈើពួតភ្លើង ក៏មានន័យដូចគ្នា ។

ចំណែករោងឆាន់ ជាសេនាសនៈពិត, ព្រោះហេតុនោះ សមគួរ

កំណត់ឱ្យភិក្ខុមួយរូប ឬច្រើនរូបកាន់រពេងឆាន់ដូច្នោះ ។ ពាក្យទាំងពួងនេះលោកពោលពិស្តារក្នុងមហាបច្ចរី ។

ភិក្ខុជាសេនាសនគាហាបកៈ គប្បីឱ្យភិក្ខុទាំងឡាយ កាន់សេនាសនៈតាំងពីអរុណនៃថ្ងៃបាដិបទ(១) ទៅដរាបដល់អរុណថ្មី មិនទាន់បែក ។

ពិតមែន សេចក្តីកំណត់កាលនេះ ជាខេត្រដែននៃការកាន់សេនាសនៈ ។

បើថា កាលឱ្យភិក្ខុទាំងឡាយកន់សេនាសនៈអំពីព្រឹក ភិក្ខុដទៃអ្នកមានចិត្តរាវរែកមកសូមសេនាសនៈ ។ ភិក្ខុសេនាសនគាហាបកៈគប្បីប្រាប់ថា "លោកម្ចាស់ដ៏ចម្រើន សេនាសនៈកាន់ស្រេចហើយ សង្ឃចូលវស្សាហើយ វិហារជាទីត្រួវរីករាយ បណ្តាទីផ្សេង ៗ មានគល់ឈើជាដើម លោកម្ចាស់ប្រាថ្នាទីធំនៅក្នុងទីណា ចូរនៅក្នុងទីនោះចុះ ។

ភិក្ខុទាំងឡាយអ្នកចូលវស្សា គប្បីប្រាប់ភិក្ខុទាំងឡាយ អ្នកតាំងវត្តប្រចាំខាងក្នុងវស្សាហើយចាំវស្សាថា "លោកទាំងឡាយចូរចងអំបោសទុក" ។ បើដងនិងផ្តិងជារបស់រកបានងាយ; គួរចងអំបោសទុកមួយអន្លើ ៥-៦ បាច់ ឬចងអំបោសទុកមួយអន្លើ ២-៣ បាច់ ។ បើជារបស់រក

---

១. ថ្ងៃ ១រោច នៃខែនោះ ៗ រាប់ជាថ្ងៃដើមខែរបស់អ្នកមគធ ព្រោះរាប់ថ្ងៃ ពេញបូណ៌មីជាថ្ងៃ អស់ខែ ។

បានលំបាក គប្បីចងអំបោសទុកមួយអន្លង់ ២-៣ បាច់ ឬចងអំបោសទុកមួយអន្លង់ ១ បាច់ សាមណេរទាំងឡាយ គប្បីចងរុំគប់ភ្លើងទុក ៥-៦ បាច់ ។ គប្បីធ្វើការប្រោះព្រំដោយទឹកអម្ពត់ក្នុងស្ថានទីនោះ ។

ក៏កាលនឹងតាំងវត្ត មិនគប្បីតាំងវត្តដែលមិនជាធម៌បែបនេះថា "កុំរៀនខ្លួនឯង កុំឱ្យអ្នកដទៃរៀន កុំធ្វើការសាធ្យាយ កុំឱ្យបព្វជ្ជា កុំឱ្យឧបសម្បទា កុំឱ្យនិស្ស័យ កុំធ្វើធម្មស្សវនៈ ព្រោះថា ពួកយើងទាំងអស់នេះ ជាអ្នកនៅមានធម៌ជាគ្រឿងយឺតយូរ នឹងជាអ្នកមិនមានធម៌ជាគ្រឿងយឺតយូរ ធ្វើសមណធម៌ប៉ុណ្ណោះ" ឬថា "ភិក្ខុគ្រប់រូបចូរសមាទានធុតង្គ ១៣ កុំសម្រេចការដេក ចូរឱ្យយប់ និងថ្ងៃកន្លងទៅ ដោយការឈរនិងចង្រ្កម ចូរកាន់មូគវត្ត (ប្រព្រឹត្តដូចមនុស្សគ) សូម្បីត្រូវទៅដោយសត្តាហករណីយ៍ កុំបានភណ្ឌៈដែលសង្ឃគួរចែក" ។

តែគប្បីធ្វើយ៉ាងនេះ គឺ គប្បីធ្វើវត្តបែបនេះថា "ធម្មតាបរិយត្តិធម៌ រមែងញ៉ាំងសទ្ធម្មសូម្បី ៣ យ៉ាងឱ្យតាំងមាំ ព្រោះហេតុនោះ លោកទាំងឡាយចូររៀនបាលី ចូរឱ្យរៀនបាលីដោយគោរព ចូរសាធ្យាយដោយគោរព កុំប្រៀតបៀតភិក្ខុទាំងឡាយ អ្នកនៅក្នុងផ្ទះបំពេញព្យាយាម ចូរអង្គុយខាងក្នុងសំណាក់ រៀនបាលី ឱ្យរៀនបាលី ធ្វើការសាធ្យាយ ចូរធ្វើការស្តាប់ធម៌ឱ្យសម្រេច កាលឱ្យបព្វជ្ជា ត្រូវជម្រះឱ្យរៀបរយហើយទើបឱ្យបព្វជ្ជា កាលឧបសម្បទាត្រូវជម្រះឱ្យរៀបរយហើយទើបឱ្យ

ឧបសម្បទា កាលឱ្យនិស្ស័យត្រូវជម្រះឱ្យរៀបរយហើយ ទើបឱ្យនិស្ស័យ ព្រោះថា កុលបុត្រសូម្បីតែម្នាក់បានបព្វជ្ជា និងឧបសម្បទាហើយ នឹងតម្រង់ព្រះសាសនាទាំងមូលទុកបាន ចូរសមាទានធុតង្គ តាមសមត្ថភាពដែលអាចសមាទានបាន ដោយកម្លាំងរបស់ខ្លួន, ដែលឈ្មោះថា រហូតអស់ខាងក្នុងព្រះវស្សានេះ ត្រូវជាអ្នកមិនប្រមាទ ត្រូវប្រារព្ធសេចក្តីព្យាយាម រហូតអស់ថ្ងៃ និងក្នុងបឋមយាម និងបច្ឆិមយាមនៃរាត្រី, សូម្បីព្រះមហាថេរៈទាំងឡាយចាស់ ៗ ជំនន់មុន ក៏បានកាត់កង្វល់គ្រប់យ៉ាងចេញ បំពេញវត្ត គឺ កម្មដ្ឋានភាវនា ដែលនឹងគប្បីប្រព្រឹត្តតែម្នាក់ឯងក្នុងព្រះវស្សា ។ សមគួរដឹងប្រមាណក្នុងពាក្យដែលត្រូវពោល ធ្វើកថាវត្ថុ ១០ អសុភៈ ១០ អនុស្សតិ ១០ និងកថាប្រារព្ធអារម្មណ៍ ៣៨ ។ សមគួរធ្វើវត្តដល់ពួកភិក្ខុអាគន្តុកៈ, សមគួរអបលោកន៍ឱ្យដល់ភិក្ខុទាំងឡាយដែលទៅដោយសត្តាហករណីយ៍ ។

មួយទៀត គប្បីដាស់តឿនភិក្ខុទាំងឡាយថា "កុំពោលពាក្យទាស់ទែង និងពាក្យសិកសៀត និងពាក្យគ្រោតគ្រាត, ត្រូវទឹកដល់សីលរាល់ ៗថ្ងៃ កុំឱ្យអារក្ខកម្មដ្ឋាន ៤ សាបសូន្យ ចូរជាអ្នកច្រើនដោយមនសិការ" ។

គប្បីប្រាប់ទំនៀមទំពារឈើស្ទន់ គប្បីប្រាប់វត្ត គឺមារយាទ ។

កាលកំពុងថ្វាយបង្គំព្រះចេតិយ ឬដើមពោធិព្រឹក្សក្តី កាលកំពុង

បូជាដោយរបស់ក្រអូប និងកម្រងផ្កាក្តី កាលកំពុងយកបាត្រប្រកចូលស្លោកក្តី មិនគួរប្រាប់ ។

គប្បីប្រាប់ទំនៀមត្រាច់បិណ្ឌបាត កុំពោលពាក្យទាក់ទិនដល់បច្ច័យ ឬពាក្យមិនត្រូវគ្នា នឹងជនទាំងឡាយខាងក្នុងស្រុក ។

គប្បីប្រាប់និយ្យានិកកថាសូម្បីច្រើនបែបនេះខ្លះថា "ត្រូវជាអ្នកប្រុងប្រយ័ត្នឥន្ទ្រិយ ត្រូវបំពេញខន្ធកវត្ត និងសេខិយវត្ត" ដូច្នេះឯង ។ មួយទៀត ក្នុងថ្ងៃចូលវស្សាក្រោយ និងកាលប្រកាសវេលាសង្ឃប្រជុំគ្នាហើយ អ្នកណា ៗ នាំសំពត់ប្រវែង ១២ ហត្ថ មកប្រគេនជាសំពត់ចំណាំវស្សា បើថា ភិក្ខុអាគន្តុកៈជាសង្ឃត្ថេរៈ គប្បីប្រគេនដល់លោក ។

បើជានវកៈ ភិក្ខុដែលបានទទួលសន្ទត គប្បីទូលព្រះសង្ឃត្ថេរៈថា "លោកម្ចាស់ដ៏ចម្រើន បើលោកម្ចាស់ត្រូវការ សូមលោកម្ចាស់លះបង់ចំណែកទី ១ ចេញ កាន់យកសំពត់នេះ" ; មិនគប្បីឱ្យដល់លោកដែលមិនព្រមលះបង់ ។

ក៏បើថា លោកព្រមលះបង់ចំណែកដែលឱ្យកាន់យកមុនហើយកាន់យកសោត គប្បីផ្លាស់ប្តូរគ្នា ចាប់ផ្តើមតាំងពីព្រះថេរៈទី ២ ទៅដោយឧបាយនេះឯង ហើយឱ្យដល់អាគន្តុកៈ ក្នុងទីដែលចូលមកដល់ ។

បើថា ភិក្ខុទាំងឡាយអ្នកចាំវស្សាមុន បានសំពត់ ២ ផ្ទាំង ឬ ៣

ផ្ទាំងឬ ៤ ផ្ទាំង ឬ ៥ ផ្ទាំង ។ គប្បីឱ្យលោកព្រមលះបង់សំពត់ដែលបានទៅហើយ ៗ ដោយឧបាយនោះហើយ ទើបឱ្យភិក្ខុអាគន្តុកៈ ជរាបទាល់តែស្មើគ្នា ។

ក៏ឯកាលភិក្ខុអាគន្តុកៈនោះ បានចំណែកស្មើគ្នាហើយ ចំណែកដ៏សេស គប្បីថែមឱ្យក្នុងថេរាសនៈ ។

សមគួរនឹងធ្វើកតិកាគ្នាទុកថា "កាលលាភកើតឡើងហើយ នឹងពេញចិត្តចែកគ្នាតាមលំដាប់ដែលមាន" ។

បើជាសម័យដែលមានភិក្ខាខ្វះខាត ភិក្ខុទាំងឡាយដែលចូលវស្សាក្នុងវស្សូបនាយិកាទាំង ២ លំបាកដោយភិក្ខា ទើបនិយាយគ្នាថា "លោកមានអាយុ ក៏ពួកយើងនៅក្នុងទីនេះ រមែងលំបាកទាំងអស់គ្នា, ល្អណាស់យើងបែងចែកគ្នាជា ២ ចំណែក ។ ទីនៃញាតិ និងជនបវារណា របស់ភិក្ខុពួកណាមាន ភិក្ខុទាំងនោះ ចូរនៅក្នុងទីនៃញាតិ និងជនបវារណានោះហើយចូរមកបវារណា កាន់យកសំពត់ចំណាំវស្សាដែលត្រូវបានដល់ខ្លួន" ។

ក្នុងភិក្ខុទាំងនោះ ភិក្ខុពួកណា នៅក្នុងទីនៃញាតិ និងជនបវារណានោះហើយ មកដើម្បីបវារណា, គប្បីធ្វើអបលោកនកម្មឱ្យសំពត់ចំណាំវស្សាដល់ភិក្ខុទាំងនោះ ។

ពិតមែន ភិក្ខុទាំងនោះ សូម្បីត្រេកអរក៏មិនបានជាម្ចាស់របស់នៃសំពត់ចំណាំវស្សាហើយមកដើម្បីបវារណា, គប្បីធ្វើអបលោកនកម្មឱ្យ

សំពត់ចំណាំវស្សាដល់ភិក្ខុទាំងនោះ ។

ពិតមែន ភិក្ខុទាំងនោះ សូម្បីត្រេកអរក៏មិនបានជាម្ចាស់នៃសំពត់ចំណាំវស្សាទេ ចំណែកពួកអាវាសិកភិក្ខុ សូម្បីពោលថា "ទឹងមិនឱ្យ" រមែងមិនបានដូចគ្នា ។

តែក្នុងកុរុន្ទីពន្យល់ថា ភិក្ខុទាំងឡាយនឹងគប្បីធ្វើកតិកាវត្តថា "បើថា យាគូនិងភត្តក្នុងទីនេះ នឹងមិនគ្រប់គ្រាន់ដល់ពួកយើងទាំងអស់គ្នាទេ, លោកទាំងឡាយ ចូរនៅក្នុងទីនៃភិក្ខុដែលជាសភាគគ្នា ហើយចូរមក, នឹងបានសំពត់ចាំវស្សា ដែលត្រូវបានដល់ពួកលោក" ។ បើភិក្ខុមួយរូបជំទាស់កតិកាវត្តនោះសោត, ជាការជំទាស់ប្រពៃ ។ បើមិនជំទាស់កតិកាជាការធ្វើប្រពៃ ; ខាងក្រោយត្រូវអបលោកន៍ឱ្យដល់ភិក្ខុទាំងនោះអ្នកនៅក្នុងទីនៃញាតិ និងជនបវារណាហើយមក, ក្នុងវេលាអបលោកនៈមិនបានឱ្យជំទាស់ ។

លោកពោលទៀតថា ក៏បើថា ភិក្ខុពួកខ្លះ មិនបានសំពត់ចំណាំវស្សា ក្នុងបណ្តាភិក្ខុដែលចាំវស្សា, ភិក្ខុទាំងឡាយគប្បីធ្វើកតិកាថា "សង្ឃត្រេកអរទឹងឱ្យសំពត់ចំណាំវស្សារបស់ភិក្ខុដែលដាច់វស្សា និងសំពត់ចំណាំវស្សា ដែលកើតឡើង ក្នុងឥឡូវនេះ ដល់ភិក្ខុទាំងនេះ" ។ កាលបានតាំងកតិកាទុកយ៉ាងនេះហើយ សំពត់ចំណាំវស្សា រមែងដូចជាបានឱ្យពួកលោកកាន់យកហើយដូចគ្នា; ទាំងត្រូវឱ្យសំពត់ដែលកើតឡើង

ហើយ ៗ ដល់ពួកលោកផង ។ ភិក្ខុដែលចាត់ចែងទឹកឆាន់ បោសសំអាត មកទៅវិហារ ទីលានចេតិយ និងទីលានពោធិព្រឹក្សជាដើម ស្រោចទឹកដើមពោធិព្រឹក្ស រហូតអស់ត្រៃមាសហើយជៀសចេញទៅក្តី លាសិក្ខាក្តី គង់បានសំពត់ចំណាំវស្សាដូចគ្នា ។ ព្រោះសំពត់ចាំវស្សានោះ ដែលភិក្ខុនោះ បានហើយដូចធ្វើឱ្យជាតម្លៃឈ្នួល ។

អាចារ្យពួកខ្លះពោលថា ចំណែកសំពត់ចំណាំវស្សាដែលជារបស់សង្ឃដែលធ្វើអបលោកនកម្មហើយចែកគ្នា សូម្បីភិក្ខុលាសិក្ខាខាងក្នុងវស្សា រមែងបានដូចគ្នា តែមិនបានឱ្យកាន់យកដោយអំណាចបច្ច័យ ។

បើថា ភិក្ខុដែលចាំវស្សាស្រេចហើយ ត្រៀមនឹងទៅកាន់ទិសបានកាន់យកវត្ថុជាកប្បិយភណ្ឌខ្លះ អំពីដៃរបស់ភិក្ខុដែលនៅក្នុងអាវាសហើយប្រាប់ថា "សំពត់ចំណាំវស្សារបស់យើងមានក្នុងត្រកូលឯណោះ ចូរលោកកាន់យកសំពត់ចំណាំវស្សានោះដែលដល់ហើយ" ដូច្នេះហើយលាសិក្ខាបទក្នុងទីដែលខ្លួនទៅហើយ ។ សំពត់ចំណាំវស្សា រមែងជារបស់សង្ឃ តែបើភិក្ខុនោះ ឱ្យនាំពួកអ្នកស្រុកទទួលរងចំពោះមុខហើយទើបទៅ ភិក្ខុដែលនៅក្នុងអាវាស រមែងបាន ។

កាលទាយកបង្គាប់ទុកថា "ខ្ញុំព្រះករុណាទាំងឡាយ ប្រគេនសំពត់ចំណាំវស្សានេះ ដល់ភិក្ខុអ្នកចាំវស្សាហើយ ក្នុងសេនាសនៈរបស់ពួកខ្ញុំព្រះករុណា", សេនាសនៈនោះ ដែលសេនាសនៈគាហាបកៈឱ្យភិក្ខុណា

កាន់យក, រមែងជារបស់ភិក្ខុនោះឯង ។

ក៏បើថា បុត្រនិងធីតាជាដើមរបស់ម្ចាស់នៃសេនាសនៈ នាំសំពត់ជាច្រើនមកពោលថា "លោកម្ចាស់ទាំងឡាយចូរឱ្យក្នុងសេនាសនៈរបស់ពួកខ្ញុំព្រះករុណា" ដូច្នេះ ដើម្បីត្រូវការនឹងឱ្យជាទីពេញចិត្តរបស់ម្ចាស់សេនាសនៈ សម្រាប់ភិក្ខុដែលចាំវស្សាក្នុងសេនាសនៈនោះ គប្បីឱ្យតែមួយផ្ទាំងប៉ុណ្ណោះ, សំពត់ដ៏សេសជារបស់សង្ឃ, គប្បីឱ្យភិក្ខុទាំងឡាយកាន់តាមលំដាប់សំពត់ចំណាំវស្សា ។ កាលលំដាប់មិនមាន គប្បីឱ្យកាន់យកតាំងពីថេរាសនៈចុះមក ។

សូម្បីក្នុងសំពត់ចាំវស្សា ដែលទាយកនាំសំពត់មកច្រើនដោយចិត្តជ្រះថ្លា ដែលអាស្រ័យភិក្ខុអ្នកចាំវស្សា ក្នុងសេនាសនៈនុ៎ះឯង កើតឡើងហើយពោលថា "ខ្ញុំព្រះករុណាថ្វាយដល់សេនាសនៈ" ដូច្នេះ ក៏មានន័យដូចគ្នា ។

ក៏បើថា ទាយកដាក់ទុកទៀបជើងហើយពោលថា "ខ្ញុំព្រះករុណាប្រគេនដល់ភិក្ខុនោះ"; សំពត់ទាំងអស់ រមែងជារបស់ភិក្ខុនោះប៉ុណ្ណោះ ។

ក្នុងផ្ទះរបស់ទាយកម្នាក់ មានសំពត់ចំណាំវស្សា ២ ផ្ទាំង ចំណែកទី ១ ជារបស់ដែលឱ្យសាមណេរកាន់យកហើយ ចំណែកទី ២ ត្រូវឱ្យក្នុងថេរាសនៈ ។

ទាយកនោះបញ្ជូនសំពត់សាដក ១០ ហត្ថ មួយផ្ទាំង, ៨ ហត្ថមួយផ្ទាំង, មកថា "លោកម្ចាស់ចូរប្រគេនសំពត់ចំណាំវស្សាដែលដល់ហើយ ដល់ភិក្ខុទាំងឡាយ" ។ គប្បីជ្រើសរើសឱ្យចំណែកល្អដល់សាមណេរ ហើយឱ្យចំណែកបន្ទាប់ក្នុងថេរាសនៈ ។

តែបើគេនាំទៅផ្ទះទាំង ២រូប ឱ្យឆាន់ហើយ ដាក់ទុកទៀបជើងខ្លួនឯងតែម្តង; ផ្ទាំងណាគេប្រគេនហើយដល់ភិក្ខុរូបណា ផ្ទាំងនោះឯង រមែងជារបស់ភិក្ខុរូបនោះ តពីនេះទៅ ជាន័យដែលមកហើយក្នុងមហាបច្ចរី ។

សំពត់ចំណាំវស្សាក្នុងផ្ទះនៃទាយកម្នាក់ ត្រូវបានដល់សាមណេរកម្មោះ ។

បើគេសួរថា "សំពត់ចំណាំវស្សារបស់ខ្ញុំព្រះករុណា ត្រូវដល់អង្គណា ?" កុំប្រាប់ថា "ត្រូវបានដល់សាមណេរ", គប្បីប្រាប់ថា "លោកនឹងជ្រាបក្នុងវេលាប្រគេនហើយ" ក្នុងថ្ងៃប្រគេនគប្បីបញ្ជូនព្រះមហាថេរៈមួយរូបទៅនាំយកមក[១] ។

បើថា សំពត់ចំណាំវស្សាត្រូវបានដល់អង្គណា, អង្គនោះលាសិក្ខាចេញ ឬមរណភាពទៅ, អ្នកស្រុកគេសួរថា "សំពត់ចំណាំវស្សារបស់ពួកខ្ញុំព្រះករុណា ត្រូវបានដល់អង្គណា", គប្បីប្រាប់ដល់គេតាមពិត ។

---

១. ធ្វើយ៉ាងនេះ មិនមែនជាឧជុបដិបន្នោទេដឹង ?

បើគេពោលថា "ខ្ញុំព្រះករុណាប្រគេនដល់លោក" ; សំពត់នោះរមែងត្រូវបានដល់ភិក្ខុនោះ ។

បើគេថ្វាយដល់សង្ឃឬដល់គណៈ, ក៏ត្រូវបានដល់សង្ឃឬដល់គណៈ ។

បើថា ភិក្ខុទាំងឡាយអ្នកចាំវស្សា ជាអ្នកទ្រទ្រង់សំពត់បង្សុកូលសុទ្ធទាំងនោះ ; សំពត់ចំណាំវស្សាដែលគេនាំមកប្រគេនហើយ គប្បីធ្វើឱ្យជាសេនាសនបរិក្ខាររក្សាទុក, ឬគប្បីធ្វើឱ្យជាខ្នើយជាដើមចុះ ដូច្នេះឯង ។ នេះជាវត្តសម្រាប់ភិក្ខុម្ចាស់ទីកន្លែង ។

សេនាសនគាហវិនិច្ឆ័យ ចប់

## ការកាន់សេនាសនៈរម្ងាប់

[៣៩៣] វិនិច្ឆ័យក្នុងរឿងព្រះឧបនន្ទៈ ។ ក្នុងពាក្យថា តត្ថ តយា មោឃបុរិស គហិតំ, ឥធ មុត្តំ, ឥធ គហិតំ, តត្រ មុត្តំ : ម្នាលមោឃបុរស (បើ)អ្នកទទួលយកសេនាសនៈក្នុងទីនោះហើយ មានតែលែងទទួលយកក្នុងទីនេះ (បើ)អ្នកទទួលយកក្នុងទីនេះហើយ មានតែលែងទទួលយកក្នុងទីនោះ នេះ គប្បីជ្រាបដូច្នេះ ៖

សេនាសនៈណាក្នុងក្រុងសាវត្ថីនោះ ដែលលោកកាន់យកហើយ សេនាសនៈនោះ ឈ្មោះថា លោកអ្នកកាន់យកនុ៎ះឯង លះបង់ចេញហើយក្នុងគាមកាវាសនេះ ។

មួយទៀត កាលលោកពោលថា "អ្នកមានអាយុ ឥឡូវនេះ យើងលះបង់សេនាសនៈក្នុងគាមកាវាសនេះ" ដូច្នេះ សេនាសនៈនោះ ឈ្មោះថា លោកលះបង់ហើយ សូម្បីក្នុងគាមកាវាសនោះ ដោយប្រការយ៉ាងនេះ លោកជាអ្នកនៅខាងក្រៅ នៃអាវាសទាំង ២ ។

ចំណែកវិនិច្ឆ័យក្នុងពាក្យនេះ គប្បីជ្រាបដូច្នេះ ៖

ការកាន់ រមែងរម្ងាប់ព្រោះការកាន់ ។ អាល័យ រមែងរម្ងាប់ព្រោះការកាន់ ។ ការកាន់ រមែងរម្ងាប់ព្រោះអាល័យ ។ អាល័យ រមែងរម្ងាប់ព្រោះអាល័យ ។

តើយ៉ាងណា ? ភិក្ខុរូបខ្លះក្នុងសាសនានេះ កាន់សេនាសនៈ ក្នុងវត្តមួយហើយទៅកាន់វត្តជិតខាង កាន់សេនាសនៈក្នុងវត្តនោះទៀត ក្នុងថ្ងៃចូលវស្សា, ការកាន់គ្រាដំបូងរបស់ភិក្ខុនោះ រមែងរម្ងាប់ព្រោះការកាន់ (គ្រាក្រោយ) នេះ ។

ភិក្ខុមួយរូបទៀតធ្វើត្រឹមតែអាល័យថា "យើងនឹងនៅក្នុងវត្តនេះ" ហើយទៅកាន់វត្តជិតខាង កាន់សេនាសនៈក្នុងវត្តនោះឯង ។ អាល័យ

ដែលមានមុនរបស់ភិក្ខុនោះ រមែងរម្ងាប់ព្រោះការកាន់នេះ ។

ភិក្ខុមួយរូបកាន់សេនាសនៈឬធ្វើអាល័យថា "យើងនឹងនៅក្នុងទីនេះ" ហើយទៅកាន់វត្តជិតខាង កាន់សេនាសនៈក្នុងវត្តនោះ ឬ ធ្វើអាល័យថា "ឥឡូវនេះ យើងនឹងនៅក្នុងទីនេះឯង"; ដោយប្រការយ៉ាងនេះ ការកាន់របស់លោក រមែងរម្ងាប់ព្រោះអាល័យខ្លះ អាល័យរបស់លោក រមែងរម្ងាប់ព្រោះអាល័យខ្លះ ។

ភិក្ខុ រមែងតាំងនៅក្នុងការកាន់ ឬក្នុងអាល័យគ្រាក្រោយ ៗ ក្នុងទីទាំងពួង ។

មួយទៀត ភិក្ខុណា កាន់សេនាសនៈក្នុងវត្តមួយហើយ ទៅដោយគិតថា "យើងនឹងនៅក្នុងវត្តដទៃ" ; ក្នុងខណៈដែលភិក្ខុនោះ ឈានកន្លងឧបចារៈសីមាទៅ ការកាន់សេនាសនៈ រមែងរម្ងាប់ ។

តែបើថា ភិក្ខុទៅដោយតាំងចិត្តថា "បើក្នុងវត្តនោះនឹងមានសេចក្ដីសប្បាយ យើងនឹងនៅ, បើមិនមាន យើងនឹងមក" ដូច្នេះ កាលជ្រាបថា "មិនមានសេចក្ដីសប្បាយ" ទើបត្រឡប់មកក្នុងខាងក្រោយ ដូច្នេះ សមគួរ ។

# ភិក្ខុដែលមានអាសនៈស្មើគ្នា

[៣៩៦] ភិក្ខុណាជាអ្នកចាស់ជាងគ្នា ឬខ្ចីជាងគ្នាត្រឹមតែ ២ វស្សា ភិក្ខុនោះ ឈ្មោះថា អ្នកមានខាងក្នុង៣ វស្សា ក្នុងពាក្យថា តិវស្សន្តរេន : ភិក្ខុដែលមានវស្សាវរាង ៣ នេះ ។

ចំណែកភិក្ខុណា ជាអ្នកចាស់ជាងគ្នា ឬខ្ចីជាង ត្រឹមតែមួយវស្សា ឬថា ភិក្ខុណាមានវស្សាប៉ុនគ្នា មិនមានពាក្យ នឹងត្រូវពោលក្នុងភិក្ខុនោះឡើយ ។ ពិតមែន ភិក្ខុទាំងអស់នេះ រមែងបានដើម្បីអង្គុយជាគូ ៗ គ្នាលើគ្រែ ឬលើតាំងតែមួយជាមួយគ្នា ។

ទីអង្គុយណា ល្មមដល់ភិក្ខុ ៣ រូប, ទីអង្គុយនោះ នឹងជារបស់ដែលបុរទីបាន ឬបុរទីមិនបានក៏ដោយ ; រមែងបានដើម្បីអង្គុយ លើទីអង្គុយបែបនោះ ។ មិនតែប៉ុណ្ណោះលើផែនក្តារ នឹងអង្គុយ រួមសូម្បីនឹងអនុបសម្បន្ន ក៏គួរ ។

# គិហិវិកតំ

[៤០០] បទថា ហត្ថិនខកំ គឺ ប្រាសាទដែលតាំងប្រតិស្ឋានលើពោននៃដំរីទាំងឡាយ ។

បានឮថា ពាក្យថា ហត្ថិនខកៈ នេះ ជាឈ្មោះនៃប្រាសាទដែលធ្វើយ៉ាងនោះ ។

ប្រើនបទថា សព្វំ បាសាទំ បរិភោគំ : ការប្រើប្រាស់ប្រាសាទគ្រប់យ៉ាង មានសេចក្ដីថា បង្អួច គ្រែ តាំង ផ្ចិតស្លឹកត្នោត វិចិត្រដោយមាស និងប្រាក់ជាដើមក្ដី ឆ្នាំងទឹក ផ្តិលទឹកធ្វើដោយមាសនិងប្រាក់ក្ដី ឬថា គ្រឿងប្រើប្រាស់ វត្ថុណាមួយ ដែលឆ្លាក់ក្បាច់ក្បូរស្រស់ល្អក្ដីគួរគ្រប់យ៉ាង ។

ជនទាំងឡាយពោលថា "ខ្ញុំព្រះករុណាឱ្យទាស ទាសី ស្រែ សួន គោ ក្របី ប្រាសាទ" ។ មិនមានកិច្ចនឹងទទួលផ្នែកមួយ កាលទទួលប្រាសាទ ក៏ជាការទទួលទុកដោយពិត ។ នឹងប្រើប្រាស់កម្រាលព្រំជាដើមលើគ្រែនិងតាំង ក្នុងកុដិរបស់សង្ឃ ឬជារបស់ចំណែកបុគ្គលមិនគួរ ។

តែទីដែលគេក្រាលទុកលើធម្មាសនៈ រមែងបានដើម្បីប្រើប្រាស់ដោយការជាប្រើប្រាស់គិហិវិកតិ ។

សូម្បីលើធម្មាសនៈនោះ មិនគួរដេក ។

# គរុភណ្ឌ

[៤០២] បទថា **បញ្ចិមានិ : ៥ យ៉ាងនេះ** មានសេចក្ដីថា គរុភណ្ឌទាំងឡាយ ពោលដោយអំណាចពួក មាន ៥ ពួក ៗ ក៏គរុភណ្ឌទាំងនេះ ពោលអំពីអំណាចរួម រមែងមានច្រើនសន្ទឹកសន្ធប់ ។

បណ្ដាគរុភណ្ឌទាំងនោះ សួនផ្កាឈើឬសួនផ្លែឈើ ឈ្មោះថា អារាម ។ ឱកាសដែលគេកំណត់តាំងទុក ដើម្បីប្រយោជន៍ដល់ អារាមទាំងនោះឯង ឬកាលអារាមទាំងនោះ ជាស្ថានសាបសូន្យទៅហើយ ភូមិភាគចាស់នៃអារាមនោះ ឈ្មោះថា អារាមវត្ថុ ។

សេនាសនៈមានប្រាសាទជាដើម ប្រភេទណាមួយ ឈ្មោះថា វិហារ ។

ឱកាសជាទីប្រតិស្ឋានសេនាសនៈ មានប្រាសាទជាដើម នោះ ឈ្មោះថា វិហារវត្ថុ ។

បណ្ដាគ្រែ ៤ ប្រភេទ ដែលពោលហើយក្នុងកាលមុន ទាំងនេះ គឺ គ្រែដែលមានមេគេបញ្ចូលទៅក្នុងជំណាប់ជើង, គ្រែដែលគេបង្ខាំជើងដោយមេគ្រែ, គ្រែមានជើងដូចជើងក្ដាម, គ្រែមានជើងទល់មេគ្រែ, ប្រភេទណាមួយ ឈ្មោះថា គ្រែ ៗ

បណ្ដាតាំង ៤ ប្រភេទ មានតាំងដែលមានមេគេបញ្ចូលទៅ ក្នុងជំណាប់ជើងជាដើម ប្រភេទណាមួយ ឈ្មោះថា តាំង ។

បណ្តាពូក ៥ ប្រភេទ មានពូកដែលញាត់ដោយរោមសត្វជាដើម ប្រភេទណាមួយ ឈ្មោះថា ពូក ។

បណ្តាខ្នើយមានប្រការដូចពោលហើយ ប្រភេទណាមួយ ឈ្មោះថា ខ្នើយ ។

ផ្ទាំងដែលធ្វើដោយលោហៈ ប្រភេទណាមួយ ជាដែកក៏ដោយ ជាស្ពាន់ក៏ដោយ ឈ្មោះថា ផ្ទាំងលោហៈ ។ សូម្បីក្នុងខ្ទះលោហៈជាដើម ក៏មានន័យដូចគ្នា ។ ក៏ក្នុងខ្ទះលោហៈជាដើមនេះ ក្រឡ ហៅថា ខ្ទះ, ក្អមទឹកហៅថា ក្អម ។ ផើងនោះឯងហៅថា ផើង ។ ក្នុងគ្រឿងដែមានកាំបិតជាដើម និងក្នុងគ្រឿងប្រើប្រាស់មានវល្លិជាដើម ដែលឈ្មោះថា វត្ថុដែលលំបាកស្គាល់ រមែងមិនមាន ។

ព្រះលោកនាថ ទ្រង់មានចក្ខុ ៥ ដែលប្រាសចាកមន្ទិល ទ្រង់ប្រកាសគរុភណ្ឌ ២៥យ៉ាង ដោយពូក ៥យ៉ាងនេះ គឺ ២ពូក សង្គ្រោះគរុភណ្ឌ មួយពូក ៗ មានវត្ថុ២, ពូកទី៣ រាប់គរុភណ្ឌបាន ៤វត្ថុ, ពូកទី៤ មាន ៩វត្ថុ, ពូកទី ៥ចែកជា ៨វត្ថុ ដោយប្រការដូច្នេះ ។

វិនិច្ឆ័យកថា ក្នុងគរុភណ្ឌនោះ គប្បីជ្រាបដូចតទៅនេះ ៖

ក៏គរុភណ្ឌទាំងពួងនេះ សូម្បីក្នុងសេនាសនក្ខន្ធកៈនេះ លោកពោលថា មិនគួរលះ ឬចែកទេ ។ ចំណែកក្នុងគម្ពីរបរិវារមកហើយថា

"ព្រះមានព្រះភាគជាមហាឥសី (ទ្រង់ស្វែងរកប្រយោជន៍ដ៏

ប្រសើរ ) ទ្រង់ត្រាស់ថា របស់៥យ៉ាង មិនត្រូវលះ មិនត្រូវចែក តែកាលបើភិក្ខុលះ និងប្រើប្រាស់ មិនត្រូវអាបត្តិ; ប្រស្នានេះ ពួកលោកអ្នកឆ្លាសវៃបានគិតមកហើយ”[១] ។

ព្រោះហេតុនោះ គប្បីជ្រាបអធិប្បាយក្នុងពាក្យនេះ យ៉ាងនេះថា គរុភណ្ឌនេះ ដែលថា មិនគួរលះបង់ មិនគួរចែក ដោយអំណាចជារបស់បុគ្គលនោះ តែកាលភិក្ខុលះបង់ និងប្រើប្រាស់ដោយអំណាចការផ្លាស់ប្តូរ មិនជាអាបត្តិ ។

អនុបុព្វីកថា ក្នុងគរុភណ្ឌនោះ ដូច្នេះ ៖

មិនគួរបង្អោនគរុភណ្ឌ សូម្បីទាំង ៥ ប្រភេទនេះ ចូលទៅដើម្បីប្រយោជន៍ដល់ចីវរ បិណ្ឌបាត និងភេសជ្ជៈមុន ។ តែនឹងយកថាវរវត្ថុប្តូរជាមួយថាវរវត្ថុ និងយកគរុភណ្ឌប្តូរជាមួយគរុភណ្ឌ គួរ ។

ចំណែកក្នុងថាវរវត្ថុ, ថាវរវត្ថុបែបនេះ គឺស្រែ ទីស្រែ បឹង អណ្តូង ភិក្ខុចាត់ចែង ឬទទួល ឬអនុមតិ( ព្រមទទួល )ជំនួសសង្ឃ មិនគួរ ។

ថាវរវត្ថុនោះ ដែលកប្បិយការកន្ទុះឯង ចាត់ចែង, កប្បិយភណ្ឌៈបានមកអំពីថាវរវត្ថុបែបនោះ គួរ ។

មួយទៀត នឹងយកអារាមជួរថាវរវត្ថុទាំង ៤ យ៉ាងនេះ គឺ អារាម អារាមវត្ថុ វិហារ វិហារវត្ថុ គួរ ។

---

១. វិន. បរិ. សេទមោចនគាថា. ១៣. ៣៨០/៤០០ ។

# បរិវត្តននិ័យ

បរិវត្តននិ័យក្នុងគរុភណ្ឌ ៤ យ៉ាងមានអារាមជាដើមនោះដូច្នេះ ៖

ចំការដូងរបស់សង្ឃនៅឆ្ងាយ, ទាំងពួកកប្បិយការកៈបរិភោគអស់ច្រើនជាង, សូម្បីដែលមិនបានបរិភោគ ក៏ត្រូវនាំមក, ក៏ត្រូវដកឱ្យតម្លៃឈ្នួលរទេះដែរ នាំមកប្រគេនតិចតួច ។

ចំណែកពួកមនុស្សដទៃ ដែលនៅក្នុងស្រុកមិនឆ្ងាយពីចំការនោះ មានចំការនៅជិតវត្ត ។ គេចូលទៅរកសង្ឃសូមយកចំការរបស់ខ្លួនប្តូរយកចំការនោះ សង្ឃគប្បីអបលោកនៈថា "រុច្ចតិ សង្ឃស្ស : (ការប្តូរនេះ)គាប់ចិត្តដល់សង្ឃដែរឬទេ" សង្ឃយល់ព្រមហើយទទួលចុះ ។

សូម្បីថា ចំការរបស់ពួកភិក្ខុ មានដើមឈើមួយពាន់ដើម, សួនរបស់អ្នកស្រុកមានដើមឈើប្រាំរយដើម ; (បើមានផ្លែច្រើនជាង) ក៏មិនគួរពោលជំទាស់ថា "ចំការរបស់អ្នកតូច" ។ ព្រោះចំការនេះតូចក៏ពិត, តែតាមពិត ចំការនេះ រមែងឱ្យផ្លែច្រើនជាងចំការក្រៅពីនេះ ។

សូម្បីថា ចំការនេះឱ្យផលស្មើគ្នា ។ សូម្បីយ៉ាងនោះ នឹងព្រមទទួលដោយបំណងថា "អាចបរិភោគបានគ្រប់ខណៈដែលត្រូវការ" ក៏គួរ ។

តែបើចំការរបស់ពួកអ្នកស្រុក មានដើមឈើច្រើនជាង, គប្បីពោលថា "ដើមឈើរបស់ពួកអ្នកមានច្រើនជាងឬ ?" បើគេឆ្លើយថា

“ចំណែកដែលលើសពីនោះទៅ ចូរជាបុណ្យរបស់ពួកខ្ញុំព្រះករុណា ពួកខ្ញុំព្រះករុណាថ្វាយសង្ឃ” ។ សមគួរឱ្យភិក្ខុសង្ឃជ្រាប ហើយទើប ទទួលទុក ។

ដើមឈើរបស់ពួកភិក្ខុ មានផ្លែ, ដើមឈើរបស់ពួកអ្នកស្រុកមិនទាន់ចេញផ្លែ, គប្បីព្រមទទួលពិត ដោយសម្ងឹងឃើញថា “ដើមឈើរបស់ពួកអ្នកស្រុក មិនទាន់ចេញផ្លែក៏ពិតមែន តែមិនយូរទេ ក៏នឹងចេញផ្លែ” ។

ដើមឈើរបស់ពួកអ្នកស្រុក មានផ្លែ, ដើមឈើរបស់ពួកភិក្ខុមិនទាន់ចេញផ្លែ គប្បីពោលថា “ដើមឈើរបស់ពួកអ្នកមានផ្លែឬ ?” បើគេពោលថា “ទទួលយកចុះ លោកម្ចាស់ នឹងជាបុណ្យដល់ពួកខ្ញុំព្រះករុណា” ។ សមគួរឱ្យភិក្ខុសង្ឃជ្រាបហើយទទួលទុក ។ អារាមនឹងអារាម គប្បីប្តូរគ្នាដោយប្រការដូច្នេះ ។ អារាមវត្ថុក្តី វិហារក្តី វិហារវត្ថុក្តី ជាមួយនឹងអារាម គប្បីប្តូរគ្នាដោយន័យនេះឯង ។

មួយទៀត អារាម អារាមវត្ថុ វិហារ និងវិហារវត្ថុ ក៏គប្បីប្តូរជាមួយអារាមវត្ថុ ដែលធំក៏ដោយ តូចក៏ដោយ ដោយន័យនេះ ដូចគ្នាដូច្នេះឯង ។ វិហារនឹងវិហារនឹងប្តូរគ្នាយ៉ាងណា ? កុដិរបស់សង្ឃនៅខាងក្នុងស្រុក ប្រាសាទរបស់អ្នកស្រុកនៅក្នុងវត្ត ទាំង ២ យ៉ាងពោលអំពីតម្លៃជារបស់ប៉ុនគ្នា ។ បើថា អ្នកស្រុកសូមយកប្រាសាទនោះប្តូរកុដិនោះ

សមគួរទទួល ។

កុដិរបស់ពួកភិក្ខុមានតម្លៃច្រើនជាង. និងកាលភិក្ខុពោលថា "កុដិរបស់ពួកយើងមានតម្លៃច្រើនជាង", គេឆ្លើយថា "កុដិរបស់ពួកលោកម្ចាស់មានតម្លៃច្រើនជាងក៏ពិត, តែមិនសមគួរដល់បព្វជិត បព្វជិតមិនអាចនៅក្នុងកុដិនោះបាន, ចំណែកផ្ទះខ្ញុំព្រះករុណានេះសមគួរ សូមលោកម្ចាស់ទាំងឡាយទទួលចុះ" ; សូម្បីយ៉ាងនេះ ក៏គួរទទួល ។

បើផ្ទះរបស់អ្នកស្រុកមានតម្លៃច្រើន, ភិក្ខុគប្បីពោលថា "ផ្ទះរបស់ពួកអ្នក មានតម្លៃច្រើនមិនមែនឬ ?" តែកាលគេឆ្លើយថា "ណ្ហើយចុះ លោកម្ចាស់ដ៏ចម្រើន, នឹងជាបុណ្យដល់ពួកខ្ញុំព្រះករុណា, មេត្តាទទួលចុះ" ដូច្នេះ សមគួរទទួល ។

វិហារនិងវិហារ គប្បីប្តូរគ្នាយ៉ាងនេះ ។ វិហារវត្ថុក្តី អារាមក្តី អារាមវត្ថុក្តី គប្បីប្តូរជាមួយវិហារ ដោយន័យនេះឯង ។

មួយទៀត វិហារ វិហារវត្ថុ អារាមនិងអារាមវត្ថុ ក៏គប្បីប្តូរជាមួយវិហារវត្ថុ ដែលមានតម្លៃច្រើនក៏ដោយ មានតម្លៃតិចក៏ដោយ ក៏ដោយន័យនេះដែរ ដូច្នេះឯង ។ គប្បីជ្រាបការប្តូរថាវរវត្ថុ និងថាវរវត្ថុយ៉ាងនេះចុះ ។

ចំណែកវិនិច្ឆ័យក្នុងការប្តូរគរុភណ្ឌនិងគរុភណ្ឌ គប្បីជ្រាបដូចតទៅនេះ ៖

គ្រែតាំងជំបូតូចក៏ដោយ ដោយហោចទៅមានជើងត្រឹមតែ ៤ ធ្នាប់ សូម្បីពួកក្មេងអ្នកស្រុកដែលនៅលេង ក្នុងពេងដីធ្វើ រមែងជាគរុភណ្ឌ ចាប់តាំងពីពេលដែលថ្វាយសង្ឃហើយ ។

សូម្បីបើព្រះរាជា និងរាជមហាអាមាត្យជាដើម ប្រគេនត្រឹមតែម្តងប៉ុណ្ណោះ គ្រែទាំងរយឬទាំងពាន់គ្រែ, គ្រែដែលជាកប្បិយ ទាំងអស់ គប្បីទទួលទុក ។ គ្រាទទួលហើយ គប្បីចែកតាមលំដាប់ភិក្ខុចាស់ថា "សូមលោកម្ចាស់ប្រើប្រាស់ជាគ្រឿងប្រើប្រាស់របស់សង្ឃ" ។ កុំឱ្យជាចំណែកបុគ្គល ។ សូម្បីតាំងនិងគ្រែដ៏ច្រើន តម្កល់ទុកក្នុងឃ្លាំងជាដើម ហើយរក្សាបាត្រចីវរ ក៏គួរ ។

គ្រែដែលគេថ្វាយក្រៅសីមាថា "ខ្ញុំព្រះករុណាថ្វាយដល់សង្ឃ" ដូច្នេះ គប្បីឱ្យទុកក្នុងស្ថានទីនៅរបស់ព្រះសង្ឃថេរៈ ។ បើក្នុងស្ថានទីនៅរបស់ព្រះសង្ឃថេរៈនោះ មានគ្រែច្រើន, មិនត្រូវការប្រើប្រាស់គ្រែ ; ក្នុងស្ថានទីនៅរបស់ភិក្ខុណា ដែលមានសេចក្តីត្រូវការប្រើប្រាស់គ្រែ, គប្បីឱ្យទុកក្នុងស្ថានទីនៅរបស់ភិក្ខុនោះ បង្គាប់ថា "ចូរលោកប្រើប្រាស់ដោយការប្រើប្រាស់ជារបស់សង្ឃ" ។

គ្រែមានតម្លៃច្រើន គឺ វាយតម្លៃរាប់រយឬរាប់ពាន់កហាបណៈ នឹងប្តូរគ្រែដទៃ រមែងបានច្រើនរយគ្រែ គួរប្តូរយកទុក ។ មិនមែនតែគ្រែម្យ៉ាងប៉ុណ្ណោះ សូម្បីអារាម អារាមវត្ថុ វិហារ វិហារវត្ថុ តាំងពួក

និងខ្ទើយ ក៏គួរប្តូរ ។ សូម្បីក្នុងតាំងពូកនិងខ្ទើយក៏ន័យនេះ ។ សូម្បីក្នុងគ្រែ តាំង ពូក ខ្ទើយ ទាំងអស់នេះ វត្ថុដែលជាកប្បិយ និងអកប្បិយមានន័យដូចពោលហើយនុ៎ះឯង ។

ក្នុងកប្បិយនិងអកប្បិយនោះ ដែលជាអកប្បិយមិនគួរប្រើប្រាស់ ។ ជាកប្បិយ គប្បីប្រើប្រាស់ជាគ្រឿងប្រើរបស់សង្ឃ ។ ដែលជាអកប្បិយ ឬដែលជាកប្បិយមានតម្លៃច្រើន គប្បីប្តូរយកវត្ថុដែលពោលហើយទុក ។ ដែលឈ្មោះថា ពូកនិងខ្ទើយ ដែលមិនចាត់ជាគរុភណ្ឌ រមែងមិនមាន ។

គរុភណ្ឌ ៣ យ៉ាងនេះ គឺ ឆ្នាំងលោហៈ ផើងលោហៈ ខ្ទះលោហៈ ធំឬតូចក៏ដោយ ដោយហោចទៅ សូម្បីចំណុះទឹកត្រឹមតែមួយទូកដៃ ក៏ជាគរុភណ្ឌដូចគ្នា ។

ចំណែកក្អមលោហៈ ដែលធ្វើពីដែក ស្ពាន់ សំរិទ្ធ ទង់ដែង យ៉ាងណាមួយ ចំណុះទឹកបានមួយបាទ ក្នុងកោះសីហឡចែកគ្នាបាន ។

ដែលឈ្មោះថា មួយបាទ ចំណុះទឹកប្រមាណ ៥ នាឡិមគធ ។ (ក្អមលោហៈ)ដែលចំណុះទឹកច្រើនជាងនោះ ជាគរុភណ្ឌ, ភាជនៈលោហៈដែលមកក្នុងបាលីប៉ុណ្ណោះដូចន័យមុន ។

ចំណែកកុណ្ឌីមាស កន្ទោរ ចោយ វែក ស្លាបព្រា ថាស ចាន ផ្តិល ក្លាក់ អំបែងសម្រាប់ដាក់រងើកភ្លើង និងបំពង់ផ្សែង ជាដើម

សូម្បីមិនបានមកក្នុងបាលី ទោះជាតូចឬធំក៏ដោយ ក៏ជាគរុភណ្ឌទាំងអស់ ។ តែភណ្ឌៈទាំងនេះ គឺ បាត្រតូច ភាជនៈតូច ភាជនៈស្ពាន់ ជារបស់គួរចែកគ្នា បានភាជនៈភ្លឺថ្លា ដែលធ្វើពីសំរិទ្ធ ឬទង់ដែង គួរប្រើប្រាស់ ជាគ្រឿងប្រើប្រាស់របស់សង្ឃ ឬជាគិហិវិកតិ មិនគួរប្រើប្រាស់ដោយការប្រើប្រាស់ជាចំណែកបុគ្គល ។

ក្នុងមហាបច្ចរីពោលថា ភាជនៈសំរិទ្ធិជាដើម ដែលគេថ្វាយសង្ឃនឹងរក្សាទុកប្រើប្រាស់ខ្លួនឯង មិនគួរ, គប្បីប្រើប្រាស់ដោយទំនងគិហិវិកតិប៉ុណ្ណោះ ចំណែកក្នុងភណ្ឌលោហៈ ដែលជាកប្បិយសូម្បីដទៃ វៀរលែងតែភាជនៈដ៏វិចិត្រប្លែក ៗ ចេញ ក្លាក់ថ្នាំបន្ទក់ភ្នែក ចង្កឹះថ្នាំបន្ទក់ភ្នែក កន្ធាត្បារត្រចៀក ម្ជុល ដែកចារ កាំបិតតូច ដែកខៃតូច សោកូនសោ វនុក កងឈើប្រត់ បំពង់ថ្នាំហឹត (នត្ថុ) ស្វាន ផើងលោហៈ បន្ទុះលោហៈ ដុំលោហៈ វត្ថុលោហៈ ដែលធ្វើទុកសូម្បីយ៉ាងដទៃ ជារបស់គួរចែកគ្នាបាន ។

ចំណែកបំពង់ថ្នាំជក់ ភាជន៍លោហៈ គោមមានជង គោមតាំងគោមព្យួរ រូបស្ត្រី រូបបុរស និងរូបសត្វតិរច្ឆាន ឬវត្ថុលោហៈពួកដទៃ ដែលភ្ជាប់ទុកតាមជញ្ជាំង ឬដំបូល ឬសន្លឹកទ្វារជាដើម, វត្ថុលោហៈទាំងពួង ដោយហោចទៅសូម្បីចម្រឹងដែកគោល ក៏ជាគរុភណ្ឌដែរ សូម្បីខ្លួនឯងបានមក ក៏មិនគួររក្សាទុកប្រើដូចជាគ្រឿងប្រើប្រាស់ចំណែកបុគ្គល ។

គួរប្រើប្រាស់ដូចគ្រឿងប្រើប្រាស់របស់សង្ឃ ឬប្រើប្រាស់ជាគិហិវិកតិ ។ សូម្បីក្នុងវត្ថុសំណា ក៏មានន័យដូចគ្នា ។ ចាន និងផ្តិលជាដើម ដែលធ្វើដោយថ្មកែវ ជាគរុភណ្ឌដូចគ្នា, ចំណែកផ្ទាំង ឬ ភាជនៈប្រេងធំលើសពីចំណុះប្រេងមួយបាទឡើងទៅប៉ុណ្ណោះ ជាគរុភណ្ឌ ។

ភាជន៍មាស ប្រាក់ ទង់ហ៊ា និងកែវផលឹក សូម្បីប្រើប្រាស់ជាគិហិវិកតិ ក៏មិនគួរ, មិនចាំបាច់ពោលទៅថ្វី ដល់ការប្រើប្រាស់ដោយការប្រើប្រាស់ជារបស់សង្ឃ ឬដោយការប្រើប្រាស់ជាចំណែកបុគ្គល (គឺមិនគួរទាំងអស់) ។

តែដោយគ្រឿងប្រើប្រាស់សម្រាប់សេនាសនៈ វត្ថុគ្រប់យ៉ាងដែលគួរប៉ះពាល់ និងដែលមិនគួរប៉ះពាល់ នឹងប្រើប្រាស់ក៏គួរ ។

ក្នុងកាំបិតជាដើម កាំបិតដែលមិនអាចប្រើប្រាស់ធ្វើការងារធំយ៉ាងដទៃបាន វៀរលែងតែការកាត់ឈើស្ទន់ ឬការសក អំពៅចេញ ជារបស់គួរចែកគ្នាបាន ។ កាំបិតដែលធ្វើដោយ អាការយ៉ាងណាមួយដែលធំជាងនោះ ជាគរុភណ្ឌ ។

ចំណែកពូថៅ ដោយហោចទៅសូម្បីជាពូថៅ សម្រាប់កាត់សរសៃរបស់ពួកពេទ្យ រមែងជាគរុភណ្ឌដូចគ្នា ។

ក្នុងជីងមានវិនិច្ឆ័យដូចពូថៅ ទុំះឯង ។ ចំណែកជីងដែលធ្វើសម្រាប់ជាអាវុធ ជាអនាមាស ។

ចបដោយហោចទៅ សូម្បីខ្នាត ៤ ធ្នាប់ ក៏ជាគរុភណ្ឌពិត ។

ពន្លាក មានជ្រុង៤ក្តី មានមាត់ជាចង្អូរក្តី កោងក្តី ត្រង់ក្តី ដោយហោចទៅ សូម្បីដែកចោះ អំបោស ជារបស់បញ្ចូលដងទុក ជាគរុភណ្ឌពិត ។ តែដែកចោះ អំបោសមិនមានដង មានតែតួប៉ុណ្ណោះ ជារបស់អាចដាក់ស្រោមរក្សាទុកបាន ជារបស់គួរចែក ។

សូម្បីដែកស្រួចក៏សង្គ្រោះដោយវត្ថុនុ៎ះឯង ។

កាំបិតជាដើម ជារបស់ដែលជនពួកណាថ្វាយទុកក្នុងវិហារ, កាលបើជនទាំងនោះត្រូវភ្លើងឆេះផ្ទះ ឬត្រូវចោរប្លន់ ទើបពោលថា "លោកម្ចាស់ដ៏ចម្រើន ចូរឱ្យឧបករណ៍ដល់ពួកខ្ញុំព្រះករុណាចុះ, ហើយនឹងសងវិញ", គួរឱ្យ ។ បើគេនាំមកសង កុំគប្បីហាម, សូម្បីគេមិននាំមកសង ក៏មិនគប្បីទាមទារ ។

គ្រឿងឧបករណ៍ដែលធ្វើដោយលោហៈគ្រប់យ៉ាង មានដែកទ្រនាប់ញញួរ ដង្កាប់ និងដងជញ្ជីងជាដើមរបស់ជាងដែក ជាងឈើ ជាងក្រឡឹង ជាងជម្លាញ ជាងកែវ និងជាងបាត្រ ជាគរុភណ្ឌចាប់ដើមអំពីកាលដែលថ្វាយសង្ឃហើយ ។ សូម្បីក្នុងឧបករណ៍ របស់ជាងសំណ ជាងមាស ជាងស្បែក ក៏មានន័យដូចគ្នា ។

ចំណែកសេចក្តីដែលប្លែកគ្នាដូច្នេះ ៖

គ្រឿងឧបករណ៍ទាំងនេះ គឺ ក្នុងពួកគ្រឿងឧបករណ៍របស់ជាង

សំណា កាំបិតកាត់សំណា, ក្នុងពួកគ្រឿងឧបករណ៍របស់ជាងមាស កាំបិតកាត់មាស, ក្នុងពួកគ្រឿងឧបករណ៍របស់ជាងស្បែក កាំបិតតូចសម្រាប់កាត់ស្បែក, ដែលជម្រះសំអាតហើយ ជាវត្ថុដែលគួរចែក ។

សូម្បីក្នុងគ្រឿងឧបករណ៍របស់ជាងកោរកាត់ និងជាងដេរប៉ះ រៀវកន្ទ្រៃធំ ចន្ទាសធំ និងកាំបិតធំចេញ គួរចែកគ្រប់យ៉ាង ។ កន្ទ្រៃធំជាដើម ជាគរុភណ្ឌ ។

វិនិច្ឆ័យក្នុងវល្លិជាដើម គប្បីជ្រាបដូច្នេះ ៖

វល្លិមួយប្រភេទមានផ្តៅជាដើម ប្រមាណត្រឹមកន្លះហត្ថ ( ១ ចំអាម ៤ ធ្នាប់ ) ដែលគេថ្វាយដល់សង្ឃ ក៏ដោយ ដែលកើតឡើងក្នុងដីសង្ឃនោះ ក៏ដោយ ដែលសង្ឃគ្រប់គ្រងរក្សាទុក ជាគរុភណ្ឌ ។

វល្លិនោះ កាលការងាររបស់សង្ឃ និងការងារចេតិយ ធ្វើសម្រេចហើយ បើជារបស់នៅសល់, ទីងបង្អោនចូលទៅក្នុងការងារចំណែកបុគ្គលខ្លះ ក៏គួរ ។ តែបើវល្លិដែលសង្ឃមិនរក្សា មិនជាគរុភណ្ឌឡើយ ។

ខ្សែឬពួរដែលធ្វើសម្រេចដោយអំបោះ ធ្មៃ ព្រៀល ជក់ដូង និងស្បែកក្តី ខ្សែវេញមួយធ្នុង ឬ ពីរធ្នុង ដែលគេវេញព្រៀល ឬជក់ដូងធ្វើក្តី រមែងជាគរុភណ្ឌ ចាប់តាំងពីពេលគេថ្វាយដល់សង្ឃហើយ ។

ចំណែកអំបោះដែលគេមិនបានវេញប្រគេន និងសំបកធ្មៃ ក្រចៅ

ស្រកីជូនចែកគ្នាបាន ។

មួយទៀត ខ្សែនិងពួរជាដើមទាំងនោះ ជារបស់ដែលជនពួកណាប្រគេន, បើជនទាំងនោះខ្ចីទៅដោយករណីយកិច្ចរបស់ខ្លួន មិនគួរហួងហែង ។

ឫស្សីប្រភេទណាមួយ ដោយហោចទៅសូម្បីទំហំប៉ុនម្ជុលឈើ[១] ប្រវែង ៨ ធ្នាប់ដែលគេថ្វាយសង្ឃ ឬដែលកើតក្នុងធរណីសង្ឃនោះ ដែលសង្ឃគ្រប់គ្រងរក្សាទុក ជាគរុភណ្ឌ ។

កាលការងាររបស់សង្ឃ និងការងាររបស់ចេតិយ ធ្វើរួចស្រេចហើយ សូម្បីឫស្សីនោះក៏នៅសល់ នឹងប្រើប្រាស់ក្នុងការងារជាចំណែកបុគ្គល ក៏គួរ ។

ក៏ក្នុងភណ្ឌៈ គឺ ឫស្សីនេះ ភណ្ឌយ៉ាងនេះ គឺ បំពង់ប្រេងចំណុះមួយបាទ ឈើប្រចត់ ដងវែក ស្បែកជើង ដងឆត្រ ឆ្អឹងឆត្រ ជារបស់ចែកគ្នាបាន ។

ពួកអ្នកស្រុកត្រូវភ្លើងឆេះផ្ទះកាន់យកទៅ មិនគួរហាម ។ កាលភិក្ខុកាន់យកឫស្សីដែលសង្ឃរក្សាគ្រប់គ្រង ត្រូវធ្វើថាវរវត្ថុដែលស្មើគ្នា ឬលើសជាងគ្នា ដោយហោចទៅធ្វើផាតិកម្ម (ការចម្រើន) សូម្បីដោយ

---

១. សុចិទណ្ឌក ម្ជុលឈើ (សម្រាប់ដេររបស់ធំ មានបាវជាដើម) ។

ដីខ្សាច់ដែលមានតម្លៃស្មើនឹងឫស្សីនោះ ហើយទើបកាន់យក ។ កាល មិនធ្វើផាតិកម្មកាន់យក ត្រូវប្រើប្រាស់ក្នុងវត្តនោះប៉ុណ្ណោះ ។ ក្នុងវេលា ដែលនឹងទៅ ត្រូវរក្សាទុកក្នុងទីនៅរបស់សង្ឃសិន សឹមទៅ ។ ភិក្ខុ ដែលកាន់យកទៅ ដោយសេចក្ដីវង្វេងភ្លេច ត្រូវសងវិញ ។ ទៅកាន់ ប្រទេសដទៃហើយ គប្បីរក្សាទុកក្នុងទីនៅរបស់សង្ឃក្នុងវត្តដែលទៅដល់ ។

ស្មៅនោះ គឺ ស្មៅប្រភេទណាមួយ ដែលក្រៅអំពីស្មៅ ដំណេកទន្សាយ និងស្មៅយ៉ាប្លង ។ ក៏ក្នុងទីណា មិនមានស្មៅ, ក្នុងទី នោះ គេប្រក់ដោយស្លឹកឈើ; ព្រោះដូច្នោះ សូម្បីស្លឹកឈើ ក៏ សង្គ្រោះដោយស្មៅដូចគ្នា ។

ក្នុងស្មៅដំណេកទន្សាយជាដើម ស្មៅប្រភេទណាមួយ សូម្បីមាន ប្រមាណមួយក្ដាប់ សូម្បីក្នុងស្លឹកឈើ មានស្លឹកត្នោតជាដើម សូម្បីមួយ សន្លឹក ដែលគេថ្វាយដល់សង្ឃ ឬដែលកើតក្នុងដីសង្ឃនោះ ឬជាស្មៅ ដែលកើតក្នុងសួនស្មៅរបស់សង្ឃ ខាងក្រៅអារាមដែលសង្ឃគ្រប់ គ្រងរក្សា ជាគរុភណ្ឌ ។

កាលការងាររបស់សង្ឃ ឬការងារក្នុងចេតិយធ្វើរួចស្រេចហើយ ស្មៅសូម្បីនោះ ក៏នៅសល់ ទឹងប្រើប្រាស់ក្នុងការងារ ជាចំណែកបុគ្គល ក៏គួរ ។ ពួកអ្នកស្រុកត្រូវភ្លើងឆេះផ្ទះ មកកាន់យកទៅ មិនគួរហាម ។

ក្នុងស្លឹករឹតទទេ សូម្បីខាត(ប្រវែង)ត្រឹមតែ ៨ ធ្នាប់ ក៏ជាគរុ

ភណ្ឌដូចគ្នា ។

ដីឥដ្ឋ ទោះជាដីធម្មតា ឬជាដីពណ៌, ៥ ឬកំបោរសក៏ដោយ ឬបណ្ដាជ័រផង់ជ័រស្រេស់និងជ័រចុងជាដើម ជ័រប្រភេទណាមួយ ដែលគេនាំមកប្រគេនក្នុងទីដែលរកបានលំបាកក្ដី ដែលកើតក្នុងដីសង្ឃនោះក្ដី ទំហំប៉ុនផ្លែត្នោតទុំ ដែលសង្ឃគ្រប់គ្រងរក្សាទុក ជាគរុភណ្ឌ ។

កាលការងាររបស់សង្ឃ ឬការងាររបស់ចេតិយធ្វើរួចស្រេចហើយ ជ័រសូម្បីដែលនៅសល់នោះ នឹងប្រើប្រាស់ក្នុងការងារជាចំណែកបុគ្គល ក៏គួរ ។

ចំណែកហិង្គុ ហិង្គុលក(រង់) ហរិតាល មនោសិលា និងថ្នាំសម្រាប់បន្ដក់ ភ្នែក ជារបស់គួរចែកគ្នា ។

វិនិច្ឆ័យក្នុងវត្ថុ គឺ ឈើ គប្បីជ្រាបដូច្នេះ ៖

ក្នុងកុរុន្ទីពន្យល់ថា ភណ្ឌៈឈើប្រភេទណាមួយ សូម្បីទំហំប៉ុនម្ជុលឈើ ប្រវែង ៨ ធ្នាប់ គេថ្វាយសង្ឃក្នុងទីដែលរកបានលំបាក ឬកើតក្នុងដីសង្ឃនោះ ដែលសង្ឃគ្រប់គ្រងរក្សា នេះជាគរុភណ្ឌ ។

ចំណែកក្នុងមហាអដ្ឋកថា សង្គ្រោះរបស់ប្លែកដែលធ្វើដោយវត្ថុជាដើមថា ឈើ ឫស្សី ស្បែក និងថ្ម សូម្បីគ្រប់យ៉ាងដោយភណ្ឌៈឈើ ហើយពោលវិនិច្ឆ័យនៃភណ្ឌៈឈើ ចាប់តាំងពីបាលីនេះថា "តេន ខោ បន សមយេន សង្ឃស្ស អាសន្ទិកោ ឧប្បន្នោ ហោតិ : សម័យ

នោះឯង តាំង ៤ ជ្រុង កើតឡើងដល់សង្ឃ”[១] ។

ក្នុងមហាអដ្ឋកថានោះ វិនិច្ឆ័យសេចក្ដីដូច្នេះ ៖

ក្នុងរបស់ទាំងនេះ គឺ តាំង ៤ ជ្រុង (សូម្បីមានជើងខ្ពស់) ក្រៃគមានអង្គ ៧ (សូម្បីមានជើងខ្ពស់) តាំងចាក់ផ្កាំ តាំងសំពត់ តាំងមានជើងដូចជើងពពែ តាំង (ជើងច្រើន) មានអាការដូចជាផ្លែកន្ទួតព្រៃ តាំងក្ដារ កៅអី តាំងញាត់ចំបើង ប្រភេទណាមួយ តូចឬធំក៏ដោយ ដែលគេថ្វាយដល់សង្ឃហើយ ក៏ជាគរុភណ្ឌ ។

មួយទៀត សូម្បីតាំងដែលញាត់ដោយស្លឹកចេកជាដើម សង្គ្រោះក្នុងតាំងទាំងនោះដោយតាំងញាត់ចំបើង ។

កៅអីដែលពាសដោយស្បែកខ្លាធំក្ដី ព័ទ្ធដោយរូបសត្វ សាហាវក្ដី ដេរដោយរតនៈក្ដី ជាគរុភណ្ឌដូចគ្នា ។

ក្នុងរបស់ទាំងនោះ គឺ ក្ដារកោង ក្ដារវែង ក្ដារបោកចីវរ ក្ដារទ្រសម្រាប់ដំ អន្លូងសម្រាប់ដំ ជ្រញកាត់ឈើស្ងួន ឈើព្រនង់ ធុងឈើស្នូកជ្រលក់ ក៏សៀវទឹក ស្នុកឈើ ឬស្នុកភ្លុក ឬស្នុកឫស្សី មានជើងក៏ដោយ មិនមានជើងក៏ដោយ ហិប ប្រអប់មានខ្នាតមិនលើសពីចំណុះទឹកមួយបាទ ស្នុកទឹក ផើងទឹក ប្រោយ វែក ផ្ដិលទឹក ស័ង្ខដងទឹក

១. នៅក្នុង [៣២៣]

ប្រភេទណាមួយ ដែលថ្វាយដល់សង្ឃហើយ ជាគរុភណ្ឌ, ចំណែកភាជនៈ ដែលធ្វើដោយស័ង្ខចែកគ្នាបាន ។ បំពង់ទឹកដែលធ្វើដោយឈើក៏ដូចគ្នា ។

រន្វេលជូតជើង ដែលធ្វើដោយឈើ ឬធ្វើដោយស្លឹកត្នោត ជាដើមក៏ដោយ ជាគរុភណ្ឌទាំងអស់ ។

ក្នុងរបស់ទាំងនេះ គឺ ជើងបាត្រ គម្របបាត្រ ផ្លិតស្លឹកត្នោត ផ្លិតវីជនី ក្លាក់ ជាល អំបោសដងវែង អំបោសដងខ្លីយ៉ាងណាមួយ តូចឬធំក៏ដោយ ធ្វើដោយរបស់យ៉ាងណាមួយ មានឈើ ឬស្សី ស្លឹកឈើនិងស្បែកជាដើម ជាគរុភណ្ឌដូចគ្នា ។

បណ្ដាគ្រឿងផ្ទះមានសសរ រនូត ជណ្ដើរ និងក្ដារជាដើម គ្រឿងផ្ទះយ៉ាងណាមួយ ដែលធ្វើដោយឈើក្ដី ធ្វើដោយ សិលាក្ដី កន្ទេលផែងប្រភេទណាមួយ កម្រាលប្រភេទណាមួយ ស្បែកដែលជាកប្បិយប្រភេទណាមួយ ដែលគេថ្វាយ ជាល អំបោសដងវែង អំបោសដងខ្លីយ៉ាងណាមួយ តូចឬធំក៏ដោយ ធ្វើដោយរបស់ដល់សង្ឃហើយ ជាគរុភណ្ឌសមគួរធ្វើឱ្យជាកម្រាលផែនដី ។

ចំណែកស្បែកពពែ សូម្បីមានគតិដូចជាកម្រាល ក៏ជាគរុភណ្ឌដូចគ្នា ។ ស្បែកជាកប្បិយ ជារបស់គួរចែកគ្នាបាន ។

តែក្នុងកុរុន្ទីពោលថា ស្បែកគ្រប់ប្រភេទមានខ្នាតប៉ុនគ្រែ ជាគរុ

ភណ្ឌ ។ ត្បាល់ អង្រែ ចង្អេរ ថ្មកិន កូនថ្មកិន ស្នូកសិលា ផើងសិលា ភណ្ឌៈរបស់ជាងតម្បាញជាដើមគ្រប់យ៉ាង មានត្រល់ កី និងតម្បាញជាដើម គ្រឿងធ្វើស្រែគ្រប់យ៉ាង កង់គ្រប់យ៉ាង ជាគរុភណ្ឌទាំងអស់ ។

ជើងគ្រែ មេគ្រែ ជើងតាំង មេតាំង ដងកាំបិត និងពូថៅជាដើម ក្នុងរបស់ទាំងនេះ យ៉ាងណាមួយ ដែលចាំងទុកម្ខាងមិនទាន់រួចស្រេច ចែកគ្នាបាន តែដែលចាំងរលីងរាបស្មើហើយ ជាគរុភណ្ឌ ។

មួយទៀត របស់ដូច្នេះ គឺ ដងកាំបិតដែលទ្រង់អនុញ្ញាតដងនិង ស្លឹកឆត្រ ឈើប្រត់ ស្បែកជើង ឈើពំនួតភ្លើង ធម្មក្រក បំពង់ទឹករាង ដូចផ្លែកន្ទួតព្រៃ ឆ្នាំងទឹករាងដូចផ្លែកន្ទួតព្រៃ បំពង់ទឹកផ្លែឃ្លោក ឆ្នាំងទឹក ស្បែក ឆ្នាំងទឹករាងដូចឃ្លោក បំពង់ទឹកធ្វើដោយស្នែង ចំណុះទឹកមិន លើសមួយបាទ ចែកគ្នាបានគ្រប់យ៉ាង ធំជាងនោះជាគរុភណ្ឌ ។ ភ្លុកដំរីឬ ស្នែងប្រភេទណាមួយ មិនទាន់បានរលីង នៅដូចដើម ចែកគ្នាបាន ។

ក្នុងជើងគ្រែជាដើម ដែលធ្វើដោយភ្លុកដំរី និងស្នែងទាំងនោះ មានវិនិច្ឆ័យដូចដែលមានមកហើយ ក្នុងកាលខាងដើមនុ៎ះឯង ។

របស់ដូច្នេះ គឺ ក្លាក់ដាក់ហិង្គុ ក្លាក់ដាក់ថ្នាំភ្នែក សូម្បីខាត់ រលីងស្រេចហើយ ក្តុំ ក្រវិលក្តុំ បំពង់ថ្នាំភ្នែក ចង្កិះថ្នាំបន្តក់ភ្នែក សំពត់ជូតទឹកគ្រប់យ៉ាងចែកគ្នាបានទាំងអស់ ។

វិនិច្ឆ័យក្នុងរបស់ដែលធ្វើដោយដី គប្បីជ្រាបដូច្នេះ ៖

គ្រឿងឧបភោគនិងបរិភោគរបស់មនុស្សទាំងពួង គឺ ភាជន៍ដីមានឆ្នាំងគម្របជាដើម ផើងសម្រាប់ដុតបាត្រ ចង្ក្រាន បំពង់ផ្សែង គោមមានជង គោមតាំង ឥដ្ឋសម្រាប់សាងសង់ គ្រឿងសម្រាប់ប្រក់ គ្រឿងព្រំ ជាគរុភណ្ឌចាប់តាំងពីវេលាដែលថ្វាយសង្ឃហើយ ។

ក៏ក្នុងភណ្ឌដែលធ្វើដោយដីនេះ ភណ្ឌដូច្នេះ គឺ ឆ្នាំង បាត្រ ភាជន៍ កន្ទោរមាត់ធំ កន្ទោរធម្មតា ខ្នាតធំបង្គួរមិនលើសពីចំណុះទឹកមួយបាទ ជាភណ្ឌដែលចែកគ្នាបាន ។ មួយទៀត សូម្បីក្នុងភណ្ឌលោហៈគប្បីជ្រាបវិនិច្ឆ័យដូចក្នុងភណ្ឌដី ។ កន្ទោរទឹកបូកចូលនឹងចំណែកដែលចែកគ្នាបានដូចគ្នា ។ អនុបុព្វីកថា ក្នុងគរុភណ្ឌនេះ ប៉ុណ្ណោះ ។

## នវកម្ម

[៤០៥] បទថា ភណ្ឌិកាឋានមត្តេន : គ្រាន់តែបិទបាំងទីអាស្រ័យនៅនៃសត្វព្រាប មានសេចក្តីថា ភិក្ខុក្រេងអាឡវី រមែងឱ្យនវកម្ម (គឺសាងថ្មី) ដោយត្រឹមតែប្រកបវត្ថុដែលបិទដែលអាស្រ័យនៅនៃសត្វព្រាបដែលធ្វើលើសន្ទះទ្វារ ។

បទថា បរិភណ្ឌករណមត្តេន : គ្រាន់តែជួសជុល គឺ ដោយត្រឹមតែធ្វើការបូកលាបដោយអាចម៍គោ និងលាបដោយទឹកអម្ចត់ ។

បទថា ធូមកាលិកំ : ក្នុងកាលមានផ្សែង មានសេចក្តីថា ភិក្ខុ

ក្រុងអាឡវី រមែងអបលោកន៍ឱ្យទីនៅ ដែលសាងធ្វើសម្រេចហើយនេះ ក្នុងវេលានៃផ្សេងយ៉ាងនេះថា "ផ្សេងនៃចិត្តកម្មរបស់ទីនៅនោះ មិនទាន់ប្រាកដត្រឹមណា, ទីនៅនេះ ចូរជារបស់ភិក្ខុនោះត្រឹមនោះ" ។

វិនិច្ឆ័យក្នុងបទថា **វិប្បកតំ : ធ្វើមិនទាន់ហើយ** នេះ គប្បីជ្រាបដូច្នេះ ៖

បង្គន់ទាំងឡាយ មិនទាន់បានយកឡើងត្រឹមណា ទីនៅ ឈ្មោះថា **ធ្វើមិនទាន់ហើយ** ត្រឹមនោះ ។

តែកាលបង្គន់ទាំងឡាយ បានយកឡើងហើយ ទីលំនៅ ឈ្មោះថា ធ្វើហើយដោយច្រើន, ព្រោះដូច្នោះ ចាប់ផ្ដើមតាំងពីវេលាដែលយកបង្គន់ឡើងហើយទៅនោះ មិនគួរឱ្យធ្វើថ្មី ។ ម្ចាស់របស់ទីនឹងសូមកម្លាំងភិក្ខុឱ្យជួយសាងបន្ថិចបន្តួចទៀតប៉ុណ្ណោះ ។

ពាក្យថា **ខុទ្ទកេ វិហារេ កម្មំ ឱលោកេត្វា ឆប្បញ្ចវស្សិកំ : (បើ) វិហារតូច ឱ្យត្រួតមើលការងារហើយសឹមឱ្យនវកម្មអស់ត្រឹម ៥ ឬ ៦ ឆ្នាំ** មានសេចក្ដីថា ភិក្ខុគប្បីត្រួតមើលល្អហើយឱ្យនវកម្ម ៤ ឆ្នាំ សម្រាប់ ទីលំនៅខ្នាត ៤ ហត្ថ, ៥ ឆ្នាំ សម្រាប់ទីលំនៅ ៥ ហត្ថ, ៦ ឆ្នាំ សម្រាប់ទីលំនៅ ៦ ហត្ថ, ចំណែកអឌ្ឍយោគ: គឺរានហាល ជារបស់មានខ្នាត ៧-៨ ហត្ថ ព្រោះដូច្នោះ ក្នុងរានហាលនេះ ទើបព្រះមាន

ព្រះភាគត្រាស់ថា "៧ ឆ្នាំ ឬ ៨ ឆ្នាំ" ។ ក៏បើវាទហាលនោះមានខ្នាត ៩ ហត្ថ, គប្បីឱ្យនវកម្ម៩ ឆ្នាំក៏បាន ។

មួយទៀត គប្បីឱ្យនវកម្ម ១០ ឆ្នាំ ឬ ១១ ឆ្នាំ សម្រាប់ទីលំនៅ ឬប្រាសាទចាស់មានខ្នាត ១០ ហត្ថ ឬ ១១ ហត្ថ ។ តែគប្បីឱ្យនវកម្ម ១២ ឆ្នាំប៉ុណ្ណោះ សម្រាប់ទីលំនៅ ឬប្រាសាទមានខ្នាត ១២ ហត្ថ ឬ សូម្បីដូចទីនលោហៈប្រាសាទ ដែលធំហួសពីនោះ, មិនគប្បីឱ្យនវកម្មឱ្យ ក្រៃលែងជាង ១២ ឆ្នាំនោះទៅ ។

នវកម្មិកភិក្ខុបានទីលំនៅនោះ ខាងក្នុងវស្សវគ្គៀង, មិនបាន ដើម្បី ទីងហាមឃាត់ក្នុងឧតុកាល (ហេមន្តរដូវនិងគិម្ហរដូវ) ។

បើទីលំនៅនោះទ្រុឌទ្រោម, គប្បីប្រាប់ដល់ម្ចាស់របស់អាវាស ឬ ដល់អ្នកណា ៗ ដែលកើតក្នុងវង្សរបស់គេថា "ទីនៅរបស់ពួកលោកទ្រុឌ ទ្រោម លោកចូរជួសជុលទីលំនៅនោះ" ។

បើថា គេមិនអាច ភិក្ខុទាំងឡាយគប្បីបបួលញាតិ ឬ ឧបដ្ឋាក ជួយជួសជុល ។ បើសូម្បីញាតិនិងឧបដ្ឋាកទាំងនោះ ក៏មិនអាច, គប្បី ជួសជុលដោយបច្ច័យរបស់សង្ឃ សូម្បីកាលបច្ច័យ របស់សង្ឃនោះ មិនមាន ក៏គប្បីចំណាយអាវាស(កុដិ) មួយខ្ទង់ចេញ ជួសជុលអាវាស ដ៏សេសទុក ។ សូម្បីចំណាយអាវាសជាច្រើន ជួសជុលអាវាសមួយខ្ទង់ ទុក ក៏គួរដូចគ្នា ។

ក្នុងគ្រាទុព្ភិក្ខភ័យ កាលភិក្ខុទាំងឡាយនាំគ្នាជៀសចេញទៅអាវាសទាំងពួងនឹងវិនាស, ព្រោះដូច្នោះ គប្បីចំណាយអាវាសមួយខ្នង ឬ ២ ខ្នង ឬ ៣ ខ្នងហើយ បរិភោគយាគូ ភត្ត និងចីវរជាដើម អំពីអាវាសដែលចំណាយនោះ រក្សាអាវាសដ៏សេសទុកចុះ ។

ចំណែកក្នុងកុរុន្ទីពោលថា កាលបច្ច័យរបស់សង្ឃមិនមាន គប្បីបង្គាប់ភិក្ខុមួយរូបថា "លោកចូរកាន់យកទីលួមគ្រែមួយ សម្រាប់លោកជួសជុលចុះ" ។

បើថា ភិក្ខុនោះត្រូវការច្រើនជាងនោះ គប្បីឱ្យបីចំណែក (នៃបួនចំណែក) ឬពាក់កណ្តាលក៏បាន ឱ្យជួសជុលចុះ ។

បើថា លោកមិនប្រាថ្នាដោយឃើញថា "ក្នុងទីនៅនេះ នៅសល់ត្រឹមតែសសរប៉ុណ្ណោះ កិច្ចការដែលនឹងត្រូវធ្វើច្រើន" គប្បីប្រាប់ឱ្យលោកជួសជុលថា "ចូរលោកជួសជុលជាចំណែករបស់លោកប៉ុណ្ណោះចុះ" ព្រោះថា សូម្បីកាលដូច្នេះ ក៏នៅមានទីរក្សារបស់សង្ឃផង នឹងមានស្ថានជាទីនៅរបស់ភិក្ខុថ្មីទាំងឡាយផង ។ ក៏ឯអាវាសដែលភិក្ខុទាំងឡាយជួសជុលហើយយ៉ាងនោះ រមែងជារបស់ចំណែកបុគ្គល ក្នុងកាលភិក្ខុនោះនៅមានជីវិត, កាលភិក្ខុនោះ មរណភាពហើយ រមែងធ្លាក់ជារបស់សង្ឃពិត ។

បើថា ភិក្ខុនោះជាអ្នកប្រាថ្នានឹងឱ្យ (ជាទីនៅ) ដល់សទ្ធិវិហារិ

កទាំងឡាយ ។ សង្ឃគប្បីត្រួតមើលការងារ ហើយគប្បីលើកចំណែកទី ៣ ឬពាក់កណ្តាល ឱ្យលោកជួសជុលជាចំណែកខ្លួន ។

ពិតមែន លោករមែងអាចឱ្យចំណែកនោះ ដល់សទ្ធិវិហារិកទាំងឡាយ ។ ក៏កាលអ្នកជួសជុលយ៉ាងនោះ មិនមាន, គប្បីឱ្យជួសជុលតាមន័យដែលថា គប្បីចំណាយអាវាសមួយខ្ទង់ ដូច្នេះជាដើម ។ ពាក្យសូម្បីនេះផង ពាក្យដទៃផង លោកពោលទុកក្នុងកុរុន្ទីនុ៎ះឯង ។

ភិក្ខុ ២ រូប កាន់យកផ្ទៃដីរបស់សង្ឃ ប្មោសប្រាសហើយ សាងសេនាសនៈជារបស់សង្ឃ ទីដីនោះ ភិក្ខុណាកំណត់មុន, ភិក្ខុនោះជាម្ចាស់ទីនោះ ។ សូម្បីលោកទាំង ២ រូបសាងជាចំណែកបុគ្គល, ភិក្ខុដែលកំណត់មុននុ៎ះឯង ជាម្ចាស់ទី ។

ភិក្ខុដែលកំណត់ផ្ទៃដីមុននោះ សាងជារបស់សង្ឃ, មួយរូបទៀតសាងជាចំណែកបុគ្គល ។ បើថា ទីសាងសេនាសនៈដទៃ ៗ នៅមានច្រើន សូម្បីលោកសាងជាចំណែកបុគ្គល ក៏មិនគួរហាម ។ តែកាលកន្លែងដែលសមគួរដូច្នោះ កន្លែងដទៃមិនមាន ភិក្ខុដែលជាអ្នកសាងរបស់សង្ឃនុ៎ះឯង គប្បីហាមលោក ហើយសាងចុះ ។

ក៏គ្រឿងប្រើប្រាស់ មានសម្ភារៈជាដើម ដែលនឹងត្រូវប្រើប្រាស់អស់ទៅ ក្នុងស្ថានជាទីសាងអាវាសរបស់សង្ឃនោះ របស់ភិក្ខុនោះ សង្ឃគប្បីព្រមឱ្យដល់លោក ។

មួយទៀត បើថា ក្នុងអាវាសដែលសាងរួចហើយក្តី ក្នុងស្ថានជាទីសាងអាវាសក្តី មានដើមឈើដែលអាស្រ័យមួយបាន និងមានផ្លែ, គប្បីអបលោកនៈឱ្យនាំយកចេញចុះ ។ បើដើមឈើទាំងនោះជារបស់បុគ្គល, គប្បីប្រាប់ដល់ម្ចាស់របស់ ។ បើម្ចាស់( របស់ដើមឈើ )មិនព្រមឱ្យ, គប្បីប្រាប់ត្រឹមតែ ៣ ដង ហើយឱ្យកាប់ចេញ ដោយព្រមទទួលថា "ពួកយើងនឹងឱ្យតម្លៃដើមឈើ" ។

ចំណែកភិក្ខុណា មិនកាន់យកគ្រឿងប្រើប្រាស់ សូម្បីកំណត់ប្រមាណថា វល្លិរបស់សង្ឃ ឱ្យសាងទីនៅជាចំណែកបុគ្គល ក្នុងផ្ទៃដីរបស់សង្ឃ ដោយគ្រឿងឧបករណ៍ដែលខ្លួនរកមក, ជារបស់សង្ឃពាក់កណ្តាល ជារបស់បុគ្គលពាក់កណ្តាល ។ បើជាប្រាសាទ[១] ប្រាសាទជាន់ក្រោមជារបស់សង្ឃ ជាន់លើជារបស់បុគ្គល ។ បើភិក្ខុណា ត្រូវការប្រាសាទជាន់ក្រោម, ប្រាសាទជាន់ក្រោម រមែងជារបស់ភិក្ខុនោះ ។ បើលោកត្រូវការទាំងជាន់ក្រោមទាំងជាន់លើ, រមែងបានពាក់កណ្តាលក្នុងជាន់ទាំង ២ ។

ភិក្ខុឱ្យសាងសេនាសនៈ ២ កន្លែង ជារបស់សង្ឃមួយកន្លែង ជា

---

១. ប្រាសាទ សំដៅយកថា ផ្ទះជាន់តាំងពីពីរជាន់ឡើងទៅ មិនបានសំដៅថា ប្រាសាទរាជមណ្ឌប ។

របស់បុគ្គលមួយកន្លែង ។ បើថា ភិក្ខុឲ្យសាងដោយសម្ភារៈជារបស់សង្ឃដែលកើតឡើងក្នុងវត្ត, លោករមែងបានចំណែកទី ៣ ។ បើថាភិក្ខុធ្វើការកសាងឡើងថ្មីក្នុងទីដែលមិនបានធ្វើទុកក្តី តយ៉ាងមុខឡើងខាងក្រោយជញ្ជាំងក្តី, ពាក់កណ្តាលជារបស់សង្ឃពាក់កណ្តាលជារបស់លោក ។ បើថា ស្ថានទីធំមិនស្មើ ជាទីដែលភិក្ខុពូនឲ្យស្មើ សម្តែងមកដើរក្នុងកន្លែងដែលមិនមែនមក, សង្ឃមិនជាធំក្នុងទីនោះ ។

## សិទ្ធិនៃនវកម្មិកៈ

[៤០៩] ក្នុងពាក្យថា ឯកំ វរសេយ្យំ : ទីដេកដ៏ប្រសើរ ១ នេះ មានសេចក្តីថា ក្នុងស្ថានទីឲ្យនវកម្មក្តី ក្នុងស្ថានទីតាមលំដាប់វស្សាក្តី ភិក្ខុដែលជួសជុលប្រាថ្នាសេនាសនៈណា រមែងបានសេនាសនៈនោះ, អធិប្បាយថា តថាគតអនុញ្ញាតឲ្យ (ភិក្ខុដែលធ្វើនវកម្មនោះ) ទទួលទីដេកដ៏ប្រសើរមួយកន្លែងបាន ។

[៤១៥] ពាក្យថា បរិយោសិតេ បក្កមតិ តស្សេវ តំ : ហើយចៀសចេញទៅក្នុងវេលាដែលធ្វើ (នវកម្ម) ហើយស្រេច (លុះត្រឡប់មកនៅវិញ) នវកម្មនុ៎ះ ជារបស់ភិក្ខុនោះឯង ។ មានសេចក្តីថា កាលភិក្ខុនោះត្រឡប់មកចាំវស្សាទៀត សេនាសនៈនោះ ជារបស់លោក

ប៉ុណ្ណោះ រហូតដល់អស់ខាងក្នុងវស្សាតែកាលលោកមិនមក សទ្ធិវិហារិកជាដើម នឹងកាន់យកមិនបាន ។

[៤២១] បទថា ឆាភិហរន្តិ[1] : មិនហ៊ាននាំចេញ មានសេចក្តីថា ភិក្ខុទាំងឡាយមិនហ៊ាននាំ (សេនាសនៈ)ទៅប្រើប្រាស់ក្នុងទីដទៃ ។ បទថា គុត្តត្ថាយ : យកទៅទុករក្សា មានសេចក្តីថា តថាគតអនុញ្ញាតឱ្យនាំសេនាសនៈ មានគ្រែ និងតាំងជាដើម ក្នុងទីនៅនោះទៅ ក្នុងទីដទៃ ដើម្បីប្រយោជន៍ដល់ការរក្សាសេនាសនៈនោះ ។ ព្រោះហេតុនោះ កាលភិក្ខុនាំទៅក្នុងទីដទៃ ហើយប្រើប្រាស់ជាសង្ឃបរិភោគ សេនាសនៈនោះវិនាសទៅ ក៏ជាការវិនាសទៅដោយល្អ ចាស់ទៅ ក៏ជាការចាស់ទៅដោយល្អ, បើសេនាសនៈនោះ មិនទាន់វិនាសទេ គប្បីរក្សាទុកដាក់ដូចដើមវិញ ក្នុងកាល ដែលទីនៅនោះ បានជួសជុលរួចស្រេចហើយ ។ កាលភិក្ខុប្រើប្រាស់ដោយការប្រើប្រាស់ជាចំណែក បុគ្គល សេនាសនៈនោះវិនាសទៅក្តី ចាស់ទៅក្តី ជាសំណង ។ កាលទីនៅនោះ បានជួសជុលរួចស្រេចហើយ ត្រូវសងវិញតែម្តង ។

បើថា ភិក្ខុកាន់យកសម្ភារៈទាំងឡាយ មានបង្គន់ជាដើម ពីសង្ឃិកាវាសនោះ ប្រកបក្នុងសង្ឃិកាវាសដទៃ ដែលប្រកបហើយ ក៏ជាការ

១. ភូមា. នាតិហរន្តិ ។

ប្រកបដោយល្អ ។

តែភិក្ខុដែលប្រកបក្នុងអាវាសចំណែកបុគ្គល ត្រូវឱ្យតម្លៃ ឬ ត្រូវយកត្រឡប់សងទុកដូចដើម ។ ភិក្ខុមានថេយ្យចិត្ត កាន់យកគ្រែ និងតាំងជាដើម អំពីទីនៅដែលត្រូវលះបោល ព្រះវិន័យធរ គប្បីពិន័យតាមតម្លៃភណ្ឌៈ ក្នុងខណៈដែលលើកឡើងតែម្តង ។

កាលភិក្ខុកាន់យកប្រើប្រាស់ ជាសង្ឃបរិភោគ ដោយតាំងចិត្តថា នឹងឱ្យក្នុងវេលាដែលអាវាសិកភិក្ខុត្រឡប់មកវិញ, (គ្រែ និងតាំងជាដើមនោះ)វិនាសទៅ ក៏វិនាសទៅដោយល្អ ចាស់ទៅ ក៏ចាស់ទៅដោយល្អ, បើមិនវិនាស គប្បីសងទុកដូចដើម, កាលភិក្ខុប្រើប្រាស់ដោយការប្រើប្រាស់ជាចំណែកបុគ្គល វិនាសទៅ ជាសំណង ។ សម្ភារៈមានទ្វារបង្អួចជាដើម ដែលភិក្ខុកាន់យកចាកទីនៅដែលត្រូវលះបោលនោះ ទៅផ្សំប្រើក្នុងសង្ឃិកាវាស ឬក្នុងអាវាសចំណែកបុគ្គល ត្រូវសងវិញពិត ។

[៤២២] បទថា ជាតិកម្មត្ថាយ **: ដើម្បីប្រយោជន៍ជាផាតិកម្ម គឺការចម្រើន** គឺ ដើម្បីប្រយោជន៍ដល់ការធ្វើបន្ថែមឡើង ។

ក៏សេនាសនៈមានគ្រែ និងតាំងជាដើមនុះឯង ដែលមានតម្លៃស្មើគ្នា ឬច្រើនជាង ជាផាតិកម្ម រមែងគួរក្នុងពាក្យថា ដើម្បីប្រយោជន៍ដល់ផាតិកម្ម នេះ ។

# ការប្រើសេនាសនៈ

[៤២៥] គ្រឿងជូតជើង មានសណ្ឋានស្រដៀងកូនកង់ ដែលធ្វើការរុំដោយសំពត់កម្ពលជាដើម ឈ្មោះថា ចក្កលី ។

[៤២៨] ពាក្យថា អល្លេហិ បាទេហិ : ទាំងជើងទទឹក មានសេចក្ដីថា ទឹករមែង ប្រាកដក្នុងទីដែលជើងជាន់ហើយ, ផែនដីក្ដីសេនាសនៈក្ដី ដែលធ្វើដោយការបូកលាប ដែលភិក្ខុមិនគប្បីជាន់ដោយជើង ដូច្នោះ ។ តែបើថា ប្រាកដត្រឹមតែស្នាមទឹកព្រាល ៗប៉ុណ្ណោះ ទឹកមិនប្រាកដទេ, គួរជាន់បាន ។ មួយទៀត ទីងជាន់សំពត់ជូតជើង សូម្បីដោយជើងដែលសើមជោគ ក៏គួរដូចគ្នា ។

[៤២៩] ភិក្ខុដែលពាក់ស្បែកជើង មិនគួរជាន់ក្នុងទីដែលគប្បីជាន់ដោយជើងលាងហើយតែម្ដង ។

[៤៣១] ពាក្យថា ចោឡកេន បលិវេឋេត្វា : រុំដោយកំណាត់សំពត់ មានសេចក្ដីថា ទីផ្ទៃកំបោរស ឬទីផ្ទៃបូកលាប បើមិនមានកន្ទេលទន់ ឬកន្ទេលផែង[១], គប្បីយកសំពត់រុំជើង (គ្រែនិងតាំង)ចេញ ។ កាលសំពត់នោះ មិនមាន សូម្បីស្លឹកឈើក៏គួរទ្រាប់ ។ ភិក្ខុដែលដាក់

---

១. ហៅកន្ទេលផែងនេះ ថាកន្ទេលរឹង ក៏បាន ព្រោះធ្វើដោយបន្ទះឫស្សី, គួគ្នានឹងកន្ទេលទន់

(គ្រែនិងតាំង)ចុះទៅ ដោយមិនទ្រាប់អ្វី ៗសោះ ត្រូវអាបត្តិទុក្កដ ។

បើនេវាសិកភិក្ខុនោះ ដាក់លើផែនដី សូម្បីក្រាលហើយ តែប្រើប្រាស់ទាំងដែលមានជើងមិនបានលាង, នឹងប្រើប្រាស់យ៉ាងនោះខ្លះ ក៏គួរ ។

[៤៣២] ពាក្យថា ន ភិក្ខវេ បរិកម្មកតា ភិត្តិ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវផ្អែកនឹងជញ្ជាំងដែលគេលាបថ្នាំផ្សេង ៗទេ មានសេចក្ដីថា ជញ្ជាំងដែលលាបកំបោរសក៏ដោយ ជញ្ជាំងដែលធ្វើចិត្តកម្មក៏ដោយ មិនគួរផ្អែក, និងមិនគួរផ្អែកជញ្ជាំងតែម្យ៉ាងប៉ុណ្ណោះក៏ទេ, សូម្បីទ្វារក្ដី បង្អួចក្ដី ភ្នាក់ដៃ(ឬបង្អែក)ក្ដី សសរថ្មក្ដី សសរឈើក្ដី ភិក្ខុមិនទ្រាប់ដោយចីវរ ឬរបស់យ៉ាងណាមួយហើយ រមែងមិនបានដើម្បីនឹងផ្អែកដូចគ្នា ។

[៤៣៣] ពាក្យថា ធោតបាទកា : មានជើងលាងស្រេចហើយ មានសេចក្ដីថា ភិក្ខុជាអ្នកមានជើងលាងហើយ រមែងរង្កៀសទីដេក ក្នុងទីដែលគប្បីជាន់ដោយជើងដែលលាងហើយ ។ បាឋៈថា ធោតបាទកេ ខ្លះក៏មាន ។

ពាក្យថា ធោតបាទកេ នោះ ជាឈ្មោះរបស់ដែលត្រូវជាន់ដោយជើងដែលលាងហើយ ។

ពាក្យថា បច្ចត្ថរិត្វា : ឱ្យក្រាលកម្រាល មានសេចក្ដីថា ផ្ទៃដីបូកលាបក្ដីសេនាសនៈ មានទ្រនាប់ផែនដីក្ដី គ្រែតាំងរបស់សង្ឃក្ដី ត្រូវ

យកកម្រាលរបស់ ខ្លួនក្រាលទ្រជាមុន សឹមដេក ។

បើសូម្បីកាលភិក្ខុកំពុងលង់លក់ កម្រាលរំកិលរសាត់ផុតពីអវយវៈនៃសរីរៈចំណែកខ្លះប៉ះត្រូវគ្រែ ឬតាំង, ជាអាបត្តិដូចគ្នា ។ តែកាលរោមពាល់ត្រូវ ជាអាបត្តិតាមចំនួនរោម[១] ។ សូម្បីកាលផ្អែកដោយប្រាថ្នាប្រើប្រាស់ជាធំ ក៏មានន័យដូចគ្នា ។ តែពាល់ត្រូវឬជាន់ដោយបាតដៃបាតជើង គួរ ។ គ្រែតាំងប៉ះខ្លួនកាយរបស់ភិក្ខុដែលកំពុងជញ្ជូនទៅមិនជាអាបត្តិ ។

## សង្ឃភត្ត

[៤៣៥] ពាក្យថា ន សក្កោន្តិ សង្ឃភត្តំ កាតុំ : មិនអាចនឹងធ្វើសង្ឃភត្តបាន មានសេចក្ដីថា ក៏ឯជនទាំងឡាយមិនអាចធ្វើភត្តដើម្បីសង្ឃទាំងមូលបាន ។ វិនិច្ឆ័យក្នុងពាក្យថា ឥច្ឆន្តិ ឧទ្ទេសភត្តំ : ហើយក៏ប្រាថ្នានឹងធ្វើឧទ្ទេសភត្ត ជាដើម គប្បីជ្រាបដូច្នេះ ៖

ជនទាំងឡាយប្រាថ្នានឹងធ្វើភត្ត ដើម្បីភិក្ខុដែលខ្លួនបានដោយការចំពោះយ៉ាងនេះថា "សូមលោកម្ចាស់ឱ្យភិក្ខុ ១ រូប ឬ ២ រូប ។ល។ ឬ ១០ រូបដែលចាត់អំពីសង្ឃ" ។

---

១. បើពិន័យអាបត្តិតាមចំនួនប៉ះត្រូវ តើសមគួរទេ ? ព្រោះក្នុងការពិន័យ អាបត្តិដទៃ (គឺ កាយសំសគ្គៈ) លោកមិនពិន័យដោយសរសៃរោមយ៉ាងនេះ ។

ជនមួយពួកទៀត ប្រាថ្នានឹងកំណត់ចំនួនភិក្ខុយ៉ាងនោះ ដូចគ្នា និមន្តហើយធ្វើភត្តដើម្បីភិក្ខុទាំងនោះ ។

មួយពួកទៀត ប្រាថ្នានឹងកំណត់ស្លាក និមន្តហើយធ្វើភត្តដើម្បីភិក្ខុទាំងនោះ ។

មួយពួកទៀត ប្រាថ្នានឹងធ្វើភត្តដើម្បីភិក្ខុ ១ រូប ឬ ២ រូប ។ល។ ឬ ១០ រូប និមន្តទុកយ៉ាងនេះថា បក្ខិកភត្ត ឧបោសថិកភត្ត បាដិបទិកភត្ត ភត្តមានប្រមាណប៉ុណ្ណេះ បានវោហារនេះថា ឧទ្ទេសភត្ត និមន្តនភត្ត ដោយប្រការដូច្នេះ ។

មួយទៀត សូម្បីបើថា ជនទាំងនោះ មិនអាចនឹងធ្វើសង្ឃភត្តបាន ក្នុងគ្រាទុព្ភិក្ខភ័យ, តែនឹងអាចធ្វើសង្ឃភត្តបាន ក្នុងគ្រាមានភិក្ខាហារបានងាយ; ព្រោះដូច្នោះ ទើបព្រះមានព្រះភាគទ្រង់រួម សូម្បីនូវសង្ឃភត្តនោះ ទុកក្នុងចំនួនដោយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសង្ឃភត្ត ឧទ្ទេសភត្ត" ដូច្នេះ ជាដើម ។

បណ្តាភត្តទាំងនោះ ក្នុងសង្ឃភត្តមិនមានលំដាប់ជាធម្មតា, ព្រោះដូច្នោះក្នុងសង្ឃភត្តនោះ ភិក្ខុទាំងឡាយមិនគួរពោលយ៉ាងនេះថា "១០ ថ្ងៃ ឬ ១២ ថ្ងៃ ទាំងថ្ងៃនេះហើយ ចំពោះដែលពួកយើងឆាន់, ឥឡូវនេះ ចូរលោកនិមន្តភិក្ខុមកអំពីទីដទៃចុះ" ។ ទាំងមិនបានដើម្បីពោលយ៉ាងនេះថា "ក្នុងថ្ងៃមុន ៗ ពួកយើងមិនបានឡើយ, ឥឡូវនេះ ចូរលោកឱ្យពួក

យើងទទួលសង្ឃភត្តនោះខ្លះ” ដូច្នេះ ។ ព្រោះថា សង្ឃភត្តនោះ រមែងត្រូវបានដល់ភិក្ខុដែលមកហើយ ៗ ប៉ុណ្ណោះ ។

## ឧទ្ទេសភត្ត

ចំណែកក្នុងឧទ្ទេសភត្តជាដើម មានន័យដូច្នេះ ៖

កាលព្រះរាជាឬមហាមាត្យរបស់ព្រះរាជា បញ្ជូនមនុស្សទៅនិមន្តថា “សូមលោកម្ចាស់ចាត់អំពីសង្ឃមកប៉ុណ្ណេះរូប” ដូច្នេះ ភត្តុទ្ទេសកៈគប្បីបញ្ជាក់វេលាសួរកេលំដាប់, បើលំដាប់មានគប្បីឱ្យទទួលតាំងពីលំដាប់នោះ, បើមិនមាន គប្បីឱ្យទទួលតាំងពីថេរាសនៈចុះមក, ភត្តុទ្ទេសកៈកុំគប្បីរំលងលំដាប់ សូម្បីនៃភិក្ខុដែលត្រាច់បិណ្ឌបាត ។ ភិក្ខុដែលត្រាច់បិណ្ឌបាតទាំងនោះ កាលរក្សាធុតង្គ ទើងឱ្យរំលង(គឺហាមឃាត់)ដោយខ្លួនឯង ។

កាលឱ្យទទួលដោយវិធីយ៉ាងនេះ ព្រះមហាថេរៈជាអ្នកមានប្រក្រតីយឺតយ៉ាវមកខាងក្រោយ, កុំពោលនឹងលោកថា “លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាកំពុងឱ្យភិក្ខុ ២០ វស្សាទទួល, លំដាប់របស់លោកម្ចាស់រំលងហួសទៅហើយ” ដូច្នេះឡើយ ។ គប្បីវៀរលំដាប់ទុកឱ្យព្រះមហាថេរៈទាំងនោះ ទទួលស្រេចហើយ សឹមឱ្យទទួលតាមលំដាប់ខាងក្រោយបន្តទៀត ។

ភិក្ខុទាំងឡាយ បានស្តាប់ដំណឹងថា “ក្នុងសំណាក់ឯណោះ ឧទ្ទេសភត្តកើតឡើងច្រើន” ទើបនាំគ្នាមក សូម្បីពីសំណាក់ដែលមានចម្ងាយមួយយោជន៍ ។ គប្បីឱ្យភិក្ខុទាំងនោះ ទទួលចាប់ផ្តើមតាំងពីស្ថានដែលពួកលោកមកទាន់ហើយ ៗ ឈរ ។

កាលអន្តេវាសិកជាដើម ទទួលជំនួសអាចារ្យ និងឧបជ្ឈាយ៍ សូម្បីមកមិនទាន់ តែបានចូលក្នុងឧបចារៈសីមាហើយ គប្បីឱ្យទទួលចុះ ។ ពួកលោកពោលថា “លោកម្ចាស់ចូរឱ្យ ( ខ្ញុំព្រះករុណា ) ទទួលជំនួសភិក្ខុទាំងឡាយ ដែលស្ថិតនៅក្រៅឧបចារៈសីមា”, កុំឱ្យទទួល ។ តែថា ភិក្ខុដែលនៅត្រង់ទ្វារសំណាក់ ឬទីខាងក្នុងសំណាក់របស់ខ្លួន ( ខាងក្រៅឧបចារៈសីមា ) ដែលនៅជាប់តអំពីភិក្ខុទាំងឡាយ ដែលចូលក្នុងឧបចារៈសីមាហើយ ។ សីមាចាត់ថា រីកចេញដោយអំណាចបរិស័ទ ព្រោះដូច្នោះ គប្បីឱ្យទទួល ។

សូម្បីឱ្យដល់សង្ឃនវកៈហើយ ក៏គួរឱ្យភិក្ខុទាំងឡាយដែលមកខាងក្រោយទទួលដូចគ្នា ។ តែកាលចំណែកទី ២ បានលើកឡើងកាន់ថេរាសនៈហើយ ចំណែកទី ១ រមែងមិនត្រូវបានដល់ភិក្ខុដែលមកខាងក្រោយ ។ គប្បីឱ្យទទួលតាមលំដាប់វស្សាតាំងពីចំណែកទី ២ ទៅ ។

ក្នុងសំណាក់មួយ ឧទ្ទេសភត្ត ដែលទាយកកំណត់ស្ថានទីចែកភត្តទុកមួយកន្លែង ហើយប្រាប់ក្នុងទីណាមួយ ក្នុងឧបចារៈសីមា សូម្បីមាន

ប្រមាណមួយគាវុត ត្រូវឱ្យទទួលក្នុងស្ថានទីចែកភត្តនោះឯង ។

ទាយកម្នាក់ បញ្ជូនដំណឹងដល់ភិក្ខុមួយរូបថា "ស្អែកនេះ សូមលោកម្ចាស់បញ្ជូនភិក្ខុអំពីសង្ឃចំនួន ១០ រូប" ។ ភិក្ខុនោះ គប្បីប្រាប់សេចក្ដីនោះដល់ភត្តុទ្ទេសកៈ បើថ្ងៃនោះភ្លេច, ព្រឹកឡើងគប្បីប្រាប់ ។ បើភ្លេចហើយ កាលចូលទៅបិណ្ឌបាត ទើបរលឹកបាន, សង្ឃមិនទាន់ឈានកន្លងឧបចារៈសីមាត្រឹមណា, គប្បីឱ្យទទួលជាប់ដោយលំដាប់តាមប្រក្រតីក្នុងរោងឆាន់ត្រឹមនោះ ។

សូម្បីភិក្ខុទាំងឡាយ ឈានកន្លងឧបចារៈសីមាទៅ ហើយ ជាអ្នកជាប់បន្តគ្នាជាមួយនឹងភិក្ខុទាំងឡាយដែលតាំងនៅក្នុងឧបចារៈសីមា គឺដើរទៅមិនឆ្ងាយពីគ្នា ១២ ហត្ថ ។ គប្បីឱ្យទទួលជាប់គ្នាតាមលំដាប់ជាប្រក្រតី តែកាលការជាប់បន្តជាមួយគ្នា ដូច្នោះ របស់ភិក្ខុទាំងឡាយមិនមាន, ខ្លួនរលឹកបានក្នុងទីខាងក្រៅឧបចារៈសីមា, គប្បីចាត់លំដាប់ថ្មីឱ្យកាន់យកក្នុងទីនោះ ។ កាលរលឹកបានត្រង់រោងឆាន់ខាងក្នុងស្រុក គប្បីឱ្យកាន់យកតាមលំដាប់ក្នុងរោងឆាន់ ។ រលឹកបានក្នុងទីណាមួយ ក៏គប្បីឱ្យកាន់យកពិត, នឹងមិនឱ្យកាន់យកមិនគួរ ។ ព្រោះថា ក្នុងថ្ងៃទី ២ នឹងមិនបានភត្តនោះ ។

បើទាយកខ្លះឃើញភិក្ខុទាំងឡាយចេញចាកទីនៅរបស់ខ្លួន ទៅកាន់សំណាក់ដទៃ ទើបសូមឱ្យចែកឧទ្ទេសភត្ត ។

ភិក្ខុទាំងឡាយ នៅខាងក្នុងទីជិតនឹងភិក្ខុទាំងឡាយ ដែលតាំងនៅក្នុងឧបចារៈសីមា ជាអ្នកជាប់បន្តជាមួយគ្នា តាមន័យដែលពោលហើយនុ៎ះឯង គប្បីឱ្យកាន់យកដោយអំណាចលំដាប់ ក្នុងទីនៅរបស់ខ្លួននុ៎ះឯងត្រឹមនោះ ។

ចំណែកឧទ្ទេសភត្ត ដែលទាយកប្រគេនភិក្ខុទាំងឡាយ ឋិតនៅក្រៅឧបចារៈ កាលគេពោលថា "លោកម្ចាស់ សូមលោកសម្តែងភិក្ខុត្រឹមប៉ុណ្ណោះរូបអំពីសង្ឃ" ដូច្នេះ គប្បីឱ្យកាន់យកតាមលំដាប់នៃភិក្ខុដែលមកទាន់ ។

សូម្បីភិក្ខុដែលឋិតនៅក្នុងទីឆ្ងាយ តាមន័យដែលជាប់ជាជួរតែមួយ មិនឆ្ងាយពីគ្នា ១២ ហត្ថ ក្រៅឧបចារៈនោះឯង គប្បីជ្រាបថា អ្នកមកទាន់ដូចគ្នា ។

បើភិក្ខុទាំងឡាយទៅកាន់សំណាក់ណា, គេប្រាប់ដល់ភិក្ខុទាំងឡាយអ្នកចូលទៅក្នុងសំណាក់នោះហើយ ; គប្បីកាន់យកដោយអំណាចលំដាប់នៃសំណាក់នោះ ។

សូម្បីទាយកណាមួយ ជួបភិក្ខុក្បែរទ្វារស្រុក ឬត្រង់ថ្នល់ ឬត្រង់មកបែកជា ៤ ឬក្នុងចន្លោះស្រុក ទើបប្រាប់ភត្តដែលគប្បីសម្តែងអំពីសង្ឃ ឱ្យភិក្ខុទាំងឡាយ ដែលនៅខាងក្នុងឧបចារៈនោះ កាន់យក ។

ក៏បណ្តាឧបចារៈនៃទ្វារស្រុកជាដើមនេះ ឧបចារៈផ្ទះ គប្បីជ្រាប

ដោយអំណាចនៃផ្ទះទាំងនេះ គឺ ៖

ផ្ទះមួយខ្នង មានឧបចារៈតែមួយ, ផ្ទះមួយខ្នង មានឧបចារៈផ្សេងគ្នា ។ ផ្ទះច្រើនខ្នង មានឧបចារៈជាមួយគ្នា, ផ្ទះច្រើនខ្នង មានឧបចារៈផ្សេងគ្នា ។

ក្នុងផ្ទះទាំងនោះ ផ្ទះរបស់ត្រកូលណាមួយ ជាទីប្រើប្រាស់ (ដែលចេញដោយទ្វារតែមួយរួមគ្នា), ផ្ទះនោះ ឈ្មោះថា មានឧបចារៈតែមួយ រួមចូលមកខាងក្នុងតាំងពីដែនកំណត់ទីធ្លាក់ចុះនៃចង្អ្រែ ។

ឧទ្ទេសលាភដែលកើតឡើងក្នុងផ្ទះនោះ រមែងត្រូវបានដល់ភិក្ខុទាំងពួងដែលនៅឈរ សូម្បីដោយភិក្ខាចារវត្ត ក្នុងឧបចារៈនោះ, នេះឈ្មោះថា ផ្ទះមួយខ្នង មានឧបចារៈតែមួយ ។

ចំណែកផ្ទះណាមួយ គេបាំងជញ្ជាំងត្រង់កណ្តាល ដើម្បីត្រូវការនៅសប្បាយសម្រាប់ភរិយា ២ នាក់ ធ្វើទ្វារសម្រាប់ប្រើប្រាស់ម្នាក់មួយ, ឧទ្ទេសលាភដែលកើតឡើងក្នុងផ្ទះនោះ មិនត្រូវបានដល់ភិក្ខុដែលនៅខាងក្នុងបន្ទប់ជញ្ជាំងផ្នែកមួយ ត្រូវបានដល់ភិក្ខុដែលអង្គុយនៅក្នុងទីនោះប៉ុណ្ណោះ, នេះឈ្មោះថា ផ្ទះមួយខ្នង ឧបចារៈផ្សេងគ្នា ។

ចំណែកក្នុងផ្ទះណា គេនិមន្តភិក្ខុច្រើនរូបឱ្យអង្គុយជាប់តគ្នា តាំងពីខាងក្នុងផ្ទះដរាបពេញទិសហៀរដល់ផ្ទះមិត្តជិតខាង, ឧទ្ទេសលាភដែលកើតឡើងក្នុងផ្ទះនោះ ត្រូវបានដល់ភិក្ខុគ្រប់រូបទាំងអស់ ។

សូម្បីផ្ទះណារបស់ត្រកូលផ្សេងគ្នា គេមិនធ្វើជញ្ជាំងកណ្ដាល ប្រើប្រាស់មកទ្វារតែមួយរួមគ្នានុ៎ះឯង, សូម្បីក្នុងផ្ទះនោះ ក៏មានន័យដូចគ្នា, នេះឈ្មោះថា ផ្ទះផ្សេងគ្នា មានឧបចារៈជាមួយគ្នា ។

ឧទ្ទេសលាភណា កើតឡើងដល់ភិក្ខុទាំងឡាយ ដែលអង្គុយក្នុងផ្ទះត្រកូលផ្សេងគ្នា, ភិក្ខុទាំងឡាយ រមែងឃើញគ្នាតាមប្រហោងជញ្ជាំងក៏ពិតមែន, តែថាឧទ្ទេសលាភនោះ រមែងត្រូវបានដល់ភិក្ខុទាំងឡាយដែលអង្គុយក្នុងផ្ទះនោះ ៗ ប៉ុណ្ណោះ, នេះឈ្មោះថា ផ្ទះផ្សេងគ្នា មានឧបចារៈផ្សេងគ្នា ។

មួយទៀត ភិក្ខុណាបានឧទ្ទេសភត្តត្រង់ទ្វារស្រុក ថ្នល់ និង មកបែកជា ៤ ស្ថានទីណាមួយ, កាលភិក្ខុដទៃមិនមាន ទើប( អធិដ្ឋាន )ឱ្យសម្រេចដល់ខ្លួន ហើយនឹងបានឧទ្ទេសភត្តដទៃក្នុងទីនោះឯង សូម្បីក្នុងថ្ងៃស្អែក ។ ភិក្ខុនោះឃើញភិក្ខុដទៃណាជានវកៈ ឬចាស់ក៏ដោយ គប្បីឱ្យភិក្ខុនោះទទួល ។ បើថា មិនមានអ្នកណា ៗ ឡើយ, ក៏( អធិដ្ឋានឱ្យ )បានដល់ខ្លួន ហើយឆាន់ចុះ ។

បើថា កាលភិក្ខុទាំងឡាយ អង្គុយរង់ចាំវេលា នៅក្នុងសាលាឆាន់ មានឧបាសកខ្លះមកពោលថា "សូមលោកម្ចាស់ឱ្យបាត្រដែលសង្ឃចាត់, សូមលោកម្ចាស់ឱ្យបាត្រដែលចាត់, សូមលោកម្ចាស់ឱ្យបាត្រដែលសម្ដែងអំពីសង្ឃ, សូមលោកម្ចាស់ឱ្យបាត្ររបស់សង្ឃ" ។ ឧទ្ទេសបាត្រគួរឱ្យ

ភិក្ខុទទួលតាមពាក្យបង្គាប់ ហើយឱ្យទៅចុះ ។

សូម្បីក្នុងពាក្យដែលគេពោលថា "សូមលោកម្ចាស់ឱ្យភិក្ខុដែលសង្ឃចាត់ សូមលោកម្ចាស់ឱ្យភិក្ខុដែលសម្ដែងអំពីសង្ឃ សូមលោកម្ចាស់ឱ្យភិក្ខុជារបស់សង្ឃ" ក៏មានន័យដូចគ្នា ។

ក៏ក្នុងរឿងឧទ្ទេសភត្តនេះ គប្បីប្រាថ្នាភត្តុទ្ទេសកៈ ជាអ្នកមានសីលជាទីស្រឡាញ់ មានសេចក្ដីខ្លាសបាប មានសេចក្ដីឆ្លាត ។ ភិក្ខុភត្តុទ្ទេសកៈនោះ គប្បីសួរលំដាប់ ៣ ដង បើមិនមានអ្នកណា ៗ ជ្រាបលំដាប់ គប្បីឱ្យកាន់យកតាមថេរាសនៈ ។ តែបើភិក្ខុរូបខ្លះពោលថា "ខ្ញុំព្រះករុណាជ្រាបភិក្ខុ ១០ វស្សាបាន" គប្បីសួរថា "អ្នកមានអាយុ ១០ វស្សាមានទេ ?" បើភិក្ខុបានស្ដាប់ពាក្យរបស់លោកទើបប្រាប់ថា "យើង ១០ វស្សា យើង ១០ វស្សា" ហើយនាំគ្នាមកច្រើន ។ កុំគប្បីពោលថា "ត្រូវបានដល់លោក ត្រូវបានដល់លោក" គប្បីបង្គាប់ថា "ពួកលោកចូរស្ងៀមស្ងាត់សំឡេងទាំងអស់" ហើយចាត់តាមលំដាប់ ។

គ្រាចាត់ហើយ គប្បីសួរឧបាសកថា "អ្នកត្រូវការភិក្ខុប៉ុន្មាន ?" កាលគេឆ្លើយថា "ប៉ុណ្ណេះលោកម្ចាស់" ហើយកុំពោលថា "ត្រូវបានដល់លោក ត្រូវបានដល់លោក" គប្បីសួរដល់ចំនួនវស្សា រដូវ ចំណែកនៃថ្ងៃ និងស្រមោលរបស់ភិក្ខុដែលមកថ្មីគ្រប់រូប ។

កាលកំពុងសួរដល់ស្រមោល ភិក្ខុដែលចាស់ជាងភិក្ខុដទៃមកដល់,

គប្បីឱ្យដល់លោក, បើកាលសួរដល់ស្រមោលរួចស្រេចហើយបន្ទាប់ថា "ដល់លោកផង" ដូច្នេះ ភិក្ខុដែលចាស់ជាងមកដល់ ក៏មិនបាន ។

ពិតមែន កាលភិក្ខុដែលចាស់ជាង អង្គុយដោយសេចក្តីយឺតយូរនៃពាក្យក្តី ដេកលក់ក្តី ឧទ្ទេសភត្តដែលឱ្យភិក្ខុថ្មីជាងកាន់យកហើយ ក៏ជាការឱ្យកាន់យកហើយដោយល្អ, កន្លងហួសលំដាប់ទៅ ក៏ជាការកន្លងទៅដោយល្អ ។ ព្រោះថា ធម្មតារបស់ដែលគួរចែកគ្នានោះ រមែងត្រូវបានដល់ភិក្ខុដែលមកទាន់ប៉ុណ្ណោះ, ភាពជាអ្នកមកទាន់ក្នុងទីនោះ គប្បីកំណត់ដោយឧបចារៈ ។

ក៏ឯខាងក្នុងរោងឆាន់ គ្រឿងលោមព័ទ្ធជាឧបចារៈ ។ លាភរមែងត្រូវបានដល់ភិក្ខុដែលនៅក្នុងឧបចារៈនោះ ដូច្នេះឯង ។

ទាយកខ្លះ ប្រើមនុស្សឱ្យនាំឧទ្ទេសបាត្រ ៨ មកពីរោងឆាន់ដាក់ភោជនប្រណីតពេញ ៧ បាត្រ, បាត្រមួយដាក់ទឹកពេញបញ្ជូនទៅកាន់រោងឆាន់ អ្នកកាន់មកមិននិយាយយ៉ាងណាទេ ប្រគេនទុកក្នុងដៃភិក្ខុទាំងឡាយហើយជៀសទៅ ។ ភត្តណាដែលភិក្ខុបានហើយ ភត្តនោះ រមែងជារបស់ភិក្ខុនោះនុ៎ះឯង ។

ចំណែកទឹកភិក្ខុណាបាន គប្បីវៀរលំដាប់សូម្បីដែលកន្លងហួសទៅហើយរបស់ភិក្ខុនោះ ឱ្យលោកកាន់យកឧទ្ទេសភត្តចំណែកដទៃ ។

ក៏ឯលោកបានឧទ្ទេសភត្ត ចំណែកនោះ ស្មោហ្មងក៏ដោយ

ប្រណីតក៏ដោយ មានត្រៃចីវរជាបរិវារក៏ដោយ ភត្តនោះ រមែងជារបស់លោកទាំងអស់ ។

ពិតមែន លាភដូច្នេះ ជាបុណ្យពិសេសរបស់លោក, តែទឹកមិនមែនអាមិស ព្រោះដូច្នោះ លោកទើបត្រូវបានឧទ្ទេសភត្តដទៃ ។

តែបើជនអ្នកកាន់មកនោះពោលថា "លោកម្ចាស់ដ៏ចម្រើន បានឮថា ភត្តទាំងពួងនេះ លោកម្ចាស់ចូរបែងចែកគ្នាឆាន់នោះឯង" ដូច្នេះហើយទើបទៅ ។ ទឹកដែលភិក្ខុទាំងពួងគប្បីបែងចែកគ្នាផឹក ។

តែកាលទាយកពោលថា "លោកម្ចាស់ចាត់អំពីសង្ឃ ឱ្យព្រះមហាថេរៈ ៨ រូប, ឱ្យភិក្ខុកណ្តាល, ឱ្យភិក្ខុថ្មី, ឱ្យសាមណេរអ្នកមានឆ្នាំគ្រប់, ឱ្យភិក្ខុដែលពោលមជ្ឈិមនិកាយជាដើម ចូរឱ្យភិក្ខុដែលជាញាតិរបស់ខ្ញុំព្រះករុណា" ។

ភិក្ខុភត្តុទ្ទេសកៈ គប្បីពោលថា "ឧបាសក ក អ្នកនិយាយយ៉ាងនេះ, តែលំដាប់របស់លោកទាំងនោះ មិនទាន់ដល់" ដូច្នេះហើយ គប្បីឱ្យជាប់ដោយលំដាប់នោះឯង មួយទៀត កាលភិក្ខុកម្លោះនិងសាមណេរបានឧទ្ទេសភត្តហើយ, បើក្នុងផ្ទះរបស់ពួកទាយក មានមង្គល, គប្បីបង្គាប់ថា "ពួកលោកចូរនិមន្តអាចារ្យ និងឧបជ្ឈាយ៍របស់លោកមកចុះ" ។

ក៏ក្នុងឧទ្ទេសភត្តណា ចំណែកទី ១ ត្រូវបានដល់សាមណេរ ចំណែកបន្ទាប់ត្រូវបានដល់ព្រះមហាថេរៈទាំងឡាយ ក្នុងឧទ្ទេសភត្តនោះ

សាមណេរ រមែងមិនបាន ដើម្បីនឹងទៅខាងមុខដោយធ្វើទុកក្នុងចិត្តថា "យើងទាំងឡាយបានចំណែកទី ១" គប្បីទៅតាមលំដាប់ន៏ុះឯង ។

កាលទាយកពោលថា "សូមលោកម្ចាស់ចាត់អំពីសង្ឃមកដោយខ្លួនឯងចុះ" ដូច្នេះ ភិក្ខុគប្បីពោលថា "សម្រាប់យើង អ្នកនឹងជ្រាបបានដោយប្រការដទៃខ្លះ តែលំដាប់ រមែងដល់យ៉ាងនេះ" ហើយគប្បីឱ្យកាន់យកដោយអំណាចនៃលំដាប់ន៏ុះឯង ។

បើគេពោលថា "សូមលោកម្ចាស់ឱ្យបាត្រដែលចាត់អំពីសង្ឃ" ដូច្នេះ កាលបាត្រដែលភត្តុទ្ទេសកៈ មិនទាន់បង្គាប់ឱ្យកាន់ ក៏កាន់យកបាត្ររបស់ភិក្ខុរូបណាមួយ បញ្ចុះពេញនាំមក ។ សូម្បីឧទ្ទេសភត្តដែលគេនាំមកហើយ គប្បីឱ្យកាន់យកតាមលំដាប់ដូចគ្នា ។

ជនម្នាក់ ដែលគេប្រើទៅថា "អ្នកចូរនាំបាត្រដែលសង្ឃចាត់មក" ដូច្នេះពោលថា "លោកម្ចាស់ សូមលោកម្ចាស់ប្រគល់បាត្រមួយ ខ្ញុំព្រះករុណានឹងនាំនិមន្តនភត្តមកប្រគេន", បើភិក្ខុទាំងឡាយជ្រាបនូវជននោះថា "អ្នកនេះមកពីផ្ទះឧទ្ទេសភត្ត" ទើបសួរថា "អ្នកមកពីផ្ទះឯណោះ មិនមែនឬ ?" ទើបឆ្លើយថា "ត្រូវហើយ លោកម្ចាស់ដ៏ចម្រើន មិនមែននិមន្តនភត្ត ជាឧទ្ទេសភត្ត", គប្បីឱ្យកាន់យកតាមលំដាប់ ។

ចំណែកជនណា ដែលបង្គាប់គេថា "ចូរនាំបាត្រតូចមួយមក" ទើបសាកសួរថា "នឹងនាំបាត្រអ្វីមក" បានទទួលឆ្លើយថា "ចូរនាំមកតាម

ពេញចិត្តរបស់អ្នក” ដូច្នេះ ហើយមក ; ជននេះ ឈ្មោះថា វិស្សដ្ឋទូត (គឺ ទូតដែលគេព្រមតាមចិត្ត) គេត្រូវការបាត្រដែលសង្ឃចាត់ ឬបាត្រតាមលំដាប់ ឬបាត្រចំណែកបុគ្គលយ៉ាងណា គប្បីឱ្យបាត្រនោះដល់គេ ។

មនុស្សល្ងង់មិនឈ្លាស ដែលគេប្រើទៅថា “ចូរនាំបាត្រអំពីសង្ឃមក” ដូច្នេះ មិនយល់ពាក្យនិយាយ ទើបឈរនៅស្ងៀម, ភិក្ខុមិនគួរសួរគេថា “អ្នកមករកអង្គណា” ឬថា “អ្នកនឹងនាំបាត្ររបស់អង្គណាទៅ” ព្រោះថា គេត្រូវសួរយ៉ាងនោះហើយ នឹង គប្បីតបតាមពាក្យសួរថា “មករកលោកម្ចាស់” ឬថា “នឹងនាំបាត្ររបស់លោកម្ចាស់ទៅ” ។ ព្រោះហេតុដែលពោលនោះ ភិក្ខុពួកដទៃនឹងនាំគ្នាស្អប់ មិនក្រលេកមើលភិក្ខុនោះក៏បាន ។ ដែលសមគួរសួរថា “អ្នកទៅណា ?” ឬថា “អ្នកនឹងទៅធ្វើអ្វី” ។

កាលគេឆ្លើយថា “មកដើម្បីត្រូវការបាត្រអំពីសង្ឃ” ដូច្នេះ គប្បីឱ្យភិក្ខុកាន់យកហើយ ឱ្យបាត្រទៅ ។

ដែលចាត់ថា លំដាប់គោងមានមួយប្រភេទ ។ ពិតមែន ក្នុងព្រះរាជនិវេសន៍ ឬក្នុងផ្ទះរបស់រាជមហាអាមាត្យប្រគេនឧទ្ទេសភត្តយ៉ាងប្រណីតក្រៃលែង ៨ កន្លែងជានិច្ច ភិក្ខុទាំងឡាយចាត់ឧទ្ទេស ភត្តទាំងនោះ ឱ្យជាភត្តដែលគប្បីត្រូវបានដល់ភិក្ខុមួយរូបម្តង ឆាន់តាមលំដាប់

មួយផ្នែក ។

ភិក្ខុពួកខ្លះចាំកំណត់លំដាប់របស់ខ្លួនថា "ស្រុកនេះឯង នឹងត្រូវបានដល់ពួកយើង" ដូច្នេះ ហើយទៅ ។

គ្រាកាលភិក្ខុទាំងនោះ មិនទាន់មក ភិក្ខុអាគន្តុកៈពួកដទៃ មកអង្គុយក្នុងរោងឆាន់ ។ ក្នុងខណៈនោះឯង រាជបុរសនាំគ្នាពោលថា "សូមលោកម្ចាស់ឱ្យបាត្រសម្រាប់បណិតភត្ត" ពួកភិក្ខុអាគន្តុកៈមិនជ្រាបលំដាប់ ឱ្យភិក្ខុទាំងឡាយកន់យក ។ ក្នុងខណៈនោះឯង ភិក្ខុដែលជ្រាបលំដាប់ក៏នាំគ្នាមក ទើបសួរថា "លោកឱ្យកាន់យកអ្វី ?" ។

ភិក្ខុអាគន្តុកៈ ឆ្លើយថា "បណិតភត្តក្នុងព្រះរាជនិវេសន៍" "តាំងពីវស្សាប៉ុនណាទៅ ?" "តាំងពីវស្សាប៉ុណ្ណោះទៅ" ។

ពួកភិក្ខុដែលជ្រាបលំដាប់ គប្បីហាមថា "កុំគប្បីឱ្យកាន់" ហើយកន់យកតាមលំដាប់ ។

ភិក្ខុទាំងឡាយដែលជ្រាបលំដាប់ហើយ ក្នុងកាលភិក្ខុអាគន្តុកៈឱ្យភិក្ខុទាំងឡាយកន់យកហើយក្តី, មកហើយក្នុងវេលាដែលឱ្យបាត្រក្តី, មកក្នុងវេលាដែលឱ្យទៅក្តី, មកហើយក្នុងវេលាដែលរាជបុរសញ៉ាំងបាត្រឱ្យពេញ នាំមកពីព្រះរាជនិវេសន៍ក្តី, មកហើយក្នុងវេលាដែលភិក្ខុអាគន្តុកៈទាំងឡាយ កាន់បិណ្ឌបាត ដែលព្រះរាជាទ្រង់ប្រើរាជបុរសទៅថា "ថ្ងៃនេះ ភិក្ខុទាំងឡាយចូរមកខ្លួនឯងចុះ" ដូច្នេះហើយ ទ្រង់ប្រគេនបិណ្ឌបាត

ក្នុងដៃរបស់ភិក្ខុទាំងឡាយនោះឯង  មកហើយក្តី,  គប្បីហាមថា  “កុំឆាន់” ហើយគប្បីឱ្យភិក្ខុទាំងឡាយកន់យកតាមលំដាប់ចុះ ។

បើថា  ព្រះរាជាទ្រង់និមន្តភិក្ខុអាគន្តុកៈទាំងនោះឆាន់ហើយ  ញ៉ាំងបាត្ររបស់ពួកលោកឱ្យពេញហើយប្រគេនផង ។  ភត្តដែលលោកនាំមកគប្បីឱ្យកាន់យកតាមលំដាប់  តែបើមានភត្តត្រឹមតែបន្តិចបន្តួច  ដែលគេដាក់ក្នុងបាត្រ  ដោយគិតថា  “ភិក្ខុទាំងឡាយកុំទៅដៃទទេ” ។  ភត្តនោះមិនគប្បីឱ្យកាន់យក ។

ព្រះមហាសុមត្ថេរៈពោលថា  បើឆាន់រួចហើយមានបាត្រទទេត្រឡប់មក,  ភត្តដែលពួកលោកឆាន់ហើយ  រមែងជាបំណុលដល់ពួកលោក ។

ចំណែកព្រះមហាបទុមត្ថេរៈពោលថា  ក្នុងការឆាន់បណីតភោជននេះ  មិនមានកិច្ចជាប់ដោយបំណុល ។  ភិក្ខុដែលមិនដឹងលំដាប់  គប្បីអង្គុយចាំដរាបដល់ភិក្ខុដែលជ្រាបលំដាប់មក,  សូម្បីកាលបើដូច្នេះ  ភត្តដែលឆាន់ហើយ  ជាការឆាន់ហើយដោយល្អ,  តែមិនគប្បីឱ្យលោកកាន់យកភត្តដទៃ  ក្នុងទីដែលលោកចូលឥឡូវនេះ ។  បិណ្ឌបាតមានតម្លៃមួយរយ  មានត្រៃចីវរជាបរិវារត្រូវបានដល់ភិក្ខុមិនមានវស្សា  បើថា  កន្លងទៅ ៦០  ឆ្នាំ  បិណ្ឌបាតបែបនោះដទៃ  ទើបកើតឡើងទៀត ។

សួរថា  បិណ្ឌបាតនេះ  គប្បីឱ្យកាន់យកតាមលំដាប់ភិក្ខុដែលមិន

មានវស្សាឬថា នឹងគប្បីឱ្យកាន់យកតាមលំដាប់ភិក្ខុដែលមានវស្សា ៦០ ?

ឆ្លើយថា ក្នុងអដ្ឋកថាទាំងឡាយពោលថា គប្បីឱ្យកាន់យកតាមលំដាប់ភិក្ខុដែលមានវស្សា ៦០, ព្រោះថា ភិក្ខុនេះ ទទួលលំដាប់ហើយក៏ចាស់ទៅឯង ។

ភិក្ខុមួយរូបឆាន់ឧទ្ទេសភត្តហើយ (លាសិក្ខា) ជាសាមណេរ រមែងបានដើម្បីកាន់យកភត្តនោះ ដែលដល់តាមលំដាប់នៃសាមណេរទៀត ។ បានឮថា ភិក្ខុនេះឈ្មោះថា អ្នកធ្លាក់ចុះក្នុងចន្លោះ ។

ចំណែកសាមណេររូបណា មានឆ្នាំបរិបូរណ៍, នឹងបានឧទ្ទេសភត្តក្នុងថ្ងៃស្អែក តែលោកឧបសម្បទាក្នុងថ្ងៃនេះ, លំដាប់របស់សាមណេររូបនោះ ជាការហួសទៅ ។

ឧទ្ទេសភត្តត្រូវបានដល់ភិក្ខុមួយរូប, តែបាត្ររបស់លោកមិនទំណេរ, លោកទើបឱ្យប្រគល់បាត្ររបស់ភិក្ខុដទៃ ដែលអង្គុយជិតគ្នាទៅជំនួស ។

បើថា ជនទាំងនោះ នាំបាត្រនោះចេញទៅដោយចិត្តលួច, ជាសំណាងដល់លោក ។ តែបើភិក្ខុនោះព្រមឱ្យទៅដោយខ្លួនឯងថា "យើងឱ្យបាត្ររបស់យើងជំនួសលោក" នេះ មិនជាសំណាង ។

សួរថា ភិក្ខុនោះ ជាអ្នកមិនមានសេចក្តីត្រូវការដោយភត្តនោះ ទើប

ប្រាប់ចំពោះភិក្ខុដទៃថា "ភត្តរបស់យើងល្មមហើយ, យើងឱ្យភត្តនោះដល់លោក លោកចូរបញ្ជូនបាត្រទៅឱ្យនាំភត្តមកចុះ" ។ វត្ថុណាគេនាំមកពីទីនោះ, វត្ថុនោះទាំងអស់ រមែងជារបស់ភិក្ខុម្ចាស់បាត្រ ។

បើថា អ្នកដែលនាំបាត្រទៅ លួចបន្លំសទៅ, ក៏ជាការលួចទៅដោយល្អ, មិនជាសំណង ព្រោះលោកបានឱ្យភត្តដល់ម្ចាស់របស់បាត្រ ។

ក្នុងសំណាក់មានភិក្ខុ ១០ រូប, ក្នុង១០ រូបនោះ ជាអ្នកកាន់បិណ្ឌបាតិកធុតង្គ ៩ រូប, ១រូបទទួល កាលទាយកពោលថា "សូមលោកម្ចាស់ប្រគល់បាត្រសម្រាប់ឧទ្ទេសភត្ត ១០ បាត្រ" ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ មិនអាចនឹងឱ្យកាន់យក ភិក្ខុក្រៅនេះ ទទួលដោយគិតថា "ឧទ្ទេសភត្តទាំងអស់ សម្រេចដល់យើង" ដូច្នេះ មិនមានលំដាប់ ។

បើថា លោកទទួលយកឱ្យដល់( ខ្លួន )ម្តងមួយចំណែក ៗ លំដាប់រមែងឋិតនៅ ។ ភិក្ខុនោះគ្រាទទួលហើយយ៉ាងនោះ ឱ្យគេនាំមកទាំង ១០ បាត្រហើយ ប្រគេន ៩ បាត្រដល់ភិក្ខុអ្នកកាន់បិណ្ឌបាតិកធុតង្គថា "សូមលោកដ៏ចម្រើន ធ្វើសេចក្តីសង្គ្រោះដល់ខ្ញុំព្រះករុណា" ភត្ត ដូច្នេះ ចាត់ជាភត្តដែលភិក្ខុប្រគេនដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ សមគួរទទួល ។

បើថា ឧបាសកនោះនិមន្តថា "លោកម្ចាស់ដ៏ចម្រើន គប្បីទៅផ្ទះ"

ភិក្ខុនោះបបួលភិក្ខុទាំងនោះថា "និមន្តមកចុះលោកដ៏ចម្រើន ចូរជាសម្លាញ់ខ្ញុំព្រះករុណា" ដូច្នេះហើយ ទៅផ្ទះឧបាសកនោះ លោកបានវត្ថុណា ក្នុងផ្ទះនោះ វត្ថុនោះទាំងអស់ រមែងជារបស់លោកប៉ុណ្ណោះ ភិក្ខុក្រៅនេះ រមែងបានរបស់ដែលលោកប្រគេន ។

បើថា ឧបាសកនោះនិមន្តឱ្យអង្គុយក្នុងផ្ទះហើយ និងប្រគេនទឹកទក្ខិណោទក ហើយប្រគេនយាគូនិងរបស់ទំពារជាដើម ដល់ភិក្ខុទាំងនោះ យាគូជាដើមនោះ រមែងគួរដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គក្រៅនេះ ព្រោះពាក្យរបស់ភិក្ខុនោះដែលពោលថា "លោកដ៏ចម្រើន ជនទាំងឡាយប្រគេនវត្ថុណា លោកចូរកាន់យកវត្ថុនោះចុះ" ដូច្នេះ ។

ពួកទាយកដាក់ភត្តចូលក្នុងបាត្រពេញហើយប្រគេន ដើម្បីត្រូវការឱ្យកាន់យកទៅ ភត្តទាំងអស់ រមែងជារបស់ភិក្ខុនោះប៉ុណ្ណោះ ភត្តដែលភិក្ខុនោះឱ្យ ទើបគួរដល់ពួកភិក្ខុក្រៅនេះ ។

តែបើថា ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គទាំងនោះ ដែលភិក្ខុនោះប្រកាសទុកតែក្នុងសំណាក់ថា "លោកដ៏ចម្រើន ចូរទទួលភិក្ខារបស់ខ្ញុំព្រះករុណា និងសមគួរធ្វើតាមពាក្យរបស់ពួកអ្នកស្រុក" ដូច្នេះ ទើបទៅ, ពួកលោកឆាន់ភត្តណា ក្នុងទីនោះ និងនាំភត្តណាក្នុងទីនោះទៅ ភត្តនោះទាំងអស់ជារបស់ពួកលោកប៉ុណ្ណោះ ។

សូម្បីថា ពួកលោកដែលភិក្ខុនោះ មិនបានប្រកាសថា "លោកចូរ

ទទួលភិក្ខារបស់ខ្ញុំព្រះករុណា” តែបានទទួលប្រកាសថា “សមគួរធ្វើតាមពាក្យរបស់ពួកអ្នកស្រុក” ដូច្នេះ ទើបទៅ ។

បើថា ពួកអ្នកស្រុកស្តាប់ភិក្ខុមួយរូបក្នុងភិក្ខុទាំងនោះ អ្នកធ្វើអនុមោទនាដោយសំឡេងដ៏ពីរោះ និងជ្រះថ្លាក្នុងអាការដែលស្ងប់រម្ងាប់របស់ព្រះថេរៈទាំងឡាយ ប្រគេនសមណបរិក្ខារជាច្រើន លាភនេះកើតឡើងព្រោះសេចក្តីជ្រះថ្លាក្នុងពួកព្រះថេរៈ ចាត់ជាចំណែកពិសេស ព្រោះដូច្នោះ រមែងបានដល់ភិក្ខុគ្រប់រូប ។

ទាយកម្នាក់ នាំបាត្រដែលឱ្យសង្ឃចាត់ ហើយឱ្យកាន់យកតាមលំដាប់ទៅដាក់ភត្តក្នុងបាត្រពេញដោយខាទនិយៈ និងភោជនីយៈដ៏ប្រណីតនាំមកប្រគេនថា “លោកម្ចាស់ដ៏ចម្រើន សូមសង្ឃទាំងពួងឆាន់ភត្តនេះ” ភិក្ខុទាំងពួងគប្បីបែងចែកគ្នាឆាន់ តែត្រូវវៀរលំដាប់ សូម្បីដែលកន្លងទៅហើយរបស់ភិក្ខុជាម្ចាស់បាត្រចេញ ឱ្យឧទ្ទេសភត្តដទៃ ។

បើថា ទាយកពោលថា “សូមលោកម្ចាស់ប្រគល់បាត្រជារបស់សង្ឃទាំងពួងឱ្យមុនតែម្តង” គប្បីប្រគល់ឱ្យបាត្រជារបស់ភិក្ខុលជ្ជីមួយរូបនិងកាលគេនាំមកហើយពោលថា “សូមសង្ឃទាំងអស់បរិភោគចុះ” ដូច្នេះ គប្បីបែងចែកគ្នាឆាន់ ។

មួយទៀត ទាយកនាំភត្តសម្រាប់ភិក្ខុមួយរូបមកប្រគេនថា “ខ្ញុំព្រះ

ករុណាសូមប្រគេនភត្តចំពោះសង្ឃ” កុំឱ្យភិក្ខុកាន់យកមួយរូបមួយដុំ ៗ គប្បីឱ្យដោយស្មានឱ្យល្មមញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដល់ភិក្ខុមួយរូបតាមលំដាប់ ។

បើថា គេនាំភត្តមកហើយ មិនប្រាប់ថា “នឹងនិយាយយ៉ាងណា” ទើបជាអ្នកនៅស្ងៀម, កុំសួរគេថា “អ្នកនាំមកដើម្បីអង្គណា ? អ្នកប្រាថ្នានឹងប្រគេនអង្គណា ?” ព្រោះថា គេគប្បីតបតាមពាក្យសួរថា “នាំមកដើម្បីលោកម្ចាស់ ប្រាថ្នានឹងប្រគេនលោកម្ចាស់” ។ ព្រោះដូច្នោះ ភិក្ខុពួកដទៃនឹងនាំគ្នាស្អប់ខ្ពើមភិក្ខុនោះ នឹងមិនគប្បីយកចិត្តទុកដាក់ចំពោះលោក សូម្បីដែលជាអ្នកគួរក្រលេកមើល ។

តែបើភិក្ខុសួរថា “អ្នកអញ្ជើញទៅណា ? អ្នកត្រាច់ទៅធ្វើអ្វី ?” ដូច្នេះ គេនឹងឆ្លើយថា “ខ្ញុំព្រះករុណាកាន់យកឧទ្ទេសភត្តមក” ភិក្ខុលជ្ជីមួយរូប គប្បីឱ្យកាន់យកតាមលំដាប់ ។

បើភត្តដែលគេនាំមកមានច្រើន និងល្មមដល់ភិក្ខុទាំងពួង មិនត្រូវឱ្យកាន់យកតាមលំដាប់ ។ គប្បីប្រគេនភត្តក្នុងបាត្រឱ្យពេញហើយតាំងពីថេរាសនៈចុះមក ។

កាលទាយកពោលថា “សូមលោកប្រគល់បាត្រដែលសង្ឃចាត់ហើយ” កុំសួរថា “អ្នកនឹងនាំអ្វីមក ?” គប្បីឱ្យកាន់យកតាមលំដាប់

ប្រក្រតីទុំះឯង ។

ចំណែកបាយបាយាស ឬបិណ្ឌបាតមានរសយ៉ាងណា សង្ឃតែង បានជានិច្ច, សម្រាប់ភោជនប្រណីតដូច្នោះ គប្បីចាត់លំដាប់ទុកមួយ ផ្នែក ។ យាគូព្រមទាំងរបស់ជាបរិវារក្តី ផ្លែឈើដែលមានតម្លៃច្រើនក្តី របស់ទំពាដែលប្រណីតក្តី គួរចាត់លំដាប់ទុកមួយផ្នែក ដូចគ្នា ។ តែភត្ត យាគូផ្លែឈើ និងរបស់ទំពារតាមប្រក្រតី គួរចាត់លំដាប់តែមួយពិត ។

កាលទាយកពោលថា "ខ្ញុំព្រះករុណានឹងនាំទឹកដោះថ្លាមក សម្រាប់ទឹកដោះថ្លាទាំងពួង" គួរចាត់លំដាប់តែមួយដូចគ្នា ។ ប្រេងទាំង ពួងក៏ដូចគ្នា ។

មួយទៀត កាលគេពោលថា "ខ្ញុំព្រះករុណានឹងនាំទឹកឃ្មុំមក" សម្រាប់ទឹកឃ្មុំគួរជាលំដាប់តែមួយដូចគ្នា ។ ទឹកអំពៅនិងភេសជ្ជៈ មាន ឈើអែមជាដើមក៏ដូចគ្នា ។

សួរថា បើពួកទាយកប្រគេនផ្កាកម្រង និងរបស់ក្រអូបចំពោះ សង្ឃ, ទីងគួរដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ ឬមិនគួរ ?

អាចារ្យទាំងឡាយពោលថា គួរ ព្រោះលោកហាមតែអាមិស ប៉ុណ្ណោះ តែមិនគួរកាន់យកព្រោះគេប្រគេនចំពោះសង្ឃ ។

ឧទ្ទេសភត្តកថា ចប់

# និមន្តនភត្ត

និមន្តនភត្ត បើជារបស់ចំណែកបុគ្គល, អ្នកទទួលខ្លួនឯងនោះជាធំ ចំណែកភត្តដែលជារបស់សង្ឃ គប្បីឱ្យកាន់យកតាមន័យដែលពោល ហើយក្នុងឧទ្ទេសភត្តនុ៎ះឯង ។

តែក្នុងនិមន្តនភត្តនេះ បើជាទូតឆ្លាត គេមិនពោលថា "លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយ ទទួលភត្តសម្រាប់ភិក្ខុសង្ឃក្នុងព្រះរាជនិវេសន៍" ពោលថា "សូមលោកម្ចាស់ទាំងឡាយទទួលភិក្ខា" ដូច្នេះ ភត្តនោះ រមែងគួរសូម្បីដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ ។

បើទូតមិនឆ្លាតពោលថា "សូមលោកម្ចាស់ទាំងឡាយទទួលភត្ត" ដូច្នេះ ។ ភត្តុទ្ទេសកៈជាអ្នកឆ្លាត មិនចេញឈ្មោះថា ភត្ត ពោលត្រឹមតែថា "លោកដ៏ចំរើន លោកចូរទៅ"ដូច្នេះ សូម្បីយ៉ាងនេះ ភត្តនោះ រមែងគួរដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ ។

តែកាលភត្តុទ្ទេសកៈ ពោលថា "ភត្តត្រូវបានដល់ពួកលោកតាមលំដាប់" ដូច្នេះមិនគួរដល់ភិក្ខុកាន់បិណ្ឌបាតិកធុតង្គ ។

បើមនុស្សទាំងឡាយ មកដើម្បីនិមន្ត ចូលទៅកាន់រោងឆាន់ ហើយពោលថា "សូមលោកម្ចាស់ឱ្យភិក្ខុ ៨ រូប" ឬថា "សូមលោកម្ចាស់ឱ្យបាត្រ ៨" សូម្បីយ៉ាងនេះ ក៏គួរដល់ភិក្ខុដែលកាន់បិណ្ឌបាតិ

កធុតង្គ ។ ភត្តុទ្ទេសកៈគប្បីពោលថា “លោកផង និមន្តទៅ” ។ តែបើគេពោលថា “សូមលោកម្ចាស់ឱ្យភិក្ខុ ៨ រូប សូមលោកម្ចាស់ទាំងឡាយ ទទួលភត្ត” ឬថា “សូមលោកម្ចាស់ឱ្យបាត្រ ៨ សូមលោកម្ចាស់ទាំងឡាយ ទទួលភត្ត” ដូច្នេះ ភត្តុទ្ទេសកៈគប្បីឱ្យភិក្ខុទាំងឡាយ កាន់យកតាមលំដាប់ ។ កាលនឹងឱ្យកាន់យក មិនចេញឈ្មោះ ភត្ត តែពោលថា “លោកផង លោកផង និមន្តទៅ” ដូច្នេះ គួរដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ ។

កាលគេពោលថា “លោកម្ចាស់ សូមលោកម្ចាស់ឱ្យបាត្ររបស់ពួកលោកម្ចាស់ និមន្តលោកម្ចាស់មក” ដូច្នេះ គប្បីទទួលថា “ល្អណាស់ឧបាសក” ហើយទៅចុះ ។

កាលគេពោលថា “សូមលោកម្ចាស់ទាំងឡាយនិមន្តអំពីសង្ឃចុះ” ដូច្នេះ គប្បីឱ្យកាន់យកតាមលំដាប់ ។

មួយទៀត កាលគេមកពីផ្ទះនិមន្តនភត្ត ដើម្បីត្រូវការបាត្រ គប្បីឱ្យបាត្រតាមលំដាប់ ដោយន័យដែលពោលហើយក្នុងឧទ្ទេសភត្តនុ៎ះឯង ។

ទាយកម្នាក់មិនពោលថា “ចូរឱ្យបាត្រតាមលំដាប់អំពីសង្ឃ” ពោលត្រឹមតែថា “សូមលោកម្ចាស់ឱ្យបាត្រមួយ” ដូច្នេះ កាលមិនទាន់ឱ្យកាន់យកបាត្រទេ ក៏ឆក់យកបាត្ររបស់ភិក្ខុរូបណាមួយទៅ ដាក់ភត្តពេញនាំមក ភត្តនោះជារបស់ភិក្ខុម្ចាស់បាត្រប៉ុណ្ណោះ កុំឱ្យកាន់យកតាមលំដាប់

ដូចក្នុងឧទ្ទេសភត្ត ។

សម្បីក្នុងនិមន្តនភត្តនេះ ទាយកណាមកហើយ ឈរនៅស្ងៀម ទាយកនោះដែលភិក្ខុមិនគប្បីសួរថា "អ្នកមករកអង្គណា ?" ឬថា "អ្នកនឹងនាំបាត្ររបស់អង្គណាទៅ ?" ព្រោះថា គេនឹងគប្បីតបតាមពាក្យសួរថា "ខ្ញុំព្រះករុណាមករកលោកម្ចាស់ នឹងនាំបាត្ររបស់លោកម្ចាស់ទៅ" ព្រោះដូច្នោះ ភិក្ខុនោះ នឹងគប្បីត្រូវភិក្ខុទាំងឡាយស្អប់ខ្ពើម ។

តែកាលភិក្ខុសួរថា "អ្នកអញ្ជើញទៅណា អ្នកត្រាច់ធ្វើអ្វី ?" កាលគេឆ្លើយថា "មកដើម្បីត្រូវការបាត្រ" ដូច្នេះ គប្បីឱ្យកាន់យកបាត្រតាមលំដាប់រៀងគ្នាទៅ ។

សម្បីកាលគេពោលថា "សូមលោកម្ចាស់ឱ្យបាត្រសម្រាប់នាំភត្តមក" ក៏គប្បីឱ្យតាមលំដាប់ភត្តរៀងគ្នាដែរ ។

បើគេនាំមកហើយពោលថា "សូមព្រះសង្ឃទាំងពួងឆាន់" គប្បីចែកគ្នាឆាន់ វៀរត្រូវលំដាប់ សម្បីដែលកន្លងទៅហើយរបស់ភិក្ខុម្ចាស់បាត្រចេញ ឱ្យលោកកាន់យកភត្តក្នុងលំដាប់ថ្មីដទៃ ។

ទាយកម្នាក់ នាំភត្តមកដោយថាស ហើយពោលថា "ខ្ញុំព្រះករុណាថ្វាយសង្ឃ" គប្បីបែងចែកគ្នាដោយសង្ខេបជាពំនូត ៗ តាំងពីដើម លំដាប់នៃអាលោបភត្តទៅ ។

មួយទៀត បើគេនៅស្ងៀម ភិក្ខុកុំសួរគេថា "អ្នកនាំមកដើម្បីអង្គ

ណា អ្នកប្រាថ្នានឹងប្រគេនអន្តណា ?” កាលបើភិក្ខុសួរថា “អ្នកអញ្ជើញទៅណា ? អ្នកត្រាច់ទៅធ្វើអ្វី ?” គេឆ្លើយថា “ខ្ញុំព្រះករុណានាំភត្តមកដើម្បីសង្ឃ, ខ្ញុំព្រះករុណានាំភត្តមកដើម្បីព្រះថេរៈ” ដូច្នេះ គប្បីទទួលហើយបែងចែកឱ្យតាមលំដាប់នៃអាលោបភត្ត ។

ក៏បើថា ភត្តដែលគេនាំមកយ៉ាងនោះមានច្រើន ល្មមដល់សង្ឃទាំងអស់ នេះឈ្មោះថា **អភិហដភិក្ខា** ( ភិក្ខាដែលគេនាំមកល្មម ) រមែងគួរសូម្បីដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ ។ មិនមានកិច្ចដែលត្រូវសួរដល់លំដាប់ ។ គប្បីដាក់ភត្តចូលក្នុងបាត្រឱ្យពេញតាំងពីថេរាសនៈ ចុះមក ។

ឧបាសកបញ្ជូនដំណឹង ទៅដល់ព្រះសង្ឃថេរៈក្តី ភិក្ខុដែលមានកេរ្តិ៍ឈ្មោះជាប់ដោយគន្ថធុរៈនិងធុតង្គក្តី ភត្តុទ្ទេសកៈក្តី ថា “សូមលោកម្ចាស់នាំភិក្ខុ ៨ រូបមក ដើម្បីប្រយោជន៍ដល់ការទទួលភត្តរបស់ខ្ញុំព្រះករុណា” ។

សូម្បីថា បាយនោះនឹងជាដំណឹងដែលញាតិ និងឧបដ្ឋាកបញ្ជូនទៅក្តី ភិក្ខុ ៣ រូប ( មានព្រះសង្ឃថេរៈជាដើម ) នេះ រមែងមិនបានដើម្បីនឹងសាកសួរគេ ។ លំដាប់ជាការលើកឡើងតែម្តង ។ គប្បីឱ្យនិមន្តភិក្ខុ ៨ រូបអំពីសង្ឃ មានខ្ញុំជាគម្រប់ ៩ ទៅចុះ ព្រោះហេតុអ្វី ? ព្រោះថា លាភអាស្រ័យភិក្ខុទាំងនោះ ទើបកើតឡើងដល់ភិក្ខុសង្ឃ ។

ចំណែកភិក្ខុម្ចាស់អាវាស ដែលមិនមានការចេះដឹងផ្នែកគន្ធធុរៈ និងធុតង្គជាដើមនឹងសួរក៏បាន ។ ព្រោះដូច្នោះ លោកគប្បីសួរគេថា "ខ្ញុំព្រះករុណានឹងនិមន្តអំពីសង្ឃ" ឬថា "នឹងមកជាមួយភិក្ខុទាំងឡាយដែលខ្ញុំព្រះករុណាស្គាល់ ?" ដូច្នេះហើយ ទើបចាត់ចូលលំដាប់បដិបត្តិតាមដែលទាយកគេបង្គាប់ ។

ក៏កាលគេបង្គាប់ថា "សូមលោកម្ចាស់នាំនិស្សិតរបស់លោកម្ចាស់ ឬ ភិក្ខុដែលលោកម្ចាស់ស្គាល់មកចុះ" ដូច្នេះ នឹងទៅជាមួយភិក្ខុដែលខ្លួន ប្រាថ្នានឹងនិមន្តក៏បាន ។

បើគេបញ្ជូនដំណឹងមកថា "សូមលោកម្ចាស់បញ្ជូនភិក្ខុមក ៨ រូប" គប្បីបញ្ជូនទៅអំពីសង្ឃប៉ុណ្ណោះ បើខ្លួនអាចនឹងបានភិក្ខាក្នុងស្រុកដទៃ គប្បីទៅស្រុកដទៃ ។ បើថា ជាអ្នកមិនអាចនឹងបាន ក៏គប្បីចូលទៅបិណ្ឌបាតក្នុងស្រុកនោះឯង ។

ភិក្ខុទាំងឡាយ ដែលទទួលនិមន្ត អង្គុយនៅក្នុងរោងឆាន់ បើមនុស្សទាំងឡាយមកកាន់រោងឆាន់នោះប្រាប់ថា "សូមលោកម្ចាស់ទាំងឡាយឱ្យបាត្រ" ភិក្ខុដែលមិនបានទទួលនិមន្តកុំឱ្យ គប្បីប្រាប់ថា "នេះភិក្ខុដែលអ្នកនិមន្តទុក" ។ តែកាលគេឆ្លើយថា "សូមឱ្យបាត្រលោកម្ចាស់មកផង" ដូច្នេះ គួរឱ្យ ។

ក្នុងកាលមានមហោស្រពជាដើម ជនទាំងឡាយទៅកាន់បរិវេណ

និងផុះបំពេញព្យាយាម និមន្តភិក្ខុដែលទ្រទ្រង់ព្រះត្រៃបិដក និងធម្មកថិកមួយអន្លើដោយភិក្ខុមួយរយរូបនោះតែម្តង ។

ក្នុងកាលនោះ ភិក្ខុដែលទ្រទ្រង់ព្រះត្រៃបិដក ធម្មកថិកទាំងនោះ នឹងនាំភិក្ខុទាំងឡាយដែលជ្រាបទៅ ក៏គួរ ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ជនទាំងឡាយ មានសេចក្តីត្រូវការដោយភិក្ខុសង្ឃពួកធំ ទើបទៅកាន់បរិវេណ និងផុះបំពេញព្យាយាមក៏ទេ ។ តែគេនិមន្តភិក្ខុទាំងឡាយ តាមសតិតាមកម្លាំង ទៅអំពីទីប្រជុំនៃភិក្ខុទាំងឡាយ ។

ក៏បើថា ព្រះសង្ឃថេរៈ ឬភិក្ខុដែលមានប្រាជ្ញាដឹងច្បាស់ផ្ទែកគន្ថធុរៈ និងធុតង្គ ឬភត្តុទ្ទេសកៈក្តី ចាំវស្សាក្នុងទីដទៃ ឬទៅក្នុងទីកន្លែងខ្លះ ត្រឡប់មកកាន់ស្ថានរបស់ខ្លួនទៀត ។ ជនទាំងឡាយ ទើបធ្វើសក្ការៈសម្រាប់អាគន្តុកៈ គប្បីនាំភិក្ខុទាំងឡាយដែលស្គាល់ទៅ ១ វារៈ ។ ចាប់ផ្តើមតាំងពីកាលដែលជាប់តគ្នាទៅ កាលផ្តើមវារៈទី ២ គប្បីនិមន្តទៅអំពីសង្ឃប៉ុណ្ណោះ ។

មួយទៀត ភិក្ខុទាំងឡាយជាអាគន្តុកៈដែលមកថ្មី ៗ ទៅដោយតាំងចិត្តថា "នឹងសួរសុខទុក្ខញាតិ ឬឧបដ្ឋាក" ក្នុងត្រកូលនៃញាតិនិងឧបដ្ឋាកទាំងឡាយរបស់ភិក្ខុអាគន្តុកៈពួកនោះ ធ្វើសក្ការៈ ។

ក៏ឯក្នុងអាវាសនោះ ភិក្ខុពួកណាជ្រាប គប្បីនិមន្តភិក្ខុទាំងនោះទៅ, ចំណែកភិក្ខុណា ជាអ្នកមានលាភបរិបូណ៌, ឋានៈរបស់លោក និងឋានៈ

របស់អាគន្តុកៈដូចគ្នា, ជនទាំងឡាយក្នុងទីទាំងពួងត្រៀមសង្ឃភត្តស្រេចហើយ ។ ភិក្ខុនោះ គប្បីនិមន្តភិក្ខុទៅអំពីសង្ឃប៉ុណ្ណោះ, នេះជាសេចក្តីប្លែកគ្នាក្នុងនិមន្តនភត្ត ។

បញ្ញាទាំងពួងដ៏សេស គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងឧទ្ទេសភត្តនុ៎ះឯង ។

ចំណែកក្នុងកុរុន្ទីថា កាលគេពោលថា "សូមលោកម្ចាស់ឱ្យព្រះមហាថេរៈ ៨ រូប" ។ គប្បីឱ្យព្រះថេរៈ ៨ រូប ប៉ុណ្ណោះ ។ ក្នុងភិក្ខុទាំងឡាយ មានភិក្ខុកណ្តាលជាដើម ក៏ន័យនេះឯង ។

តែបើគេពោលមិនឱ្យប្លែកគ្នាថា "សូមលោកម្ចាស់ឱ្យភិក្ខុ ៨ រូប" ដូច្នេះ គប្បីនិមន្តឱ្យទៅអំពីសង្ឃ ដូច្នេះឯង ។

និមន្តនភត្តកថា ចប់

# សលាកភត្តកថា

[៤៣៨] មួយទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងសលាកភត្ត, ព្រោះព្រះបាលីថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យចារិកឈ្មោះក្នុងស្លាក ឬដំបា(បន្ទះឫស្សី ឬស្លឹកត្នោតជាដើម) លាបើកហើយ សឹមសម្តែងភត្ត" ដូច្នេះភត្តុទ្ទេសកៈដែលប្រកបដោយ អង្គ ៥ គប្បីសរសេរអក្សរចុះក្នុងស្លាកឈើខឹម ឬក្នុងផ្ទាំងផ្ទាកដែលដោតឆ្អឹងឫស្សីនិងស្លឹកត្នោតជាដើម យ៉ាងនេះថា "សលាកភត្តរបស់ទាយកឈ្មោះឯណោះ" ហើយរួមស្លាកទាំងអស់ដាក់ក្នុងល្អី ឬក្នុងថ្នក់ចីវរ ហើយត្រឡប់ទៅមកជរាបដល់ខាងក្រោម និងខាងលើតែម្តង បើលំដាប់មានគប្បីចែកស្លាកចាប់ផ្តើមតាំងពីលំដាប់ទៅ, បើមិនមាន គប្បីចែកតាំងពីទីថេរាសនៈចុះមក ។

ភិក្ខុដែលមកខាងក្រោយក្តី ភិក្ខុដែលតាំងនៅក្នុងទីឆ្ងាយដោយអំណាចជាប់តគ្នាក្តី គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងឧទ្ទេសភត្តនុ៎ះឯង ។

ប្រសិនបើ ដោយជុំវិញសំណាក់មានគោចរគ្រាមច្រើន, ចំណែកភិក្ខុមានចំនួនមិនច្រើន ស្លាកទាំងឡាយរមែងដល់សូម្បីដោយអំណាចនៃ

ស្រុក គប្បីចែកស្លាកដោយអំណាចនៃស្រុកតែម្តងថា "សលាកភត្តទាំងឡាយ ក្នុងស្រុកឯណោះ ត្រូវបានដល់ពួកលោក" ។

កាលភត្តុទ្ទេសកៈឱ្យកាន់យកយ៉ាងនោះ សូម្បីថា ក្នុងស្រុកមួយ ៗ មានសលាកភត្ត ៦០ ស្លាក មានប្រការផ្សេង ៗគ្នា សលាកភត្តទាំងអស់ គឺ លោកឱ្យកាន់យកស្រេចអស់ទៅហើយ ។

ក្នុងស្រុកជិតខាងនឹងស្រុកដែលត្រូវបានដល់ភិក្ខុ នៅមានសលាកភត្តដទៃទៀត ២-៣ ស្លាក, សូម្បីសលាកភត្តទាំងនោះ ក៏គួរឱ្យដល់លោកផង ។ ព្រោះថា ភត្តុទ្ទេសកៈមិនអាចនឹងបញ្ជូនភិក្ខុដទៃទៅព្រោះហេតុនៃសលាកភត្តទាំងនោះបាន ដូច្នេះឯង ។

បើថា ក្នុងស្រុកខ្លះមានសលាកភត្តច្រើន គប្បីកំណត់ឱ្យដល់ភិក្ខុ ៧ រូប ខ្លះ, ៨ រូបខ្លះ តែកាលឱ្យ ត្រូវចងស្លាករួមគ្នាឱ្យដល់ភិក្ខុ ៤-៥ រូបដែលទៅ ។

បើថា បន្ទាប់ស្រុកនោះទៅ មានស្រុកដទៃ, ក្នុងស្រុកនោះ មានសលាកភត្តត្រឹមតែមួយ ។ គេប្រគេនសលាកភត្តនោះអំពីព្រឹកតែម្តង ។ សូម្បីសលាកភត្តនោះ គប្បីឱ្យដោយបង្គាប់ដល់ភិក្ខុមួយរូបក្នុងភិក្ខុទាំងនេះ ហើយបង្គាប់លោកថា "លោកចូរទទួលសលាកភត្តនោះតាំងអំពីព្រឹកខាងក្រោយសឹមទទួលភត្តក្រៅនេះ ក្នុងទីស្រុកជិត" ។

ក្នុងកុរុន្ទីពោលន័យដូច្នេះថា បើកាលសលាកភត្តទាំងឡាយក្នុង

ស្រុកជិត មិនទាន់បានចែកគ្នានៅឡើយទេ ភិក្ខុនោះចេញទៅ ដោយសម្គាល់ថា "បានចែកគ្នារួចស្រេចហើយ", កាលឱ្យកាន់យកសលាកភត្តក្នុងស្រុកឆ្ងាយហើយ ត្រូវត្រឡប់មកវិហារទៀត ទទួលចំណែកសលាកភត្តក្រៅនោះ ហើយសឹមទៅស្រុកជិត ព្រោះថា លាភសង្ឃចែកគ្នាខាងក្រៅសីមា រមែងមិនបាន ។

តែបើភិក្ខុមានច្រើន, ស្លាកដោយអំណាចនៃស្រុកមិនល្មមគ្នា ; គប្បីឱ្យកាន់យកដោយអំណាចថ្នល់មួយ ឬដោយអំណាច ត្រើយម្ខាងក្នុងថ្នល់មួយ ឬដោយអំណាចត្រកូលមួយក៏បាន ។

ក៏ក្នុងថ្នល់ជាដើម ក្នុងទីណាមានភត្តច្រើន, ទីនោះ គប្បីឱ្យភិក្ខុច្រើនរូបកាន់ដោយខ្លួនឯង តាមន័យដែលពោលហើយក្នុងស្រុកនុ៎ះឯង ។ កាលស្លាកមិនមាន គប្បីចំពោះឱ្យកាន់យកក៏បាន ។ កាលភិក្ខុដែលឱ្យស្លាក ត្រូវស្គាល់វត្ត ។

ពិតមែន ភិក្ខុដែលឱ្យស្លាកនោះ គប្បីក្រោកឡើងតាំងពីព្រឹកយកបាត្រនិងចីវរទៅកាន់បន្ទប់ឆាន់ បោសស្ថានទីដែលមិនទាន់បាន បោសចាត់តាំងទឹកឆាន់ទឹកប្រើប្រាស់ទុកក្នុងវេលាថា "ឥឡូវនេះវត្ត ជាការដែលភិក្ខុទាំងឡាយធ្វើស្រេចហើយ" ទើបវាយរគាំង កាលភិក្ខុទាំងឡាយប្រជុំគ្នាហើយ គប្បីឱ្យកាន់យកសលាកភត្តក្នុងស្រុកវេនមុន, គឺ គប្បីពោលថា "ស្លាកក្នុងស្រុកវេនឯណោះ ត្រូវបានដល់លោក លោកចូរទៅស្រុក

នោះ” ។

បើថា ស្រុកនៅក្នុងរយៈមកលើសពី ១ គាវុត, ភិក្ខុដែលទៅក្នុងថ្ងៃនោះ រមែងលំបាក, គប្បីឱ្យយកចេញក្នុងថ្ងៃនេះ តែម្តងថា “ស្អែកនេះសលាកភត្តក្នុងស្រុកវេន ត្រូវបានដល់លោក” ។

ភិក្ខុណា ត្រូវបញ្ជូនទៅស្រុកវេន មិនព្រមទៅ ទឹងជ្រើសរើសយកស្លាកដទៃកុំគប្បីឱ្យដល់ភិក្ខុនោះ ។ ព្រោះថា ទឹងសាបសូន្យបុណ្យរបស់ពួកជនដែលមានសទ្ធា និងជាច់លាភសង្ឃ ; ព្រោះដូច្នោះ សូម្បីក្នុងថ្ងៃទី ២ ទី ៣ ក៏កុំគប្បីឱ្យស្លាកដទៃដល់លោក ។ គប្បីប្រាប់លោកថា “លោកចូរទៅកាន់ស្ថានទីត្រូវបានដល់ខ្លួនហើយឆាន់ចុះ” ។ តែកាលលោកមិនព្រមទៅគ្រប់ ៣ ថ្ងៃ គប្បីឱ្យលោកកាន់យកស្លាកក្នុងស្រុកដែលជិតស្រុកវេនចូលមក ។

បើថា លោកព្រមទទួលស្លាកនោះសោត, ចាប់ផ្តើមតាំងពីនោះទៅមិនសមគួរឱ្យស្លាកដទៃដល់លោក ។

ចំណែកទណ្ឌកម្មត្រូវដាក់ឱ្យធ្ងន់ គឺ គប្បីដាក់ទណ្ឌកម្មឱ្យជង ទឹកកុំឱ្យតិចជាង ៥០ ឬ ៦០ ឆ្នាំង ឬឱ្យជញ្ជូនខសកុំឱ្យតិចជាង ៥០ ឬ ៦០ បាច់ ឬឱ្យជញ្ជូនខ្សាច់កុំឱ្យខ្វះពី ៥០ ឬ ៦០ បាត្រ ។

កាលឱ្យទទួលស្លាកក្នុងស្រុកវេនហើយ គប្បីឱ្យទទួលវារៈអ្នកចាំលំនៅ ។ គប្បីប្រាប់លោកថា “វារៈអ្នកចាំលំនៅត្រូវបាន ដល់

លោក” ។ គប្បីឱ្យសលាកយាគូ ២-៣ ស្លាក និងសលាកភត្ត ៣ ឬ ៤ ស្លាក ដល់ភិក្ខុដែលទទួលភារៈអ្នកចាំលំនៅ, តែកុំឱ្យជាប្រចាំ ។ ព្រោះថា ទាយកអ្នកប្រគេនយាគូនិងភត្ត នឹងដល់នូវសេចក្ដីខូចចិត្តថា “ពួកភិក្ខុដែលចាំលំនៅប៉ុណ្ណោះ ឆាន់យាគូនិងភត្តរបស់ពួកយើង” ព្រោះដូច្នោះ ទើបគួរឱ្យស្លាកក្នុងត្រកូលដទៃ ៗ ។

បើថា ពួកភិក្ខុដែលស្រឡាញ់ពេញចិត្តគ្នារបស់ភិក្ខុដែលទទួលភារៈអ្នកចាំលំនៅ នាំមកប្រគេនខ្លួនឯង ។ យ៉ាងនោះ ជាការល្អ ; បើថាពួកលោកមិននាំមកប្រគេន, គប្បីឱ្យទទួលភារៈជំនួស ។ ឱ្យនាំយាគូនិងភត្តមកប្រគេនដល់ភិក្ខុដែលទទួលភារៈអ្នកចាំលំនៅទាំងនោះ ។ និងស្លាកទាំងនោះ របស់ពួកភិក្ខុដែលទទួលភារៈអ្នកចាំលំនៅនោះ រមែងជាចំណែកបន្ថែមពិត លោកទាំងឡាយ រមែងបានដើម្បីកាន់យកសលាកភត្តប្រណីតសូម្បីដទៃ ក្នុងទីដែលដល់តាមលំដាប់វស្សាផង, គប្បីចែកស្លាកតាមលំដាប់ទុកមួយផ្នែក សម្រាប់ឯកវារិយភត្ត ដែលមានរស់ដ៏ក្រៃលែង ។

បើថា ស្លាកដែលភិក្ខុណាបានហើយ, តែភិក្ខុនោះមិនបានភត្តនោះក្នុងថ្ងៃនោះ គប្បីឱ្យលោកទទួលក្នុងថ្ងៃស្អែក ។

ភិក្ខុណាបានតែភត្ត មិនបានសម្ពុឌ្ឍវិភង្គ, សូម្បីយ៉ាងនេះ ក៏គប្បីឱ្យទទួលថ្មី ។

សូម្បីក្នុងសលាកភត្តមានទឹកដោះស្រស់ ក៏ន័យនេះឯង ។

តែថា បានតែទឹកដោះស្រស់ មិនបានភត្ត, កុំគប្បីឱ្យទទួលដដែលទៀត ចាប់ផ្ដើមតាំងពីបានទឹកដោះស្រស់ទៅហើយ ។ ឯកវារិយភត្ត ២-៣ កន្លែង ត្រូវបានដល់ភិក្ខុមួយរូបប៉ុណ្ណោះ, ក្នុងទុព្ភិក្ខសម័យគប្បីបែងចែកឱ្យកាន់ជាផ្នែក ៗ ក្នុងវេលាដែលសង្ឃនវកៈបានហើយ ។ សលាកភត្តតាមប្រក្រតី សូម្បីភិក្ខុដែលមិនទាន់បាន ក៏គប្បីឱ្យទទួលក្នុងថ្ងៃស្អែក ។

បើជាសំណាក់តូច, ភិក្ខុទាំងពួងឆាន់រួមគ្នា, កាលឱ្យកាន់យកស្លាកអំពៅនឹងឱ្យដល់ភិក្ខុណាមួយ ដែលនៅចំពោះមុខ ហើយសកប្រគេនព្រះមហាថេរៈ ជាដើមក្នុងកាល ក៏គួរ ។

ស្លាកទឹកអំពៅ គ្រាចែកគ្នាហើយ សូម្បីខាងក្រោយភត្ត គប្បីត្រងឬឱ្យធ្វើជាផាណិតៈ ហើយប្រគេនសូម្បីដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គជាដើម, ត្រូវដឹងថា "ភិក្ខុអាគន្តុកៈមកហើយ ឬមិនទាន់មក" ទើបឱ្យកាន់យកស្លាក ។

ក្នុងអាវាសធំ ត្រូវចាត់លំដាប់ឱ្យកាន់យក ។ ស្លាកខ្លាញ់[1] នឹងឱ្យក្នុងទីនៃភិក្ខុដែលជាសភាគគ្នា ឬនឹងឱ្យកំដៅ ឬនឹងឱ្យចំហៀវ ប្រគេនព្រះថេរៈទាំងឡាយ ក៏គួរ ។ គប្បីបដិបត្តិតាមន័យដែលពោលហើយក្នុងអាវាសធំនុ៎ះឯង ។

(១) យត ហៅតាមឥណ្ឌាថា ឃី (Ghee) ខ្មែរ ហៅថា ខ្លាញ់

សូម្បីស្លាកផ្លែឈើ ស្លាកទំនិងស្លាកភេសជ្ជៈ ស្លាកគ្រឿងក្រអូបនិងផ្កាកម្រងជាដើម គប្បីឱ្យកាន់យកតាមលំដាប់ជាផ្នែក ៗ ។

ក៏ឯក្នុងស្លាកទាំងនេះ ស្លាកភេសជ្ជៈជាដើម រមែងគួរដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ ក៏ពិតមែនហើយ តែថា ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ ក៏មិនគប្បីត្រេកអរ ព្រោះជាបច្ច័យដែលឱ្យកាន់យកជាប់ដោយស្លាក ។

ទាយកប្រគេនសលាកភត្ត សូម្បីមានត្រឹមតែថា ភិក្ខាដ៏ប្រសើរ, គប្បីសួរដល់លំដាប់ហើយឱ្យកាន់យក ។ កាលមិនមានលំដាប់ គប្បីឱ្យតាំងពីថេរាសនៈ ចុះមក ។ បើថា ភត្តដូច្នោះមានច្រើន, គប្បីឱ្យដល់ភិក្ខុមួយរូប ២-៣ ស្លាក ។ បើមិនមានច្រើន, គប្បីឱ្យមួយរូបមួយស្លាកប៉ុណ្ណោះ កាលលំដាប់អស់ហើយ គប្បីឱ្យតាំងពីទីថេរាសនៈចុះមកទៀត ។ បើដាច់ចេញពីចន្លោះ, គប្បីចាំលំដាប់ ទុក ។ បើភត្តដូច្នោះជារបស់មានប្រចាំតែម្តង, ភត្តនោះត្រូវបានដល់ភិក្ខុជានិច្ចគប្បីប្រាប់ភិក្ខុនោះថា "លោកបានហើយក៏ដោយ មិនទាន់បានក៏ដោយ សូម្បីស្អែកនេះក៏គប្បីទទួល" ។

ភត្តមួយ ជារបស់ដែលគេមិនបានឱ្យជានិច្ច តែក្នុងថ្ងៃដែលបាន រមែងបានល្មមឆាន់ ។ ថ្ងៃដែលមិនបាន មានច្រើនជាង ។ ភត្តនោះ

មិនត្រូវបានដល់ភិក្ខុណា, គប្បីបង្គាប់ភិក្ខុនោះថា "លោកមិនបាន គប្បីទទួលក្នុងថ្ងៃស្អែកនេះចុះ" ។

កាលឱ្យចាប់ស្លាកហើយ ភិក្ខុណាមកខាងក្រោយ, ស្លាករបស់ភិក្ខុនោះកន្លងទៅហើយ កុំគប្បីចាត់ចែងឱ្យឡើយ ។

ចាប់ផ្ដើមតាំងពីវាយរគាំងទៅ ភិក្ខុដែលមកលាតដៃនោះឯង រមែងបានលាភ គឺ ស្លាកពិត ។

កាលភិក្ខុដទៃ សូម្បីមកឈរក្នុងទីជិត ស្លាកក៏កន្លងហួសទៅហើយ តែបើភិក្ខុដទៃ អ្នកទទួលជំនួសភិក្ខុនោះមាន, ភិក្ខុនោះ សូម្បីមិនមកខ្លួនឯង រមែងបាន ។

ក្នុងឋានជាអ្នកសភាគគ្នា ភិក្ខុអ្នកចែកដឹងថា "ភិក្ខុឯណោះមិនទាន់មក" ទឹងរក្សាទុកឱ្យដោយតាំងចិត្តថា "នេះស្លាករបស់ភិក្ខុនោះ" ដូច្នេះក៏គួរ ។

បើថា ភិក្ខុទាំងឡាយធ្វើកតិកាទុកថា "មិនគប្បីឱ្យ សូម្បីភិក្ខុដែលមិនមក", កតិកានោះ មិនជាធម៌ ។ ព្រោះថា ភណ្ឌៈដែលគប្បីចែកគ្នា រមែងត្រូវបានដល់ភិក្ខុដែលតាំងនៅក្នុងឧបចារៈ ។ បើថា ភិក្ខុទាំងឡាយធ្វើសំឡេងអឺងកងថា "លោកចូរឱ្យដល់ភិក្ខុអ្នកមិនមក" គប្បីផ្ដើមតាំងទណ្ឌកម្ម គប្បីពោលថា "ចូរលោកមកទទួលយកដោយខ្លួនឯងចុះ" ។ ស្លាកបាត់ទៅ ៥-៦ បន្ទះ, ភត្តុទ្ទេសកៈរលឹកឈ្មោះទាយកមិន

បាន បើថា ភត្តុទ្ទេសកៈនោះ ឱ្យស្លាកដែលបាត់ដល់ព្រះមហាថេរៈ ឬដល់ខ្លួនហើយ គប្បីបង្គាប់ភិក្ខុទាំងឡាយថា "សលាកភត្តក្នុងស្រុកឯណោះ យើងឱ្យដល់ខ្លួនយើង លោកទាំងឡាយគប្បីឆាន់សលាកភត្តដែលបានក្នុងស្រុកនោះចុះ" ដូច្នេះ សមគួរ ។

តែមិនបានប្រគេនក្នុងសំណាក់ បានភត្តនោះក្នុងរោងឆាន់ ហើយចែកគ្នាឆាន់ក្នុងរោងដូច្នោះឯង មិនគួរទេ ។

កាលទាយកពោលថា "តាំងពីថ្ងៃនេះទៅ សូមលោកម្ចាស់ទាំងឡាយ ទទួលសលាកភត្តរបស់ខ្ញុំព្រះករុណា" ដូច្នេះ នឹងឱ្យកាន់យកក្នុងរោងឆាន់នោះ មិនគួរ ។ ត្រូវនាំមកកាន់វិហារហើយ ទើបឱ្យកាន់យក ។

មួយទៀត កាលទាយកពោលថា "លោកម្ចាស់ទាំងឡាយចូរទទួលសលាកភត្តរបស់ខ្ញុំព្រះករុណា តាំងពីថ្ងៃស្អែកនេះទៅ" ដូច្នេះ គប្បីប្រាប់ដល់ភត្តុទ្ទេសកៈថា "ត្រកូលឈ្មោះឯណោះ ប្រគេនសលាកភត្តតាំងពីថ្ងៃស្អែកនេះទៅ, លោកគប្បីទឹកក្នុងវេលាឱ្យចាប់ស្លាក" ។

ក្នុងគ្រាទុព្ភិក្ខភ័យ ជនទាំងឡាយ វៀរសលាកភត្តចេញ កាលដល់គ្រារកភិក្ខាបានងាយ ឃើញភិក្ខុរបខ្វះហើយ ផ្ដើមតាំងទុកទៀតថា "សូមលោកម្ចាស់ទាំងឡាយ ទទួលសលាកភត្តរបស់ពួកខ្ញុំព្រះករុណា តាំងពីថ្ងៃនេះទៅ" ។ កុំចែកគ្នាខាងក្នុងស្រុក ត្រូវនាំមកវិហារសិន សឹមចែក

គ្នា ។ ព្រោះថា ធម្មតាសលាកភត្តនេះ មិនដូចជាឧទ្ទេសភត្ត, ទាយក រមែងប្រគេនចំពោះវិហារ; ព្រោះដូច្នោះ ទើបមិនគួរចែកគ្នាក្រៅឧបចារៈ ។

មួយទៀត កាលទាយកប្រាប់ថា "សូមលោកម្ចាស់ទាំងឡាយ ទទួលសលាកភត្តរបស់ខ្ញុំព្រះករុណា តាំងពីស្រុកនេះទៅ" ដូច្នេះ ត្រូវចែកគ្នាក្នុងវិហារប៉ុណ្ណោះ ។

គមិកភិក្ខុ មានប្រាថ្នានឹងទៅកាន់ទីដទៃក្នុងទិសណា, ស្លាកដែលអ្នកស្រុកវេនក្នុងទិសនោះ ជារបស់ដែលភិក្ខុដទៃបានហើយ, គមិកភិក្ខុនឹងកាន់យកស្លាកនោះ ហើយពោលចំពោះភិក្ខុក្រៅនេះថា "លោកចូរកាន់យកស្លាកដែលត្រូវបានដល់យើង" ដូច្នេះ ហើយទៅ ក៏គួរ ។ តែភិក្ខុនោះ ត្រូវកាន់យកស្លាករបស់គមិកភិក្ខុនោះ ក្នុងកាលលោកនៅមិនទាន់ឈានកន្លងឧបចារៈសីមាទៅប៉ុណ្ណោះ ។

មនុស្សទាំងឡាយ នៅក្នុងវិហារដែលបោះបង់ចោលហើយ ចាត់តាំងសលាកភត្តទុកដោយគិតថា "ភិក្ខុទាំងឡាយបោសសំអាតទីលានដើមពោធិព្រឹក្ស និងចេតិយជាដើមហើយ ចូរឆាន់ចុះ" ដូច្នេះ ។ ភិក្ខុទាំងឡាយ នៅក្នុងទីដែលមានភិក្ខុជាសភាគគ្នា ហើយទៅពីព្រឹកព្រលឹម ធ្វើវត្តក្នុងវិហារដែលបោះបង់ចោលនោះ ហើយឆាន់ភត្តនោះ គួរ ។

បើថា កាលភិក្ខុទាំងនោះ ឱ្យដល់ខ្លួនដើម្បីនឹងបានឆាន់ក្នុងថ្ងៃស្អែក

ហើយនាំគ្នាទៅ ភិក្ខុអាគន្តុកៈនៅក្នុងវិហារដែលបោះបង់ចោលនោះ ធ្វើវត្តអំពីព្រឹកប៉ុណ្ណោះ វាយរគាំងហើយញុំាងសលាកភត្តឱ្យដល់ខ្លួន ហើយទៅកាន់រោងឆាន់ ។ ភិក្ខុអាគន្តុកៈ នោះឯង ជាធំនៃភត្តនោះ ។

ចំណែកភិក្ខុណា កាលភិក្ខុទាំងឡាយកំពុងធ្វើវត្ត បោសជី ២-៣ កន្លែងហើយ វាយរគាំងហើយទៅ ដោយធ្វើទុកក្នុងចិត្តថា "សលាកភត្តក្នុងស្រុកឆ្ងាយត្រូវបានដល់យើង" ។ សលាកភត្តនោះ រមែងមិនដល់ភិក្ខុនោះ ព្រោះលោកកាន់យក ដោយអាការជាចោរ, រមែងជារបស់ភិក្ខុដែលធ្វើវត្ត រួចស្រេចហើយឱ្យដល់ភិក្ខុដែលមកខាងក្រោយប៉ុណ្ណោះ ។

ស្រុកមួយនៅឆ្ងាយពេក, ភិក្ខុទាំងឡាយមិនប្រាថ្នាដើម្បីទៅជានិច្ច ។ ជនទាំងឡាយទើបពោលថា "ពួកខ្ញុំព្រះករុណាជាអ្នកឃ្លាតឆ្ងាយចាកបុណ្យ" ។ គប្បីពោលនឹងភិក្ខុទាំងឡាយ ដែលជាសភាគគ្នាក្នុងវិហារជិតស្រុកនោះថា "ក្នុងថ្ងៃដែលភិក្ខុទាំងនេះមិនមក ពួកលោកចូរឆាន់ចុះ" ។

មួយទៀត ស្លាកត្រូវឱ្យចាប់រាល់ថ្ងៃ ។ ក៏ស្លាកនោះឯង មិនឈ្មោះថា ភត្តុទ្ទេសកៈនោះឱ្យចាប់ហើយ ដោយអាការត្រឹមតែវាយរគាំង ឬត្រឹមតែគោះល្អី ។

តែត្រូវចាប់ល្អីកៀរស្លាកចុះក្នុងល្អី មិនគប្បីចាប់ល្អីត្រង់កណ្តាប់មាត់ ។ ព្រោះថា ក្នុងល្អីនោះមានពស់ឬសត្វខ្ទួយ វានឹងញុំាង

អ្នក ( ចាប់ ) ឱ្យដល់នូវទុក្ខ ព្រោះដូច្នោះ ត្រូវចាប់ខាងក្រោម បន្ទិលមាត់ល្អីចេញក្រៅ និងកាលចាប់ល្អីហើយគប្បីកៀរស្លាកចុះ ។

សូម្បីមានពស់, វានឹងវត់ទៅខាងឯណោះនោះឯង ព្រោះដូច្នោះ ទើបត្រូវកៀរស្លាកយ៉ាងនោះ ។ ស្លាកគប្បីឱ្យចាប់ជាប់ដោយស្រុកជាដើម តាមន័យដែលពោលហើយក្នុងកាលមុននុ៎ះឯង ។

មួយទៀត ភិក្ខុដែលចែកស្លាកនោះ ឱ្យស្លាកមួយដល់ព្រះមហាថេរៈ ហើយ ទើបឱ្យដល់ខ្លួនថា “ស្លាកដ៏សេសត្រូវបានដល់យើង” ដូច្នេះ ធ្វើវត្តថ្វាយបង្គំចេតិយហើយ កាលភិក្ខុទាំងឡាយ ដែលនៅត្រង់រោងរម្ងាប់វិតក្កសួរថា “អ្នកមានអាយុ ស្លាកឱ្យចាប់ហើយឬ ?” គប្បីឆ្លើយថា “លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ចូរទទួលសលាកភត្ត ក្នុងស្រុកដែលពួកលោកម្ចាស់ទៅដល់ហើយចុះ” ។

ពិតមែន ស្លាកសូម្បីដែលឱ្យដល់ហើយយ៉ាងនេះ ចាត់ថា ឱ្យដល់ហើយដោយល្អដូចគ្នា ។

ភិក្ខុទាំងឡាយ ទៅកាន់សំណាក់ដទៃ ដើម្បីស្តាប់ធម៌ រហូតដល់អស់មួយយប់ ទើបបង្គាប់ថា “យើងទាំងឡាយមិនទទួល ទានក្នុងទីនោះទេ នឹងត្រាច់បិណ្ឌបាតក្នុងគោចរគ្រាមរបស់យើង ហើយនឹងមក”ដូច្នេះ មិនទទួលស្លាកហើយចេញទៅ ។ ភិក្ខុទាំងនោះ នឹងមកដើម្បីឆាន់សលាកភត្ត ដែលត្រូវបានដល់ព្រះថេរៈក្នុងសំណាក់ដូច្នេះ ក៏គួរ ។

បើថា សូម្បីព្រះមហាថេរៈក៏ទៅជាមួយភិក្ខុទាំងនោះ ដោយគិតថា "យើងនឹងធ្វើអ្វីនៅត្រង់នេះ" ភិក្ខុទាំងនោះ មិនបានឆាន់ក្នុងសំណាក់ដែលខ្ពង់ទៅ ត្រាច់ទៅកាន់គោចរគ្រាមតាមលំដាប់ កុំគប្បីឱ្យបាត្រ ក្នុងកាលទាយកពោលថា "លោកម្ចាស់ដ៏ចម្រើន ចូរប្រគល់បាត្រឱ្យចុះ, ខ្ញុំព្រះករុណានឹងនាំស្លាកយាគូជាដើមមកប្រគេន" ។

កាលគេសួរថា "លោកម្ចាស់ដ៏ចម្រើន ហេតុអ្វី ទើបមិនឱ្យហ្ន៎ ?" គប្បីតបគេថា "ភត្តចំពោះវិហារ រមែងត្រូវបានដល់ភិក្ខុទាំងឡាយដែលនៅក្នុងវិហារ យើងទាំងឡាយនៅក្នុងវិហារដទៃ" ។

ក៏កាលគេពោលថា "លោកម្ចាស់ដ៏ចម្រើន សូមមេត្តាឱ្យចុះ ខ្ញុំព្រះករុណាមិនបានថ្វាយដល់សង្ឃក្នុងសីមានៃវិហារទេ, ខ្ញុំព្រះករុណាប្រគេនដល់លោកម្ចាស់, សូមលោកទទួលភិក្ខារបស់ខ្ញុំព្រះករុណាចុះ" ដូច្នេះ សមគួរឱ្យបាត្រទៅបាន ។

សលាកភត្តកថា ចប់

# បក្ខិកភត្តជាដើម

ក៏វិនិច្ឆ័យក្នុងបក្ខិកភត្តជាដើម គប្បីជ្រាបដូច្នេះ ៖

ភត្តណា ដែលជនទាំងឡាយខ្វល់ខ្វាយក្នុងការងារ ប្រគេនក្នុងថ្ងៃបក្ខ (ដែលបណ្ឌិតកំណត់ទុក) ទាំងនេះ គឺ ថ្ងៃ ១៤, ថ្ងៃ ១៥, ថ្ងៃ ៥, ថ្ងៃ ៨, ដើម្បីត្រូវការដាស់តឿនសតិ សម្រាប់ធ្វើឧបោសថភត្តនោះ ឈ្មោះថា បក្ខិកភត្ត ។ បក្ខិកភត្តនោះ មានគតិដូចជាសលាកភត្តនុ៎ះឯង ។ គប្បីឱ្យភិក្ខុទាំងឡាយទទួលឆាន់ ។

បើថា សលាកភត្តក្តី បក្ខិកភត្តក្តី មានច្រើនទូទៅត្រូវបានដល់ភិក្ខុទាំងពួង, ភត្តុទ្ទេសកៈគប្បីឱ្យកាន់យកភត្ត សូម្បីទាំង ២ ផ្នែក ៗ ។

បើថា ភិក្ខុសង្ឃមានច្រើន, គប្បីឱ្យកាន់យកបក្ខិកភត្តហើយ ទើបឱ្យកាន់យកសលាកភត្ត ដែលជាលំដាប់នៃបក្ខិកភត្តនោះ ក៏បាន ឬគប្បីឱ្យកាន់យកសលាកភត្តហើយ ទើបឱ្យកាន់យកបក្ខិកភត្តដែលជាលំដាប់នៃសលាកភត្តនោះ ក៏បាន ។

ភត្ត ២ នោះ មិនទាន់ត្រូវបានដល់ភិក្ខុពួកណា, ភិក្ខុទាំងនោះនឹងត្រាច់បិណ្ឌបាត ។

សូម្បីបើថា ភត្តទាំង ២ មានច្រើន, ភិក្ខុមានតិច ៗ ភិក្ខុរមែងបានសលាកភត្តរាល់ថ្ងៃ ។

ព្រោះដូច្នោះ គប្បីវៀរស្លាកនោះចេញ ឱ្យកាន់យកតែបក្ខិកភត្ត ប៉ុណ្ណោះថា "លោកដ៏មានអាយុ លោកចូរឆាន់បក្ខិកភត្តចុះ" ដូច្នេះ ។

ពួកទាយកប្រគេនបក្ខិកភត្តប្រណីត, គប្បីចាត់លំដាប់ទុកផ្សេងដទៃ ។ មិនគប្បីឱ្យកាន់យកបក្ខិតភត្តតែក្នុងថ្ងៃនេះថា "ស្អែកនេះ ជាថ្ងៃបក្ខ" ។

ក៏ឯបើទាយកទាំងឡាយពោលថា "ស្អែកនេះឯង ក្នុងផ្ទះរបស់ពួកខ្ញុំព្រះករុណានឹងមានភត្តសៅហ្មង, សូមលោកម្ចាស់ចែកបក្ខិកភត្តក្នុងថ្ងៃនេះតែម្តង" ។ យ៉ាងនេះគួរឱ្យកាន់យកក្នុងថ្ងៃនេះបាន ។

ដែលឈ្មោះថា ឧបោសថិកភត្តនោះ គប្បីជ្រាបដូច្នេះ ៖

បុគ្គលសមាទានអង្គឧបោសថ ក្នុងថ្ងៃឧបោសថរាល់កន្លះខែ ហើយខ្លួនឯងបរិភោគភត្តណា, ភត្តនោះឯងដែលគេតែងឱ្យ ។

ដែលឈ្មោះថា បាដិបទិកភត្តនោះ បានដល់ ទានដែលទាយកឱ្យក្នុងថ្ងៃបាដិបទដោយកំណត់ថា "ក្នុងថ្ងៃឧបោសថ ជនជាច្រើនមានសទ្ធាជ្រះថ្លា តែងធ្វើសក្ការៈដល់ភិក្ខុទាំងឡាយ, ចំណែកក្នុងថ្ងៃបាដិបទ ភិក្ខុទាំងឡាយ រមែងលំបាក, ទានដែលប្រគេនក្នុងថ្ងៃបាដិបទ រមែងជាកុសលមានផលច្រើន ដូចនឹងទុព្ភិក្ខទាន, ឬទានដែលប្រគេនក្នុងថ្ងៃទី២ ដល់ភិក្ខុដែលមានសីលបរិសុទ្ធិ ព្រោះឧបោសថកម្ម រមែងជាកុសលមានផលច្រើន" ដូច្នេះ ។

ភត្តទាំង ២ សូម្បីនោះ មានគតិដូចជាសលាកភត្តដូចគ្នា ។

ភត្តទាំង ៧ យ៉ាងនោះ មិនគួរដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ

រមែងធ្វើនូវការបែកធ្លាយនៃធុតង្គដោយពិត ដោយប្រការដូច្នេះ ។

## អាគន្តុកភត្តជាដើម

សូម្បីភត្តដទៃ ៤ ប្រភេទទៀត ដែលឧបាសិកាវិសាខាសូមពរ ដើម្បីប្រគេនដល់ភិក្ខុ ៤ ពួក ក្នុងចីវរក្ខន្ធកៈ[១] គឺ អាគន្តុកភត្ត គមិកភត្ត គិលានភត្ត គិលានុបដ្ឋាកភត្តមកហើយក្នុងបាលីដូចគ្នា ។

បណ្ដាភត្តទាំង ៤ នោះ ភត្តដែលប្រគេនដល់ភិក្ខុអាគន្តុកៈឈ្មោះអាគន្តុកភត្ត ។ ក្នុងភត្ត ៣ យ៉ាងដ៏សេស មានន័យដូចគ្នា ។

ក៏បើថា ក្នុងភត្តទាំង ៤ យ៉ាងនេះ ទាំងអាគន្តុកភត្ត ទាំងអាគន្តុកភិក្ខុមានច្រើន, គប្បីឱ្យភិក្ខុទាំងពួងកាន់យកមួយអង្គមួយចំណែក ៗ កាលភត្តមិនគ្រប់គ្រាន់ គប្បីឱ្យយកតាមលំដាប់ ។

ភិក្ខុអាគន្តុកៈមួយរូបមកមុន ឱ្យកាន់យកគន្តុកភត្តទាំងអស់ ដើម្បីខ្ទនហើយអង្គុយ, អាគន្តុកភត្តទាំងពួង រមែងជារបស់លោកប៉ុណ្ណោះ ភិក្ខុអាគន្តុកៈទាំងឡាយ ដែលមកខាងក្រោយ គប្បីឆាន់ភត្តដែលលោកឱ្យហើយ ។

សូម្បីលោកក៏គប្បីកាន់យក ដើម្បីខ្ទនមួយចំណែកហើយ គប្បីឱ្យចំណែកដ៏សេស ។ នេះជាសេចក្ដីប្រពៃក្រៃលែង ។

១. វិន. មហា. ៨. ៥៩/១២៩-១៣០ ។

តែបើថា ភិក្ខុអាគន្តុកៈនោះ សូម្បីមកមុន មិនបានកាន់យកដើម្បីខ្លួន ហើយអង្គុយនៅស្ងៀម ។ ភិក្ខុអាគន្តុកៈទាំងឡាយ ដែលមកខាងក្រោយ គប្បីកាន់យកតាមលំដាប់ព្រមទាំងលោក ។

បើភិក្ខុអាគន្តុកៈមកជានិច្ច គប្បីឆាន់អាគន្តុកភត្តតែក្នុងថ្ងៃដែលមកប៉ុណ្ណោះ, បើមកក្នុងចន្លោះ ៗ គប្បីឆាន់មួយអង្គ ២-៣ ថ្ងៃ ។

ចំណែកក្នុងមហាបច្ចរីពោលថា គួរឆាន់បាន ៧ ថ្ងៃ ។ អាវាសិកភិក្ខុទៅក្នុងទីណាហើយមកក្តី, សូម្បីលោកក៏គប្បីឆាន់អាគន្តុកភត្ត ។

មួយទៀត បើថា អាគន្តុកភត្តនោះ ជារបស់ដែលគេឱ្យជានិច្ចក្នុងវិហារត្រូវឱ្យកាន់យកក្នុងវិហារ ។ បើវិហារនៅឆ្ងាយ ទើបគេឱ្យជានិច្ចក្នុងរោងឆាន់ ត្រូវឱ្យកាន់យកក្នុងរោងឆាន់ ។

ក៏បើថា កាលភិក្ខុអាគន្តុកៈមិនមាន ទើបទាយកពោលថា "សូម្បីភិក្ខុអាវាសិកក៏ឆាន់បាន" ដូច្នេះ, សមគួរដល់អាវាសិកភិក្ខុ នឹងឆាន់ ។ កាលគេមិនពោល មិនគួរ ។

កថាមគ្គ សូម្បីក្នុងគមិកភត្ត ក៏ដូចគ្នានេះ ។ ចំណែកសេចក្តីដែលប្លែកដូច្នេះ ៖

អាគន្តុកភិក្ខុ រមែងបានតែអាគន្តុកភត្តប៉ុណ្ណោះ ។

គមិកភិក្ខុ រមែងបានទាំងអាគន្តុកភត្ត ទាំងគមិកភត្ត ។ សូម្បីអាវាសិកភិក្ខុមានចំណង់នឹងជៀសចេញទៅ រមែងក្លាយជាគមិកភិក្ខុ រមែងបានគមិកភត្ត ។ ដូចជាអាគន្តុកភត្ត ដែលអាគន្តុកភិក្ខុ រមែងបាន យ៉ាងណា គមិកភត្តនេះ ដែលគមិកភិក្ខុ រមែងបាន ២-៣ ថ្ងៃ ឬ ៧ ថ្ងៃ ដូច្នោះ ក៏ទេ ។

ភិក្ខុដែលឆាន់ដោយតាំងចិត្តថា "យើងនឹងទៅ" រហូតដល់អស់ថ្ងៃនោះ ទៅមិនបាន ព្រោះករណីយ៍ណាទីមួយ ក៏ដោយ, សូម្បីក្នុងថ្ងៃស្អែកនឹងឆាន់ ក៏គួរ ព្រោះនៅមានឧស្សាហ៍ (ដែលនឹងទៅ) ។

ក្នុងមហាបច្ចរីពោលថា កាលភិក្ខុតាំងចិត្តថា "នឹងទៅ" ឆាន់ស្រេចហើយ ពួកចោរចាំស្កាត់មកក្តី, ទឹកជន់មកក្តី, ភ្លៀងធ្លាក់ក្តី, ពួករទេះមិនទាន់ទៅក្តី, លោកនៅមានឧស្សាហ៍ គប្បីឆាន់ ។

ភិក្ខុដែលរួចផុតពីឧបទ្រវៈទាំងនោះហើយ នឹងឆាន់ ២-៣ ថ្ងៃក៏គួរ ។ ចំណែកភិក្ខុអាងលេសថា "នឹងទៅ" រមែងមិនបានដើម្បីឆាន់ ។

គិលានភត្តនោះឯង បើមានល្មមដល់ភិក្ខុដែលអាពាធគ្រប់រូប, ក៏គប្បីឱ្យគ្រប់រូប បើថាមិនល្មម ក៏គប្បីចាត់តាមលំដាប់ឱ្យកាន់យក ។

ភិក្ខុអាពាធមួយរូប ប្រាកដដូចភិក្ខុដែលមិនមានរោគ អាចទៅខាង

ក្នុងស្រុកបាន, មួយរូបមិនអាច ភិក្ខុនេះ ឈ្មោះថា អ្នកអាពាធធ្ងន់ ។ គប្បីឱ្យគិលានភត្តដល់លោកពិត ។

ភិក្ខុដែលអាពាធធ្ងន់ ២ រូប, ភិក្ខុមួយរូបមានលាភច្រើន ជាអ្នកមានកេរ្តិ៍ឈ្មោះល្អ បានខាទនីយៈភោជនីយៈច្រើន, ភិក្ខុមួយរូប ជាភិក្ខុអនាថាចូលទៅខាងក្នុងស្រុក ព្រោះសភាពនៃខ្លួនជាអ្នកមានលាភតិច, គប្បីឱ្យគិលានភត្តដល់ភិក្ខុនោះ ។

ចំណែកក្នុងគិលានភត្ត មិនមានកំណត់ថ្ងៃ, ភិក្ខុដែលអាពាធគប្បីឆាន់រហូតអស់វេលាដែលរោគមិនទាន់ស្ងប់ កាលមិនឆាន់ ភោជនដែលសប្បាយ នឹងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅមិនបាន ។

តែក្នុងកាលណា ភិក្ខុដែលអាពាធនោះ សូម្បីឆាន់យាគូដែលលាយ ឬភត្តដែលលាយ រោគក៏មិនកម្រើក, ចាប់ផ្តើម តាំងពីកាលនោះទៅ មិនគប្បីឆាន់គិលានភត្ត ។

សូម្បីគិលានុបដ្ឋាកភត្តនោះ មានល្មមដល់ភិក្ខុដែលព្យាបាលជម្ងឺគ្រប់ ៗរូប ក៏គប្បីឱ្យគ្រប់រូបទាំងអស់, បើថា មិនល្មម គប្បីចាត់តាមលំដាប់ឱ្យកាន់យក ។

សូម្បីគិលានុបដ្ឋាកភត្តនេះ ក៏គប្បីចែកឱ្យដល់ភិក្ខុដែលព្យាបាល

ភិក្ខុអាពាធជូន់ក្នុងបណ្តាភិក្ខុដែលអាពាធ ២ រូប ។

ត្រកូលណា ប្រគេនទាំងគិលានភត្ត ទាំងគិលានុបដ្ឋាកភត្តដល់ភិក្ខុអ្នកព្យាបាលភិក្ខុអនាថាដែលអាពាធ ក្នុងបណ្តាភិក្ខុអាពាធជូន់ ២ រូប ភត្តក្នុងត្រកូលនោះ ត្រូវបានដល់ភិក្ខុអាពាធរូបណា សូម្បីភិក្ខុដែលព្យាបាលភិក្ខុអាពាធរូបនោះ ក៏គប្បីឱ្យកាន់យកក្នុងត្រកូលនោះឯង ។

សូម្បីក្នុងគិលានុបដ្ឋាកភត្ត ក៏មិនមានកំណត់ថ្ងៃ ។ ភិក្ខុអាពាធតែងបានត្រឹមណា, សូម្បីអ្នកព្យាបាលរបស់លោក រមែងបានត្រឹមនោះ, ព្រោះហេតុនោះ ភត្ត ៤ យ៉ាងនេះ ជារបស់ដែលគេប្រគេនយ៉ាងនេះថា "ភិក្ខុអាគន្តុកៈ, ភិក្ខុដែលត្រៀមខ្លួនទៅ, ភិក្ខុដែលអាពាធ, និងភិក្ខុដែលព្យាបាលភិក្ខុអាពាធ, ចូរទទួលភិក្ខារបស់ខ្ញុំព្រះករុណា" រមែងគួរ សូម្បីដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ ។ តែបើជារបស់ដែលគេប្រគេនយ៉ាងនេះថា "ខ្ញុំព្រះករុណាចាត់ចែងភត្តទុកជាប្រចាំ ដើម្បីភិក្ខុអាគន្តុកៈជាដើម, ភិក្ខុអាគន្តុកៈជាដើមចូរទទួលភត្តរបស់ខ្ញុំព្រះករុណា" មិនគួរដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គនោះ ។

## ភត្ត ៣ ប្រភេទទៀត

សូម្បីភត្តដទៃ ៣ ប្រភេទទៀត គឺ ធុវភត្ត កុដិភត្ត វារកភត្ត ។ ក្នុងភត្ត ៣ ប្រភេទនោះ និច្ចភត្ត ហៅថា ធុវភត្ត ។ ធុវភត្តនោះ មាន ២ យ៉ាង គឺ របស់សង្ឃ ១ របស់បុគ្គល ១ ។

ក្នុង២ យ៉ាងនោះ ធុវភត្តណា ដែលទាយកប្រគេនឱ្យជាប្រចាំថា "ខ្ញុំព្រះករុណាសូមប្រគេនធុវភត្តដល់សង្ឃ" ដូច្នេះ ធុវភត្តនោះ មានគតិដូចសលាកភត្តដូចគ្នា ។ ក៏ឯធុវភត្តនោះ ដែលទាយកពោលថា "សូមលោកម្ចាស់ទាំងឡាយ ទទួលភិក្ខាប្រចាំរបស់ខ្ញុំព្រះករុណា" ដូច្នេះ រមែងគួរសូម្បីដល់ភិក្ខុទាំងឡាយកាន់បិណ្ឌបាតិកធុតង្គ ។

សូម្បីកាលធុវភត្តជារបស់ចំពោះបុគ្គល ដែលទាយកពោលថា "ខ្ញុំព្រះករុណាប្រគេនធុវភត្តដល់លោកម្ចាស់ទាំងឡាយ" ដូច្នេះ ធុវភត្តនោះ មិនគួរដល់ភិក្ខុទាំងឡាយ ដែលកាន់បិណ្ឌបាតិកធុតង្គប៉ុណ្ណោះ ។ តែកាលគេពោលថា "សូមម្ចាស់ទាំងឡាយ ទទួលភិក្ខាប្រចាំរបស់ខ្ញុំព្រះករុណា" ដូច្នេះ គួរ, ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ គួរត្រេកអរ ។

សូម្បីថា ខាងក្រោយ កាលកន្លងទៅហើយ ២-៣ ថ្ងៃ គេពោលថា "សូមលោកម្ចាស់ទាំងឡាយ ទទួលធុវភត្ត" ភត្តនោះគួរដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ ព្រោះជារបស់ដែលលោកទទួលទុកល្អហើយក្នុងថ្ងៃ

ដំបូង ។

ដែលឈ្មោះថា **កុដិភត្ត** គឺ ភត្តដែលទាយកសាងទីលំនៅថ្វាយសង្ឃហើយ ប្រគេនឱ្យជាប្រចាំយ៉ាងនេះថា “លោកម្ចាស់ទាំងឡាយ ដែលនៅក្នុងសេនាសនៈរបស់ពួកខ្ញុំព្រះករុណា សូមទទួលភត្តរបស់ពួកខ្ញុំព្រះករុណាប៉ុណ្ណោះ” ដូច្នេះ កុដិភត្តនោះ មានគតិដូចជាសលាកភត្តដែរ, គប្បីឱ្យភិក្ខុទាំងឡាយទទួលមកឆាន់ ។

ក៏កាលទាយកពោលថា “លោកម្ចាស់ទាំងឡាយ ដែលនៅក្នុងសេនាសនៈរបស់ពួកខ្ញុំព្រះករុណា សូមទទួលភិក្ខារបស់ពួកខ្ញុំព្រះករុណាប៉ុណ្ណោះ” ដូច្នេះ កុដិភត្តនោះ រមែងគួរសូម្បីដល់ភិក្ខុទាំងឡាយ ដែលកាន់បិណ្ឌបាតិកធុតង្គ ចំណែកកុដិភត្តណា ដែលទាយកជ្រះថ្លាក្នុងបុគ្គលហើយសាងទីនៅដើម្បីបុគ្គលនោះថ្វាយថា “ខ្ញុំព្រះករុណាថ្វាយដល់លោកម្ចាស់” ដូច្នោះកុដិនោះ រមែងគួរដល់បុគ្គលនោះប៉ុណ្ណោះ កាលបុគ្គលនោះចេញទៅក្នុងទីណា ៗ ពួកនិស្សិតគប្បីឆាន់ជំនួស ។

ដែលឈ្មោះថា **វារកភត្ត** គឺ ភត្តដែលទាយកប្រគេនចាប់ផ្តើមតាំងពីផ្ទះជិតទៅថា “ពួកខ្ញុំព្រះករុណានឹងផ្លាស់វារៈគ្នាទំនុកបម្រុងភិក្ខុទាំងឡាយ ក្នុងសម័យដែលភិក្ខារកបានលំបាក”, សូម្បីវារកភត្តនោះ ដែលទាយកប្រគេនចេញឈ្មោះភិក្ខា ក៏គួរដល់ភិក្ខុទាំងឡាយអ្នកកាន់បិណ្ឌបាតិកធុតង្គ តែកាលទាយកពោលថា “ប្រគេនវារកភត្ត” ដូច្នេះ វារកភត្ត

នោះ មានគតិដូចជាសលាកភត្ត ។

ក៏បើថា ពួកទាយកបញ្ញូនអន្តរជាដើមទៅថា "សាមណេរទាំងឡាយចូរបំអិនប្រគេន" ដូច្នេះ, ភត្តនោះ គួរដល់ភិក្ខុដែលកាន់បិណ្ឌបាតិកធុតង្គ ។

ភត្តទាំង ៣ នេះ នឹងភត្ត ៤ ទៀត មានអាគន្តុកភត្តជាដើម រួមជា ៧, ភត្ត ៧ នោះ រួមជាមួយភត្តដទៃ ៧ ទៀត មានសង្ឃភត្តជាដើម ទើបជាភត្ត ១៤ យ៉ាង ដោយប្រការដូច្នេះ ។

## ភត្តដទៃ ៤ យ៉ាងក្នុងអដ្ឋកថា

មួយទៀត ក្នុងអដ្ឋកថាពោលភត្ត ៤ យ៉ាងសូម្បីដទៃ គឺ វិហារភត្ត អដ្ឋកភត្ត ចតុក្កភត្ត គុឡកភត្ត ។ បណ្ដាភត្តទាំង ៤ យ៉ាងនោះ ដែលឈ្មោះថា វិហារភត្ត បានដល់ ភត្តដែលកើតអំពីតម្លៃរបស់សង្ឃក្នុងវិហារនោះ ។ វិហារភត្តនោះ សង្គ្រោះដោយសង្ឃភត្ត ។

មួយទៀត វិហារភត្តនោះ រមែងគួរសូម្បីដល់ភិក្ខុទាំងឡាយ អ្នកកាន់បិណ្ឌបាតិកធុតង្គ ក្នុងឋានៈទាំងឡាយដូច្នោះ ព្រោះជាភត្តដែលព្រះទីណាស្រេចសម្រេចបដិសម្ភិទា ក្នុងតិស្សមហាវិហារ និងចិត្តលបព្វតជាដើមទទួលហើយ ដូចជាភត្តដែលភិក្ខុ សូម្បីកាន់បិណ្ឌបាតិកធុតង្គក៏អាចឆាន់បាន ។ ចំណែកភត្តដែលទាយកប្រគេនយ៉ាងនេះថា "ខ្ញុំព្រះករុណា

ប្រគេនដល់ភិក្ខុ ៨ រូប, ខ្ញុំព្រះករុណាប្រគេនដល់ភិក្ខុ ៤ រូប” ដូច្នេះ ឈ្មោះថា អដ្ឋកភត្ត និងឈ្មោះថា ចតុកភត្ត ។

សម្បីអដ្ឋកភត្ត និងចតុកភត្តនោះ ដែលទាយកប្រគេនចេញឈ្មោះភិក្ខា គួរដល់ភិក្ខុអ្នកកាន់បិណ្ឌបាតិកធុតង្គ ។

ភត្តដែលទាយកកំណត់បាត្រទុក ដោយទំមានរសឆ្ងាញ់ក្រៃលែងមានគ្រឿងផ្សំច្រើនហើយប្រគេន ឈ្មោះគុឡកភត្ត ។ ភត្តទាំង ៣ យ៉ាងនេះ មានគតិដូចជាសលាកភត្តដែរ ។

សម្បីភត្តដទៃទៀតដែលឈ្មោះថា គុឡកភត្ត ក៏មាន (គឺ) មនុស្សទាំងឡាយពួកខ្លះក្នុងលោកនេះ ឱ្យធ្វើការស្តាប់ធម៌ជាការធំ និងការបូជាក្នុងវិហារហើយពោលថា “ពួកខ្ញុំព្រះករុណាមិនអាចប្រគេនដល់ព្រះសង្ឃទាំងអស់បាន, សូមភិក្ខុ ២-៣ រយរូបទទួលភិក្ខារបស់ពួកខ្ញុំព្រះករុណា”ដូច្នេះ, ហើយប្រគេនស្ករអំពៅដើម្បីដឹងចំនួនភិក្ខុ ។ គុឡកភត្តនេះ រមែងគួរសម្បីដល់ភិក្ខុទាំងឡាយដែលកាន់បិណ្ឌបាតិកធុតង្គ ។

ចីវរដែលគួរចែក ខ្ញុំព្រះករុណាបានពោលហើយក្នុងចីវរក្ខន្ធកៈ ចំណែកសេនាសនៈដែលគួរចែក និងបិណ្ឌបាតដែលគួរចែក ខ្ញុំព្រះករុណាបានពោលក្នុងសេនាសនក្ខន្ធកៈនេះ ដោយប្រការដូច្នេះ ។

# គិលានប្បច្ច័យដែលគួរចែក

ចំណែកគិលានបច្ច័យដែលគួរចែក គប្បីជ្រាបយ៉ាងនេះ ៖

បណ្តាភេសជ្ជៈមានទឹកដោះថ្លាជាដើម ព្រះរាជាឬរាជមហាមាត្យ បញ្ជូនទឹកដោះថ្លាមួយរយឆ្នាំងក្តី មួយពាន់ឆ្នាំងក្តី ទៅកាន់សំណាក់មុន ៗ ភត្តុទ្ទេសកៈវាយរគាំង ចាក់ឱ្យពេញភាជនៈ ដែលកាន់មកចាប់ផ្តើមតាំងពីថេរាសនៈចុះមក ។ ទឹកដោះថ្លានោះ រមែងគួរ សូម្បីដល់ភិក្ខុទាំងឡាយដែលកាន់បិណ្ឌបាតិកធុតង្គ ។

បើថា ព្រះមហាថេរៈទាំងឡាយ ជាអ្នកច្រើនដោយការយឺតយាវមកខាងក្រោយ កុំគប្បីពោលនឹងលោកថា "លោកម្ចាស់ ខ្ញុំព្រះករុណាកំពុងចែកដល់ភិក្ខុដែលមានវស្សា ២០, លំដាប់របស់ពួកលោកម្ចាស់ហួសទៅហើយ, គប្បីវៀរលំដាប់ទុកសិន ប្រគេនដល់ព្រះមហាថេរៈទាំងនោះហើយ ទើបប្រគេនតាមលំដាប់ក្នុងខាងក្រោយតទៀត ។ ភិក្ខុទាំងឡាយបានស្តាប់ (ដំណឹង) ថា "ក្នុងវិហារឯណោះ មានទឹកដោះថ្លាកើតឡើងច្រើន" ទើបនាំគ្នាមកសូម្បីអំពីវិហារក្នុងរវាងមួយយោជន៍ ។ គប្បីឱ្យតាំងពីស្ថានដែលលោកទាំងឡាយមកទាន់ ៗ គ្នាឈរ ។

កាលពួកនិស្សិត មានអន្តេវាសិកជាដើម នឹងទទួលជំនួសភិក្ខុទាំង

ទ្បាយ សូម្បីមកមិនទាន់ ដែលចូលឧបចារៈសីមាហើយ ក៏គួរឱ្យ ។

ពួកនិស្សិតទាំងនោះពោលថា "លោកចូរឱ្យដល់ឧបជ្ឈាយ៍ អាចារ្យរបស់ខ្ញុំព្រះករុណា ដែលតាំងនៅខាងក្រៅឧបចារៈសីមា" ដូច្នេះ មិនគប្បីឱ្យ ។

បើថា ភិក្ខុទាំងឡាយនៅជាប់ជាពួកតែមួយនឹងភិក្ខុ ដែលចូលកាន់ឧបចារៈសីមាហើយ មានត្រង់ទ្វារវិហាររបស់ខ្លួនក្តី នៅខាងក្នុងនៃសំណាក់តែម្តងក្តី, សីមាឈ្មោះថា ពង្រីកចេញដោយអំណាចបរិស័ទ; ព្រោះដូច្នោះ គប្បីឱ្យ ។ សូម្បីកាលឱ្យចំណែក ដល់សង្ឃនវកៈរូបស្រេចហើយ ក៏គប្បីឱ្យដល់ភិក្ខុទាំងឡាយ ដែលមកខាងក្រោយដូចគ្នា ។

ប៉ុន្តែថា កាលចំណែកទី ២ បានលើកឡើងកាន់ថេរាសនៈហើយ ចំណែកទី ១ រមែងមិនត្រូវបានដល់ភិក្ខុទាំងឡាយដែលមកពេលក្រោយទៀត, គប្បីឱ្យតាមលំដាប់វស្សាតាំងពីចំណែកទី ២ ទៅ ទឹកដោះថ្លាជារបស់ដែលទាយក ចូលទៅកាន់ឧបចារៈសីមា ហើយឱ្យក្នុងទីណាមួយ, ទឹកដោះថ្លាទាំងអស់គប្បីចែកក្នុងទីប្រជុំប៉ុណ្ណោះ ។

ក្នុងវិហារណា មានភិក្ខុ ១០ រូប និងឆ្នាំងទឹកដោះថ្លាជាដើមដែលទាយកប្រគេន ១០ ឆ្នាំងដូចគ្នា, ក្នុងវិហារនោះ គប្បីចែកគ្នាមួយ

រូបមួយឆ្នាំង ។ ទឹកដោះថ្លាមានតែមួយឆ្នាំង, ភិក្ខុមាន១០ រូប, គប្បីបែងចែកចេញហើយឱ្យកាន់យក ។

បើថា ភិក្ខុទាំងនោះកាន់យកថា "ទឹកដោះថ្លាទាំងឆ្នាំងតាមដែលឋិតនៅនុ៎ះឯង រមែងត្រូវបានដល់ពួកយើង" ដូច្នេះ, ទឹកដោះថ្លានោះ ជាការកាន់យកមិនប្រពៃ, រមែងជារបស់សង្ឃក្នុងទីដែលខូនទៅហើយ ៗ តែម្តង ។

ប៉ុន្តែថា ភិក្ខុផ្ងៀងឆ្នាំង ចាក់ទឹកដោះថ្លាចុះក្នុងភាជនៈបន្តិច ហើយពោលថា "នេះត្រូវបានដល់ព្រះមហាថេរៈ, ដ៏សេសត្រូវបានដល់ពួកយើង" ដូច្នេះហើយ ត្រឡប់ដាក់ទឹកដោះថ្លានោះចុះ ក្នុងឆ្នាំងនុ៎ះឯង កាន់យកទៅតាមត្រូវការ គួរ ។

បើថា ទឹកដោះជាដុំ សូម្បីឆ្អូតជាស្ពាមកាន់យកដោយគិតថា "ចំណែកដទៃអំពីស្ពាមដែលឆ្អូត រមែងត្រូវបានដល់ព្រះមហាថេរៈ, ចំណែកដ៏សេសត្រូវបានដល់ពួកយើង" ដូច្នេះ ឈ្មោះថា កាន់យកប្រពៃ ។

ក្នុងភិក្ខុនិងឆ្នាំងទឹកដោះថ្លា សូម្បីខ្វះឬលើសពីកំណត់ ដូចពោលហើយ ក៏គប្បីបែងចែកគ្នាដោយឧបាយនោះឯង ។ ក៏បើនៅមានភិក្ខុតែ

មួយរូប ទឹកដោះថ្លាក៏នៅមានតែមួយឆ្នាំង ភិក្ខុនោះ នឹងវាយ រគាំងហើយកន់យកដោយគិតថា “នេះដល់យើង” ដូច្នេះក្តី គួរ ។ សូម្បីឱ្យដល់(ខ្ទួន) ម្តងបន្តិច ៗ យ៉ាងនេះថា “នេះចំណែកទី ១ ត្រូវបានដល់យើង, ចំណែកទី ២ នេះ ត្រូវបានដល់យើង” ដូច្នេះ ក៏គួរ ។ សូម្បីក្នុងភេសជ្ជៈដ៏សេស មានទឹកដោះខាប់ជាដើម ក៏ន័យនេះ ។

ប៉ុន្តែថា ស្ពាមគួសមិនតាំងនៅក្នុងប្រេងល្ងជាដើមដែលថ្លាពាវទេ, ប្រេងល្ងជាដើមនោះ គប្បីដួសចែកពិត ។

ភេសជ្ជៈមានខ្ទឹស្រស់ និងម្ទេសជាដើមក្តី, សមណបរិក្ខារ មានបាត្រ និងភាជនៈដ៏សេសជាដើមក្តី, ទាំងអស់គប្បីកំណត់ឱ្យល្អ ហើយចែកតាមន័យដែលសមគួរដល់អធិប្បាយ ដូចពោលហើយនុ៎ះឯង ។

ភិក្ខុដែលឈ្លាសវៃ គប្បីពិចារណាបាលីនិងអដ្ឋកថាហើយ កុំប្រមាទចែកបច្ច័យរបស់សង្ឃយ៉ាងនោះចុះ ។

កថាពោលអំពីបច្ច័យ ដែលគួរចែក ដោយអាការទាំងពួង ចប់ហើយដោយប្រការដូច្នេះ ។

# តួនាទីរបស់អ្នកចែក

ភិក្ខុអ្នកចែក មានចែកយាគូជាដើម ដែលសង្ឃសន្មតតាំងទុក មិនបាច់សួរ (សង្ឃ) ជាមុនក៏បាន គប្បីឱ្យដល់ភិក្ខុសាមណេរទាំងឡាយ ដែលមកកាន់ស្ថានទីចែក មួយរូប ៗកន្លះចំណែក ប៉ុន្តែភិក្ខុដែលមិនបានទទួលសន្មតត្រូវអបលោកនះឱ្យ ។

អ្នកចែករបស់បន្តិចបន្តួច គប្បីឱ្យម្ជុលពីរ គឺ វែងមួយ ខ្លីមួយ ដល់ភិក្ខុដែលធ្វើចីវរកម្មពោលថា "លោកចូរឱ្យម្ជុល" ដូច្នេះ ។ មិនមានកិច្ចដែលត្រូវសួរ ព្រោះកើតសេចក្តីវង្វៀសថា "ភណ្ឌះរបស់សង្ឃមិនគួរចែក" ។

គប្បីឱ្យកាំបិតតូចមួយ ដល់ភិក្ខុដែលមានសេចក្តីត្រូវការដោយកាំបិតតូច ។

គប្បីឱ្យស្បែកជើងមួយគូ ដល់ភិក្ខុដែលប្រាថ្នានឹងធ្វើដំណើរតាមមកកន្តារ ។

គប្បីឱ្យកាយពន្ធ ដល់ភិក្ខុដែលត្រូវការដោយវត្ថុពន្ធចង្កេះ ។

គប្បីឱ្យអង្សៈដល់ភិក្ខុដែលមកសូមថា "អង្សៈរបស់ខ្ញុំព្រះករុណាចាស់ហើយ" ។

គប្បីឱ្យសំពត់តម្រងទឹក ដល់ភិក្ខុដែលមានសេចក្តីត្រូវការដោយសំពត់តម្រងទឹក ។

គប្បីឱ្យធម្មក្រក ដល់ភិក្ខុដែលត្រូវការដោយធម្មក្រក បើមិនមានសំពត់ គប្បីឱ្យធម្មក្រកព្រមទាំងសំពត់ ។

កាលភិក្ខុសូមថា "ខ្ញុំព្រះករុណានឹងបន្ថែមផ្ទាំងសំពត់ផ្អប( សំពត់ថ្មី )" គប្បីឱ្យសំពត់ល្មមដល់កុសិ និងអឌ្ឍកុសិ ។

កាលភិក្ខុមក ( ប្រាប់ ) ថា "សំពត់មណ្ឌលមិនល្មម" គប្បីឱ្យសំពត់មណ្ឌលមួយផ្ទាំង, គប្បីឱ្យសំពត់អឌ្ឍមណ្ឌល ២ ផ្ទាំង ។ កាលលោកសូមសំពត់មណ្ឌល ២ ផ្ទាំង មិនគប្បីឱ្យ ២ ផ្ទាំង ។

គប្បីឱ្យសំពត់ដែលល្មមដល់ចីវរមួយផ្ទាំង ដល់ភិក្ខុដែលត្រូវការដោយសំពត់អនុវាទបណ្ដោយ និងអនុវាទទទឹង ។

ជូសភេសជ្ជៈបានប្រមាណមួយនាឡិ គប្បីឱ្យចំណែកទី ៣ អំពីមួយនាឡិនោះ ដល់ភិក្ខុអាពាធដែលត្រូវការដោយភេសជ្ជៈ មានទឹកដោះថ្លា និងទឹកដោះខាប់ជាដើម ។

កាលឱ្យ ៣ ថ្ងៃយ៉ាងនោះ គ្រប់មួយនាឡិហើយ តាំងពីថ្ងៃទី ៤ ទៅ ត្រូវប្រាប់សង្ឃហើយសិន សឹមឱ្យ ។

ក្នុងស្ករអំពៅនោះ គប្បីឱ្យចំណែកទី៣ ក្នុងមួយថ្ងៃ ។ កាលយកគ្រប់៣ថ្ងៃយ៉ាងនោះហើយ តពីនោះទៅ ត្រូវប្រាប់សង្ឃហើយទើបឱ្យ ។

ពាក្យដ៏សេសទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

**សេនាសនក្ខន្ធកវណ្ណនា ចប់**

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## ចុល្លវគ្គ

## ទុតិយភាគ ១០

## ចប់

# សមន្តបាសាទិកា

## អដ្ឋកថា  វិនយបិដក

## ចុល្លវគ្គ

## តតិយភាគ  ១១

# ១៧. សង្ឃភេទក្ខន្ធកវណ្ណនា

វិនិច្ឆ័យក្នុងសង្ឃភេទក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

[១] ពីរបទថា អភិញ្ញាតា អភិញ្ញាតា : សុទ្ធតែជាអ្នកមាននាមល្បីល្បាញ មានសេចក្តីថា អាមាត្យ ១០ នាក់ មានកាឡុទាយីអាមាត្យជាដើម ព្រមដោយពួកបរិវារ និងពួកជនជាច្រើនដទៃ ឈ្មោះថាសក្យកុមារអ្នកប្រាកដហើយ ៗ ។

[២] បទថា អម្ហាកំ : របស់យើង គឺ យើងទាំងឡាយ ។ ម្យ៉ាងទៀត មានពាក្យអធិប្បាយថា អំពីត្រកូលរបស់យើងទាំងឡាយ ។

ពីរបទថា ឃរាវាសត្ថំ អនុសាសិស្សាមិ[1] : បងនឹងពន្យល់ប្រយោជន៍របស់ឃរាវាសដល់ប្អូន មានសេចក្តីថា កិច្ចយ៉ាងណាលោកគប្បីធ្វើនៅក្នុងឃរាវាស បងនឹងឱ្យប្អូនជ្រាបនូវកិច្ចនោះ ។

បទថា អតិនេតព្វំ : ត្រូវបញ្ចូល គឺ គប្បីបញ្ចូលទឹក ។

បទថា ឧទកំ និន្នេតព្វំ : ត្រូវបញ្ចេញទឹក មានសេចក្តីថា ទឹកជារបស់ស្មើគ្នា ក្នុងទីទាំងពួងដោយប្រការណា គប្បីឱ្យដោយប្រការនោះ ។

បទថា និទ្ធាបេតព្វំ : ត្រូវជម្រះស្មៅ គឺ គប្បីជម្រះស្មៅ ។

---

១. ថៃ. អនុសិស្សាមិ ។

ពីរបទថា កុសិកា ឧទ្ធរាបេតព្វា : ត្រូវជជុះយកចំបើង មានសេចក្ដីថា ធញ្ញជាតិ ដែលលាយនឹងចំបើងល្អិត គប្បីនាំចេញអំពីចំបើង ។

បទថា ឱជុណាបេតព្វំ : ត្រូវជជុះយកកំទេចចេញ មានសេចក្ដីថា គប្បីរោយឱ្យកំទេចស្មៅ និងកំទេចចំបើងចេញ ។

ពាក្យថា តេនហិ ត្វញ្ញេវ ឃរាវាសត្ថេន ឧបជានាហិ : បើដូច្នោះអនុជឯង ចូរជ្រាបអំពីប្រយោជន៍របស់ឃរាវាសចុះ មានសេចក្ដីថា អ្នកនុ៎ះឯង គប្បីជ្រាបដើម្បីការគ្រប់គ្រងផ្ទះ ។

[៤] ក្នុងពាក្យថា អហំ តយា យថាសុខំ បព្វជាហិ : បព្វជ្ជានោះលើកទុកទៅចុះ ខ្ញុំគង់តែនឹងបួសជាមួយនឹងអ្នកតាមសប្បាយដែរ នេះ គប្បីជ្រាបដូច្នេះ ៖

អនុរុទ្ធសក្យ: ជាអ្នកប្រាថ្នាដើម្បីពោលដោយរហ័សក្នុងភាពជាសម្លាញ់ថា "យើងជាមួយអ្នក នឹងបួស", ជាអ្នកមានហឫទ័យ ត្រូវសេចក្ដីលោភក្នុងសិរីរាជសម្បត្តិទាក់ទាញចិត្តទុកទៀត ពោលបានត្រឹមតែថា "យើងនឹងអ្នក"ប៉ុណ្ណោះ ហើយមិនអាចពោលពាក្យដ៏សេស ។

[៦] បទថា និប្បាតិតា : អ្នកនេះហើយជាអ្នកសម្លាប់ មានសេចក្ដីថា កុមារទាំងឡាយ ដែលឧបាលីនេះឱ្យចេញទៅហើយ ។

[៧] បទថា មានសម្បិនោ : តែងមានមានះ មានសេចក្តីថា ពួកខ្ញុំព្រះអង្គ ជាអ្នកដែលមានះអាស្រ័យហើយ, មានពាក្យអធិប្បាយថា ពួកខ្ញុំព្រះអង្គជាអ្នកមាននូវមានះ ។

[១០] ក្នុងបទថា បរទត្តុបជីវិនោ : ចិញ្ចឹមជីវិតដោយចតុប្បច្ច័យដែលបុគ្គលដទៃឱ្យនេះ មានសេចក្តីថា ឈ្មោះថា អ្នកប្រព្រឹត្តទៅដោយបច្ច័យដែលជនដទៃឱ្យ ព្រោះជាអ្នកចិញ្ចឹម ជីវិតដោយបច្ច័យដែលអ្នកដទៃឱ្យ ។

[១១] បាទនៃគាថាថា យស្សន្តរតោ[១] ន សន្តិ កោបា : សេចក្តីក្រោធមិនមានក្នុងចិត្តរបស់អ្នកណា មានសេចក្តីថា កិលេសជាគ្រឿងញាំងចិត្តទាំងឡាយឱ្យកម្រើក ឈ្មោះថា មិនមានក្នុងចិត្តរបស់អ្នកណា ព្រោះហេតុថា សេចក្តីក្រោធនោះ ជាកិលេសដែលមគ្គទី ៣ ដកចេញហើយ ។

ក៏ព្រោះសម្បត្តិ ឈ្មោះថា ភវៈ, វិបត្តិឈ្មោះថា វិភវៈ, មួយទៀត សេចក្តីចម្រើន ឈ្មោះថា ភវៈ, សេចក្តីសាបសូន្យ ឈ្មោះថា វិភវៈ ។ សេចក្តីទៀង ឈ្មោះថា ភវៈ, សេចក្តីដាច់សូន្យ ឈ្មោះថា វិភវៈ ។ បុណ្យ ឈ្មោះថា ភវៈ, បាបឈ្មោះថា វិភវៈ ។ ពាក្យថា

១. ឆដ្ឋសង្គាយនា. ថៃ. យស្សន្តរតោ ។

វិភវ: និង អភវ: នេះ ជាពាក្យតែមួយដោយសេចក្តីពិត ; ហេតុនោះ ក្នុងបាទនៃគាថាថា ឥតិ ភវាភវតញ្ច វីតិវត្តោ : អ្នកនោះឈ្មោះថា កន្លងផុតនូវសេចក្តីចម្រើននិងសេចក្តីវិនាស ច្រើនប្រការ នេះ គប្បីឃើញសេចក្តីយ៉ាងនេះថា សេចក្តីមាន និងសេចក្តីមិនមាន មានប្រការយ៉ាងនោះ គឺ មានប្រការចំរុះច្រើននោះយ៉ាងណា ដែលព្រះមានព្រះភាគត្រាស់ដោយអំណាចសម្បត្តិ និងវិបត្តិ, សេចក្តីចម្រើននិងសេចក្តីសាបសូន្យ, សេចក្តីទៀង និងសេចក្តីដាច់សូន្យ, បុណ្យ និងបាប អ្នកនោះឈានកន្លងសេចក្តីមាន និងសេចក្តីមិនមាន មានប្រការយ៉ាងនោះ ៗ ដោយន័យនោះ តាមសមគួរដល់ហេតុ ដោយមគ្គសូម្បីទាំង ៤ ។

បទថា នានុភវន្តិ : កម្រទីងបាន មានសេចក្តីថា រមែងមិនអាច, អធិប្បាយថា ការឃើញបុគ្គលនោះ សូម្បីទេវតាទាំងឡាយ ក៏បានដោយលំបាក ។

[១៣] បទថា អហិមេខលិកាយ : ពាក់សង្វារពស់ គឺ ព័ន្ធពស់ទុកត្រង់ចង្កេះ ។

បទថា ឧច្ចង្កេ : លើភ្លៅ បានដល់ លើអវយវ:ទាំងឡាយ ។

[១៦] បទថា សម្មន្នតិ : តែងរាប់អាន បានដល់ កំពុងរាប់អាន ។

ច្រើនបទថា យំ តុមោ ករិស្សតិ : ទឹងធ្វើកម្មណា មាន សេចក្តីថា គេនឹងធ្វើនូវកម្មបែបណា ។

[២៥] ក្នុងពាក្យថា ខេឡាសកស្ស[1] : ដូចជាជុំទឹកមាត់ នេះ មានសេចក្តីថា ទេវទត្តដែលព្រះមានព្រះភាគត្រាស់ថា ជាអ្នកផឹកទឹកមាត់ ព្រោះពាក្យអធិប្បាយថា បច្ច័យដែលកើតឡើងដោយមិច្ឆាជីវៈ ដែលព្រះអរិយទាំងឡាយ គប្បីខាកចេញ ដូចគ្នានឹងទឹកមាត់, ទេវទត្តនេះ រមែងលេបនូវបច្ច័យបែបនោះ ។

[៣៣] ពីរបទថា បត្ថុទ្ធេន កាយេន : ឈរគាំងខ្លួន មាន សេចក្តីថា មានកាយរឹងស្តូកដូចស្លឹករឹត ។

[៤១] ទេវទត្ត កាលលើកខ្លួនឯងដោយសភាពដែលជាព្រះញាតិ របស់ព្រះរាជាថា "ព្រះរាជាទ្រង់ស្គាល់យើង" ទើបពោលថា "មយំ ខោ ភណេ រាជញាតកា ឆាម : យើងនេះ ជាព្រះញាតិនឹងស្តេច" ។

បទថា បហដ្ឋកណ្ណវាលោ : សម្រឹងត្រចៀកនិងកន្ទុយ មាន សេចក្តីថា ដំរីនាឡាគិរីធ្វើត្រចៀកទាំង ២ ឱ្យឈប់ស្ងៀម ។

[៤៣] បាទគាថាថា ទុក្ខំ ហិ កុញ្ជរ ឆាគមាសទោ : ម្នាល កុញ្ជរ ព្រោះថា អ្នកប៉ុនប៉ងសម្លាប់ព្រះពុទ្ធនាគជាហេតុឱ្យកើតទុក្ខ មាន

១. ថៃ. ខេឡសកោ ។

សេចក្តីថា កុញ្ជរដ៏ចម្រើន ឈ្មោះថា ការចូលជិតព្រះពុទ្ធដ៏ប្រសើរ ទ្រង់មិនត្រេកអរដោយចិត្តគិតសម្លាប់ជាទុក្ខ ។

បទថា នាគហតស្ស : **អ្នកប៉ុនប៉ងសម្លាប់ព្រះពុទ្ធនាគ** មានសេចក្តីថា សុគតិរបស់បុគ្គលដែលសម្លាប់ព្រះពុទ្ធដ៏ប្រសើរ រមែងមិនមាន ។

[៤៤] ពីរបទថា បដិកុដិតោ[១] បដិសក្កិ : **អន្ទញជើងមុខថយក្រោយ** មានសេចក្តីថា ដំរីនាឡាគិរី បែរមុខទៅរកព្រះតថាគតហើយ លុតជង្គង់ចុះដោយជើងមុខទាំង ២ ។

[៤៥] ក្នុងបទថា អលក្ខិកោ : **ជាអ្នកឥតគ្រឿងកំណត់** នេះ មានសេចក្តី ថា ទេវទត្តនេះ រមែងមិនកំណត់ ។ អធិប្បាយថា រមែងមិនដឹង ព្រោះដូច្នោះ ទើបឈ្មោះថា **អលក្ខិកៈ** អ្នកឥតបុណ្យកំណត់ ។ ទេវទត្ត រមែងមិនដឹងថា "យើងធ្វើកម្មដ៏លាមកទេ" ។ ទេវទត្តនោះ អ្នកណា ៗ មិនគប្បីកំណត់ចំណាំបាន អធិប្បាយថា អ្នកណា ៗ មិនគប្បីឃើញ ព្រោះដូច្នោះ ទើបឈ្មោះថា ជាបុគ្គល ដែលមិនមានអ្នកណា ៗ កំណត់បាន (ថា "លាមកត្រឹមណា") ។

[៤៦] ក្នុងបទថា តិកភោជនំ : **ភោជនល្មម ៣ រូប** នេះ

១. ថៃ. ភូមា. បដិកុដិយោវ; ឱ.ម. បដិកុដិយោ ។

មានសេចក្តីថា ភោជនដែលជន ៣ នាក់ គប្បីបរិភោគ ។

ពីរបទថា បញ្ញាបេសុញ្ញាមិ[១] : តថាគតនឹងអនុញ្ញាត មានសេចក្តីថា តថាគតនឹងអនុញ្ញាតតិកភោជននោះ ។ តែក្នុងគណភោជន ភិក្ខុត្រូវធ្វើតាមធម៌ ។

[៥០] បទថា កប្បំ : កប្ប បានដល់ មួយអាយុកប្ប[២] ។

បទថា ព្រហ្មបុញ្ញំ : នូវបុណ្យដ៏ប្រសើរ បានដល់ បុណ្យដ៏ប្រសើរបំផុត ។

ពីរបទថា កប្បំ សគ្គម្ហិ : ក្នុងឋានសួគ៌, ១ កប្ប បានដល់ មួយអាយុកប្បនុ៎ះឯង ។

[៥៤] ច្រើនបទថា អជ ខោ ធេវទត្តោ សង្ឃំ ភិន្ទិត្វា : លំដាប់នោះ ទេវទត្តបំបែកសង្ឃហើយ មានសេចក្តីថា បានឮថា ទេវទត្តនោះ កាលឱ្យចាប់ស្លាកយ៉ាងនោះហើយ ធ្វើឧបោសថមួយផ្នែក ក្នុងក្រុងរាជគ្រឹះនោះឯងហើយទើបទៅ, ដោយហេតុនោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ទើបពោលពាក្យនេះថា អជ ខោ ធេវទត្តោ : លំដាប់នោះ ទេវទត្ត ជាដើម ។

---

១. ថៃ. តំ បញ្ញាបេស្សាមិ ។ ២. តាមកំណត់អាយុក្នុងអវិចីតាំងពីធ្លាក់ដល់ជិតឆេះផែនដី ។

[៥៧] ត្រើនបទថា បិដ្ឋិ មេ អាគិលាយតិ : ត្បិតខ្នងខ្ញុំឈឺណាស់ មានសេចក្ដីថា ខ្នងរបស់យើង រមែងនឿយហត់ ព្រោះមានវេទនាខ្លាំងក្លា ដោយការអង្គុយយូរ ។

ត្រើនបទថា តមហំ អាយមិស្សាមិ : ខ្ញុំនឹងសម្រាកបន្តិច មានសេចក្ដីថា យើងនឹងទម្រេតខ្នងនោះ ។

ការដឹងចិត្តរបស់អ្នកដទៃយ៉ាងនេះថា "ចិត្តរបស់អ្នកយ៉ាងនេះខ្លះ ចិត្តរបស់អ្នកយ៉ាងនោះខ្លះ" ដូច្នេះ ហើយសម្ដែងធម៌ល្មមសមគួរដល់ចិត្តរបស់អ្នកដទៃនោះ ឈ្មោះថា អាទេសនាបាដិហារ្យ និងអនុសាសនីបាដិហារ្យ ។

[៦០] បទថា មមានុកុព្ពំ : ធ្វើតាមតថាគត មានសេចក្ដីថា កាលធ្វើកិរិយា ត្រាប់តាមតថាគត ។

បទថា គរុបណេណា : ដល់សេចក្ដីលំបាក សេចក្ដីថា ដល់ទុក្ខហើយ ។

[៦១] បទថា មហាវរាហស្ស : កាលដំរីធំរក្សាហ្វូង សេចក្ដីថា កាលស្ដេចដំរី ។

បទថា មហឹ វិកុព្ពតោ : គាស់រំលើងផែនដី សេចក្ដីថា ទំលាយផែនដី ។

ពីរបទថា ភិសំ ឃសានស្ស[1] : ទំពារស៊ីក្រអៅ សេចក្ដីថា ខាំស៊ីនូវក្រអៅឈូក ឬមើមឈូក ។

ក្នុងពាក្យថា ឆទីសុ ជគ្គតោ : ក្នុងស្រះនទី នេះ មានសេចក្ដីថា បានឮថា ស្ដេចដំរីនោះ កាលចុះកាន់ស្រះបោក្ខរណី ដែលមាននាមថា នទីនោះ លេងនៅក្នុងវេលាល្ងាច ឈ្មោះថា ញ៉ាំងរាត្រីទាំងពួងឱ្យកន្លងទៅ គឺ ធ្វើភាពជាអ្នកភ្ញាក់ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "នទីសុ ជគ្គតោ : លេងនៅក្នុងស្រះទឹក ឈ្មោះថា នទី" ។

## អង្គនៃទូតជាដើម

[៦៣] បទថា សោតា[2] : ជាអ្នកស្ដាប់បានដោយខ្លួនឯង បានដល់ អ្នកស្ដាប់ ។

[៦៤] បាទគាថាថា អសន្ទិទ្ធោ ច អក្ខាតិ : មិនប្រាប់ឱ្យប្រឡំពាក្យ មានសេចក្ដីថា ជាអ្នកមិនមានសេចក្ដីសង្ស័យប្រាប់ឱ្យដឹង គឺ អ្នកប្រាប់ប្រកបដោយអំណាចនៃពាក្យដែលបន្តគ្នាតាមលំដាប់ ។

១. ឆដ្ឋភូមា. ឃសមានស្ស ។ ២. ថៃថា. សុតា ។

[៦៥] ទេវទត្តនឹងកើតក្នុងអបាយ ព្រោះដូច្នោះ ទើបឈ្មោះថា ជាអ្នកទៅកើតក្នុងអបាយ ។ ទៅកើតក្នុងនរក ក៏ដូចគ្នា ។ ទេវទត្តនឹងរស់នៅក្នុងនរកអស់ ១ កប្ប ព្រោះដូច្នោះ ទើបឈ្មោះថា ឋិតនៅអស់មួយកប្ប ។

[៦៦] ឥឡូវនេះ ទេវទត្ត សូម្បីព្រះពុទ្ធទាំងពាន់អង្គ ក៏មិនអាចកែខ្វនបាន ព្រោះដូច្នោះ លោកទើបឈ្មោះថា អតេកិច្ឆោ : កែខ្វនលែងបាន ឬថា ជាបុគ្គលដែលព្រះពុទ្ធមិនអាចជួយកែបាន ។

[៦៧] ច្រើនបទថា មា ជាតុ កោចិ លោកស្មឹ : បុគ្គលឯណាមួយ ... កុំ ( កើត ) ក្នុងលោកឡើយ មានសេចក្ដីថា សូម្បីក្នុងកាលណា ៗ សត្វណាមួយ កុំ ( កើត ) ក្នុងលោកឡើយ ។

បទថា ឧបបជ្ជថ[១] : សូមកើត បានដល់ ចូរកើតឡើង ។

បាទគាថាថា ជលំ វ[២] យសសា អដ្ឋា : ទេវទត្តហាក់ដូចជារុងរឿង ដោយយសបិតនៅ មានសេចក្ដីថា ទេវទត្តតាំងនៅដូចជាអ្នករុងរឿងដោយយស ។

---

១. ឱ. ឧទបជ្ជថ ។ ២. ឆដ្ឋសង្គាយនា. ថៃ. ជលំវ ។

បាទគាថាថា ទេវទត្តោតិ មេ សុតំ : តថាគតបានឮថា ទេវទត្ត មានសេចក្តីថា សូម្បីពាក្យដែលព្រះមានព្រះភាគ ទ្រង់ស្តាប់ហើយថា “ទេវទត្ត ដូច្នេះ” ក៏មាននៅ, ពាក្យថា ទេវទត្តហាក់ដូចជាកាលរុងរឿង ដោយយសឋិតនៅ នេះ ព្រះធម្មសង្គាហកាចារ្យ ពោលសំដៅយកពាក្យ ដែលព្រះមានព្រះភាគទ្រង់ស្តាប់ហើយនុ៎ះឯង ។

ក្នុងពាក្យថា សោ បមាទំ អនុចិណ្ណោ : ទេវទត្តនោះ តែង សន្សំសេចក្តីប្រមាទរឿយ ៗ នេះ មានសេចក្តីថា ទេវទត្តនោះ រមែង សន្សំសេចក្តីប្រមាទ ព្រោះដូច្នោះ លោកទើបឈ្មោះថា អ្នក សន្សំរឿយ ៗ អធិប្បាយថា សេចក្តីប្រមាទដែលលោកមិនលះចេញ ។

ពីរបទថា អាសជ្ជ នំ : ហើយបៀតបៀនតថាគតនោះ មាន សេចក្តីថា ដល់ហើយ ឬថា បៀតបៀនព្រះតថាគតនោះ ដោយចិត្ត លាមក ។

ចំណែកពាក្យថា អវីចិនិរយំ បត្តោ : ធ្លាក់ទៅរងទុក្ខក្នុង អវីចិនរក នេះ ជាពាក្យពោលសេចក្តីដែលកន្លងទៅហើយ ប្រព្រឹត្តទៅ ក្នុងសេចក្តីប្រាថ្នា ។

បទថា ភេស្មា : គួរឱ្យសឥប់សែឥង គឺ នាំភ័យមក ។

# សង្ឃរាជី

[៦៨] ពាក្យថា ឯកតោ ឧបាលិ ឯកោ : ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាងមួយរូប មានសេចក្តីថា ក្នុងចំណែកធម្មវាទីមានតែមួយរូប ។

ពាក្យថា ឯកតោ ទ្វេ : ម្ខាងពីររូប សេចក្តីថា ក្នុងចំណែកអធម្មវាទី មាន ២ រូប ។

ពាក្យថា ចតុត្ថោ អនុស្សាវេតិ សលាកំ គាហេតិ : ឯភិក្ខុគម្រប់ ៤ សូធ្យឱ្យភិក្ខុចាប់ស្លាក មានសេចក្តីថា អធម្មវាទីជាគម្រប់ ៤ គិតថា "យើងនឹងទម្លាយសង្ឃ" ។

បទថា អនុស្សាវេតិ : សូធ្យ សេចក្តីថា ប្រកាសឱ្យអ្នកដទៃយល់ព្រមទទួលដឹង ។ អធិប្បាយថា លោកប្រកាសភេទករវត្ថុ ១៨ ប្រការយ៉ាងនេះថា "ភិក្ខុក្នុងធម្មវិន័យនេះ រមែងសម្តែងធម៌ថា ធម៌" ដូច្នេះ ដោយន័យជាដើមថា "ទាំងពួកលោក ទាំងពួកយើងមិនមានសេចក្តីខ្លាចចំពោះនរកឡើយ មកនៃអវិចី សូម្បីពួកយើងក៏មិនបានបិទបាំងទុក ពួកយើងមិនខ្លាចចំពោះអកុសល បើថា វត្ថុនេះ គប្បីជាសភាពមិនមែនធម៌ ឬវត្ថុនេះ គប្បីជាសភាពមិនមែនវិន័យ ឬថា វត្ថុនេះមិនគប្បីជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ; យើងទាំងឡាយ មិនគប្បីកាន់យក" ។

ពាក្យថា សលាកំ គាហេតិ : ឱ្យភិក្ខុចាប់ស្លាក មានសេចក្តីថា

ក៏កាលប្រកាសយ៉ាងនេះហើយ ទើបប្រាប់ឱ្យចាប់ស្លាកថា "លោកទាំងឡាយចូរចាប់ស្លាកនេះ, លោកទាំងឡាយចូរពេញចិត្តស្លាកនេះ" ។

សូម្បីក្នុងបទទាំងឡាយថា ឯកតោ ឧបាលិ ទ្វេ ហោន្តិ : ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាងពីររូប ជាដើម ក៏មានន័យដូចគ្នា ។

ពាក្យថា ឯវម្បិ ខោ ឧបាលិ សង្ឃរាជិ ចេវ ហោតិ សង្ឃភេទោ ច : ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថា សេចក្តីប្រេះឆានៃសង្ឃ មិនមែនជាសង្ឃភេទ មានសេចក្តីថា ការប្រេះឆានៃសង្ឃផង សេចក្តីបែកនៃសង្ឃផង រមែងមានដោយហេតុត្រឹមតែឱ្យចាប់ស្លាកយ៉ាងនេះ, ក៏ប៉ុន្តែថា សង្ឃនឹងជាអ្នកបែកគ្នាហើយ ដោយហេតុត្រឹមតែប៉ុណ្ណេះក៏ទេ ។

ក្នុងពាក្យនេះថា "ម្នាលឧបាលិ លុះតែភិក្ខុដែលមានខ្លួនជាប្រក្រតីមានសំវាសស្មើគ្នា ឋិតនៅក្នុងសីមាជាមួយគ្នា ទើបឈ្មោះថា បំបែកសង្ឃ"[១] ដូច្នេះ គប្បីមានពាក្យសួរថា កាលបើដូច្នោះ ភិក្ខុទេវទត្ត ឈ្មោះថាបកតត្តយ៉ាងណា ភិក្ខុទេវទត្តមិនមែនជាបកតត្តទៅហើយ ព្រោះលោកឱ្យសម្លាប់ព្រះរាជា និងព្រោះលោកធ្វើលោហិតុប្បាទ យ៉ាងណា ?

ខ្ញុំព្រះករុណាសូមពោលក្នុងពាក្យសួរនេះថា ការឱ្យសម្លាប់ព្រះរាជា

១. វិន. ចុល្ល. សង្ឃភេទក្ខន្ធកៈ. ១១. ៦៨/៧៨ ។

ឈ្មោះថា មិនមាន ព្រោះពាក្យបង្គាប់បញ្ជាខុសសង្កេតហើយ, ពិតមែន ពាក្យបង្គាប់បញ្ជារបស់ភិក្ខុទេវទត្តនោះយ៉ាងនេះថា “កុមារ បើដូច្នោះ អ្នកចូរសម្លាប់ព្រះបិតាហើយជាព្រះរាជាចុះ, អាត្មានឹងសម្លាប់ព្រះមានព្រះភាគហើយជាព្រះពុទ្ធ”, តែកុមារជាព្រះរាជាហើយ ទើបញ៉ាំងព្រះបិតាឱ្យអស់ជីវិតជាខាងក្រោយ ; ការឱ្យសម្លាប់ព្រះរាជា ឈ្មោះថា មិនមាន ព្រោះពាក្យបង្គាប់បញ្ជាខុសសង្កេត ដោយប្រការដូច្នេះ ។

ចំណែកភាពជាអភព្វបុគ្គល ដែលមានលោហិតុប្បាទជាបច្ច័យ ព្រះមានព្រះភាគមិនបានត្រាស់ហើយ ក្នុងកាលលោហិតុប្បាទ លុះភិក្ខុទេវទត្តធ្វើហើយប៉ុណ្ណោះ សភាពដែលភិក្ខុទេវទត្តនោះ ជាអភព្វបុគ្គល វៀរពាក្យរបស់ព្រះមានព្រះភាគចេញហើយ អ្នកណា ៗ ក៏មិនអាចនឹងលើកឡើងបាន ។ ចំណែកពាក្យថា “លោហិតុប្បាទកោ ភិក្ខវេ អនុបសម្បន្នោ ន ឧបសម្បាទេតព្វោ ឧបសម្បន្នោ នាសេតព្វោ : ម្នាលភិក្ខុទាំងឡាយ មនុស្សដែលធ្វើលោហិតុប្បាទ (ធ្វើព្រះលោហិតឱ្យពួរពងឡើង) ជាឧបសម្បន្នមិនបានទេ សង្ឃមិនគប្បីឱ្យឧបសម្បទា ឡើយ, បើជាឧបសម្បន្នហើយ សង្ឃគប្បីឱ្យវិនាសចេញ”[១] នេះ ព្រះមានព្រះភាគត្រាស់ខាងក្រោយអំពីសង្ឃភេទ ; ព្រោះហេតុនោះ សង្ឃឈ្មោះថាដែលភិក្ខុទេវទត្តជាបកតត្តទំលាយហើយ ។

១. វិន. មហា. មហាខន្ធកៈ. ៦. ១៣១/២៩៣ ។

## ភេទករវត្ថុ ១៨ ប្រការ

[៦៩] វិនិច្ឆ័យក្នុងភេទករវត្ថុ ១៨ ប្រការ មានពាក្យថា សម្តែងអធម៌ថា ធម៌ ជាដើម ។

ដោយសុត្តន្តបរិយាយមុន ៗ កុសលកម្មបថ ១០ ឈ្មោះថា ធម៌, អកុសលធម៌បថ ១០ ឈ្មោះថា អធម៌ ។

មួយទៀត ពោធិបក្ខិយធម៌ ៣៧ ប្រការ គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គ មានអង្គ ៨ ឈ្មោះថា ធម៌ ។ ពាក្យនេះ គឺ សតិប្បដ្ឋាន ៣ សម្មប្បធាន ៣ ឥទ្ធិបាត ៣ ឥន្ទ្រិយ ៦ ពលៈ ៦ ពោជ្ឈង្គ ៨ មគ្គមានអង្គ ៩ ឈ្មោះថា អធម៌ ។

ម្យ៉ាងទៀត ពាក្យនេះ គឺ ឧបាទាន៤ នីវរណៈ៥ អនុស័យ៧ មិច្ឆត្តៈ៨ ឈ្មោះថា ធម៌ ។ ពាក្យនេះ គឺ ឧបាទាន៣ នីវរណៈ៤ អនុស័យ៦ មិច្ឆត្តៈ៧ ឈ្មោះថា អធម៌ ។

បណ្តាធម៌និងអធម៌នោះ ភិក្ខុទាំងឡាយអ្នកកាន់យកចំណែក គឺអធម៌ម្យ៉ាង យ៉ាងណាមួយ ពោលហើយនូវអធម៌នោះថា "នេះជាធម៌" ដោយធ្វើទុកក្នុងចិត្តថា "យើងនឹងធ្វើអធម៌នេះថា ធម៌ ដោយប្រការយ៉ាងនេះ ត្រកូលនៃអាចារ្យរបស់ពួកយើងនឹងប្រសើរខ្ពង់ខ្ពស់, ពួកយើង

ទីងជាអ្នកមានមុខមាត់ក្នុងលោក” ឈ្មោះថា សម្តែងអធម៌ថា ធម៌, កាល កាន់យកតែមួយចំណែក ក្នុងចំណែកនៃធម៌ទាំងឡាយពោលថា “នេះជា អធម៌” យ៉ាងនោះឯង ឈ្មោះថា សម្តែងធម៌ថា មិនមែនធម៌ ។

ដោយវិន័យបរិយាយ ចំណែកកម្មដែលគប្បីចោទហើយឱ្យរលឹក ហើយធ្វើតាមពាក្យបដិញ្ញា ដោយវត្ថុដែលពិត ឈ្មោះថា ធម៌ ។ កម្ម ដែលមិនចោទ មិនរំលឹកសិន មិនធ្វើតាមពាក្យប្តេជ្ញា ដោយវត្ថុមិនពិត ឈ្មោះថា អធម៌ ។

ដោយសុត្តន្តបរិយាយ ពាក្យនេះ គឺ រាគវិន័យ ទោសវិន័យ មោហវិន័យ សំវរៈ បហានៈ ការពិចារណា ឈ្មោះថា វិន័យ ។ ពាក្យ នេះ គឺ ការមិនកម្ចាត់កិលេស មានរាគៈជាដើម ការមិនសង្រួម ការមិន លះបង់ ការមិនពិចារណា ឈ្មោះថា អវិន័យ ។

ដោយវិន័យបរិយាយ ពាក្យនេះ គឺ វត្ថុសម្បត្តិ ញត្តិសម្បត្តិ អនុស្សាវនាសម្បត្តិ សីមាសម្បត្តិ បរិសសម្បត្តិ ឈ្មោះថា វិន័យ ។ ពាក្យនេះ គឺ វត្ថុវិបត្តិ ។ល។ បរិសវិបត្តិ ឈ្មោះថា អវិន័យ ។

ដោយសុត្តន្តបរិយាយ ពាក្យនេះថា សតិប្បដ្ឋាន ៤ ។ល។ អរិយមគ្គមានអង្គ ៨ ឈ្មោះថា ព្រះតថាគតទ្រង់ត្រាស់ហើយ ។ ពាក្យ នេះថា សតិប្បដ្ឋាន ៣ ។ល។ មគ្គមានអង្គ ៩ ឈ្មោះថា ព្រះ តថាគតទ្រង់មិនត្រាស់ហើយ ។

ដោយវិន័យបរិយាយ ពាក្យនេះថា បារាជិក៤ សង្ឃាទិសេស១៣ អនិយត២ និស្សគ្គិយបាចិត្តិយ៣០ ឈ្មោះថា ព្រះតថាគតទ្រង់ត្រាស់ហើយ ។ ពាក្យនេះ ថា បារាជិក៣ សង្ឃាទិសេស១៤ អនិយត៣ និស្សគ្គិយ បាចិត្តិយ៣១ ឈ្មោះថា ព្រះតថាគតទ្រង់មិនត្រាស់ហើយ ។

ដោយសុត្តន្តបរិយាយ ពាក្យនេះ គឺ ការចូលផលសមាបត្តិ ការចូលមហាករុណាសមាបត្តិ ការសម្លឹងមើលសត្វលោកដោយពុទ្ធចក្ខុរាល់ថ្ងៃ ការសម្តែងសុត្តន្ត: ការត្រាស់ជាតក ជាប់ដោយសេចក្តីកើតរឿងឡើង ឈ្មោះថា **តថាគតធ្លាប់សន្សំមក** ។ ពាក្យនេះ គឺ ការមិនចូលផលសមាបត្តិរាល់ថ្ងៃ ។ល ។ ការមិនត្រាស់ជាតក ឈ្មោះថា **តថាគតមិនធ្លាប់សន្សំមក** ។

ដោយវិន័យបរិយាយ ប្រការនេះ គឺ ការនៅចាំវស្សាហើយពោលលាហើយ ទើបជៀសទៅកាន់ទីចារិករបស់ភិក្ខុដែលទទួលនិមន្តហើយ ការបវារណាហើយ ទើបជៀសទៅកាន់ទីចារិកការ ធ្វើការទទួលជាមួយភិក្ខុអាគន្តុក: ឈ្មោះថា **តថាគតធ្លាប់សន្សំមក** ។ ការមិនធ្វើកិច្ចមានមិនពោលលាមុនត្រាច់ទៅកាន់ទីចារិកនោះឯង ឈ្មោះថា **តថាគតមិនធ្លាប់សន្សំមក** ។

ដោយសុត្តន្តបរិយាយ ពាក្យនេះ គឺ សតិប្បដ្ឋាន៤ ។ល ។ អរិយមគ្គមានអង្គ៨ ឈ្មោះថា ព្រះតថាគតទ្រង់បញ្ញត្តិហើយ ។ ពាក្យ

នេះ គឺ សតិប្បដ្ឋាន៣ ។ល ។ មគ្គមានអង្គ៩ ឈ្មោះថា ព្រះតថាគតទ្រង់មិនបញ្ញត្តិហើយ ។

ដោយវិន័យបរិយាយ ពាក្យនេះថា បារាជិក៤ សង្ឃាទិសេស១៣ អនិយត២ និស្សគ្គិយបាចិត្តិយ៣០ ឈ្មោះថា ព្រះតថាគតទ្រង់បញ្ញត្តិហើយ ។ ពាក្យនេះថា បារាជិក៣ សង្ឃាទិសេស១៤ អនិយត៣ និស្សគ្គិយ បាចិត្តិយ៣១ ឈ្មោះថា ព្រះតថាគតទ្រង់មិនបញ្ញត្តិហើយ ។

អនាបត្តិដែលព្រះតថាគត ត្រាស់ហើយក្នុងសិក្ខាបទនោះ ៗ ថា "មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនដឹង អ្នកមិនមានថេយ្យចិត្ត អ្នកមិនប្រាថ្នានឹងឱ្យស្លាប់ អ្នកមិនប្រាថ្នានឹងអួត អ្នកមិនប្រាថ្នានឹងបញ្ចេញ" ឈ្មោះថា អនាបត្តិ ; អាបត្តិដែលព្រះតថាគតត្រាស់ហើយដោយន័យជាដើមថា "ជាអាបត្តិដល់ភិក្ខុដែលដឹង អ្នកមានថេយ្យចិត្ត" ឈ្មោះថា អាបត្តិ ។ អាបត្តិ ៥ កង ឈ្មោះថា អាបត្តិស្រាល ។ អាបត្តិ ២ កង ឈ្មោះថា អាបត្តិធ្ងន់ ។ អាបត្តិ ៦ កង ឈ្មោះថា អាបត្តិមានចំណែកដ៏សេស ។ កងអាបត្តិបារាជិកតែមួយ ឈ្មោះថា អាបត្តិមិនមានចំណែកដ៏សេស ។ អាបត្តិ ២ កង ឈ្មោះថា អាបត្តិអាក្រក់ ។ អាបត្តិ ៥ កង ឈ្មោះថា អាបត្តិមិនអាក្រក់ ។

ក៏ក្នុងធម៌ និងអធម៌ជាដើម ដែលពោលហើយដោយវិន័យបរិយាយនេះ ភិក្ខុដែលពោលនូវធម៌មានប្រការដូចពោលហើយថា "នេះ

មិនមែនធម៌” ដោយន័យមុននុ៎ះឯង ឈ្មោះថា សម្តែងធម៌ថា “មិនមែនធម៌” ។

កាលពោលនូវខដែលមិនមែនវិន័យថា “នេះជាវិន័យ” ឈ្មោះថា សម្តែងពាក្យដែលមិនមែនវិន័យថា “វិន័យ” ។ល ។ កាលពោលនូវអាបត្តិមិនអាក្រក់ថា “នេះជាអាបត្តិអាក្រក់” ឈ្មោះថា សម្តែងអាបត្តិមិនអាក្រក់ថា “អាបត្តិអាក្រក់” ។

កាលសម្តែងធម៌ថា “ជាធម៌” ។ល ។ ឬកាលសម្តែងអាបត្តិមិនអាក្រក់ថា “អាបត្តិអាក្រក់” យ៉ាងនោះឯង បានពួកហើយធ្វើសង្ឃកម្ម ៤ យ៉ាងណាមួយ ជាផ្នែក ក្នុងសីមាជាមួយគ្នា សង្ឃឈ្មោះថា ជាការដែលភិក្ខុទាំងនោះទំលាយហើយ ។

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “តេ ឥមេហិ អដ្ឋារសហិ វត្ថូហិ អបកស្សន្តិ : ភិក្ខុទាំងនោះ ក៏ទង់ទាញគៀរគរ (បរិស័ទ) ដោយ(ភេទករ)វត្ថុ ១៨ ប្រការនេះឯង” ជាដើម ។

បណ្តាបទទាំងនោះ បទថា អបកស្សន្តិ : ទង់ទាញ មានសេចក្តីថា រមែងដណ្តើម គឺ រមែងបែងចែកនូវបរិស័ទ បានដល់ រមែងកាត់បរិស័ទឱ្យក្រោកទៅអន្តយក្នុងចំណែកម្ខាង ។

បទថា អវបកាសន្តិ : គៀរគរយក មានសេចក្តីថា រមែងញុះ

ញ្ញន់យ៉ាងក្រៃលែង គឺ ភិក្ខុទាំងឡាយ នឹងជាអ្នកមិនសម្រេះសម្រួលគ្នា ដោយប្រការណា រមែងធ្វើដោយប្រការនោះ ។

បទថា **អាវេណិកំ :** ផ្សេងគ្នា គឺ មួយផ្នែក ។

ពាក្យថា **ឯត្តាវតា ខោ ឧបាលិ សង្ឃោ ភិន្នោ ហោតិ :** ម្នាលឧបាលិ សង្ឃដែលបែកធ្លាយ ដោយហេតុប៉ុណ្ណោះឯង មានសេចក្តីថា សូម្បីកាលភិក្ខុទាំងឡាយ សម្តែងវត្ថុយ៉ាងណាមួយ ក្នុងភេទករវត្ថុ ១៨ ហើយឱ្យភិក្ខុទាំងឡាយ សម្គាល់ដឹងដោយហេតុនោះ ៗ ថា "លោកទាំងឡាយ ចូរចាប់ស្លាកនេះ, លោកទាំងឡាយចូរគាប់ចិត្តស្លាកនេះ" ដូច្នេះ ឱ្យចាប់ស្លាក ហើយធ្វើសង្ឃកម្មផ្នែកមួយ យ៉ាងនោះហើយ សង្ឃ ឈ្មោះថា បែកគ្នា ។ ចំណែកក្នុងគម្ពីរបរិវារព្រះមានព្រះភាគត្រាស់ថា "ម្នាលឧបាលី សង្ឃបែកគ្នាដោយអាការ ៥"[1] ជាដើម ។

ពាក្យនោះនឹងលក្ខណៈនៃសង្ឃភេទនេះ ដែលត្រាស់ក្នុងសង្ឃភេទក្ខន្ធកៈនេះ ដោយសេចក្តីមិនមានសេចក្តីផ្សេងគ្នា ។ ហើយខ្ញុំព្រះករុណានឹងប្រកាសសេចក្តីផ្សេងគ្នា នៃពាក្យនោះ ក្នុងគម្ពីរបរិវារនោះឯង ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

**សង្ឃភេទក្ខន្ធកវណ្ណនា ចប់**

១. វិន. បរិ. ឧបាលិបញ្ចក. ១៣. ២៩៥/៣៣៦ ។

# ១៨. វត្តក្ខន្ធកវណ្ណនា

វិនិច្ឆ័យក្នុងវត្តក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

[៧៩] ព្រះមានព្រះភាគ ទ្រង់សម្តែងទីជិតឧបចារៈសីមា ដោយព្រះពុទ្ធវចនៈនេះថា "អញនឹងចូលទៅកាន់អារាម ក្នុងកាលឥឡូវនេះ"; ព្រោះដូច្នោះ ភិក្ខុដល់ឧបចារៈសីមាហើយ គប្បីធ្វើគារវកិច្ចទាំងពួង មានដោះស្បែកជើងជាដើម ។

បទថា គហេត្វា : កាន់យកទៅ បានដល់ កាន់យកឈើប្រត់និងស្បែកជើងទៅ ។

បទថា បដិក្កមន្តិ : កាលឈានត្រឡប់ បានដល់ សន្និបតន្តិ : ប្រជុំគ្នា ។

ច្រើនបទថា ឧបាហនបុញ្ឆនចោឡកំ[១] បុច្ឆិត្វា ឧបាហនាបុញ្ឆិតព្វា : ត្រូវសួររកកំណាត់សំពត់សម្រាប់ជូតស្បែកជើង រួចជូតស្បែកជើងទាំងឡាយចុះ សេចក្តីថា គប្បីសួរអាវាសិកភិក្ខុទាំងឡាយថា "សំពត់ជូតស្បែកជើងនៅទីណា" ។

បទថា វិស្សជ្ជេតព្វំ : ត្រូវកំណត់ទុកក្នុងចិត្ត គឺ គប្បីរំពឹងទុក ។

---

១. ថៃ. ...ចោឡន្តំ ។

ពាក្យថា គោចរោ បុច្ឆិតព្វោ : ត្រូវសួររកគោចរគ្រាម មានសេចក្តីថា គប្បីសួរដល់ទីត្រាច់ចរ ដើម្បីភិក្ខាយ៉ាងនេះថា "គោចរគ្រាមនៅជិតឬឆ្ងាយ" ។ ភិក្ខុគប្បីត្រាច់ទៅបិណ្ឌបាតក្នុងពេលព្រឹកឬពេលថ្ងៃដូច្នេះ ។ ស្រុករបស់ពួក មិច្ឆាទិដ្ឋិក្តី ស្រុកដែលមានភិក្ខាគេកំណត់ទុកក្តី ឈ្មោះថា **អគោចរ** ។

ភិក្ខាក្នុងស្រុកណា គេប្រគេនដល់ភិក្ខុមួយរូប ឬ ២ រូប, ស្រុកសូម្បីនោះ ក៏គួរសួរ ។

ច្រើនបទថា ឋានីយំ បុច្ឆិតព្វំ, បរិភោជនីយំ បុច្ឆិតព្វំ : ត្រូវសួររកទឹកសម្រាប់ឆាន់ ត្រូវសួររកទឹកសម្រាប់ប្រើប្រាស់[១] មានសេចក្តីថា គប្បីសួរដល់ទឹកឆាន់និងទឹកប្រើប្រាស់យ៉ាងនេះថា "ភិក្ខុទាំងឡាយ រមែងឆាន់ទឹកដែលគួរឆាន់ក្នុងស្រះនេះ ទាំងធ្វើការប្រើប្រាស់ មានផ្ងូតជាដើមផងឬ ?" សត្វកាច ឬពួកអមនុស្ស រមែងមានក្នុងទឹកខ្លែងខ្លះ; ព្រោះដូច្នោះ ទើបគួរសួរថា "គួរចូលទៅវេលាណា ? គួរចេញមកវេលាណា ?"

ពីរបទថា ពហិ ឋិតេន : ហើយឈរខាងក្រៅ មានសេចក្តីថា ឃើញមករបស់ពស់ ឬរបស់អមនុស្សកំពុងចេញទៅ គប្បីឈរមើលនៅខាងក្រៅ ។

---

១. ក្នុងបិដកបាត់ពាក្យប្រែនេះ ។

ច្រើនបទថា សចេ ឧស្សហតិ សោធេតព្វោ : បើអាគន្តុកភិក្ខុអាច ត្រូវសំអាតចេញ មានសេចក្តីថា បើថា ខ្លួនអាច, គប្បីជម្រះវិហារទាំងអស់ឱ្យស្អាត, កាលមិនអាច គប្បីចាត់ចែងឱកាសជាទីនៅរបស់ខ្លួន ។

ក៏ឯក្នុងទំនៀមនៃការជម្រះវិហារឱ្យស្អាត ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ សម្រាប់ភិក្ខុដែលអាចជម្រះវិហារទាំងអស់ឱ្យស្អាត គប្បីជ្រាបវិនិច្ឆ័យ តាមន័យដែលពោលហើយ ក្នុងមហាខន្ធកៈនុ៎ះឯង ។

## អាវាសិកវត្ត

[៨១] វិនិច្ឆ័យក្នុងអាវាសិកវត្ត គប្បីជ្រាបដូច្នេះ ៖

កាលអាគន្តុកៈអ្នកចាស់ជាងមក គប្បីវៀរចីវរកម្ម ឬ នវកម្មចេញ ធ្វើកិច្ចទាំងពួង មានជាដើមយ៉ាងនេះថា ត្រូវក្រាលអាសនៈ ដូច្នេះ កំពុងបោសលានចេតិយ គប្បីទុកដាក់អំបោស ផ្តើមធ្វើវត្តដល់លោក ។

បើថា អាគន្តុកៈជាអ្នកឆ្លាត, លោកពោលថា "ចូរបោសលានចេតិយជាមុនចុះ អ្នកមានអាយុ" ។

មួយទៀត កំពុងធ្វើថ្នាំដើម្បីអ្នកជម្ងឺ បើថា អ្នកជម្ងឺមិនធ្ងន់ទេ, គប្បីវៀរទុកធ្វើវត្តជាមុនសិន, តែសម្រាប់ជម្ងឺធ្ងន់ ត្រូវធ្វើថ្នាំមុន បើអាគន្តុកៈជាអ្នកឆ្លាត, លោកពោលថា "ចូរធ្វើថ្នាំជាមុន" ។

កាលសួរដល់ទឹកឆាន់ បើថា អាគន្តុកៈផឹកទឹកដែលនាំមក ហើយម្តងអស់, គប្បីសួរលោកថា "ខ្ញុំព្រះករុណានឹងត្រូវនាំមកទៀតទេ" ?

មួយទៀត គប្បីបក់ផ្លិតដល់លោក ។ កាលបក់ គប្បីបក់ត្រង់ខ្នងជើងម្តង កណ្តាលខ្លួនម្តង សីសៈម្តង ។ កាលលោកពោលថា "ល្មមហើយ ឈប់ចុះ" គប្បីបក់ឱ្យតិចចុះ ។

កាលលោកពោលថា "ល្មមប៉ុណ្ណឹងហើយ" គប្បីបក់ឱ្យតិចចុះជាងនោះ ។ លោកពោលដល់គ្រាទី ៣ គប្បីដាក់ផ្លិតចុះ ។ គប្បីលាងជើងរបស់លោក ។ គ្រាលាងហើយ បើប្រេងរបស់ខ្លួនមាន, គប្បីលាបដោយប្រេង ។ បើមិនមាន, គប្បីលាបដោយប្រេងរបស់លោក ។ ចំណែកការជូតស្បែកជើង គប្បីធ្វើតាមសេចក្តីពេញចិត្តរបស់ខ្លួន ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា "**សចេ ឧស្សហតិ :** បើអាវាសិកភិក្ខុមានសេចក្តីឧស្សាហ៍" ។ ព្រោះហេតុនោះ ទើបមិនត្រូវអាបត្តិ សូម្បីដល់ភិក្ខុដែលមិនជូតស្បែកជើង ។

បើលោកសួរថា "សេនាសនៈត្រូវបានដល់យើងនៅទីណា ?" គប្បីចាត់ចែង សេនាសនៈ អធិប្បាយថា គប្បីប្រាប់យ៉ាងនេះថា "សេនាសនៈនេះត្រូវបានដល់លោកម្ចាស់" ដូច្នេះ ។ សមពិតដែលនឹងត្រូវប្រាប់ជាមុនសិន សីមក្រោល ។

វិនិច្ឆ័យក្នុងវត្តរបស់អាគន្តុកៈជានវកៈ គប្បីជ្រាបដូច្នេះ ៖

ពាក្យថា **ធានីយំ អាចិក្ខិតព្វំ** : ត្រូវប្រាប់ទឹកសម្រាប់ឆាន់ មានសេចក្ដីថា អាវាសិកភិក្ខុ គប្បីប្រាប់ថា "សូមលោកម្ចាស់កាន់យកទឹកនោះឆាន់" ដូច្នេះ ។ សូម្បីក្នុងទឹកប្រើប្រាស់ ក៏មានន័យដូចគ្នា ។ ពាក្យដ៏សេសដូចពាក្យមុននុ៎ះឯង ។

ពិតមែន អាវាសិកភិក្ខុមិនធ្វើវត្តដល់អាគន្តុកៈ ដែលមកដល់វិហាររបស់ខ្លួន សូម្បីក្នុងអាវាសធំ រមែងមិនបាន ។

## គមិកវត្ត

[៨២] វិនិច្ឆ័យក្នុងគមិកវត្ត គប្បីជ្រាបដូច្នេះ ៖

បទថា **ធារុភណ្ឌំ** : គ្រឿងឈើ បានដល់ គ្រែនិងតាំងជាដើម ដែលពោលហើយក្នុងសេនាសនក្ខន្ធកៈ ។ សូម្បីភណ្ឌៈដី ក៏បានដល់ ភាជនៈសម្រាប់ជ្រលក់ជាដើម ភណ្ឌៈទាំងពួង មានប្រភេទដូចពោលហើយក្នុងសេនាសនក្ខន្ធកៈនុ៎ះឯង ។

ភណ្ឌៈទាំងពួងនោះ ដែលភិក្ខុត្រៀមនឹងទៅ គប្បីរក្សាទុកត្រង់រោងភ្លើង ឬក្នុងទីណាមួយដែលថែរក្សាបានហើយទើបទៅ ។ គប្បីរក្សា

ទុកក្នុងញកភ្នំ ដែលភ្លៀងមិនសាចទឹក ក៏គួរ ។

[៨៣] វិនិច្ឆ័យក្នុងពាក្យថា សេនាសនំ អាបុច្ឆិតព្វំ[១] : អើពើនឹងសេនាសនៈ នេះ គប្បីជ្រាបដូច្នេះ ៖

សេនាសនៈណា សាងទុកលើថ្មដា ឬលើសសរថ្ម, កណ្ដៀរទាំងឡាយ ឡើងមិនបានក្នុងសេនាសនៈណា, មិនត្រូវអាបត្តិ សូម្បីដល់ភិក្ខុមិនប្រាប់ដល់ភិក្ខុអ្នកប្រគល់សេនាសនៈនោះ ។

ពាក្យថា ចតូសុ បាសាណកេសុ : លើថ្មតូច ៤ ដុំ ជាដើម ព្រះមានព្រះភាគត្រាស់ដើម្បីសម្ដែងអាការៈដែលគប្បីធ្វើ ក្នុងសេនាសនៈមានបណ្ណសាលាជាដើម ដែលជាស្ថានទីកើតនៃកណ្ដៀរទាំងឡាយ ។

ពាក្យនេះថា អបេយ្យំ ឆាម អដ្ឋានិបិ សេសេយ្យុំ : ធ្វើម្ដេចនឹងឱ្យ អវយវៈ (របស់គ្រែនិងតាំង)ទាំងឡាយ សល់នៅបានដូច្នេះ ជាអានិសង្សក្នុងសេនាសនៈដែលតាំងទុកកណ្ដាលវាល ។

ចំណែកក្នុងផ្ទះដែលភ្លៀងសាចស្រោចបាន កាលស្មៅនិងដុំដីធ្លាក់ចុះខាងលើ (នៃគ្រែនិងតាំង) សូម្បីចំណែកទាំងឡាយ នៃគ្រែនិងតាំងរមែងវិនាសទៅ ។

---

១. ឱ. អាបុច្ឆា បក្កមិតព្វំ ។

# អនុមោទនាវត្ត

វិនិច្ឆ័យក្នុងអនុមោទនាវត្ត គប្បីជ្រាបដូច្នេះ ៖

[៨៦] ពីរបទថា ឥទ្ធំ អហោសិ : ចុះមានបរិបូណ៌ទេឬ មានសេចក្ដីថា ភត្តបានជារបស់ដល់ព្រមហើយ ។

ពាក្យថា ចតូហិ បញ្ចហិ : បួនប្រាំរូប មានសេចក្ដីថា កាលព្រះសង្ឃត្ថេរៈ អង្គុយហើយដើម្បីត្រូវការនឹងអនុមោទនា ភិក្ខុ ៤ រូប គប្បីអង្គុយតាមលំដាប់ខាងចុង ។ កាលព្រះអនុត្ថេរៈអង្គុយហើយ ព្រះមហាត្ថេរៈគប្បីអង្គុយ និងភិក្ខុ ៣ រូប គប្បីអង្គុយខាងចុង ។ កាលភិក្ខុរូបទី ៥ អង្គុយហើយ ភិក្ខុ ៤ រូប គប្បីអង្គុយខាងលើ ។ កាលភិក្ខុកម្លោះខាងចុង ដែលព្រះសង្ឃត្ថេរៈសូម្បីនិមន្តហើយ ភិក្ខុ ៤ រូប គប្បីអង្គុយតាំងពីព្រះសង្ឃត្ថេរៈចុះមកតែម្ដង ។

ក៏បើថា ភិក្ខុដែលអនុមោទនាពោលថា "ទៅចុះ លោកម្ចាស់ដ៏ចម្រើន មិនមានកិច្ចដែលនឹងត្រូវនៅចាំ" ដូច្នេះ គួរទៅ ។ កាលព្រះមហាត្ថេរៈពោលថា "អ្នកមានអាយុ ពួកយើងនឹងទៅ" លោកពោលថា "និមន្តទៅចុះ", សូម្បីយ៉ាងនេះ ក៏គួរទៅ ។

ព្រះមហាត្ថេរៈសូម្បីធ្វើសេចក្ដីចងចិត្តថា "ពួកយើងនឹងចាំនៅក្រៅស្រុក" ដូច្នេះ ទៅដល់ក្រៅស្រុកហើយ សូម្បីបន្ទាប់និស្សិតរបស់ខ្លួនថា

"លោកទាំងឡាយ ចូរផ្សំបាំភិក្ខុនោះមកដល់" ដូច្នេះ ហើយបេញទៅ គួរដូចគ្នា ។

តែបើអ្នកស្រុកឱ្យភិក្ខុមួយរូប ដែលខ្វះពេញចិត្ត ធ្វើការអនុមោទនា មិនជាអាបត្តិដល់ភិក្ខុអ្នកអនុមោទនានោះទេ, ព្រោះមិនជាភារៈដល់ព្រះមហាថេរៈ ។

ពិតមែន ព្រោះក្នុងឧបនិសិន្នកថា ត្រូវប្រាប់ព្រះថេរៈជាមុន ក្នុងកាលជនទាំងឡាយសូមឱ្យពោល ។ ចំណែកភិក្ខុដែលព្រះមហាថេរៈនិមន្តដើម្បីអនុមោទនាជំនួស ភិក្ខុទាំងឡាយត្រូវនៅចាំ ។ នេះជាលក្ខណៈក្នុងរឿងអនុមោទនានេះ ។

[៨៧] បទថា វច្ចិតោ : **ឈឺបន្ទោបង់** មានសេចក្តីថា ព្រះថេរៈឈឺបន្ទោបង់ឧច្ចារៈ, អធិប្បាយថា អ្នកដែលឧច្ចារៈបៀតបៀនហើយ ។

## ភត្តគ្គវត្ត

វិនិច្ឆ័យក្នុងភត្តគ្គវត្ត គប្បីជ្រាបដូច្នេះ ៖

[៨៩] ក្នុងអដ្ឋកថាទាំងឡាយពោលថា ទោះជាក្នុងចន្លោះស្រុក ឬក្នុងវត្តក៏ដោយ, ការដែលភិក្ខុទៅកាន់ទីអង្គៀសរបស់ជនទាំងឡាយដណ្តប់ចីវរចងកាយពន្ធន៍ះឯង សមគួរ ។

ច្រើនបទថា ន ថេរេ ភិក្ខូ អនូបខជ្ជ : មិនប្រៀតបៀតពួកភិក្ខុជាថេរៈ មានសេចក្តីថា មិនគប្បីអង្គុយជ្រៀតបៀតភិក្ខុដែលជាថេរៈទេ, បើថា អាសនៈស្មើនឹងអាសនៈដែលព្រះមហាថេរៈអង្គុយ, កាលអាសនៈមានច្រើន គប្បីអង្គុយវៀរទុក ១ ឬ ២ អាសនៈ មិនគប្បីអង្គុយលើអាសនៈ ដែលគេរាប់ភិក្ខុចាត់ចែងទុក, ព្រះមហាថេរៈបង្គាប់ថា "ចូរអង្គុយចុះ" គប្បីអង្គុយ ។ បើព្រះមហាថេរៈមិនបង្គាប់, គប្បីប្រាប់ថា "អាសនៈនេះខ្ពស់ លោកម្ចាស់" កាលលោកប្រាប់ថា "លោកចូរអង្គុយចុះ" គប្បីអង្គុយ, ក៏បើថា កាលភិក្ខុថ្មី សូម្បីប្រាប់ហើយយ៉ាងនោះ ព្រះមហាថេរៈមិនអនុញ្ញាត, មិនជាអាបត្តិដល់លោកដែលអង្គុយ ។ ជាអាបត្តិដល់ព្រះមហាថេរៈប៉ុណ្ណោះ ។ ពិតមែន ភិក្ខុថ្មីមិនប្រាប់ជាមុន អង្គុយលើអាសនៈបែបនោះ រមែងត្រូវអាបត្តិ, ដូចព្រះថេរៈដែលភិក្ខុថ្មីប្រាប់ហើយ មិនអនុញ្ញាតដូច្នោះ ។

ច្រើនបទថា ន សង្ឃាដឹ ឱត្ថរិត្វា : មិនត្រូវអង្គុយសង្កត់សង្ឃាដិ មានសេចក្តីថា មិនគប្បីក្រាលសង្ឃាដិហើយអង្គុយសង្កត់ ។

ពាក្យថា ឧភោហិ ហត្ថេហិ : ដោយដៃទាំងពីរ ព្រះមានព្រះភាគត្រាស់សំដៅយកទឹកសម្រាប់លាងបាត្រ ចំណែកទឹកទក្ខិណោទក គប្បីដាក់បាត្រលើជើងខាងមុខហើយ សឹមទទួល ។

បទថា សាធុកំ : ឱ្យស្រួល បានដល់ មិនធ្វើឱ្យមានសំឡេងទឹក ។

ពីរបទថា សូបស្ស ឱកាសោ : ទីឱកាសដាក់សម្លបានផង មានសេចក្តីថា ឱកាសនៃសម្លរនឹងមានយ៉ាងណា គប្បីទទួលបាយល្មមប្រមាណយ៉ាងនោះ ។

ពាក្យថា សមកំ សម្បាទេហិ : ចូរអ្នកចាត់ចែងដល់ភិក្ខុគ្រប់រូបឱ្យបានស្មើ ៗគ្នា នេះ ដែលព្រះថេរៈ គប្បីពោលក្នុងទឹកដោះថ្លាជាដើមតែម្យ៉ាងក៏ទេ, សូម្បីក្នុងបាយ ក៏គប្បីពោល ។

ក៏បណ្តាភេសជ្ជៈមានទឹកដោះថ្លាជាដើម វត្ថុណាមានតិច, វត្ថុនោះសមគួរដល់ភិក្ខុមួយរូប ឬ ២ រូប, កាលព្រះថេរៈពោលថា "លោកចូរឱ្យដល់ភិក្ខុទាំងអស់ស្មើ ៗគ្នា" សេចក្តីស្រេកឃ្លាន រមែងមានដល់ពួកអ្នកស្រេក ព្រោះដូច្នោះ របស់យ៉ាងនោះ គប្បីទទួលម្តង ឬ ២ ដងហើយ វត្ថុដ៏សេស មិនគួរទទួល ។

ពាក្យថា ន តាវ ថេរេន ភុញ្ជិតព្វំ : ភិក្ខុជាថេរៈមិនគប្បីឆាន់ត្រឹមនោះ នេះ ព្រះមានព្រះភាគត្រាស់សំដៅយករោងឆាន់ដែលមានភិក្ខុដែលទាយកកំណត់ទុក ( និង ) រោងឆាន់ដែលមនុស្សទាំងឡាយ ជាអ្នកប្រាថ្នានឹងឱ្យអាហារដល់ភិក្ខុគ្រប់រូប ហើយថ្វាយបង្គំ ។

ចំណែករោងឆាន់ណា ជារោងធំ, គឺ ក្នុងរោងឆាន់ណា ភិក្ខុទាំងឡាយឆាន់នៅក្នុងប្រទេសមួយ, ទាយកប្រគេនទឹកក្នុងប្រទេសមួយ, ក្នុងរោងឆាន់នោះ គប្បីឆាន់តាមសប្បាយ ។

ពាក្យថា **ន តាវ ថេរេន ឧទកំ : ភិក្ខុជាថេរៈមិនគប្បីទទួលយកទឹកត្រឹមនោះ** នេះ ព្រះមានព្រះភាគត្រាស់សំដៅយកទឹកលាងដៃ, ចំណែកភិក្ខុដែលមានសេចក្តីក្តៅក្រហាយក្នុងចន្លោះ ឬអ្នកមានអាមិសជាប់ក (អួល) គប្បីឆាន់ទឹក មិនគប្បីលាងដៃ ។

បើថា ជនទាំងឡាយពោលថា "ទិមន្តលាងបាត្រនិងដៃចុះលោកម្ចាស់ដ៏ចម្រើន" ឬភិក្ខុទាំងឡាយពោលថា "សូមលោកម្ចាស់ទទួលទឹកចុះ", ព្រះថេរៈ គួរលាងដៃ ។

ពាក្យថា **និវត្តន្តេន : កាលបើត្រឡប់វិញ** ព្រះមានព្រះភាគទ្រង់សម្តែងថា "សង្ឃកាលទឹងក្រោកឡើងត្រឡប់អំពីរោងភត្ត គប្បីត្រឡប់យ៉ាងនេះ" ។ យ៉ាងណា ? គប្បីឃើញពាក្យទាំងពួងថា នវកេហិ ជាដើម ។

ពិតមែន ក្នុងផ្ទះទាំងឡាយដែលចង្អៀត មិនមានឱកាសដែលព្រះថេរៈទាំងឡាយចេញ ; ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនោះ ។

ក៏នវកភិក្ខុទាំងឡាយ អ្នកត្រឡប់យ៉ាងនោះ ចាំនៅត្រង់ទ្វារផ្ទះ គប្បីទៅតាមលំដាប់គ្នាបាន ក្នុងកាលព្រះថេរៈទាំងឡាយ ចេញហើយ ។

បើថា ព្រះមហាថេរៈទាំងឡាយ អង្គុយនៅឆ្ងាយ ពួកភិក្ខុនវកៈអង្គុយនៅខាងក្នុងផ្ទះ, គប្បីចេញមកតាមលំដាប់តាំងពីថេរាសនៈចុះមកតែម្តង កុំឱ្យកាយនិងកាយបៀតបៀនគ្នា ដើរជាជួរឆ្ងាយ ៗ ឱ្យជនទាំងឡាយអាចទៅក្នុងចន្លោះបាន ។

## បិណ្ឌចារិកវត្ត

[៩១] វិនិច្ឆ័យក្នុងបិណ្ឌចារិកវត្ត គប្បីជ្រាបដូច្នេះ ៖

ពាក្យថា កម្មំ វា និក្ខិបន្តិ : គេបញ្ឈប់ការងារក្តី មានសេចក្តីថា ជនទាំងឡាយកន់វត្ថុណាជាកប្បាស ឬចង្អេរ ឬអង្រែ កំពុងធ្វើការ ជាអ្នកឈរក៏ដោយ អង្គុយក៏ដោយ, ដាក់វត្ថុនោះចេញ ។

ពាក្យថា ន ច ភិក្ខាទាយិកាយ មុខំ ឱលោកេតព្វំ : កុំសម្លឹងមើលមុខស្រីដែលប្រគេន មានសេចក្តីថា អ្នកប្រគេនភិក្ខា ជាស្ត្រីក៏ដោយ បុរសក៏ដោយ ក្នុងវេលាប្រគេនភិក្ខា ភិក្ខុមិនគប្បីមើលមុខ (គេ) ។

# អារញ្ញកវត្ត

[៩៣] វិនិច្ឆ័យក្នុងអារញ្ញកវត្ត គប្បីជ្រាបដូច្នេះ ៖

ពីរបទថា សេនាសនា ឱតរិតព្វំ : រួចហើយចុះពីសេនាសនៈ មានសេចក្តីថា គប្បីចេញចាកទីលំនៅ ។

ក្នុងពាក្យថា បត្តំ ថវិកាយ បក្ខិបិត្វា : ហើយប្រកបបាត្រក្នុងស្លោក នេះ មានវិនិច្ឆ័យថា ប្រសិនបើខាងក្រៅស្រុកមិនមានទឹក, គប្បីធ្វើភត្តកិច្ចខាងក្នុងស្រុកនុ៎ះឯង, បើថា ខាងក្រៅស្រុកមានទឹក, គប្បីធ្វើភត្តកិច្ច ខាងក្រៅស្រុកហើយលាងបាត្រ ធ្វើឱ្យស្ងួតទឹកហើយដាក់ស្លោក ។

ពាក្យថា បរិភោជនីយំ ឧបដ្ឋាបេតព្វំ : ត្រូវដងទឹកសម្រាប់ប្រើប្រាស់ទុក មានសេចក្តីថា បើភាជនៈទាំងឡាយមិនល្មមសោត, គប្បីត្រៀមទឹកឆាន់នុ៎ះឯងទុក ធ្វើឱ្យជាទឹកប្រើផង ។ កាលមិនបានភាជនៈ គប្បីយាំងទុកក្នុងបំពង់ឫស្សីក៏បាន ។ ភិក្ខុដែលមិនបាន សូម្បីនូវបំពង់ឫស្សីនោះ គប្បីធ្វើឱ្យមានអណ្តូងទឹកនៅក្នុងទីជិត ។ កាលឈើពួតភ្លើងមិនមាន សូម្បីមិនបង្កាត់ភ្លើងក៏គួរ ។ ដូចយ៉ាងភិក្ខុដែលនៅព្រៃ គប្បីត្រូវការឈើពួតភ្លើងយ៉ាងណា, សូម្បីភិក្ខុដែលធ្វើដំណើរតាមមកកន្តារក៏គប្បីត្រូវការឈើពួតភ្លើង ដូច្នោះ តែសម្រាប់ភិក្ខុដែលនៅក្នុងពួក ការនៅ សូម្បីវៀរចាកឈើពួតភ្លើងនោះ ក៏គួរ ។

ផ្កាយនក្ខត្តឫក្សទាំងឡាយនុ៎ះឯង ឈ្មោះថា នក្ខត្តបទានិ ។

# សេនាសនវត្ត

[៩៥] វិនិច្ឆ័យក្នុងសេនាសនវត្ត គប្បីជ្រាបដូច្នេះ ៖

ធម្មតាទ្វារជាមកដែលប្រើច្រើន ព្រោះដូច្នោះ មិនមានកិច្ចដែលនឹងត្រូវប្រាប់សម្រាប់ទ្វារ, ចំណែកកិច្ចដ៏សេសជាដើមថា បង្រៀនបាលី (គឺបិដក) ត្រូវប្រាប់ជាមុនសិន សឹមធ្វើ, សមគួរប្រាប់រាល់ថ្ងៃ ។

សូម្បីបើថា កាលនវកភិក្ខុពោលថា "លោកម្ចាស់ដ៏ចម្រើន ចំពោះកិច្ចដែលខ្ញុំព្រះករុណាត្រូវប្រាប់ ចូរជាការប្រាប់ចុះ" ភិក្ខុចាស់ជាងទទួលថា "ល្អណាស់" ឬភិក្ខុដែលចាស់ជាង ប្រាប់ដោយខ្លួនឯងថា "លោកចូរនៅតាមសប្បាយចុះ" ; សូម្បីយ៉ាងនេះ នឹងមិនប្រាប់ក៏បាន ។ សូម្បីដោយសេចក្តីស្និទ្ធស្នាល នឹងមិនប្រាប់ដល់ភិក្ខុដែលសភាគគ្នា គួរដូចគ្នា ។

ពាក្យថា យេន វុឌ្ឍោ តេន បរិវត្តិតព្វំ : **ភិក្ខុចាស់ចង្រ្កមតាមមកណា ភិក្ខុខ្ទីត្រូវដើរចៀសពីមកនោះ** មានសេចក្តីថា ត្រង់ចំពីមុខភិក្ខុចាស់ គប្បីចៀសចេញទៅ ។ សូម្បីក្នុងភោជនសាលាជាដើម គប្បីបដិបត្តិយ៉ាងនេះដូចគ្នា ។

# ជន្តាឃរវត្ត

[៩៧] វិនិច្ឆ័យក្នុងជន្តាឃរវត្ត គប្បីជ្រាបដូច្នេះ ៖

ពាក្យថា បរិភណ្ឌំ នោះ បានដល់ ភនខាងក្រៅ ។

# និទាននៃវច្ចកុដិវត្ត រឿងទឹកជម្រះ

[៩៨] វិនិច្ឆ័យក្នុងរឿងទឹកជម្រះ គប្បីជ្រាបដូច្នេះ ៖

ក្នុងពាក្យថា សតិ ឧទកេ នេះ មានវិនិច្ឆ័យថា បើមានទឹក តែមិនមានទីកំបាំង, គប្បីប្រើភាជនៈដួសទៅជម្រះ ។ កាលមិនមានភាជនៈ គប្បីយកបាត្រដួសទៅ ។ សូម្បីបាត្រក៏មិនមាន ក៏ឈ្មោះថា មិនមានភាជនៈ ។ ភិក្ខុដែលទៅដោយធ្វើទុកក្នុងចិត្តថា "ទីនេះស្រឡះពេកណាស់ ខាងមុខនឹងមានទឹកដទៃ" មិនទាន់បានទឹកវេលាភិក្ខាចារ, គប្បីជូតដោយឈើ ឬរបស់យ៉ាងណាមួយ ហើយសឹមទៅ ។ ភិក្ខុនោះ ឆាន់ក្តី ធ្វើអនុមោទនាក្តី រមែងគួរ ។

[៩៩] បទថា អាគតបដិបាដិយា : តាមលំដាប់ដែលមកដល់ មានសេចក្តីថា លំដាប់នៃអ្នកមកប៉ុណ្ណោះ ជាប្រមាណ ក្នុងស្ថានទាំង ៣ គឺ វច្ចកុដិ ទីបន្ទោបង់បស្សាវៈ កំពង់ទឹក ។

# វច្ចកុដិវត្ត

វិនិច្ឆ័យក្នុងវច្ចកុដិវត្ត គប្បីជ្រាបដូច្នេះ ៖

[១០១] ពាក្យថា មិនគប្បីទំពារឈើស្ទន់បណ្ដើរ បន្ទោបង់ឧច្ចារៈបណ្ដើរ នេះជាការហាមក្នុងទីទាំងពួងតែម្ដង ទាំងវច្ចកុដិ ទាំងមិនមែនវច្ចកុដិ ។

ពាក្យថា ន ផរុសេន កដ្ឋេន អវលេខិតព្វំ : **មិនត្រូវកិតដោយឈើគ្រោតគ្រាត** មានសេចក្ដីថា មិនគួរជូតដោយ ឈើដែលពុះ ឬឈើដែលមុត ឬឈើមានពកឬឈើមានបន្លា ឬ ឈើមានដំបៅ ឬ ឈើពុកផុយ ។ តែមិនជាអាបត្តិដល់ភិក្ខុដែលមិនកាន់ឈើជម្រះចូលទៅ ។

ពាក្យថា ន អាចមនសរាវកេ ឧទកំ សេសេតព្វំ : **មិនត្រូវទុកទឹកឱ្យសល់នៅក្នុងភាជន៍សម្រាប់ជម្រះ** នេះ ព្រះមានព្រះភាគត្រាស់សំដៅយកឋានដែលទូទៅដល់ភិក្ខុទាំងពួង ។

ពិតមែន ភិក្ខុដទៃ ៗ រមែងមកកាន់ទីសាធារណឋាននោះ, ព្រោះដូច្នោះ ទើបមិនគួរបន្សល់ទឹកទុក ។ ចំណែកឋានណា ជាស្ថានទីធ្វើទុកក្នុងឯកទេសក្នុងវត្ត សូម្បីជារបស់សង្ឃ ដើម្បីត្រូវការទៅបន្ទោបង់ជានិច្ច ឬជាឋានចំណែកបុគ្គល, ក្នុងឋាននោះ នៅបន្សល់ទឹកទុកក្នុងភាជន៍

ជម្រះក៏បាន ។ សូម្បីភិក្ខុដែលឆាន់ថ្នាំបញ្ចុះ ចូលទៅរឿយ ៗ ទឹងបន្សល់ទុក ក៏គួរដូចគ្នា ។

បទថា ឩហតា : ប្រឡាក់ បានដល់ ប្រឡាក់ស្មោកគ្រោក អធិប្បាយថា ខាងក្រៅប្រឡាក់ដោយលាមក ។

បទថា ធោវិតព្វា : ត្រូវលាងចេញ បានដល់ គប្បីនាំទឹកមកលាង ។ ទឹកមាន ភាជនៈមិនមាន, ក៏ឈ្មោះថា មិនមាន ; ភាជនៈមានទឹកមិនមាន, សូម្បីយ៉ាងនេះ ក៏ឈ្មោះថា មិនមាន ; កាលមិនមានទាំង២យ៉ាង, ឈ្មោះថា មិនមានពិត ។ គប្បីជូតដោយឈើ ឬដោយរបស់យ៉ាងណាមួយ ហើយសឹមទៅ ពាក្យដ៏សេសគ្រប់ស្ថានងាយយល់ទាំងអស់ ដូច្នេះឯង ។

## វត្តក្ខន្ធកវណ្ណនា ចប់

## ១៩. បាតិមោក្ខដ្ឋបនក្ខន្ធកវណ្ណនា

វិនិច្ឆ័យក្នុងបាតិមោក្ខដ្ឋបនក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

[១១១] ពីរបទថា **ឧទ្ធស្តំ អរុណំ នន្ទិមុខិយា រត្តិយា :** រាត្រីក៏ប្រាកដដូចជាមានមុខស្រស់ មានសេចក្ដីថា រាត្រីប្រាកដដូចមានមុខដ៏ផ្អែតស្កប់ស្កល់ក្នុងវេលាអរុណរះឡើង ដោយហេតុនោះ ព្រះឧបាលីថេរៈ ទើបពោលថា "រាត្រី ក៏ប្រាកដដូចជាមានមុខស្រស់ហើយ" ។

[១១២] បទថា **អន្តោបូតី :** ស្អុយក្នុងមានសេចក្ដីថា អ្នកស្អុយខាងក្នុងដោយភាពជាអ្នកស្អុយ ព្រោះកិលេសខាងក្នុងសន្ដានចិត្ត ។

បទថា **អវស្សុតំ :** មានចិត្តជោគដោយរាគៈ មានសេចក្ដីថា អ្នកជោគហើយដោយអំណាចនៃសេចក្ដីអាក្រក់នៃកិលេស ។

បទថា **កសម្ពុជាតំ :** កខ្វក់ដូចសម្រាម មានសេចក្ដីថា ឈ្មោះថា អ្នកសៅហ្មង ព្រោះជាអ្នកមានទោសពាសពេញ ។

ដោយពាក្យថា **យាវ ពាហាគហណាបិ ឆាម :** ជរាបទាល់តែគេចាប់ទាញដៃ ព្រះមានព្រះភាគទ្រង់សម្ដែងព្រះប្រាថ្នាថា "ពិតមែន មោឃបុរសនោះ លុះបានស្ដាប់ពាក្យថា '**អបរិសុទ្ធា អានន្ទ បរិសាតិ :** ម្នាលអានន្ទ បរិស័ទមិនបរិសុទ្ធិទេ' គប្បីជៀសចេញទៅក៏មាន, មោឃបុរសនោះ មិនជៀសទៅដោយពាក្យយ៉ាងនោះ នឹងមកត្រឹមតែចាប់

ដើមដៃប៉ុណ្ណោះ, សេចក្ដីនេះ គួរអស្ចារ្យ" ។

[១១៣] ពាក្យថា ន អាយតកេនេវ បបាតោ ហោតិ : មិនមែនចោតជ្រៅទៅតែម្ដងដូចជាអណ្ដូងទេ មានសេចក្ដីថា មហាសមុទ្រជារបស់ជ្រៅចោតពីដំបូង ក៏ទេ គឺ ជារបស់ជម្រាលជ្រៅទៅតាមលំដាប់ ។

[១១៤] ពាក្យថា ឋិតធម្មោ វេលំ នាតិវត្តតិ : មហាសមុទ្រមានទឹកតាំងនៅជាធម្មតា មានសេចក្ដីថា ទឹកមហាសមុទ្រមិនហៀរប្រាំង គឺ ខណ្ឌដែនជាទីចុះ និងឡើងនៃរលកផ្កាត្រែងទាំងឡាយ ។

[១១៥] ពីរបទថា តីរំ វាហេតិ : បន្សាត់សាកសពស្លាប់ មានសេចក្ដីថា រលកផ្កាត្រែង រមែងបោកឡើងប្រាំង គឺ គរវែងឡើងលើគោក ។

[១២១] បទថា អញ្ញាបដិវេធោ : ការត្រាស់ដឹងព្រះអរហត្តបានដល់ ការដល់ព្រះអរហត្ត ។

[១២៩] ពាក្យថា ឆន្នមតិវស្សតិ : ភិក្ខុត្រូវអាបត្តិហើយ បិទអាបត្តិទុក រមែងត្រូវអាបត្តិថ្មីដទៃ នេះ ព្រះមានព្រះភាគត្រាស់សំដៅយកសេចក្ដីនេះថា កាលត្រូវអាបត្តិហើយបិទបាំងទុក ឈ្មោះថា ត្រូវអាបត្តិថ្មីដទៃ ។

ពាក្យថា វិវដំ នាតិវស្សតិ : ភិក្ខុត្រូវអាបត្តិហើយ បើកអាបត្តិ

មិនត្រូវអាបត្តិដទៃ នេះ ព្រះមានព្រះភាគត្រាស់ សំដៅយកសេចក្តីនេះថា ត្រូវអាបត្តិហើយបើកបង្ហាញចេញ ឈ្មោះថា មិនត្រូវអាបត្តិដទៃ ។

## ការឃាត់បាតិមោក្ខ

[១៣០] វិនិច្ឆ័យក្នុងពាក្យថា ឋបិតំ ហោតិ បាដិមោក្ខំ : សង្ឃឈ្មោះថា បញ្ឈប់បាតិមោក្ខហើយ នេះ គប្បីជ្រាបដូច្នេះ ៖

បាដិមោក្ខដែលឃាត់មុន ឬខាងក្រោយក៏មាន ដែលមិនឃាត់មុន ឬខាងក្រោយក៏មាន, តែបាដិមោក្ខដែលឃាត់ក្នុងខេត្តប៉ុណ្ណោះ ទើបជាការឃាត់, ព្រោះដូច្នោះ បាដិមោក្ខដែលសង្ឃ គប្បីឃាត់ត្រឹម តែការសូត្រ រេ អក្សរក្នុងពាក្យនេះថា សុណាតុ មេ ភន្តេសង្ឃោ អជ្ជុបោសថោ បណ្ណរសោ យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោឧបោសថំ ករេយ្យ នេះឯង ឈ្មោះថា ខេត្ត ។ តែកាលសូត្រ យ អក្សរហើយ ទើបឃាត់ ជាការឃាត់ខាងក្រោយ ។

ពាក្យថា សុណាតុ មេ មិនទាន់បានផ្តើម កាលឃាត់ ជាការឃាត់មុន ។

[១៤៣] ពាក្យថា អមូលិកាយ ទិដ្ឋិវិបត្តិយា បាដិមោក្ខំ ឋបេតិ អកកតាយ : ការបញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តមិនមានមូល

ដែលភិក្ខុមិនបានធ្វើ មានសេចក្តីថា វិបត្តិនោះ ទឹងជាការដែលបុគ្គលនោះធ្វើហើយ ឬមិនបានធ្វើក៏ដោយ, សេចក្តីសម្គាល់របស់ភិក្ខុដែលឃាត់បាដិមោក្ខ រមែងជារបស់មិនមានមូលដោយអំណាចនៃវិបត្តិដែលមិនមានមូល ។

[១៨៩] ពាក្យថា កតាកតាយ : ដែលភិក្ខុធ្វើហើយ និងមិនធ្វើហើយ ដែលព្រះមានព្រះភាគ ត្រាស់រួមទាំង ២ យ៉ាង ទាំងដែលធ្វើ ទាំងដែលមិនធ្វើ ។

[១៥១-២] ពាក្យថា ធម្មិកាំ សាមគ្គឹ ន ឧបេតិ : ភិក្ខុមិនចូលមកព្រមព្រៀងគ្នា ប្រកបដោយធម៌ មានសេចក្តីថា កាលសង្ឃកម្មដែលសង្ឃធ្វើ ភិក្ខុមិនមក មិនប្រគល់ឆន្ទៈ និងនៅក្នុងទីចំពោះមុខជំទាស់ព្រោះភាពជាអ្នកប្រាថ្នានឹងញុំាងកម្មឱ្យកម្រើក, ដោយហេតុនោះលោកទើបត្រូវអាបត្តិទុក្កដ ។ បាដិមោក្ខរបស់ភិក្ខុដែលមានអាបត្តិជាប់ខ្លួននុ៎ះឯង រមែងជាការឃាត់ដោយប្រការដូច្នេះ ។

បទថា បច្ចាទិយតិ : ត្រឡប់សើរើ មានសេចក្តីថា រមែងត្រឡប់កាន់ថា "កម្មត្រូវធ្វើថ្មី" ។

ព្រោះការរុះរើនោះ លោករមែងត្រូវបាចិត្តិយ ។ បាដិមោក្ខរបស់ភិក្ខុដែលមានអាបត្តិជាប់ខ្លួនសូម្បីនោះឯង រមែងជាការឃាត់ ដោយ

ប្រការដូច្នេះ ។

[១៥៣] ក្នុងពាក្យថា យេហិ អាការេហិ លិង្គេហិ យេហិ និមិត្តេហិ : ដោយអាការណា ដោយនិមិត្តណា នេះគប្បីជ្រាប គ្រឿងសំដៅដឹងមានអាការៈជាដើម ក្នុងអង្គទាំងឡាយមានញ៉ាំងមគ្គនឹងមគ្គឱ្យដល់គ្នាជាដើម ។

វត្ថុដែលបានឃើញហើយ និងវត្ថុដែលបានស្តាប់ហើយ ក្នុងពាក្យថា តេន ទិដ្ឋេន តេន សុតេន តាយ បរិសង្កាយ : ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះ នេះ មកហើយក្នុងព្រះបាលីនុ៎ះឯង ។

ក៏បើថា ភិក្ខុគប្បីញ៉ាំងសេចក្តីរង្កៀសឱ្យកើតឡើង ព្រោះវត្ថុដែលបានឃើញ និងបានស្តាប់ហើយទាំងនោះសោត, ពាក្យថា ដោយសេចក្តីរង្កៀសនោះ ព្រះមានព្រះភាគត្រាស់សំដៅយកសេចក្តីរង្កៀសនោះ ។

## អង្គនៃការកាន់យកអធិករណ៍

[១៦៣] ភិក្ខុដែលប្រាថ្នានឹងជម្រះព្រះសាសនាឱ្យហ្មត់ចត់ ទើបកាន់យកអធិករណ៍ណា ដោយខ្លួនឯង, អធិករណ៍នោះ ព្រះឧបាលីថេរៈហៅថា អត្តាទានំ ក្នុងពាក្យថា អត្តាទានំ អាទាតុកាមេន : ភិក្ខុដែលមានប្រាថ្នានឹងកាន់យកនូវអត្តាទាន ។

កាលនេះ គឺ រាជភ័យ ចោរភ័យ ទុព្ភិក្ខភ័យ កាលដែលភ្លៀងជោគជាំ ជាសម័យមិនមែនកាល ក្នុងពាក្យថា អកាលោ ឥមំ អត្តាធានំ អាធាតុំ : ជាកាលមិនទំនងនឹងកាន់យកនូវអត្តាទាននេះទេ នេះ កាលគប្បីឃើញប្លែកគ្នា ។

ពាក្យថា អភូតំ ឥធំ អត្តាធានំ : អត្តាទាននេះមិនពិត មានសេចក្ដីថា អធិករណ៍ នេះមិនមាន, អធិប្បាយថា បើភិក្ខុកាលពិចារណាជ្រាបយ៉ាងនេះថា "អធម៌ យើងថា ជាធម៌", ឬថា "ធម៌ យើងកាន់ថាអធម៌", ឬថា "អវិន័យ យើងកាន់ថា វិន័យ", ឬថា "វិន័យ យើងកាន់ថា អវិន័យ", ឬថា "បុគ្គលទ្រុស្តសីល យើងកាន់ថា បុគ្គលមានសីល" ឬថា "បុគ្គលមានសីល យើងកាន់ថា បុគ្គលទ្រុស្តសីល" ។ អធិករណ៍ដែលពិត គប្បីជ្រាបដោយបរិយាយ ដែលប្លែកគ្នា ។

អធិករណ៍ណា ប្រព្រឹត្តទៅដើម្បីអន្តរាយនៃជីវិត ឬដើម្បីអន្តរាយដល់ព្រហ្មចរិយ អធិករណ៍នេះ ឈ្មោះថា មិនប្រកបដោយប្រយោជន៍ ក្នុងពាក្យថា អនត្ថសញ្ហិតំ ឥធំ អត្តាធានំ : អត្តាទាននេះ មិនប្រកបដោយប្រយោជន៍ នេះ ។ អធិករណ៍ដែលផ្ទុយ(ពីនោះ) ឈ្មោះថា ប្រកបដោយប្រយោជន៍ ។

ពាក្យថា ន លភិស្សាមិ សន្ទិដ្ឋេ សម្ភត្តេ ភិក្ខូ : នឹងមិន

បានពួកភិក្ខុជាមិត្តសម្លាញ់ដែលគ្រាន់តែជួបគ្នា ឬជាមិត្តសម្លាញ់តែងនៅរួមជាមួយគ្នា មានសេចក្ដីថា ពិតណាស់ ក្នុងកាលខ្លះ ភិក្ខុទាំងឡាយគាំទ្របក្ខពួករបស់ខ្លួនបែបនោះ រមែងជាអ្នកដែលលោកមិនអាចបាន ព្រោះភ័យទាំងឡាយមានរាជភ័យជាដើម ។ ព្រះមានព្រះភាគទ្រង់សំដៅយកការមិនបាននោះ ទើបត្រាស់ថា "នឹងមិនបាន" ។ តែក្នុងកាលខ្លះភិក្ខុទាំងឡាយបែបនោះ ជាអ្នកដែលលោកអាចបាន ព្រោះរួចផុតភ័យ និងមានភិក្ខាល្អជាដើម ។ ព្រះមានព្រះភាគទ្រង់សំដៅយកសេចក្ដីបាននោះ ទើបត្រាស់ថា "នឹងបាន" ។ ពាក្យថា ភវិស្សតិ សង្ឃស្ស តតោ និទានំ ភណ្ឌនំ : តែងមានការប្រកួតប្រកាន់ ការឈ្លោះ នឹងកើតមានដល់សង្ឃ មានសេចក្ដីថា ការប្រកួតប្រកាន់ ការឈ្លោះ ការប្រកាន់ខុស ការទាស់ទែង និងការបែកគ្នានៃសង្ឃ នឹងមានដល់សង្ឃ ដូចមានដល់ពួកភិក្ខុក្រុងកោសម្ពី ។

ពាក្យថា បច្ឆាបិ អវិប្បដិសារករំ ភវិស្សតិ : នឹងមិនធ្វើឲ្យកើតសេចក្ដីក្ដៅក្រហាយចិត្តក្នុងកាលជាខាងក្រោយឡើយ មានសេចក្ដីថា ការត្រឡប់មករលឹកដល់អធិករណ៍នោះ ក្នុងកាលខាងក្រោយ មិនធ្វើសេចក្ដីក្ដៅក្រហាយឲ្យកើតឡើង ដូចការត្រឡប់មករលឹករបស់ព្រះមហាកស្សបត្ថេរៈ អ្នកធ្វើបញ្ចសតិកសង្គីតិសង្កត់សង្កិនសុភទ្ទភិក្ខុ ដែលបួស

ក្នុងវ័យចាស់, និងដូចការត្រឡប់មករលឹករបស់ព្រះយស ដែលធ្វើសត្តសតិកសង្គីតិសង្កត់សង្កិននូវពួកភិក្ខុមួយម៉ឺនរូប ព្រោះអធិករណ៍ មានវត្ថុ ១០, និងដូចការត្រឡប់មករលឹករបស់ព្រះមោគ្គល្លីបុត្តតិស្សត្ថេរៈ ដែលធ្វើសហស្សកសង្គីតិ សង្កត់សង្កិននូវពួកភិក្ខុ ៦ ម៉ឺនរូប មិនធ្វើសេចក្តីក្តៅក្រហាយ ឱ្យកើតឡើងក្នុងកាលខាងក្រោយ ដូច្នោះ ។ ទាំងអធិករណ៍ដែលប្រកបដោយអង្គ ៥ យ៉ាងនោះ ដែលភិក្ខុចោទហើយរមែងប្រព្រឹត្តទៅ ដើម្បីព្រះសាសនាដែលជារបស់មានសិរី ហាក់បីដូចព្រះចន្ទ និងព្រះអាទិត្យដែលប្រាសចាកទោស គ្រឿងសៅហ្មង ។

## ធម៌ដែលអ្នកចោទគប្បីពិចារណាចំពោះខ្លួន

[១៦៤] វិនិច្ឆ័យក្នុងពាក្យថា អច្ឆិទ្ទេន អប្បដិមំសេន : មិនធ្លុះធ្លាយ មិនមានទំនងគួរឱ្យគេចាប់ថ្នាក់បាន ជាដើម គប្បីជ្រាបដូច្នេះ ៖

បណ្តាគ្រហស្ថនិងបព្វជិតទាំងឡាយ អ្នកណាម្នាក់ ជាអ្នកដែលបុគ្គលណាប្រហារហើយក្តី វេជ្ជកម្មទាំងឡាយ មានការវះបូសជាដើមដែលបុគ្គលណាធ្វើហើយដល់គ្រហស្ថទាំងឡាយក្តី កាយសមាចាររបស់បុគ្គលនោះធ្លុះធ្លាយ ដូចស្លឹកត្នោត ដែលកណ្តៀរស៊ី និងឈ្មោះថា មានទោសដែលគួរចាប់ថ្នាក់ ព្រោះជារបស់ដែលអាចដើម្បីស្ទាបអង្អែលបាន

គឺ ដើម្បីចាប់ថ្នាក់ក្នុងទីណាមួយបាន ។ កាយសមាចារដែលប្លែកគ្នា គប្បីជ្រាបថា មិនមានប្រយោជន៍ធ្ងះធ្ងាយ មិនមាន ទោសដែលគួរឱ្យគេចាប់ថ្នាក់បាន ។

ចំណែកវចីសមាចារ រមែងធ្ងះធ្ងាយ និងមានទោសគួរចាប់ថ្នាក់ ព្រោះនិយាយកុហក និយាយចាក់ដោត និយាយស៊កសៀត និងចោទអាបត្តិមិនមានមូលជាដើម ។ វចីសមាចារដែលប្លែកគ្នា គប្បីជ្រាបថា មិនមានធ្ងះធ្ងាយ និងមិនមានទោសដែលគួរចាប់ថ្នាក់ ។

[១៦៦] ពាក្យថា មេត្តំ នុ ខោ មេ ចិត្តំ : ចិត្តរបស់អាត្មាអញមានមេត្តាតាំងមាំ មានសេចក្តីថា ចិត្តរបស់យើងមានមេត្តាកាត់កន្លង់ដែលសន្ទុតហើយដោយការដាក់ចិត្តក្នុងកម្មដ្ឋានភាវនា ។

បទថា អនាឃាតំ : មិនមានចង្អៀតចង្អល់ បានដល់ វៀរចាកអាឃាត អធិប្បាយថា ប្រាសចាកអាឃាតដោយអំណាចនៃការគ្របសង្កត់ ។

[១៦៨] ពាក្យថា ឥធំ បនាវុសោ កត្ថ វុត្តំ ភគវតា : ម្នាលអាវុសោ ចុះសិក្ខាបទនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងក្នុងទីណា មានសេចក្តីថា សិក្ខាបទនេះ ព្រះមានព្រះភាគត្រាស់ហើយក្នុងនគរណា ?

# ធម៌ដែលអ្នកចោទគប្បីតាំងមាំក្នុងខ្លួន

[១៦៩] វិនិច្ឆ័យក្នុងពាក្យថា កាលេន វក្ខាមិ : អាត្មាអញនឹងនិយាយត្រូវតាមកាល ជាដើម គប្បីជ្រាបដូច្នេះ ៖

ភិក្ខុមួយរូប កាលញ៉ាំងបុគ្គលម្នាក់ឱ្យធ្វើឱកាសហើយទើបចោទ ឈ្មោះថា ពោលដោយកាល ។ កាលចោទនៅកណ្ដាលសង្ឃ នៅកណ្ដាលគណៈ នៅរោងស្លាកយាគូ រោងវិតក្កៈ មកដែលត្រាច់ភិក្ខា និងនៅរោងឆាន់ជាដើមក្ដី ក្នុងខណៈដែលឧបដ្ឋាកទាំងឡាយ បរិវារណាក្ដី ឈ្មោះថា ពោលដោយមិនមែនកាល ។

កាលពោលដោយពាក្យសច្ចៈ ឈ្មោះថា ពោលដោយពាក្យពិត ។

កាលពោលថា "នែលោកដ៏ចម្រើន នែលោកជាធំ នែលោកអ្នកត្រាច់ក្នុងបរិស័ទ នែលោកជាអ្នកកាន់បង្សុកូល នែលោកធម្មកថិក នេះសមគួរដល់លោក" ឈ្មោះថា ពោលដោយពាក្យគ្រោតគ្រាត ។

តែកាលពោលឱ្យជាពាក្យអាស្រ័យហេតុថា "លោកដ៏ចម្រើន លោកជាអ្នកធំ លោកជាអ្នកត្រាច់ទៅក្នុងបរិស័ទ លោកជាអ្នកកាន់បង្សុកូល លោកជាធម្មកថិក នេះសមគួរដល់ពួកលោក" ឈ្មោះថា ពោលដោយពាក្យពីរោះ ។

កាលពោលឱ្យជាពាក្យអាស្រ័យហេតុ ឈ្មោះថា ពោលដោយពាក្យប្រកបដោយប្រយោជន៍ ។

ពាក្យថា មេត្តចិត្តោ វក្ខាមិ នោ ទោសន្តរោ : **អាត្មាអញនឹងតាំងមេត្តាចិត្តហើយសឹមនិយាយ មិននិយាយទាំងមានទោសចិត្ត** មានសេចក្តីថា យើងនឹងចូលទៅពោលដោយតាំងចិត្តមេត្តា នឹងមិនជាអ្នកពោលដោយចិត្តប្រទូសរ៉ាយ ។

## ធម៌ដែលអ្នកចោទគប្បីពិចារណាក្នុងខ្លួន

[១៧៤] ពីរបទថា អជ្ឈត្តំ មនសិករិត្វា[1] : **ត្រូវធ្វើទុកក្នុងចិត្តនូវធម៌ក្នុងខ្លួនឯងសិន** បានដល់ គប្បីញុំាងសេចក្តីគិតរបស់ខ្លួនឱ្យកើតឡើង ។

បទថា ការុញ្ញតា : **ជាអ្នកមានចិត្តករុណា** នោះ បានដល់ ការមានចិត្តករុណា ។

ព្រះមានព្រះភាគ ទ្រង់សម្តែងករុណានិងធម៌ជាចំណែកខាងដើមនៃករុណា ដោយការមានករុណានេះ ។

---

១. ភូមា. មនសិ ករិត្វា ។

ការប្រាថ្នារកប្រយោជន៍ ឈ្មោះថា ភាពជាអ្នកស្វែងរកប្រយោជន៍ ។

សេចក្តីប្រកបព្រមដោយប្រយោជន៍នោះ ឈ្មោះថា ភាពជាអ្នកអនុគ្រោះ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងមេត្តា និងធម៌ជាចំណែកខាងដើមនៃមេត្តា ដោយភាពជាអ្នកស្វែងរកប្រយោជន៍ និងភាពជាអ្នកអនុគ្រោះសូម្បីទាំង ២ ។

ការឱ្យចេញចាកអាបត្តិហើយ ឱ្យតាំងនៅក្នុងចំណែកនៃអ្នកបរិសុទ្ធិ ឈ្មោះថា ការចេញចាកអាបត្តិ ។

ការចោទហើយឱ្យលើកធ្វើតាមពាក្យប្តេជ្ញា ធ្វើកម្មតាមដែលប្តេជ្ញាយ៉ាងណា ឈ្មោះថា ភាពជាអ្នកធ្វើព្រះវិន័យ ឱ្យជាទីគោរព ។

ពាក្យថា ឥមេ បញ្ច ធម្មេ : ធម៌ ៥ យ៉ាងនេះឯង មានសេចក្តីថា ធម៌ទាំងនេះណា ដែលយើងពោលហើយ ដោយន័យមានពាក្យថា **ការុញ្ញតា** ជាដើម, ភិក្ខុអ្នកចោទ គប្បីពិចារណាធម៌ទាំង ៥ នេះ ខាងក្នុងខ្លួនហើយ ទើបចោទអ្នកដទៃ ដូច្នេះឯង ។

## ធម៌របស់អ្នកត្រូវគេចោទ

[១៧៥] ពាក្យថា សច្ចេ ច អកុប្បេ ច : សេចក្តីពិតត្រង់ ១ សេចក្តីមិនក្រោធ ១ មានសេចក្តីថា អ្នកត្រូវគេចោទ គប្បីតាំងនៅក្នុងពាក្យពិត និងក្នុងភាពជាអ្នកមិនក្រោធ, ពិតមែន អ្នកត្រូវគេចោទត្រូវរាយករណ៍តាមពិត ត្រូវមិនធ្វើអាការក្រោធខឹង ។ អធិប្បាយថា មិនគប្បីក្រោធដោយខ្លួនឯង មិនគប្បីថ្នាំងថ្នាក់ដល់អ្នកដទៃ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

## ឃាតិមោក្ខដ្ឋបនក្ខន្ធកវណ្ណនា ចប់

# ២០. ភិក្ខុនីខន្ធកវណ្ណនា

## គរុធម៌ ៨

វិនិច្ឆ័យក្នុងភិក្ខុនីខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

[១៧៧] សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ឃាត់ថា "កុំឡើយ ព្រះនាងគោតមី ព្រះនាងកុំគប្បីមានព្រះទ័យឱ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ (នោះ) ឡើយ" ។ បរិស័ទរបស់ព្រះពុទ្ធ សូម្បីទាំងពួង រមែងមាន ៤ មិនមែនឬ ?

ឆ្លើយថា បរិស័ទរបស់ព្រះពុទ្ធសូម្បីទាំងពួងមាន ៤ ពិតមែនហើយ, តែថា ព្រះមានព្រះភាគទ្រង់មានព្រះបំណង នឹងញុំាងព្រះនាងមហាបជាបតីគោតមីឱ្យលំបាកហើយ ទើបទ្រង់អនុញ្ញាតធ្វើឱ្យជារបស់សំខាន់ (យ៉ាងនេះ) ថា "ស្ត្រីទាំងឡាយនឹងគិតថា បព្វជ្ជានេះ យើងបានដោយលំបាក" ដូច្នេះ ហើយនឹងរក្សានូវបព្វជ្ជាទុកដោយប្រពៃ ដែលត្រូវព្រះនាងអង្វរហើយច្រើនលើក ទើបអនុញ្ញាត ដូច្នេះ, ទើបទ្រង់ហាមឃាត់ ។

[១៨០] កថា ពោលអំពីគរុធម៌ ៨ បានពោលទុកហើយក្នុង

មហាវិភង្គ[1] ដូច្នេះឯង ។

[១៨២] បទថា កុម្ភជេនកេហិ : លួចដោយក្អមឆ្នាំង បានដល់ ចោរ ដែលអុជប្រទីបក្នុងឆ្នាំងហើយ គន់រកមើលវត្ថុក្នុងផ្ទះរបស់ជនដទៃ ដោយពន្លឺនោះ លួចយកវត្ថុទៅ ។

ពាក្យថា សេតដ្ឋិកា នាម រោគជាតិ : រោគជាតិ ឈ្មោះ **សេតដ្ឋិកា** នោះ បានដល់ ឈ្មោះសត្វ( ក្រារ )មានជីវិតមួយប្រភេទ ។ កួរស្រូវសាលី សូម្បីដុះចេញហើយ មិនអាចចិញ្ចឹមទឹកដោះទុកបាន ព្រោះត្រូវសត្វណាចោះហើយ សត្វនោះ រមែងចោះនូវកួរនៃស្រូវសាលី ដែលនៅក្នុងសំបក ។

ពាក្យថា មញ្ចេដ្ឋិកា[2] នាម រោគជាតិ : រោគជាតិ ឈ្មោះ **មញ្ជេដ្ឋិកា** នោះ បានដល់ អំពៅដែលមានរោគក្រារក្រហម ( ឬដង្កូវក្រា )ខាងក្នុង ។

ក៏ពាក្យថា មហាតោ តឡាកស្ស បដិកច្ចេវ ធាឡឹ : ប្រញាប់លើកទំនប់ទប់ទឹកស្រះដ៏ធំ នេះ ព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនេះថា កាលទំនប់នៃស្រះធំ សូម្បីមិនបានបង្ករហើយ ទឹកតិច

១. សមន្ត. បាចិ. ៤. ២៧/១៦៧ ។ ២. ភូមា. ថៃ. មញ្ជេដ្ឋិកា ; បិដកបាលីជា មញ្ចេដ្ឋិកា ក្លាយជា មញ្ជេដ្ឋិកា ។

តួចគប្បីឋិតនៅបាន, តែកាលបានបង្ករទំនប់ទុកជាមុនហើយ ទឹកណាមិនគប្បីឃាំងនៅ ព្រោះហេតុដែលមិនបានទប់ទំនប់ទុក, ទឹកសូម្បីនោះគប្បីឃាំងនៅបាន កាលបានទប់ទំនប់ហើយ សេចក្តីនេះយ៉ាងណា ; គរុធម៌ទាំងនេះ ដែលព្រះមានព្រះភាគទ្រង់ប្រញាប់បញ្ញត្តិជាមុន ដើម្បីការពារនូវការប្រព្រឹត្តកន្លង ក្នុងកាលដែលមិនទាន់កើតឡើង, កាលគរុធម៌ទាំងនោះដែលព្រះមានព្រះភាគមិនបានទ្រង់បញ្ញត្តិ ព្រះសទ្ធម្មនឹងគប្បីតាំងនៅបាន (ត្រឹមតែ) ប្រាំរយឆ្នាំ ព្រោះហេតុដែលមាតុគ្រាមបួស, តែព្រោះហេតុដែលទ្រង់បញ្ញត្តិគរុធម៌ទាំងនោះទុកជាមុន ព្រះសទ្ធម្មនឹងតាំងនៅបានប្រាំរយឆ្នាំទៀត សេចក្តីនេះ ក៏យ៉ាងនោះឯង ទើបរួមសេចក្តីថា ព្រះសទ្ធម្មនឹងតាំងនៅរហូតដល់អស់មួយពាន់ឆ្នាំ ដែលត្រាស់ដំបូងនុ៎ះឯងដោយប្រការដូច្នេះ ។

ពាក្យថា មួយពាន់ឆ្នាំនោះ ព្រះអង្គត្រាស់ដោយអំណាចព្រះខីណាស្រព ដែលដល់ការបែកធ្លាយក្នុងបដិសម្ភិទាប៉ុណ្ណោះ ។ តែកាលនឹងតាំងនៅក្រៃលែងជាងមួយពាន់ឆ្នាំនោះខ្លះ នឹងតាំងនៅអស់មួយពាន់ឆ្នាំដោយអំណាចនៃព្រះខីណាស្រពសុក្ខវិបស្សកៈ, នឹងតាំងនៅអស់មួយពាន់ឆ្នាំ ដោយអំណាចនៃព្រះអនាគាមី, នឹងតាំងនៅអស់មួយពាន់ឆ្នាំដោយអំណាចនៃព្រះសកទាគាមី, នឹងតាំងនៅអស់មួយពាន់ឆ្នាំ ដោយអំណាចព្រះសោតាបន្ន, រួមសេចក្តីថា បដិវេធសទ្ធម្មនឹងតាំងនៅរហូត

ដល់អស់ប្រាំពាន់ឆ្នាំ ដោយប្រការដូច្នេះ ។

ចំណែកព្រះបរិយត្តិធម៌ នឹងតាំងនៅដូច្នោះដូចគ្នា ។ កាលបរិយត្តិមិនមាន បដិវេធក៏រមែងមិនមាន, កាលបរិយត្តិមាន បដិវេធមិនមែនមិនមាន ។ តែកាលបរិយត្តិសាបសូន្យទៅហើយ ភេទនឹងប្រព្រឹត្តទៅរហូតអស់កាលយូរដូច្នេះឯង ។

## ឧបសម្ពទានៃភិក្ខុនីជាដើម

[១៨៣] ភិក្ខុទាំងឡាយឱ្យឧបសម្បទានាងសាកិយានីប្រាំរយ ធ្វើឱ្យជាសទ្ធិវិហារិនីរបស់ព្រះនាងមហាបជាបតីគោតមី ដោយព្រះអនុញ្ញាតនេះថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុទាំងឡាយ ឱ្យឧបសម្បទាដល់ពួកភិក្ខុនីបាន” ។ សូម្បីពួកសាកិយានីទាំងពួងនោះ ក៏ឈ្មោះថា ឧបសម្បទាព្រមគ្នាហើយ ដោយប្រការដូច្នេះ ។

[១៨៧] ព្រះនាងគោតមី សម្រេចព្រះអរហត្តដោយព្រះឱវាទនេះថា យេ ខោ ត្វំ គោតមិ (ជាដើម) ។

[១៩២] ពាក្យថា កម្មំ ន ករិយតិ : មិនបានធ្វើកម្ម មានសេចក្ដីថា ភិក្ខុទាំងឡាយមិនធ្វើកម្មទាំង ៧ យ៉ាង មានតជ្ជនីយកម្មជា

ដើម ។

[១៩៣] បទថា **ខមាបេន្តិ : ខមាទោស** មានសេចក្តីថា ភិក្ខុទាំងនេះ រមែងសូមទោសថា “យើងទាំងឡាយនឹងមិនធ្វើកម្មបែបនេះទៀត” ។

[១៩៥] វិនិច្ឆ័យក្នុងពាក្យថា **អនុជានាមិ ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ កម្មំ អារោបេត្វា ភិក្ខុនីនំ និយ្យាទេតុំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុលើកកម្មរបស់ពួកភិក្ខុនី ហើយប្រគល់ឱ្យភិក្ខុនី ឱ្យភិក្ខុនីធ្វើកម្មដល់ភិក្ខុនីផងគ្នា** នេះ គប្បីជ្រាបដូច្នេះ ៖

កាលភិក្ខុទាំងឡាយគប្បីលើកឡើងយ៉ាងនេះថា “បណ្តាកម្ម មានតជ្ជនីយកម្មជាដើម កម្មឈ្មោះនេះ គប្បីធ្វើដល់ភិក្ខុនីនោះ” ហើយគប្បីប្រគល់ឱ្យថា “ឥឡូវនេះ លោកទាំងឡាយទុំះឯង ចូរធ្វើកម្មនោះ” ។

ក៏បើថា ភិក្ខុនីទាំងឡាយធ្វើកម្មដទៃ ក្នុងកាលកម្មដទៃ ដែលភិក្ខុលើកឡើងហើយ លោកទាំងឡាយ រមែងដល់ភាពជាអ្នកដែលសង្ឃគួរពិន័យទោស តាមន័យដែលពោលហើយក្នុងបាលីនេះថា **“តជ្ជនីយកម្មារហស្ស និយស្សកម្មំ ករោតិ : ធ្វើនិយស្សកម្ម ដល់ភិក្ខុដែលគួរដល់តជ្ជនីយកម្មវិញ”**[១] តែម្តង ។

១. វិន. មហា. ចម្បេយ្យក្ខន្ធកៈ. ៨. ១០៥/២៣៣ ។

# អវន្ទិយករណ៍ជាដើម

[១៩៧] វិនិច្ឆ័យក្នុងពាក្យថា កទ្ទមោទកេន : ភក់និងទឹកនេះ គប្បីជ្រាបដូច្នេះ ៖

មិនមែនជាអាបត្តិទុក្កដ ដល់ភិក្ខុដែលសាចដោយទឹកភក់តែម្យ៉ាងប៉ុណ្ណោះទេ សូម្បីកាលសាចដោយទឹកថ្លា ទឹកព្រមទាំងភក់ជាដើម យ៉ាងណាមួយ ក៏ត្រូវអាបត្តិទុក្កដដែរ ។

ពាក្យថា អវន្ទិយោ សោ ភិក្ខវេ ភិក្ខុនីសង្ឃេន កាតព្វោ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសង្ឃគប្បីធ្វើភិក្ខុនោះឱ្យជាអវន្ទិយបុគ្គល មានសេចក្ដីថា ភិក្ខុនីសង្ឃគប្បីប្រជុំគ្នា ក្នុងសំណាក់ភិក្ខុនី សូធ្យប្រកាស ៣ ដង, យ៉ាងនេះថា "ម៉ែម្ចាស់ ខ្ញុំព្រះករុណាសូរភិក្ខុនីសង្ឃថា លោកម្ចាស់ឈ្មោះឯណោះ សម្ដែងអាការមិនគួរ ជ្រះថ្លាដល់ភិក្ខុនីទាំងឡាយ, ការធ្វើលោកម្ចាស់នោះ ឱ្យជាអ្នកដែលភិក្ខុនីទាំងឡាយ មិនគប្បីថ្វាយបង្គំ គាប់ចិត្តដល់សង្ឃឬ ?" ចាប់តាំងពីនោះ ភិក្ខុនោះ ដែលភិក្ខុនីទាំងឡាយ ធ្វើឱ្យជាអ្នកដែលខ្លួនមិនគួរថ្វាយបង្គំ ដោយសូធ្យប្រកាសត្រឹមតែប៉ុណ្ណេះ ។ ចាប់ផ្ដើមតាំងពីពេលនោះ ភិក្ខុនោះ ដែលភិក្ខុនីសូម្បីឃើញហើយ មិនគប្បីថ្វាយបង្គំ ដូចដែលឃើញសាមណេរហើយ មិនថ្វាយបង្គំ ដូច្នោះ ។

កាលភិក្ខុនោះ (ដែលភិក្ខុនីទាំងឡាយ មិនថ្វាយបង្គំ ត្រឡប់កើតហិរិនិងឱត្តប្បៈឡើងហើយ) ប្រព្រឹត្តវត្តដោយប្រពៃ, (គប្បីសូមទោសភិក្ខុនីទាំងឡាយ កាលនឹងសូមទោស) មិនគប្បីទៅកាន់សំណាក់ភិក្ខុនី គប្បីចូលរកសង្ឃ ឬគណៈ ឬភិក្ខុមួយរូប ក្នុងវិហារនុ៎ះឯង អង្គុយប្រហោងផ្គងអញ្ជលី សូមទោសថា "លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាពិចារណាហើយ នឹងតាំងនៅក្នុងសំវរៈតទៅ, នឹងមិនសម្តែងអាការមិនគួរជ្រះថ្លាទៀត, សូមភិក្ខុនីសង្ឃអត់ទោសដល់ខ្ញុំព្រះករុណាចុះ" ។ ភិក្ខុ (ដែលទទួលពាក្យ)នោះ គប្បីចូលទៅកាន់សំណាក់ភិក្ខុនីពោលថា "ភិក្ខុនោះសូមទោសពួកលោក" ចាប់តាំងពីពេលនោះមក ភិក្ខុនីទាំងឡាយគប្បីថ្វាយបង្គំភិក្ខុនោះ ។ សេចក្តីសង្ខេបក្នុងភិក្ខុនីខន្ធកៈនេះប៉ុណ្ណេះ តែខ្ញុំព្រះករុណានឹងពោលសេចក្តីពិស្តារ ក្នុងកម្មវិភង្គ ។

[១៩៨] បទថា ឱភាសេន្តិ : **ចំអកចំអន់** មានសេចក្តីថា ភិក្ខុឆព្វគ្គិយ៍ រមែងបបួលភិក្ខុនីទាំងឡាយ ដោយអសទ្ធម្ម ។

ប្រើនបទថា ភិក្ខុនីហិ សទ្ធឹ សម្បយោជេន្តិ : **ផ្សំផ្គុំជាមួយនឹងពួកភិក្ខុនី** មានសេចក្តីថា ភិក្ខុឆព្វគ្គិយ៍ជួយដឹកនាំបុរសនឹងភិក្ខុនីដោយអសទ្ធម្ម ។ ការធ្វើឱ្យជាអ្នកដែលភិក្ខុនីទាំងឡាយ មិនគប្បីថ្វាយបង្គំ

មានន័យដូចពោលហើយនុ៎ះឯង ។

បទថា **អាវរណំ : អាវរណកម្ម** បានដល់ ការរារាំងការពារ មានការហាមមិនឱ្យចូលក្នុងវិហារជាដើម ។

បទថា **ន អាទិយន្តិ : មិនទទួលដោយស្រួលស្រួល** មានសេចក្ដីថា ពួកឆព្វគ្គិយាភិក្ខុនី មិនព្រមទទួលខ្លួនឯងដោយប្រពៃ ។

វិនិច្ឆ័យក្នុងពាក្យថា **ឱវាទំ ឋបេតុំ : បញ្ឈប់ឱវាទ** នេះ គប្បីជ្រាបដូច្នេះ ៖

ឱវាទដែលភិក្ខុមិនគប្បីទៅ លើកលែងសំណាក់ភិក្ខុនី តែគប្បីប្រាប់ភិក្ខុនីទាំងឡាយ ដែលមកដើម្បីប្រយោជន៍ដល់ឱវាទថា "ភិក្ខុនីឈ្មោះឯណោះ មានអាបត្តិជាប់ខ្លួន យើងវៀរឱវាទដល់ភិក្ខុនីនោះ លោកទាំងឡាយកុំធ្វើឧបោសថនឹងភិក្ខុនីនោះ" ។ ទណ្ឌកម្ម សូម្បីក្នុងការបើកកាយជាដើម មានន័យដូចពោលហើយដូចគ្នា ។

[២០៦] ពាក្យថា **ន ភិក្ខវេ ភិក្ខុនិយា ឱវាទោ ន គន្តព្វោ : ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវមិនទៅទទួលឱវាទទេ** ជាដើម ខ្ញុំព្រះករុណាបានពោលរួចហើយ ក្នុងវណ្ណនានៃភិក្ខុនីវិភង្គ ។

# ការតែងខ្លួនជាដើម

[២១៧] ពាក្យថា ផាសុកេ ធមេន្តិ[១] : ចងរឹតឆ្អឹងជំនី មានសេចក្តីថា ភិក្ខុនីទាំងឡាយ ប្រើកាយពន្ធចងរឹតឆ្អឹងជំនី ដើម្បីប្រយោជន៍ដល់ការពត់តម្រង់ ដូចស្រីគ្រហស្ថទើបតែពេញក្រមុំ ចងដោយសំពត់ចងដោះដូច្នោះ ។

បទថា ឯកបរិយាយកតំ[២] : ល្មមព័ទ្ធតែ ១ ជុំបាន បានដល់ កាយពន្ធដែលចងបានតែមួយជុំ ។

[២១៨] ពីរបទថា វិលិវេន បដ្ដេន : ដោយផ្ទាំងសំពត់ដែលធ្វើអំពីបន្ទោះឫស្សី បានដល់ សំពត់ផ្ទាំងដែលត្បាញដោយបន្ទោះឫស្សីយ៉ាងល្អិត ។

បទថា ទុស្សបដ្ដេន : ផ្ទាំងសំពត់ បានដល់ ផ្ទាំងសំពត់ពណ៌ស ។

បទថា ទុស្សវេណិយា : សំណុំសំពត់ បានដល់ សំណុំដែលធ្វើដោយសំពត់ ។

បទថា ទុស្សវដ្ដិយា : ខ្នាញ់សំពត់ បានដល់ ខ្នាញ់ដែលធ្វើដោយសំពត់ ។

ក្នុងសំពត់ផ្ទាំងតូចជាដើម សំពត់កាសាវៈផ្ទាំងតូច គប្បីជ្រាបថា

---

១. ឆត្ត. ផាសុកា នាមេន្តិ; ឱ. បាសុកេ ។ ២. ឱ. ម. ឯកបរិយាកតំ ។

ឈ្មោះថា សំពត់ផ្ទាំងតូច ។

[២១៩] បទថា អដ្ឋិល្លេន : ឆ្អឹងគោ បានដល់ ឆ្អឹងស្មងនៃគោ ។ ផ្នែកក្រោយចង្កេះ ហៅថា ត្រគាក ។

ពីរបទថា ហត្ថំ គោធ្ដាបេន្តិ : ឱ្យគេជំដៃ បានដល់ ឱ្យជំចុងដៃតែងឱ្យ ល្អដោយរោមសត្វក្ងោកជាដើម ។

បទថា ហត្ថកោច្ឆំ : ឱ្យគេជំខ្នងដៃ បានដល់ ខ្នងដៃ ។

បទថា បាទំ : ឱ្យគេជំជើង បានដល់ ស្មងជើង ។

បទថា បាទកោច្ឆំ : ឱ្យគេជំខ្នងជើង បានដល់ ខ្នងជើង ។ ការលាបមុខជាដើម មានន័យដូចពោលហើយនុ៎ះឯង ។

[២២១] ពីរបទថា អវង្គំ ករោន្តិ : ធ្វើទូវគំនូសខាងក្រោមមាត់ មានសេចក្ដីថា ពួកឆព្វគ្គិយាភិក្ខុនី គូរក្បាច់បែរមុខចុះក្រោម ត្រង់កន្ទុយភ្នែក ដោយឈើចង្កឹះថ្នាំភ្នែក ។

បទថា វិសេសកំ : គំនូសប្លែក មានសេចក្ដីថា ភិក្ខុនីទាំងនោះ ធ្វើរូបសត្វប្លែក ៗ មានទ្រង់ទ្រាយស្រស់ល្អ ត្រង់ថ្ពាល់ ។

បទថា ឱលោកេន្តិ : ក្រឡេកមើល មានសេចក្ដីថា បើកបង្អួចក្រលេកមើលថ្នល់ ។

ពីរបទថា សាលោកេ តិដ្ឋន្តិ : ឈរបង្ហាញកាយពាក់កណ្ដាល មានសេចក្ដីថា បើកទ្វារឈរបង្ហាញកាយនៅពាក់កណ្ដាលខ្លួន ។

បទថា សនច្ចំ : មហោស្រព មានសេចក្តីថា ឲ្យធ្វើការមហោស្រពដោយអ្នករបាំ ។

ពីរបទថា វេសឹ វុដ្ឋាបេន្តិ : បំបួសស្រីផ្កាមាស មានសេចក្តីថា បានតាំងស្រីនគរសោភេណី ។

ពីរបទថា ធានាគារំ ឋបេន្តិ : តាំងរោងសុរា មានសេចក្តីថា រមែងលក់សុរា ។

ពីរបទថា សូនំ ឋបេន្តិ : តាំងរោងលក់សាច់ មានសេចក្តីថា រមែងលក់សាច់ ។

បទថា អាបណំ : បើករានផ្សារ មានសេចក្តីថា រមែងតាំងរានទំនិញផ្សេង ៗ ច្រើនយ៉ាង ។

ពីរបទថា ធាសំ ឧបដ្ឋាបេន្តិ : ឲ្យខ្ញុំប្រុសបម្រើ មានសេចក្តីថា រមែងទទួលទាសហើយញុំាងទាសនោះ ឲ្យធ្វើការបម្រើកិច្ចការរបស់ខ្លួន ។ សូម្បីក្នុងទាសីជាដើម ក៏មានន័យដូចគ្នា ។

ពីរបទថា ហរិតកបត្តិកំ បកិណន្តិ[1] : លក់វត្ថុខ្ចីនិងវត្ថុទុំ មានសេចក្តីថា រមែងលក់របស់ស្រស់និងរបស់ក្រៀម ។ មានពាក្យអធិប្បាយថា រមែងបើករានលក់របស់បន្តិចបន្តួច ។

ការពោលអំពីចីវរខៀវទាំងពួងជាដើម បានពោលហើយនោះឯង ។

---

១. ថៃ. បកីណន្តិ ។

# ការដាក់បរិក្ខារ

[២២៣] ក្នុងពាក្យថា ភិក្ខុនី ចេ ភិក្ខវេ កាលំ ករោន្តិ : ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនីទៀបនឹងមរណកាល ជាដើម មានវិនិច្ឆ័យក្រៅព្រះបាលី ដូចតទៅនេះ ៖

ក៏បើថា ក្នុងសហធម្មិកទាំង ៥ អ្នកណាម្នាក់ កាលនឹងធ្វើ កាលកិរិយាទើបបន្ទាប់ថា "ដោយសម័យដែលខ្ញុំព្រះករុណាកន្លងទៅ បរិក្ខាររបស់ខ្ញុំព្រះករុណាចូរជារបស់ព្រះឧបជ្ឈាយ៍ ឬថា ចូរជារបស់អាចារ្យ ឬថា ចូរជារបស់សទ្ធិវិហារិក ឬថា ចូរជារបស់អន្តេវាសិក ឬថា ចូរជារបស់មាតា ឬថា ចូរជារបស់បិតា ឬថា ចូរជារបស់អ្នកណា ៗដទៃ" បរិក្ខាររបស់អ្នកនោះ មិនជារបស់ជនទាំងនោះគង់ជារបស់សង្ឃប៉ុណ្ណោះ ព្រោះថា ការឱ្យដោយកាលដែលកន្លងទៅ (នៃខ្លួន) របស់សហធម្មិកទាំង ៥ រមែងប្រើមិនបាន របស់ពួកគ្រហស្ថប្រើបាន ។

ភិក្ខុធ្វើកាលកិរិយាក្នុងសំណាក់របស់ភិក្ខុនី បរិក្ខាររបស់លោករមែងជារបស់ភិក្ខុទាំងឡាយប៉ុណ្ណោះ ។ ភិក្ខុនីធ្វើកាលកិរិយាក្នុងសំណាក់របស់ភិក្ខុបរិក្ខាររបស់លោក រមែងជារបស់ភិក្ខុនីទាំងឡាយប៉ុណ្ណោះ ។

[២២៤] បទថា បុរាណមល្លី : ប្រពន្ធចាស់របស់ស្តេចមល្ល: មានសេចក្តីថា ជាភរិយារបស់អ្នកប្រជាល់ ក្នុងកាលមុន គឺ ក្នុងគ្រាជា

គ្រហស្ថ ។

[២២៧] បទថា **បុរិសព្យញ្ជនំ** : ព្យញ្ជនរបស់បុរស មានសេចក្ដីថា និមិត្តរបស់បុរស ទីងជាអវយវៈដែលបិទបាំងក៏ដោយ មិនបានបិទបាំងក៏ដោយ គឺ ទីងជារបស់ដែលវត្ថុណា ៗ កំបាំងក៏ដោយ មិនបានកំបាំងក៏ដោយ ។ បើភិក្ខុនី សម្លឹងមើលញ៉ាំងចិត្តឱ្យកើតឡើងថា "និមិត្តរបស់បុរសនៅត្រង់នេះ" ត្រូវទុក្កដ ។

## អាមិសដែលគេប្រគេនចំពោះខ្លួន

[២២៨] អាមិសណាដែលគេប្រាប់ថា "សូមលោកម្ចាស់បរិភោគខ្លួនឯង" អាមិសនោះ ឈ្មោះថា របស់ដែលគេប្រគេន ដើម្បីប្រយោជន៍ដល់ការបរិភោគចំពោះខ្លួន កាលភិក្ខុឱ្យអាមិសនោះដល់អ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ តែកាន់យកចំណែកល្អជាមុន ហើយ ទើបឱ្យគួរ ។

បើថា អាមិសនោះ មិនជាទីសប្បាយ ទីងលះបង់ចេញទាំងអស់ក៏គួរ ។ ប្រើប្រាស់ចីវរមួយថ្ងៃ ឬ ពីរថ្ងៃហើយទើបឱ្យ ក៏គួរ ។ សូម្បីក្នុងបាត្រជាដើម ក៏មានន័យដូចគ្នា ។

## ឋានៈនៃរបស់ដែលទទួលប្រគេន

[២៣៣] ពាក្យថា ភិក្ខុនីនំ សន្និធឹ ភិក្ខុហិ ភិក្ខុនីហិ បដិគ្គហាបេត្វា : អនុញ្ញាតឱ្យភិក្ខុឬភិក្ខុនី ទទួលការសន្សំរបស់ភិក្ខុនីបរិភោគចុះ មានសេចក្ដីថា អាមិសដែលភិក្ខុទទួលប្រគេនរក្សាទុកកាលពីថ្ងៃម្សិលមិញ កាលអនុបសម្បន្នដទៃមិនមានក្នុងថ្ងៃនេះ ភិក្ខុនីទាំងឡាយគប្បីឱ្យភិក្ខុទទួលប្រគេនហើយឆាន់ ។ ព្រោះថា អាមិសដែលភិក្ខុទទួលប្រគេនហើយ រមែងតាំងនៅក្នុងឋានៈនៃអាមិសដែលមិនទាន់បានទទួលប្រគេនសម្រាប់ភិក្ខុនី ។ សូម្បីសម្រាប់ភិក្ខុ ក៏មានន័យដូចក្នុងភិក្ខុនីនុ៎ះឯង ។

## ការអង្គុយ

[២៤៦] ពីរបទថា អាសនំ សង្គាយន្តិយោ : រវល់រៀបចំអាសនៈ មានសេចក្ដីថា ភិក្ខុនីទាំងឡាយកលញ្ញាំងគ្នា និងគ្នាឱ្យកាន់យកទីអង្គុយ ។

ពីរបទថា កាលំ វីតិនាមេសុំ : ធ្វើភត្តកាលឱ្យកន្លងហួសទៅ មានសេចក្ដីថា រវល់តែឱ្យមួយរូបក្រោកឡើង ឱ្យមួយរូបទៀតអង្គុយ បានញ៉ាំងវេលាឆាន់ឱ្យកន្លងហួសទៅ ។

វិនិច្ឆ័យក្នុងពាក្យថា អជ្ជន្តំ ភិក្ខុនីនំ យថាវុឌ្ឍំ : លំដាប់ទីចាស់ទុំចំពោះភិក្ខុនី ៨ រូប នេះ គប្បីជ្រាបដូច្នេះ ៖

បើថា ភិក្ខុនី ៨ រូបអង្គុយក្នុងទីជិត ភិក្ខុនីដទៃដែលប្រព្រឹត្តទៅខាងក្នុងនៃភិក្ខុនីទាំងនោះមក ។ លោករមែងបានដើម្បីញាំងភិក្ខុនីដែលទុំជាងខ្លួនឱ្យក្រោកឡើងហើយអង្គុយជំនួស ។

ចំណែកភិក្ខុនីណា ជាអ្នកទុំជាងភិក្ខុនីទាំង៨រូប ភិក្ខុនីនោះសូម្បីបើនឹងមានវស្សា៦០ រមែងបានដើម្បីអង្គុយតាមលំដាប់នៃអ្នកមកប៉ុណ្ណោះ ។

[២៤៧] ពាក្យថា អញ្ញត្ថ យថាវុឌ្ឍំ ន បដិពាហិតព្វំ : ភិក្ខុមិនត្រូវឃាត់លំដាប់ទីចាស់ទុំ មានសេចក្តីថា ក្នុងទីចែកបច្ច័យ ៤ កន្លែងដទៃ ក្រៅអំពីរោងឆាន់ អ្នកណានឹងហាមភិក្ខុចាស់ថា "យើងមកមុន" ហើយកន់យកវត្ថុណា ៗ មិនបាន ។ ការកាន់យកតាមលំដាប់ភិក្ខុចាស់នុ៎ះឯងទើបគួរ ។

[២៤៨-២៥៥] ការពោលអំពីបវារណា ខ្ញុំព្រះករុណាបានពោលរួចហើយ ។

[២៥៦] យានគ្រប់ប្រភេទ ដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ដោយពាក្យថា ឥត្ថិយុត្តំ : មានស្រីជាអ្នកបរ ជាដើម ។

[២៥៨] បទថា បាដង្កឹ : យានដែលអូសដោយដៃ បានដល់អង្រឹងសំពត់ ។

## ការឧបសម្បទាដោយទូត

[២៥៩] ការឧបសម្បទាដោយទូត រមែងគួរ ព្រោះអន្តរាយយ៉ាងណាមួយ បណ្តាអន្តរាយ ១០ យ៉ាង ។ ក្នុងវេលាចប់កម្មវាចា ភិក្ខុនីនោះនឹងឈរឬអង្គុយ ក៏ដោយ ភ្ញាក់ ឬលង់លក់ ក៏ដោយ ក្នុងសំណាក់ភិក្ខុនី, លោករមែងជាអ្នកឧបសម្បទាហើយពិត ។ ក្នុងខណៈនោះ ភិក្ខុសង្ឃគប្បីប្រាប់ចំណែកនៃថ្ងៃមានពាក្យថា "ស្រមោល" ជាដើម ដល់ភិក្ខុនីទូតដែលមកហើយ ។

## រោងរក្សារបស់ជាដើម

[២៦២] បទថា ឧទ្ទោសិតោ : ឃ្លាំង បានដល់ រោងរក្សាទ្រព្យ ។

បទថា ន សម្មតិ : មិនគ្រប់គ្រាន់ បានដល់ មិនល្មម ។

បទថា ឧបស្សយំ : លំនៅ បានដល់ ផ្ទះ ។

បទថា នវកម្មំ : ការងារថ្មី មានសេចក្តីថា តថាគតអនុញ្ញាតឱ្យភិក្ខុនីធ្វើការសាងថ្មី ដើម្បីប្រយោជន៍ដល់សង្ឃ ។

[២៦៣] ពីរបទថា តស្សា បព្វជិតាយ : ស្រីនោះបួសហើយ បានដល់ ក្នុងវេលាដែលស្រីនោះបួសហើយ ។

ត្រើនបទថា យាវ សោ ទារកោ វិញ្ញុតំ បាបុណាតិ : ដរាបទាល់តែទារកនោះបានដឹងក្តី មានសេចក្តីថា (តថាគតអនុញ្ញាតឱ្យចិញ្ចឹមរក្សា) ដរាបដល់ទារកនោះអាចបរិភោគ និងផ្លូតបាន តាមធម្មតារបស់ខ្លួន ។

ពីរបទថា ឋបេត្វា សាគារំ : ឱ្យថែរក្សា បានដល់ វៀរត្រឹមតែបន្ទប់ផ្ទះ ដែលជាសហសេយ្យ ។ ព្រះមានព្រះភាគទ្រង់សម្តែងថា "តថាគតអនុញ្ញាតឱ្យ (ភិក្ខុនីដែលជាសម្លាញ់) ថែរក្សាក្នុងទារកនោះ ដូចជាការប្រតិបត្តិក្នុងបុរសដទៃ ដែរ" ។ ភិក្ខុនីជាមាតា រមែងបានដើម្បីញ៉ាំងទារកនោះឱ្យផ្លូត ឱ្យផឹក និងឱ្យ បរិភោគ ដើម្បីតែងខ្លួនទារកនិងឱ្យទារកនោះ ដេកលើទ្រូង ។

# លាសិក្ខាជាដើម

[២៦៥] ដោយពាក្យថា យទេវ សា វិព្ភន្តា : ភិក្ខុនីនោះសឹកចេញទៅ ព្រះមានព្រះភាគទ្រង់សម្តែងថា "ព្រោះភិក្ខុនីនោះ សឹកហើយស្លៀកសំពត់សដោយការត្រេកអរពេញចិត្តរបស់ខ្លួន" ដូច្នោះឯង លោកទើបមិនមែនភិក្ខុនី ។ នាងមិនមែនភិក្ខុនី ព្រោះការលាសិក្ខាក៏ទេ ។ នាងរមែងមិនបានឧបសម្បទាទៀត ។

[២៦៦] ពាក្យថា សា អាគតា ន ឧបសម្បាទេតព្វា : ហើយនាងនោះត្រឡប់មកវិញ សង្ឃមិនត្រូវឱ្យឧបសម្បទាទេ មានសេចក្តីថា ក៏ភិក្ខុនីនោះ ដែលសង្ឃមិនគប្បីឱ្យឧបសម្បទាតែម្យ៉ាងប៉ុណ្ណោះ ក៏ទេ, នាងក៏មិនបានសូម្បីនូវបព្វជ្ជាផង ។ ចំណែកនាងដែលស្លៀកសសឹកទៅ បានត្រឹមតែបព្វជ្ជា ។

## ត្រេកអរការអភិវាទជាដើម

[២៦៧] ក្នុងបទថា អភិវាទនំ : កិរិយាថ្វាយបង្គំ ជាដើម មានសេចក្តីថា បុរសទាំងឡាយ កាលប្រព្រឹត្តជើង រមែងសំពះ រមែងគោរសក់, រមែងកាត់ក្រចក, រមែងធ្វើការរក្សាដំបៅ, ភិក្ខុនីទាំងឡាយ រង្កៀសចំពោះកិច្ចការទាំងអស់នោះ ទើបមិនត្រេកអរ ។

ក្នុងពាក្យថា អភិវាទនំ ជាដើមនោះ អាចារ្យពួកខ្លះពោលថា បើជាអ្នកដែលរាគៈគ្របសង្កត់ហើយ ជាអ្នកមានសេចក្តីតម្រេកខាំងក្លាខាងភិក្ខុនីមួយចំណែក ឬ ទាំង ២ ខាង, ជាអាបត្តិតាមវត្ថុពិត ។

អាចារ្យពួកមួយពោលថា ក្នុងការសំពះជាដើមនេះ មិនមានអាបត្តិ ។ ព្រះអដ្ឋកថាចារ្យទាំងឡាយ សម្តែងអាចរិយវាទ យ៉ាងនេះ ពោលទុកក្នុងអដ្ឋកថាថា ការសំពះជាដើមនេះ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតចំពោះភិក្ខុនីទាំងឡាយ ទើបសមគួរ ។ ពាក្យនៃអដ្ឋកថានោះ

ជាប្រមាណ ។ ព្រោះថា ការដែលបុរសទាំងឡាយសំពះជាដើម ជាកិច្ចសមគួរ ដោយព្រះបាលីថា "អនុជានាមិ ភិក្ខវេ សាទិយតុំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុនីត្រេកអរ" ដូច្នេះឯង ។

[២៦៨] ពីរបទថា បល្លង្កេន និសីទន្តិ : អង្គុយពែនភ្នែនហើយ បានដល់ អង្គុយចម្រើនសមាធិ ។

[២៦៩] បទថា អឌ្ឍបល្លង្កំ : អង្គុយពែនជើងម្ខាង បានដល់ អង្គុយចម្រើនសមាធិបត់ជើងចូលតែម្ខាង ។

[២៧០] វិនិច្ឆ័យក្នុងពាក្យថា ហេដ្ឋាវិវដេ ឧបរិបដិច្ឆន្នេ : ក្នុងទីខាងក្រោម ដែលមិនមានបិទបាំង មានបិទតែខាងលើជុំវិញ នេះគប្បីជ្រាបដូច្នេះ ៖

បើជារណ្តៅដែលគេជីក ត្រឹមតែឈើរៀបខាងលើប៉ុណ្ណោះ ប្រាកដក្នុងទិសទាំងពួង, នឹងបន្ទោបង់ឧច្ចារៈក្នុងរណ្តៅ សូម្បីបែបនោះក៏គួរ ។

[២៧១] ពីរបទថា កុក្កុសំ មត្តិកំ : កណ្តុក និងដីស្អិត បានដល់ អង្កាម និងដីឥដ្ឋ ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

**ភិក្ខុនិក្ខន្ធកវណ្ណនា ចប់**

# ២១. បញ្ចសតិកក្ខន្ធកវណ្ណនា

វិនិច្ឆ័យក្នុងបញ្ចសតិកក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

[២៨៣] ពីរបទថា បញ្ច[1] និកាយេ បុច្ឆិ : សួរនូវនិកាយទាំង ៥ មានសេចក្ដីថា ព្រះមហាកស្សបៈសួរនិកាយ ៥ គឺ ទីឃនិកាយ មជ្ឈិមនិកាយ អង្គុត្តរនិកាយ សំយុត្តនិកាយ ខុទ្ទកនិកាយ ។

[២៨៤] ពាក្យយ៉ាងនេះថា វៀរបារាជិក ៤ ចេញ សិក្ខាបទដ៏សេស ជាសិក្ខាបទតូចនិងតូចបន្ទាប់ជាដើម ព្រះសង្គាហកថេរៈទាំងឡាយពោលហើយដោយបរិយាយ ដើម្បីសម្ដែងសិក្ខាបទទាំងពួង កាលដែលលោកស្ដាប់រូបរួមយកទុក មិនលះចោល សូម្បីសិក្ខាបទតែមួយ ។

[២៨៥] ច្រើនបទថា ឥទំ វោ សមណានំ : អំពើនេះ (គួរ) ដល់លោកទាំងឡាយជាសមណៈ មានសេចក្ដីថា នេះ សមគួរដល់សមណៈទាំងឡាយ ។ វោ អក្សរ ប្រើក្នុងអត្ថត្រឹមតែញ៉ាំងបទឱ្យពេញ ។

បទថា ធូមកាលិកំ : កាលនៃផ្សែងភ្លើង មានសេចក្ដីថា ផ្សែងនៃចិត្តការធារជាទីបរិនិព្វានរបស់ព្រះសមណៈ នៅប្រាកដត្រឹមណា,

---

១. ភូមា. បញ្ចបិ ។

កាលត្រឹមនោះ ជាកាលនៃសិក្ខាបទដែលព្រះសមណៈ ទ្រង់បញ្ញត្តិហើយ ដល់សាវកទាំងឡាយ ។

[២៨៦] ពាក្យថា ឥធន្តេ[១] អាវុសោ អានន្ទ ទុក្កដំ : នៃអាវុសោ អានន្ទ នេះជាអំពើអាក្រក់របស់លោកនេះ ដែលព្រះថេរៈ ទាំងឡាយ ត្រឹមតែនឹងតិះដៀលថា "ឥទំ តយា ទុដ្ឋុ កតំ : កម្មនេះ ដែលលោកធ្វើមិនល្អហើយ" ទើបពោលហើយ, មិនបានពោលសំដៅ ដល់អាបត្តិទេ ។ ដែលព្រះថេរៈទាំងនោះ នឹងមិនស្គាល់អាបត្តិ និងមិន មែនអាបត្តិ ក៏ទេ ។

ពិតមែន ក្នុងឥឡូវនេះ ព្រះមហាកស្សបៈបានប្រកាសពាក្យនេះថា "សង្ឃោ អបញ្ញត្តំ ន បញ្ញាបេតិ បញ្ញត្តំ ន សមុច្ឆិន្ទតិ : សង្ឃមិន បញ្ញត្តិសិក្ខាបទ ដែលព្រះមានព្រះភាគទ្រង់មិនបញ្ញត្តិទុក, មិនដកនូវ សិក្ខាបទ ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយទេ" ។

មួយទៀត សូម្បីពាក្យថា ទេសេហិ តំ ទុក្កដំ : ចូរលោក សម្តែងអំពើអាក្រក់នោះចេញ នេះ ដែលព្រះថេរៈទាំងឡាយ ពោល សំដៅដល់សេចក្តីប្រាថ្នានេះថា "លោកចូរប្តេជ្ញាការមិនទូលសួរនោះថា

---

១. ភូមា. ឥទំបិ តេ ; ថៃ. ឥទម្បិ តេ ។

'ជាការធ្វើមិនល្អ' យ៉ាងនេះថា 'អាម ភន្តេ ទុដ្ឋុ មយា កតំ : លោកដ៏ចម្រើន ខ្ញុំព្រះករុណាធ្វើមិនល្អពិត'" ទើងពោលសំដៅដល់ការសម្តែងអាបត្តិ ក៏ទេ ។

ចំណែកព្រះថេរៈមិនទូលសួរ ព្រោះរលឹកមិនបាន មិនមែនព្រោះមិនអើពើទេ; ព្រោះដូច្នោះ លោកកាលកំណត់មិនបាន សូម្បីការសម្តែងចេញ ព្រោះមិនទូលសួរនោះ ៗ ទើបពោលថា "នាហំ តំ ទុក្កដំ បស្សាមិ : ខ្ញុំព្រះករុណាមិនឃើញអំពើអាក្រក់នោះទេ" កាលទើងសម្តែងសេចក្តីគោរពក្នុងព្រះថេរៈទាំងឡាយ ទើបពោលថា "អបិចាយស្មន្តានំ សទ្ធាយ[១] ទេសេមិ តំ ទុក្កដំ : ប៉ុន្តែ ខ្ញុំព្រះករុណា សម្តែងនូវអាបត្តិអាក្រក់នោះចេញ ដោយសេចក្តីជឿលោកមានអាយុទាំងឡាយ" ។ មានពាក្យអធិប្បាយថា លោកទាំងឡាយ ពោលយ៉ាងណា, ខ្ញុំព្រះករុណាព្រមប្តេជ្ញាយ៉ាងនោះ ។ ក្នុងស្ថានទាំង ៤ សូម្បីដ៏សេសមានន័យដូចគ្នា ។

ព្រះអានន្ទពោលថា "មាយិមា[២] វិកាលេ អហេសុំ : កុំឱ្យមាតុគ្រាមនេះនៅក្នុងវេលាវិកាល" ដោយអធិប្បាយថា ការទៅក្នុងវេលាវិកាលរបស់ស្ត្រី កុំបានមានឡើយ ។

---

(១) ក្នុងយោជនាជា សទ្ធាយ ។ ២. ថៃ. មា យិមា; ភូមា. មាយិមាសំ ។

[២៩០] ពីរបទថា វរជោហរណំ គារិស្សាម : ធ្វើជាសំពត់ជូតធូលី មានសេចក្ដីថា អាត្មាភាពទាំងឡាយនឹងជ្រលក់ទឹក ពូតហើយជូតផែនដី ដែលធ្វើបរិកម្ម ។

ពីរបទថា ន កុលវំ គមេន្តិ : មិនធ្វើសំពត់ឱ្យដល់សេចក្ដីវិនាសឥតប្រយោជន៍ មានអធិប្បាយថា សមណសក្យបុត្រទាំងនេះ មិនរក្សាទុកដាក់ក្នុងឃ្លាំង ។

[២៩១] ពីរបទថា យធគ្គេន តយា : លោក ក្នុងកាលជាទីបំផុតណា មានសេចក្ដីថា បើថា ព្រះអរហត្តដែលលោកធ្វើឱ្យច្បាស់ហើយ ក្នុងកាលផ្ដើមដំបូងតែម្ដង ដូច្នេះឯង ។

ពាក្យណាដែលនឹងត្រូវពោល (ឱ្យពិស្ដារ) ដែលនៅមានក្នុងបញ្ចសតិកក្ខន្ធកៈនេះ ពាក្យនោះ ខ្ញុំព្រះករុណាបានពោលក្នុងនិទានវណ្ណនារួចហើយ ។

## បញ្ចសតិកក្ខន្ធកវណ្ណនា ចប់

# ២២. សត្តសតិកក្ខន្ធកវណ្ណនា

វិនិច្ឆ័យក្នុងសត្តសតិកក្ខន្ធកៈ គប្បីជ្រាបដូច្នេះ ៖

[២៩៦] បទថា ភិក្ខគ្គេន[1] មានសេចក្តីថា ភិក្ខុវជ្ជីបុត្រអ្នកក្រុងវេសាលី រាប់ភិក្ខុទាំងឡាយតាមចំនួនភិក្ខុហើយ ចាត់ចំណែកទុកមានប្រមាណប៉ុណ្ណោះ ។

[២៩៨] បទថា មហិកា : ពពក បានដល់ អ័ព្ទក្នុងកាលធ្លាក់សន្សើម ។

[២៩៩] បទថា អវិជ្ជានិវុតា[2] : អវិជ្ជាបិទបាំង បានដល់ អ្នកដែលអវិជ្ជាបិទបាំងហើយ ។

បទថា បោសា : អ្នកដែលគេចិញ្ចឹម បានដល់ បុរស ។ ឈ្មោះថា អ្នកសរសើរនូវរូបបិយ ព្រោះរីករាយណាស់ គឺ ប្រាថ្នានូវរូបបិយៈ ។

បទថា អវិទ្ទសូ[3] : មិនដឹងច្បាស់ បានដល់ មិនដឹង ឈ្មោះថា អ្នកមានធូលីដោយធូលីគឺ រាគៈ, ឈ្មោះថា អ្នកហាក់ដូចជាម្រឹគ ព្រោះជាអ្នកស្រដៀងម្រឹគ ។ ឈ្មោះថា អ្នកមានតណ្ហាគ្រឿងនាំទៅកាន់ភព

---

១. ឱ.ម. ភិក្ខគ្គេន ។ ២. ភូមា. អវិជ្ជានីវុដា ។ ៣. ថៃ. អវិទ្ទសុ ។

ព្រោះប្រព្រឹត្តទៅដោយតណ្ហាជាគ្រឿងទៅកាន់ភព ។

បាទគាថាថា វឌ្ឍន្តិ[1] កដសី ឃោរំ : តែញុំាងរាងកាយជារបស់គ្រោតគ្រាត ឱ្យចម្រើនឡើង មានសេចក្តីថា រមែងញុំាងភូមិជាទីចោលសាកសព ឱ្យក្រាស់ឡើងរឿយ ៗ ក៏ឯកាលញុំាងភូមិជាទីចោលសាកសព ឱ្យក្រាស់ឡើងរឿយ ៗ យ៉ាងនោះ ឈ្មោះថា រមែងកាន់យកភពថ្មីដែលគួរខ្លាច គឺ ថា រមែងកើត ទៀត ដូច្នេះឯង ។

[៣០៣] ពាក្យថា ធាបិតំ នោ អាវុសោ កតំ : អំពើអាក្រក់ពួកយើងបានធ្វើហើយ មានសេចក្តីថា អ្នកមានអាយុ កម្មលាមកដែលយើងទាំងឡាយធ្វើហើយ ។

[៣១១] បទថា ភុម្មិ នេះ ដែលមាននៅក្នុងពាក្យថា កតមេនត្វំ ភុម្មិ វិហារេន : លោកនៅដោយធម៌ជាគ្រឿងនៅ ដូចម្តេច នេះជាពាក្យពីរោះ ។

បានឮថា ព្រះសព្វកាមី អ្នកប្រាថ្នានឹងពោលពាក្យដ៏ពីរោះ ទើបហៅភិក្ខុថ្មីទាំងឡាយ យ៉ាងនោះ ។

បទថា កុល្លកវិហារេន : នៅដោយធម៌ជាគ្រឿងនៅបន្តិចបន្តួច បានដល់ ធម៌ជាទីនៅដែលងាយ ។

---

១. ថៃ. វឌ្ឍេន្តិ ។

# សន្និធិកោណកប្បៈ

[៣១៦] ពីរបទថា សាវត្ថិយា[១] សុត្តវិភង្គេ : ទ្រង់ឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងសាវត្ថី មានសេចក្តីថា អំបិលក្នុងក្លាក់នេះ ជារបស់ដែលព្រះមានព្រះភាគទ្រង់ហាមហើយក្នុងសុត្តវិភង្គ យ៉ាងណា ? ពិតមែន ក្នុងសុត្តវិភង្គ(សន្និធិ)នោះ អំបិលក្នុងក្លាក់ជារបស់ដែលព្រះមានព្រះភាគត្រាស់ថា "ដែលហៅថា ខ្លួនទុកដាក់ឱ្យកន្លងរាត្រី បានដល់(ខាទនីយៈ ឬភោជនីយៈ)ដែលខ្លួនទទួលទុកក្នុងថ្ងៃនេះ ហើយឆាន់ក្នុងថ្ងៃខាងក្រោយ"[២] ដូច្នេះ ហើយត្រាស់អាបត្តិហាមទៀតថា "របស់ដែលជាសន្និធិការកៈ ភិក្ខុសម្គាល់ថា មិនមែនជាសន្និធិការកៈ ហើយទំពារស៊ីក្តី បរិភោគក្តី នូវខាទនីយៈឬភោជនីយ ត្រូវបាចិត្តិយ"[៣] ។

ក្នុងសុត្តវិភង្គនោះ អាចារ្យពួកមួយយល់ថា ក៏សិក្ខាបទនេះ ព្រះមានព្រះភាគត្រាស់ហើយថា "យោ បន ភិក្ខុ សន្និធិការកំ ខាទនីយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា បាចិត្តិយំ : ភិក្ខុណាមួយ ទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយវត្ថុ ភោជនីយវត្ថុ ជាសន្និធិការកៈ គឺវត្ថុដែលខ្លួនទុកដាក់ឱ្យកន្លងរាត្រី ត្រូវអាបត្តិបាចិត្តិយ"[៤] តែធម្មតាអំបិល

---

១. ភូមា. សាវត្ថិយំ ។ ២. វិន. បាចិ. ភោជនវគ្គ. ៤. ១៣១/១៣៧ ។ ៣. វិន. បាចិ. ភោជនវគ្គ. ៤, ១៣២/១៣៧ ។ ៤. វិន. បាចិ. ភោជនវគ្គ. ៤. ១៣០/១៣៦ ។

នេះ មិនដល់ភាពជាសន្និធិ ព្រោះជាយាវជីវិក, ភិក្ខុទទួលប្រគេនអាមិស ដែលមិនប្រែ យ៉ាងណា (លាយ)ដោយអំបិលនោះ ហើយឆាន់ជាមួយ អំបិលនោះ, អាមិសនោះ ដែលភិក្ខុទទួលប្រគេនក្នុងថ្ងៃនោះ ប៉ុណ្ណោះ ព្រោះហេតុនោះ អាបត្តិទុក្កដ ព្រោះអំបិលដែលទទួលប្រគេនមុននេះ គប្បីមាន ព្រោះព្រះបាលីថា "ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាវជីវិក ច្រឡំ ដោយវត្ថុជាយាវកាលិក ដែលភិក្ខុទទួលប្រគេនក្នុងថ្ងៃនោះ គួរបានតែក្នុង កាល មិនគួរក្នុងវិកាលទេ"[១] ។

អាចារ្យទាំងនោះ ដែលបរវាទីគប្បីពោលតបថា សូម្បីអាបត្តិទុក្កដ ក៏មិនគប្បីមានតាមមតិរបស់ពួកលោក ព្រោះថា បណ្ដាអំបិលនិងអាមិស ដែលមិនប្រែនេះ អំបិលដែលជាយាវជីវិក មិនបានទទួលប្រគេនក្នុងថ្ងៃ នោះទេ អាមិសដែល មិនប្រែដែលជាយាវកាលិកប៉ុណ្ណោះទទួលប្រគេន ក្នុងថ្ងៃនោះ និងអាមិសនោះ ភិក្ខុមិនបានបរិភោគក្នុងវេលាវិកាលទេ ឬបើ ថា ពួកលោកសម្គាល់អាបត្តិទុក្កដ ព្រោះព្រះបាលីថា វិកាលេ ន កប្បតិ : មិនគួរក្នុងវិកាលទេ ដូច្នេះសោតសូម្បី អាបត្តិបាចិត្តិយ ព្រោះវិកាលភោជន មិនគប្បីមានដល់ភិក្ខុដែលបរិភោគយាវកាលិក ដែល លាយជាមួយនឹងយាវជីវិកក្នុងវេលាវិកាល ។ ព្រោះហេតុនោះ លោកមិន គប្បីកាន់យកត្រឹមតែព្យញ្ជនៈ គប្បីពិចារណាមើលសេចក្ដីផង ។

---

១. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧. ១៤១/៣៧៩ ។

ក្នុងពាក្យថា វិកាលេ កប្បតិ : គួរក្នុងវិកាល នេះ មានសេចក្ដីដូច្នេះ ៖

យាវជីវិកទឹងយាវកាលិក ដែលទទួលប្រគេនក្នុងថ្ងៃនោះ បើថាជារបស់មានរសលាយគ្នាបាន រមែងជារបស់មានគតិដូចជាយាវកាលិកពិត ៗ ព្រោះហេតុនោះ ទុក្កដ ឈ្មោះថា មិនមានក្នុងពាក្យថា កាលេ កប្បតិ វិកាលេ ន កប្បតិ នេះ ព្រោះសិក្ខាបទនេះថា យោ បន ភិក្ខុ វិកាលេ ខាទនីយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា បាចិត្តិយំ : ភិក្ខុណាមួយ ទំពាស៊ីក្ដី បរិភោគក្ដី នូវខាទនីយវត្ថុ ភោជនីយវត្ថុ ក្នុងពេលវិកាល ត្រូវអាបត្តិបាចិត្តិយ”[១] ដូច្នេះជាដើម តែរមែងមានក្នុងយាវជីវិក មានរសលាយចូលជាមួយនឹងយាវកាលិកនេះ ដោយត្រឹមតែពាក្យថា ន កប្បតិ ។

យាវជីវិកដែលទទួលប្រគេនក្នុងថ្ងៃនោះ មានរសលាយនឹងយាវកាលិក មិនគួរក្នុងវិកាលគឺ ជាកាលិកដែលនាំមកនូវបាចិត្តិយ ព្រោះវិកាលភោជន យ៉ាងណាឡើយ យាវជីវិក សូម្បីទទួលប្រគេនក្នុងថ្ងៃនេះ មានរសលាយចូលជាមួយយាវកាលិក ក្នុងថ្ងៃដទៃទៀត មិនគួរ គឺ ជាកាលិកនាំមកនូវបាចិត្តិយ ព្រោះឆាន់របស់ជាសន្និធិ សេចក្ដីនេះក៏ដូច្នោះ ។ ភិក្ខុសូម្បីមិន

១. វិន. បាចិ. ភោជនវគ្គ. ៤. ១២៦/១៣២ ។

ដឹងនូវកាលិកនោះថា នេះជាសន្និធិ(របស់ដែលធ្វើការសន្សំ) រមែងមិនផុត (អំពីអាបត្តិ) ។

ពិតមែន ពាក្យនេះ ដែលព្រះធម្មសង្គាហកាចារ្យពោលហើយថា "របស់ដែលជាសន្និធិការកៈ ភិក្ខុសម្គាល់ថា មិនមែនជាសន្និធិការកៈ ហើយទំពារស៊ីក្តី បរិភោគក្តី នូវខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយ"[១], ព្រោះហេតុនោះ ពាក្យដែលតបថា សាវត្ថិយា សុត្តវិភង្គេ : ទ្រង់ឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងសាវត្ថី នេះ ទើបជាពាក្យតបដែលបរិសុទ្ធិល្អ នៃពាក្យដែលសួរថា កត្ថ បដិក្ខិត្តំ : ចុះព្រះមានព្រះភាគទ្រង់ឃាត់ក្នុងទីណា នេះ ។

## អាវាសកប្បៈ

[៣១៩] ពាក្យថា រាជគហេ ឧបោសថសំយុត្តេ : ទ្រង់ឃាត់ក្នុងឧបោសថសំយុត្ត ក្នុងក្រុងរាជគ្រឹះ នេះ ដែលព្រះសង្គាហកថេរៈពោលសំដៅយកព្រះពុទ្ធវចននេះថា "ន ភិក្ខវេ ឯកស្មឹ អាវាសេ ទ្វេ ឧបោសថាគារានិ សម្មន្និតព្វានិ, យោ សម្មន្នេយ្យ អាបត្តិ ទុក្កដស្ស : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសន្មតរោងឧបោសថពីរ ក្នុងអាវាសមួយ

---

១. វិន. បាចិ. ភោជនវគ្គ. ៤. ១៣២/១៣៧ ។

ទេ ភិក្ខុណាសន្ទត ត្រូវទុក្កដ”[១] ។

ពាក្យថា វិនយាតិសារេ ទុក្កដំ មានសេចក្តីថា ត្រូវអាបត្តិទុក្កដ ព្រោះប្រព្រឹត្តល្មើសក្នុងព្រះវិន័យនេះថា “ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសន្ទតរោងឧបោសថពីរ ក្នុងអាវាសមួយទេ” នេះឯង ។

## អនុមតិកប្បះ

[៣២០] ពាក្យថា ចម្បេយ្យកេ វិនយវត្ថុស្មិំ : ទ្រង់ឃាត់ក្នុងវិនយវត្ថុ ក្នុងចម្បេយ្យក្ខន្ធកៈ នេះ ព្រះសង្គាហកថេរៈ ពោលសំដៅយករឿងវិន័យ ដែលមកហើយក្នុងចម្បេយ្យក្ខន្ធកៈ ចាប់ផ្តើមយ៉ាងនេះថា “អធម្មេន ចេ ភិក្ខវេ វគ្គកម្មំ អកម្មំ ន ច ករណីយំ : ម្នាលភិក្ខុទាំងឡាយ បើកម្មជាពួក ទាំងមិនប្រកបដោយធម៌ ក៏ឈ្មោះថា មិនមែនជាកម្ម ភិក្ខុមិនត្រូវធ្វើទេ”[២] ដូច្នេះ ។

[៣២១] ពាក្យថា ឯកាច្ចោ កប្បតិ : គួរខ្លះ នេះ ព្រះសង្គាហកថេរៈ ពោលសំដៅយកការប្រព្រឹត្តត្រឹមត្រូវតាមធម៌ ។

---

១. វិន. មហា. ឧបោសថក្ខន្ធ. ៦. ១៥៨/៣៥២ ។ ២. វិន. មហា. ចម្បេយ្យក្ខន្ធកៈ ៨. ៨២/១៩៩ ។

## អទសកនិសីទនកប្បៈ

[៣២៤] ពិតមែន ពាក្យថា ឆេទនកំ បាចិត្តិយំ : ត្រូវអាបត្តិបាចិត្តិយ ព្រោះវត្ថុមានកិរិយាកាត់ជាវិនយកម្ម នេះ មកហើយក្នុងសុត្តវិភង្គថា "និសីទនំ នាម សទសំ វុច្ចតិ : ដែលហៅថា សំពត់និសីទៈ គឺសំដៅយកសំពត់និសីទនៈ ដែលមានជាយ"[១] ព្រោះហេតុនោះ ចំពោះជាយប្រមាណមួយចំអាម ដែលភិក្ខុ រមែងបានលើសជាង ២ ចំអាមព្រះសុគតឡើងទៅ ។

ពាក្យថា ត្រូវអាបត្តិបាចិត្តិយ ព្រោះវត្ថុមានកិរិយាកាត់ជាវិន័យកម្ម ដល់ភិក្ខុដែលឱ្យហួសប្រមាណនោះ នេះ រមែងជាពាក្យពិន័យបានតែម្តង ដល់ភិក្ខុដែលធ្វើតាមប្រមាណនោះ វៀរជាយចេញ ។ ព្រោះហេតុនោះ ព្រះសព្វកាមី ដែលព្រះរេវតៈសួរថា "ត្រូវអាបត្តិអ្វី ?" ទើបឆ្លើយថា "ត្រូវបាចិត្តិយ ក្នុងឆេទនកសិក្ខាបទ" អធិប្បាយថា ត្រូវអាបត្តិបាចិត្តិយ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងឆេទនកសិក្ខាបទ ។

ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ ដូច្នេះឯង ។

## សត្តសតិកក្ខន្ធកវណ្ណនា ចប់

១. វិន. បាចិ. រតនវគ្គ. ៤. ៣៨៣/៣៩៤ ។

# គាថាសរូប

ខន្ធកៈ ២២ ប្រភេទ សង្គ្រោះដោយវគ្គ ២ ដែលព្រះមានព្រះភាគទ្រង់ជាអ្នកលះទុក្ខ គឺ បញ្ចក្ខន្ធចេញ ត្រាស់ហើយក្នុងព្រះសាសនាវណ្ណនាខន្ធកៈទាំងនេះ សម្រេចហើយប្រាសចាកអន្តរាយយ៉ាងណា សូម្បីសេចក្តីប្រាថ្នាដែលល្អទាំងឡាយ របស់សត្វមានជីវិត ចូរសម្រេចយ៉ាងនោះផងចុះ ដូច្នេះឯង ។

ក្នុងចុល្លវគ្គនេះ មានខន្ធកៈ ១២ គឺ កម្មក្ខន្ធកៈ បារិវាសិកក្ខន្ធកៈ សមុច្ចយក្ខន្ធកៈ សមថក្ខន្ធកៈ ខុទ្ទកវត្ថុកក្ខន្ធកៈ សេនាសនក្ខន្ធកៈ សង្ឃភេទក្ខន្ធកៈ វត្តក្ខន្ធកៈ បាតិមោក្ខដ្ឋបនក្ខន្ធកៈ ភិក្ខុនីខន្ធកៈ បញ្ចសតិកក្ខន្ធកៈ និងសត្តសតិកក្ខន្ធកៈ ចប់ហើយ ។

# ខន្ធកៈ ២២ គឺ

| ក្នុងមហាវគ្គ មាន ខន្ធកៈ ១០ | ក្នុងចុល្លវគ្គ មានខន្ធកៈ ១២ |
|---|---|
| ១. មហាខន្ធកវណ្ណនា | ១១. កម្មក្ខន្ធកវណ្ណនា |
| ២. ឧបោសថក្ខន្ធកវណ្ណនា | ១២. បារិវាសិកក្ខន្ធកវណ្ណនា |
| ៣. វស្សូបនាយិកក្ខន្ធកវណ្ណនា | ១៣. សមុច្ចយក្ខន្ធកវណ្ណនា |
| ៤. បវារណាខន្ធកវណ្ណនា | ១៤. សមថក្ខន្ធកវណ្ណនា |
| ៥. ចម្មក្ខន្ធកវណ្ណនា | ១៥. ខុទ្ទកវត្ថុខន្ធកវណ្ណនា |
| ៦. ភេសជ្ជក្ខន្ធកវណ្ណនា | ១៦. សេនាសនក្ខន្ធកវណ្ណនា |
| ៧. កឋិនក្ខន្ធកវណ្ណនា | ១៧. សង្ឃភេទក្ខន្ធកវណ្ណនា |
| ៨. ចីវរក្ខន្ធកវណ្ណនា | ១៨. វត្តក្ខន្ធកវណ្ណនា |
| ៩. ចម្បេយ្យក្ខន្ធកវណ្ណនា | ១៩. បាតិមោក្ខដ្ឋបនក្ខន្ធកវណ្ណនា |
| ១០. កោសម្ពិកក្ខន្ធកវណ្ណនា | ២០. ភិក្ខុនីខន្ធកវណ្ណនា |
| | ២១. បញ្ចសតិកក្ខន្ធកវណ្ណនា |
| | ២២. សត្តសតិកក្ខន្ធកវណ្ណនា |

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## ចុល្លវគ្គ

## តតិយភាគ ១១

## ចប់

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## ចុល្លវគ្គ

## ភាគ ៩-១០-១១

ចប់ ដោយបរិបូណ៌



